# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# អង្គុត្តរនិកាយ ចតុក្កនិបាត
# តតិយភាគ
# ៤២



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព. ស. ២៥៥៣

# SUTTANTAPIṬAKA

## AŃGUTTARANIKĀYA

## CATUKKANIPĀTA

## TATIYABHĀGA

## 42

**សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី ជូរ គ្រី**

**សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា**

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ ៥០០ ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធ ចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំៗ តែងតែបានទទួលយកមកតម្កល់ ទុកធ្វើជាគ្រឹះ ដើម្បី ធ្វើការស្រាវ ជ្រាវសិក្សា ស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើម ឡើយគេនាំគ្នា កត់ត្រាលើ ស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈ ក៏មាន លុះចំណេរតមកក៏បាននាំគ្នា បោះពុម្ពលើក្រដាស ចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ន នេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេស ម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើប យើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុប មិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំ ក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេច ព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួល ពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមឌ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

ជូរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

Printed and donated for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
**This book is strictly for free distribution, it is not for sale.**
**សំរាប់ជាធម្មទានតែប៉ុណ្ណោះ**

# សេចក្ដីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរៈ **សម្‌ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលីៈ **តស្‌ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សង្ខិតច្បាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## អង្គុត្តរនិកាយ  ចតុក្កនិបាត

## តតិយភាគ

៤២

ព. ស. ២៤៩៦

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស ចតុក្កនិបាតោ

# តតិយោ ភាគោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បឋមបណ្ណាសកោ

## ភណ្ឌគ្គាមវគ្គោ(១)

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វជ្ជីសុ វិហរតិ ភណ្ឌគ្គាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ចតុន្នំ ភិក្ខវេ ធម្មានំ អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។ កតមេសំ ចតុន្នំ ។ អរិយស្ស ភិក្ខវេ សីលស្ស អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច

១ ម. តណ្ហាយោគវគ្គោ ។

# សុត្តន្តបិដក

# អង្គុត្តរនិកាយ    ចតុក្កនិបាត

# តតិយភាគ

*សូមនមស្ការ ព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។*

## បឋមបណ្ណាសក

## ភណ្ឌគ្គាមវគ្គ

[១] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងភណ្ឌគ្រាម ក្នុងដែនវជ្ជី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅ ត្រេចរង្គាត់ទៅ អស់កាលដ៏វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះ នូវធម៌ ៤ ។ ធម៌ ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅ ត្រេចរង្គាត់ទៅ អស់កាលដ៏វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះ នូវអរិយសីល (សីលដ៏ប្រសើរ) ១*

អរិយស្ស ភិក្ខវេ សមាធិស្ស អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច អរិយាយ ភិក្ខវេ បញ្ញាយ អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច អរិយាយ ភិក្ខវេ វិមុត្តិយា អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។ តយិទំ ភិក្ខវេ អរិយំ សីលំ អនុពុទ្ធំ បដិវិទ្ធំ អរិយោ សមាធិ អនុពុទ្ធោ បដិវិទ្ធោ អរិយា បញ្ញា អនុពុទ្ធា បដិវិទ្ធា អរិយា វិមុត្តិ អនុពុទ្ធា បដិវិទ្ធា ឧច្ឆិន្នា ភវតណ្ហា ខីណា ភវនេត្តិ នត្ថិទានិ បុនព្ភវោតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅ ត្រេចរង្គាត់ទៅ អស់កាលដ៏វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះ នូវអរិយសមាធិ (សមាធិដ៏ប្រសើរ) ១ ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅ ត្រេចរង្គាត់ទៅ អស់កាលដ៏វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះ នូវអរិយបញ្ញា (បញ្ញាដ៏ប្រសើរ) ១ ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅ ត្រេចរង្គាត់ទៅ អស់កាលដ៏វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះ នូវអរិយវិមុត្តិ (វិមុត្តិដ៏ប្រសើរ) ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសីលនោះ តថាគតក្តី អ្នកទាំងឡាយក្តី បានត្រាស់ដឹងហើយ ចាក់ធ្លុះហើយ អរិយសមាធិ ក៏បានត្រាស់ដឹងហើយ ចាក់ធ្លុះហើយ អរិយបញ្ញា ក៏បានត្រាស់ដឹងហើយ ចាក់ធ្លុះហើយ អរិយវិមុត្តិ ក៏បានត្រាស់ដឹងហើយ ចាក់ធ្លុះហើយ សេចក្តីប្រាថ្នាក្នុងភព ក៏បានកាត់ចោលហើយ តណ្ហាជាគ្រឿងនាំទៅក្នុងភពក៏អស់ហើយ ឥឡូវនេះ ការកើតតទៅទៀតមិនមានឡើយ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នូវពាក្យនេះ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់នូវពាក្យនេះរួចហើយ ទើបទ្រង់ត្រាស់នូវព្រះគាថានេះតទៅទៀតថា

៣



សីលសមាធិបញ្ញា ច វិមុត្តិ ច អនុត្តរា
អនុពុទ្ធា ឥមេ ធម្មា គោតមេន យសស្សិនា ។
ឥតិ ពុទ្ធោ អភិញ្ញាយ ធម្មមក្ខាសិ ភិក្ខុនំ
ទុក្ខស្សន្តករោ សត្ថា ចក្ខុមា បរិនិព្វុតោតិ ។

[២] ចតូហិ ភិក្ខវេ ធម្មេហិ អសមន្នាគតោ ឥមស្មា ធម្មវិនយា បបតិតោតិ វុច្ចតិ ។ កតមេហិ ចតូហិ ។ អរិយេន ភិក្ខវេ សីលេន អសមន្នាគតោ ឥមស្មា ធម្មវិនយា បបតិតោតិ វុច្ចតិ អរិយេន ភិក្ខវេ សមាធិនា អសមន្នាគតោ ឥមស្មា ធម្មវិនយា បបតិតោតិ វុច្ចតិ អរិយាយ ភិក្ខវេ បញ្ញាយ អសមន្នាគតោ ឥមស្មា ធម្មវិនយា បបតិតោតិ វុច្ចតិ អរិយាយ ភិក្ខវេ វិមុត្តិយា អសមន្នាគតោ ឥមស្មា ធម្មវិនយា បបតិតោតិ វុច្ចតិ ។

សីល សមាធិ បញ្ញានិងវិមុត្តិ ជាធម៌រកគុណជាតិ
ដទៃប្រសើរជាងគ្មាន ធម៌ទាំងអម្បាលនេះ ព្រះគោតម
មានយស បានត្រាស់ដឹងហើយ ។ ព្រះពុទ្ធ
សម្តែងធម៌ដល់ភិក្ខុទាំងឡាយ ព្រោះត្រាស់ដឹងច្បាស់
ដោយប្រការដូច្នេះ សាស្តាមានចក្ខុ ធ្វើនូវទីបំផុត
នៃទុក្ខហើយ ចេញចាកវាន: គឺតណ្ហាហើយ ។

[២] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានប្រកបដោយធម៌ ៤ យ៉ាង តថាគតហៅថា ឃ្លាតចាកធម្មវិន័យនេះ ។ ធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានប្រកបដោយអរិយសីល តថាគតហៅថា ឃ្លាតចាកធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានប្រកបដោយអរិយសមាធិ តថាគតហៅថា ឃ្លាតចាកធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានប្រកបដោយ អរិយបញ្ញា តថាគតហៅថា ឃ្លាតចាកធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានប្រកបដោយអរិយវិមុត្តិ តថាគតហៅថា ឃ្លាតចាកធម្មវិន័យនេះ ១ ។

ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ អសមន្នា-
គតោ ឥមស្មា ធម្មវិនយា បបតិតោតិ វុច្ចតិ ។
ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឥមស្មា
ធម្មវិនយា អប្បបតិតោតិ វុច្ចតិ ។ កតមេហិ ចតូហិ ។
អរិយេន ភិក្ខវេ សីលេន សមន្នាគតោ ឥមស្មា ធម្ម-
វិនយា អប្បបតិតោតិ វុច្ចតិ អរិយេន ភិក្ខវេ សមាធិនា
សមន្នាគតោ ឥមស្មា ធម្មវិនយា អប្បបតិតោតិ
វុច្ចតិ អរិយាយ ភិក្ខវេ បញ្ញាយ សមន្នាគតោ ឥមស្មា
ធម្មវិនយា អប្បបតិតោតិ វុច្ចតិ អរិយាយ ភិក្ខវេ
វិមុត្តិយា សមន្នាគតោ ឥមស្មា ធម្មវិនយា អប្បបតិតោតិ
វុច្ចតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នា-
គតោ ឥមស្មា ធម្មវិនយា អប្បបតិតោតិ វុច្ចតីតិ ។

ចុតា បតន្តិ បតិតា គិទ្ធា ច បុនរាគតា

ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានប្រកបដោយធម៌ ៤ យ៉ាងនេះឯង តថាគត ហៅថា ឃ្លាតចាកធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង ទើបតថាគតហៅថា មិនឃ្លាតចាកធម្មវិន័យនេះ ។ ធម៌ ៤ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយអរិយសីល តថាគតហៅថា មិនឃ្លាតចាកធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយអរិយសមាធិ តថាគតហៅថា មិនឃ្លាតចាកធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយអរិយបញ្ញា តថាគតហៅថា មិនឃ្លាតចាកធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលប្រកបដោយអរិយវិមុត្តិ តថាគតហៅថា មិនឃ្លាតចាកធម្មវិន័យនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះឯង តថាគតហៅថា មិនឃ្លាតចាកធម្មវិន័យនេះ ។

បុគ្គលដែលឃ្លាតចាក (ធម្មវិន័យ) រមែងធ្លាក់ចុះ បុគ្គល
ដែលធ្លាក់ចុះ ជាអ្នកជាប់ជំពាក់ដោយរាគៈ រមែង
មក (កាន់ជាតិ ជរា ព្យាធិ មរណៈ) ម្ដងទៀត

កតកិច្ចំ វតំ វម្មំ សុខេជាឆ្វាកតំ សុខន្តិ ។

[៣] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កតមេហិ ចតូហិ ។ អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា វណ្ណារហស្ស អវណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា អប្បសាទនីយេ ឋានេ បសាទំ ឧបទំសេតិ អននុវិច្ច អបរិយោគាហេត្វា បសាទនីយេ ឋានេ អប្បសាទំ ឧបទំសេតិ ។

(បើ) កិច្ច (ដោយមគ្គទាំង ៤) បុគ្គលនោះបានធ្វើស្រេចហើយ បានត្រេកអរហើយ ក្នុងគុណជាតដែលបុគ្គលគប្បីត្រេកអរ សេចក្តីសុខបានមក ដោយសេចក្តីសុខ[១] (រមែងមានដល់បុគ្គលនោះ) ។

[៣] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរស ប្រកបដោយធម៌ ៤ យ៉ាង រមែងរក្សាខ្លួនដែលខ្លួនជីកគាស់កម្ចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀល របស់អ្នកប្រាជ្ញទាំងឡាយផង បាននូវបាបដ៏ច្រើនផង ។ ធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលនោះ មិនបានពិចារណា ស្ទាបស្ទង់មើល ហើយពោលសរសើរ បុគ្គលដែលគួរតិះដៀល ១ មិនបានពិចារណា ស្ទាបស្ទង់មើល ហើយពោលតិះដៀលបុគ្គលដែលគួរសរសើរ ១ មិនបានពិចារណា ស្ទាបស្ទង់មើល ហើយកើតសេចក្តីជ្រះថ្លា ក្នុងហេតុដែលមិនគួរជ្រះថ្លា ១ មិនបានពិចារណា ស្ទាបស្ទង់មើល ហើយកើតសេចក្តីមិនជ្រះថ្លា ក្នុងហេតុដែលគួរជ្រះថ្លា ១ ។

---

១ សេចក្តីសុខបានដល់ព្រមហើយ ដោយសេចក្តីសុខ គឺថាសេចក្តីសុខជាទិព្វ សម្រេចមកដោយសេចក្តីសុខជារបស់មនុស្ស សេចក្តីសុខរបស់វិបស្សនា សម្រេចមកដោយសេចក្តីសុខរបស់ឈាន សេចក្តីសុខរបស់មគ្គសម្រេចមក ដោយសេចក្តីសុខរបស់វិបស្សនា សេចក្តីសុខរបស់ផល សម្រេចមកដោយសេចក្តីសុខរបស់មគ្គ សេចក្តីសុខរបស់ព្រះនិព្វាន សម្រេចមកដោយសេចក្តីសុខរបស់ផល ។ អដ្ឋកថា ។

ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ[១] វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ[២] វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតិ ។ កតមេហិ ចតូហិ ។ អនុវិច្ច បរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា វណ្ណារហស្ស វណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា អប្បសាទនីយេ ឋានេ អប្បសាទំ ឧបទំសេតិ អនុវិច្ច បរិយោគាហេត្វា បសាទនីយេ ឋានេ បសាទំ ឧបទំសេតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតីតិ ។

---

១ ឱ. ម. សានុវជ្ជោ ច ។ ២ ឱ. ម. អននុវជ្ជោ ច ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរសប្រកបដោយធម៌ទាំង ៤ យ៉ាងនេះឯង រមែងរក្សាខ្លួនដែលខ្លួនជីកគាស់ កម្ចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង រមែងបាននូវបាបដ៏ច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិត ឈ្លាសវៃ ជាសប្បុរសប្រកបដោយធម៌ ៤ យ៉ាង រមែងរក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនបានកម្ចាត់គុណចោល ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀល របស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។ ធម៌ ៤ តើដូចម្តេចខ្លះ ។ គឺបុគ្គលនោះ ពិចារណា ស្ទាបស្ទង់មើលរួចហើយ ទើបពោលតិះដៀលបុគ្គលដែលគួរតិះដៀល ១ ពិចារណា ស្ទាបស្ទង់មើលរួចហើយ ទើបពោលសរសើរបុគ្គលដែលគួរសរសើរ ១ ពិចារណា ស្ទាបស្ទង់មើលរួចហើយ ទើបកើតសេចក្តីមិនជ្រះថ្លា ក្នុងហេតុដែលមិនគួរជ្រះថ្លា ១ ពិ-ចារណា ស្ទាបស្ទង់មើលរួចហើយ ទើបកើតសេចក្តីជ្រះថ្លា ក្នុងហេតុដែលគួរជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិត ឈ្លាសវៃ ជាសប្បុរសប្រកបដោយធម៌ ៤ យ៉ាងនេះឯងរមែងរក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនបានកម្ចាត់គុណចោល ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។

៧

បឋមបណ្ណាសកេ ភណ្ឌគាមវគ្គោ

យោ និន្ទិយំ បសំសតិ
តំ វា និន្ទតិ យោ បសំសិយោ
វិចិនាតិ មុខេន សោ កលឹ
កលិនា តេន សុខំ ន វិន្ទតិ ។
អប្បមត្តោ អយំ កលិ
យោ អក្ខេសុ ធនបរាជយោ
សព្វស្សាបិ សហាបិ អត្តនា
អយមេវ មហត្តរោ កលិ[១]
យោ សុគតេសុ មនំ បទោសយេ
សតំ សហស្សានំ និរព្វុទានំ
ឆត្តឹសតិ បញ្ច ច អព្វុទានិ[២]
យមរិយំ គរហីយំ និរយំ ឧបេតិ
វាចំ មនញ្ច បណិធាយ បាបកន្តិ ។

១ ឱ. មហន្តតរោ កលិ ។ ២ ឱ. ឆត្តឹស ច បញ្ច ច អព្វុទានិ ។ ម. ឆត្តឹសតិ បញ្ចធា និរព្វុទានិ ។

បឋមបណ្ណាសក ភណ្ឌាគ្គាមវគ្គ

បុគ្គលណាសរសើរបុគ្គល ដែលគួរតិះដៀលក្តី តិះ-ដៀលបុគ្គល ដែលគួរសរសើរក្តី បុគ្គលនោះឈ្មោះថា ជ្រើសរើសយកកំហុស ដោយមាត់ពាក្យ រមែងមិន បានសេចក្តីសុខ ព្រោះកំហុសនោះឡើយ ។ ការចាញ់ ដោយទ្រព្យណា ព្រមទាំងទ្រព្យរបស់ខ្លួនក្តី ទាំង ខ្លួនក្តី ព្រោះល្បែងភ្នាល់ ការចាញ់ដោយទ្រព្យនេះ ជាកំហុស មានប្រមាណតិចទេ បុគ្គលណាញុំាងចិត្ត ឲ្យប្រទូស្ត ក្នុងពួកបុគ្គលដែលស្រុះស្រួលមូលមិត្រគ្នា កំហុសរបស់បុគ្គលនោះឯង ទើបធំជាង បុគ្គលដែល តម្កល់វាចានិងចិត្តដ៏លាមក តិះដៀលព្រះអរិយៈ រមែងទៅកើតក្នុងនរកអស់ ១ សែនកប្ប និង ៣៦ និរព្ទុទៈផង និង ៥ អព្ទុទៈផង ។

[៤] ចតូសុ ភិក្ខវេ មិច្ឆាបដិបជ្ជមានោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កាតមេសុ ចតូសុ ។ មាតរិ ភិក្ខវេ មិច្ឆាបដិបជ្ជមានោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ បិតរិ ភិក្ខវេ មិច្ឆាបដិបជ្ជមានោ ។ បេ ។ តថាគតេ ភិក្ខវេ មិច្ឆាបដិបជ្ជមានោ ។ បេ ។ តថាគតស្សាវកេ ភិក្ខវេ មិច្ឆាបដិបជ្ជមានោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ ឥមេសុ ខោ ភិក្ខវេ ចតូសុ មិច្ឆាបដិបជ្ជមានោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ

[៤] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុសក្នុងបុគ្គល ៤ ពួក ឈ្មោះថា រក្សាខ្លួន ដែលខ្លួនជីកគាស់ កម្ចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀល របស់អ្នកប្រាជ្ញទាំងឡាយផង បាននូវបាបដ៏ច្រើនផង ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស កាលបើប្រតិបត្តិខុសក្នុងមាតា ឈ្មោះថា រក្សាខ្លួន ដែលខ្លួនជីកគាស់ កម្ចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបានបាបដ៏ច្រើនផង ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលពាលប្រតិបត្តិខុសក្នុងបិតា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលប្រតិបត្តិខុសក្នុងព្រះតថាគត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុសក្នុងសាវ័ករបស់ព្រះតថាគត ឈ្មោះថា រក្សាខ្លួនដែលខ្លួនជីកគាស់ កម្ចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀល របស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបាបដ៏ច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុសក្នុងបុគ្គល ៤ ពួកនេះឯងឈ្មោះថា រក្សាខ្លួន ដែលខ្លួនជីកគាស់ កម្ចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង

៩



សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ ចតូសុ ភិក្ខវេ សម្មាបដិបជ្ជមានោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតិ ។ កតមេសុ ចតូសុ ។ មាតរិ ភិក្ខវេ សម្មាបដិបជ្ជមានោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតិ បិតរិ ភិក្ខវេ សម្មាបដិបជ្ជមានោ ។ បេ ។ តថាគតេ ភិក្ខវេ សម្មាបដិបជ្ជមានោ ។ បេ ។ តថាគតស្សាវកេ ភិក្ខវេ សម្មាបដិបជ្ជមានោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតិ ។ ឥមេសុ ខោ ភិក្ខវេ ចតូសុ សម្មាបដិបជ្ជមានោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ

ប្រកបដោយសេចក្ដីតិះដៀល របស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបាបដ៏ច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងបុគ្គល ៤ ពួក ឈ្មោះថា រក្សាខ្លួន ដែលខ្លួនមិនបានជីកគាស់ មិនបានកម្ចាត់គុណាចោល ជាអ្នកមិនមានទោសផង មិនមានសេចក្ដីតិះដៀល របស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។ បុគ្គល ៤ ពួក តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គឺបុគ្គល ជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងមាតា ឈ្មោះថា រក្សាខ្លួន ដែលខ្លួនមិនបានជីកគាស់ មិនបានកម្ចាត់គុណាចោល ជាអ្នកមិនមានទោសផង មិនមានសេចក្ដីតិះដៀល របស់អ្នកប្រាជ្ញទាំង-ឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ម្នាលភិក្ខុទាំងឡាយ កាលប្រតិបត្តិត្រូវក្នុងបិតា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលប្រតិបត្តិត្រូវក្នុងព្រះតថាគត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងសាវ័កនៃព្រះតថាគត ឈ្មោះថារក្សាខ្លួន ដែលខ្លួនមិនបានជីកគាស់ មិនបានកម្ចាត់គុណាចោល ជាអ្នកមិនមានទោសផង មិនមានសេចក្ដីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងបុគ្គល ៤ ពួកនេះឯង

អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតីតិ ។

មាតរិ បិតរិ ចាបិ យោ មិច្ឆាបដិបជ្ជតិ
តថាគតេ ច សម្ពុទ្ធេ អថវា តស្ស សាវកេ
ពហុញ្ច សោ បសវតិ អបុញ្ញំ តាទិសោ នរោ ។
តាយ អធម្មចរិយាយ មាតាបិតូសុ បណ្ឌិតា
ឥធេវ នំ គរហន្តិ បេច្ចាបាយញ្ច គច្ឆតិ ។
មាតរិ បិតរិ ចាបិ យោ សម្មាបដិបជ្ជតិ
តថាគតេ ច សម្ពុទ្ធេ អថវា តស្ស សាវកេ
ពហុញ្ច សោ បសវតិ បុញ្ញំបិ តាទិសោ នរោ[១] ។

១ ឱ. ម. បុញ្ញំ ឯតាទិសោ នរោ ។

ឈ្មោះថា រក្សាខ្លួនដែលខ្លួន មិនបានជីកគាស់ មិនបានកម្ចាត់គុណចោល ជាអ្នកមិនមានទោសផង មិនមានសេចក្ដីតិះដៀល របស់អ្នកប្រាជ្ញទាំង-ឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។

ជនណាប្រតិបត្តិខុសក្នុងមាតា ១ ក្នុងបិតា ១ ក្នុងព្រះតថាគតជាសម្ពុទ្ធ ១ ក្នុងសាវ័ករបស់ព្រះតថាគតនោះ ១ ជនដូច្នោះនោះ រមែងបាននូវបាបដ៏ច្រើន ។ ក្នុងលោកនេះ បណ្ឌិតទាំងឡាយ រមែងតិះដៀលបុគ្គលនោះ លុះបុគ្គលនោះទៅកាន់លោកខាងមុខហើយ រមែងទៅកាន់អបាយទៀតព្រោះការប្រព្រឹត្តមិនត្រូវតាមធម៌នោះ ក្នុងមាតានិងបិតាទាំងឡាយ ។ ជនណាប្រតិបត្តិត្រូវ ក្នុងមាតា ១ ក្នុងបិតា ១ ក្នុងព្រះតថាគតជាសម្ពុទ្ធ ១ ក្នុងសាវ័ករបស់ព្រះតថាគតនោះ ១ ជនដូច្នោះនោះ រមែងបាននូវបុណ្យដ៏ច្រើន ។ ក្នុងលោកនេះ

តាយ ធម្មចរិយាយ[១] មាតាបិតូសុ បណ្ឌិតា
ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតីតិ ។

[៤] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ អនុស្សោតគាមី បុគ្គលោ បដិស្សោតគាមី បុគ្គលោ ឋិតត្តោ បុគ្គលោ តិណ្ណោ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ ។ កតមោ ច ភិក្ខវេ អនុស្សោតគាមី បុគ្គលោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ កាមេ ច បដិសេវតិ បាបញ្ច កម្មំ ករោតិ ។ អយំ វុច្ចតិ ភិក្ខវេ អនុស្សោតគាមី បុគ្គលោ ។ កតមោ ច ភិក្ខវេ បដិស្សោតគាមី បុគ្គលោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ កាមេ ច ន បដិសេវតិ បាបញ្ច កម្មំ ន ករោតិ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន អស្សុមុខោបិ រុទមានោ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ ។ អយំ វុច្ចតិ ភិក្ខវេ បដិស្សោតគាមី បុគ្គលោ ។

១ ឱ. ម. តាយ នំ ធម្មចរិយាយ ។

បណ្ឌិតទាំងឡាយ រមែងសរសើរជននោះ លុះជននោះទៅកាន់លោកខាងមុខហើយ រមែងរីករាយក្នុងស្ថានសួគ៌ ព្រោះការប្រព្រឹត្តត្រូវតាមធម៌នោះ ចំពោះមាតានិងបិតាទាំងឡាយ ។

[៥] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលមានដំណើរទៅបណ្តោយតាមខ្សែទឹក ១ បុគ្គលមានដំណើរទៅច្រាសខ្សែទឹក ១ បុគ្គលមានសភាពជាអ្នកឈរនៅ ១ បុគ្គលបានឆ្លងទៅដល់ត្រើយនាយហើយ ជាព្រាហ្មណ៍ឋិតនៅលើគោក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានដំណើរទៅបណ្តោយតាមខ្សែទឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តែងសេពកាមទាំងឡាយផង តែងធ្វើអំពើអាក្រក់ផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានដំណើរទៅបណ្តោយតាមខ្សែទឹក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានដំណើរទៅច្រាសខ្សែទឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មិនសេពកាមទាំងឡាយផង មិនធ្វើអំពើអាក្រក់ផង តែជាអ្នកប្រកបដោយទុក្ខនិងទោមនស្ស មានមុខទទឹកដោយទឹកភ្នែកទួញយំ ខំប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌ បរិសុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានដំណើរទៅច្រាសខ្សែទឹក ។

កតមោ ច ភិក្ខវេ ឋិតត្តោ បុគ្គលោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថបរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ អយំ វុច្ចតិ ភិក្ខវេ ឋិតត្តោ បុគ្គលោ ។ កតមោ ច ភិក្ខវេ បុគ្គលោ តិណ្ណោ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ តិណ្ណោ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។

យេ កេចិ កាមេសុ អសញ្ញតា ជនា
អវីតរាគា ឥធ កាមភោគិនោ
បុនប្បុនំ ជាតិជរូបគា ហិ តេ[១]
តណ្ហាធិបន្នា អនុសោតគាមិនោ ។

១ ឱ. ម. ជាតិជរូបគាមិ តេ ។

ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានសភាពជាអ្នកឈរនៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាឱបបាតិកៈបរិនិព្វាន ក្នុងលោកនោះ មានការមិនបានត្រឡប់ចាកលោកនោះជាធម្មតា ព្រោះអស់ទៅនៃឱរម្ភាគិយសញ្ញោជនៈទាំង ៥ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានសភាពជាអ្នកឋិតនៅ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលបានឆ្លងទៅដល់ត្រើយនាយ ជាព្រាហ្មណ៍ឋិតនៅលើគោក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯងហើយ សម្រេចសម្រាន្តនៅ ក្នុងបច្ចុប្បន្ននេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលបានឆ្លងទៅដល់ត្រើយនាយហើយ ជាព្រាហ្មណ៍ឋិតនៅលើគោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមាននៅក្នុងលោក ។

ជនទាំងឡាយណានីមួយ មិនសង្រួម ក្នុងកាមទាំងឡាយ មិនបានប្រាសចាករាគៈ ជាអ្នកបរិភោគកាមក្នុងលោកនេះ ជនទាំងនោះឯង តែងចូលទៅកាន់ជាតិនិងជរាជារឿយ ៗ ត្រូវតណ្ហាគ្របសង្កត់ ឈ្មោះថា ជាអ្នកមានដំណើរទៅបណ្តោយតាមខ្សែទឹក ។

តស្មា ហិ ធីរោ ឥធុបដ្ឋិតាសតិ(១)
កាមេ ច បាបេ ច អសេវមានោ
សហាបិ ទុក្ខេន ជហេយ្យ កាមេ
បដិស្សោតគាមីតិ តមាហុ បុគ្គលំ ។
យោ វេ កិលេសានិ បហាយ បញ្ច
បរិបុណ្ណសេក្ខោ អបរិហានធម្មោ
ចេតោវសិប្បត្តោ សមាហិតិន្ទ្រិយោ
ស វេ ឋិតត្តោតិ នរោ បវុច្ចតិ ។
បរោបរា(២) យស្ស សមេច្ច ធម្មា
វិធូបិតា អត្ថគតា ន សន្តិ
ស វេទគូ វុសិតព្រហ្មចរិយោ(៣)
លោកន្តគូ បារគតោតិ វុច្ចតីតិ ។

[៦] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ អប្បស្សុតោ

---

១ ឥធុបដ្ឋិតស្សតី ឥតិ អម្ហាកំ មតិ ។ ។ ២ ឱ. បរោវរា ។ ៣ ម. សចេ មុនិ វុសិត-ព្រហ្មចរិយោ ។

ព្រោះហេតុនោះ បុគ្គលអ្នកមានប្រាជ្ញាក្នុងលោកនេះ ជាអ្នកមានសតិតម្កល់ខ្ជាប់ មិនសេពកាមទាំងឡាយផង មិនធ្វើនូវអំពើអាក្រក់ទាំងឡាយផង តែជាអ្នកប្រកបដោយទុក្ខ លះបង់កាម ទើបអ្នកប្រាជ្ញទាំងឡាយហៅបុគ្គលនោះថា ជាអ្នកមានដំណើរទៅច្រាសខ្សែទឹក ។ ជនណា លះបង់នូវកិលេសទាំង ៥ មានការសិក្សាបរិបូណ៌ហើយ មានសភាពមិនបានសាបសូន្យ ជាអ្នកដល់នូវការស្ទាត់ជំនាញដោយចិត្ត មានឥន្ទ្រិយតម្កល់មាំ ជននោះឯង ហៅថា មានសភាពជាអ្នកឋិតនៅ ។ ធម៌ទាំងឡាយ ដ៏ឧត្តមនិងលាមក ដែលខ្លួនបានត្រាស់ដឹងហើយ បានកម្ចាត់ចោលហើយ ដល់នូវសេចក្តីវិនាសទៅ មិនមាន ដល់បុគ្គលណា បុគ្គលនោះហៅថា អ្នកចេះចប់នូវត្រៃវេទ មានមគ្គ-ព្រហ្មចរិយៈ នៅស្រេចហើយ ដល់នូវទីបំផុតនៃត្រៃលោក ដល់នូវត្រើយហើយ ។

[៦] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលចេះដឹងតិច

សុតេន អនុបបន្នោ អប្បស្សុតោ សុតេន ឧបបន្នោ ពហុស្សុតោ សុតេន អនុបបន្នោ ពហុស្សុតោ សុតេន ឧបបន្នោ ។ កថញ្ច ភិក្ខវេ បុគ្គលោ អប្បស្សុតោ ហោតិ សុតេន អនុបបន្នោ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស អប្បកំ សុតំ ហោតិ សុត្តំ គេយ្យំ វេយ្យា-ករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ

*មិនបានប្រកបដោយការចេះដឹង ១ មានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹង ១ មានសេចក្តីចេះដឹងច្រើន មិនបានប្រកបដោយការចេះដឹង ១ មានសេចក្តីចេះដឹងច្រើន ហើយបានប្រកបដោយការចេះដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានសេចក្តីចេះដឹងតិច មិនបានប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ*[១]

---

១. បាឡីក្នុងឧភតោវិភង្គនិទ្ទេស ខន្ធកៈ បរិវារ សុត្តនិបាត មង្គលសុត្ត រតនសុត្ត នាឡកសុត្ត តុវដសុត្ត និងពុទ្ធវចនៈដទៃដែលមានឈ្មោះថាសុត្ត (សូត្រ) ហៅថា សុត្តៈ ។ សុត្តៈដែលប្រកបដោយគាថាទាំងអស់ហៅថា គេយ្យៈ ។ សគាថវគ្គទាំងអស់ក្នុងសំយុត្តនិកាយដោយឡែកក្តី អភិធម្មបិដកទាំងអស់ក្តីសូត្រដែលមិនមានគាថាក្តីនឹងពុទ្ធវចនៈណាដែលមិនបានសង្គ្រោះដោយអង្គទាំង ៨ គឺដទៃអំពីអង្គទាំង ៨ ក្តី ពុទ្ធវចនៈនោះហៅថា វេយ្យាករណៈ ។ ធម្មបទ ថេរគាថា ថេរីគាថា និងពាក្យជាគាថាសុទ្ធដែលមិនមានឈ្មោះថាសុត្តៈ ក្នុងសុត្តនិបាតហៅថា គាថា ។ សុត្តៈ ៨២ ដែលប្រកបដោយគាថាកើតអំពីសេចក្តីសោមនស្សហៅថាឧទានៈ ។ សុត្តៈ ១១០ ដែលប្រព្រឹត្តទៅដោយន័យថា "វុត្តមិទំ ភគវតា" (ពាក្យនេះព្រះដ៏មានព្រះភាគទ្រង់ពោលហើយ) ដូច្នេះជាដើមហៅថាឥតិវុត្តកៈ ។ ជាតកទាំង ៥៥០ មានអបណ្ណកជាតកជាដើមហៅថា ជាតកៈ ។ សូត្រដែលប្រកបដោយអច្ឆរិយអព្ភូតធម៌ គឺធម៌ជាអស្ចារ្យចម្លែក ដែលប្រព្រឹត្តទៅដោយន័យថា "ចត្តារោ មេ ភិក្ខវេ អច្ឆរិយា អព្ភូតធម្មា អានន្ទេ" ម្នាលភិក្ខុទាំងឡាយ ធម៌ជាអស្ចារ្យចម្លែក ៤ យ៉ាងនេះមានក្នុងអានន្ទ) ដូច្នេះជាដើមហៅថាអព្ភូតធម៌ ។ ចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហាសូត្រនិងសង្ខារភាជនិយមហាបុណ្ណមសូត្រជាដើម និងសូត្រទាំងពួងដែលកើតឡើងដោយបុគ្គលណាមួយបានចំពោះ នូវសេចក្តីរីករាយ ត្រេកអរ ហើយចូលទៅក្រាបទូលសួរហៅថា វេទល្លៈ ។

សោ តស្ស អប្បកស្ស សុតស្ស ន អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ អប្បស្សុតោ ហោតិ សុតេន អនុបបន្នោ ។ កថញ្ច ភិក្ខវេ បុគ្គលោ អប្បស្សុតោ ហោតិ សុតេន ឧបបន្នោ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស អប្បកំ សុតំ ហោតិ សុត្តំ គេយ្យំ ។ បេ ។ វេទល្លំ សោ តស្ស អប្បកស្ស សុតស្ស អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ អប្បស្សុតោ ហោតិ សុតេន ឧបបន្នោ ។ កថញ្ច ភិក្ខវេ បុគ្គលោ ពហុស្សុតោ ហោតិ សុតេន អនុបបន្នោ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស ពហុំ សុតំ ហោតិ សុត្តំ គេយ្យំ ។ បេ ។ វេទល្លំ សោ តស្ស ពហុកស្ស សុតស្ស ន អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្ប-ដិបន្នោ ហោតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ពហុស្សុតោ ហោតិ សុតេន អនុបបន្នោ ។

បុគ្គលនោះមិនចេះអដ្ឋកថា មិនចេះបាលីនៃពុទ្ធវចនៈ មានប្រមាណតិចនោះ មិនប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌[១] ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងឈ្មោះថា បុគ្គលមានសេចក្តី ចេះដឹងតិចមិនបានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ ។ បេ ។ វេទល្លៈ មានតិចដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ បុគ្គលនោះ ចេះអដ្ឋកថា ចេះបាលីនៃពុទ្ធវចនៈមានប្រមាណតិចនោះ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌[២] ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងឈ្មោះថា បុគ្គលមានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានសេចក្តីចេះដឹងច្រើន តែមិនបានប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈគឺ សុត្តៈ គេយ្យៈ ។ បេ ។ វេទល្លៈ មានច្រើនដល់បុគ្គលពួកខ្លះក្នុងលោកនេះ បុគ្គលនោះ មិនចេះអដ្ឋកថា មិនចេះបាលីនៃពុទ្ធវចនៈមានប្រមាណច្រើននោះ មិនប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌[៣] ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងឈ្មោះថា បុគ្គលមានសេចក្តីចេះដឹងច្រើន តែមិនបានប្រកបដោយការចេះដឹង ។

---

១ បានដល់បុថុជ្ជនមានសេចក្តីចេះដឹងតិចហើយជាអ្នកទ្រុស្តសីល ។ អដ្ឋកថា ។

២ បានដល់ព្រះខីណាស្រពដែលមានសេចក្តីចេះដឹងតិច ។ អដ្ឋកថា ។

៣ បានដល់បុថុជ្ជនមានសេចក្តីចេះដឹងច្រើន ជាអ្នកទ្រុស្តសីល ។

កថញ្ច ភិក្ខវេ បុគ្គលោ ពហុស្សុតោ ហោតិ សុតេន ឧបបន្នោ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស ពហុំ សុតំ ហោតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ សោ តស្ស ពហុកស្ស សុតស្ស អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ពហុស្សុតោ ហោតិ សុតេន ឧបបន្នោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

អប្បស្សុតោបិ ចេ ហោតិ សីលេសុ អសមាហិតោ
ឧភយេន តំ គរហន្តិ សីលតោ ច សុតេន ច ។
អប្បស្សុតោបិ ចេ ហោតិ សីលេសុ សុសមាហិតោ
សីលតោ នំ បសំសន្តិ ជាស្ស សម្បជ្ជតេ សុតំ ។

មានតិចដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គល មានសេចក្តីចេះដឹងច្រើន ប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ មានច្រើនដល់បុគ្គលពួកខ្លះក្នុងលោកនេះ បុគ្គលនោះចេះអដ្ឋកថា ចេះបាលីនៃពុទ្ធវចនៈមានប្រមាណច្រើននោះ ហើយប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌[១] ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា បុគ្គលមានសេចក្តីចេះដឹងច្រើន ប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមាននៅក្នុងលោក ។

បើបុគ្គលមានសេចក្តីចេះដឹងតិច ទាំងមិនបានឋិតនៅក្នុងសីលទាំងឡាយ អ្នកប្រាជ្ញទាំងឡាយ រមែងតិះដៀលបុគ្គលនោះ ដោយហេតុទាំង ២ គឺសីល ១ សេចក្តីចេះដឹង ១ ។ បើបុគ្គលមានសេចក្តីចេះដឹងតិច តែឋិតនៅខ្ជាប់ខ្ជួនក្នុងសីលទាំងឡាយ អ្នកប្រាជ្ញទាំង-ឡាយ តែងសរសើរបុគ្គលនោះ តែដោយសីល ប៉ុន្តែសេចក្តីចេះដឹង មិនសម្រេចដល់បុគ្គលនោះទេ ។

១ បានដល់ព្រះខីណាស្រពដែលមានសេចក្តីចេះដឹងច្រើន ។ អដ្ឋកថា ។

ពហុស្សុតោបិ ចេ ហោតិ សីលេសុ អសមាហិតោ

សីលតោ នំ គរហន្តិ តស្ស សម្បជ្ជតេ សុតំ ។

ពហុស្សុតោបិ ចេ ហោតិ សីលេសុ សុសមាហិតោ

ឧភយេន នំ បសំសន្តិ សីលតោ ច សុតេន ច ។

ពហុស្សុតំ ធម្មធរំ សប្បញ្ញំ ពុទ្ធសាវកំ

នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ

ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោ ។

[៧] ចត្តារោមេ ភិក្ខវេ វិយត្តា វិនីតា វិសារទា

ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សង្ឃំ

បើបុគ្គលមានសេចក្តីចេះដឹងច្រើន តែមិនឋិតនៅក្នុងសីលទាំងឡាយទេ អ្នកប្រាជ្ញទាំងឡាយរមែងតិះដៀលបុគ្គលនោះដោយសីល ប៉ុន្តែសេចក្តីចេះដឹងតែងសម្រេចដល់បុគ្គលនោះ ។ បើបុគ្គលមានសេចក្តីចេះដឹងច្រើនទាំងតាំងនៅខ្ជាប់ខ្ជួន ក្នុងសីលទាំងឡាយ អ្នកប្រាជ្ញទាំងឡាយ រមែងសរសើរបុគ្គលនោះ ដោយហេតុទាំង ២ គឺសីល ១ សេចក្តីចេះដឹង ១ ។ អ្នកណាគួរនិន្ទាបុគ្គលអ្នកមានសេចក្តីចេះដឹងច្រើន ទ្រទ្រង់នូវធម៌ប្រកបដោយបញ្ញា ជាពុទ្ធសាវ័កនោះ ដែលដូចជាដុំនៃមាសជម្ពូនទបាន ទេវតានិងមនុស្សទាំងឡាយរមែងសរសើរបុគ្គលនោះ សូម្បីព្រហ្មក៏សរសើរដែរ ។

[៧] ម្នាលភិក្ខុទាំងឡាយ បុគ្គលឆ្លៀវឆ្លាស វាងវៃ ក្លៀវក្លា ជាអ្នកចេះដឹងច្រើន ទ្រទ្រង់នូវធម៌ ប្រតិបត្តិធម៌ ដ៏សមគួរដល់ឋានៈនៃបុគ្គល

សោភេន្តិ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ វិយត្តោ វិនីតោ វិសារទោ ពហុស្សុតោ ធម្មធរោ ធម្មានុធម្មប្បដិបន្នោ សង្ឃំ សោភេតិ ។ ភិក្ខុនី ភិក្ខវេ ។ បេ ។ ឧបាសកោ ភិក្ខវេ ។ បេ ។ ឧបាសិកា ភិក្ខវេ វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សង្ឃំ សោភេតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សង្ឃំ សោភេន្តីតិ ។

យោ ហោតិ ព្យត្តោ ច វិសារទោ ច
ពហុស្សុតោ ធម្មធរោ ច ហោតិ
ធម្មស្ស ហោតិ អនុធម្មចារី
ស តាទិសោ វុច្ចតិ សង្ឃសោភណោ ។
ភិក្ខុ ច សីលសម្បន្នោ ភិក្ខុនី ច ពហុស្សុតា

៤ ពួកនេះរមែងញុំាងសង្ឃឲ្យរុងរឿង ។ បុគ្គល ៤ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឆ្លៀវឆ្លាស វាងវៃ ក្លៀវក្លា ជាអ្នកចេះដឹងច្រើន ទ្រទ្រង់នូវធម៌ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ រមែងញុំាងសង្ឃឲ្យរុងរឿង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី ។ បេ ។ ម្នាលភិក្ខុទាំង-ឡាយ ឧបាសក ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកា ឆ្លៀវឆ្លាស វាងវៃ ក្លៀវក្លា ជាអ្នកចេះដឹងច្រើន ទ្រទ្រង់នូវធម៌ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ រមែងញុំាងសង្ឃឲ្យរុងរឿង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឆ្លៀវឆ្លាស វាងវៃ ក្លៀវក្លា ជាអ្នកចេះដឹងច្រើន ទ្រទ្រង់នូវធម៌ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ទាំង ៤ ពួកនេះឯង រមែងញុំាងសង្ឃឲ្យរុងរឿង ។

បុគ្គលណា ឆ្លៀវឆ្លាស ក្លៀវក្លា ជាអ្នកចេះដឹងច្រើន
ទ្រទ្រង់នូវធម៌ ជាអ្នកប្រព្រឹត្តធម៌ ដ៏សមគួរដល់ធម៌
បុគ្គលប្រាកដដូច្នោះនោះ ឈ្មោះថាញុំាងសង្ឃឲ្យ
រុងរឿង ។ គឺភិក្ខុបរិបូណ៌ ដោយសីល ១ ភិក្ខុនី
មានសេចក្តីចេះដឹងច្រើន ១ ឧបាសកមានសទ្ធា ១

ឧបាសកោ ច យោ សទ្ធោ យា ច សទ្ធា ឧបាសិកា ឯតេ ខោ សង្ឃំ សោភេន្តិ ឯតេ ហិ សង្ឃសោភនាតិ ។

[៨] ចត្តារីមានិ ភិក្ខវេ តថាគតស្ស វេសារជ្ជានិ យេហិ វេសារជ្ជេហិ សមន្នាគតោ តថាគតោ អាសភ-ណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្ម-ចក្កំ បវត្តេតិ ។ កតមានិ ចត្តារិ ។ សម្មាសម្ពុទ្ធស្ស តេ បដិជានតោ ឥមេ ធម្មា អនភិសម្ពុទ្ធាតិ តត្រ វត មំ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ សហធម្មេន បដិ-ចោទេស្សតីតិ និមិត្តមេតំ ភិក្ខវេ ន សមនុបស្សាមិ ឯតំបហំ ភិក្ខវេ និមិត្តំ អសមនុបស្សន្តោ ខេមប្បត្តោ អភយប្បត្តោ វេសារជ្ជប្បត្តោ វិហរាមិ ។

ឧបាសិកាមានសទ្ធា ១ បុគ្គលទាំងអម្បាលនេះឯង រមែងញ៉ាំងសង្ឃឲ្យរុងរឿង ព្រោះថា បុគ្គលទាំងនេះ ជាអ្នកធ្វើសង្ឃឲ្យរុងរឿង ។

[៨] ម្នាលភិក្ខុទាំងឡាយ តថាគត ប្រកបដោយវេសារជ្ជញ្ញាណ (ប្រាជ្ញាក្លៀវក្លា) បែបណា តែងប្តេជ្ញានូវទីដ៏ប្រសើរ បន្លឺនូវសីហនាទ ក្នុងពួកបរិសទ្យ ញ៉ាំងព្រហ្មចក្រ (ចក្រគឺធម៌ដ៏ប្រសើរ) ឲ្យប្រព្រឹត្តទៅបាន វេសារជ្ជញ្ញាណនេះរបស់តថាគត មាន ៤ យ៉ាង ។ វេសារជ្ជញ្ញាណ ៤ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនូវនិមិត្ត គឺធម៌ឬបុគ្គលនុ៎ះថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយ ក្នុងលោកក្តី នឹងចោទតថាគត ដោយពាក្យប្រកបដោយធម៌ ក្នុងហេតុនោះថា លោកប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងឯងដោយប្រពៃ ប៉ុន្តែធម៌ទាំងអម្បាលនេះ លោកមិនបានត្រាស់ដឹងទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគត មិនឃើញ នូវនិមិត្តនុ៎ះឯង ទើបដល់នូវសេចក្តីក្សេម ដល់នូវភាពជាអ្នកមិនមានភ័យ ដល់នូវភាពជាអ្នកក្លៀវក្លា ១ ។

ខីណាសវស្ស តេ បដិជានតោ ឥមេ អាសវា អបរិក្ខី-
ណាតិ តត្រ វត មំ សមណោ វា ព្រាហ្មណោ វា ទេវោ
វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ
សហធម្មេន បដិចោទេស្សតីតិ និមិត្តមេតំ ភិក្ខវេ
ន សមនុបស្សាមិ ឯតំបហំ ភិក្ខវេ និមិត្តំ អសមនុ-
បស្សន្តោ[១] ខេមប្បត្តោ អភយប្បត្តោ វេសារជ្ជប្បត្តោ
វិហរាមិ ។ យេ ខោ បន តេ អន្តរាយិកា
ធម្មា វុត្តា តេ បដិសេវតោ នាលំ អន្តរាយាយាតិ
តត្រ វត មំ សមណោ វា ព្រាហ្មណោ វា ទេវោ វា
មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ សហធម្មេន
បដិចោទេស្សតីតិ និមិត្តមេតំ ភិក្ខវេ ន សមនុបស្សាមិ
ឯតំបហំ ភិក្ខវេ និមិត្តំ អសមនុបស្សន្តោ ខេម-
ប្បត្តោ អភយប្បត្តោ វេសារជ្ជប្បត្តោ វិហរាមិ ។

១ ឱ. សមនុបស្សន្តោ ។

ម្នាលភិក្ខុទាំងឡាយ តថាគត មិនឃើញនូវនិមិត្តគឺធម៌ ឬ បុគ្គលនុ៎ះថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយក្នុងលោកក្តី នឹងចោទតថាគត ដោយពាក្យប្រកបដោយធម៌ ក្នុងហេតុនោះថា លោកប្តេជ្ញាខ្លួនថាជាអ្នកអស់អាសវៈហើយ ប៉ុន្តែអាសវៈទាំងអម្បាលនេះមិនទាន់អស់ទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគត មិនឃើញនូវនិមិត្តនុ៎ះឯង ទើបដល់នូវសេចក្តីក្សេម ដល់នូវភាពជាអ្នកមិនមានភ័យ ដល់នូវភាពជាអ្នកក្លៀវក្លា ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនូវនិមិត្តគឺធម៌ ឬ បុគ្គលនុ៎ះថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយ ក្នុងលោកក្តី នឹងចោទតថាគត ដោយពាក្យប្រកបដោយធម៌ ក្នុងហេតុនោះថា ធម៌ទាំងឡាយណា ដែលលោកពោលថា ធម៌ជាគ្រឿងធ្វើនូវអន្តរាយ ធម៌ទាំងអម្បាលនោះមិនអាចធ្វើអន្តរាយ ដល់បុគ្គលអ្នកសេពបានទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគត មិនឃើញនូវនិមិត្តនុ៎ះឯង ទើបដល់នូវសេចក្តីក្សេម ដល់នូវភាពជាអ្នកមិនមានភ័យ ដល់នូវភាពជាអ្នកក្លៀវក្លា ១ ។

២១



យស្ស ខោ បន តេ អត្ថាយ ធម្មោ ទេសិតោ សោ ន និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយាតិ តត្រ វត មំ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ សហធម្មេន បដិ-ចោទេស្សតីតិ និមិត្តមេតំ ភិក្ខវេ ន សមនុបស្សាមិ ឯតំបហំ ភិក្ខវេ និមិត្តំ អសមនុបស្សន្តោ ខេមប្បត្តោ អភយប្បត្តោ វេសារជ្ជប្បត្តោ វិហរាមិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ តថាគតស្ស វេសារជ្ជានិ យេហិ វេសា-រជ្ជេហិ សមន្នាគតោ តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតីតិ ។

យេ កេចិមេ វាទបថា បុថុស្សិតា
យន្និស្សិតា សមណព្រាហ្មណា ច
តថាគតំ បត្វាន តេ ភវន្តិ
វិសារទំ វាទបថាតិវត្តំ[១]

១ ឱ. ម. វាទបថាតិ វុត្តំ ។

ម្នាលភិក្ខុទាំងឡាយ តថាគត មិនឃើញនូវនិមិត្ត គឺធម៌ ឬ បុគ្គលទុំះថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយក្នុងលោកក្តី នឹងចោទតថាគត ដោយពាក្យប្រកបដោយធម៌ក្នុងហេតុនោះថា ធម៌ដែលលោកសម្តែងហើយ ដើម្បីប្រយោជន៍ដល់គុណវិសេសណា គុណវិសេសនោះ មិនអាចស្រោចស្រង់ ដើម្បីឲ្យអស់ទៅនៃទុក្ខដោយប្រពៃដល់អ្នកធ្វើតាមនូវធម៌នោះទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតមិនឃើញនូវនិមិត្តទុំះឯង ទើបដល់នូវសេចក្តីក្សេម ដល់នូវភាពជាអ្នកមិនមានភ័យ ដល់នូវភាពជាអ្នកក្លៀវក្លា ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រកបដោយវេសារជ្ជញ្ញាណណា តែងប្តេជ្ញានូវទីដ៏ប្រសើរ បន្លឺនូវសីហនាទ ក្នុងពួកបរិសទ្យ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅបាន វេសារជ្ជញ្ញាណនោះរបស់តថាគត មាន ៤ យ៉ាងនេះឯង ។

គន្លងនៃពាក្យណានីមួយដ៏ច្រើន ដែលគេរៀបរៀង
ទុកហើយក្តី ពួកសមណព្រាហ្មណ៍ ដែលអាស្រ័យនូវ
គន្លងនៃពាក្យណាក្តី គន្លងពាក្យទាំងនោះ លុះមកដល់
ព្រះតថាគតដែលជាអ្នកមានសេចក្តីក្លៀវក្លា គ្របសង្កត់
នូវគន្លងនៃពាក្យ ហើយក៏រមែងវិនាសសាបសូន្យទៅ

យោ ធម្មចក្កំ អភិភុយ្យ កេវលំ
បវត្តយី[១] សព្វភូតានុកម្បី
តំ តាទិសំ ទេវមនុស្សសេដ្ឋំ[២]
សត្តា នមស្សន្តិ ភវស្ស បារគុន្តិ ។

[៩] ចត្តារោមេ ភិក្ខវេ តណ្ហុប្បាទា យត្ថ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ។ កតមេ ចត្តារោ ។ ចីវរហេតុ វា ភិក្ខវេ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ បិណ្ឌបាតហេតុ វា ភិក្ខវេ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ សេនាសនហេតុ វា ភិក្ខវេ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឥតិភវាភវហេតុ វា ភិក្ខវេ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ តណ្ហុប្បាទា យត្ថ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតីតិ ។

---

១ ឱ. កេវលិម្បវត្តយី ។ ម. កេវលោ បវត្តយី ។ ២ ម. ទេវមនុស្សានំ សេដ្ឋំ ។

ព្រះតថាគតណា គ្របសង្កត់នូវធម៌ទាំងអស់ មានសេចក្តីអនុគ្រោះដល់សត្វទាំងអស់ ហើយញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ពួកសត្វតែងថ្វាយបង្គំ នូវព្រះតថាគតប្រាកដដូច្នោះនោះ ព្រះអង្គប្រសើរជាងទេវតានិងមនុស្ស ទ្រង់ឆ្លងដល់ត្រើយនៃភព ។

[៩] ម្នាលភិក្ខុទាំងឡាយ តណ្ហា កាលកើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះបច្ច័យណា បច្ច័យនោះឈ្មោះថា ជាទីកើតឡើងនៃតណ្ហាមាន ៤ យ៉ាងនេះ ។ បច្ច័យជាទីកើតឡើងនៃតណ្ហា ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើង ព្រោះហេតុចីវរ ១ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះហេតុបិណ្ឌបាត ១ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើង ព្រោះហេតុសេនាសនៈ ១ ម្នាលភិក្ខុទាំងឡាយ តណ្ហា កាលកើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះហេតុភេសជ្ជៈឧត្តមនិងថ្ងៃថ្លាដូច្នេះ ៗ ១ ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះបច្ច័យណា បច្ច័យនោះឈ្មោះថាជាទីកើតឡើងនៃតណ្ហាមាន ៤ យ៉ាងប៉ុណ្ណេះ ។

តណ្ហាទុតិយោ បុរិសោ ទីឃមទ្ធានសំសរំ
ឥត្ថភាវញ្ញថាភាវំ សំសារំ នាតិវត្តតិ ។
ឯតមាទីនវំ ញត្វា(១) តណ្ហំ ទុក្ខស្ស សម្ភវំ
វីតតណ្ហោ អនាទានោ សតោ ភិក្ខុ បរិព្វជេតិ ។

[១០] ចត្តារោមេ ភិក្ខវេ យោគា ។ កតមេ ចត្តារោ ។ កាមយោគោ ភវយោគោ ទិដ្ឋិយោគោ អវិជ្ជាយោគោ ។ កតមោ ច ភិក្ខវេ កាមយោគោ ។ ឥធ ភិក្ខវេ ឯកច្ចោ កាមានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ តស្ស កាមានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានតោ យោ កាមេសុ កាមរាគោ កាមនន្ទិ កាមស្នេហោ កាមមុច្ឆា កាមបិបាសា

---

១ ម. ឯវមាទីនវំ ញត្វា ។

*បុរសមានតណ្ហា ជាគម្រប់ពីរអន្ទោលទៅ (ក្នុងសង្សារវដ្ត) អស់កាលដ៏វែង រមែងមិនប្រព្រឹត្តកន្លងនូវសង្សារគឺខន្ធ ធាតុ អាយតនៈ ដែលមានក្នុងអត្តភាពនេះនិងខាងមុខ ។ លុះភិក្ខុដឹងច្បាស់នូវតណ្ហានេះថាជាទោស ជាដែនកើតព្រមនៃទុក្ខ ហើយជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីប្រកាន់មាំ មានស្មារតីនៅគ្រប់ឥរិយាបថ ។*

[១០] *ម្នាលភិក្ខុទាំងឡាយ យោគៈ (កិលេសជាគ្រឿងប្រកបសត្វទុកក្នុងវដ្តៈ) នេះមាន ៤ យ៉ាង ។ យោគៈ ៤ យ៉ាង តើដូចម្តេច ។ គឺកាមយោគៈ ១ ភវយោគៈ ១ ទិដ្ឋិយោគៈ ១ អវិជ្ជាយោគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ កាមយោគៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវកាមទាំងឡាយ កាលបើបុគ្គលនោះ មិនដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវកាមទាំងឡាយ ក៏កើតមានតម្រេក ក្នុងកាម សេចក្តីរីករាយ ក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីជប់នៅក្នុងកាម សេចក្តីស្រេកឃ្លានក្នុងកាម*

កាមបរិឡាហោ កាមជ្ឈោសានំ កាមតណ្ហា សានុសេតិ អយំ វុច្ចតិ ភិក្ខវេ កាមយោគោ ។ ឥតិ កាមយោគោ ។ ភវយោគោ ច កថំ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ ភវានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ តស្ស ភវានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានតោ យោ ភវេសុ ភវរាគោ ភវនន្ទិ ភវស្នេហោ ភវមុច្ឆា ភវបិបាសា ភវបរិឡាហោ ភវជ្ឈោសានំ ភវតណ្ហា សានុសេតិ អយំ វុច្ចតិ ភិក្ខវេ ភវយោគោ ។ ឥតិ កាមយោគោ ភវ-យោគោ ។ ទិដ្ឋិយោគោ ច កថំ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ ទិដ្ឋីនំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ

សេចក្តីអន្ទះអន្ទែងព្រោះកាម សេចក្តីជ្រុលជ្រប់ក្នុងកាម សេចក្តីប្រាថ្នាក្នុងកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កាមយោគៈ[១] ។ កាមយោគៈដូច្នេះឯង ។ ភវយោគៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវភពទាំងឡាយ កាលបើបុគ្គលនោះ មិនដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ផង នូវភពទាំងឡាយ ក៏កើតមានតម្រេកក្នុងភព សេចក្តីរីករាយក្នុងភព សេចក្តីស្នេហាក្នុងភព សេចក្តីជប់នៅក្នុងភព សេចក្តីស្រេកឃ្លានក្នុងភព សេចក្តីអន្ទះអន្ទែងព្រោះភព សេចក្តីជ្រុលជ្រប់ក្នុងភព សេចក្តីប្រាថ្នាក្នុងភព ក្នុងភពទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះហៅថាភវយោគៈ[២] ។ កាមយោគៈនិងភវយោគៈដូច្នេះឯង ។ ទិដ្ឋិយោគៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មិនដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវទិដ្ឋិទាំងឡាយ

---

១. បានដល់សេចក្តីត្រេកត្រអាលប្រកបដោយកាមគុណទាំង ៥ ។ អដ្ឋកថា ។

២. បានដល់សេចក្តីប្រាថ្នានិងសេចក្តីត្រេកអរក្នុងរូបភពនិងអរូបភាព ។

តស្ស ទិដ្ឋីនំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានតោ យោ ទិដ្ឋីសុ ទិដ្ឋិរាគោ ទិដ្ឋិនន្ទិ ទិដ្ឋិស្នេហោ ទិដ្ឋិមុច្ឆា ទិដ្ឋិបិបាសា ទិដ្ឋិបរិឡាហោ ទិដ្ឋិជ្ឈោសានំ ទិដ្ឋិតណ្ហា សានុសេតិ អយំ វុច្ចតិ ភិក្ខវេ ទិដ្ឋិយោគោ ។ ឥតិ កាមយោគោ ភវយោគោ ទិដ្ឋិយោគោ ។ អវិជ្ជាយោគោ ច កថំ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ តស្ស ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានតោ យា ឆសុ ផស្សាយតនេសុ អវិជ្ជា អញ្ញាណំ សានុសេតិ អយំ វុច្ចតិ ភិក្ខវេ អវិជ្ជាយោគោ ។ ឥតិ កាមយោគោ ភវយោគោ ទិដ្ឋិយោគោ អវិជ្ជាយោគោ ។

កាលបើបុគ្គលនោះ មិនដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវទិដ្ឋិទាំងឡាយ ក៏កើតមាន តម្រេកក្នុងទិដ្ឋិ សេចក្តីរីករាយក្នុងទិដ្ឋិ សេចក្តីស្នេហាក្នុងទិដ្ឋិ សេចក្តីជប់នៅក្នុងទិដ្ឋិ សេចក្តីស្រេកឃ្លានក្នុងទិដ្ឋិ សេចក្តីអន្ទះអន្ទែងព្រោះទិដ្ឋិ សេចក្តីជ្រុលជ្រប់ក្នុងទិដ្ឋិ សេចក្តីប្រាថ្នាក្នុងទិដ្ឋិក្នុងទិដ្ឋិទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះហៅថាទិដ្ឋិយោគៈ[១] ។ កាមយោគៈ ភវយោគៈនិងទិដ្ឋិយោគៈដូច្នេះឯង ។ អវិជ្ជាយោគៈតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវផស្សាយតនៈទាំង ៦ កាលបើបុគ្គលនោះ មិនដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវផស្សាយតនៈទាំង ៦ ក៏កើតមានសេចក្តីល្ងង់មិនដឹងក្នុងផស្សាយតនៈទាំង ៦ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អវិជ្ជាយោគៈ ។ កាមយោគៈ ភវយោគៈ ទិដ្ឋិយោគៈនិងអវិជ្ជាយោគៈដូច្នេះឯង ។

១ បានដល់តម្រេកប្រកបដោយសស្សតទិដ្ឋិ ៦២ ។ អដ្ឋកថា ។

សម្បយុត្តោ បាបកេហិ អកុសលេហិ ធម្មេហិ សំកិលេសិកេហិ បោនោព្ភវិកេហិ សទរេហិ ទុក្ខវិបាកេហិ អាយតឹជាតិជរាមរណិកេហិ តស្មា អយោគក្ខេមីតិ វុច្ចតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ យោគា ។ ចត្តារោមេ ភិក្ខវេ វិសំយោគា ។ កតមេ ចត្តារោ ។ កាមយោគវិសំយោគោ ភវយោគវិសំយោគោ ទិដ្ឋិយោគវិសំយោគោ អវិជ្ជាយោគវិសំយោគោ ។ កតមោ ច ភិក្ខវេ កាមយោគវិសំយោគោ ។ ឥធ ភិក្ខវេ ឯកច្ចោ កាមានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ តស្ស កាមានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានតោ យោ កាមេសុ កាមរាគោ កាមនន្ទិ កាមស្នេហោ កាមមុច្ឆា កាមបិបាសា កាមបរិឡាហោ កាមជ្ឈោសានំ កាមតណ្ហា

បុគ្គលប្រកបដោយអកុសលធម៌ដ៏លាមក ជាគ្រឿងសៅហ្មង ជាគ្រឿងនាំឲ្យកើត ក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ជាគ្រឿងនាំឲ្យកើតជាតិជរាមរណៈតទៅ ព្រោះហេតុនោះ (បុគ្គលនោះ) ហៅថា ជាអ្នកមិនមានសេចក្តីក្សេមចាកយោគៈទេ ។ ម្នាលភិក្ខុទាំងឡាយ យោគៈមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ការមិនប្រកបដោយយោគៈនេះមាន ៤ យ៉ាង ។ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺការមិនប្រកបដោយកាមយោគៈ ១ ការមិនប្រកបដោយភវយោគៈ ១ ការមិនប្រកបដោយទិដ្ឋិយោគៈ ១ ការមិនប្រកបដោយអវិជ្ជា-យោគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះការមិនប្រកបដោយកាមយោគៈតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវកាមទាំងឡាយ កាលបើបុគ្គលនោះដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវកាមទាំងឡាយ ក៏មិនកើតមានតម្រេកក្នុងកាម សេចក្តីរីករាយក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីជប់នៅក្នុងកាម សេចក្តីស្រេកឃ្លានក្នុងកាម សេចក្តីអន្ទះអន្ទែងព្រោះកាម សេចក្តីជ្រុលជ្រប់ក្នុងកាម សេចក្តីប្រាថ្នាក្នុងកាម ក្នុងកាមទាំងឡាយ

សា នានុសេតិ អយំ វុច្ចតិ ភិក្ខវេ កាមយោគវិសំយោគោ ។ ឥតិ កាមយោគវិសំយោគោ ។ ភវយោគវិសំយោគោ ច កថំ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ ភវានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ តស្ស ភវានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានតោ យោ ភវេសុ ភវរាគោ ភវនន្ទិ ភវស្នេហោ ភវមុច្ឆា ភវបិបាសា ភវបរិឡាហោ ភវជ្ឈោសានំ ភវតណ្ហា សា នានុសេតិ អយំ វុច្ចតិ ភិក្ខវេ ភវយោគវិសំយោគោ ។ ឥតិ កាមយោគវិសំយោគោ ភវយោគវិសំយោគោ ។ ទិដ្ឋិយោគវិសំយោគោ ច កថំ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ ទិដ្ឋីនំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ

ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការមិនប្រកបដោយកាមយោគៈ ។ ការមិនប្រកបដោយកាមយោគៈដូច្នេះឯង ។ ចុះការមិនប្រកបដោយភវយោគៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងផង សេចក្ដីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវភពទាំងឡាយ កាលបើបុគ្គលនោះដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្ដីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវភពទាំងឡាយ ក៏មិនកើតមានតម្រេកក្នុងភព សេចក្ដីរីករាយក្នុងភព សេចក្ដីស្នេហាក្នុងភព សេចក្ដីជប់នៅក្នុងភព សេចក្ដីស្រេកឃ្លានក្នុងភព សេចក្ដីអន្ទះអន្ទែងព្រោះភព សេចក្ដីជ្រុលជ្រប់ក្នុងភព សេចក្ដីប្រាថ្នាក្នុងភព ក្នុងភពទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការមិនប្រកបដោយភវយោគៈ ។ ការមិនប្រកបដោយកាមយោគៈ និងការមិនប្រកបដោយភវយោគៈ ដូច្នេះឯង ។ ចុះការមិនប្រកបដោយទិដ្ឋិយោគៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងផង សេចក្ដីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវទិដ្ឋិទាំងឡាយ

តស្ស ទិដ្ឋីនំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានតោ យោ ទិដ្ឋីសុ ទិដ្ឋិរាគោ ទិដ្ឋិនន្ទិ ទិដ្ឋិស្នេហោ ទិដ្ឋិមុច្ឆា ទិដ្ឋិបិបាសា ទិដ្ឋិបរិឡាហោ ទិដ្ឋិជ្ឈោសានំ ទិដ្ឋិតណ្ហា សា នានុសេតិ អយំ វុច្ចតិ ភិក្ខវេ ទិដ្ឋិយោគវិសំយោគោ ។ ឥតិ កាមយោគវិសំយោគោ ភវយោគវិសំយោគោ ទិដ្ឋិយោគវិសំយោគោ ។ អវិជ្ជាយោគវិសំយោគោ ច កថំ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ តស្ស ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានតោ យា ឆសុ ផស្សាយតនេសុ អវិជ្ជា អញ្ញាណំ សា នានុសេតិ អយំ វុច្ចតិ ភិក្ខវេ អវិជ្ជាយោគវិសំយោគោ ។

កាលបើបុគ្គលនោះដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវទិដ្ឋិទាំងឡាយ ក៏មិនកើតមានតម្រេកក្នុងទិដ្ឋិ សេចក្តីរីករាយក្នុងទិដ្ឋិ សេចក្តីស្នេហាក្នុងទិដ្ឋិ សេចក្តីជប់នៅក្នុងទិដ្ឋិ សេចក្តីស្រេកឃ្លានក្នុងទិដ្ឋិ សេចក្តីអន្ទះអន្ទែងព្រោះទិដ្ឋិ សេចក្តីជ្រុលជ្រប់ក្នុងទិដ្ឋិ សេចក្តីប្រាថ្នាក្នុងទិដ្ឋិ ក្នុងទិដ្ឋិទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការមិនប្រកបដោយទិដ្ឋិយោគៈ ។ ការមិនប្រកបដោយកាមយោគៈ ការមិនប្រកបដោយភវយោគៈ និងការមិនប្រកបដោយទិដ្ឋិយោគៈដូច្នេះឯង ។ ចុះការមិនប្រកបដោយអវិជ្ជាយោគៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវផស្សាយតនៈទាំង ៦ កាលបើបុគ្គលនោះ ដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវផស្សាយតនៈទាំង ៦ ក៏មិនមានសេចក្តីល្ងង់ សេចក្តីមិនដឹងក្នុងផស្សាយតនៈទាំង ៦ ឡើយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការមិនប្រកបដោយអវិជ្ជាយោគៈ ។

ឥតិ កាមយោគវិសំយោគោ ភវយោគវិសំយោគោ ទិដ្ឋិយោគវិសំយោគោ អវិជ្ជាយោគវិសំយោគោ ។ វិសំយុត្តោ បាបកេហិ អកុសលេហិ ធម្មេហិ សំកិលេសិកេហិ បោនោព្ភវិកេហិ សទរេហិ ទុក្ខវិបាកេហិ អាយតឹជាតិជរាមរណិកេហិ តស្មា យោគក្ខេមីតិ វុច្ចតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ វិសំយោគាតិ ។

កាមយោគេន សំយុត្តា ភវយោគេន ចូភយំ
ទិដ្ឋិយោគេន សំយុត្តា អវិជ្ជាយ បុរក្ខតា
សត្តា គច្ឆន្តិ សំសារំ ជាតិមរណគាមិនោ ។
យេ ច កាមេ បរិញ្ញាយ ភវយោគញ្ច សព្វសោ
ទិដ្ឋិយោគំ សមូហច្ច អវិជ្ជញ្ច វិរាជយំ
សព្វយោគវិសំយុត្តា តេ វេ យោគាតិគា មុនីតិ[១] ។

ភណ្ឌគ្គាមវគ្គោ បឋមោ ។

---

១ ឱ. តេ វេ យោគាតិគាមិនោ ។ ម. តេ មេ យោគាតិគាមុនីតិ ។

ការមិនប្រកបដោយកាមយោគៈ ការមិនប្រកបដោយភវយោគៈ ការមិនប្រកបដោយទិដ្ឋិយោគៈ និងការមិនប្រកបដោយអវិជ្ជាយោគៈដូច្នេះឯង ។ បុគ្គលប្រាសចាកអកុសលធម៌ដ៏លាមក ជាគ្រឿងសៅហ្មង ជាហេតុនាំឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ជាហេតុនាំឲ្យកើតជាតិ ជរា មរណៈតទៅ ព្រោះហេតុនោះ (បុគ្គលនោះ) ទើបហៅថាជាអ្នកមានសេចក្តីក្សេមចាកយោគៈ ។ ម្នាលភិក្ខុទាំងឡាយ ការមិនប្រកបដោយយោគៈមាន ៤ យ៉ាងប៉ុណ្ណោះ ។

ពួកសត្វប្រកបដោយកាមយោគៈ និងភវយោគៈ
ទាំង ២ ប្រកបដោយទិដ្ឋិយោគៈត្រូវអវិជ្ជាយោគៈ
ចោមរោម ជាអ្នកមានដំណើរទៅកាន់ជាតិ (ជរា) និង
មរណៈជាប្រក្រតី រមែងអន្ទោលទៅរកសង្សារ ។
ចំណែកពួកជនណា បានកំណត់ដឹងនូវកាមយោគៈ
ផង ភវយោគៈដោយអាការទាំងពួងផង ដកឡើង
នូវទិដ្ឋិយោគៈផង លះបង់នូវអវិជ្ជាយោគៈផង ជា
អ្នកប្រាសចាកយោគៈទាំងពួង ជនទាំងនោះ
ឈ្មោះថាជាអ្នកប្រាជ្ញកន្លងផុតនូវយោគៈ ។

ចប់ ភណ្ឌគ្គាមវគ្គទី ១ ។

៣០

សុត្តន្តបិដកេ អង្គុត្តរនិកាយស្ស ចតុក្កនិបាតោ

# តស្សុទ្ទានំ

អនុពុទ្ធំ បបតិតំ

ទ្វេខតំ អនុស្សោតបញ្ចមំ

អប្បស្សុតោ ច សោភេន្តិ[១]

(វេសារជ្ជំ) តណ្ហាយោគេន តេ ទសាតិ ។

---

១ ម. សោភណំ

សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត

# ឧទ្ទាននៃភណ្ឌគ្គាមវគ្គនោះគឺ

*និយាយអំពីការត្រាស់ដឹងធម៌ ៤ យ៉ាង ១ អំពីភិក្ខុជាអ្នកធ្លាក់ចុះចាកធម្មវិន័យ ១ អំពីការជីករំលើងគុណមាន ២ លើក ១ ជាគម្រប់ ៥ និងបុគ្គលមានដំណើរទៅតាមខ្សែទឹក ១ អំពីបុគ្គលមានសេចក្តីចេះដឹងតិច ១ អំពីបុគ្គលញុំាងសង្ឃឲ្យរុងរឿង ១ (អំពីវេសារជ្ជញ្ញាណ) ១ អំពីការកើតឡើងនៃតណ្ហា ១ និងយោគៈ ១ ទៀតជា ១០ ។*

# ចរវគ្គោ

[១១] ចរតោ ចេបិ ភិក្ខវេ ភិក្ខុនោ ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ច(១) ភិក្ខុ អធិវាសេតិ នប្បជហាតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវំ គមេតិ ចរម្បិ(២) ភិក្ខវេ ភិក្ខុ ឯវំភូតោ អនាតាបី អនោត្តប្បី សតតំ សមិតំ កុសីតោ ហីនវីរិយោតិ វុច្ចតិ ។ ឋិតស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ច ភិក្ខុ អធិវាសេតិ នប្បជហាតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវំ គមេតិ ឋិតោបិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អនាតាបី អនោត្តប្បី សតតំ សមិតំ កុសីតោ ហីនវីរិយោតិ វុច្ចតិ ។ និសិន្នស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ឧប្បជ្ជតិ កាម-វិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ច ភិក្ខុ អធិវាសេតិ នប្បជហាតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវំ គមេតិ

---

១ ឱ. ម. តញ្ចេ ។ ២ ឱ. ចរញ្ចេបិ ។ ម. ចរន្តោបិ ។

# ចរវគ្គ

[១១] ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងដល់ភិក្ខុកំពុងដើរទៅ បើភិក្ខុតាំងចិត្តទទួល មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យអស់ទៅ មិនឲ្យដល់នូវសេចក្តីវិនាស នូវវិតក្កៈទាំងនោះទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដើរទៅ មានសភាពយ៉ាងនេះ ហៅថា មិនមានព្យាយាម ដុតកម្តៅកិលេស មិនខ្លាចពាក្យតិះដៀល ខ្ជិលច្រអូស មានព្យាយាមថោកថយ ជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងដល់ភិក្ខុកំពុងឈរ បើភិក្ខុតាំងចិត្តទទួល មិនលះបង់ មិនបន្ទោ-បង់ មិនធ្វើឲ្យអស់ទៅ មិនឲ្យដល់នូវសេចក្តីវិនាស នូវវិតក្កៈទាំងនោះទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈរ មានសភាពយ៉ាងនេះ ហៅថា មិនមានព្យាយាមដុតកម្តៅកិលេស មិនខ្លាចពាក្យតិះដៀល ខ្ជិលច្រអូស មានព្យាយាមថោកថយ ជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងដល់ភិក្ខុកំពុងអង្គុយ បើភិក្ខុតាំងចិត្តទទួល មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យអស់ទៅ មិនឲ្យដល់នូវសេចក្តីវិនាស នូវវិតក្កៈទាំងនោះទេ

និសិន្នោបិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អនាតាបី អនោត្តប្បី សតតំ សមិតំ កុសីតោ ហីនវីរិយោតិ វុច្ចតិ ។ សយានស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ជាគរស្ស ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ចេ ភិក្ខុ អធិវាសេតិ នប្បជហាតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវំ គមេតិ សយានោបិ ភិក្ខវេ ភិក្ខុ ជាគរោ ឯវំភូតោ អនាតាបី អនោត្តប្បី សតតំ សមិតំ កុសីតោ ហីនវីរិយោតិ វុច្ចតិ ។ ចរតោ ចេបិ ភិក្ខវេ ភិក្ខុនោ ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ចេ ភិក្ខុ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ចរម្បិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អាតាបី ឱត្តប្បី សតតំ សមិតំ អារទ្ធវីរិយោ បហិតត្តោតិ វុច្ចតិ ។ ឋិតស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលអង្គុយ មានសភាពយ៉ាងនេះ ហៅថា មិនមានព្យាយាមដុតកម្តៅកិលេស មិនខ្លាចពាក្យតិះដៀល ខ្ជិលច្រអូស មានព្យាយាមថោកថយ ជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងដល់ភិក្ខុកំពុងដេក កំពុងភ្ញាក់រលឹក បើភិក្ខុតាំងចិត្តទទួល មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យអស់ទៅ មិនឲ្យដល់នូវសេចក្តីវិនាស នូវវិតក្កៈទាំងនោះទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលដេក ភ្ញាក់រលឹកមានសភាពយ៉ាងនេះ ហៅថា មិនមានព្យាយាមដុតកម្តៅកិលេស មិនខ្លាចពាក្យតិះដៀល ខ្ជិលច្រអូស មានព្យាយាមថោកថយ ជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងដល់ភិក្ខុកំពុងដើរ បើភិក្ខុមិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ចេញ ធ្វើឲ្យអស់ទៅ ឲ្យដល់នូវសេចក្តីវិនាស នូវវិតក្កៈទាំងនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដើរ មានសភាពយ៉ាងនេះ ហៅថា មានព្យាយាមដុតកម្តៅកិលេស មានសេចក្តីខ្លាចពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងដល់ភិក្ខុកំពុងឈរ

៣៣

បឋមបណ្ណាសកេ ចរវគ្គោ

តញ្ច ភិក្ខុ ជាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ឋិតោបិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អាតាបី ឱត្តប្បី សតតំ សមិតំ អារទ្ធវីរិយោ បហិតត្តោតិ វុច្ចតិ ។ និសិន្នស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ច ភិក្ខុ ជាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ និសិន្នោបិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អាតាបី ឱត្តប្បី សតតំ សមិតំ អារទ្ធវីរិយោ បហិតត្តោតិ វុច្ចតិ ។ សយានស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ជាគរស្ស ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ច ភិក្ខុ ជាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ សយានោបិ ភិក្ខវេ ភិក្ខុ ជាគរោ ឯវំភូតោ អាតាបី ឱត្តប្បី សតតំ សមិតំ អារទ្ធវីរិយោ បហិតត្តោតិ វុច្ចតីតិ ។

បើភិក្ខុមិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ ធ្វើឲ្យអស់ទៅ ឲ្យដល់នូវសេចក្តីវិនាសនូវវិតក្កៈទាំងនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈរមានសភាពយ៉ាងនេះហៅថា មានព្យាយាមដុតកម្តៅកិលេស មានសេចក្តីខ្លាចពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងដល់ភិក្ខុកំពុងអង្គុយ បើភិក្ខុមិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ ធ្វើឲ្យអស់ទៅ ឲ្យដល់នូវសេចក្តីវិនាសនូវវិតក្កៈទាំងនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអង្គុយមានសភាពយ៉ាងនេះហៅថា មានព្យាយាមដុតកម្តៅកិលេស មានសេចក្តីខ្លាចពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងដល់ភិក្ខុកំពុងដេកកំពុងភ្ញាក់រលឹក បើភិក្ខុមិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ ធ្វើឲ្យអស់ទៅ ឲ្យដល់នូវសេចក្តីវិនាសនូវវិតក្កៈទាំងនោះ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុកាលដេក ភ្ញាក់រលឹកមានសភាពយ៉ាងនេះហៅថា មានព្យាយាមដុតកម្តៅកិលេស មានសេចក្តីខ្លាចពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជានិច្ចនិរន្តរ៍ ។

ចរំ វា យទិ វា តិដ្ឋំ
និសិន្នោ ឧទ វា សយំ
យោ វិតក្កំ វិតក្កេតិ
ចាបកំ គេហនិស្សិតំ
កុម្មគ្គំ[១] បដិបន្នោ សោ
មោហនេយ្យេសុ មុច្ឆិតោ
អភព្វោ តាទិសោ ភិក្ខុ
ផុដ្ឋុំ សម្ពោធិមុត្តមំ ។
យោ ចរំ វាបិ តិដ្ឋំ វា[២]
និសិន្នោ ឧទ វា សយំ
វិតក្កំ សមយិត្វាន
វិតក្កូបសមេ រតោ
ភព្វោ សោ តាទិសោ ភិក្ខុ
ផុដ្ឋុំ សម្ពោធិមុត្តមន្តិ ។

១ ឱ. ម. កុម្មគ្គ ។ ២ យោ ច ចរំ វា តិដ្ឋំ វា ។

ភិក្ខុណា កាលដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី តែង ត្រិះរិះនូវវិតក្កៈ ដែលអាស្រ័យនូវផ្ទះគឺកិលេសដ៏លាមក ភិក្ខុប្រាកដដូច្នោះនោះ ឈ្មោះថា ដើរទៅកាន់ផ្លូវ ដែលបណ្ឌិតគប្បីខ្ពើម ជ្រប់នៅក្នុងអារម្មណ៍ ជាគ្រឿង វង្វេង មិនអាចពាល់ត្រូវនូវញាណ ជាគ្រឿងត្រាស់ដឹងដ៏ ឧត្តមទេ ។ ភិក្ខុណា កាលដើរក្តី ឈរក្តី អង្គុយក្តី ដេក ក្តី បានរម្ងាប់នូវវិតក្កៈ ត្រេកអរក្នុងធម៌ ជាគ្រឿងរម្ងាប់ នូវវិតក្កៈ ភិក្ខុប្រាកដដូច្នោះនោះ ទើបអាចពាល់ត្រូវ នូវញាណ ជាគ្រឿងត្រាស់ដឹងដ៏ឧត្តមបាន ។

[១២] សម្បន្នសីលា ភិក្ខវេ វិហរថ សម្បន្នប្បាតិមោក្ខា ចាតិមោក្ខសំវរសំវុតា វិហរថ អាចារគោចរសម្បន្នា អណុមត្តេសុ វជ្ជេសុ ភយទស្សាវិនោ សមាទាយ សិក្ខថ សិក្ខាបទេសុ ។ សម្បន្នសីលានំ ភិក្ខវេ វិហរតំ សម្បន្នប្បាតិមោក្ខានំ ចាតិមោក្ខសំវរសំវុតានំ វិហរតំ អាចារគោចរសម្បន្នានំ អណុមត្តេសុ វជ្ជេសុ ភយទស្សាវីនំ សមាទាយ សិក្ខតំ សិក្ខាបទេសុ កិមស្ស ឧត្តរិករណីយំ ។ ចរតោ ចេបិ ភិក្ខវេ ភិក្ខុនោ អភិជ្ឈា... ព្យាបាទោ វិគតោ ហោតិ ថីនមិទ្ធំ... ឧទ្ធច្ចកុក្កុច្ចំ... វិចិកិច្ឆា បហីនា ហោតិ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ ឧបដ្ឋិតា សតិ អប្បមុដ្ឋា បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គំ ចរំបិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អាតាបី ឱត្តប្បី

[១២] ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ បរិបូណ៌ដោយសីល បរិបូណ៌ដោយបាតិមោក្ខ សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោស សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយបរិបូណ៌ដោយសីល បរិបូណ៌ដោយបាតិមោក្ខ សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោស សូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ តើគប្បីមានកិច្ចអ្វីដែលគួរធ្វើឱ្យក្រៃលែងឡើងទៀត ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុកាលដើរមានអភិជ្ឈា... មានព្យាបាទទៅប្រាសហើយ មានសេចក្តីងងុយនិងងោកងក់... មានសេចក្តីរវើរវាយនិងសេចក្តីរំខានចិត្ត... មានសេចក្តីសង្ស័យលះបង់ហើយ មានព្យាយាមប្រារព្ធហើយ មិនបានរួញរា មានស្មារតីប្រុងខ្ជាប់ មិនបានវង្វេងភ្លេច មានកាយស្ងប់រម្ងាប់ មិនបានក្រវល់ក្រវាយ មានចិត្តតម្កល់មាំនៅក្នុងអារម្មណ៍តែមួយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដើរមានសភាពយ៉ាងនេះហៅថា មានព្យាយាមដុតកម្តៅកិលេស មានសេចក្តីខ្លាច

សតតំ សមិតំ អារទ្ធវីរិយោ បហិតត្តោតិ វុច្ចតិ ។ ឋិតស្ស ចេបិ ភិក្ខវេ ភិក្ខុនោ... និសិន្នស្ស ចេបិ ភិក្ខវេ ភិក្ខុនោ... សយានស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ជាគរស្ស អភិជ្ឈា... ព្យាបាទោ វិគតោ ហោតិ ថីនមិទ្ធំ... ឧទ្ធច្ចកុក្កុច្ចំ... វិចិកិច្ឆា បហីនា ហោតិ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ ឧបដ្ឋិតា សតិ អប្បមុដ្ឋា បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គំ សយានោបិ ភិក្ខវេ ភិក្ខុ ជាគរោ ឯវំភូតោ អាតាបី ឱត្តប្បី សតតំ សមិតំ អារទ្ធវីរិយោ បហិតត្តោតិ វុច្ចតីតិ ។

យតញ្ចរេ យតំ តិដ្ឋេ
យតំ អច្ឆេ យតំ សយេ(១)
យតំ សម្មិញ្ជយេ ភិក្ខុ
យតមេតំ បសារយេ
ឧទ្ធំ តិរិយំ អបាចីនំ
យាវតា ជគតោ គតិ

១ ម. យថា ចរេ យថា តិដ្ឋេ យថា អច្ឆេ យថា សយេ ។

ពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុឈរ... ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុអង្គុយ... ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុកំពុងដេក កំពុងភ្ញាក់រលឹក មានអភិជ្ឈា... មានព្យាបាទទៅប្រាសហើយ មានសេចក្តីងងុយនិងងោកងក់... មានសេចក្តីរវើរវាយនិងសេចក្តីរំខានចិត្ត... មានសេចក្តីសង្ស័យលះបង់ហើយ មានព្យាយាមប្រារព្ធហើយ មិនបានរួញរា មានស្មារតីប្រុងខ្ជាប់ មិនបានវង្វេងភ្លេច មានកាយស្ងប់រម្ងាប់ហើយ មិនបានក្រវល់ក្រវាយ មានចិត្តតម្កល់មាំនៅក្នុងអារម្មណ៍តែមួយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដេកភ្ញាក់រលឹកមានសភាពដូច្នេះ ហៅថាមានព្យាយាមដុតកម្តៅកិលេស មានសេចក្តីខ្លាចពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជានិច្ចនិរន្តរ៍ ។

ភិក្ខុគប្បីដើរ សង្រួម គប្បីឈរ សង្រួម
គប្បីអង្គុយ សង្រួម គប្បីដេក សង្រួម គប្បីបត់
( នូវអវយវៈតូចធំ ) សង្រួម គប្បីលានូវអវយវៈតូច
ធំនុ៎ះ សង្រួម គតិនៃសត្វលោក ទាំងខាងលើ
កណ្តាលនិងខាងក្រោម[១] មានកំណត់ត្រឹមណា

១. បានដល់បញ្ចក្ខន្ធជាអតីត បច្ចុប្បន្ន និងអនាគត ។ អដ្ឋកថា ។

សមវេក្ខិតា ច ធម្មានំ
ខន្ធានំ ឧទយព្វយំ
ចេតោសមថសាមីចឹ
សិក្ខមានំ សទាសតឹ[១]
សតតំ បហិតត្តោតិ
អាហុ ភិក្ខុំ តថាវិធន្តិ ។

[១៣] ចត្តារីមានិ ភិក្ខវេ សម្មប្បធានានិ ។ កតមានិ ចត្តារិ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ

១ ឱ. ម. សទាសតំ ។

អ្នកប្រាជ្ញទាំងឡាយ ពិចារណាឃើញនូវកិរិយាកើតឡើងនិងវិនាសទៅនៃធម៌ គឺខន្ធទាំងឡាយ មានកំណត់ត្រឹមណោះ ទើបពោលថា ភិក្ខុមានសភាពដូច្នោះ ជាអ្នកសិក្សានូវបដិបទាដ៏សមគួរ ដល់នូវសេចក្ដីស្ងប់រម្ងាប់ចិត្ត មានសតិសព្វកាល ឈ្មោះថា ជាអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានជានិច្ច ។

[១៣] ម្នាលភិក្ខុទាំងឡាយ សម្មប្បធាន (សេចក្ដីព្យាយាមប្រពៃ) នេះ មាន ៤ យ៉ាង ។ សម្មប្បធាន ៤ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ១ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងកុសលធម៌ដែលមិនទាន់កើតឡើងឲ្យកើតឡើង ១

ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ សម្មប្បធានានីតិ ។

សម្មប្បធានា មារធេយ្យាភិភូតា[១]
តេ អសិតា ជាតិមរណភយស្ស បារគូ
តេ តុសិតា ជេត្វាន មារំ សវាហនំ
តេ អនេជា (សព្វំ) នមុចិពលំ
ឧបាតិវត្តា (តេ សុខិតាតិ) ។

[១៤] ចត្តារីមានិ ភិក្ខវេ បធានានិ ។ កតមានិ ចត្តារិ ។ សំវរប្បធានំ បហានប្បធានំ ភាវនាបធានំ អនុរក្ខនាបធានំ ។ កតមញ្ច ភិក្ខវេ សំវរប្បធានំ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី

១ ឱ. មារធេយ្យាភិភុនោ ។

ញ៉ាំងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញ៉ាំងកុសលធម៌ដែលកើតឡើងហើយ ឲ្យស្ថិតនៅ មិនឲ្យភ្លេចភ្លាំងទៅ ឲ្យចម្រើនធំទូលាយ បរិបូណ៌ក្រៃលែងឡើង ១ ។ ម្នាលភិក្ខុទាំងឡាយ សម្មប្បធាន មាន ៤ យ៉ាងប៉ុណ្ណេះ ។

ព្រះខីណាស្រពទាំងនោះ ជាអ្នកមានព្យាយាមដោយប្រពៃ គ្របសង្កត់នូវមារគឺវដ្តៈបាន ជាអ្នកមិនបានអាស្រ័យ ជាអ្នកដល់ត្រើយនៃភ័យ គឺជាតិនិងមរណៈត្រេកអរ បានឈ្នះនូវមារព្រមទាំងវាហនៈ គឺសេនារបស់មារ ព្រះខីណាស្រពនោះ មិនបានញាប់ញ័រដោយតណ្ហា កន្លងបង់នូវពល នៃមារទាំងអស់បាន (លោកដល់នូវសេចក្តីសុខហើយ) ។

[១៤] ម្នាលភិក្ខុទាំងឡាយ បធាន (សេចក្តីព្យាយាម) នេះ មាន ៤ យ៉ាង ។ បធានទាំង ៤ យ៉ាង តើដូចម្តេច ។ គឺសំវរប្បធាន ១ បហានប្បធាន ១ ភាវនាបធាន ១ អនុរក្ខនាបធាន ១ ។ ម្នាលភិក្ខុទាំងឡាយ សំវរប្បធាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែកហើយ មិនបានកាន់យកនូវនិមិត្ត

ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ ឥទំ វុច្ចតិ ភិក្ខវេ សំវរប្បធានំ ។ កតមញ្ច ភិក្ខវេ បហានប្បធានំ ។ ឥធ ភិក្ខវេ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ឧប្បន្នំ ព្យាបាទវិតក្កំ... ឧប្បន្នំ វិហឹសាវិតក្កំ... ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ។

មិនបានកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គល ដែលមិនបានសង្រួមនូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិ ដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ជញ្ជាបរសដោយអណ្តាត ពាល់ត្រូវនូវផ្សព្វដោយកាយ... ដឹងនូវធម្មារម្មណ៍ដោយចិត្ត មិនបានកាន់យកនូវនិមិត្ត មិនបានកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិ ដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងមនិ-ន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សំវរប្បធាន ។ ម្នាលភិក្ខុទាំង-ឡាយ បហានប្បធាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ ធ្វើឲ្យអស់ទៅ ឲ្យដល់នូវសេចក្តីវិនាសនូវកាមវិតក្កៈ ដែលកើតឡើងហើយ ព្យាបាទវិតក្កៈដែលកើតឡើងហើយ... វិហឹសាវិតក្កៈដែលកើតឡើងហើយ... មិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ ធ្វើឲ្យអស់ទៅ ឲ្យដល់នូវសេចក្តីវិនាសនូវអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយកើតឡើងហើយ ។

ឥទំ វុច្ចតិ ភិក្ខវេ បហានប្បធានំ ។ កតមញ្ច ភិក្ខវេ ភាវនាបធានំ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ... វីរិយសម្ពោជ្ឈង្គំ ភាវេតិ... បីតិសម្ពោជ្ឈង្គំ ភាវេតិ... បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ... សមាធិ-សម្ពោជ្ឈង្គំ ភាវេតិ... ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គ-បរិណាមឹ ។ ឥទំ វុច្ចតិ ភិក្ខវេ ភាវនាបធានំ ។ កតមញ្ច ភិក្ខវេ អនុរក្ខនាបធានំ ។ ឥធ ភិក្ខវេ ភិក្ខុ ឧប្បន្នំ ភទ្ទកំ សមាធិនិមិត្តំ អនុរក្ខតិ អដ្ឋិកសញ្ញំ បុឡវកសញ្ញំ វិនីលកសញ្ញំ វិបុព្វកសញ្ញំ វិច្ឆិទ្ទកសញ្ញំ ឧទ្ធុមាតកសញ្ញំ ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា បហានប្បធាន ។ ម្នាលភិក្ខុទាំងឡាយ ភាវនាបធាន តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្ដីស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវសេចក្ដីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ចម្រើននូវធម្មវិចយសម្ពោជ្ឈង្គ... ចម្រើននូវវីរិយសម្ពោជ្ឈង្គ... ចម្រើននូវបីតិសម្ពោជ្ឈង្គ... ចម្រើននូវបស្សទ្ធិសម្ពោជ្ឈង្គ... ចម្រើននូវសមាធិសម្ពោជ្ឈង្គ... ចម្រើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្ដីស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវសេចក្ដីរលត់ មានកិរិយាបង្អោនទៅ ដើម្បីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាវនាបធាន ។ ម្នាលភិក្ខុទាំងឡាយ អនុរក្ខនាបធាន តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រក្សាទុកនូវសមាធិនិមិត្ត គឺអដ្ឋិកសញ្ញា បុឡវកសញ្ញា វិនីលកសញ្ញា វិបុព្វកសញ្ញា វិច្ឆិទ្ទកសញ្ញា ឧទ្ធុមាតកសញ្ញា[១] ដ៏ល្អ ដែលកើតឡើងហើយ ។

១. ប្រែថា សេចក្ដីសម្គាល់នូវរាងឆ្អឹង សេចក្ដីសម្គាល់នូវអសុភមានគំនរដង្កូវ សេចក្ដីសម្គាល់នូវអសុភមានសម្បុរខៀវ សេចក្ដីសម្គាល់នូវអសុភមានខ្ទុះហូរចេញ សេចក្ដីសម្គាល់នូវអសុភដាច់ពាក់កណ្ដាល សេចក្ដីសម្គាល់នូវអសុភហើមប៉ោង ។ ក្នុងទីនេះ សំដៅយកអសុភទាំង ១០ ដែលមានពិស្ដារក្នុងវិសុទ្ធិមគ្គ ។ អដ្ឋកថា ។

ឥទំ វុច្ចតិ ភិក្ខវេ អនុរក្ខនាបធានំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ បធានានីតិ ។

សំវរោ ច បហានញ្ច
ភាវនា អនុរក្ខនា
ឯតេ បធានា ចត្តារោ
ទេសិតាទិច្ចពន្ធុនា
យេហិ ភិក្ខុ ឥធាតាបី
ខយំ ទុក្ខស្ស បាបុណោតិ(១) ។

[១៤] ចតស្សោ ឥមា ភិក្ខវេ អគ្គប្បញ្ញត្តិយោ ។ កតមា ចតស្សោ ។ ឯតទគ្គំ ភិក្ខវេ អត្តភាវីនំ យទិទំ រាហុ អសុរិន្ទោ ឯតទគ្គំ ភិក្ខវេ កាមភោគីនំ យទិទំ រាជា មន្ធាតា

១ ឱ. បាបុណាតិ ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនុរក្ខនាបធាន ។ ម្នាលភិក្ខុទាំងឡាយ បធាន មាន ៤ យ៉ាងប៉ុណ្ណេះ ។

សំវរប្បធាន ១ បហានប្បធាន ១ ភាវនាបធាន ១ អនុរក្ខនាបធាន ១ បធានទាំង ៤ យ៉ាងនេះ ព្រះពុទ្ធ ជាផៅពង្សនៃព្រះអាទិត្យ ទ្រង់សម្តែងហើយ ដែលភិក្ខុ ក្នុងសាសនានេះ មានព្យាយាម ដុតកម្តៅកិលេស បានដល់នូវអរហត្ត ជាធម៌អស់ទៅនៃទុក្ខ ។

[១៥] ម្នាលភិក្ខុទាំងឡាយ អគ្គប្បញ្ញត្តិ (បញ្ញត្តិដ៏ប្រសើរ) នេះមាន ៤ យ៉ាង ។ អគ្គប្បញ្ញត្តិ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រាហុអសុរិន្ទនេះ ធំលើសជាងពួកសត្វមានអត្តភាព(១) ១ ម្នាលភិក្ខុទាំងឡាយ ព្រះបាទមន្ធាតុនេះ ប្រសើរជាងបុគ្គលអ្នកបរិភោគកាម(២) ទាំងឡាយ ១

---

១. បានឮរៀងមកថា រាហុអសុរិន្ទមានកម្ពស់ ៤៨០០ យោជន៍ ចន្លោះដើមដៃគឺពីស្មាម្ខាងទៅស្មាម្ខាងប្រវែង ១២០០ យោជន៍ ផ្ទៃបាតដៃនិងបាតជើងកម្រាស់ ៣០០ យោជន៍ ថ្នាំងម្រាមដៃប្រវែង ៥០ យោជន៍ ចន្លោះចិញ្ចើម ( ប្រជុំចិញ្ចើម ) ប្រវែង ៥០ យោជន៍ ថ្ងាស ៣០០ យោជន៍ ក្បាល ៩០០ យោជន៍ ។ រាហុអសុរិន្ទមានអត្តភាពធំសំបើមយ៉ាងនេះ ។

២. ស្តេចមន្ធាតុនេះបានសោយរាជ្យ បរិភោគកាមជាទិព្វក្នុងស្ថានសួគ៌ផង ក្នុងមនុស្សផង ស្តេចនេះ កើតក្នុងមនុស្សលោកមានអាយុ ១ អសំខេយ្យ អាចញុំាងភ្លៀងប្រាក់ឲ្យធ្លាក់ចុះមកបាន ក្នុងខណៈដែលប្រាថ្នា លុះបរិភោគកាមរបស់មនុស្សលោកអស់កាលជាយូររួចហើយ ក៏ទៅសោយរាជ្យ បរិភោគកាមដ៏ឧត្តមក្នុងទេវលោក កំណត់កាលអស់អាយុនៃព្រះឥន្ទ្រ ៣៦ អង្គទៀត ជាបុគ្គលប្រសើរជាងអ្នកបរិភោគកាមយ៉ាងនេះ ។ អដ្ឋកថា ។

ឯតទគ្គំ ភិក្ខវេ អាធិបតេយ្យានំ យទិទំ មារោ ចាបិមា សទេវកេ ភិក្ខវេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ តថាគតោ អគ្គមក្ខាយតិ អរហំ សម្មាសម្ពុទ្ធោ ។ ឥមា ខោ ភិក្ខវេ ចតស្សោ អគ្គប្បញ្ញត្តិយោតិ ។

រាហុគ្គំ អត្តភាវីនំ
មន្ធាតា កាមភោគិនំ
មារោ អាធិបតេយ្យានំ
ឥទ្ធិយា យសសា ជលំ
ឧទ្ធំ តិរិយំ អចាចីនំ
យាវតា ជគតោ គតិ
សទេវកស្ស លោកស្ស
ពុទ្ធោ អគ្គំ[១] បវុច្ចតីតិ ។

---

១ ម. អគ្គោ ។

ម្នាលភិក្ខុទាំងឡាយ មារមានចិត្តបាបនេះ ប្រសើរជាងពួកសត្វដែលមានតំណែងធំ ៗ ១ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរក្នុងមនុស្សលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ១ ។ ម្នាលភិក្ខុទាំងឡាយ អគ្គប្បញ្ញត្តិមាន ៤ យ៉ាងប៉ុណ្ណេះ ។

រាហុធំលើសពួកសត្វដែលមានអត្តភាព ស្តេចមន្ធាតុ
ប្រសើរជាងបុគ្គលអ្នកបរិភោគកាមទាំងឡាយ មារ
ប្រសើរជាងពួកសត្វដែលមានតំណែងធំ ៗ ជាអ្នក
រុងរឿងដោយឫទ្ធិគឺ ការសម្រេចដោយទិព្វសម្បត្តិ និង
ដោយយសបរិវារ គតិនៃសត្វលោកមានកំណត់ត្រឹម
ណាទោះជាន់ខាងលើក្តី កណ្តាលក្តី ខាងក្រោមក្តី
ព្រះពុទ្ធ ដែលអ្នកប្រាជ្ញទាំងឡាយពោលថាប្រសើរ
ជាងមនុស្សលោក ព្រមទាំងទេវលោក មានកំណត់
ត្រឹមណោះ ។

[១៦] ចត្តារីមានិ ភិក្ខវេ សោឌ្ធម្មានិ ។ កាតមានិ ចត្តារិ ។ ឥធ ភិក្ខវេ ភិក្ខុ រូបសោឌ្ធម្មេន សមន្នាគតោ ហោតិ បរមេន តេន ច រូបសោឌ្ធម្មេន អញ្ញំ រូបសោឌ្ធម្មំ ឧត្តរិតរំ វា បណី-តតរំ វា ន សមនុបស្សតិ តេន ច រូបសោឌ្ធម្មេន អញ្ញំ រូបសោឌ្ធម្មំ ឧត្តរិតរំ វា បណីតតរំ វា ន បត្ថេតិ វេទនាសោឌ្ធម្មេន សមន្នាគតោ ហោតិ សញ្ញាសោឌ្ធម្មេន សមន្នាគតោ ហោតិ សង្ខារ-សោឌ្ធម្មេន សមន្នាគតោ ហោតិ បរមេន តេន ច សង្ខារសោឌ្ធម្មេន អញ្ញំ សង្ខារសោឌ្ធម្មំ ឧត្តរិតរំ វា បណីតតរំ វា ន សមនុបស្សតិ តេន ច សង្ខារសោ-ឌ្ធម្មេន អញ្ញំ សង្ខារសោឌ្ធម្មំ ឧត្តរិតរំ វា បណីតតរំ វា ន បត្ថេតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ សោឌ្ធម្មានីតិ ។

[១៦] ម្នាលភិក្ខុទាំងឡាយ ញាណជាគ្រឿងចាក់ធ្លុះនូវលក្ខណៈដ៏ល្អិតនេះមាន ៤ យ៉ាង ។ ញាណជាគ្រឿងចាក់ធ្លុះនូវលក្ខណៈដ៏ល្អិត ៤ យ៉ាងតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយញាណជាគ្រឿងកំណត់នូវលក្ខណៈ ដ៏ល្អិតក្នុងរូបក្រៃលែង ប៉ុន្តែមិនពិចារណាឃើញនូវញាណជាគ្រឿងកំណត់នូវលក្ខណៈ ដ៏ល្អិតក្នុងរូបដទៃទៀត ដែលលើសលុបជាង ឬថ្លៃថ្លាជាងញាណ ជាគ្រឿងកំណត់នូវលក្ខណៈដ៏ល្អិតក្នុងរូបនោះ ទាំងមិនបានប្រាថ្នានូវញាណជាគ្រឿងកំណត់នូវលក្ខណៈដ៏ល្អិតក្នុងរូបដទៃទៀត ដែលលើសលុបជាង ឬថ្លៃថ្លាជាងញាណ ជាគ្រឿងកំណត់នូវលក្ខណៈ ដ៏ល្អិតក្នុងរូបនោះឯង ១ ប្រកបដោយញាណ ជាគ្រឿងកំណត់នូវលក្ខណៈ ដ៏ល្អិតក្នុងវេទនា ១ ប្រកបដោយញាណ ជាគ្រឿងកំណត់នូវលក្ខណៈ ដ៏ល្អិតក្នុងសញ្ញា ១ ប្រកបដោយញាណ ជាគ្រឿងកំណត់នូវលក្ខណៈ ដ៏ល្អិតក្នុងសង្ខារដ៏ក្រៃលែង ប៉ុន្តែមិនពិចារណាឃើញនូវញាណ ជាគ្រឿងកំណត់នូវលក្ខណៈ ដ៏ល្អិតក្នុងសង្ខារដទៃដែលលើសលុបជាង ឬថ្លៃថ្លាជាងញាណ ជាគ្រឿងកំណត់នូវលក្ខណៈ ដ៏ល្អិតក្នុងសង្ខារនោះ ទាំងមិនបានប្រាថ្នានូវញាណ ជាគ្រឿងកំណត់នូវលក្ខណៈ ដ៏ល្អិតក្នុងសង្ខារដទៃទៀត ដែលលើសលុបជាង ឬថ្លៃថ្លាជាងញាណ ជាគ្រឿងកំណត់នូវលក្ខណៈដ៏ល្អិតក្នុងសង្ខារនោះឯង ១ ។ ម្នាលភិក្ខុទាំងឡាយ ញាណជាគ្រឿងចាក់ធ្លុះនូវលក្ខណៈដ៏ល្អិតមាន ៤ យ៉ាងប៉ុណ្ណេះ ។

រូបសោខុម្មតំ ញត្វា
វេទនានញ្ច សម្ភវំ
សញ្ញា យតោ សមុទេតិ
អត្ថំ គច្ឆតិ យត្ថ ច
សង្ខារេ បរតោ ញត្វា
ទុក្ខតោ នោ ច អត្តតោ
សវេ[១] សម្មទ្ទសោ ភិក្ខុ
សន្តោ សន្តិបទេ រតោ
ធារេតិ អន្តិមំ ទេហំ
ជេត្វា មារំ សវាហនន្តិ ។

[១៧] ចត្តារីមានិ ភិក្ខវេ អគតិគមនានិ ។ កតមានិ ចត្តារិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អគតិគមនានីតិ ។

---
១ ឱ. សចេ ។

ភិក្ខុណាដឹងសភាពដ៏ល្អិតនូវរូបក្ខន្ធផង នូវហេតុ ជាដែនកើតឡើង នៃវេទនាខន្ធផង សញ្ញាខន្ធតាំងឡើងដោយហេតុណា ដល់នូវការរលត់ទៅ ក្នុងទីណា (ដឹងច្បាស់នូវហេតុនោះដឹងទីនោះ) ផង ដឹងនូវសង្ខារក្ខន្ធថាជារបស់អ្នកដទៃ គឺមិនទៀង ជាទុក្ខ មិនមែនជារបស់ខ្លួនផង ភិក្ខុនោះឈ្មោះថា ឃើញដោយប្រពៃ ជាអ្នកស្ងប់រម្ងាប់ ត្រេកអរក្នុងសន្តិបទគឺព្រះនិព្វាន បានឈ្នះនូវមារព្រមទាំងវាហនៈគឺសេនាហើយ រមែងទ្រទ្រង់ទុកនូវរាងកាយក្នុងភពជាទីបំផុត ។

[១៧] ម្នាលភិក្ខុទាំងឡាយ ការលុះអគតិ (សេចក្ដីលំអៀង) នេះមាន ៤ យ៉ាង ។ អគតិ ៤ យ៉ាង តើដូចម្ដេច ។ គឺលុះអគតិ ព្រោះសេចក្ដីស្រឡាញ់ ១ លុះអគតិ ព្រោះសេចក្ដីស្អប់ ១ លុះអគតិ ព្រោះសេចក្ដីល្ងង់ ១ លុះអគតិ ព្រោះសេចក្ដីខ្លាច ១ ។ ម្នាលភិក្ខុទាំងឡាយ ការលុះអគតិ មាន ៤ យ៉ាងប៉ុណ្ណោះ ។

ឆន្ទា ទោសា ភយា មោហា
យោ ធម្មំ អតិវត្តតិ
និហីយតិ តស្ស យសោ
កាឡបក្ខេវ ចន្ទិមាតិ ។

[១៨] ចត្តារីមានិ ភិក្ខវេ នាគតិគមនានិ ។ កាតមានិ ចត្តារិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ នាគតិគមនានីតិ ។

ឆន្ទា ទោសា ភយា មោហា
យោ ធម្មំ នាតិវត្តតិ
អាបូរតិ តស្ស យសោ
សុក្កបក្ខេវ ចន្ទិមាតិ ។

[១៩] ចត្តារីមានិ ភិក្ខវេ អគតិគមនានិ ។ កាតមានិ ចត្តារិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អគតិគមនានីតិ ។

បុគ្គលណា កន្លងនូវសុចរិតធម៌ ព្រោះសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីខ្លាច សេចក្តីល្ងង់ យសរបស់បុគ្គលនោះ រមែងសាបសូន្យទៅ ដូចជាព្រះចន្ទ្រក្នុងកាឡបក្ស គឺខាងរនោច ។

[១៨] ម្នាលភិក្ខុទាំងឡាយ ការមិនលុះអគតិ នេះមាន ៤ យ៉ាង ។ ឯការមិនលុះអគតិ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺមិនលុះអគតិ ព្រោះសេចក្តីស្រឡាញ់ ១ មិនលុះអគតិ ព្រោះសេចក្តីស្អប់ ១ មិនលុះអគតិ ព្រោះសេចក្តីល្ងង់ ១ មិនលុះអគតិ ព្រោះសេចក្តីខ្លាច ១ ។ ម្នាលភិក្ខុទាំងឡាយ ការមិនលុះអគតិ មាន ៤ យ៉ាងប៉ុណ្ណោះ ។

បុគ្គលណា មិនបានកន្លងនូវសុចរិតធម៌ ព្រោះសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីខ្លាច សេចក្តីល្ងង់ យសរបស់បុគ្គលនោះ រមែងពេញបរិបូណ៌ ដូចជាព្រះចន្ទ្រ ក្នុងសុក្កបក្សគឺខាងខ្នើត ។

[១៩] ម្នាលភិក្ខុទាំងឡាយ ការលុះអគតិ នេះមាន ៤ យ៉ាង ។ ការលុះអគតិ ៤ យ៉ាង តើដូចម្តេច ។ គឺលុះអគតិ ព្រោះសេចក្តីស្រឡាញ់ ១ លុះអគតិ ព្រោះសេចក្តីស្អប់ ១ លុះអគតិ ព្រោះសេចក្តីល្ងង់ ១ លុះអគតិ ព្រោះសេចក្តីខ្លាច ១ ។ ម្នាលភិក្ខុទាំងឡាយ ការលុះអគតិ ៤ យ៉ាងប៉ុណ្ណោះ ។

ឆន្ទា ទោសា ភយា មោហា
យោ ធម្មំ អតិវត្តតិ
និហីយតិ តស្ស យសោ
កាឡបក្ខេវ ចន្ទិមាតិ ។

[២០] ចត្តារីមានិ ភិក្ខវេ ភត្តុទ្ទេសកស្ស (?)

[២០] ចត្តារីមានិ ភិក្ខវេ នាគតិគមនានិ ។ កាតមានិ ចត្តារិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ នាគតិគមនានីតិ ។

ឆន្ទា ទោសា ភយា មោហា
យោ ធម្មំ នាតិវត្តតិ
អាបូរតិ តស្ស យសោ
សុក្កបក្ខេវ ចន្ទិមាតិ ។

[២១] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភត្តុទ្ទេសកោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។

បុគ្គលណា ប្រព្រឹត្តកន្លងនូវសុចរិតធម៌ ព្រោះសេចក្តី
ស្រឡាញ់ សេចក្តីស្អប់ សេចក្តីខ្លាច សេចក្តីល្ងង់
យសរបស់បុគ្គលនោះ រមែងសាបសូន្យទៅ ដូច
ជាព្រះចន្ទ្រ ក្នុងកាឡបក្ស ។

[២០] ម្នាលភិក្ខុទាំងឡាយ ការមិនលុះអគតិ នេះមាន ៤ យ៉ាង ។ ការមិនលុះអគតិ ៤ យ៉ាង តើដូចម្តេច ។ គឺមិនលុះអគតិ ព្រោះសេចក្តីស្រឡាញ់ ១ មិនលុះអគតិ ព្រោះសេចក្តីស្អប់ ១ មិនលុះអគតិ ព្រោះសេចក្តីល្ងង់ ១ មិនលុះអគតិ ព្រោះសេចក្តីខ្លាច ១ ។ ម្នាលភិក្ខុទាំងឡាយ ការមិនលុះអគតិ មាន ៤ យ៉ាងប៉ុណ្ណោះ ។

បុគ្គលណា មិនប្រព្រឹត្តកន្លងនូវសុចរិតធម៌ ព្រោះសេចក្តី
ស្រឡាញ់ សេចក្តីស្អប់ សេចក្តីខ្លាច សេចក្តីល្ងង់ យសរបស់
បុគ្គលនោះរមែងពេញបរិបូណ៌ដូចជាព្រះចន្ទ្រក្នុងសុក្កបក្ស ។

[២១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាភត្តុទ្ទេសកៈ (អ្នកសម្តែងនូវភត្ត) ប្រកបដោយធម៌ ៤ យ៉ាង រមែងធ្លាក់ចុះទៅក្នុងនរកដូចជាគេនាំទៅទម្លាក់ ។

កតមេហិ ចតូហិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភត្តុទ្ទេសកោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភត្តុទ្ទេសកោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ចតូហិ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភត្តុទ្ទេសកោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

យេ កេចិ កាមេសុ អសញ្ញតា ជនា
អធម្មិកា ហោន្តិ អធម្មគារវា
ឆន្ទា ច ទោសា ច ភយា ច គាមិនោ
បរិសកសដោ[១] ច បនេស វុច្ចតិ

១ ឱ. បរិសក្កសាវោ ច ។

ចោល ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ គឺលុះអគតិ ព្រោះសេចក្តីស្រឡាញ់ ១ លុះអគតិ ព្រោះសេចក្តីស្អប់ ១ លុះអគតិ ព្រោះសេចក្តីល្ងង់ ១ លុះអគតិ ព្រោះសេចក្តីខ្លាច ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាភត្តុទ្ទេសកៈ ប្រកបដោយធម៌ ៤ យ៉ាងនេះឯង រមែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ចោល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាភត្តុទ្ទេសកៈប្រកបដោយធម៌ ៤ យ៉ាង រមែងទៅកើត ក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ គឺមិនលុះអគតិ ព្រោះសេចក្តីស្រឡាញ់ ១ មិនលុះអគតិ ព្រោះសេចក្តីស្អប់ ១ មិនលុះអគតិ ព្រោះសេចក្តីល្ងង់ ១ មិនលុះអគតិ ព្រោះសេចក្តីខ្លាច ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាភត្តុទ្ទេសកៈ ប្រកបដោយធម៌ ៤ យ៉ាងនេះ រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

ជនណានីមួយ មិនសង្រួមក្នុងកាម មិនប្រកបដោយធម៌ មិនគោរពក្នុងធម៌ លុះអគតិ ព្រោះសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីខ្លាច (សេចក្តីល្ងង់) ជននោះហៅថា ជាមនុស្សកាកក្នុងបរិសទ្យ

ឯវំ ហិ វុត្តំ សមណេន[១] ជានតា

តស្មា ហិ តេ សប្បុរិសា បសំសិយា

ធម្មេ ឋិតា យេ ន ករោន្តិ បាបកំ

ន ឆន្ទទោសា ន ភយា ច គាមិនោ[២] ។

បរិសាយ មណ្ឌោ ច បនេស វុច្ចតិ

ឯវំ ហិ វុត្តំ សមណេន ជានតាតិ ។

ចរវគ្គោ ទុតិយោ ។

តស្សុទ្ទានំ

ចារំ សីលំ បធានានិ

សំវរំ បញ្ញត្តិបញ្ចមំ

សោខុម្មំ តយោ អគតី

ភត្តុទ្ទេសេន តេ ទសាតិ ។

---

១ ឱ. សមណោ ។ ២ ម. ន ឆន្ទា ន ទោសា ន មោហា ន ភយា ច គាមិនោ ។

ព្រោះព្រះពុទ្ធសមណៈអ្នកត្រាស់ដឹង ទ្រង់សម្តែងទុកយ៉ាងនេះ ព្រោះហេតុនោះ ជនទាំងឡាយណាស្ថិតនៅក្នុងធម៌ មិនធ្វើអំពើលាមក មិនលុះអគតិ ព្រោះសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីខ្លាច (សេចក្តីល្ងង់) ជនទាំងនោះ ជាសប្បុរសដែលអ្នកប្រាជ្ញគប្បីសរសើរ ។ ជននោះ ហៅថា ជាអ្នកផូរផង់ក្នុងបរិសទ្យ ព្រោះព្រះពុទ្ធសមណៈអ្នកត្រាស់ដឹង ទ្រង់សម្តែងទុកហើយយ៉ាងនេះ ។

ចប់ ចរវគ្គ ទី ២ ។

# ឧទ្ទាននៃចរវគ្គនោះគឺ

និយាយអំពីការដើរជាដើម ១ អំពីសីល ១ អំពីសេចក្តីព្យាយាម ១ អំពីសេចក្តីសង្រួម ១ អគ្គប្បញ្ញត្តិមួយទៀតជាគម្រប់ ៥ អំពីញាណជាគ្រឿងកំណត់ដឹង នូវលក្ខណៈដ៏ល្អិត ១ អំពីអគតិមាន ៣ លើក និងភិក្ខុជាអ្នកសម្តែងនូវភត្តមួយទៀត ត្រូវជា ១០ ។

# ឧរុវេលវគ្គោ

[២២] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ឯកមិទាហំ ភិក្ខវេ សមយំ ឧរុវេលាយំ វិហរាមិ នជ្ជា នេរញ្ជរាយ តីរេ អជបាលនិគ្រោធេ បឋមាភិសម្ពុទ្ធោ ។ តស្ស មយ្ហំ ភិក្ខវេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ ទុក្ខំ ខោ[១] អគារវោ វិហរតិ អប្បតិស្សោ កិន្នុ ខោ អហំ សមណំ វា ព្រាហ្មណំ វា សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរេយ្យន្តិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ អបរិបូរស្ស ខោ មេ[២] សីលក្ខន្ធស្ស បារិបូរិយា អញ្ញំ សមណំ វា ព្រាហ្មណំ វា សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរេយ្យំ ន ខោ បនាហំ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ

១ ម. ខោសទ្ទោ នត្ថិ ។ ២ ឱ. ម. អហំ ។

# ឧរុវេលវគ្គ

[២២] សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះទទួលស្តាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សម័យមួយ តថាគតបានត្រាស់ដឹងជាដំបូងហើយ នៅក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលានិគមឯណោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ សម្ងំនៅក្នុងទីស្ងាត់ តែម្នាក់ឯង មានចិត្តត្រិះរិះយ៉ាងនេះថា បុគ្គលមិនមានសេចក្តីគោរពកោតក្រែង រមែងនៅបានទាំងលំបាកណាស់ តថាគតគួរចូលទៅ ធ្វើសក្ការៈ ធ្វើសេចក្តីគោរព សមណៈឬព្រាហ្មណ៍ ណាហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះថា តថាគតគប្បីចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរព សមណៈឬព្រាហ្មណ៍ឯទៀត ដើម្បីបំពេញនូវសីលក្ខន្ធ របស់តថាគតដែលមិនទាន់ពេញ តែក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្ស ជាសម្មតិទេពនិងមនុស្សដ៏សេស

អញ្ញំ សមណំ វា ព្រាហ្មណំ វា អត្តនា សីលសម្បន្នតរំ យមហំ សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរេយ្យំ អបរិបូរស្ស ខោ មេ សមាធិក្ខន្ធស្ស... បញ្ញាខន្ធស្ស... វិមុត្តិក្ខន្ធស្ស បារិបូរិយា អញ្ញំ សមណំ វា ព្រាហ្មណំ វា សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរេយ្យំ ន ខោ បនាហំ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អញ្ញំ សមណំ វា ព្រាហ្មណំ វា អត្តនា វិមុត្តិសម្បន្នតរំ យមហំ សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរេយ្យន្តិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ យន្នូនាហំ យោចាយំ[១] ធម្មោ មយា អភិសម្ពុទ្ធោ តមេវ ធម្មំ សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរេយ្យន្តិ ។ អថខោ ភិក្ខវេ ព្រហ្មា សហម្បតិ មម ចេតសា ចេតោ បរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរហិតោ មម បុរតោ បាតុរហោសិ ។

១ ម. យ្វាយំ ។

តថាគតមិនឃើញសមណៈឬព្រាហ្មណ៍ឯទៀត ដែលបរិបូណ៌ដោយសីល ជាងតថាគត គួរឲ្យតថាគតចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរពបានឡើយ នូវសមាធិក្ខន្ធរបស់តថាគតដែលមិនទាន់ពេញ... នូវបញ្ញាខន្ធ... តថាគត គួរចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរព សមណៈឬព្រាហ្មណ៍ឯទៀត ដើម្បីបំពេញវិមុត្តិក្ខន្ធ តែក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្ស ជាសម្មតិទេពនិងមនុស្សដ៏សេស តថាគតមិនឃើញសមណៈឬព្រាហ្មណ៍ឯទៀត ឲ្យបរិបូណ៌ដោយវិមុត្តិជាងតថាគត ល្មមឲ្យតថាគតចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរពបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះថា បើដូច្នោះ គួរតែតថាគត ចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរពធម៌ដែលតថាគតត្រាស់ដឹងហើយនោះ ។ ម្នាលភិក្ខុទាំង-ឡាយ គ្រានោះឯង សហម្បតិព្រហ្ម បានដឹងសេចក្តីត្រិះរិះក្នុងចិត្តរបស់តថាគតក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះមុខតថាគត ដូចជាបុរសមានកម្លាំង លាដៃដែលខ្ជួនបត់ ឬបត់ដៃដែលខ្ជួនលាចេញ ។

៥១



អថខោ ភិក្ខវេ ព្រហ្មា សហម្បតិ ឯកំសំ ឧត្ត-រាសង្គំ ករិត្វា ទក្ខិណជានុមណ្ឌលំ បឋវិយំ និហន្ត្វា[១] យេនាហំ តេនញ្ជលិំ បណាមេត្វា មំ ឯតទវោច ឯវមេតំ ភគវា ឯវមេតំ សុគត យេបិ តេ ភន្តេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេបិ ភគវន្តោ ធម្មំយេវ សក្កត្វា គរុំ កត្វា ឧប-និស្សាយ វិហរឹសុ យេបិ តេ ភន្តេ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេបិ ភគវន្តោ ធម្មំយេវ សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរិស្សន្តិ ភគវាបិ ភន្តេ ឯតរហិ អរហំ សម្មាសម្ពុទ្ធោ ធម្មំ-យេវ សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរតូតិ ។ ឥទមវោច ព្រហ្មា សហម្បតិ ឥទំ វត្វា អថាបរំ ឯតទវោច

យេ ច អតីតា[២] សម្ពុទ្ធា
យេ ច ពុទ្ធា អនាគតា

---

១ ម. និហន្តា ។ ២ ឱ. ម. យេ ចព្ភតីតា ។

ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សហម្បតិព្រហ្ម បង់កសំពត់ឆៀងស្មា ម្ខាងលុតជង្គង់ខាងស្តាំលើប្រថពីប្រណម្យអញ្ជលីចំពោះតថាគត និយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះដ៏មានព្រះភាគ ការណ៍នុ៎ះយ៉ាងនេះហើយ បពិត្រព្រះសុគត ការណ៍នុ៎ះយ៉ាងនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធទាំងឡាយណាមានហើយ ក្នុងកាលអតីតក្តី ព្រះដ៏មានព្រះភាគទាំងឡាយនោះ ចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរព ចំពោះធម៌តែប៉ុណ្ណោះ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា នឹងមានក្នុងកាលអនាគតក្តី ព្រះដ៏មានព្រះភាគទាំងឡាយនោះ នឹងចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរពចំពោះព្រះធម៌ដែរ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធក្នុងកាលឥឡូវនេះ ចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរពចំពោះព្រះធម៌ដែរចុះ ។ សហម្បតិព្រហ្មបានពោលពាក្យនេះហើយ លុះពោលពាក្យនេះហើយ ក៏ពោលពាក្យជាគាថាពន្ធ យ៉ាងនេះតទៅទៀតថា

ព្រះសម្ពុទ្ធទាំងឡាយណា ក្នុងកាលជាអតីតក្តី
ព្រះសម្ពុទ្ធទាំងឡាយណា ក្នុងកាលអនាគតក្តី

យោ ចេតរហិ សម្ពុទ្ធោ
ពហុន្នំ សោកនាសនោ
សព្វេ សទ្ធម្មគរុនោ
វិហរឹសុ វិហរន្តិ(១) ច
អថាបិ វិហរិស្សន្តិ
ឯសា ពុទ្ធានធម្មតា
តស្មា ហិ អត្តកាមេន
មហត្តមភិកង្ខតា
សទ្ធម្មោ គរុកាតព្វោ
សរំ ពុទ្ធានសាសនន្តិ ។

ឥទមវោច ភិក្ខវេ ព្រហ្មា សហម្បតិ ឥទំ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ។ ឥធខ្វាហំ(២) ភិក្ខវេ ព្រហ្មុនោ អជ្ឈេសនំ វិទិត្វា អត្តនោ ច បដិរូបំ យោថាយំ ធម្មោ មយា អភិ-សម្ពុទ្ធោ តមេវ ធម្មំ សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហាសឹ យតោ ច ខោ ភិក្ខវេ សង្ឃោបិ មហត្តេន សមន្នាគតោ អថ មេ សង្ឃេបិ គារវោតិ(៣)

១ វិហាតិ ចាតិប្បត្តិ ។ ២ ឱ. ម. អថខ្វាហំ ។ ៣ ឱ. តិព្វគារវោតិ ។

ព្រះសម្ពុទ្ធណា ក្នុងកាលឥឡូវនេះក្តី ព្រះអង្គបាន
ញុំាងសេចក្តីសោក របស់ពួកជនច្រើន ឲ្យវិនាស
ព្រះសម្ពុទ្ធគ្រប់អង្គនោះ គោរពព្រះសទ្ធម្មហើយផង
កំពុងគោរពព្រះសទ្ធម្មផង នឹងគោរពព្រះសទ្ធម្ម
ផង នេះជាធម្មតា របស់ព្រះពុទ្ធទាំងឡាយ ហេតុ
នោះ បុគ្គលអ្នកត្រូវការប្រយោជន៍ផ្ទាល់ខ្លួន ប្រាថ្នា
នូវភាវៈនៃខ្លួនជាធំ កាលរលឹកពាក្យប្រៀនប្រដៅ
របស់ព្រះពុទ្ធទាំងឡាយ ត្រូវតែគោរពព្រះសទ្ធម្ម ។

ម្នាលភិក្ខុទាំងឡាយ សហម្បតិព្រហ្ម បាននិយាយពាក្យនេះ លុះនិយាយពាក្យនេះហើយ ក៏ថ្វាយបង្គំតថាគត រួចធ្វើប្រទក្សិណហើយបាត់ពីទីនោះទៅ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានដឹងច្បាស់នូវការនិមន្តរបស់សហម្បតិព្រហ្មផង នូវការដ៏សមគួរដល់តថាគតផង ក្នុងទីឯណោះហើយ ក៏ធ្វើសក្ការៈ ធ្វើសេចក្តីគោរព ចំពោះធម៌ដែលតថាគតត្រាស់ដឹងហើយនោះ ម្នាលភិក្ខុទាំងឡាយ បើសង្ឃដែលប្រកបដោយគុណដ៏ធំ ក្នុងកាលណា កាលនោះតថាគតមានសេចក្តីគោរពចំពោះសង្ឃដែរ ។

[២៣] ឯកមិទាហំ ភិក្ខវេ សមយំ ឧរុវេលាយំ វិហរាមិ នជ្ជា នេរញ្ជរាយ តីរេ អជបាលនិគ្រោធេ បឋមាភិសម្ពុទ្ធោ ។ អថ ខោ ភិក្ខវេ សម្ពហុលា ព្រាហ្មណា ជិណ្ណា វុឌ្ឍា មហល្លកា អទ្ធគតា វយោ-អនុប្បត្តា យេនាហំ តេនុបសង្កមឹសុ ឧបសង្កមិត្វា មយា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ ភិក្ខវេ តេ ព្រាហ្មណា មំ ឯតទវោចុំ សុតំ មេតំ[១] ភោ គោតម ន សមណោ គោតមោ ព្រាហ្មណេ ជិណ្ណេ វុឌ្ឍេ មហល្លកេ អទ្ធគតេ វយោអនុប្បត្តេ អភិវាទេតិ វា បច្ចុដ្ឋេតិ វា អាសនេន វា និមន្តេតីតិ តយិទំ ភោ គោតម តថេវ ន ហិ ភវំ គោតមោ

---

១ កត្ថចិ សុតំ នេតន្តិ ទិស្សតិ ។

[២៣] ម្នាលភិក្ខុទាំងឡាយ សម័យមួយ កាលតថាគត ទើបនឹងបាន ត្រាស់ដឹងជាដំបូង នៅក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាឯណោះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកព្រាហ្មណ៍ ច្រើនគ្នា ចាស់គ្រាំគ្រា ព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅយូរឆ្នាំមក ហើយ មានអាយុក៏ជ្រុលចូលមក ក្នុងបច្ឆិមវ័យហើយ បានចូលទៅរក តថាគត លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងតថាគត លុះបញ្ចប់ពាក្យ ដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយ ក្នុងទីសមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកព្រាហ្មណ៍ទាំងនោះ អង្គុយ ក្នុងទីដ៏សមគួរហើយ បាននិយាយនឹងតថាគតដូច្នេះថា បពិត្រ ព្រះគោតមដ៏ចម្រើន យើងខ្ញុំបានឮយ៉ាងនេះថា ព្រះសមណគោតម មិនសំពះ មិនក្រោកទទួល ពួកព្រាហ្មណ៍ ដែលចាស់គ្រាំគ្រា ព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុ ក៏ជ្រុលចូល មក ក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅរក នូវព្រាហ្មណ៍ ទាំងនោះឲ្យអង្គុយលើអាសនៈ (ព្រះអង្គក៏មិនធ្វើផង) បពិត្រព្រះគោតមដ៏ ចម្រើន ពាក្យដែលយើងខ្ញុំបានឮមកនោះជាប្រាកដថា ព្រះគោតមដ៏ចម្រើន

ព្រាហ្មណោ ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ អភិវាទេតិ វា បច្ចុដ្ឋេតិ វា អាសនេន វា និមន្តេតិ តយិទំ ភោ គោតម ន សម្បន្នមេវាតិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ នចយិមេ[១] អាយស្មន្តោ ជានន្តិ ថេរំ វា[២] ថេរករណេ វា ធម្មេតិ វុឌ្ឍោ ចេបិ ភិក្ខវេ ហោតិ អសីតិកោ វា នវុតិកោ វា វស្សសតិកោ វា ជាតិយា សោ ច ហោតិ អកាលវាទី អភូតវាទី អនត្ថវាទី អធម្មវាទី អវិនយវាទី អនិធានវតឹ វាចំ ភាសិតា អកាលេន អនបទេសំ អបរិយន្តវតឹ អនត្ថសញ្ហិតំ អថខោ សោ ពាលោ ថេរោត្វេវ សង្ខំ គច្ឆតិ ទហរោ ចេបិ ភិក្ខវេ ហោតិ យុវា សុសូ កាឡកេសោ ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា សោ ច ហោតិ

១ ឱ. ន វត មេ ។ ម. ន យិមេ ។ ២ ម. ថេរេ ច ។

មិនសំពះ មិនក្រោកទទួលពួកព្រាហ្មណ៍ ដែលចាស់គ្រាំគ្រា ព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅយូរឆ្នាំមកហើយ មានអាយុ ក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយថា សូម្បីត្រឹមតែអញ្ជើញហៅរកពួកព្រាហ្មណ៍ ទាំងនោះឲ្យអង្គុយលើអាសនៈ (ព្រះអង្គក៏មិនធ្វើ) បពិត្រព្រះគោតមដ៏ចម្រើន កិច្ចមានការមិនសំពះជាដើមនោះ ជាទំនងពុំសមគួរឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា អ្នកដ៏មានអាយុទាំងឡាយនេះ មិនស្គាល់នូវបុគ្គលចាស់ផង នូវធម៌ទាំងឡាយដែលធ្វើខ្លួនឲ្យជាបុគ្គលចាស់ផង ម្នាលភិក្ខុទាំងឡាយ បើបុគ្គលចម្រើនដោយវ័យ តាំងពីកើតមកមានអាយុ ៨០ ឆ្នាំក្តី ៩០ ឆ្នាំក្តី ១០០ ឆ្នាំក្តី តែបុគ្គលនោះ ជាអ្នកនិយាយខុសកាល និយាយពាក្យមិនពិត និយាយពាក្យឥតប្រយោជន៍ និយាយពាក្យមិនមែនធម៌ និយាយពាក្យមិនមែនវិន័យ និយាយពាក្យដែលមិនគួរឲ្យតម្កល់ទុកក្នុងហឫទ័យ ខុសកាល ប្រាសចាកគ្រឿងអាង ជាពាក្យមិនមានទីបំផុត មិនប្រកបដោយប្រយោជន៍ កាលបើដូច្នោះ បុគ្គលពាលនោះក៏ដល់នូវការរាប់ថាជាបុគ្គលចាស់ខ្លៅ ម្នាលភិក្ខុទាំងឡាយ បុគ្គលនៅក្មេងកម្លោះជំទង់ មានសក់ខ្មៅប្រកបដោយវ័យចម្រើន គឺបឋមវ័យមែន តែបុគ្គលនោះ

កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធានវតឹ វាចំ ភាសិតា កាលេន សាបទេសំ បរិយន្តវតឹ អត្ថ-សញ្ហិតំ អថខោ សោ បណ្ឌិតោ ថេរោត្វេវ សង្ខំ គច្ឆតិ ។ ចត្តារោមេ ភិក្ខវេ ថេរករណា ធម្មា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរ-សម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសាន-កល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុ-បេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ចតុន្នំ ឈានានំ អភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាម-លាភី ហោតិ អកិច្ឆលាភី អកសិរលាភី

ជាអ្នកនិយាយពាក្យត្រូវកាល និយាយពាក្យពិត និយាយពាក្យជាប្រយោជន៍ និយាយពាក្យជាធម៌ និយាយពាក្យជាវិន័យ និយាយសម្ដីគួរតម្កល់ទុកក្នុងហឫទ័យ ត្រូវតាមកាល មានគ្រឿងអាង មានទីបំផុត ប្រកបដោយប្រយោជន៍ កាលបើដូច្នោះ បុគ្គលនោះក៏រាប់ថាជាចាស់ចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ នេះជាធម៌សម្រាប់ធ្វើឲ្យជាថេរៈ (បុគ្គលចាស់) ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរៈ ឃើញភ័យក្នុងទោសគ្រាន់តែបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សូត ទ្រទ្រង់សុតៈមិនភ្លេច សន្សំទុកនូវសុតៈ ពួកធម៌ណា មានលម្អបទខាងដើម លម្អបទកណ្ដាល លម្អបទចុង ប្រកាសនូវព្រហ្មចារ្យដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ប្រកបដោយអត្ថព្រមទាំងព្យញ្ជនៈ ធម៌ទាំងឡាយ មានសភាពដូច្នោះ ភិក្ខុនោះ ចេះចាំច្រើន ទ្រទ្រង់ រត់មាត់ពិចារណាបានតាមចិត្ត ដឹងដោយប្រពៃដោយទិដ្ឋិគឺបញ្ញា ១ ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយមិនខុសវេលា នូវឈានទាំង ៤ ដែលកើត ក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១

អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេ ខោ[១] ភិក្ខវេ ចត្តារោ វេសារជ្ជករណា ធម្មាតិ ។

យោ ឧទ្ធតេន ចិត្តេន
សម្ផញ្ច ពហុភាសតិ
អសមាហិតសង្កប្បោ
អសទ្ធម្មរតោ មគោ[២]
អារកា សោ ថាវរេយ្យម្ហា
បាបទិដ្ឋិ អនាទរោ[៣] ។
យោ ច សីលេន សម្បន្នោ
សុតវា បដិភាណវា
សំយុត្តោ ធីរធម្មេសុ[៤]
បញ្ញាយត្ថំ វិបស្សតិ
បារគូ សព្វធម្មានំ
អខិលោ បដិភាណវា ។

---

១ ឱ. ឥមេ ហិ ខោ ។ ២ ឱ. ម. មគោ ។ ៣ ម. អនាទរេ ។ ៤ ឱ. ម. សញ្ញតោ ធីរោ ធម្មេសុ ។

ជាអ្នកធ្វើឲ្យជាក់ច្បាស់ បានដល់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ នេះ ជាធម៌ធ្វើឲ្យបានឋានៈជាថេរៈ ។

អ្នកណា មានចិត្តអណ្តែតអណ្តូង ច្រើនតែនិយាយពាក្យឥតប្រយោជន៍ មានគំនិតមិនតម្កល់ស៊ប់សួន មិនត្រេកអរនឹងព្រះសទ្ធម្ម ប្រហែលគ្នានឹងសត្វម្រឹគ អ្នកដែលមានទិដ្ឋិដ៏លាមក មិនមានសេចក្តីអើពើនោះ (តែងតែ) ឆ្ងាយចាកសភាវៈមាំទាំ ។ បើអ្នកណា បរិបូណ៌ដោយសីល មានសុតៈ មានសេចក្តីឆ្លៀវឆ្លាស ប្រកបក្នុងធម៌ទាំងឡាយ ដែលធ្វើឲ្យជាថេរៈ ឃើញច្បាស់នូវសេចក្តីនៃសច្ចៈទាំង ៤ ដោយមគ្គប្បញ្ញាព្រមទាំងវិបស្សនា ជាអ្នកឆ្លងផុតនូវធម៌ទាំងអស់ (មានខន្ធជាដើម) បានមានចិត្តមិនជាប់ចំពាក់ (មានការមិនជាប់ចំពាក់ព្រោះរាគៈជាដើម) បរិបូណ៌ដោយសេចក្តីឆ្លៀវឆ្លាស ។

បហីនជាតិមរណោ
ព្រហ្មចរិយស្ស កេវលី
តមហំ វទាមិ ថេរោតិ
យស្ស នោ សន្តិ អាសវា
អាសវានំ ខយា ភិក្ខុ
សោ[១] ថេរោតិ បវុច្ចតីតិ ។

[២៤] លោកោ ភិក្ខវេ តថាគតេន អភិសម្ពុទ្ធោ លោកស្មា តថាគតោ វិសំយុត្តោ លោកសមុទយោ ភិក្ខវេ តថាគតេន អភិសម្ពុទ្ធោ លោកសមុទយោ តថាគតស្ស បហីនោ លោកនិរោធោ ភិក្ខវេ តថាគតេន អភិសម្ពុទ្ធោ លោកនិរោធោ តថាគតស្ស សច្ឆិកតោ លោកនិរោធគាមិនី បដិបទា ភិក្ខវេ តថាគតេន អភិសម្ពុទ្ធា លោកនិរោធគាមិនី បដិបទា តថាគតស្ស ភាវិតា ។ យំ ភិក្ខវេ សទេវកស្ស លោកស្ស សមារកស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ

១ ម. សោសទ្ធោ នត្ថិ ។

អ្នកណា លះបង់ជាតិនិងមរណៈបានហើយ មានព្រហ្ម-
ចារ្យ គ្រប់គ្រាន់ តថាគតហៅអ្នកនោះ ថាជាថេរៈ
ភិក្ខុណា មិនមាន អាសវៈទាំងឡាយ ព្រោះអស់អាសវៈ
ទាំងឡាយ តថាគត ហៅភិក្ខុនោះ ថាជាថេរៈ ។

[២៤] ម្នាលភិក្ខុទាំងឡាយ លោក (គឺទុក្ខសច្ច) តថាគតបានត្រាស់ដឹងហើយ តថាគតផុតចាកលោក (គឺទុក្ខសច្ច) ហើយ ម្នាលភិក្ខុទាំងឡាយ លោកសមុទយៈ តថាគតបានត្រាស់ដឹងហើយ លោកសមុទយៈ តថាគតបានលះបង់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធៈតថាគតបានត្រាស់ដឹងហើយ លោកនិរោធៈតថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធគាមិនីបដិបទា តថាគតបានត្រាស់ដឹងហើយ លោកនិរោធគាមិនីបដិបទា តថាគតបានចម្រើនហើយ ។ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណា ដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដែលពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្ស ជាសម្មតិទេពនិងមនុស្សដ៏សេស ឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់

បត្តំ បរិយេសិតំ អនុវិចរិតំ មនសា សព្វំ[១] តំ តថាគតេន អភិសម្ពុទ្ធំ តស្មា តថាគតោតិ វុច្ចតិ ។ យញ្ច ភិក្ខវេ រត្តឹ តថាគតោ អភិសម្ពុជ្ឈតិ យញ្ច រត្តឹ បរិនិព្វាយតិ យំ ឯតស្មឹ អន្តរេ ភាសតិ លបតិ និទ្ទិសតិ សព្វន្តំ តថេវ ហោតិ នោ អញ្ញថា តស្មា តថាគតោតិ វុច្ចតិ ។ យថាវាទី ភិក្ខវេ តថាគតោ តថាការី យថាការី តថាវាទី ឥតិ យថាវាទី តថាការី យថាការី តថាវាទី តស្មា តថាគតោតិ វុច្ចតិ ។ សទេវកេ ភិក្ខវេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ តថាគតោ អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តិ តស្មា តថាគតោតិ វុច្ចតីតិ ។

សព្វលោកំ អភិញ្ញាយ
សព្វលោកេ យថាតថំ
សព្វលោកវិសំយុត្តោ
សព្វលោកេ អនុស្សយោ[២]
សវេ សព្វាភិភូ ធីរោ

១ ឱ. ម. សព្វំ ។ ២ ឱ. ម. អនុប្បយោ ។

បានដល់ ស្វែងរក ត្រិះរង្គាត់រក អារម្មណ៍នោះ តថាគតបានដឹងជាក់ស្តែង ហើយដោយសារចិត្ត ព្រោះហេតុនោះបានជាគេហៅថា តថាគត ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានត្រាស់ ក្នុងរាត្រីណា បរិនិព្វាន ក្នុងរាត្រីណា តែងពោលចរចា សម្តែងចេញនូវវាចាណា ក្នុងចន្លោះនោះ កិច្ចមានការត្រាស់ដឹងជាដើមទាំងនោះ ដូច្នោះមែន មិនមែនជាមិនមែនទេ ព្រោះហេតុនោះ បានជាគេហៅថា តថាគត ។ ម្នាលភិក្ខុទាំងឡាយ តថាគតថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ហេតុនោះ ទើបបានជាគេហៅថា តថាគត ។ ម្នាលភិក្ខុទាំងឡាយ តថាគត ជាអ្នកគ្របសង្កត់ អង់អាច ជាអ្នកឃើញពិត មានអំណាចគ្របសង្កត់លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្ស ជាសម្មតិទេពនិងមនុស្សដ៏សេសបាន ហេតុនោះ បានជាគេហៅថា តថាគត ។

បុគ្គលណា ដឹងច្បាស់នូវលោកទាំងអស់ ដឹងច្បាស់
ក្នុងលោកទាំងអស់ តាមពិត ផុតចាកលោកទាំងអស់
មិនមានការកពូន ក្នុងលោកទាំងអស់ បុគ្គលនោះ
ឯង ជាអ្នកប្រាជ្ញ គ្របសង្កត់នូវអារម្មណ៍ទាំងអស់បាន

៤៩



សព្វគន្ថប្បមោចនោ
ផុដ្ឋស្ស បរមា សន្តិ
និព្វានំ អកុតោ ភយំ
ឯស ខីណាសវោ ពុទ្ធោ
អនិឃោ ឆិន្នសំសយោ
សព្វកម្មក្ខយំ បត្តោ
វិមុត្តោ ឧបធិសង្ខយេ
ឯវំ សោ[១] ភគវា ពុទ្ធោ
ឯស សីហោ អនុត្តរោ
សទេវកស្ស លោកស្ស
ព្រហ្មចក្កំ បវត្តយិ ។
ឥតិ ទេវា មនុស្សា ច
យេ ពុទ្ធំ សរណំ គតា
សង្គម្ម តំ នមស្សន្តិ
មហន្តំ វីតសារទំ ។

---

១ ឱ. ម. ឯស សោ ។

ជាអ្នករួចចាកគន្ថៈទាំងអស់ ព្រះនិព្វាន បុគ្គលនោះពាល់ត្រូវហើយ ព្រះនិព្វានមិនមានភ័យមកពីណាទេ បុគ្គលនោះជាខីណាសវៈ បានត្រាស់ដឹងហើយ ជាអ្នកមិនមានទុក្ខ អ្នកផ្តាច់នូវសេចក្តីសង្ស័យហើយ ដល់នូវការអស់ទៅនៃកម្ម ទាំងអស់រួចស្រឡះ (ដោយផលវិមុត្តិ ដែលមានអារម្មណ៍) ក្នុងធម៌ជាគ្រឿងអស់ទៅនៃឧបធិក្កិលេស បុគ្គលនោះជាភគវន្ត អ្នកត្រាស់ដឹង បុគ្គលនេះជាសីហៈ មិនមានបុគ្គលដទៃស្មើ ញុំាំងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅក្នុងលោកព្រមទាំងទេវលោកដោយប្រការដូច្នេះឯង ។ ពួកទេវតានិងពួកមនុស្សដែលបានដល់ព្រះពុទ្ធ ជាទីរលឹក តែងនាំគ្នាមកនមស្ការព្រះតថាគតនោះ អ្នកមានគុណធំប្រាសចាកសេចក្តីញញើតញញើម ។

ទន្តោ សមយតំ សេដ្ឋោ
សន្តោ ឧមយតំ ឥសិ
មុត្តោ មោចយតំ អគ្គោ
តិណ្ណោ តារយតំ វរោ
ឥតិ ហេតំ នមស្សន្តិ
មហន្តំ វីតសារទំ ។
សទេវកស្មឹ លោកស្មឹ
នត្ថិ មេ បដិបុគ្គលោតិ ។

[២៨] ឯកំ សមយំ ភគវា សាកេតេ វិហរតិ កាឡកាភមេ[១] ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច យំ ភិក្ខវេ សទេវកស្ស លោកស្ស សមារកស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ

១ ម. កាឡិការាមេ ។

តថាគតមានខ្លួនទូន្មានល្អហើយ ប្រសើរជាងពួកបុគ្គលអ្នកទូន្មានខ្លួន ពុទ្ធឥសី ដែលមានចិត្តស្ងប់រម្ងាប់ហើយ ប្រសើរជាងពួកបុគ្គលអ្នកទូន្មានខ្លួន តថាគតមានចិត្តផុតស្រឡះហើយ ខ្ពង់ខ្ពស់ជាងពួកបុគ្គលអ្នកមានចិត្តផុតស្រឡះហើយ តថាគតឆ្លងផុតហើយប្រសើរជាងពួកបុគ្គលអ្នកឆ្លង ពួកទេវតានិងមនុស្ស តែងនាំគ្នាមកនមស្ការ តថាគតនោះមានគុណដ៏ធំប្រាសចាកសេចក្តីញញើតញញើម ដោយប្រការដូច្នេះ ។ ក្នុងលោកនេះព្រមទាំងទេវលោក មិនមានបុគ្គលប្រៀបនឹងតថាគតបានទេ ។

[២៤] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកាឡការាម ជិតក្រុងសាកេត ។ ក្នុងទីនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណា ដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោកនិងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស បានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់

៦១

បឋមបណ្ណាសកេ ឧរុវេលវគ្គោ

បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តមហំ ជានាមិ យំ ភិក្ខវេ សទេវកស្ស លោកស្ស សមារកស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តមហំ អព្ភញ្ញាសឹ តំ តថាគតស្ស វិទិតំ តំ តថាគតេ ន ឧបដ្ឋាសិ[១] ។ យំ ភិក្ខវេ សទេវកស្ស លោកស្ស... ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តមហំ ជានាមីតិ វទេយ្យំ តំ មមស្ស មុសា... តមហំ ជានាមិ ច ន ច ជានាមីតិ វទេយ្យំ តំ បិស្ស[២] តាទិសមេវ... តមហំ នេវ ជានាមិ ន ន ជានាមីតិ វទេយ្យំ តំ មមស្ស កលិ ឥតិ ខោ ភិក្ខវេ តថាគតោ ទិដ្ឋា ទដ្ឋព្វំ ទិដ្ឋំ ន មញ្ញតិ អទិដ្ឋំ ន មញ្ញតិ ទដ្ឋព្វំ ន មញ្ញតិ

---

១ ឱ. ម. តថាគតោ ន ឧបដ្ឋាសិ ។ ២ ម. តំ មមស្ស ។

បានដល់ ស្វែងរក ពិចារណារឿយ ៗ ដោយចិត្ត តថាគតដឹងច្បាស់នូវអារម្មណ៍នោះ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោកនិងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ និងមនុស្ស ជាសម្មតិទេពនិងមនុស្សដ៏សេស បានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ពិចារណារឿយ ៗ ដោយចិត្ត តថាគតដឹងនូវអារម្មណ៍នោះ ឯអារម្មណ៍នោះ តថាគតដឹងប្រាកដហើយ អារម្មណ៍នោះមិនឋិតនៅ ក្នុងតថាគតទេ ។ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណា ដែលលោកព្រមទាំងទេវលោក.... បានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ពិចារណារឿយ ៗ ដោយចិត្ត ប្រសិនបើ តថាគតពោលថា អាត្មាអញ ដឹងនូវអារម្មណ៍នោះ ពាក្យនោះ គប្បីជាពាក្យកុហករបស់តថាគត... ប្រសិនបើតថាគតពោលថា អាត្មាអញដឹងខ្លះ មិនដឹងខ្លះនូវអារម្មណ៍នោះ ពាក្យនោះ គប្បីជាពាក្យកុហកដែរ... ប្រសិនបើតថាគតពោលថា អាត្មាអញ មិនមែនដឹង មិនមែនជាមិនដឹង នូវអារម្មណ៍នោះ ពាក្យនោះ គប្បីជាទោសរបស់តថាគត ម្នាលភិក្ខុទាំងឡាយ តថាគតមិនសម្គាល់នូវអារម្មណ៍ ដែលមហាជនឃើញហើយ ថាគួរឃើញ ព្រោះបានឃើញ មិនសម្គាល់នូវអារម្មណ៍ ដែលមហាជនមិនឃើញ មិនសម្គាល់នូវអារម្មណ៍ ដែលមហាជន គប្បីឃើញ

ទដ្ឋានំ[១] ន មញ្ញតិ សុតា[២] សោតព្វំ សុតំ ន មញ្ញតិ អស្សុតំ ន មញ្ញតិ សោតព្វំ ន មញ្ញតិ សុតានំ[៣] ន មញ្ញតិ មុតា[៤] មោតព្វំ មុតំ ន មញ្ញតិ អមុតំ ន មញ្ញតិ មោតព្វំ ន មញ្ញតិ មុតានំ[៥] ន មញ្ញតិ វិញ្ញាតា[៦] វិញ្ញាតព្វំ វិញ្ញាតំ ន មញ្ញតិ អវិញ្ញាតំ ន មញ្ញតិ វិញ្ញាតព្វំ ន មញ្ញតិ វិញ្ញាតានំ[៧] ន មញ្ញតិ ឥតិ ខោ ភិក្ខវេ តថាគតោ ទិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ តាទិសោ[៨] វ តាទី តម្ហា ច បន តាទិម្ហា អញ្ញោ តាទី ឧត្តរិតរោ វា បណីតតរោ វា នត្ថីតិ វទាមីតិ ។

យំ កិញ្ចិ ទិដ្ឋំ ច សុតំ មុតំ វា
អជ្ឈោសិតំ សច្ចមុតំ[៩] បរេសំ ។

---

១ ឱ. ទដ្ឋារំ ។ ២ ឱ. ម. សុត្វា ។ ៣ ឱ. សោតារំ ។ ៤ ឱ. ម. មុត្វា ។ ៥ ឱ. មោតារំ ។ ម. មោតានំ ។ ៦ ឱ. ម. វិញ្ញត្វា ។ ៧ ឱ. វិញ្ញាតារំ ។ ៨ ឱ. តាទិសេយេវ ។ ម. តាទិយេវ តាទីយេវេកា ។ ៩ ម. សច្ចំមុសា ។

មិនសម្គាល់នូវបុគ្គលអ្នកឃើញ មិនសម្គាល់នូវសំឡេង ដែលមហាជន ឮ ហើយថា គួរឮ ព្រោះបានឮ មិនសម្គាល់នូវសំឡេង ដែលមហាជន មិនបានឮ ហើយមិនសម្គាល់នូវសំលេង ដែលមហាជនត្រូវឮ មិន សម្គាល់នូវបុគ្គលអ្នកឮសំឡេង មិនសម្គាល់នូវអារម្មណ៍ ដែលមហាជន ពាល់ត្រូវហើយ ថា គួរពាល់ត្រូវ ព្រោះបានពាល់ត្រូវ មិនសម្គាល់នូវ អារម្មណ៍ ដែលមហាជនមិនពាល់ត្រូវហើយ មិនសម្គាល់នូវអារម្មណ៍ ដែលមហាជនគប្បីពាល់ត្រូវ មិនសម្គាល់នូវបុគ្គលអ្នកពាល់ត្រូវ មិនសំ-គាល់នូវអារម្មណ៍ ដែលមហាជនដឹងច្បាស់ហើយ ថា គួរដឹងច្បាស់ ព្រោះ បានដឹងច្បាស់ មិនសម្គាល់នូវអារម្មណ៍ ដែលមហាជន មិនដឹងច្បាស់ មិនសម្គាល់នូវអារម្មណ៍ ដែលមហាជនត្រូវដឹងច្បាស់ មិនសម្គាល់នូវបុគ្គល អ្នកដឹងច្បាស់ ម្នាលភិក្ខុទាំងឡាយ តថាគត ជាតាទិបុគ្គលប្រាកដដូចនោះ ក្នុងធម៌គឺអារម្មណ៍ទាំងឡាយ ដែលមហាជនត្រូវឃើញ ឮ ពាល់ត្រូវ ដឹង ច្បាស់ តថាគតហៅថា តាទិបុគ្គលឯទៀត មិនថ្លៃថ្នូរផង មិនវិសេស វិសាលផង ជាងតថាគត ជាតាទិបុគ្គលនោះ ដោយប្រការដូច្នេះឡើយ ។

អារម្មណ៍ណាមួយ ដែលពួកជនបានឃើញក្តី បានឮ
ក្តី បានពាល់ត្រូវក្តី ដឹងច្បាស់ក្តី អារម្មណ៍នោះ ពួក
ជនដទៃ សម្គាល់ថាជារបស់ពិតហើយប្រកាន់មាំ ។

ន តេសុ តាទី សយសំវុតេសុ
សច្ចំ មុសា វាបិ[១] បរំ ទហេយ្យ ។
ឯតញ្ច សល្លំ បដិកច្ច[២] ទិស្វា
អជ្ឈោសិតា យត្ថ បជា វិសត្តា
ជានាមិ បស្សាមិ តថេវ ឯតំ
អជ្ឈោសិតំ នត្ថិ តថាគតានន្តិ ។

[២៦] នយិទំ ភិក្ខវេ ព្រហ្មចរិយំ វុស្សតិ ជនកុហនត្ថំ ន ជនលបនត្ថំ ន លាភសក្ការ-សិលោកានិសំសត្ថំ ន ឥតិវាទប្បមោក្ខានិសំសត្ថំ ន ឥតិ មំ ជនោ ជានាតូតិ ។ អថខោ ឥទំ ភិក្ខវេ ព្រហ្មចរិយំ វុស្សតិ សំវរត្ថំ បហានត្ថំ វិរាគត្ថំ និរោធត្ថន្តិ ។

១ ឱ. សច្ចំ មុសំ វាបិ ។ ២ ឱ. បដិគច្ច ។

បណ្ដាពួកជន សង្រួមដោយខ្លួនឯង ព្រះតថាគត ជាតាទិបុគ្គល មិនគប្បីជឿពាក្យដទៃ ដែលពិតក្ដី មិនពិតក្ដី ។ ពួកសត្វឃើញសរគឺទិដ្ឋិនោះមុនបំផុត ហើយជ្រុលជ្រប់ជាប់នៅ ក្នុងអារម្មណ៍ណា តថាគត ដឹងច្បាស់ ឃើញច្បាស់ នូវសរគឺអារម្មណ៍នោះដូច្នោះ សេចក្ដីជ្រុលជ្រប់ (ដោយសរគឺទិដ្ឋិ) នោះ មិន មានដល់ព្រះតថាគតទាំងឡាយឡើយ ។

[២៦] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ដើម្បីកុហកមហាជនក៏ទេ ដើម្បីល្បួងលួងមហាជនក៏ទេ ដើម្បីលាភសក្ការៈនិងសេចក្ដីសរសើរជាអានិសង្សក៏ទេ ដើម្បីបានអានិសង្សព្រោះការដោះនូវពាក្យជនដទៃដូច្នេះដូច្នោះថា មហាជន ចូរស្គាល់នូវតថាគតដូច្នេះក៏ទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រព្រឹត្តព្រហ្មចារ្យនេះ ដើម្បីសង្រួម ដើម្បីលះ ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់ទុក្ខ តែប៉ុណ្ណោះឯង ។

សំវរត្ថំ បហានត្ថំ ព្រហ្មចរិយំ អនីតិហំ[១]
អទេសយិ សោ ភគវា និព្វានោគធគាមិនំ
ឯស មគ្គោ មហន្តេហិ អនុយាតោ មហេសិភិ ។
យេ ច តំ បដិបជ្ជន្តិ យថា ពុទ្ធេន ទេសិតំ
ទុក្ខស្សន្តំ ករិស្សន្តិ សត្ថុសាសនការិនោតិ ។

[២៧] យេ តេ ភិក្ខវេ ភិក្ខូ កុហា ថទ្ធា លបា សិង្គី ឧន្នឡា អសមាហិតា ន មេ តេ ភិក្ខវេ ភិក្ខូ មាមកា អបគតា ច តេ ភិក្ខវេ ភិក្ខូ ឥមស្មា ធម្មវិនយា ន ច តេ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តិ ។ យេ ច ខោ តេ ភិក្ខវេ ភិក្ខូ និក្កុហា និល្លបា ធីរា អត្ថទ្ធា

១ ម. អនីតិយំ ។

ព្រះដ៏មានព្រះភាគនោះ ទ្រង់បានសម្តែងនូវព្រហ្មចារ្យ មិនបានជឿអ្នកដទៃ ដើម្បីសង្រួម ដើម្បីលះបង់ ជាដំណើរទៅ ក្នុងព្រះនិព្វាន ផ្លូវហ្នឹងដែលព្រះពុទ្ធជាចម្បងយាត្រាទៅ ។ បើពួកជនណា ដើរតាមផ្លូវដែលព្រះពុទ្ធសម្តែងហើយនោះ បើពួកជននោះ ធ្វើតាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តានោះ ទើបនឹងធ្វើទីបំផុតទុក្ខបាន ។

[២៧] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាជាអ្នកកុហក រឹងរូស រឡេះរឡោះ មានកិលេសលេចឡើងប្រាកដដូចជាស្នែង ដំឡើងមានះ មានចិត្តមិននឹងធឹង ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនោះ មិនមែនជាអ្នករាប់អានតថាគតទេ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនោះ ជាអ្នកប្រាសចាកធម្មវិន័យនេះ ពួកភិក្ខុទាំងនោះ មិនដល់នូវសេចក្តីចម្រើន ដុះដាលធំទូលាយ ក្នុងធម៌វិន័យនេះបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ជាអ្នកមិនកុហក មិនរឡេះរឡោះ ជាអ្នកខ្ជាប់ខ្ជួន មិនរឹងរូស

សុសមាហិតា តេ ខោ មេ ភិក្ខវេ ភិក្ខូ មាមកា
អនបគតា ច តេ ភិក្ខវេ ភិក្ខូ ឥមស្មា ធម្មវិនយា
តេ ច ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តីតិ ។

កុហា ថទ្ធា លចា សិង្គី ឧន្នឡា ចាសមាហិតា
ន តេ ធម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេ ។
និក្កុហា និល្លចា ធីរា អត្ថទ្ធា សុសមាហិតា
តេ វេ ធម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេតិ ។

[២៨] ចត្តារិមានិ ភិក្ខវេ អប្បានិ ច សុលភានិ ច តានិ ច អនវជ្ជានិ ។ កតមានិ ចត្តារិ ។ បំសុកូលំ ភិក្ខវេ ចីវរានំ អប្បញ្ច សុលភញ្ច តញ្ច អនវជ្ជំ បិណ្ឌិយាលោបោ ភិក្ខវេ ភោជនានំ អប្បញ្ច

មានចិត្តនឹងធឹង ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនោះ ឈ្មោះថាជាអ្នករាប់អានតថាគតផង ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនោះ មិនប្រាសចាកធម្មវិន័យនេះផង ពួកភិក្ខុទាំងនោះ តែងដល់នូវសេចក្ដីចម្រើនដុះដាលធំទូលាយ ក្នុងធម្មវិន័យនេះផង ។

ពួកភិក្ខុណា កុហក រឹងរូស រឡេះរឡោះ មាន
កិលេសលេចឡើងប្រាកដដូចជាស្នែង ដំឡើងមានះ
មានចិត្តមិននឹងធឹង ភិក្ខុទាំងនោះ រមែងមិនដុះដាល
ក្នុងធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងហើយទេ ។
ភិក្ខុណា ជាអ្នកមិនកុហក មិនរឡេះរឡោះ ជាអ្នកខ្ជាប់
ខ្ជួន មិនរឹងរូស មានចិត្តនឹងធឹង ភិក្ខុទាំងនោះ ទើបដុះ
ដាល ក្នុងធម៌ដែលព្រះសម្មាសម្ពុទ្ធសម្ដែងហើយ ។

[២៨] ម្នាលភិក្ខុទាំងឡាយ វត្ថុ ៤ យ៉ាងនេះជារបស់តិចផង បានដោយងាយផង មិនមានទោសផង ។ វត្ថុ ៤ តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាចីវរទាំងឡាយ បង្សុកូលចីវរជារបស់តិចផង បានដោយងាយផង មិនមានទោសផង ១ ម្នាលភិក្ខុទាំងឡាយ បណ្ដាភោជនទាំង-ឡាយ ដុំបាយដែលភិក្ខុបានដោយកម្លាំងនៃកំភួនជើង ជារបស់តិចផង

## ៦៦



សុលភញ្ច តញ្ច អនវជ្ជំ រុក្ខមូលំ ភិក្ខវេ សេនាសនានំ អប្បញ្ច សុលភញ្ច តញ្ច អនវជ្ជំ បូតិមុត្តំ ភិក្ខវេ ភេសជ្ជានំ អប្បញ្ច សុលភញ្ច តញ្ច អនវជ្ជំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អប្បានិ ច សុលភានិ ច តានិ ច អនវជ្ជានិ យតោ ខោ ភិក្ខវេ ភិក្ខុ អប្បេន ច សន្តុដ្ឋោ ហោតិ សុលភេន ច ឥទមស្សាហំ អញ្ញតរំ សាមញ្ញង្គន្តិ[១] វទាមីតិ ។

អនវជ្ជេន តុដ្ឋស្ស អប្បេន សុលភេន ច
ន សេនាសនមារព្ភ[២] ចីវរំ បានភោជនំ
វិឃាតោ ហោតិ ចិត្តស្ស ទិសា នប្បដិហញ្ញតិ ។

---
១ ឱ. ម. សាមញ្ញន្តិ ។ ២ ឱ. សេនាសនញ្ច អារព្ភ ។

បានដោយងាយផង មិនមានទោសផង ១ ម្នាលភិក្ខុទាំងឡាយ បណ្ដាសេនាសនៈទាំងឡាយ រុក្ខមូលសេនាសនៈ ជារបស់តិចផង បានដោយងាយផង មិនមានទោសផង ១ ម្នាលភិក្ខុទាំងឡាយ បណ្ដាភេសជ្ជៈទាំង-ឡាយ បូតិមុត្តភេសជ្ជៈជារបស់តិចផង បានដោយងាយផង មិនមានទោសផង ១ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុទាំង ៤ នេះជារបស់តិចផង បានដោយងាយផង មិនមានទោសផង ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុជាអ្នកសន្ដោសដោយវត្ថុតិចផង បានដោយងាយផង តថាគតហៅថា នេះជាអង្គរបស់សមណៈដ៏ប្រសើរ ។

សេចក្ដីចង្អៀតចង្អល់ចិត្ត តែងមិនមានដល់ភិក្ខុ
អ្នកត្រេកអរ ដោយរបស់មិនមានទោសផង តិច
ផង បានដោយងាយផង ព្រោះប្រារព្ធនូវ
សេនាសនៈផង ចីវរផង ភេសជ្ជៈផង ភោជនផង
ទាំងទិសក៏មិនបៀតបៀន[១] (ភិក្ខុនោះ) ។

១ មិនប្រាស់ប្រាលចិត្ត ព្រោះការស្វែងលាភក្នុងទិសផ្សេង ៗ ។ អដ្ឋកថា ។

យេចស្ស ធម្មា អក្ខាតា សាមញ្ញស្សានុលោមិកា
អជ្ឈគហិតា តុដ្ឋស្ស អប្បមត្តស្ស ភិក្ខុនោតិ ។

[២៩] ចត្តារោមេ ភិក្ខវេ អរិយវំសា អគ្គញ្ញា រត្តញ្ញា វំសញ្ញា ចោរាណា អសង្កិណ្ណា អសង្កិណ្ណាបុព្វា ន សង្កីយន្តិ ន សង្កីយិស្សន្តិ អប្បដិកុដ្ឋា សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរេន ចីវរេន ឥតរីតរចីវរសន្តុដ្ឋិយា ច វណ្ណវាទី ន ច ចីវរហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច ចីវរំ ន បរិតស្សតិ លទ្ធា ច ចីវរំ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ តាយ ច បន ឥតរីតរចីវរសន្តុដ្ឋិយា នេវត្តានុក្កំសេតិ នោ បរំ វម្ភេតិ ។

មួយទៀត ពួកធម៌ណា ដែលតថាគតសម្តែងហើយ ជាធម៌សមគួរ ដល់សមណភាព ធម៌នោះតាំងនៅ ខាងក្នុង (ចិត្ត) របស់ភិក្ខុ អ្នកមានសេចក្តីសន្តោស អ្នកមិនប្រមាទនោះ ។

[២៩] ម្នាលភិក្ខុទាំងឡាយ អរិយវង្ស ៤ យ៉ាងនេះ ជាច្បាប់ទម្លាប់ដឹងអស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរតាត់រតាយ មិនរាត់រាយ ដែលសមណព្រាហ្មណ៍ទាំងឡាយជាអ្នកប្រាជ្ញ មិនអាចតិះដៀលបាន ។ ៤ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោសដោយចីវរតាមមានតាមបាន ជាអ្នកសរសើរគុណនៃសេចក្តីសន្តោសដោយចីវរតាមមានតាមបាន មិនដល់នូវការស្វែងរកដ៏មិនសមគួរ ព្រោះហេតុតែចីវរ មិនប្រាស់ប្រាល់ព្រោះមិនបានចីវរ បានចីវរហើយមិនរីករាយ មិនជ្រុលជ្រប់ មិនទំរន់ឲ្យតណ្ហាគ្របសង្កត់ចិត្ត ជាអ្នកឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿងរលាស់ចេញ បរិភោគ មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់បុគ្គលដទៃ ព្រោះតែសេចក្តីសន្តោស ដោយចីវរតាមមានតាមបាននោះ ។

យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ បតិស្សតោ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ចោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរេន បិណ្ឌបាតេន ឥតរីតរបិណ្ឌបាតសន្តុដ្ឋិយា ច វណ្ណវាទី ន ច បិណ្ឌបាតហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច បិណ្ឌបាតំ ន បរិតស្សតិ លទ្ធា ច បិណ្ឌបាតំ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណប្បញ្ញោ បរិភុញ្ជតិ តាយ ច បន ឥតរី-តរបិណ្ឌបាតសន្តុដ្ឋិយា នេវត្តានុក្កំសេតិ នោ បរំ វម្ភេតិ ។ យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ បតិស្សតោ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ចោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរេន សេនាសនេន ឥតរីតរសេនាសនសន្តុដ្ឋិយា ច វណ្ណវាទី

មែនពិត ភិក្ខុណាឈ្វាសវៃ មិនខ្ជិលច្រអូស ជាអ្នកដឹងខ្លួន មានស្មារតីតម្កល់មាំ ក្នុងសេចក្តីសន្តោសនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា អ្នកតាំងនៅក្នុងអរិយវង្ស ជាច្បាប់ទម្លាប់ចាស់ ១ ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយបិណ្ឌបាតតាមមានតាមបាន ជាអ្នកសរសើរគុណនៃសេចក្តីសន្តោសដោយបិណ្ឌបាត មិនដល់នូវការស្វែងរកដ៏មិនសមគួរ ព្រោះហេតុតែបិណ្ឌបាត មិនច្រាស់ច្រាល់ ព្រោះតែមិនបានចង្ហាន់បិណ្ឌបាត បានចង្ហាន់បិណ្ឌបាតហើយ មិនរីករាយ មិនជ្រុលជ្រប់ មិនទំរន់ឲ្យតណ្ហាគ្របសង្កត់ ឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿងរលាស់ចេញ បរិភោគមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់បុគ្គលដទៃ ព្រោះតែសេចក្តីសន្តោសដោយបិណ្ឌបាតតាមមានតាមបាននោះឡើយ ។ មែនពិត ភិក្ខុណាឈ្វាសវៃ មិនខ្ជិលច្រអូស ជាអ្នកដឹងខ្លួន មានស្មារតីតម្កល់មាំ ក្នុងសេចក្តីសន្តោសនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា អ្នកតាំងនៅក្នុងអរិយវង្ស ជាច្បាប់ទម្លាប់ចាស់ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោស ដោយសេនាសនៈតាមមានតាមបាន ជាអ្នកសរសើរគុណនៃសេចក្តីសន្តោស ដោយសេនាសនៈតាមមានតាមបាន

ន ច សេនាសនហេតុ អនេសនំ អប្បដិរូបំ
អាបជ្ជតិ អលទ្ធា ច សេនាសនំ ន បរិតស្សតិ
លទ្ធា ច សេនាសនំ អគធិតោ អមុច្ឆិតោ
អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណប្បញ្ញោ
បរិភុញ្ជតិ តាយ ច បន ឥតរីតរសេនាសន-
សន្តុដ្ឋិយា នេវត្តានុក្កំសេតិ នោ បរំ វម្ភេតិ ។
យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ
បតិស្សតោ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ចោភណោ
អគ្គញ្ញេ អរិយវំសេ ឋិតោ ។ បុន ចបរំ ភិក្ខវេ
ភិក្ខុ ភាវនារាមោ ហោតិ ភាវនារតោ បហានារាមោ
ហោតិ បហានរតោ តាយ ច បន ភាវនារាមតាយ
ភាវនារតិយា បហានារាមតាយ បហានរតិយា
នេវត្តានុក្កំសេតិ នោ បរំ វម្ភេតិ ។ យោ ហិ តត្ថ ទក្ខោ
អនលសោ សម្បជានោ បតិស្សតោ អយំ វុច្ចតិ
ភិក្ខវេ ភិក្ខុ ចោភណោ អគ្គញ្ញេ អរិយវំសេ ឋិតោ ។

មិនដល់នូវការស្វែងរកដ៏មិនសមគួរ ព្រោះហេតុតែសេនាសនៈ មិនប្រាស់ប្រាល់ ព្រោះតែមិនបានសេនាសនៈ បានសេនាសនៈហើយ ក៏មិនរីករាយ មិនជ្រុលជ្រប់ មិនទំរន់ឲ្យតណ្ហាគ្របសង្កត់ ឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿងរលាស់ចេញ បរិភោគមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់បុគ្គលដទៃ ព្រោះតែសេចក្តីសន្តោស ដោយសេនាសនៈតាមមានតាមបាននោះឡើយ ។ មែនពិត ភិក្ខុណាឈ្លាសវៃ មិនខ្ជិលច្រអូស ជាអ្នកដឹងខ្លួន មានស្មារតីតម្កល់មាំ ក្នុងសេចក្តីសន្តោសនោះ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុនេះតថាគតហៅថា អ្នកតាំងនៅក្នុងអរិយវង្ស ជាច្បាប់ទម្លាប់ចាស់ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានការចម្រើនជាទីត្រេកអរ ជាអ្នកត្រេកអរក្នុងការចម្រើន មានការលះបង់កិលេសទាំងពួងជាទីត្រេកអរ ជាអ្នកត្រេកអរក្នុងការលះ មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់បុគ្គលដទៃ ព្រោះតែការចម្រើន ជាទីត្រេកអរ ត្រេកអរក្នុងការចម្រើន មានការលះជាទីត្រេកអរ ត្រេកអរក្នុងការលះនោះឡើយ ។ មែនពិត ភិក្ខុណាឈ្លាសវៃ មិនខ្ជិលច្រអូស ជាអ្នកដឹងខ្លួន មានស្មារតីតាំងមាំ ក្នុងការត្រេកអរនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា អ្នកតាំងនៅក្នុងអរិយវង្ស ជាច្បាប់ទម្លាប់ចាស់ ១ ។

ឥមេ ខោ ភិក្ខវេ ចត្តារោ អរិយវំសា អគ្គញ្ញា រត្តញ្ញា វំសញ្ញា បោរាណា អសង្កិណ្ណា អសង្កិណ្ណបុព្វា ន សង្កីយន្តិ ន សង្កីយិស្សន្តិ អប្បដិកុដ្ឋា សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ ឥមេហិ ច បន ភិក្ខវេ ចតូហិ អរិយវំសេហិ សមន្នាគតោ ភិក្ខុ បុរត្ថិមាយ ចេបិ ទិសាយ វិហរតិ ស្វេវ អរតឹ សហតិ ន តំ អរតិ សហតិ បច្ឆិមាយ ចេបិ ទិសាយ វិហរតិ... ឧត្តរាយ ចេបិ ទិសាយ វិហរតិ... ទក្ខិណាយ ចេបិ ទិសាយ វិហរតិ ស្វេវ អរតឹ សហតិ ន តំ អរតិ សហតិ ។ តំ កិស្ស ហេតុ ។ អរតិរតិសហោ ហិ ភិក្ខវេ ធីរោតិ ។

ធារតី សហតី ធីរំ  ធារតី ធីរ សំហតិ[១]

ធីរោ ច អរតឹ សហតិ  ធីរោ ហិ អរតឹ សហោ ។

---

១ ធីរំ សហាតីតិ ឆេទោ ។

ម្នាលភិក្ខុទាំងឡាយ អរិយវង្ស ៤ យ៉ាងនេះជាច្បាប់ទម្លាប់ ដឹងអស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរតាត់រតាយ មិនរាត់រាយ ដែលសមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកប្រាជ្ញ មិនអាចតិះដៀលបាន ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុបរិបូណ៌ដោយអរិយវង្សទាំង ៤ នេះ ទុកណាជានៅក្នុងបុរត្ថិមទិស ភិក្ខុនោះឯង អាចអត់សង្កត់នូវសេចក្តីអផ្សុកបាន សេចក្តីអផ្សុកក៏មិនអាចគ្របសង្កត់ភិក្ខុនោះបានឡើយ ទុកណាជានៅក្នុងបច្ឆិមទិស... ទុកណាជានៅក្នុងឧត្តរទិស... ទុកណាជានៅក្នុងទក្ខិណទិស ភិក្ខុនោះឯងអាចគ្របសង្កត់នូវសេចក្តីអផ្សុក សេចក្តីអផ្សុក ក៏មិនគ្របសង្កត់ភិក្ខុនោះបានឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុជាអ្នកខ្ជាប់ខ្ជួន អាចអត់សង្កត់នូវសេចក្តីអផ្សុកនិងសេចក្តីត្រេកអរ (ក្នុងកាមគុណទាំង ៥) បាន ។

សេចក្តីអផ្សុក មិនអាចគ្របសង្កត់ នូវភិក្ខុអ្នកខ្ជាប់ខ្ជួនបាន
ទាំងសេចក្តីអផ្សុក មិនអាចគ្របសង្កត់ ភិក្ខុអ្នកខ្ជាប់ខ្ជួន
បាន ភិក្ខុអ្នកខ្ជាប់ខ្ជួន ក៏អាចគ្របសង្កត់នូវសេចក្តីអផ្សុក
បាន ភិក្ខុអ្នកខ្ជាប់ខ្ជួន គ្របសង្កត់នូវសេចក្តីអផ្សុកបាន ។

សព្ពកម្មវិហាយីនំ[១] បនុណ្ណំ កោ និវារយេ
នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ
ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោតិ ។

[៣០] ចត្តារីមានិ ភិក្ខវេ ធម្មបទានិ អគ្គញ្ញានិ រត្តញ្ញានិ វំសញ្ញានិ ចោរាណានិ អសង្កិណ្ណានិ អសង្កិណ្ណបុព្វានិ ន សង្កីយន្តិ ន សង្កីយិស្សន្តិ អប្បដិកុដ្ឋានិ សមណេហិ ព្រាហ្មណេហិ[២] វិញ្ញូហិ ។ កតមានិ ចត្តារិ ។ អនភិជ្ឈា ភិក្ខវេ ធម្មបទំ អគ្គញ្ញំ រត្តញ្ញំ វំសញ្ញំ ចោរាណំ អសង្កិណ្ណំ អសង្កិណ្ណបុព្វំ ន សង្កីយតិ ន សង្កីយិស្សតិ អប្បដិកុដ្ឋំ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ អព្យាបាទោ ភិក្ខវេ ធម្មបទំ... សម្មាសតិ ភិក្ខវេ ធម្មបទំ... សម្មាសមាធិ ភិក្ខវេ ធម្មបទំ អគ្គញ្ញំ រត្តញ្ញំ វំសញ្ញំ ចោរាណំ អសង្កិណ្ណំ

១ ឱ. សម្មាកម្មវិយាគតំ ។ ២ ឱ. សមណេហិ វា ព្រាហ្មណេហិ វា ។

រាគៈ ទោសៈដូចម្តេច យាត់នូវបុគ្គលអ្នកលះបង់នូវកម្ម ទាំងពួង អ្នកបន្ទោបង់នូវកិលេសទាំងឡាយបាន អ្នកណាគួរនឹងនិន្ទានូវបុគ្គលដែលប្រាកដស្មើដោយគ្រឿងនៃមាសជម្ពូនទនោះបាន ពួកទេវតានិងមនុស្សក៏សរសើរ សូម្បីតែព្រហ្មក៏សរសើរបុគ្គលនោះដែរ ។

[៣០] ម្នាលភិក្ខុទាំងឡាយ ធម្មបទ ៤ យ៉ាងនេះ ជាច្បាប់ទម្លាប់ គប្បីដឹង អស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនបានច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរតាត់រតាយ មិនរាត់រាយ ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនអាចតិះដៀលបាន ។ ធម្មបទ ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺអនភិជ្ឈា ជាធម្មបទ ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរតាត់រតាយ មិនរាត់រាយ ដែលសមណ-ព្រាហ្មណ៍ទាំងឡាយ ជាអ្នកប្រាជ្ញ មិនអាចតិះដៀលបាន ១ ម្នាលភិក្ខុទាំងឡាយ អព្យាបាទ ជាធម្មបទ... ម្នាលភិក្ខុទាំងឡាយ សម្មាសតិ ជាធម្មបទ... ម្នាលភិក្ខុទាំងឡាយ សម្មាសមាធិ ជាធម្មបទ ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ

អសង្កិណ្ណាបុព្វំ ន សង្កីយតិ ន សង្កីយិស្សតិ អប្ប-ដិកុដ្ឋំ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ធម្មបទានិ អគ្គញ្ញានិ រត្តញ្ញានិ វំសញ្ញានិ បោរាណានិ អសង្កិណ្ណានិ អសង្កិណ្ណបុព្វានិ ន សង្កីយន្តិ ន សង្កីយិស្សន្តិ អប្បដិកុដ្ឋានិ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។

អនភិជ្ឈាលុ វិហរេយ្យ អព្យាបន្នេន ចេតសា
សតោ ឯកគ្គចិត្តស្ស[១] អជ្ឈត្តំ សុសមាហិតោតិ ។

[៣១] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តេន ខោ បន សមយេន សម្ពហុលា អភិញ្ញាតា អភិញ្ញាតា បរិព្វាជកា សិប្បិនិយា តីរេ បរិព្វាជការាមេ បដិវសន្តិ សេយ្យថីទំ អន្នភារោ វរធរោ[២] សកុលុទាយិ ច បរិព្វាជកោ អញ្ញេ ច អភិញ្ញាតា អភិញ្ញាតា បរិព្វាជកា ។ អថខោ ភគវា

១ ម. ឯកគ្គចិត្តាយំ ។ ២ ឱ. វរធរោ ។ ម. ច វរោ ។

មិនដែលប្រឡូកប្រឡំ មិនរតាត់រតាយ មិនរាត់រាយ ដែលពួកសមណ-ព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនអាចតិះដៀលបាន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម្មបទ ៤ យ៉ាងនេះឯង ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនប្រឡូកប្រឡំ មិនដែលប្រឡូកប្រឡំ មិនរតាត់រតាយ មិនរាត់រាយ ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនអាចតិះ-ដៀលបានឡើយ ។

ភិក្ខុគប្បីជាអ្នកមិនមានអភិជ្ឈា មានចិត្តមិនប្រកបដោយ
ព្យាបាទ បរិបូណ៌ដោយស្មារតី មានចិត្តតាំងនៅនឹងក្នុង
អារម្មណ៍តែមួយ មានចិត្តតាំងនៅមាំជាកណ្តាល ។

[៣១] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ សម័យនោះ ពួកបរិព្វាជកដ៏ច្រើន ជាអ្នកចេះដឹង អាស្រ័យនៅក្នុងអារាមនៃបរិព្វាជក ក្បែរឆ្នេរស្ទឹងឈ្មោះសិប្បិនី បរិព្វាជក ទាំងនោះគឺអន្នភារបរិព្វាជក ១ វរធរបរិព្វាជក ១ សកុលុទាយិបរិព្វាជក ១ និងពួកបរិព្វាជកជាអ្នកចេះដឹងឯទៀត ។ គ្រានោះ ព្រះដ៏មានព្រះភាគ

សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន សិប្បិនិយា តីរំ បរិព្វាជការាមោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា តេ បរិព្វាជកេ ឯតទវោច ចត្តារិមានិ បរិព្វាជកា ធម្មបទានិ អគ្គញ្ញានិ រត្តញ្ញានិ វំសញ្ញានិ ចោរាណានិ អសង្កិណ្ណានិ អសង្កិណ្ណបុព្វានិ ន សង្កីយន្តិ ន សង្កីយិស្សន្តិ អប្បដិកុដ្ឋានិ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ កតមានិ ចត្តារិ ។ អនភិជ្ឈា បរិព្វាជកា ធម្មបទំ អគ្គញ្ញំ រត្តញ្ញំ វំសញ្ញំ ចោរាណំ អសង្កិណ្ណំ អសង្កិណ្ណបុព្វំ ន សង្កីយតិ ន សង្កីយិស្សតិ អប្បដិកុដ្ឋំ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ អព្យាចាទោ បរិព្វាជកា ធម្មបទំ... សម្មាសតិ បរិព្វាជកា ធម្មបទំ... សម្មាសមាធិ បរិព្វាជកា ធម្មបទំ អគ្គញ្ញំ រត្តញ្ញំ វិសញ្ញំ ចោរាណំ អសង្កិណ្ណំ អសង្កិណ្ណបុព្វំ ន សង្កីយតិ ន សង្កីយិស្សតិ អប្បដិកុដ្ឋំ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។

ទ្រង់ចេញអំពីទីសម្ងំ ក្នុងវេលាថ្ងៃរសៀល ក៏យាងចូលទៅឯអារាមនៃបរិព្វាជក ក្បែរឆ្នេរស្ទឹងឈ្មោះសិប្បិនី លុះយាងចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេតាក់តែងថ្វាយ ។ លុះព្រះដ៏មានព្រះភាគគង់រួចហើយបានត្រាស់នឹងពួកបរិព្វាជកទាំងនោះដូច្នេះថា ម្នាលបរិព្វាជកទាំងឡាយធម្មបទ ៤ យ៉ាងនេះ ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏យូរ ជាបវេណីជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរតាត់រតាយមិនរាត់រាយ ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញមិនអាចតិះដៀលបាន ។ ធម្មបទ ៤ តើដូចម្តេច ។ ម្នាលបរិព្វាជកទាំងឡាយ អនភិជ្ឈា ជាធម្មបទ ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏យូរ ជាបវេណី ជាច្បាប់ចាស់មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរតាត់រតាយ មិនរាត់រាយដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញមិនអាចតិះដៀលបាន ១ ។ ម្នាលបរិព្វាជកទាំងឡាយ អព្យាបាទ ជាធម្មបទ... ម្នាលបរិព្វាជកទាំងឡាយសម្មាសតិ ជាធម្មបទ... ម្នាលបរិព្វាជកទាំងឡាយ សម្មាសមាធិ ជាធម្មបទ ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏យូរ ជាបវេណី ជាច្បាប់ចាស់មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរតាត់រតាយ មិនរាត់រាយដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញមិនអាចតិះដៀលបាន ១ ។

ឥមានិ ខោ បរិព្វាជកា ចត្តារិ ធម្មបទានិ អគ្គញ្ញានិ រត្តញ្ញានិ វំសញ្ញានិ ពោរាណានិ អសង្កិណ្ណានិ អសង្កិណ្ណបុព្វានិ ន សង្កីយន្តិ ន សង្កីយិស្សន្តិ អប្បដិកុដ្ឋានិ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ យោ ខោ បរិព្វាជកា ឯវំ វទេយ្យ អហមេតំ អនភិជ្ឈំ ធម្មបទំ បច្ចក្ខាយ អភិជ្ឈាលុំ កាមេសុ តិព្វសារាគំ សមណំ វា ព្រាហ្មណំ វា បញ្ញាបេស្សាមីតិ តមហំ តត្ថ ឯវំ វទេយ្យំ[១] ឯតុ វទតុ ព្យាហរតុ បស្សាមិស្សានុភាវន្តិ ។ សោ វត បរិព្វាជកា អនភិជ្ឈំ ធម្មបទំ បច្ចក្ខាយ អភិជ្ឈាលុំ កាមេសុ តិព្វសារាគំ សមណំ វា ព្រាហ្មណំ វា បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ យោ ខោ បរិព្វាជកា ឯវំ វទេយ្យ អហមេតំ អព្យាបាទំ ធម្មបទំ បច្ចក្ខាយ ព្យាបន្នចិត្តំ បទុដ្ឋមនសង្កប្បំ សមណំ វា ព្រាហ្មណំ វា បញ្ញាបេស្សាមីតិ តមហំ តត្ថ ឯវំ វទេយ្យំ ឯតុ វទតុ ព្យាហរតុ បស្សាមិស្សានុភាវន្តិ ។

---

១ ឱ. តត្ថេវ វទេយ្យំ ។

ម្នាលពួកបរិព្វាជក ធម្មបទទាំង៤ យ៉ាងនេះជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏យូរ ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរតាត់រតាយ មិនរាត់រាយ ដែលពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញក៏មិនអាចតិះដៀលបាន ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកណាគប្បីនិយាយយ៉ាងនេះថា អាត្មាអញនឹងឃាត់ហាមនូវអនភិជ្ឈា ជាធម្មបទនុ៎ះ ហើយបញ្ញត្តបុគ្គលអ្នកមានអភិជ្ឈា អ្នកមានតម្រេកដ៏ក្លៀវក្លាក្នុងកាមទាំងឡាយ ថាជាសមណៈឬព្រាហ្មណ៍ កាលបើអ្នកនោះនិយាយដូច្នេះហើយ តថាគតត្រូវនិយាយនឹងអ្នកនោះចំពោះហេតុនោះយ៉ាងនេះថា អ្នកចូរមក ចូរនិយាយដោះស្រាយទៅមើល តថាគតនឹងមើលអានុភាពរបស់អ្នក ម្នាលបរិព្វាជកទាំងឡាយ អ្នកនោះនឹងឃាត់ហាមនូវអនភិជ្ឈាជាធម្មបទហើយ បញ្ញត្តបុគ្គលណាមួយដែលមានអភិជ្ឈា អ្នកមានតម្រេកដ៏ក្លៀវក្លាក្នុងកាមទាំងឡាយ ថាជាសមណៈឬព្រាហ្មណ៍ដូច្នេះ ហេតុនោះមិនមានឡើយ ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកណាគប្បីនិយាយយ៉ាងនេះថា អាត្មាអញនឹងឃាត់ហាមនូវអព្យាបាទ ជាធម្មបទនុ៎ះហើយ បញ្ញត្តបុគ្គលណាមួយ អ្នកមានចិត្តព្យាបាទ មានគំនិតដែលទោសប្រទូស្តហើយ ថាជាសមណៈឬព្រាហ្មណ៍ កាលបើអ្នកនោះនិយាយដូច្នេះហើយ តថាគតត្រូវនិយាយនឹងអ្នកនោះ ចំពោះហេតុនោះ យ៉ាងនេះថា អ្នកចូរមក ចូរនិយាយដោះស្រាយទៅមើល តថាគតនឹងមើលអានុភាពរបស់អ្នក ។

៧៤



សោ វត បរិព្វាជកា អព្យាបាទំ ធម្មបទំ បច្ចក្ខាយ ព្យាបន្នចិត្តំ បទុដ្ឋមនសង្កប្បំ សមណំ វា ព្រាហ្មណំ វា បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ យោ ខោ បរិព្វាជកា ឯវំ វទេយ្យ អហមេតំ សម្មាសតឹ ធម្មបទំ បច្ចក្ខាយ មុដ្ឋស្សតឹ អសម្បជានំ សមណំ វា ព្រាហ្មណំ វា បញ្ញាបេស្សាមីតិ តមហំ តត្ថ ឯវំ វទេយ្យំ ឯតុ វទតុ ព្យាហរតុ បស្សាមិស្សា-នុភាវន្តិ ។ សោ វត បរិព្វាជកា សម្មាសតឹ ធម្មបទំ បច្ចក្ខាយ មុដ្ឋស្សតឹ អសម្បជានំ សមណំ វា ព្រាហ្មណំ វា បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ យោ ខោ បរិព្វាជកា ឯវំ វទេយ្យ អហមេតំ សម្មាសមាធឹ ធម្មបទំ បច្ចក្ខាយ អសមាហិតំ វិព្ភន្តចិត្តំ សមណំ វា ព្រាហ្មណំ វា បញ្ញាបេស្សាមីតិ តមហំ តត្ថ ឯវំ វទេយ្យំ ឯតុ វទតុ ព្យាហរតុ បស្សាមិស្សានុភាវន្តិ ។

ម្នាលបរិព្វាជកទាំងឡាយ អ្នកនោះឯងនឹងឃាត់ហាមនូវអព្យាបាទ ជាធម្មបទ ហើយបញ្ញត្តបុគ្គលណាមួយ អ្នកមានចិត្តព្យាបាទ អ្នកមានគំនិតដែលទោសប្រទូស្តហើយ ថាជាសមណៈឬព្រាហ្មណ៍ដូច្នេះ ហេតុនុ៎ះមិនមានឡើយ ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកណាគប្បីនិយាយយ៉ាងនេះថា អាត្មាអញនឹងឃាត់ហាមនូវសម្មាសតិ ជាធម្មបទនោះហើយ បញ្ញត្តបុគ្គលណាមួយដែល មិនមានសតិ មិនមានសម្បជញ្ញៈ ថាជាសមណៈឬព្រាហ្មណ៍ កាលបើអ្នកនោះនិយាយដូច្នេះហើយ តថាគតត្រូវនិយាយនឹងអ្នកនោះ ចំពោះហេតុនុ៎ះយ៉ាងនេះថា អ្នកចូរមក ចូរនិយាយដោះស្រាយទៅមើល តថាគតនឹងមើលអានុភាពរបស់អ្នក ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកនោះឯងនឹងឃាត់ហាមនូវសម្មាសតិ ជាធម្មបទ ហើយបញ្ញត្តបុគ្គលណាមួយ ដែលមិនមានសតិ មិនមានសម្បជញ្ញៈ ថាជាសមណៈឬព្រាហ្មណ៍ដូច្នេះ ហេតុនុ៎ះមិនមានឡើយ ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកណាគប្បីនិយាយយ៉ាងនេះថា អាត្មាអញនឹងឃាត់ហាមសម្មាសមាធិ ជាធម្មបទនុ៎ះហើយបញ្ញត្តបុគ្គលណាមួយ ដែលមិនមានចិត្តតម្កល់មាំ ដែលមានចិត្តរវើរវាយ ថាជាសមណៈឬព្រាហ្មណ៍ កាលបើអ្នកនោះនិយាយដូច្នេះហើយ តថាគតត្រូវនិយាយចំពោះហេតុនុ៎ះយ៉ាងនេះថា អ្នកចូរមក ចូរនិយាយដោះស្រាយទៅមើល តថាគតនឹងមើលអានុភាពរបស់អ្នក ។

សោ វត បរិព្វាជកោ សម្មាសមាធឹ ធម្មបទំ បច្ចក្ខាយ អសមាហិតំ វិព្ភន្តចិត្តំ សមណំ វា ព្រាហ្មណំ វា បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ យោ ខោ បរិព្វាជកោ ឥមានិ ចត្តារិ ធម្មបទានិ គរហិតព្វំ បដិក្កោសិតព្វំ មញ្ញេយ្យ តស្ស ទិដ្ឋេវ ធម្មេ ចត្តារោ សហធម្មិកា វាទានុបាតា គារយ្ហា ឋានា[១] អាគច្ឆន្តិ ។ កតមេ ចត្តារោ ។ អនភិជ្ឈំ[២] ចេ ភវំ ធម្មបទំ គរហតិ បដិក្កោសតិ យេ ច ហិ អភិជ្ឈាលូ កាមេសុ តិព្វសារាគា សមណា វា ព្រាហ្មណា វា តេ ភោតោ បុជ្ជា តេ ភោតោ បាសំសា ។ អព្យាបាទំ ចេ ភវំ ធម្មបទំ គរហតិ បដិក្កោសតិ យេ ច ហិ ព្យាបន្នចិត្តា បទុដ្ឋមនសង្កប្បា សមណា វា ព្រាហ្មណា វា តេ ភោតោ បុជ្ជា តេ ភោតោ បាសំសា ។ សម្មាសតឹ ចេ ភវំ ធម្មបទំ គរហតិ បដិក្កោសតិ

---

១ ម. គារយ្ហំ ឋានំ ។ ២ ម. អនភិជ្ឈា ។

ម្នាលបរិព្វាជកទាំងឡាយ អ្នកនោះឯងឃាត់ហាមសម្មាសមាធិ ជាធម្មបទ ហើយបញ្ញត្តបុគ្គលណាមួយ ដែលមិនមានចិត្តតម្កល់មាំ ដែលមានចិត្តរវើរវាយ ថាជាសមណៈឬព្រាហ្មណ៍ដូច្នេះ ហេតុនុ៎ះមិនមានឡើយ ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកណាគប្បីសម្គាល់នូវធម្មបទទាំង ៤ នេះ ថាជារបស់ដែលគេគួរតិះដៀល គួរឃាត់ហាមគន្ទងនៃពាក្យ ប្រកបដោយហេតុទាំង ៤ យ៉ាង ក៏មកកាន់ហេតុដែលគេគួរតិះដៀលចំពោះអ្នកនោះក្នុងបច្ចុប្បន្ន ។ ធម្មបទ ៤ តើដូចម្តេច ។ បើអ្នកដ៏ចម្រើន តិះដៀលឃាត់ហាមអនភិជ្ឈា ជាធម្មបទថា សមណៈឬព្រាហ្មណ៍ទាំងឡាយណា ជាអ្នកប្រកបដោយអភិជ្ឈា អ្នកមានតម្រេកដ៏ក្រាស់ ក្នុងកាមទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីបូជារបស់អ្នកដ៏ចម្រើន សមណៈឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីសរសើររបស់អ្នកដ៏ចម្រើន ១ ។ បើអ្នកដ៏ចម្រើន តិះដៀលឃាត់ហាមអព្យាបាទ ជាធម្មបទថា សមណៈឬព្រាហ្មណ៍ទាំងឡាយណា មានចិត្តព្យាបាទ មានគំនិតដែលទោសប្រទូស្តហើយ សមណៈឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីបូជារបស់អ្នកដ៏ចម្រើន សមណៈឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីសរសើររបស់អ្នកដ៏ចម្រើន ១ ។ បើអ្នកដ៏ចម្រើន តិះដៀលឃាត់ហាមសម្មាសតិ ជាធម្មបទថា

យេ ច ហិ មុដ្ឋស្សតី អសម្បជានា សមណា វា ព្រាហ្មណា វា តេ ភោតោ បុជ្ជា តេ ភោតោ បាសំសា ។ សម្មាសមាធឹ ចេ ភវំ ធម្មបទំ គរហតិ បដិក្កោសតិ យេ ច ហិ អសមាហិតា វិព្ភន្តចិត្តា សមណា វា ព្រាហ្មណា វា តេ ភោតោ បុជ្ជា តេ ភោតោ បាសំសា ។ យោ ខោ បរិព្វាជកា ឥមានិ ចត្តារិ ធម្មបទានិ គរហិតព្វំ បដិក្កោសិតព្វំ មញ្ញេយ្យ តស្ស ទិដ្ឋេវ ធម្មេ ឥមេ ចត្តារោ សហធម្មិកា វាទានុបាតា គារយ្ហា ឋានា អាគច្ឆន្តិ ។ យេបិ តេ បរិព្វាជកា អហេសុំ ឧក្កលា វស្សភញ្ញា អហេតុកវាទា អកិ-រិយវាទា នត្ថិកវាទា តេបិ ឥមានិ ចត្តារិ ធម្មបទានិ ន គរហិតព្វំ ន បដិក្កោសិតព្វំ អមញ្ញឹសុ ។ តំ កិស្ស ហេតុ ។ និន្ទាព្យារោសឧបារម្ភភយាតិ[១] ។

១ ម. និន្ទាព្យារោសឧបវាទភយាតិ ។

សមណៈឬព្រាហ្មណ៍ទាំងឡាយណា ជាអ្នកភ្លេចស្មារតី មិនមានសម្បជញ្ញៈ សមណៈឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីបូជារបស់អ្នកដ៏ចម្រើន សមណៈឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីសរសើររបស់អ្នកដ៏ចម្រើន ១ ។ បើអ្នកដ៏ចម្រើន តិះដៀលឃាត់ហាមសម្មាសមាធិ ជាធម្មបទថា សមណៈឬព្រាហ្មណ៍ទាំងឡាយណា មានចិត្តមិនតម្កល់មាំ មានចិត្តរវើរវាយ សមណៈឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីបូជារបស់អ្នកដ៏ចម្រើន សមណៈឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីសរសើររបស់អ្នកដ៏ចម្រើន ១ ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកណាគប្បីសម្គាល់នូវធម្មបទទាំង ៤ នេះ ថាជារបស់ដែលគេគួរតិះដៀល គួរឃាត់ហាម គន្លងនៃពាក្យប្រកបដោយហេតុទាំង ៤ នេះ ក៏មកកាន់ហេតុដែលគេគួរតិះដៀលចំពោះអ្នកនោះ ក្នុងបច្ចុប្បន្ននេះ ។ ម្នាលបរិព្វាជកទាំងឡាយ ជនទាំងឡាយពីរនាក់គឺវស្សៈ ១ ភញ្ញៈ ១ ជាអ្នកនៅក្នុងឧក្កលជនបទ ជាអហេតុកវាទ អកិរិយាវាទនិងនត្ថិកវាទ ក៏ជនទាំងពីរនាក់នោះបានសម្គាល់នូវធម្មបទទាំង ៤ នេះ ថាជារបស់ដែលមិនត្រូវតិះដៀល ថាជារបស់ដែលមិនត្រូវហាមឃាត់ឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះខ្លាចគេនិន្ទា ពេបជ្រាយ តិះដៀលដល់ខ្លួន ។

អព្យាបន្នោ សទា សតោ អជ្ឈត្តំ សុសមាហិតោ
អភិជ្ឈាវិនយេ សិក្ខំ អប្បមត្តោតិ វុច្ចតីតិ ។

ឧរុវេលវគ្គោ តតិយោ ។

## តស្សុទ្ទានំ

ទ្វេ ឧរុវេលា លោកោ
កាឡកោ[១] ព្រហ្មចរិយបញ្ចមំ[២]
កុហំ សន្តុដ្ឋិ វំសោ ច
ធម្មបទំ បរិព្វាជកេន ចាតិ ។

---

១ ម. កោឡិកោ ។ ២ ឱ. ម. ព្រហ្មចរិយេន បញ្ចមំ ។

បុគ្គលអ្នកមិនមានចិត្តព្យាបាទ មានស្មារតីគ្រប់កាល មានចិត្តតម្កល់មាំ ប្រព្រឹត្តទៅក្នុងខាងក្នុង សិក្សាក្នុងការបន្ទោបង់នូវអភិជ្ឈា តថាគតហៅថាអ្នកមិនប្រមាទ ។

ចប់ ឧរុវេលវគ្គទី ៣ ។

## ឧទ្ទាននៃឧរុវេលវគ្គនោះគឺ

ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងឧរុវេលនិគមពីរដង ១ លោកគឺទុក្ខជាដើម ដែលព្រះតថាគតត្រាស់ដឹងហើយ ១ ព្រះអង្គគង់ក្នុងកាឡការាម ១ ព្រហ្មចរិយធម៌ជាគម្រប់ប្រាំ ១ ពួកកុហកជាដើម ១ សេចក្តីសន្តោស ១ អរិយវង្ស ១ ធម្មបទ (ជាច្បាប់ចាស់) ១ ធម្មបទ ទ្រង់សម្តែង ចំពោះពួកបរិញ្វាជក ១ ។

# ចក្កវគ្គោ

[៣២] ចត្តារីមានិ ភិក្ខវេ ចក្កានិ យេហិ សមន្នាគតានំ ទេវមនុស្សានំ ចតុចក្កំ បវត្តតិ យេហិ សមន្នាគតា ទេវមនុស្សា ន ចិរស្សេវ មហន្តត្តំ វេបុល្លត្តំ បាបុណន្តិ ភោគេសុ ។ កតមានិ ចត្តារិ ។ បដិរូបទេស-វាសោ សប្បុរិសូបស្សយោ អត្តសម្មាបណិធិ បុព្វេ ច កតបុញ្ញតា ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ចក្កានិ យេហិ សមន្នាគតានំ ទេវមនុស្សានំ ចតុចក្កំ បវត្តតិ យេហិ សមន្នាគតា ទេវមនុស្សា នចិរស្សេវ មហន្តត្តំ វេបុល្លត្តំ បាបុណន្តិ ភោគេសូតិ ។

បដិរូបេ វសេ ទេសេ អរិយមិត្តករោ សិយា
សម្មាបណិធិសម្បន្នោ បុព្វេ បុញ្ញកតោ នរោ
ធញ្ញំ ធនំ យសោ កិត្តិ សុខញ្ចេតំ ធិវត្តតីតិ ។

# ចក្កវគ្គ

[៣២] ម្នាលភិក្ខុទាំងឡាយ ចក្រនេះមាន ៤ ចក្រ ៤ តែងប្រព្រឹត្តទៅ (ដើម្បីជាប្រយោជន៍) ដល់ពួកទេវតានិងមនុស្សដែលប្រកបដោយចក្រ ពួកទេវតានិងមនុស្សដែលប្រកបដោយចក្រហើយ មិនយូរប៉ុន្មានក៏បានដល់នូវភាពនៃខ្លួនជាធំទូលាយក្នុងភោគៈទាំងឡាយ ។ ចក្រ ៤ ដូចម្ដេចខ្លះ ។ គឺការនៅក្នុងប្រទេសដ៏សមគួរ ១ ការចូលទៅសេពគប់នឹងពួកសប្បុរស ១ ការតម្កល់ទុកខ្លួនដោយល្អ ១ បុណ្យដែលបានធ្វើទុកហើយក្នុងកាលមុន ១ ។ ម្នាលភិក្ខុទាំងឡាយ ចក្រនេះ មាន ៤ យ៉ាង ចក្រ ៤ នេះ តែងប្រព្រឹត្តទៅ ដល់ពួកទេវតានិងមនុស្សដែលប្រកបព្រមដោយចក្រ ពួកទេវតានិងមនុស្សដែលប្រកបដោយចក្រហើយ មិនយូរប៉ុន្មានគង់បានដល់នូវភាវៈនៃខ្លួនជាធំទូលាយ ក្នុងភោគៈទាំងឡាយ ។

ជនណា នៅក្នុងប្រទេសដ៏សមគួរ សេពគប់នូវមិត្ត
ដ៏ប្រសើរ ប្រកបដោយការតម្កល់ទុកនូវខ្លួនដោយល្អ
បានធ្វើបុណ្យទុក ក្នុងកាលមុន ធញ្ញជាតិ ទ្រព្យ
យស សេចក្ដីសរសើរ សុខ តែងឃុំគ្រងនូវជននុ៎ះ ។

[៣៣] ចត្តារីមានិ ភិក្ខវេ សង្គហវត្ថូនិ ។ កាតមានិ ចត្តារិ ។ ទានំ បេយ្យវជ្ជំ អត្ថចរិយា សមានត្តតា ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ សង្គហវត្ថូនីតិ ។

ទានញ្ច បេយ្យវជ្ជញ្ច អត្ថចរិយា ច យា ឥធ
សមានត្តតា ច ធម្មេសុ តត្ថ តត្ថ យថារហំ
ឯតេ ខោ សង្គហា លោកេ រថស្សាណីវ យាយតោ
ឯតេ ច សង្គហា នាស្សុ ន មាតា បុត្តការណា
លភេថ មានំ បូជំ វា បិតា វា បុត្តការណា ។
យស្មា ច សង្គហា ឯតេ សមវេក្ខន្តិ បណ្ឌិតា
តស្មា មហត្តំ បប្បោន្តិ បាសំសា ច ភវន្តិ តេតិ ។

[៣៣] ម្នាលភិក្ខុទាំងឡាយ សង្គហវត្ថុនេះមាន ៤ ។ សង្គហវត្ថុ ៤ តើដូចម្តេចខ្លះ ។ គឺការឲ្យទាន ១ ការពោលពាក្យគួរស្រឡាញ់បាន ១ ការប្រព្រឹត្តជាប្រយោជន៍ ១ ភាពនៃបុគ្គលអ្នកមានខ្លួនស្មើ ១ ។ ម្នាលភិក្ខុទាំងឡាយ សង្គហវត្ថុមាន ៤ យ៉ាងនេះឯង ។

ការឲ្យទាន ១ ការពោលពាក្យគួរស្រឡាញ់បាន ១
ការប្រព្រឹត្តជាប្រយោជន៍ ១ ភាពនៃបុគ្គលអ្នកមានខ្លួន
ស្មើ ១ ដែលមានក្នុងលោកនេះ តាមសមគួរក្នុងធម៌
ទាំងឡាយនោះ ៗ បើសង្គហវត្ថុទាំងឡាយនេះមានក្នុង
លោក ដូចជាភ្លៅរបស់រថ ដែលអាចវិលទៅបាន ។
បើពួកសង្គហៈនេះ មិនមានទេ មាតាមិនគួរបាននូវ
សេចក្តីរាប់អានឬការបូជា អំពីបុត្រ បិតាក៏មិនគួរបាន
នូវសេចក្តីរាប់អានឬការបូជា អំពីបុត្រ (ប្រុសស្រី)
ឡើយ ព្រោះហេតុណា ហេតុនោះបានជា បណ្ឌិត
ទាំងឡាយ តែងសម្លឹងមើលនូវសង្គហៈទាំងឡាយ
នេះ បណ្ឌិតទាំងឡាយនោះ ក៏បានដល់នូវភាពនៃ
ខ្លួនជាធំផង ជាបុគ្គលគួរសរសើរផង ។

[៣៤] សីហោ ភិក្ខវេ មិគរាជា សាយណ្ហសមយំ អាសយា និក្ខមតិ អាសយា និក្ខមិត្វា វិជម្ភតិ វិជម្ភិត្វា សមន្តា ចតុទ្ទិសា អនុវិលោកេតិ សមន្តា ចតុទ្ទិសា អនុវិលោកេត្វា តិក្ខត្តុំ សីហនាទំ នទតិ តិក្ខត្តុំ សីហនាទំ នទិត្វា គោចរាយ បក្កមតិ ។ យេ ខោ បន តេ ភិក្ខវេ តិរច្ឆានគតា បាណា សីហស្ស មិគរញ្ញោ[១] នទតោ សទ្ទំ សុណន្តិ តេ យេភុយ្យេន ភយំ សំវេគំ សន្តាសំ អាបជ្ជន្តិ ពិលំ ពិលាសយា បវិសន្តិ ឧទកំ ឧទកាសយា បវិសន្តិ វនំ វនាសយា បវិសន្តិ អាកាសំ បក្ខិនោ ភជន្តិ ។ យេបិ តេ ភិក្ខវេ រញ្ញោ នាគា គាមនិគមរាជធានីសុ ទឡ្ហេហិ វរត្តេហិ ពន្ធនេហិ ពទ្ធា តេបិ តានិ ពន្ធនានិ សញ្ឆិន្ទិត្វា សម្បទាលេត្វា ភីតា មុត្តករីសំ ចជមានា យេន វា តេន វា បលាយន្តិ ។ ឯវំមហិទ្ធិកោ ខោ ភិក្ខវេ សីហោ មិគរាជា តិរច្ឆានគតានំ បាណានំ ឯវំមហេសក្ខោ ឯវំមហានុភាវោ ។

---

១ មិគរាជស្ស ។

[៣៤] ម្នាលភិក្ខុទាំងឡាយ វេលាថ្ងៃរសៀល សត្វសីហៈ ជាស្តេចម្រឹគ រមែងចេញអំពីដំណេក លុះចេញអំពីដំណេកហើយ ក៏មិតពត់ខ្លួន លុះមិតពត់ខ្លួនហើយ ក៏ក្រឡេកមៀងមើលទិសទាំង ៤ ជុំវិញ លុះក្រឡេកមៀងមើលទិសទាំង ៤ ជុំវិញ រួចក៏បន្លឺសីហនាទ ៣ ដង លុះបន្លឺសីហនាទ ៣ ដងហើយ ទើបដើរចេញទៅរកចំណី ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតិរច្ឆានណា ឮសំឡេងសត្វសីហៈ ជាស្តេចម្រឹគកំពុងបន្លឺ ពួកសត្វតិរច្ឆាននោះក៏ភិតភ័យ សង្វេគញ័រចំប្រប់រាល់គ្នា ពួកសត្វនៅក្នុងរូង រមែងស្ទុះចូលទៅកាន់រូង ពួកសត្វអាស្រ័យនៅនឹងទឹក ក៏ស្ទុះទៅរកទឹក ពួកសត្វអាស្រ័យនៅក្នុងព្រៃ ក៏ចូលព្រៃ ពួកសត្វបក្សីហើរទៅឯអាកាស ។ ម្នាលភិក្ខុទាំងឡាយ ពួកដំរីណារបស់ស្តេច ដែលគេចងដោយចំណងព្រ័ត្រដ៏មាំ ក្នុងស្រុក និគមនិងរាជធានីទាំងឡាយ ក៏ពួកដំរីទាំងនោះ ស្ទុះផ្តាច់ចំណងទាំងអំបាលនោះហើយ ភិតភ័យរាកនោម រាកអាចម៍បោលប្រាសទៅខាងណេះខ្វះខាងណោះខ្វះ ។ ម្នាលភិក្ខុទាំងឡាយ សត្វសីហៈ ជាស្តេចនៃម្រឹគ មានឫទ្ធិច្រើនយ៉ាងនេះ មានយសសក្តិធំយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ជាងពួកសត្វតិរច្ឆាន មានឧបមាយ៉ាងណា ។

ឯវមេវ ខោ ភិក្ខវេ យទា តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ធម្មំ ទេសេតិ ឥតិ សក្កាយោ ឥតិ សក្កាយស្ស សមុទយោ ឥតិ សក្កាយស្ស និរោធោ ឥតិ សក្កាយស្ស និរោធគាមិនី បដិបទាតិ ។ យេបិ តេ ភិក្ខវេ ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលា ឧច្ចេសុ វិមានេសុ ចិរដ្ឋិតិកា តេបិ តថាគតស្ស ធម្មទេសនំ សុត្វា យេភុយ្យេន ភយំ សំវេគំ សន្តាសំ អាបជ្ជន្តិ អនិច្ចា វត កិរ ភោ មយំ សមានា និច្ចម្ហាតិ អមញ្ញិម្ហា[១] អទ្ធុវា វត កិរ ភោ មយំ សមានា ធុវាតិ[២] អមញ្ញិម្ហា អសស្សតា វត កិរ ភោ មយំ សមានា សស្សតម្ហាតិ អមញ្ញិម្ហា មយំ កិរ ភោ អនិច្ចា អទ្ធុវា អសស្សតា សក្កាយបរិយាបន្នាតិ

១ ឱ. ម. អមញ្ញិម្ហ ។ ២ ឱ. ម. ធុវម្ហាតិ ។

ម្នាលភិក្ខុទាំងឡាយ កាលណាព្រះតថាគត បានត្រាស់ឡើង ក្នុងលោក ជាអ្នកឆ្ងាយចាកកិលេស ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ បរិបូណ៌ដោយវិជ្ជានិងចរណៈ មានដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណ រកបុគ្គលដទៃប្រៀបផ្ទឹមមិនបាន ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ បានត្រាស់ដឹងនូវអរិយសច្ចធម៌ លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះតថាគតនោះ ទ្រង់សម្តែងធម៌ថា សក្កាយ ដូច្នេះ ការកើតនៃសក្កាយ ដូច្នេះ ការរលត់នៃសក្កាយដូច្នេះ បដិបទា ដំណើរទៅកាន់ទីរលត់នៃសក្កាយ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាណាដែលមានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ឋិតនៅលើវិមានទាំងឡាយដ៏ខ្ពស់អស់កាលយូរ ពួកទេវតាទាំងនោះ បានស្តាប់នូវធម៌ទេសនារបស់ព្រះតថាគត ហើយច្រើនតែភិតភ័យ សង្វេគ ញ័រចំប្រប់គ្រប់គ្នាថា ម្នាលអ្នកដ៏ចម្រើន ពួកយើងមិនទៀងទេតើ តែពួកយើងសម្គាល់ថាទៀង ម្នាលអ្នកដ៏ចម្រើន ពួកយើងមិនមាំមួនទេតើ តែពួកយើងសម្គាល់ថា មាំមួន ម្នាលអ្នកដ៏ចម្រើន ពួកយើងមិនឋិតថេរទេតើ តែពួកយើងសម្គាល់ថា ឋិតថេរ ម្នាលអ្នកដ៏ចម្រើន ពួកយើងមិនទៀង មិនមាំមួន មិនឋិតថេរទេ (ព្រោះ) រាប់បញ្ចូលក្នុងសក្កាយគឺខន្ធទាំង ៥

ឯវំមហិទ្ធិកោ ខោ ភិក្ខវេ តថាគតោ សទេវកស្ស លោកស្ស ឯវំមហេសក្ខោ ឯវំមហានុភាវោតិ ។

យថា[១] ពុទ្ធោ អភិញ្ញាយ ធម្មចក្កំ បវត្តយិ
សទេវកស្ស លោកស្ស សត្ថា អប្បដិបុគ្គលោ
សក្កាយញ្ច និរោធញ្ច សក្កាយស្ស ច សម្ភវំ
អរិយដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ
យេបិ ទីឃាយុកា ទេវា វណ្ណវន្តោ យសស្សិនោ
ភីតា សន្តាសមាចាទុំ សីហស្សេវិតរេ មិគា[២]
អវីតិវត្តា សក្កាយំ អនិច្ចា កិរ ភោ មយំ
សុត្វា អរហតោ វាក្យំ វិប្បមុត្តស្ស តាទិនោតិ ។

---

១ ឱ. ម. យទា ។ ២ ឱ. មិគា តេ ។

ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត មានឫទ្ធិច្រើនយ៉ាងនេះ មានយសស័ក្តិធំយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ជាងសត្វលោកព្រមទាំងទេវ-លោក ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

កាលព្រះពុទ្ធ បានត្រាស់ដឹងហើយ ទ្រង់ធ្វើធម្មចក្រ
ឲ្យប្រព្រឹត្តទៅ ដល់សត្វលោក ព្រមទាំងទេវលោក
ជាសាស្តាមិនមានបុគ្គលដទៃ ប្រៀបផ្ទឹមស្មើបាន ទ្រង់
សម្តែងនូវសក្កាយផង នូវសេចក្តីរលត់ទៅនៃសក្កាយ
ផង នូវហេតុជាទីកើតឡើងនៃសក្កាយផង នូវមគ្គ
ប្រកបដោយអង្គ ៨ ដ៏ប្រសើរ ជាដំណើរទៅកាន់ទីរលត់
ទុក្ខផង ពួកទេវតាដែលមានអាយុវែង មានសម្បុរល្អ
មានយសស័ក្តិ ដែលមិនទាន់ផុត អំពីសក្កាយ
លុះឮព្រះពុទ្ធដីកា របស់ព្រះអរហន្ត ជាតាទិបុគ្គល
ដែលរួចស្រឡះ (ចាកអកុសលធម៌) ហើយក៏ភិត-
ភ័យ ដល់នូវសេចក្តីតក់ស្លុត ថាពួកយើងមិនទៀងទេតើ
ដូចពួកម្រឹគដទៃខ្លាចសីហៈ ។

[៣៤] ចត្តារោមេ ភិក្ខវេ អគ្គប្បសាទា ។ កតមេ ចត្តារោ ។ យាវតា ភិក្ខវេ សត្តា អបទា វា ទ្វិបទា វា ចតុប្បទា វា ពហុបទា វា រូបិនោ វា អរូបិនោ វា សញ្ញិនោ វា អសញ្ញិនោ វា នេវសញ្ញិនាសញ្ញិនោ វា តថាគតោ តេសំ អគ្គមក្ខាយតិ អរហំ សម្មាសម្ពុទ្ធោ ។ យេ ភិក្ខវេ ពុទ្ធេ បសន្នា អគ្គេ តេ បសន្នា អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ ។ យាវតា ភិក្ខវេ ធម្មា សង្ខតា អរិយោ អដ្ឋង្គិកោ មគ្គោ តេសំ អគ្គមក្ខាយតិ ។ យេ ភិក្ខវេ អរិយេ អដ្ឋង្គិកេ មគ្គេ បសន្នា អគ្គេ តេ បសន្នា អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ ។ យាវតា ភិក្ខវេ ធម្មា សង្ខតា វា អសង្ខតា វា វិរាគោ តេសំ អគ្គមក្ខាយតិ យទិទំ មទនិម្មទនោ បិបាសវិនយោ អាលយសមុគ្ឃាតោ

[៣៤] ម្នាលភិក្ខុទាំងឡាយ អគ្គប្បសាទ (សេចក្តីជ្រះថ្លាដ៏ប្រសើរ) នេះមាន ៤ ។ អគ្គប្បសាទ ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលឥតជើងក្តី មានជើង ២ ក្តី មានជើង ៤ ក្តី មានជើងច្រើនក្តី មានរូបក្តី គ្មានរូបក្តី មានសញ្ញាក្តី គ្មានសញ្ញាក្តី មិនមែនជាមិនមានសញ្ញាក្តី ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរលើសជាងពួកសត្វទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណាជ្រះថ្លាក្នុងព្រះពុទ្ធ ពួកសត្វទាំងនោះឈ្មោះថា ជ្រះថ្លាក្នុងបុគ្គលប្រសើរ ផលដ៏ប្រសើរតែងមានដល់ពួកសត្វអ្នកជ្រះថ្លាក្នុងបុគ្គលប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសង្ខតធម៌ ធម៌ដែលបច្ច័យតាក់តែងទាំងប៉ុន្មាន មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ប្រាកដជាប្រសើរជាង ពួកសង្ខតធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណា ជ្រះថ្លា ក្នុងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ពួកសត្វនោះឈ្មោះថា ជ្រះថ្លា ក្នុងព្រះធម៌ដ៏ប្រសើរ ផលដ៏ប្រសើរតែងមានដល់ពួកសត្វអ្នកជ្រះថ្លាក្នុងធម៌ដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មាន ជាសង្ខតធម៌ក្តី អសង្ខតធម៌ក្តី វិរាគធម៌ប្រាកដជាប្រសើរជាងពួកធម៌ទាំងនោះ ព្រោះថា វិរាគធម៌នេះ ជាធម៌សម្រាប់បន្ទោបង់នូវសេចក្តីស្រវឹង ជាធម៌កម្ចាត់បង់នូវសេចក្តីស្រេកឃ្លាន ជាធម៌អាចដកនូវសេចក្តីអាល័យ

វដ្ដុបច្ឆេទោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ ។ យេ ភិក្ខវេ វិរាគេ ធម្មេ បសន្នា អគ្គេ តេ បសន្នា អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ ។ យាវតា ភិក្ខវេ សង្ឃា វា គណា វា តថាគតស្សាវកសង្ឃោ តេសំ អគ្គមក្ខាយតិ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ យេ ភិក្ខវេ សង្ឃេ បសន្នា អគ្គេ តេ បសន្នា អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អគ្គប្បសាទាតិ ។

ជាធម៌ផ្តាច់បង់នូវវដ្តៈ ជាធម៌អស់ទៅនៃតណ្ហា ជាធម៌ប្រាសចាកតម្រេក ជាធម៌រលត់ ជាធម៌មិនមានគ្រឿងចាក់ស្រែះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណា ជ្រះថ្លាក្នុងវិរាគធម៌ ពួកសត្វនោះ ឈ្មោះថា ជ្រះថ្លាក្នុងធម៌ដ៏ប្រសើរ ផលដ៏ប្រសើរ តែងមានដល់ពួកសត្វអ្នកជ្រះថ្លា ក្នុងធម៌ដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃក្តី គណៈក្តី ទាំងប៉ុន្មាន សង្ឃសាវ័កនៃតថាគត បើរាប់ជាគូបាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ នេះជាសង្ឃសាវ័ករបស់ព្រះដ៏មានព្រះភាគ គួរទទួលរបស់ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្មដែលសត្វលោកគប្បីធ្វើ ជាស្រែបុណ្យដ៏ប្រសើរនៃសត្វលោកប្រាកដជាប្រសើរ ជាងសង្ឃឬគណៈទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណា ជ្រះថ្លាក្នុងព្រះសង្ឃ ពួកសត្វនោះ ឈ្មោះថា ជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ផលដ៏ប្រសើរ តែងមានដល់ពួកសត្វអ្នកជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ អគ្គប្បសាទ (សេចក្តីជ្រះថ្លាដ៏ប្រសើរ) មាន ៤ យ៉ាងនេះឯង ។

អគ្គតោ វេ បសន្នានំ អគ្គំ ធម្មំ វិជានតំ
អគ្គេ ពុទ្ធេ បសន្នានំ ទក្ខិណេយ្យេ អនុត្តរេ
អគ្គេ ធម្មេ បសន្នានំ វិរាគូបសមេ សុខេ
អគ្គេ សង្ឃេ បសន្នានំ បុញ្ញក្ខេត្តេ អនុត្តរេ
អគ្គស្មឹ ទានំ ទទតំ អគ្គំ បុញ្ញំ បវឌ្ឍតិ
អគ្គំ អាយុ ច វណ្ណោ ច យសោ កិត្តិ សុខំ ពលំ ។
អគ្គស្ស ទាតា មេធាវី អគ្គធម្មសមាហិតោ
ទេវភូតោ មនុស្សោ វា អគ្គប្បត្តោ បមោទតីតិ ។

[៣៦] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ

បុណ្យដ៏ប្រសើរផង អាយុដ៏ប្រសើរផង វណ្ណៈដ៏ប្រសើរផង យសដ៏ប្រសើរផង សេចក្តីសរសើរដ៏ប្រសើរផង សេចក្តីសុខដ៏ប្រសើរផង កម្លាំងដ៏ប្រសើរផង រមែងចម្រើន ដល់បុគ្គលទាំងឡាយអ្នកជ្រះថ្លា ចំពោះវត្ថុដ៏ប្រសើរ ដឹងច្បាស់នូវធម៌ដ៏ប្រសើរ ជ្រះថ្លាក្នុងព្រះពុទ្ធដ៏ប្រសើរ ជាទក្ខិណេយ្យបុគ្គល មិនមានបុគ្គលដទៃលើស ជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរ ជាធម៌រម្ងាប់រាគៈនាំមកនូវសេចក្តីសុខ ជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ជាស្រែបុណ្យ មិនមានស្រែដទៃលើស ឲ្យនូវទានចំពោះបុគ្គលដ៏ប្រសើរ ។ អ្នកប្រាជ្ញដែលមានចិត្តតម្កល់មាំក្នុងធម៌ដ៏ប្រសើរ ជាអ្នកឲ្យនូវទានដល់បុគ្គលដ៏ប្រសើរ ទោះកើតជាទេវតាក្តី ជាមនុស្សក្តី តែងដល់នូវភាវៈដ៏ប្រសើរ រមែងរីករាយ ។

[៣៦] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យ ក្នុងដែនមគធៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះដ៏មានព្រះភាគ

## ៨៧



សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ ភគវន្តំ ឯតទវោច ចតូហិ ខោ មយំ ភោ គោតម ធម្មេហិ សមន្នាគតំ មហាបញ្ញំ មហាបុរិសំ បញ្ញាបេម ។ កតមេហិ ចតូហិ ។ ឥធ ភោ គោតម ពហុស្សុតោ ហោតិ តស្ស តស្សេវ សុតជាតស្ស តស្ស តស្សេវ ខោ បន ភាសិតស្ស អត្ថំ ជានាតិ អយំ ឥមស្ស ភាសិតស្ស អត្ថោ អយំ ឥមស្ស ភាសិតស្ស អត្ថោតិ សតិមា ខោ បន ហោតិ ចិរកតំបិ ចិរភាសិតំបិ សរិតា អនុស្សរិតា យានិ ខោ បន តានិ គហដ្ឋកានិ កឹករណីយានិ តត្ថ ទក្ខោ ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ ។ ឥមេហិ ខោ មយំ ភោ គោតម ចតូហិ ធម្មេហិ សមន្នាគតំ មហាបញ្ញំ មហាបុរិសំ បញ្ញាបេម ។ សចេ មេ[១] ភោ គោតម អនុមោទិតព្វំ អនុមោទតុ មេ

១ ឱ. ម. សចេ បន មេ ។

លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ទើបអង្គុយក្នុងទីសមគួរ ។ លុះវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំតែងបញ្ញត្តនូវជនដែលមានបញ្ញាច្រើនប្រកបដោយធម៌ទាំង ៤ ថាជាមហាបុរស ។ ប្រកបដោយធម៌ទាំង ៤ តើដូចម្តេច ។ បពិត្រព្រះគោតមដ៏ចម្រើន ជនជាពហុស្សូត ក្នុងលោកនេះ រមែងដឹងច្បាស់នូវសេចក្តីនៃអ្នកចេះនោះ ៗ ១ នៃភាសិតនោះ ៗ ថា នេះជាសេចក្តីនៃភាសិតនេះ នេះជាសេចក្តីនៃភាសិតនេះ ១ ជនជាអ្នកមានស្មារតីតែងនឹករលឹករឿយ ៗ នូវកិច្ចដែលខ្លួនធ្វើយូរហើយផង នូវពាក្យដែលពោលយូរហើយផង ១ កិច្ចការទាំងឡាយណាជារបស់គ្រហស្ថ ក៏ជាអ្នកឈ្លាសវៃក្នុងកិច្ចការទាំងឡាយនោះ មិនខ្ជិលប្រកបដោយបញ្ញា ដែលជាឧបាយក្នុងកិច្ចនោះថា គួរធ្វើគួរចាត់ចែង ១ ។ បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំតែងបញ្ញត្តនូវជនដែលមានបញ្ញាច្រើន ប្រកបដោយធម៌ទាំង ៤ នេះឯង ថាជាមហាបុរស ។ បពិត្រព្រះគោតមដ៏ចម្រើន បើព្រះអង្គសព្វព្រះពុទ្ធហឫទ័យនឹងពាក្យខ្ញុំ សូមព្រះគោតមដ៏ចម្រើន អនុមោទនា ដល់ខ្ញុំចុះ

ភវំ គោតមោ សចេ បន មេ ភោ គោតម បដិក្កោសិតព្វំ បដិក្កោសតុ មេ ភវំ គោតមោតិ ។ នេវ ខោ ត្យាហំ ព្រាហ្មណ អនុមោទាមិ នប្បដិក្កោសាមិ ។ ចតូហិ ខោ អហំ ព្រាហ្មណ ធម្មេហិ សមន្នាគតំ មហាបញ្ញំ មហាបុរិសំ បញ្ញាបេមិ ។ កតមេហិ ចតូហិ ។ ឥធ ព្រាហ្មណ ពហុជនហិតាយ បដិបន្នោ ហោតិ ពហុជនសុខាយ ពហុស្ស ជនតា អរិយេ ញាយេ បតិដ្ឋាបិតា យទិទំ កល្យាណធម្មតា កុសលធម្មតា សោ យំ វិតក្កំ អាកង្ខតិ វិតក្កេតុំ តំ វិតក្កំ វិតក្កេតិ យំ វិតក្កំ នាកង្ខតិ វិតក្កេតុំ ន តំ វិតក្កំ វិតក្កេតិ យំ សង្កប្បំ អាកង្ខតិ សង្កប្បេតុំ តំ សង្កប្បំ សង្កប្បេតិ យំ សង្កប្បំ នាកង្ខតិ សង្កប្បេតុំ ន តំ សង្កប្បំ សង្កប្បេតិ ។ ឥតិ ចេតោវសិប្បត្តោ ហោតិ វិតក្កបថេសុ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី

បពិត្រព្រះគោតមដ៏ចម្រើន បើព្រះអង្គត្រូវការ ហាមឃាត់ពាក្យរបស់ខ្ញុំ សូមព្រះគោតមដ៏ចម្រើន ហាមឃាត់ពាក្យរបស់ខ្ញុំចុះ ។ ម្នាលព្រាហ្មណ៍ តថាគតមិនទទួលអនុមោទនា មិនហាមឃាត់ពាក្យរបស់អ្នកទេ ។ ម្នាលព្រាហ្មណ៍ តថាគតក៏តែងបញ្ញត្តនូវបុគ្គលដែលមានបញ្ញាច្រើន ប្រកបដោយធម៌ ៤ ថាជាមហាបុរសដែរ ។ ប្រកបដោយធម៌ ៤ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលក្នុងលោកនេះ ជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ពួកជនច្រើនគ្នាបានតម្កល់ហើយ ក្នុងផ្លូវដ៏ប្រសើរ គឺកល្យាណធម៌និងកុសលធម៌ បុគ្គលនោះ ប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កៈណា ក៏ត្រិះរិះនូវវិតក្កៈនោះបាន មិនប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កៈណា ក៏មិនត្រិះរិះនូវវិតក្កៈនោះ ប្រាថ្នាដើម្បីសម្រេចនូវគំនិតណា ក៏សម្រេចនូវគំនិតនោះ មិនប្រាថ្នាដើម្បីសម្រេចនូវគំនិតណា ក៏មិនសម្រេចនូវគំនិតនោះឡើយ ។ បុគ្គលជាអ្នកបានដល់នូវចេតោវសី ក្នុងផ្លូវវិតក្កៈទាំងឡាយ ជាអ្នកបានមិនបាច់ប្រាថ្នា បានដោយមិនលំបាក បានដោយមិនក្រ មិនខុសវេលាកំណត់ នូវឈានទាំង ៤ ដែលកើតក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន

អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ នេវ ខោ ត្យាហំ ព្រាហ្មណ អនុមោទាមិ នប្បដិ-ក្កោសាមិ ។ ឥមេហិ ខោ អហំ ព្រាហ្មណ ចតូហិ ធម្មេហិ សមន្នាគតំ មហាបញ្ញំ មហាបុរិសំ បញ្ញា-បេមីតិ ។ អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម យាវ សុភាសិតញ្ចិទំ ភោតា គោតមេន ។ ឥមេហិ ច បន[១] ចតូហិ ធម្មេហិ សមន្នាគតំ ភវន្តំ គោតមំ ធារេមិ ភវញ្ហិ គោតមោ ពហុជនហិតាយ បដិបន្នោ ពហុជនសុខាយ ពហុស្ស ជនតា អរិយេ ញាយេ បតិដ្ឋាបិតា យទិទំ កល្យាណធម្មតា កុសល-ធម្មតា[២] ភវញ្ហិ គោតមោ យំ វិតក្កំ អាកង្ខតិ វិតក្កេតុំ តំ វិតក្កំ វិតក្កេតិ យំ វិតក្កំ នាកង្ខតិ វិតក្កេតុំ ន តំ វិតក្កំ វិតក្កេតិ

---

១ ម. ឥមេហិ ច មយំ ភោ គោតម ។ ឱ. ឥមេហិ ច មយំ ។ ២ ម. កល្យាណធម្មតាយ កុសលធម្មតាយ ។

បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ននេះ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ។ ម្នាលព្រាហ្មណ៍ តថាគតមិនអនុមោទនា មិនហាមឃាត់ពាក្យរបស់អ្នកទេ ។ ម្នាលព្រាហ្មណ៍ តថាគតតែងបញ្ញត្តនូវជនដែលមានបញ្ញាច្រើន ប្រកបដោយធម៌ទាំង ៤ នេះឯង ថាជាមហាបុរស ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះអស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនដែលមានទេ ព្រោះថា ពាក្យដែលព្រះគោតមដ៏ចម្រើន សម្ដែងហើយ នេះជាពាក្យសុភាសិត ។ ខ្ញុំព្រះអង្គសូមចាំទុកនូវព្រះគោតមដ៏ចម្រើន ដែលប្រកបដោយធម៌ទាំង ៤ នេះ ថា ព្រះគោតមដ៏ចម្រើន ប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើនមែន ជនច្រើននាក់បានតម្កល់ហើយ ក្នុងផ្លូវដ៏ប្រសើរ គឺកល្យាណធម៌និងកុសលធម៌ ព្រះគោតមដ៏ចម្រើន ប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កៈណា តែងត្រិះរិះនូវវិតក្កៈនោះបាន មិនប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កៈណា ក៏មិនត្រិះរិះនូវវិតក្កៈនោះ

យំ សង្កប្បំ អាកង្ខតិ សង្កប្បេតុំ តំ សង្កប្បំ សង្កប្បេតិ យំ សង្កប្បំ នាកង្ខតិ សង្កប្បេតុំ ន តំ សង្កប្បំ សង្កប្បេតិ ភវញ្ហិ គោតមោ ចេតោវសិប្បត្តោ វិតក្កបថេសុ ភវញ្ហិ គោតមោ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អកិច្ឆលាភី អកសិរលាភី ភវញ្ហិ គោតមោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ អទ្ធា ខោ តេ ព្រាហ្មណ អាសជ្ជ ឧបនីយវាចា ភាសិតា អបិច ត្យាហំ ព្យាករិស្សាមិ អហញ្ហិ ព្រាហ្មណ ពហុជនហិតាយ បដិបន្នោ ពហុជនសុខាយ ពហុស្ស ជនតា អរិយេ ញាយេ បតិដ្ឋាបិតា យទិទំ កល្យាណធម្មតា កុសលធម្មតា អហញ្ហិ ព្រាហ្មណ យំ វិតក្កំ អាកង្ខាមិ វិតក្កេតុំ តំ វិតក្កំ វិតក្កេមិ យំ វិតក្កំ នាកង្ខាមិ វិតក្កេតុំ ន តំ វិតក្កំ វិតក្កេមិ

ប្រាថ្នាដើម្បីសម្រេចនូវគំនិតណា ក៏សម្រេចនូវគំនិតនោះ មិនប្រាថ្នាដើម្បីសម្រេចនូវគំនិតណា ក៏មិនសម្រេចនូវគំនិតនោះឡើយ ព្រះគោតមដ៏ចម្រើន ដល់នូវចេតោវសី ក្នុងផ្លូវវិតក្កៈទាំងឡាយ ព្រះគោតមដ៏ចម្រើន បានមិនបាច់ប្រាថ្នា បានដោយមិនលំបាក បានដោយមិនក្រ នូវឈានទាំង ៤ ដែលកើតក្នុងព្រះហឫទ័យដ៏ថ្លៃថ្លាជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ព្រះគោតមដ៏ចម្រើន បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ម្នាលព្រាហ្មណ៍ សម្ដីនាំឲ្យចង្អៀតចង្អល់ ដែលអ្នកនិយាយហើយទាំងប៉ុន្មាន តថាគតនឹងព្យាករនូវសម្ដីនោះឲ្យអ្នកស្ដាប់ ម្នាលព្រាហ្មណ៍ តថាគតប្រតិបត្តិហើយ ដើម្បីជាប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ពួកជនច្រើនគ្នា បានតម្កល់នៅក្នុងផ្លូវដ៏ប្រសើរ គឺកល្យាណធម៌និងកុសលធម៌ ម្នាលព្រាហ្មណ៍ តថាគតប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កៈណា ទើបត្រិះរិះ នូវវិតក្កៈនោះ មិនប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កៈណា ក៏មិនត្រិះរិះនូវវិតក្កៈនោះ

៩១



យំ សង្កប្បំ អាកង្ខាមិ សង្កប្បេតុំ តំ សង្កប្បំ សង្កប្បេមិ យំ សង្កប្បំ នាកង្ខាមិ សង្កប្បេតុំ ន តំ សង្កប្បំ សង្កប្បេមិ អហញ្ហិ ព្រាហ្មណ ចេតោវសិប្បត្តោ វិតក្កបថេសុ អហញ្ហិ ព្រាហ្មណ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អកិច្ឆលាភី អកសិរលាភី អហញ្ហិ ព្រាហ្មណ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ ។

យោ វេទី សព្វសត្តានំ មច្ចុបាសា បមោចនំ
ហិតំ ទេវមនុស្សានំ ញាយធម្មំ បកាសយិ
យញ្ច[១] ទិស្វា ច សុត្វា ច បសីទន្តិ ពហុជ្ជនោ
មគ្គាមគ្គស្ស កុសលោ កតកិច្ចោ អនាសវោ[២]
ពុទ្ធោ អន្តិមសារីរោ[៣] មហាបុរិសោតិ វុច្ចតីតិ[៤]។

---

១ ឱ. ម. យំ វេ ។ ២ ឱ. កុសលំ កតកិច្ចំ អនាសវំ ។ ៣ ម. អន្តិមធារិនោ ។
៤ ឱ. ម. មហាបញ្ញោបិ មហាបុរិសោតិ វុច្ចតីតិ ។

តថាគតប្រាថ្នា ដើម្បីសម្រេចនូវគំនិតណា ក៏សម្រេចនូវគំនិតនោះបាន មិនប្រាថ្នាសម្រេចនូវគំនិតណា ក៏មិនសម្រេចនូវគំនិតនោះឡើយ ម្នាលព្រាហ្មណ៍ តថាគតដល់នូវចេតោវសី ក្នុងផ្លូវវិតក្កៈទាំងឡាយ ម្នាលព្រាហ្មណ៍ តថាគតបានមិនបាច់ប្រាថ្នា បានដោយមិនលំបាក បានដោយមិនក្រ នូវឈានទាំង ៤ ដែលកើតក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នហើយ ម្នាលព្រាហ្មណ៍ តថាគតបានធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។

បុគ្គលណាជាអ្នកដឹងនូវឧបាយជាគ្រឿងរួច អំពីអន្ទាក់
នៃមច្ចុមារ របស់ពួកសត្វទាំងពួង ប្រកាសនូវញេយ្យធម៌
ជាប្រយោជន៍ ដល់ទេវតានិងមនុស្សទាំងឡាយ
ជនច្រើន បានឃើញ បានស្តាប់បុគ្គលណាហើយ
ជ្រះថ្លា បុគ្គលណា ជាអ្នកឈ្លាសវៃនូវមគ្គនិងមិនមែន
មគ្គ មានសោឡសកិច្ច ធ្វើស្រេចហើយ មិនមានអាសវៈ
ដឹងនូវសច្ចៈ ទាំង ៤ មានសរីរៈតាំងនៅ ក្នុងទីបំផុត
តថាគតហៅបុគ្គលនោះថាជាមហាបុរស ។

[៣៧] ឯកំ សមយំ ភគវា អន្តរា ច
ឧក្កដ្ឋំ អន្តរា ច សេតព្យំ អទ្ធានមគ្គប្បដិបន្នោ
ហោតិ ។ ទោណោបិ[១] ព្រាហ្មណោ អន្តរា ច
ឧក្កដ្ឋំ អន្តរា ច សេតព្យំ អទ្ធានមគ្គប្បដិបន្នោ
ហោតិ ។ អទ្ទសា ខោ ទោណោ ព្រាហ្មណោ
ភគវតោ បាទេសុ ចក្កានិ សហស្សារានិ សនេមិ-
កានិ សនាភិកានិ សព្វាការបរិបូរានិ ទិស្វានស្ស
ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ
ន វតិមានិ មនុស្សភូតស្ស បាទានិ ភវិស្សន្តីតិ ។
អថខោ ភគវា មគ្គា ឱក្កម្ម អញ្ញតរស្មឹ រុក្ខមូលេ
និសីទិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ
បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ អថខោ ទោណោ
ព្រាហ្មណោ ភគវតោ បាទានិ អនុគច្ឆន្តោ អទ្ទស
ភគវន្តំ អញ្ញតរស្មឹ រុក្ខមូលេ និសិន្នំ បាសាទិកំ
បសាទនីយំ សន្តិន្ទ្រិយំ សន្តមានសំ ឧត្តមទមថ-
សមថមនុប្បត្តំ ទន្តំ គុត្តំ យតិន្ទ្រិយំ នាគំ
ទិស្វា[២] យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា

១ ម. ឯត្ថន្តរេ សុទន្តិ អត្ថិ ។ ២ ម. ទិស្វាន ។

[៣៧] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះឧក្កដ្ឋនគរនិងសេតព្យនគរ ។ ចំណែកទោណព្រាហ្មណ៍ ក៏ដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះឧក្កដ្ឋនគរនិងសេតព្យនគរដែរ ។ ទោណ-ព្រាហ្មណ៍ក៏បានឃើញកង់ចក្រទាំងឡាយ មួយពាន់ក្នុងស្នាមព្រះបាទទាំងគូរបស់ព្រះដ៏មានព្រះភាគ ដែលប្រកបដោយខ្នងកង់និងដុំបរិបូណ៌ដោយអាការគ្រប់យ៉ាង លុះឃើញហើយ មានសេចក្តីត្រិះរិះដូច្នេះថា យីអើអស្ចារ្យណាស់ហ្ន៎ យីអើមិនដែលមានទេ ស្នាមជើងទាំងពីរនេះមិនដែលមានដល់មនុស្សជម្មតាទេ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ក៏ទ្រង់យាងបែរចេញពីផ្លូវ ហើយទ្រង់គង់ផ្គត់ព្រះភ្នែន តម្កល់ព្រះកាយឲ្យត្រង់តម្រង់ព្រះស្មារតីឲ្យនឹងក្រោមម្លប់ឈើមួយ ។ ឯទោណព្រាហ្មណ៍ដើរទៅតាមស្នាមព្រះបាទព្រះដ៏មានព្រះភាគ ក៏បានឃើញព្រះដ៏មានព្រះភាគ គួរជាទីជ្រះថ្លា ជាទីរីករាយ មានព្រះឥន្ទ្រិយស្ងប់រម្ងាប់ មានព្រះហឫទ័យស្ងប់ស្ងាត់ បានដល់នូវអរហត្តមគ្គ និងអរហត្តមគ្គសមាធិដ៏ឧត្តម ស្រគត់ស្រគំ រម្យ-ទម មានឥន្ទ្រិយរក្សាហើយ ជាបុគ្គលដ៏ប្រសើរគង់ក្រោមម្លប់ឈើមួយ លុះឃើញហើយ ក៏ចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់

ភគវន្តំ ឯតទវោច ទេវោ នោ ភវំ ភវិស្សតីតិ ។ ន ខោ អហំ ព្រាហ្មណ ទេវោ ភវិស្សាមីតិ ។ គន្ធព្វោ នោ ភវំ ភវិស្សតីតិ ។ ន ខោ អហំ ព្រាហ្មណ គន្ធព្វោ ភវិស្សាមីតិ ។ យក្ខោ នោ ភវំ ភវិស្សតីតិ ។ ន ខោ អហំ ព្រាហ្មណ យក្ខោ ភវិស្សាមីតិ ។ មនុស្សោ នោ ភវំ ភវិស្សតីតិ ។ ន ខោ អហំ ព្រាហ្មណ មនុស្សោ ភវិស្សាមីតិ ។ ទេវោ នោ ភវំ ភវិស្សតីតិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ ព្រាហ្មណ ទេវោ ភវិស្សាមីតិ វទេសិ គន្ធព្វោ នោ ភវំ ភវិស្សតីតិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ ព្រាហ្មណ គន្ធព្វោ ភវិស្សាមីតិ វទេសិ យក្ខោ នោ ភវំ ភវិស្សតីតិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ ព្រាហ្មណ យក្ខោ ភវិស្សាមីតិ វទេសិ មនុស្សោ នោ ភវំ ភវិស្សតីតិ ឥតិ បុដ្ឋោ សមានោ

បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា លោកដ៏ចម្រើននឹងកើតជាទេវតា ។ ព្រះអង្គតបថា ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាទេវតាទេ ។ លោកដ៏ចម្រើននឹងកើតជាគន្ធព្វ ។ ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាគន្ធព្វទេ ។ លោកដ៏ចម្រើននឹងកើតជាយក្ខ ។ ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាយក្ខទេ ។ លោកដ៏ចម្រើននឹងកើតជាមនុស្សឬ ។ ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាមនុស្សទេ ។ ទោណព្រាហ្មណ៍ពោលថា កាលខ្ញុំសួរថា លោកដ៏ចម្រើននឹងកើតជាទេវតាឬ លោកពោលថា ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាទេវតាទេ កាលខ្ញុំសួរថា លោកដ៏ចម្រើននឹងកើតជាគន្ធព្វឬ លោកពោលថា ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាគន្ធព្វទេ កាលខ្ញុំសួរថា លោកដ៏ចម្រើននឹងកើតជាយក្ខឬ លោកពោលថា ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាយក្ខទេ កាលខ្ញុំសួរថា លោកដ៏ចម្រើន នឹងកើតជាមនុស្សឬ

ន ខោ អហំ ព្រាហ្មណ មនុស្សោ ភវិស្សាមីតិ វទេសិ អថ[១] កោចរហិ ភវំ ភវិស្សតិ ។ យេសំ ខោ អហំ ព្រាហ្មណ អាសវានំ អប្បហីនត្តា ទេវោ ភវេយ្យំ តេ មេ អាសវា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំ កតា[២] អាយតឹអនុប្បា-ទធម្មា យេសំ ខោ អហំ ព្រាហ្មណ អាសវានំ អប្បហីនត្តា គន្ធព្វោ ភវេយ្យំ... យក្ខោ ភវេយ្យំ... មនុស្សោ ភវេយ្យំ តេ មេ អាសវា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំ កតា អាយតឹ-អនុប្បាទធម្មា ។ សេយ្យថាបិ ព្រាហ្មណ ឧប្បលំ វា បទុមំ វា បុណ្ឌរីកំ វា ឧទកេ ជាតំ ឧទកេ សំវឌ្ឍំ ឧទកា អច្ចុគ្គម្ម[៣] តិដ្ឋតិ អនុបលិត្តំ ឧទកេន ឯវមេវ ខោ អហំ ព្រាហ្មណ លោកេ ជាតោ លោកេ សំវឌ្ឍោ លោកំ អភិភុយ្យ វិហរាមិ អនុបលិត្តោ លោកេន ពុទ្ធោតិ មំ ព្រាហ្មណ ធារេហីតិ ។

---

១ ឱ. អថខោ ។ ២ យេភុយ្យេន អនភាវង្កតាតិ ទិស្សតិ ។ ៣ ម. ឧទកា បច្ចុគ្គម្ម ។

លោកពោលថា ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាមនុស្សទេ កាលបើដូច្នេះ តើលោកដ៏ចម្រើន នឹងទៅកើតជាអ្វីទៅ ។ ម្នាលព្រាហ្មណ៍ បើតថាគតកើតជាទេវតា ព្រោះថា តថាគតមិនបានលះបង់អាសវៈទាំង-ឡាយណា អាសវៈទាំងឡាយនោះ តថាគតបានលះបង់ស្រឡះហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ម្នាលព្រាហ្មណ៍ បើតថាគតកើតជាគន្ធព្វ ព្រោះតថាគតមិនទាន់បានលះបង់នូវអាសវៈទាំងឡាយណា... បើកើតជាយក្ខ... បើកើតជាមនុស្ស អាសវៈទាំងឡាយនោះ តថាគតបានលះបង់ស្រឡះហើយ បានគាស់រំលើងឫសគល់អស់ហើយ ធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលព្រាហ្មណ៍ ផ្កាព្រលឹតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី កើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ដុះផុតពីទឹក មិនជាប់ដោយទឹកវិញទេ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ តថាគតដែលកើតឡើងក្នុងលោក ចម្រើនឡើងក្នុងលោក រមែងគ្របសង្កត់នូវលោក មិនបានជាប់ចំពាក់ដោយលោកវិញ ក៏យ៉ាងនោះដែរ ម្នាលព្រាហ្មណ៍ អ្នកចូរចំណាំតថាគតថា ព្រះពុទ្ធដូច្នេះចុះ ។

យេន ទេវូបបត្យស្ស គន្ធព្វោ វា វិហង្គមោ
យក្ខត្តំ យេន គច្ឆេយ្យំ មនុស្សត្តញ្ច អព្ពជេ
តេ មយ្ហំ អាសវា ខីណា វិទ្ធស្តា វិនឡីកតា ។
បុណ្ឌរីកំ យថា ឧក្កំ[១] តោយេន នុបលិប្បតិ
នុបលិប្បាមិ លោកេន តស្មា ពុទ្ធោស្មិ ព្រាហ្មណាតិ ។

[៣៨] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលសម្បន្នោ ហោតិ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ភោជនេ មត្តញ្ញូ ហោតិ ជាគរិយំ អនុយុត្តោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សីលសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ

---

១ ឱ. ម. យថា វគ្គុ ។

តថាគតគប្បីកើតជាទេវតា ឬកើតជាគន្ធព្វត្រាច់ទៅតាមអាកាស ព្រោះអាសវៈណាក្តី គប្បីដល់នូវភាពនៃខ្លួនជាយក្ខ នឹងជួបប្រទះនូវភាពនៃខ្លួនជាមនុស្ស ព្រោះអាសវៈណាក្តី អាសវៈទាំងអស់នោះ របស់តថាគតអស់ហើយ បានកម្ចាត់បង់ហើយ ធ្វើឲ្យរបូតចំណាង់ហើយ ។ ផ្កាឈូកស ដុះឡើងផុត (ពីទឹក) មិនជាប់ដោយទឹកយ៉ាងណា តថាគតមិនជាប់ដោយលោកយ៉ាងនោះ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ តថាគតជាព្រះពុទ្ធ ។

[៣៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ ៤ យ៉ាង មិនគួរសាបសូន្យ តែងនៅក្នុងទីជិតនៃព្រះនិព្វាន ។ ប្រកបដោយធម៌ ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីលបរិបូណ៌ ១ ជាអ្នកមានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ ១ ជាអ្នកដឹងប្រមាណក្នុងភោជន ១ ជាអ្នកប្រកបរឿយ ៗ នូវការភ្ញាក់រលឹក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមានសីលបរិបូណ៌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរៈ

អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សីល-សម្បន្នោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ន និមិត្ត-គ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករ-ណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោម-នស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។

អ្នកឃើញនូវភ័យក្នុងទោសគ្រាន់តែបន្តិចបន្តួចសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសីលបរិបូណ៌យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូបដោយចក្ខុ ហើយមិនក្ដួចកាន់នូវនិមិត្ត មិនក្ដួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្សដែលជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវភិក្ខុដែលមិនបានសង្រួមចក្ខុន្ទ្រិយ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ បានឮសំឡេងដោយត្រចៀក... បានហិតក្លិនដោយច្រមុះ... បានទទួលរសដោយអណ្តាត... ពាល់ត្រូវផោដ្ឋព្វដោយកាយ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ជាអ្នកមិនក្ដួចកាន់នូវនិមិត្ត មិនក្ដួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវភិក្ខុដែលមិនបានសង្រួមមនិន្ទ្រិយ ព្រោះហេតុមិនបានសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានទ្វារគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយទាំងឡាយយ៉ាងនេះឯង ។

៩៧



កថញ្ច ភិក្ខវេ ភិក្ខុ ភោជនេ មត្តញ្ញូ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ភោជនេ មត្តញ្ញូ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ជាគរិយំ អនុយុត្តោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ទិវសំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា បឋមំ យាមំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា មជ្ឈិមំ យាមំ ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេតិ បាទេន បាទំ អច្ចាធាយ

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកដឹងប្រមាណក្នុងភោជន តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយនៃបញ្ញា នឹងបរិភោគនូវអាហារ ដើម្បីលេងក៏ទេ ដើម្បីស្រវឹងក៏ទេ ដើម្បីប្រដាប់តាក់តែងរាងកាយក៏ទេ ដើម្បីឲ្យផូរផង់សម្បុរក៏ទេ ដើម្បីនឹងឲ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញុំាងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្ដីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចារ្យប៉ុណ្ណោះឯង អាត្មាអញនឹងឃាត់បង់នូវវេទនាចាស់ផង មិនឲ្យវេទនាថ្មីកើតឡើងផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្ដី សេចក្ដីមិនមានទោសក្ដី កិរិយានៅសប្បាយក្ដី នឹងមានដល់អាត្មាអញផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដឹងប្រមាណ ក្នុងភោជន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ ជាអ្នកប្រកបរឿយ ៗ នូវការភ្ញាក់រលឹក តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅចង្ក្រមក្នុងវេលាថ្ងៃ សម្អាតចិត្តចាកអាវរណីយធម៌ទាំងឡាយ ចូលទៅចង្ក្រម អស់បឋមយាមនៃរាត្រី សម្អាតចិត្តចាកអាវរណីយធម៌ទាំងឡាយ សម្រេចសីហសេយ្យាដោយបង្អៀងខាងស្ដាំ អស់មជ្ឈិមយាមនៃរាត្រី តម្រួតជើងលើជើង

សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា រត្តិយា បច្ឆិមំ យាមំ បច្ចុដ្ឋាយ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ជាគរិយំ អនុយុត្តោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេតិ ។

សីលេ បតិដ្ឋិតោ ភិក្ខុ ឥន្ទ្រិយេសុ ច សំវុតោ
ភោជនម្ហិ ច មត្តញ្ញូ ជាគរិយំ អនុយុញ្ជតិ
ឯវំ វិហរមាតាបី[1] អហោរត្តមតន្ទិតោ
ភាវយំ កុសលំ ធម្មំ យោគក្ខេមស្ស បត្តិយា
អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេតិ ។

១ ម. វិហារីអាតាបី ។ ឱ. ឯវំ វិហរមានោបិ ។

មានស្មារតី ជាអ្នកដឹងខ្លួន ធ្វើទុកក្នុងចិត្តនូវឧដ្ឋានសញ្ញា ដល់បច្ឆិមយាម នៃរាត្រី ក្រោកឡើង ចូលទៅចង្ក្រម សម្អាតចិត្តចាកអាវរណីយធម៌ទាំង-ឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រកបរឿយ ៗ នូវការភ្ញាក់រលឹក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ទាំង ៤ នេះ មិនគួរសាបសូន្យ តែងនៅក្នុងទីជិតនៃព្រះនិព្វាន ។

ភិក្ខុឋិតនៅក្នុងសីលផង សង្រួមក្នុងឥន្ទ្រិយទាំងឡាយ
ផង ដឹងប្រមាណ ក្នុងភោជនផង ប្រកបរឿយ ៗ
ក្នុងការភ្ញាក់រលឹកផង កាលភិក្ខុប្រកបដោយសេចក្តី
ព្យាយាម មិនខ្ជិលច្រអូសទាំងថ្ងៃទាំងយប់ ចម្រើននូវ
កុសលធម៌ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាក
យោគៈយ៉ាងនេះ ភិក្ខុដែលមានសេចក្តីត្រេកអរ ក្នុង
សេចក្តីមិនប្រមាទ ឬឃើញភ័យ ក្នុងសេចក្តីប្រមាទ
មិនគួរដើម្បីសាបសូន្យ តែងនៅក្នុងទីជិតនៃព្រះនិព្វាន ។

[៣៩] បដុណ្ណប្បច្ចេកសច្ចោ ភិក្ខវេ ភិក្ខុ សមវយសដ្ឋេសនោ បស្សទ្ធកាយសង្ខារោ បដិលីនោតិ វុច្ចតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ បនុណ្ណប្បច្ចេកសច្ចោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ យានិ តានិ បុថុ-ស្សមណព្រាហ្មណានំ បុថុប្បច្ចេកសច្ចានិ សេយ្យថីទំ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា សព្វានិ[១] តានិ នុណ្ណានិ ហោន្តិ បនុ-ណ្ណានិ ចត្តានិ វន្តានិ មុត្តានិ បហីនានិ បដិនិស្សដ្ឋានិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បនុណ្ណប្បច្ចេកសច្ចោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សមវយសដ្ឋេសនោ ហោតិ ។

---

១ ឱ. សព្វានិស្ស ។ ម. សព្វានិចស្ស ។

[៣៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលតថាគតហៅថា អ្នកមានបច្ចេកសច្ចៈបន្ទោបង់ហើយ ១ មានការស្វែងរកលះបង់ហើយដោយបរិបូណ៌ ១ មានកាយសង្ខារស្ងប់រម្ងាប់ ១ ជាអ្នកពួនសម្ងំ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកមានបច្ចេកសច្ចៈបន្ទោបង់ហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកបច្ចេកសច្ចៈដ៏ច្រើនណា របស់ពួកសមណៈនិងព្រាហ្មណ៍ដ៏ច្រើន ដោយយល់ថាលោកទៀងដូច្នេះក៏មាន លោកមិនទៀងដូច្នេះក៏មាន លោកមានទីបំផុតដូច្នេះក៏មាន លោកមិនមានទីបំផុតដូច្នេះក៏មាន ជីវិតនោះគឺសរីរៈនោះ ដូច្នេះក៏មាន ជីវិតដទៃសរីរៈដទៃដូច្នេះក៏មាន សត្វស្លាប់ទៅ កើតទៀតដូច្នេះក៏មាន សត្វស្លាប់ទៅ មិនកើតទៀតដូច្នេះក៏មាន សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះ ដូច្នេះក៏មាន សត្វស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក៏មាន ពួកបច្ចេកសច្ចៈ ទាំងអស់នោះ ភិក្ខុក្នុងសាសនានេះ បន្ទោបង់ហើយ កម្ចាត់បង់ហើយ លះបង់ហើយ ខ្ជាក់ចោលហើយ ច្បូតចេញហើយ បណ្តោញបង់ហើយ បំបាត់បង់ហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានបច្ចេកសច្ចៈបន្ទោបង់ហើយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកមានការស្វែងរកលះបង់ហើយ ដោយបរិបូណ៌ តើដូចម្តេច ។

ឥធ ភិក្ខវេ ភិក្ខុនោ កាមេសនា បហីនា ហោតិ ។
ភវេសនា បហីនា ហោតិ ព្រហ្មចរិយេសនា បដិប្ប-
ស្សទ្ធា ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សមវយសដ្ឋេ-
សនោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ បស្សទ្ធកាយ-
សង្ខារោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សុខស្ស ច
បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្ស-
ទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិ-
បារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឯវំ
ខោ ភិក្ខវេ ភិក្ខុ បស្សទ្ធកាយសង្ខារោ ហោតិ ។
កថញ្ច ភិក្ខវេ ភិក្ខុ បដិលីនោ ហោតិ ។ ឥធ
ភិក្ខវេ ភិក្ខុនោ អស្មិមានោ បហីនោ ហោតិ ឧច្ឆិន្នមូលោ
តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទ-
ធម្មោ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បដិលីនោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ការស្វែងរកកាម ភិក្ខុក្នុងសាសនានេះ លះបង់ហើយ (ដោយអនាគាមិមគ្គ) ការស្វែងរកភព ភិក្ខុលះបង់ហើយ (ដោយអរហត្តមគ្គ) ការស្វែងរកព្រហ្មចារ្យ ភិក្ខុបានរម្ងាប់ហើយ (ដោយអរហត្តមគ្គ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានការស្វែងរកលះបង់ហើយ ដោយបរិបូណ៌ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកមានកាយសង្ខារស្ងប់រម្ងាប់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់សុខផង ព្រោះលះបង់ទុក្ខផង ព្រោះរលត់សោមនស្សទោមនស្សក្នុងកាលមុនផង ដល់នូវចតុត្ថជ្ឈាន មិនទុក្ខ មិនសុខ មានឧបេក្ខានិងសតិដ៏បរិសុទ្ធ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានកាយសង្ខារស្ងប់រម្ងាប់ហើយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកពួនសម្ងំ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អស្មិមានះ ភិក្ខុក្នុងសាសនានេះ លះបង់ហើយ គាស់រំលើងឫសចោលហើយ ធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពួនសម្ងំ យ៉ាងនេះឯង ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ បនុណ្ណប្បច្ចេកសច្ចោ សមវយសដ្ឋេសនោ បស្សទ្ធកាយសង្ខារោ បដិលីនោតិ វុច្ចតិ ។

កាមេសនា ភវេសនា ព្រហ្មចរិយេសនា សហ
ឥតិ សច្ចបរាមាសោ ទិដ្ឋិដ្ឋានា សមុស្សយា
សព្វរាគវិរត្តស្ស តណ្ហក្ខយវិមុត្តិនោ
ឯសនា បដិនិស្សដ្ឋា ទិដ្ឋិដ្ឋានា សមូហតា
ស វេ សន្តោ សតោ ភិក្ខុ បស្សទ្ធោ អបរាជិតោ
មានាភិសមយា ពុទ្ធោ បដិលីនោតិ វុច្ចតីតិ ។

[៤០] អថខោ ឧជ្ជយោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឧជ្ជយោ ព្រាហ្មណោ ភគវន្តំ ឯតទវោច ភវំបិ នោ គោតមោ យញ្ញំ វណ្ណេតីតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលតថាគតហៅថា មានបច្ចេកសច្ចៈបន្ទោបង់ហើយ មានការស្វែងរក លះបង់ហើយ ដោយបរិបូណ៌ មានកាយ-សង្ខារស្ងប់រម្ងាប់ ជាអ្នកពួនសម្ងំ យ៉ាងនេះឯង ។

ការប្រកាន់ថា ពិតដូច្នេះ ៗ នឹងជាទីតាំងនៃទិដ្ឋិ ភិក្ខុដកចោលហើយ ការស្វែងរកគឺការស្វែងរកកាម ស្វែងរកភពព្រមទាំងការស្វែងរកព្រហ្មចារ្យ នឹងទីតាំងនៃទិដ្ឋិ ភិក្ខុអ្នកប្រាសចាកតម្រេកក្នុងរាគៈទាំងពួង អ្នករួចផុតស្រឡះ ព្រោះអស់ទៅនៃតណ្ហា បានលះបង់ហើយ បានដកចោលហើយ ភិក្ខុនោះឯង ជាអ្នកស្ងប់រម្ងាប់ មានស្មារតី មានកាយនិងចិត្តស្ងប់រម្ងាប់ មិនចាញ់កិលេស ជាអ្នកដឹងនូវសច្ចៈ ព្រោះស្គាល់ច្បាស់នូវមានះ តថាគតហៅថា ជាអ្នកពួនសម្ងំ ។

[៤០] គ្រានោះ ឧជ្ជយព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះឧជ្ជយព្រាហ្មណ៍អង្គុយ ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគថា ព្រះគោតមដ៏ចម្រើន សរសើរការបូជារបស់យើងដែរឬទេ ។

ន ខោ អហំ ព្រាហ្មណ សព្វំ យញ្ញំ វណ្ណេមិ ន បនាហំ ព្រាហ្មណ សព្វំ យញ្ញំ ន វណ្ណេមិ ។ យថារូបេ ច ខោ ព្រាហ្មណ យញ្ញេ គាវោ ហញ្ញន្តិ អជេឡកា ហញ្ញន្តិ កុក្កុដសូករា ហញ្ញន្តិ វិវិធា ចាណា សង្ឃាតំ អាបជ្ជន្តិ ឯវរូបំ ខោ អហំ ព្រាហ្មណ សារម្ភំ យញ្ញំ ន វណ្ណេមិ ។ តំ កិស្ស ហេតុ ។ ឯវរូបញ្ហិ ព្រាហ្មណ សារម្ភំ យញ្ញំ ន ឧបសង្កមន្តិ អរហន្តោ វា អរហត្តមគ្គំ វា សមាបន្នា ។ យថារូបេ ច ខោ ព្រាហ្មណ យញ្ញេ នេវ គាវោ ហញ្ញន្តិ ន អជេឡកា ហញ្ញន្តិ ន កុក្កុដសូករា ហញ្ញន្តិ ន វិវិធា ចាណា សង្ឃាតំ អាបជ្ជន្តិ ឯវរូបំ ខោ អហំ ព្រាហ្មណ និរារម្ភំ យញ្ញំ វណ្ណេមិ យទិទំ និច្ចទានំ អនុកុលយញ្ញំ ។ តំ កិស្ស ហេតុ ។ ឯវរូបញ្ហិ ព្រាហ្មណ និរារម្ភំ យញ្ញំ ឧបសង្កមន្តិ អរហន្តោ វា អរហត្តមគ្គំ វា សមាបន្នាតិ ។

ម្នាលព្រាហ្មណ៍ តថាគតមិនសរសើរការបូជាទាំងអស់ទេ ម្នាលព្រាហ្មណ៍ តែតថាគតមិនមែនជាមិនសរសើរការបូជាទាំងអស់ទេ ។ ម្នាលព្រាហ្មណ៍ គេសម្លាប់គោទាំងឡាយ សម្លាប់ពពែនិងចៀមទាំងឡាយ សម្លាប់មាន់និងជ្រូកទាំងឡាយ សត្វទាំងឡាយផ្សេង ៗ ក៏ដល់នូវសេចក្ដីស្លាប់ ព្រោះការបូជាមានសភាពយ៉ាងណា ម្នាលព្រាហ្មណ៍ តថាគតមិនសរសើរការបូជាប្រកបដោយសេចក្ដីអន្តរាយ យ៉ាងនោះឡើយ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះអរហន្តទាំងឡាយក្ដី បុគ្គលទាំងឡាយ អ្នកដល់នូវអរហត្តមគ្គក្ដី មិនដើរទៅជិតការបូជាប្រកបដោយសេចក្ដីអន្តរាយ មានសភាពយ៉ាងនេះឡើយ ។ ម្នាលព្រាហ្មណ៍ គេមិនសម្លាប់គោទាំងឡាយ មិនសម្លាប់ពពែនិងចៀមទាំងឡាយ មិនសម្លាប់មាន់និងជ្រូកទាំងឡាយ សត្វទាំងឡាយផ្សេង ៗ ក៏មិនស្លាប់ព្រោះការបូជា មានសភាពយ៉ាងណា ម្នាលព្រាហ្មណ៍ តថាគតតែងសរសើរការបូជា ដែលមិនប្រកបដោយសេចក្ដីអន្តរាយ មានសភាពយ៉ាងនេះ គឺនិច្ចទាននិងការបូជាតាមលំអានត្រកូល ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះអរហន្តទាំងឡាយក្ដី បុគ្គលទាំងឡាយ អ្នកដល់នូវអរហត្តមគ្គក្ដី តែងពេញចិត្តការបូជាដែលមិនប្រកបដោយសេចក្ដីអន្តរាយ មានសភាពយ៉ាងនេះ ។

១០៣



អស្សមេធំ បុរិសមេធំ សម្មាបាសំ វាជបេយ្យំ[១] និរគ្គឡំ
មហាយញ្ញា មហារម្ភា ន តេ ហោន្តិ មហប្ផលា។
អជេឡកា ច គាវោ ច វិវិធា យត្ថ ហញ្ញរេ
ន តំ សម្មគ្គតា យញ្ញំ ឧបយន្តិ មហេសិនោ ។
យញ្ច យញ្ញំ និរារម្ភំ យជន្ត្យនុកុលំ សទា[២]
នាជេឡកា ច គាវោ ច[៣] វិវិធា យត្ថ[៤] ហញ្ញរេ ។
តញ្ច សម្មគ្គតា យញ្ញំ ឧបយន្តិ មហេសិនោ
ឯវំ យជេថ មេធាវី ឯសោ យញ្ញោ មហប្ផលោ។
ឯវំ ហិ[៥] យជមានស្ស សេយ្យោ ហោតិ ន បាបិយោ
យញ្ញោ ច វិបុលោ ហោតិ បសីទន្តិ ច ទេវតាតិ ។

១ ឱ. វាចបេយ្យំ ។ ២ ឱ. ម. យេ ច យញ្ញា និរារម្ភា យជន្តិ អនុកុលំ សទា ។
៣ ឱ. ម. អជេឡកា ច គាវោ ច ។ ៤ ឱ. ម. នេត្ថ ។ ៥ ឱ. ឯតំ ហិ ។

ការបូជាធំ មានកិច្ចដែលត្រូវធ្វើច្រើន គឺការសម្លាប់សេះ សម្លាប់បុរស ការទុកដាក់មនុស្ស ដោយប្រពៃការពោលពាក្យជាទីស្រឡាញ់ ផ្ទះមិនបាច់មានគន្លឹះទ្វារ ការបូជាធំទាំងនោះ មិនមានផលឡើយ គេសម្លាប់ពពែនិងចៀមក្តី គោទាំងឡាយក្តី ពួកសត្វផ្សេង ៗ ក្តី ព្រោះការបូជាណា ពួកបុគ្គលអ្នកដល់នូវអរហត្តមគ្គ និងបុគ្គលអ្នកស្វែងរកនូវគុណដ៏ធំ (ព្រះអរហន្ត) តែងមិននិយមនូវការបូជានោះទេ ។ ពួកជនបូជាសព្វកាល នូវយញ្ញណាដែលមិនប្រកប ដោយសេចក្តីអន្តរាយ តាមលំអាននៃត្រកូលក្តី គេមិនសម្លាប់ពួកពពែនិងចៀម ឬពួកគោឬក៏ពួកសត្វផ្សេង ៗ ព្រោះការបូជាណាក្តី ពួកបុគ្គលអ្នកដល់នូវអរហត្តមគ្គ និងបុគ្គលអ្នកស្វែងរកនូវគុណដ៏ធំ (ព្រះអរហន្ត) ទើបពេញចិត្តការបូជានោះៗ ។ អ្នកប្រាជ្ញ ត្រូវបូជាយ៉ាងនេះ ការបូជានុ៎ះមានផលច្រើន ។ ក៏កាលបុគ្គលបូជាយ៉ាងនេះ ទើបប្រសើរមិនមានបាប ការបូជា ឈ្មោះថា មានផលច្រើនផង ទេវតាទាំងឡាយ តែងជ្រះថ្លាផង ។

[៤១] អថខោ ឧជាយិ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឧជាយិ ព្រាហ្មណោ ភគវន្តំ ឯតទវោច ភវំបិ នោ គោតមោ យញ្ញំ វណ្ណេតីតិ ។ ន ខោ អហំ ព្រាហ្មណ សព្វំ យញ្ញំ វណ្ណេមិ ន បនាហំ ព្រាហ្មណ សព្វំ យញ្ញំ ន វណ្ណេមិ ។ យថារូបេ ខោ ព្រាហ្មណ យញ្ញេ គាវោ ហញ្ញន្តិ អជេឡកា ហញ្ញន្តិ កុក្កុដសូករា ហញ្ញន្តិ វិវិធា បាណា សង្ឃាតំ អាបជ្ជន្តិ ឯវរូបំ ខោ អហំ ព្រាហ្មណ សារម្ភំ យញ្ញំ ន វណ្ណេមិ ។ តំ កិស្ស ហេតុ ។ ឯវរូបញ្ហិ ព្រាហ្មណ សារម្ភំ យញ្ញំ ន ឧបសង្កមន្តិ អរហន្តោ វា អរហត្តមគ្គំ វា សមាបន្នា ។ យថារូបេ ច ខោ ព្រាហ្មណ យញ្ញេ នេវ គាវោ ហញ្ញន្តិ ន អជេឡកា ហញ្ញន្តិ ន កុក្កុដសូករា ហញ្ញន្តិ

[៤១] គ្រានោះ ឧទាយិព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ អង្គុយក្នុងទីសមគួរ ។ លុះឧទាយិព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគថា ព្រះគោតមដ៏ចម្រើន សរសើរការបូជារបស់យើងដែរឬទេ ។ ម្នាលព្រាហ្មណ៍ តថាគតមិនសរសើរការបូជាទាំងអស់ទេ ម្នាលព្រាហ្មណ៍ ប៉ុន្តែតថាគត មិនមែនជាមិនសរសើរការបូជាទាំងអស់ទេ ។ ម្នាលព្រាហ្មណ៍ គេសម្លាប់គោទាំងឡាយ សម្លាប់ពពែនិងចៀមទាំងឡាយ សម្លាប់មាន់និងជ្រូកទាំងឡាយ សត្វទាំងឡាយផ្សេង ៗ ស្លាប់ព្រោះការបូជាមានសភាពយ៉ាងណា ម្នាលព្រាហ្មណ៍ តថាគតមិនសរសើរការបូជាប្រកបដោយសេចក្តីអន្តរាយ មានសភាពយ៉ាងនោះឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះអរហន្តទាំងឡាយក្តី បុគ្គលទាំងឡាយអ្នកដល់នូវអរហត្តមគ្គក្តី មិននិយមការបូជា ប្រកបដោយសេចក្តីអន្តរាយ មានសភាពយ៉ាងនេះឡើយ ។ ម្នាលព្រាហ្មណ៍ គេមិនសម្លាប់គោទាំងឡាយ មិនសម្លាប់ពពែនិងចៀមទាំងឡាយ មិនសម្លាប់មាន់និងជ្រូកទាំងឡាយ

ន វិធា ចាណា សង្ឃាតំ អាបជ្ជន្តិ ឯវរូបំ ខោ អហំ ព្រាហ្មណ នីរារម្ភំ យញ្ញំ វណ្ណេមិ យទិទំ និច្ចទានំ អនុកុលយញ្ញំ ។ តំ កិស្ស ហេតុ ។ ឯវរូបញ្ហិ ព្រាហ្មណ និរារម្ភំ យញ្ញំ ឧបសង្កមន្តិ អរហន្តោ វា អរហត្តមគ្គំ វា សមាបន្នាតិ ។

អភិសង្ខតំ និរារម្ភំ
យញ្ញំ កាលេន កប្បិយំ
តាទិសំ ឧបសំយន្តិ[១]
សញ្ញតា ព្រហ្មចារយោ[២]
វិវដច្ឆទា ចេ យេ លោកេ
វីតវត្តា កុលំ គតឹ[៣]
យញ្ញមេតំ បសំសន្តិ
ពុទ្ធា បុញ្ញស្ស[៤] កោវិទា
យញ្ញេ វា យទិ វា សទ្ធេ
ហុញ្ញំ[៥] កត្វា យថារហំ
បសន្នចិត្តោ យជតិ
សុក្ខេត្តេ ព្រហ្មចារិសុ

១ ម. ឧបសង្កមន្តិ ។ ២ ឱ. ម. ព្រហ្មចរិយា ។ ៣ ឱ. វីតិវត្តកាលំ គតឹ ។ ៤ ម. យញ្ញស្ស ។ ៥ ម. ហាច្ចំ ។ ឱ. ធព្យំ ។

សត្វទាំងឡាយផ្សេង ៗ មិនស្លាប់ ព្រោះការបូជា មានសភាពយ៉ាងណា ម្នាលព្រាហ្មណ៍ តថាគតតែងសរសើរ ការបូជាមិនប្រកបដោយសេចក្តីអន្តរាយ មានសភាពយ៉ាងនេះគឺនិច្ចទាននិងការបូជាតាមលំអាននៃត្រកូល ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះអរហន្តទាំង-ឡាយក្តី បុគ្គលទាំងឡាយ អ្នកដល់នូវអរហត្តមគ្គក្តី តែងចូលទៅជិតការបូជាដែលមិនប្រកបដោយសេចក្តីអន្តរាយ មានសភាពយ៉ាងនេះ ។

យញ្ញដែលគេតាក់តែងហើយ មិនប្រកបដោយសេចក្តី
អន្តរាយ គួរតាមកាល ពួកព្រហ្មចារីបុគ្គល ជាអ្នក
សង្រួម តែងចូលទៅជិតនូវយញ្ញប្រាកដដូច្នោះ ព្រះ
ពុទ្ធទាំងឡាយ មានកិលេសដូចជាគ្រឿងប្រក់បើក
ហើយក្នុងលោក បានប្រព្រឹត្តកន្លងនូវវដ្តត្រកូលនឹង
វដ្តគតិ ព្រះអង្គឆ្លៀវឆ្លាសក្នុងបុណ្យ ទ្រង់សរសើរ
នូវការបូជានុ៎ះ បុគ្គលមានចិត្តជ្រះថ្លា ធ្វើនូវគ្រឿង
បូជាដ៏សមគួរ ទោះក្នុងយញ្ញគឺបកតិទានក្តី ទោះ
ក្នុងការបូជា ដោយសទ្ធាគឺមតកទានក្តី ហើយបូជា
ចំពោះព្រហ្មចារីបុគ្គលទាំងឡាយ ជាស្រែបុណ្យដ៏ល្អ

សុហុតំ សុយិដ្ឋំ សម្បត្តំ ទក្ខិណេយ្យេសុ យំ កតំ
យញ្ញោ ច វិបុលោ ហោតិ បសីទន្តិ ច ទេវតា ។
ឯវំ យជិត្វា មេធាវី សទ្ធោ មុត្តេន ចេតសា
អព្យាបជ្ឈំ សុខំ លោកំ បណ្ឌិតោ ឧបបជ្ជតីតិ ។

ចក្កវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

ចក្កោ សង្គហោ សីហោ
បាសាទោ វស្សការេន បញ្ចមំ
ទោណោ អបរិហានិ បដិលីនោ
ឧជ្ជយោ ឧទាយេន តេ ទសាតិ[១] ។

១ ឱ. លោកេ អបរិហានិយោ បដិលីនេន ឧជយោ តេ ទសាតិ ។ ម. ទោណោ អបរិហា-និយោ បដិលីនោ ឧជយោ ឧទាយិនា តេ ទសាតិ ។

យញ្ញណាដែលជនធ្វើហើយ ចំពោះទក្ខិណេយ្យបុគ្គលទាំងឡាយ (យញ្ញនោះ) ឈ្មោះថាបូជាហើយដោយប្រពៃ បូជាហើយដោយល្អ សម្រេចហើយដោយស្រួល ឈ្មោះថា យញ្ញមានផលច្រើនផង ទេវតាទាំងឡាយតែងជ្រះថ្លាផង ។ បណ្ឌិតជាមេធាវីមានសទ្ធាមានចិត្តលះ (ទ្រព្យ) បូជាយ៉ាងនេះហើយ រមែងចូលទៅកាន់លោកជាសុខ មិនមានការបៀតបៀន ។

ចប់ ចក្កវគ្គទី ៤ ។

## ឧទ្ទាននៃចក្កវគ្គនោះគឺ

និយាយអំពីចក្កធម៌ ១ សង្គហវត្ថុ ១ ប្រៀបដោយសត្វសីហៈ ១ ការជ្រះថ្លា ១ វស្សការព្រាហ្មណ៍ ១ ជាគម្រប់ ៥ ទោណព្រាហ្មណ៍ ១ ការមិនសាបសូន្យ (ចាកព្រះនិព្វាន) ១ ភិក្ខុមានការស្ងប់ស្ងាត់ ១ ឧជ្ជយព្រាហ្មណ៍ ១ ឧទាយិព្រាហ្មណ៍ ១ រួមទាំងអស់ត្រូវជា ១០ ។

# រោហិតស្សវគ្គោ

[៤២] ចតស្សោ ឥមា ភិក្ខវេ សមាធិភាវនា ។ កតមា ចតស្សោ ។ អត្ថិ ភិក្ខវេ សមាធិភាវនា ភាវិតា ពហុលីកតា ទិដ្ឋធម្មសុខវិហារាយ សំវត្តតិ អត្ថិ ភិក្ខវេ សមាធិភាវនា ភាវិតា ពហុលីកតា ញាណ-ទស្សនប្បដិលាភាយ សំវត្តតិ អត្ថិ ភិក្ខវេ សមាធិភាវនា ភាវិតា ពហុលីកតា សតិសម្បជញ្ញាយ សំវត្តតិ អត្ថិ ភិក្ខវេ សមាធិភាវនា ភាវិតា ពហុលីកតា អាសវានំ ខយាយ សំវត្តតិ ។ កតមា ច ភិក្ខវេ សមាធិភាវនា ភាវិតា ពហុលីកតា ទិដ្ឋធម្មសុខវិហា-រាយ សំវត្តតិ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ

# រោហិតស្សវគ្គ

[៤២] ម្នាលភិក្ខុទាំងឡាយ សមាធិភាវនា[១]នេះមាន ៤ យ៉ាង ។ សមាធិភាវនា ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ប្រព្រឹត្តទៅ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ១ ម្នាលភិក្ខុទាំងឡាយ សមាធិភាវនា ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ[២] ១ ម្នាលភិក្ខុទាំងឡាយ សមាធិភាវនា ដែលបុគ្គលចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ប្រព្រឹត្តទៅ ដើម្បីសតិនិងសម្បជញ្ញៈ ១ ម្នាលភិក្ខុទាំងឡាយ សមាធិភាវនា ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមាធិភាវនា ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ប្រព្រឹត្តទៅ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកធម៌ ជាអកុសលទាំងឡាយហើយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ សម្រេចសម្រាន្តនៅ

---

១-២- ចូរមើលតាមនយលក្ខណៈក្នុងសង្គីតិសូត្រ ទីឃនិកាយ ឆដ្ឋមភាគ បាដិកវគ្គ ។

វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយំ[១] ភិក្ខវេ សមាធិភាវនា ភាវិតា ពហុលីកតា ទិដ្ឋធម្មសុខវិហារាយ សំវត្តតិ ។ កតមា ច ភិក្ខវេ សមាធិភាវនា ភាវិតា ពហុលីកតា ញាណទស្សនប្បដិលាភាយ សំវត្តតិ ។ ឥធ ភិក្ខវេ

---

១ ឱ. អយំ វុច្ចតិ ។

ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ក៏ចូលទៅកាន់ទុតិយជ្ឈាន ជាធម្មជាត កើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខ កើតអំពីសមាធិគឺបឋមជ្ឈាន សម្រេចសម្រាន្តនៅ ព្រោះប្រាសចាកបីតិផង ជាបុគ្គលព្រងើយកន្តើយផង មានសតិនិងសម្បជញ្ញៈផង ទទួលនូវសុខដោយនាមកាយផង ព្រះអរិយទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា ប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បានដល់នូវតតិយជ្ឈាននោះ សម្រេចសម្រាន្តនៅ ព្រោះលះបង់នូវសេចក្តីសុខផង លះបង់នូវសេចក្តីទុក្ខផង មានសោមនស្សនិងទោមនស្សអស់ទៅ ក្នុងកាលមុនផង ក៏បានដល់នូវចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍ មិនមែនជាទុក្ខ មិនមែនជាសុខគឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសមាធិភាវនា ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ប្រព្រឹត្តទៅ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ចុះសមាធិភាវនា ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

ភិក្ខុ អាលោកសញ្ញំ មនសិករោតិ ទិវាសញ្ញំ អធិដ្ឋាតិ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ។ ឥតិ វិវត្តេន[១] ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។ អយំ ភិក្ខវេ សមាធិភាវនា ភាវិតា ពហុលីកតា ញាណទស្សនប្បដិលាភាយ សំវត្តតិ ។ កតមា ច ភិក្ខវេ សមាធិភាវនា ភាវិតា ពហុលីកតា សតិសម្បជញ្ញាយ សំវត្តតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ វិទិតា វេទនា ឧប្បជ្ជន្តិ វិទិតា តិដ្ឋន្តិ[២] វិទិតា អព្ភត្ថំ គច្ឆន្តិ វិទិតា សញ្ញា... វិទិតា វិតក្កា ឧប្បជ្ជន្តិ វិទិតា តិដ្ឋន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។ អយំ ភិក្ខវេ សមាធិភាវនា ភាវិតា ពហុលីកតា សតិសម្បជញ្ញាយ សំវត្តតិ ។ កតមា ច ភិក្ខវេ សមាធិភាវនា ភាវិតា ពហុលីកតា អាសវានំ ខយាយ សំវត្តតិ ។ ឥធ ភិក្ខវេ ភិក្ខុ

---

១ ឱ. ម. វិវដេន ។ ២ ឱ. ម. ឧបដ្ឋហន្តិ ។

ធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា (សេចក្តីសម្គាល់ក្នុងពន្លឺ) អធិដ្ឋាននូវទិវាសញ្ញា (សេចក្តីសម្គាល់ក្នុងវេលាថ្ងៃ) គឺថាក្នុងវេលាថ្ងៃយ៉ាងណា វេលាយប់ក៏យ៉ាងនោះ ក្នុងវេលាយប់យ៉ាងណា វេលាថ្ងៃក៏យ៉ាងនោះដែរ ។ ភិក្ខុមានចិត្តស្ងប់ស្ងាត់ មិនមានកិលេសជាគ្រឿងរួបរឹត តែងចម្រើនចិត្តដែលប្រកបដោយពន្លឺដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសមាធិភាវនា ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ តែងប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមាធិភាវនា ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ប្រព្រឹត្តទៅ ដើម្បីសតិនិងសម្បជញ្ញៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ វេទនាទាំងឡាយរបស់ភិក្ខុក្នុងសាសនានេះ តែងកើតឡើងប្រាកដ តែងឋិតនៅប្រាកដ តែងដល់នូវសេចក្តីអស់ទៅវិញប្រាកដ សញ្ញា... ប្រាកដ វិតក្កៈទាំងឡាយតែងកើតឡើងប្រាកដ តែងឋិតនៅប្រាកដ តែងដល់នូវសេចក្តីអស់ទៅវិញប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសមាធិភាវនាដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ប្រព្រឹត្តទៅ ដើម្បីសតិនិងសម្បជញ្ញៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមាធិភាវនា ដែលបុគ្គលបានចម្រើនហើយ បានធ្វើឲ្យរឿយ ៗ ហើយ ប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

បញ្ចសុ ឧបាទានក្ខន្ធេសុ ឧទយព្វយានុបស្សី វិហរតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា ឥតិ វេទនាយ សមុទយោ ឥតិ វេទនាយ អត្ថង្គមោ ឥតិ សញ្ញា ឥតិ សញ្ញាយ សមុទយោ ឥតិ សញ្ញាយ អត្ថង្គមោ ឥតិ សង្ខារា ឥតិ សង្ខារានំ សមុទយោ ឥតិ សង្ខារានំ អត្ថង្គមោ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ។ អយំ ភិក្ខវេ សមាធិភាវនា ភាវិតា ពហុលីកតា អាសវានំ ខយាយ សំវត្តតិ ។ ឥមា ខោ ភិក្ខវេ ចតស្សោ សមាធិភាវនា ។ ឥទញ្ច បន មេតំ ភិក្ខវេ សន្ធាយ ភាសិតំ បារាយនេ បុណ្ណប្បញ្ហេ ។

សង្ខាយ លោកស្មិ បរោបរានិ[១]
យស្សិញ្ជិតំ នត្ថិ កុហិញ្ចិ លោកេ
សន្តោ[២] វិធូមោ អនីឃោ និរាសោ
អតារិ សោ ជាតិជរន្តិ ព្រូមីតិ[៣] ។

១ ឱ. បរោវរានិ ។ ២ ឱ. សតោ ។ ៣ ម. ជាតិជរាយ បារន្តិ ព្រូមីតិ ។

ពិចារណាឃើញរឿយ ៗ នូវទីកើតនឹងទីរលត់ក្នុងឧបាទានក្ខន្ធទាំង ៥ ថា រូបដូច្នេះ ការកើតឡើងនៃរូបដូច្នេះ សេចក្តីអស់ទៅនៃរូបដូច្នេះ វេទនាដូច្នេះ ការកើតឡើងនៃវេទនាដូច្នេះ សេចក្តីអស់ទៅនៃវេទនាដូច្នេះ សញ្ញាដូច្នេះ ការកើតឡើងនៃសញ្ញាដូច្នេះ សេចក្តីអស់ទៅនៃសញ្ញាដូច្នេះ សង្ខារទាំងឡាយដូច្នេះ ការកើតឡើងនៃសង្ខារទាំងឡាយដូច្នេះ សេចក្តីអស់ទៅនៃសង្ខារទាំងឡាយដូច្នេះ វិញ្ញាណដូច្នេះ ការកើតឡើងនៃវិញ្ញាណដូច្នេះ សេចក្តីអស់ទៅនៃវិញ្ញាណដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសមាធិភាវនា ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ប្រព្រឹត្តទៅ ដើម្បីអស់នៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាមាន ៤ យ៉ាង នេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ តថាគតបានពោលហើយ ក្នុងបុណ្ណកប្បញ្ហា ត្រង់បរាយនវគ្គ ព្រោះសំដៅយកសមាធិភាវនាន៎ុះ ។

បុគ្គលបានពិចារណានូវសភាពធម៌ដ៏ថោកទាប និងឧត្តម ក្នុងលោក សេចក្តីរំភើបចិត្ត បន្តិចបន្តួចរបស់បុគ្គលណា មិនមានក្នុងលោក តថាគតពោលថា បុគ្គលនោះ ជាអ្នករម្ងាប់ (នូវសឹកសត្រូវគឺកិលេស) មិនមានផ្សែងគឺសេចក្តីក្រោធ មិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ឈ្មោះថា ឆ្លងនូវជាតិនិងជរាបាន ។

បឋមបណ្ណាសកេ រោហិតស្សវគ្គោ

[៤៣] ចត្តារីមានិ ភិក្ខវេ បញ្ហាព្យាករណានិ ។ កាតមានិ ចត្តារិ ។ អត្ថិ ភិក្ខវេ បញ្ហោ ឯកំសព្យា-ករណីយោ អត្ថិ ភិក្ខវេ បញ្ហោ វិភជ្ជព្យាករណីយោ អត្ថិ ភិក្ខវេ បញ្ហោ បដិបុច្ឆាព្យាករណីយោ អត្ថិ ភិក្ខវេ បញ្ហោ ឋបនីយោ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ បញ្ហាព្យាករណានីតិ ។

ឯកំសវចនំ ឯកំ វិភជ្ជវចនាបរំ
តតិយំ បដិបុច្ឆេយ្យ ចតុត្ថំ បន ឋាបយេ ។
យោ ច នេសំ តត្ថ តត្ថ ជានាតិ អនុធម្មតំ
ចតុប្បញ្ហស្ស កុសលោ អាហុ ភិក្ខុំ តថាវិធំ ។
ទុរាសទោ ទុប្បសហោ គម្ភីរោ ទុប្បធំសិយោ
អថោ អត្ថេ អនត្ថេ ច ឧភយត្ថស្ស[១] កោវិទោ

១ ឱ. ម. ឧភយស្ស ហោតិ ។

[៤៣] ម្នាលភិក្ខុទាំងឡាយ បញ្ហាព្យាករណ៍ (ការឆ្លើយប្រស្នា) នេះមាន ៤ យ៉ាង ។ បញ្ហាព្យាករណ៍ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បញ្ហាដែលគួរឆ្លើយទៅតែម្តង ១ ម្នាលភិក្ខុទាំងឡាយ បញ្ហាដែលគួរឆ្លើយចែករលែកឲ្យពិស្តារ ១ ម្នាលភិក្ខុទាំងឡាយ បញ្ហាដែលគួរសួរតបទៅវិញហើយទើបឆ្លើយ ១ ម្នាលភិក្ខុទាំងឡាយ បញ្ហាដែលគួរបញ្ឈប់ទុក ១ ។ ម្នាលភិក្ខុទាំងឡាយ បញ្ហាព្យាករណ៍ មាន ៤ យ៉ាងនេះឯង ។

បញ្ហាទី ១ ជាពាក្យគួរឆ្លើយទៅតែម្តង បញ្ហាដទៃ (ទី ២) ជាពាក្យគួរឆ្លើយចែករលែកឲ្យពិស្តារ បញ្ហាទី ៣ ជាពាក្យគួរសួរតបទៅវិញហើយទើបឆ្លើយ ចំណែកបញ្ហាទី ៤ ជាពាក្យគួរបញ្ឈប់ទុក ។ ភិក្ខុណាដឹងនូវបញ្ហាព្យាករណ៍ទាំងនោះ ដ៏សមគួរតាមធម៌ក្នុងទីនោះ ៗ អ្នកប្រាជ្ញទាំងឡាយ តែងពោលនូវភិក្ខុបែបនោះថាជាអ្នកឈ្លាសវៃ ក្នុងបញ្ហាទាំង ៤ យ៉ាង ។ មួយទៀត ភិក្ខុដែលគេបៀតបៀនបានដោយកម្រ គ្របសង្កត់បានដោយកម្រ មានធម៌ដ៏ជ្រាលជ្រៅ ដែលគេកម្ចាត់បង់បានដោយកម្រ ជាអ្នកឈ្លាសវៃ ក្នុងប្រយោជន៍ទាំងពីរគឺ សេចក្តីចម្រើន ១ សេចក្តីមិនចម្រើន ១ ។

អនត្ថំ បរិវជ្ជេតិ អត្ថំ គណ្ហាតិ បណ្ឌិតោ
អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតីតិ ។

[៤៤] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ កោធគរុ ន សទ្ធម្មគរុ មក្ខគរុ ន សទ្ធម្មគរុ លាភគរុ ន សទ្ធម្មគរុ សក្ការគរុ ន សទ្ធម្មគរុ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ សទ្ធម្មគរុ ន កោធគរុ សទ្ធម្មគរុ ន មក្ខគរុ សទ្ធម្មគរុ ន លាភគរុ សទ្ធម្មគរុ ន សក្ការ-គរុ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

កោធមក្ខគរុ ភិក្ខុ លាភសក្ការគារវោ
ន តេ ធម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេ ។

ភិក្ខុជាបណ្ឌិត តែងវៀរបង់នូវសេចក្តីមិនចម្រើន កាន់យកតែសេចក្តីចម្រើន ទើបហៅថាជាអ្នកប្រាជ្ញ មានប្រាជ្ញាជាគ្រឿងទ្រទ្រង់ ព្រោះដឹង នូវប្រយោជន៍ (ទាំងពីរប្រការនោះ) ។

[៤៤] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ មាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលជាអ្នកធ្ងន់ក្នុងសេចក្តីក្រោធ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ជាអ្នកធ្ងន់ក្នុងសេចក្តីលុបគុណ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ជាអ្នកធ្ងន់ក្នុងលាភ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ជាអ្នកធ្ងន់ក្នុងសក្ការៈ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង មាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ មាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសេចក្តីក្រោធ ១ ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសេចក្តីលុបគុណ ១ ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងលាភ ១ ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសក្ការៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង មាននៅក្នុងលោក ។

ភិក្ខុណាជាអ្នកធ្ងន់ ក្នុងសេចក្តីក្រោធ និងសេចក្តីលុបគុណ
ជាអ្នកធ្ងន់ក្នុងលាភសក្ការៈ ភិក្ខុទាំងនោះ រមែងមិនចម្រើនក្នុង
ព្រះសទ្ធម្មដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងឡើយ ។

យេ ច សទ្ធម្មគរុនោ វិហំសុ វិហរន្តិ ច
តេ វេ ជម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេតិ ។

[៤៩] ចត្តារោមេ ភិក្ខវេ អសទ្ធម្មា ។ កតមេ ចត្តារោ ។ កោធគរុតា ន សទ្ធម្មគរុតា មក្ខគរុតា ន សទ្ធម្មគរុតា លាភគរុតា ន សទ្ធម្មគរុតា សក្ការគរុតា ន សទ្ធម្មគរុតា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អសទ្ធម្មា ។ ចត្តារោមេ ភិក្ខវេ សទ្ធម្មា ។ កតមេ ចត្តារោ ។ សទ្ធម្មគរុតា ន កោធគរុតា សទ្ធម្មគរុតា ន មក្ខគរុតា សទ្ធម្មគរុតា ន លាភគរុតា សទ្ធម្មគរុតា ន សក្ការគរុតា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ សទ្ធម្មាតិ ។

ភិក្ខុទាំងឡាយណា ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម នៅហើយផង នៅឥឡូវនេះផង ភិក្ខុទាំងនោះ រមែងចម្រើនក្នុងព្រះសទ្ធម្ម ដែលព្រះសម្មាសម្ពុទ្ធត្រាស់សម្តែងហើយ ។

[៤៩] ម្នាលភិក្ខុទាំងឡាយ អសទ្ធម្មទាំងឡាយនេះមាន ៤ យ៉ាង ។ អសទ្ធម្ម ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺភាពនៃបុគ្គលជាអ្នកធ្ងន់ ក្នុងសេចក្តីក្រោធ មិនធ្ងន់ ក្នុងព្រះសទ្ធម្ម ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ ក្នុងសេចក្តីលុបគុណ មិនធ្ងន់ ក្នុងព្រះសទ្ធម្ម ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ ក្នុងលាភ មិនធ្ងន់ ក្នុងព្រះសទ្ធម្ម ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ ក្នុងសក្ការៈ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ អសទ្ធម្មមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រះសទ្ធម្មទាំងឡាយនេះ មាន ៤ យ៉ាង ។ ព្រះសទ្ធម្ម ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសេចក្តីក្រោធ ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសេចក្តីលុបគុណ ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងលាភ ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសក្ការៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសទ្ធម្មមាន ៤ យ៉ាងនេះឯង ។

កោធមក្ខគរុ ភិក្ខុ លាភសក្ការគារវោ
ទុក្ខេត្តេ វុត្តពីជំវ(១) សទ្ធម្មេ ន វិរូហតិ ។
យេ ច សទ្ធម្មគរុនោ វិហំសុ វិហរន្តិ ច
តេ វេ ធម្មេ វិរូហន្តិ ស្នេហមន្វាយមិវោសធាតិ ។

[៤៦] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ រោហិ-តស្សោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ រោហិ-តស្សោ ទេវបុត្តោ ភគវន្តំ ឯតទវោច យត្ថ នុ ខោ ភន្តេ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ សក្កា នុ ខោ(២) ភន្តេ គមនេន លោកស្ស អន្តំ ញាតុំ វា(៣) ទដ្ឋុំ វា បាបុណិតុំ វាតិ ។

១ ឱ. ម. សុខេត្តេ បូតិពីជំវ ។ ២ ឱ. សក្កា នុ ខោ សោ ។ ៣ ម. អន្តោ ញាតុំ វា ។ ឱ. អន្តំ នតុំ វា ។

ភិក្ខុជាអ្នកធ្ងន់ ក្នុងសេចក្តីក្រោធ និងសេចក្តីលុបគុណ ជាអ្នកធ្ងន់ ក្នុងលាភ ក្នុងសក្ការៈ រមែងមិនដុះដាល ឡើង ក្នុងព្រះសទ្ធម្មបានឡើយ ដូចជាពូជដែលគេព្រោះក្នុងស្រែមិនល្អ ។ ចំណែកភិក្ខុទាំងឡាយណា ជាអ្នកធ្ងន់ ក្នុងព្រះសទ្ធម្ម នៅហើយផង នៅឥឡូវនេះផង ភិក្ខុទាំងនោះឯង តែងចម្រើនក្នុងព្រះធម៌ ដូចជាពូជ តែងដុះឡើង ព្រោះអាស្រ័យទឹកដូច្នោះ ។

[៤៦] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ លំដាប់នោះឯង រោហិតស្ស-ទេវបុត្ត កាលវេលារាត្រី (បឋមយាម) កន្លងទៅហើយ មានពន្លឺដ៏រុងរឿង ញុំាងវត្តជេតពនទាំងមូល ឲ្យភ្លឺស្វាង ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ លុះរោហិតស្សទេវបុត្តឋិតនៅក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងឱកាសនៃចក្រវាឡលោកណា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលអាចដើម្បីដឹង ដើម្បីឃើញឬដើម្បីដល់នូវទីបំផុតនៃលោក (នោះ) ដោយកិរិយាដើរទៅ (ដោយជើង) បានដែរឬ ។

យត្ថ ខោ អាវុសោ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ ណាហន្តំ គមនេន លោកស្ស អន្តំ ញាតយ្យំ[១] ទដ្ឋយ្យំ បត្តយ្យន្តិ វទាមីតិ ។ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតញ្ចិទំ ភន្តេ ភគវតា យត្ថ ខោ អាវុសោ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ ណាហន្តំ គមនេន លោកស្សអន្តំ ញាតយ្យំ ទដ្ឋយ្យំ បត្តយ្យន្តិ វទាមីតិ ភូតបុព្វាហំ ភន្តេ រោហិតស្សោ នាម ឥសិ អហោសឹ ភោជបុត្តោ ឥទ្ធិមា វេហាសង្គមោ ។ តស្ស មយ្ហំ ភន្តេ ឯវរូបោ ជវោ អហោសិ សេយ្យថាបិ នាម ទឡ្ហធម្មោ ធនុគ្គហោ សុសិក្ខិតោ កតហត្ថោ កតុបាសនោ លហុកេន អសនេន អប្បកសិរេន តិរិយំ តាលច្ឆាយំ[២] អតិបាតេយ្យ

១ ញាតេយ្យន្តិ អដ្ឋកថាយំ ទិស្សតិ ។ ២ ម. តាលច្ឆាទឹ ។ ឱ. តាលច្ឆាតឹ ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារលោកណា តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ (ដោយជើង) បានឡើយ ។ រោហិតស្សទេវបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះតម្រាស់នេះ ដែលព្រះដ៏មានព្រះភាគត្រាស់ប្រពៃហើយថា ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារលោកណា តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ (ដោយជើង) បានឡើយ បពិត្រព្រះអង្គដ៏ចម្រើន កាលពីព្រេងនាយមក ខ្ញុំព្រះអង្គធ្លាប់កើតជាឥសីឈ្មោះរោហិតស្សៈ ជាបុត្ររបស់ព្រានព្រៃ មានឫទ្ធិទៅដោយអាកាសវេហាស៍បាន ។ បពិត្រព្រះអង្គដ៏ចម្រើន សន្ទុះមានសភាពយ៉ាងនេះ បានកើតដល់ខ្ញុំព្រះអង្គនោះ ប្រៀបដូចនាយខ្មាន់ធ្នូ មានធនុធម៌ដ៏មាំ បានសិក្សាដោយប្រពៃហើយ មានដៃដ៏ស្ទាត់ មានការបាញ់ដ៏ស្ទាត់ បានយកព្រួញដ៏ស្រាល (បាញ់) ឲ្យឆ្លងរំលងទទឹងស្រមោលដើមត្នោតដោយមិនលំបាក

១១៦



ឯវរូបោ បទវីតិហារោ អហោសិ សេយ្យថាបិ នាម បុរត្ថិមា សមុទ្ទា បច្ឆិមោ សមុទ្ទោ ។ តស្ស មយ្ហំ ភន្តេ ឯវរូបេន ជវេន សមន្នាគតស្ស ឯវរូបេន ច បទវីតិហារេន ឯវរូបំ ឥច្ឆាគតំ ឧប្បជ្ជិ អហំ គមនេន លោកស្ស អន្តំ បាបុណិស្សាមីតិ ។ សោ ខោ អហំ ភន្តេ អញ្ញត្រេវ អសិតបីតខាយិតសាយិតា អញ្ញត្រ ឧច្ចារបស្សាវ-កម្មា អញ្ញត្រ និទ្ទាកិលមថបដិវិនោទនា វស្សសតា-យុកោ វស្សសតជីវី វស្សសតំ គន្ត្វា អប្បត្វាវ លោកស្ស អន្តំ អន្តរាយេវ កាលកតោ ។ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតមិទំ ភន្តេ ភគវតា យត្ថ ខោ អាវុសោ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ

ជំហានឈានដើរទៅ ដោយជើង មានសភាពយ៉ាងនេះ បានកើត (ដល់ខ្ញុំព្រះអង្គ) ប្រៀបដូចសមុទ្រទិសខាងលិច (ឆ្ងាយអំពី) សមុទ្រទិសខាង[១] កើត ។ បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គនោះ ប្រកបដោយសន្ទុះមានសភាពយ៉ាងនេះ ដោយការឈានដើរទៅ (ដោយជើង) មានសភាពយ៉ាងនេះហើយ សេចក្តីប្រាថ្នាមានសភាពយ៉ាងនេះ ក៏កើតឡើងថា អាត្មាអញនឹងដល់នូវទីបំផុតនៃលោក ដោយការដើរទៅ (ដោយជើង) បាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ លើកលែងតែពេលស៊ីផឹក ទំពាហុតស្រូប (នូវអាហារជាដើម) លើកលែងតែពេលធ្វើនូវឧច្ចារៈនិងបស្សាវៈ លើកលែងតែពេលដេកនិងបន្ទោបង់នូវសេចក្តីទុក្ខលំបាក ទាំងប្រកបដោយអាយុ ១០០ ឆ្នាំ មានជីវិតរស់នៅបាន ១០០ ឆ្នាំ ដើរទៅអស់ ១០០ ឆ្នាំ ក៏គង់មិនដល់នូវទីបំផុតនៃលោកបានឡើយ ធ្វើមរណកាលក្នុងចន្លោះនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះតម្រាស់នេះ ដែលព្រះដ៏មានព្រះភាគត្រាស់ប្រពៃហើយថា ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារលោកណា

---

១ សមុទ្រទិសខាងលិចឆ្ងាយពីសមុទ្រទិសខាងកើត យ៉ាងណា កាលឈានជំហានដើរទៅក្នុងទីឆ្ងាយ ក៏យ៉ាងនុ៎ះដែរ ។ អដ្ឋកថា ។

១១៧



ណាហន្តំ គមនេន លោកស្ស អន្តំ ញាតយ្យំ ទដ្ឋយ្យំ បត្តយ្យន្តិ វទាមីតិ ។ យត្ថ ខោ អាវុសោ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ ណាហន្តំ គមនេន លោកស្ស អន្តំ ញាតយ្យំ ទដ្ឋយ្យំ បត្តយ្យន្តិ វទាមិ ន ចាហំ អាវុសោ អប្បត្វា វ លោកស្ស អន្តំ ទុក្ខស្ស អន្តកិរិយំ វទាមិ ។ អបិចាហំ អាវុសោ ឥមស្មឹយេវ ព្យាមមត្តេ កឡេវរេ សសញ្ញិម្ហិ[១] សមនកេ លោកញ្ច បញ្ញាបេមិ លោកសមុទយញ្ច លោក-និរោធញ្ច លោកនិរោធគាមិនិញ្ច បដិបទន្តិ ។

គមនេន ន បត្តព្វោ លោកស្សន្តោ កុទាចនំ
ន ច អប្បត្វា លោកន្តំ ទុក្ខា អត្ថិ បមោចនំ ។

---

១ ម. សសញ្ញិម្ហិ ។ ឱ. សញ្ញិម្ហិ ។

តថាគត មិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ (ដោយជើង) បានឡើយ ។ ម្នាលអាវុសោ បុគ្គល មិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារលោកណា តថាគត មិនបានពោលថា បុគ្គល គប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុត នៃលោកនោះដោយកិរិយាដើរទៅ (ដោយជើង) បានឡើយ ម្នាលអាវុសោ មួយទៀត បើតថាគត មិនបានដល់នូវទីបំផុតនៃសង្ខារលោកហើយ ក៏មិនបានពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខឡើយ ។ ម្នាលអាវុសោ មួយទៀត តថាគតតែងបញ្ញត្តនូវលោកគឺទុក្ខផង លោកសមុទយៈផង លោកនិរោធផង លោកនិរោធគាមិនីបដិបទាផង ក្នុងអត្តភាពប្រមាណ ១ ព្យាមនេះឯង ដែលប្រកបដោយសញ្ញាផង ប្រកបដោយចិត្តផង ។

ទីបំផុតនៃលោក បុគ្គល មិនគប្បីដល់ ដោយការដើរទៅ
(ដោយជើង) ក្នុងកាលណាម្តងឡើយ មួយទៀត ការមិនទាន់
ដល់នូវទីបំផុតនៃលោក ឈ្មោះថា មិនបានរួចចាកទុក្ខឡើយ ។

តស្មា ហវេ លោកវិទូ សុមេធោ
លោកន្តគូ វុសិតព្រហ្មចរិយោ ។
លោកស្ស អន្តំ សមិតាវិ ញត្វា
នាសីសតិ លោកមិមំ បរញ្ចាតិ ។

[៤៧] អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាមន្តេសិ ឥមំ ភិក្ខវេ រត្តឹ រោហិតស្សោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ ភិក្ខវេ រោហិតស្សោ ទេវបុត្តោ មំ ឯតទវោច យត្ថ នុ ខោ ភន្តេ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ សក្កា នុ ខោ ភន្តេ គមនេន លោកស្ស អន្តំ ញាតុំ វា ទដ្ឋុំ វា បាបុណិតុំ វាតិ ។

ព្រោះហេតុនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាប
ច្បាស់នូវលោក ទ្រង់មានបញ្ញាល្អ ទ្រង់ដល់នូវ
ទីបំផុតនៃលោក ទ្រង់ប្រព្រឹត្តចប់ព្រហ្មចរិយៈហើយ ។
ទ្រង់មានបាបរម្ងាប់បង់ហើយ ទ្រង់ជ្រាបច្បាស់
នូវទីបំផុតនៃលោកហើយ មិនប្រាថ្នានូវលោក
នេះ និងលោកខាងមុខឡើយ ។

[៤៧] លុះកន្លងរាត្រីនោះហើយ ព្រះដ៏មានព្រះភាគ បាន ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងរាត្រីនេះ រោហិតស្សទេវបុត្ត កាលដែលវេលារាត្រី (បឋមយាម) កន្លងទៅហើយ មាន ពន្លឺដ៏រុងរឿង ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ក៏ចូលមករកតថាគត លុះចូលមកដល់ ក៏ថ្វាយបង្គំតថាគតហើយឋិតនៅក្នុងទីសមគួរ ។ ម្នាល ភិក្ខុទាំងឡាយ លុះរោហិតស្សទេវបុត្ត អង្គុយក្នុងទីសមគួរហើយ បាន និយាយនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលមិនកើត មិន ចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងឱកាសនៃចក្រវាឡលោកណា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលអាចដើម្បីដឹង ដើម្បីឃើញ ឬដើម្បីដល់ នូវទីបំផុតនៃលោកនោះ ដោយកិរិយាដើរទៅ (ដោយជើង) បានដែរឬ ។

ឯវំ វុត្តេ អហំ ភិក្ខវេ រោហិតស្សំ ទេវបុត្តំ ឯតទវោចំ យត្ថ ខោ អាវុសោ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ នាហន្តំ គមនេន លោកស្ស អន្តំ ញាតយ្យំ ទដ្ឋយ្យំ បត្តយ្យន្តិ វទាមីតិ ។ ឯវំ វុត្តេ ភិក្ខវេ រោហិតស្សោ ទេវបុត្តោ មំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតញ្ចិទំ ភន្តេ ភគវតា យត្ថ ខោ អាវុសោ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ នាហន្តំ គមនេន លោកស្ស អន្តំ ញាតយ្យំ ទដ្ឋយ្យំ បត្តយ្យន្តិ វទាមីតិ ភូតបុព្វាហំ ភន្តេ រោហិតស្សោ នាម ឥសិ អហោសឹ ភោជបុត្តោ ឥទ្ធិមា វេហាសង្គមោ ។ តស្ស មយ្ហំ ភន្តេ ឯវរូបោ ជវោ អហោសិ សេយ្យថាបិ នាម ទឡ្ហធម្មោ ធនុគ្គហោ សុសិក្ខិតោ

ម្នាលភិក្ខុទាំងឡាយ កាលរោហិតស្សទេវបុត្ត ពោលនឹងតថាគតយ៉ាងនេះហើយ តថាគតបានពោលទៅនឹងរោហិតស្សទេវបុត្តថា ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារ-លោកណា តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ (ដោយដើង) បានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលតថាគតពោលយ៉ាងនេះហើយ រោហិតស្សទេវបុត្ត បាននិយាយនឹងតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះតម្រាស់នេះ ដែលព្រះដ៏មានព្រះភាគត្រាស់ប្រពៃហើយថា ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារលោកណា តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ (ដោយដើង) បានឡើយ បពិត្រព្រះអង្គដ៏ចម្រើន កាលពីព្រេងនាយមក ខ្ញុំព្រះអង្គធ្លាប់កើតជាឥសី ឈ្មោះរោហិតស្សៈ ជាបុត្តរបស់ព្រានព្រៃ មានឫទ្ធិទៅដោយអាកាសវេហាស៍បាន ។ បពិត្រព្រះអង្គដ៏ចម្រើន សន្ទុះមានសភាពយ៉ាងនេះ បានកើតដល់ខ្ញុំព្រះអង្គនោះ ប្រៀបដូចនាយខ្មាន់ធ្នូ មានធនុធម៌ដ៏មាំ បានសិក្សាដោយប្រពៃហើយ

កតហត្ថោ កតុបាសនោ លហុកេន អសនេន អប្ប-
កសិរេន តិរិយំ តាលច្ឆាយំ អតិបាតេយ្យ ឯវរូបោ បទ-
វីតិហារោ អហោសិ សេយ្យថាបិ នាម បុរត្ថិមា សមុទ្ទា
បច្ឆិមោ សមុទ្ទោ តស្ស មយ្ហំ ភន្តេ ឯវរូបេន
ជវេន សមន្នាគតស្ស ឯវរូបេន ច បទវីតិហារេន
ឯវរូបំ ឥច្ឆាគតំ ឧប្បជ្ជិ អហំ គមនេន លោកស្ស
អន្តំ បាបុណិស្សាមីតិ ។ សោ ខោ អហំ ភន្តេ
អញ្ញត្រេវ អសិតបីតខាយិតសាយិតា អញ្ញត្រ
ឧច្ចារបស្សាវកម្មា អញ្ញត្រ និទ្ទាកិលមថបដិវិនោទនា
វស្សសតាយុកោ វស្សសតជីវី វស្សសតំ គន្ត្វា អប្បត្វា
វ លោកស្ស អន្តំ អន្តរាយេវ កាលកតោ ។
អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតញ្ចិទំ
ភន្តេ ភគវតា យត្ថ ខោ អាវុសោ ន ជាយតិ
ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ

មានដៃដ៏ស្ទាត់ មានការបាញ់ដ៏ស្ទាត់ បានយកព្រួញដ៏ស្រាល (បាញ់) ឲ្យឆ្លងរំលងទទឹងស្រមោលដើមត្នោត ដោយមិនលំបាក ជំហានឈាន ដើរទៅដោយជើង មានសភាពយ៉ាងនេះ បានកើតដល់ខ្ញុំព្រះអង្គនោះ ប្រៀបដូចសមុទ្រទិសខាងលិច (ឆ្ងាយ) អំពីសមុទ្រទិសខាងកើត ។ បពិត្រ ព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គនោះ ប្រកបដោយសន្ទុះមានសភាពយ៉ាង នេះ ដោយការឈានដើរទៅ (ដោយជើង) មានសភាពយ៉ាងនេះហើយ សេចក្តីប្រាថ្នាមានសភាពយ៉ាងនេះ ក៏កើតឡើងថា អាត្មាអញនឹងដល់ នូវទីបំផុតនៃលោក ដោយកិរិយាដើរទៅ (ដោយជើង) បាន ។ បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ លើកលែងតែពេលស៊ីផឹក ទំពា ហុតស្រូប (នូវអាហារជាដើម) លើកលែងតែពេលធ្វើនូវឧច្ចារៈ និងបស្សាវៈ លើក លែងតែពេលដេកនិងបន្ទោបង់នូវសេចក្តីទុក្ខលំបាក ទាំងប្រកបដោយ អាយុ ១០០ ឆ្នាំ មានជីវិតរស់នៅបាន ១០០ ឆ្នាំ ទាំងដើរទៅអស់ ១០០ ឆ្នាំ ក៏គង់មិនដល់នូវទីបំផុតនៃលោកបានឡើយ ក៏ធ្វើមរណកាល ក្នុងចន្លោះ នោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះតម្រាស់នេះ ដែលព្រះដ៏មានព្រះភាគត្រាស់ប្រពៃហើយថា ម្នាលអាវុសោ បុគ្គលមិន កើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារលោកណា

១២១



ជាហន្តំ គមនេន លោកស្ស អន្តំ ញាតយ្យំ ទដ្ឋយ្យំ បត្តយ្យន្តិ វទាមីតិ ។ ឯវំ វុត្តេ អហំ ភិក្ខវេ រោហិតស្សំ ទេវបុត្តំ ឯតទវោចំ យត្ថ ខោ អាវុសោ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ ជាហន្តំ គមនេន លោកស្ស អន្តំ ញាតយ្យំ ទដ្ឋយ្យំ បត្តយ្យន្តិ វទាមិ ន ចាហំ អាវុសោ អប្បត្វា វ លោកស្ស អន្តំ ទុក្ខស្ស អន្តកិរិយំ វទាមិ អបិចាហំ អាវុសោ ឥមស្មឹយេវ ព្យាមមត្តេ កឡេវរេ សសញ្ញិម្ហិ សមនកេ លោកញ្ច បញ្ញាបេមិ លោកសមុទយញ្ច លោក-និរោធញ្ច លោកនិរោធគាមិនិញ្ច បដិបទន្តិ ។

គមនេន ន បត្តព្វោ លោកស្សន្តោ កុទាចនំ
ន ច អប្បត្វា លោកន្តំ ទុក្ខា អត្ថិ បមោចនំ ។

តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ (ដោយជើង) បានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលរោហិតស្សទេវបុត្ត ពោលយ៉ាងនេះហើយ តថាគត បានពោលទៅនឹងរោហិតស្សទេវបុត្តថា ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារលោកណា តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ (ដោយជើង) បានឡើយ ។ ម្នាលអាវុសោ មួយទៀត បើតថាគតមិនបានដល់នូវទីបំផុតនៃសង្ខារលោកហើយ ក៏មិនបានពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខឡើយ ម្នាលអាវុសោ មួយទៀត តថាគតតែងបញ្ញត្តនូវលោកផង លោកសមុទយៈផង លោកនិរោធផង លោកនិរោធគាមិនីបដិបទាផង ក្នុងអត្តភាពប្រមាណ ១ ព្យាមនេះឯង ដែលប្រកបដោយសញ្ញាផង ប្រកបដោយចិត្តផង ។

ទីបំផុតនៃលោក បុគ្គលមិនគប្បីដល់ដោយការដើរទៅ (ដោយ
ជើង) ក្នុងកាលណាម្តងឡើយ មួយទៀត ការមិនទាន់ដល់នូវ
ទីបំផុតនៃលោក ឈ្មោះថា មិនបានរួចចាកទុក្ខឡើយ ។

តស្មា ហវេ លោកវិទូ សុមេធោ
លោកន្តគូ វុសិតព្រហ្មចរិយោ ។
លោកស្ស អន្តំ សមិតាវិ ញត្វា
នាសីសតិ លោកមិមំ បរញ្ចាតិ ។

[៤៨] ចត្តារីមានិ ភិក្ខវេ សុវិទូរវិទូរានិ ។ កតមានិ ចត្តារិ ។ នភញ្ច ភិក្ខវេ បថវី ច ឥទំ បឋមំ សុវិទូរវិទូរេ[១] ឱរិមញ្ច ភិក្ខវេ តីរំ សមុទ្ទស្ស ចារិមញ្ច តីរំ ឥទំ ទុតិយំ សុវិទូរវិទូរេ យតោ ភិក្ខវេ វេរោចនោ អព្ភុទេតិ យត្ថ ច អត្ថង្គមេតិ ឥទំ តតិយំ សុវិទូរវិទូរេ សតញ្ច ភិក្ខវេ ធម្មោ អសតញ្ច ធម្មោ ឥទំ ចតុត្ថំ សុវិទូរវិទូរេ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ សុវិទូរវិទូរានីតិ ។

១ ឱ. ម. សុវិទូរវិទូរំ ។

ព្រោះហេតុនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាប
ច្បាស់នូវលោក ទ្រង់មានបញ្ញាល្អ ទ្រង់ដល់នូវ
ទីបំផុតនៃលោក ទ្រង់ប្រព្រឹត្តចប់ព្រហ្មចរិយៈហើយ ។
ទ្រង់មានបាបរម្ងាប់បង់ហើយ ទ្រង់ជ្រាបច្បាស់នូវ
ទីបំផុតនៃលោកហើយ មិនប្រាថ្នានូវលោកនេះ និង
លោកខាងមុខឡើយ ។

[៤៨] ម្នាលភិក្ខុទាំងឡាយ របស់ដែលឆ្ងាយក្រៃលែងឆ្ងាយនេះ មាន ៤ យ៉ាង ។ របស់ដែលឆ្ងាយក្រៃលែងឆ្ងាយ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មេឃនិងផែនដី នេះជារបស់ឆ្ងាយក្រៃលែងឆ្ងាយទី ១ ម្នាលភិក្ខុទាំងឡាយ ត្រើយសមុទ្រខាងអាយនិងត្រើយសមុទ្រខាងនាយ នេះជារបស់ឆ្ងាយក្រៃលែងឆ្ងាយទី ២ ម្នាលភិក្ខុទាំងឡាយ ព្រះអាទិត្យរះឡើងអំពីទិសណា អស្តង្គតទៅក្នុងទិសណា នេះជារបស់ឆ្ងាយក្រៃលែងឆ្ងាយទី ៣ ម្នាលភិក្ខុទាំងឡាយ ធម៌របស់ពួកសប្បុរស និងធម៌របស់ពួកអសប្បុរស នេះជារបស់ឆ្ងាយក្រៃលែងឆ្ងាយទី ៤ ។ ម្នាលភិក្ខុទាំងឡាយ របស់ដែលឆ្ងាយក្រៃលែងឆ្ងាយមាន ៤ យ៉ាងនេះឯង ។

នភញ្ច(១) ទូរេ បឋវី ច ទូរេ
បារំ សមុទ្ទស្ស តទាហុ ទូរេ
យតោ ច វេរោចនោ អព្ភុទេតិ
បភង្ករោ យត្ថ ច អត្ថមេតិ
តតោ ហវេ ទូរតរំ វទន្តិ
សតញ្ច ធម្មំ អសតញ្ច ធម្មំ ។
អព្យាយិកោ ហោតិ សតំ សមាគមោ
យាវម្បិ តិដ្ឋេយ្យ(២) តថេវ ហោតិ ។
ខិប្បញ្ហិ វេតិ អសតំ សមាគមោ
តស្មា សតំ ធម្មា អសព្ភិ អារកាតិ ។

[៤៩] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា វិសាខោ បញ្ចាលីបុត្តោ ឧបដ្ឋា-នសាលាយំ ភិក្ខូ ធម្មិយា កថាយ សន្ទ-ស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ

១ ឱ. ម. នភា ។ ២ ម. យាវាបិ តិដ្ឋេយ្យ ។

មេឃនិងផែនដី វមែងឆ្ងាយអំពីគ្នា ត្រើយសមុទ្រនោះ លោកពោលថា ឆ្ងាយអំពីគ្នា ព្រះអាទិត្យជាអ្នកធ្វើនូវពន្លឺ រះឡើងអំពីទិសណា អស្តង្គតទៅវិញក្នុងទិសណា រមែងឆ្ងាយអំពីគ្នា បណ្ឌិតទាំងឡាយពោលថា ធម៌របស់ពួកសប្បុរស និងធម៌របស់ពួកអសប្បុរស ឆ្ងាយក្រៃលែងឆ្ងាយជាងនោះទៅទៀត ។ សមាគមរបស់ពួកសប្បុរស មិនបានព្រាត់ប្រាសចាកគ្នា សមាគមរបស់ពួកសប្បុរស ឋិតនៅដរាបណា ធម៌របស់ពួកសប្បុរស ក៏មាននៅដរាបនោះ ។ សមាគមរបស់ពួកអសប្បុរស តែងព្រាត់ប្រាសទៅឆាប់ ព្រោះហេតុនោះ ធម៌ទាំងឡាយ របស់ពួកសប្បុរស ទើបឈ្មោះថា ឆ្ងាយអំពីធម៌របស់ពួកអសប្បុរស ។

[៤៨] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះវិសាខបញ្ចាលីបុត្ត (វិសាខភិក្ខុកូននៃនាងព្រាហ្មណីឈ្មោះបញ្ចាលី) ដ៏មានអាយុ ពន្យល់ភិក្ខុទាំងឡាយ ឲ្យយល់ច្បាស់ ឲ្យកាន់យកដោយល្អ ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ក្នុងរោងឆាន់

ចោរិយា វាចាយ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា បរិយាបន្នាយ អនិស្សិតាយ ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនុបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ កោ នុ ខោ ភិក្ខវេ ឧបដ្ឋានសាលាយំ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ចោរិយា វាចាយ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា បរិយាបន្នាយ អនិស្សិតាយាតិ ។ អាយស្មា ភន្តេ វិសាខោ បញ្ចាលីបុត្តោ ឧបដ្ឋានសាលាយំ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ចោរិយា វាចាយ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា បរិយាបន្នាយ អនិស្សិតាយាតិ ។

ប្រកបដោយសម្តីជារបស់អ្នកក្រុង ជាវាចាច្បាស់លាស់ ប្រាសចាកទោស អាចញុំាងអ្នកស្តាប់ ឲ្យចូលចិត្តសេចក្តីជាក់លាក់បាន រាប់បញ្ចូលក្នុងវិវដ្តៈ មិនបានអាស្រ័យនូវវដ្តសង្សារ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីពួនសម្ងំ ក្នុងសាយណ្ហសម័យហើយ ស្តេចចូលទៅកាន់រោងឆាន់ លុះចូលទៅដល់ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ស្រេចហើយ បានត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ នរណាហ្ន៎ ពន្យល់ភិក្ខុទាំងឡាយ ឲ្យយល់ច្បាស់ ឲ្យកាន់យកដោយល្អ ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ក្នុងរោងឆាន់ ប្រកបដោយសម្តីជារបស់អ្នកក្រុង ជាវាចាច្បាស់លាស់ ប្រាសចាកទោស អាចញុំាងអ្នកស្តាប់ឲ្យចូលចិត្តសេចក្តីជាក់លាក់បាន រាប់បញ្ចូលក្នុងវិវដ្តៈ មិនបានអាស្រ័យនូវវដ្តសង្សារ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះវិសាខបញ្ចាលីបុត្ត ដ៏មានអាយុ ពន្យល់ភិក្ខុទាំងឡាយ ឲ្យយល់ច្បាស់ ឲ្យកាន់យកដោយល្អ ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ក្នុងរោងឆាន់ ប្រកបដោយសម្តី ជារបស់អ្នកក្រុង ជាវាចាច្បាស់លាស់ ប្រាសចាកទោស អាចញុំាងអ្នកស្តាប់ ឲ្យចូលចិត្តសេចក្តីជាក់លាក់ រាប់បញ្ចូលក្នុងវិវដ្តៈ មិនបានអាស្រ័យនូវវដ្តសង្សារ ។

អថខោ ភគវា អាយស្មន្តំ វិសាខំ បញ្ចាលីបុត្តំ ឯត-
ទវោច សាធុ សាធុ វិសាខ សាធុ ខោ ត្វំ វិសាខ ភិក្ខូ
ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេ-
ជេសិ សម្បហំសេសិ បោរិយា វាចាយ វិស្សដ្ឋាយ
អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា បរិយាបន្នាយ
អនិស្សិតាយាតិ ។

នាភាសមានំ ជានន្តិ មិស្សំ ពាលេហិ បណ្ឌិតំ
ភាសមានញ្ច ជានន្តិ ទេសេន្តំ អមតំ បទំ ។
ភាសយេ ជោតយេ ធម្មំ បគ្គណ្ហេ ឥសិនំ ធជំ
សុភាសិតធជា ឥសយោ ធម្មោ ហិ ឥសិនំ ធជោតិ ។

លំដាប់នោះ ព្រះមានព្រះភាគបានត្រាស់ទៅនឹងព្រះវិសាខបញ្ចាលីបុត្ត ដ៏មានអាយុថា ម្នាលវិសាខៈ ប្រពៃណាស់ហើយ ម្នាលវិសាខៈ ប្រពៃណាស់ហើយ អ្នកពន្យល់ភិក្ខុទាំងឡាយ ឲ្យយល់ច្បាស់ ឲ្យកាន់យកដោយល្អ ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ប្រកបដោយសម្តីជារបស់អ្នកក្រុង ជាវាចាច្បាស់លាស់ ប្រាសចាកទោស អាចញ៉ាំងអ្នកស្តាប់ឲ្យចូលចិត្តសេចក្តីជាក់លាក់បាន រាប់បញ្ចូលក្នុងវិវដ្តៈ មិនបានអាស្រ័យនូវវដ្តសង្សារ ។

បណ្ឌិតដែលនៅច្រឡំដោយពួកបុគ្គលពាល កាលបើ
មិនទាន់និយាយទេ ជនទាំងឡាយ ក៏មិនស្គាល់ថា
(ជាបណ្ឌិតឡើយ) លុះតែបណ្ឌិតបាននិយាយឬសម្តែង
នូវចំណែកនៃព្រះនិព្វាន ទើបជនទាំងឡាយ ស្គាល់បាន ។
បណ្ឌិតគួរសម្តែង គួរបំភ្លឺ គួរលើកតម្កើងនូវ
ព្រះនពលោកុត្តរធម៌ ដែលជាទង់ជ័យរបស់ពួកឥសី
ពួកឥសី (គឺអរិយបុគ្គលមានព្រះពុទ្ធជាដើម) មាន
សុភាសិតជាទង់ជ័យ ព្រោះថា ព្រះនពលោកុត្តរធម៌
ជាទង់ជ័យរបស់ពួកឥសី ។

[៤០] ចត្តារោមេ ភិក្ខវេ សញ្ញាវិបល្លាសា ចិត្ត-
វិបល្លាសា ទិដ្ឋិវិបល្លាសា ។ កតមេ ចត្តារោ ។
អនិច្ចេ ភិក្ខវេ និច្ចន្តិ សញ្ញាវិបល្លាសោ ចិត្តវិបល្លាសោ
ទិដ្ឋិវិបល្លាសោ ទុក្ខេ ភិក្ខវេ សុខន្តិ សញ្ញាវិបល្លាសោ
ចិត្តវិបល្លាសោ ទិដ្ឋិវិបល្លាសោ អនត្តនិ ភិក្ខវេ អត្តាតិ
សញ្ញាវិបល្លាសោ ចិត្តវិបល្លាសោ ទិដ្ឋិវិបល្លាសោ អសុភេ
ភិក្ខវេ សុភន្តិ សញ្ញាវិបល្លាសោ ចិត្តវិបល្លាសោ ទិដ្ឋិ-
វិបល្លាសោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ សញ្ញាវិបល្លាសា
ចិត្តវិបល្លាសា ទិដ្ឋិវិបល្លាសា ។ ចត្តារោមេ ភិក្ខវេ
នសញ្ញាវិបល្លាសា នចិត្តវិបល្លាសា នទិដ្ឋិវិបល្លាសា ។
កតមេ ចត្តារោ ។ អនិច្ចេ ភិក្ខវេ អនិច្ចន្តិ ន-
សញ្ញាវិបល្លាសោ នចិត្តវិបល្លាសោ នទិដ្ឋិវិបល្លាសោ

[៥០] ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិវិបល្លាសទាំងឡាយនេះមាន ៤ យ៉ាង ។ វិបល្លាស ៤ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិវិបល្លាស ថា ទៀងក្នុងរបស់ដែលមិនទៀង ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិវិបល្លាស ថា ជាសុខក្នុងរបស់ដែលជាទុក្ខ ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិវិបល្លាស ថា ខ្លួនក្នុងរបស់ដែលមិនមែនខ្លួន ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិវិបល្លាស ថា ស្អាតក្នុងរបស់ដែលមិនស្អាត ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិវិបល្លាស មាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនវិបល្លាស ចិត្តមិនវិបល្លាស និងទិដ្ឋិមិនវិបល្លាសនេះមាន ៤ យ៉ាង ។ មិនវិបល្លាស ៤ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនវិបល្លាស ចិត្តមិនវិបល្លាស និងទិដ្ឋិមិនវិបល្លាស ថា មិនទៀងក្នុងរបស់ដែលមិនទៀង ១

១២៧



ទុក្ខេ ភិក្ខវេ ទុក្ខន្តិ នសញ្ញាវិបល្លាសោ នចិត្ត-វិបល្លាសោ នទិដ្ឋិវិបល្លាសោ អនត្តនិ ភិក្ខវេ អនត្តាតិ នសញ្ញាវិបល្លាសោ នចិត្តវិបល្លាសោ នទិដ្ឋិវិបល្លាសោ អសុភេ ភិក្ខវេ អសុភន្តិ នសញ្ញាវិបល្លាសោ នចិត្តវិបល្លាសោ នទិដ្ឋិវិបល្លាសោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ នសញ្ញាវិបល្លាសា នចិត្តវិបល្លាសា នទិដ្ឋិវិបល្លាសាតិ ។

អនិច្ចេ និច្ចសញ្ញិនោ ទុក្ខេ ច សុខសញ្ញិនោ
អនត្តនិ ច អត្តាតិ អសុភេ សុភសញ្ញិនោ
មិច្ឆាទិដ្ឋិហតា សត្តា ខិត្តចិត្តា វិសញ្ញិនោ
តេ យោគយុត្តា មារស្ស អយោគក្ខេមិនោ ជនា
សត្តា គច្ឆន្តិ សំសារំ ជាតិមរណគាមិនោ

ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនវិបល្លាស ចិត្តមិនវិបល្លាស និងទិដ្ឋិមិនវិបល្លាសថា ជាទុក្ខក្នុងរបស់ដែលជាទុក្ខ ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនវិបល្លាស ចិត្តមិនវិបល្លាស និងទិដ្ឋិមិនវិបល្លាស ថា មិនមែនខ្លួនក្នុងរបស់ដែលមិនមែនខ្លួន ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនវិបល្លាស ចិត្តមិនវិបល្លាស និងទិដ្ឋិមិនវិបល្លាស ថា មិនស្អាតក្នុងរបស់ដែលមិនស្អាត ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនវិបល្លាស ចិត្តមិនវិបល្លាស និងទិដ្ឋិមិនវិបល្លាសមាន ៤ យ៉ាងនេះឯង ។

សត្វទាំងឡាយ ដែលមិច្ឆាទិដ្ឋិបៀតបៀនហើយ ជាអ្នកមានចិត្តរវើរវាយ មានសញ្ញាទៅប្រាសហើយ រមែងមានសេចក្តីសម្គាល់ថា ទៀង ក្នុងរបស់ ដែលមិនទៀង មានសេចក្តីសម្គាល់ថា សុខ ក្នុងរបស់ដែលជាទុក្ខ មានសេចក្តីសម្គាល់ថា ខ្លួន ក្នុងរបស់ដែលមិនមែនខ្លួន មានសេចក្តីសម្គាល់ថា ល្អ ក្នុងរបស់ដែលមិនល្អ ជនទាំងនោះ ឈ្មោះថាជាអ្នកប្រកប ក្នុងយោគៈរបស់មារ មិនដល់នូវព្រះនិព្វានជាទីក្សេមចាកយោគៈបានឡើយ សត្វទាំងឡាយ តែងមានប្រក្រតីដល់នូវជាតិ និងមរណៈ រមែងទៅកាន់សង្សារវដ្ត

យទា ច ពុទ្ធា លោកស្មឹ ឧប្បជ្ជន្តិ បភង្ករា ។
តេមំ[១] ធម្មំ បកាសេន្តិ ទុក្ខូបសមគាមិនំ
តេសំ សុត្វាន សប្បញ្ញា សចិត្តំ បច្ចលត្ថុ តេ[២]
អនិច្ចំ អនិច្ចតោ ទុក្ខំ ទុក្ខមទ្ទក្ខុ ទុក្ខតោ[៣]
អនត្តនិ អនត្តាតិ អសុភំ អសុភតទ្ទសុំ
សម្មាទិដ្ឋិសមាទានា សព្វំ ទុក្ខំ ឧបច្ចគុន្តិ ។

[៤១] ចត្តារោមេ ភិក្ខវេ ចន្ទិមសុរិយានំ ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋា ចន្ទិមសុរិយា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ។ កតមេ ចត្តារោ ។ អព្ភា ភិក្ខវេ ចន្ទិមសុរិយានំ ឧបក្កិលេសា យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋា ចន្ទិមសុរិយា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ

១ ឱ. តេ ឥមំ ។ ម. ឥមំ ។ ២ ម. បច្ចលទ្ធា តេ ។ ៣ ម. អនិច្ចំ អនិច្ចតោ ទក្ខិ ទុក្ខំ ទុក្ខតោ មទ្ទក្ខិ ។

លុះព្រះពុទ្ធទាំងឡាយ ទ្រង់កើតឡើង ក្នុងលោក វេលាណា ក៏ទ្រង់ធ្វើនូវពន្លឺ ។ ព្រះពុទ្ធទាំងនោះ ទ្រង់សម្តែងនូវព្រះធម៌គឺសច្ចៈ ៤ នេះ ដែលជាធម៌ ប្រព្រឹត្តទៅកាន់ទីរំលត់ទុក្ខ ពួកសត្វដែលប្រកបដោយ ប្រាជ្ញា លុះបានស្តាប់ព្រះធម៌របស់ព្រះពុទ្ធទាំងនោះ ហើយ ក៏ត្រឡប់ផាកចិត្តរបស់ខ្លួន បានឃើញនូវ របស់ដែលមិនទៀងថា មិនទៀង ឃើញនូវរបស់ ដែលជាទុក្ខ ថាជាទុក្ខ បានឃើញថា មិនមែនខ្លួន ក្នុង របស់ដែលមិនមែនខ្លួន បានឃើញរបស់ដែលមិនល្អ ថា មិនល្អ (ជនទាំងនោះ) ជាអ្នកសមាទាននូវសម្មាទិដ្ឋិ បានរួចចាកទុក្ខទាំងពួង ។

[៩១] ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទនិងព្រះអាទិត្យសៅហ្មង ដោយឧបក្កិលេសទាំងឡាយណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេសរបស់ព្រះចន្ទ និងព្រះអាទិត្យទាំងឡាយនេះ មាន ៤ យ៉ាង ។ ឧបក្កិលេស ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទនិងព្រះ អាទិត្យសៅហ្មង ព្រោះឧបក្កិលេសណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេស របស់ព្រះចន្ទនិងព្រះអាទិត្យទាំងឡាយនោះ គឺ ពពក ១ ។

១២៩



មហិយា ភិក្ខវេ ចន្ទិមសុរិយានំ ឧបក្កិលេសា យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋា ចន្ទិមសុរិយា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ធូមរជោ ភិក្ខវេ ចន្ទិមសុរិយានំ ឧបក្កិលេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋា ចន្ទិមសុរិយា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ រាហុ ភិក្ខវេ អសុរិន្ទោ ចន្ទិមសុរិយានំ ឧបក្កិលេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋា ចន្ទិមសុរិយា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ចន្ទិមសុរិយានំ ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋា ចន្ទិមសុរិយា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ។ ឯវមេវ ខោ ភិក្ខវេ ចត្តារោ សមណព្រាហ្មណានំ ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋា ឯកេ សមណព្រាហ្មណា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ។ កតមេ ចត្តារោ ។ សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា សុរំ បិវន្តិ មេរយំ សុរាមេរយបានា អប្បដិវិរតា ។

ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទនិងព្រះអាទិត្យសៅហ្មង ព្រោះឧបក្កិលេសណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេសរបស់ព្រះចន្ទនិងព្រះអាទិត្យទាំងនោះគឺទឹកសន្សើម ១ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទនិងព្រះអាទិត្យសៅហ្មង ព្រោះឧបក្កិលេសណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេស របស់ព្រះចន្ទ និងព្រះអាទិត្យទាំងឡាយនោះ គឺផ្សែង ឬធូលី ១ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទនិងព្រះអាទិត្យសៅហ្មង ព្រោះឧបក្កិលេសណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេស របស់ព្រះចន្ទនិងព្រះអាទិត្យទាំងឡាយនោះគឺ រាហុអសុរិន្ទ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទនិងព្រះអាទិត្យសៅហ្មង ព្រោះឧបក្កិលេសទាំងឡាយណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេសរបស់ព្រះចន្ទនិងព្រះអាទិត្យទាំងឡាយមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សមណ-ព្រាហ្មណ៍ទាំងឡាយ ពួកមួយ សៅហ្មង ព្រោះឧបក្កិលេសទាំងឡាយណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេសទាំងឡាយ របស់ពួកសមណព្រាហ្មណ៍ មាន ៤ យ៉ាងនោះដែរ ។ ឧបក្កិលេស ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយ ពួកមួយផឹកនូវសុរានិងមេរ័យ មិនវៀរចាកការផឹកនូវសុរានិងមេរ័យឡើយ ។

អយំ ភិក្ខវេ បឋមោ សមណព្រាហ្មណានំ ឧបក្កិ-លេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋា ឯកេ សមណព្រាហ្មណា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ។ សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា មេថុនំ ធម្មំ បដិសេវន្តិ មេថុនស្មា ធម្មា អប្បដិវិរតា ។ អយំ ភិក្ខវេ ទុតិយោ សមណព្រាហ្មណានំ ឧបក្កិលេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋា ឯកេ សមណព្រាហ្មណា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ។ សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា ជាតរូបរជតំ សាទិយន្តិ ជាតរូប-រជតប្បដិគ្គហណា អប្បដិវិរតា ។ អយំ ភិក្ខវេ តតិយោ សមណព្រាហ្មណានំ ឧបក្កិលេសោ យេន ឧបក្កិ-លេសេន ឧបក្កិលិដ្ឋា ឯកេ សមណព្រាហ្មណា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ។ សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា មិច្ឆាជីវេន ជីវិតំ កប្បេន្តិ មិច្ឆាជីវា អប្បដិវិរតា ។ អយំ ភិក្ខវេ ចតុត្ថោ សមណព្រាហ្មណានំ ឧបក្កិលេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋា ឯកេ សមណ-ព្រាហ្មណា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ។

ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយ ពួកមួយ សៅហ្មង ព្រោះឧបក្កិលេសណា តែងមិនក្តៅ មិនភ្លឺ មិនរុងរឿង នេះជាឧបក្កិលេស របស់ពួកសមណព្រាហ្មណ៍ទី ១ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ ទាំងឡាយ ពួកមួយ សេពនូវមេថុនធម្ម មិនវៀរចាកការសេពមេថុនធម្ម ឡើយ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ ពួកមួយ សៅហ្មង ដោយឧបក្កិលេសណា តែងមិនក្តៅ មិនភ្លឺ មិនរុងរឿង នេះជា ឧបក្កិលេសរបស់សមណព្រាហ្មណ៍ទី ២ ។ ម្នាលភិក្ខុទាំងឡាយ សមណ-ព្រាហ្មណ៍ទាំងឡាយ ពួកមួយ ត្រេកអរនូវមាសនិងប្រាក់ មិនវៀរចាកការ ទទួលនូវមាសនិងប្រាក់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ ទាំងឡាយ ពួកមួយ សៅហ្មង ព្រោះឧបក្កិលេសណា តែងមិនក្តៅ មិនភ្លឺ មិនរុងរឿង នេះជាឧបក្កិលេសរបស់ពួកសមណព្រាហ្មណ៍ទី ៣ ។ ម្នាល ភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ ពួកមួយ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ មិនវៀរចាកមិច្ឆាជីវៈឡើយ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ ពួកមួយ សៅហ្មង ព្រោះឧបក្កិលេសណា តែងមិនក្តៅ មិនភ្លឺ មិនរុងរឿង នេះជាឧបក្កិលេសរបស់ពួកសមណព្រាហ្មណ៍ទី ៤ ។

១៣១



ឥមេ ខោ ភិក្ខវេ ចត្តារោ សមណព្រាហ្មណានំ ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋា ឯកេ សមណព្រាហ្មណា ន តបន្តិ ន ភាសន្តិ ន វិរោចន្តីតិ ។

រាគទោសុបដិក្កិដ្ឋា[១] ឯកេ សមណព្រាហ្មណា
អវិជ្ជានិវុតា ចោសា បិយរូចាភិនន្ទិនោ
សុរំ បិវន្តិ មេរយំ បដិសេវន្តិ មេថុនំ
រជតំ ជាតរូបញ្ច សាទិយន្តិ អវិទ្ទសូ
មិច្ឆាជីវេន ជីវន្តិ ឯកេ សមណព្រាហ្មណា
ឯតេ ឧបក្កិលេសា វុត្តា ពុទ្ធេនាទិច្ចពន្ធុនា
យេហិ ឧបក្កិលេសេហិ ឯកេ សមណព្រាហ្មណា
ន តបន្តិ ន ភាសន្តិ អសុទ្ធា សរជា មតា[២]
អន្ធការេន ឱនទ្ធា តណ្ហាទាសា សនេត្តិកា
វឌ្ឍេន្តិ កដសឹ ឃោរំ អាទិយន្តិ បុនព្ភវន្តិ ។

រោហិតស្សវគ្គោ បញ្ចមោ ។

---

១ ម. រាគមទបរិតុដ្ឋា ។ ២ ឱ. បកា ។ ម. មគា ។

ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ ពួកមួយ សៅហ្មង ព្រោះឧបក្កិ-លេសទាំងឡាយណា តែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេសរបស់ពួកសមណព្រាហ្មណ៍មាន ៤ យ៉ាងនេះឯង ។

សមណព្រាហ្មណ៍ ពួកមួយ ជាអ្នកសៅហ្មងដោយរាគៈនិងទោសៈ ត្រូវអវិជ្ជារួបរឹតហើយ មានប្រក្រតីរីករាយចំពោះរូបជាទីស្រឡាញ់ ជាជនល្ងង់ រមែងផឹកនូវសុរានិងមេរ័យ សេពនូវមេថុនធម្ម ត្រេកអរចំពោះប្រាក់និងមាស ។ សមណព្រាហ្មណ៍ ពួកមួយចិញ្ចឹមជីវិត ដោយមិច្ឆាជីវៈ សមណព្រាហ្មណ៍ ពួកមួយមិនស្អាត ប្រកបដោយធូលី រមែងមិនក្តៅ មិនភ្លឺព្រោះឧបក្កិលេសទាំងឡាយណា ឧបក្កិលេស ទាំងនុ៎ះព្រះសម្ពុទ្ធ ជាផៅពង្សនៃព្រះអាទិត្យ បានត្រាស់ទុកហើយ ពួកសត្វត្រូវសេចក្តីងងឹតគ្របសង្កត់ហើយ ជាខ្ញុំនៃតណ្ហាប្រព្រឹត្តទៅតាមខ្សែនៃតណ្ហា ញុំាងអត្តភាពដ៏គៀវក្លា ឲ្យចម្រើនឡើង តែងកាន់យកនូវភពថ្មី ។

ចប់ រោហិតស្សវគ្គ ទី ៥ ។

# តស្សុទ្ទានំ

សមាធិប្បញ្ហា ទ្វេ កោធា[១]
រោហិតស្សា បរេ ទុវេ
សុវិទូរវិសាខា វិបល្លាសោ[២]
ឧបក្កិលេសេន តេ ទសាតិ

បឋមោ បណ្ណាសកោ និដ្ឋិតោ ។

---

១ ម. ទ្វេ កោធគរុ ។ ២ ឱ. សុទូរវិសាខោ វិបល្លាសោ ។ ម. សុវិទូរវិសាខវិបល្លាសា ។

សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត

# ឧទ្ទាននៃរោហិតស្សវគ្គនោះគឺ

និយាយអំពីសមាធិភាវនា ១ អំពីបញ្ហាព្យាករណ៍ ១ អំពីបុគ្គលធ្ងន់ ក្នុងសេចក្តីក្រោធមាន ២ លើក អំពីរោហិតស្សទេវបុត្តដទៃ ២ លើកទៀត អំពីរបស់ដែលឆ្ងាយក្រៃលែងឆ្ងាយ ១ អំពីបញ្ហាលីបុត្តឈ្មោះវិសាខៈ ១ អំពីវិបល្លាស ១ អំពីឧបក្កិលេស ១ រួមត្រូវជា ១០ ។

ចប់ បណ្ណាសក ទី ១ ។

# ទុតិយបណ្ណាសកោ

## បុញ្ញាភិសន្ទវគ្គោ

[៥២] ចត្តារោមេ ភិក្ខវេ បុញ្ញាភិសន្ទា កុសលាភិសន្ទា សុខស្សាហារា សោវគ្គិកា សុខវិបាកា សគ្គសំវត្តនិកា ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ យស្ស ភិក្ខវេ ភិក្ខុ ចីវរំ បរិភុញ្ជមានោ អប្បមាណំ ចេតោសមាធឹ ឧបសម្បជ្ជ វិហរតិ អប្បមាណោ តស្ស បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ យស្ស ភិក្ខវេ ភិក្ខុ បិណ្ឌបាតំ បរិភុញ្ជមានោ... យស្ស ភិក្ខវេ ភិក្ខុ សេនាសនំ បរិភុញ្ជមានោ... យស្ស ភិក្ខវេ ភិក្ខុ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បរិភុញ្ជមានោ អប្បមាណំ ចេតោសមាធឹ ឧបសម្បជ្ជ វិហរតិ

# ទុតិយបណ្ណាសក

## បុញ្ញាភិសន្ទវគ្គ

[៥២] ម្នាលភិក្ខុទាំងឡាយ អានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល ជាទីនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើត ក្នុងស្ថានសួគ៌នេះ មាន ៤ យ៉ាង រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ អានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល មាន ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលប្រើប្រាស់ចីវររបស់ទាយកណា ចូលកាន់ចេតោសមាធិ ជាធម៌ប្រមាណមិនបាន អានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល របស់ទាយកនោះ ក៏រមែងប្រមាណមិនបាន ជាទីនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើត ក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបរិភោគបិណ្ឌបាត របស់ទាយកណា... ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលប្រើប្រាស់សេនាសនៈ របស់ទាយកណា... ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបរិភោគភេសជ្ជបរិក្ខារ ជាបច្ច័យដល់អ្នកជំងឺរបស់ទាយកណា ចូលកាន់ចេតោសមាធិ ជាធម៌ប្រមាណមិនបាន

អប្បមាណោ តស្ស បុញ្ញាភិសន្ទោ កុសលា-
ភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ
សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ
ហិតាយ សុខាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ
ចត្តារោ បុញ្ញាភិសន្ទា កុសលាភិសន្ទា សុខស្សាហារា
សោវគ្គិកា សុខវិបាកា សគ្គសំវត្តនិកា ឥដ្ឋាយ
កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តន្តិ ។
ឥមេហិ ច បន ភិក្ខវេ ចតូហិ បុញ្ញាភិសន្ទេហិ
កុសលាភិសន្ទេហិ សមន្នាគតស្ស អរិយសាវកស្ស
ន សុករំ បុញ្ញស្ស បមាណំ គហេតុំ[១] ឯត្តកោ
បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវ-
គ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ
មនាបាយ ហិតាយ សុខាយ សំវត្តតីតិ អថខោ អស-
ង្ខេយ្យោ អប្បមេយ្យោ មហាបុញ្ញក្ខន្ធោត្វេវ សង្ខំ គច្ឆតិ ។

១ ម. គណេតុំ ។

អានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលរបស់ទាយកនោះ ក៏រមែងប្រមាណមិនបាន ជាទីនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើត ក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល ជាទីនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅ ដើម្បីកើត ក្នុងស្ថានសួគ៌ ៤ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត កាលបើអរិយសាវ័ក ដែលប្រកបដោយអានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលទាំង ៤ នេះហើយ បុគ្គលមិនងាយនឹងរាប់នូវប្រមាណនៃបុណ្យថា អានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល ជាទីនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើត ក្នុងស្ថានសួគ៌ មានប្រមាណប៉ុណ្ណោះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្តបានឡើយ តាមពិតនោះ គឺដល់នូវការរាប់ថាជាគំនរបុណ្យយ៉ាងធំ ដែលបុគ្គលរាប់មិនបាន ប្រមាណមិនអស់ ។

សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទេ ន សុករំ ឧទកស្ស បមាណំ គហេតុំ ឯត្តកានិ ឧទកាឡ្ហកានីតិ វា ឯត្តកានិ ឧទកាឡ្ហកសតានីតិ វា ឯត្តកានិ ឧទកាឡ្ហកសហស្សានីតិ វា ឯត្តកានិ ឧទកាឡ្ហកសតសហស្សានីតិ វា អថខោ អសង្ខេយ្យោ អប្បមេយ្យោ មហាឧទកក្ខន្ធោត្វេវ សង្ខំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ ឥមេហិ ចតូហិ បុញ្ញាភិសន្ទេហិ កុសលាភិសន្ទេហិ សមន្នាគតស្ស អរិយសាវកស្ស ន សុករំ បុញ្ញស្ស បមាណំ គហេតុំ ឯត្តកោ បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតីតិ អថខោ អសង្ខេយ្យោ អប្បមេយ្យោ មហាបុញ្ញក្ខន្ធោត្វេវ សង្ខំ គច្ឆតីតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយរាប់នូវប្រមាណនៃទឹក ក្នុងមហាសមុទ្រថា ទឹកមានប៉ុណ្ណោះអាឡ្ហក ទឹកមានប៉ុណ្ណោះរយអាឡ្ហក ទឹកមានប៉ុណ្ណោះពាន់អាឡ្ហក ទឹកមានប៉ុណ្ណោះសែនអាឡ្ហកបានឡើយ តាមពិតនោះ គឺដល់នូវការរាប់ថា គំនរទឹកធំ ដែលបុគ្គលរាប់មិនបានប្រមាណមិនអស់ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័ក ដែលប្រកបដោយអានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល ទាំង ៤ យ៉ាងនេះឯងហើយ បុគ្គលមិនងាយនឹងរាប់នូវប្រមាណនៃបុណ្យថា អានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល ជាទីនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខប្រព្រឹត្តទៅដើម្បីកើត ក្នុងស្ថានសួគ៌ មានប្រមាណប៉ុណ្ណោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្តបានឡើយ តាមពិតនោះគឺដល់នូវការរាប់ថា ជា គំនរបុណ្យយ៉ាងធំ ដែលបុគ្គលរាប់មិនបាន ប្រមាណមិនអស់ ក៏យ៉ាងនោះដែរ ។

មហោទធឹ អបរិមិតំ មហាសរំ
ពហុភេរវំ រតនគណានមាលយំ[១]
នជ្ជោ យថា មច្ឆគណសង្ឃសេវិតា[២]
បុថូ សវន្តី ឧបយន្តិ សាគរំ ។
ឯវំ នរំ អន្នទបានវត្ថទំ
សេយ្យានិសជ្ជត្ថរណស្ស ទាយកំ
បុញ្ញស្ស ធារា ឧបយន្តិ បណ្ឌិតំ
នជ្ជោ យថា វារិវហាវ សាគរន្តិ ។

[៤៣] ចត្តារោមេ ភិក្ខវេ បុញ្ញាភិសន្ទា កុសលាភិសន្ទា សុខស្សាហារា សោវគ្គិកា សុខវិបាកា សគ្គសំវត្តនិកា ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ

១ ម. រតនវរានមាលយំ ។ ២ ឱ. ម. នរគណសង្ឃសេវិតា ។

ទន្លេទាំងឡាយ ដែលមានពួកត្រីនៅអាស្រ័យ ច្រើន តែហូរចុះទៅកាន់សាគរ មានអន្លង់ទឹកធំដែលបុគ្គលរាប់មិនបាន ជាស្រះធំ ប្រកបដោយអារម្មណ៍គួរស្ញប់-ស្ញែងដ៏ច្រើន ជាទីកើតនៃរតនវត្ថុទាំងឡាយ យ៉ាងណាមិញ ។ ធារនៃបុណ្យ រមែងប្រព្រឹត្តហូរទៅកាន់នរជនដែលជាបណ្ឌិតអ្នកឲ្យនូវបាយទឹកនិងសំពត់ អ្នកឲ្យនូវទីដេក ទីអង្គុយនិងគ្រឿងកម្រាល ដូចជាទន្លេស្ទឹង ដែលហូរទៅកាន់សាគរយ៉ាងនោះដែរ ។

[៥៣] ម្នាលភិក្ខុទាំងឡាយ អានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល នាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើត ក្នុងស្ថានសួគ៌ នេះមាន ៤ យ៉ាង រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ អានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសល ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើក ក្នុងព្រះពុទ្ធដូច្នេះថា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ

វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ អយំ ភិក្ខវេ បឋមោ បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ អរិយសាវកោ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ អយំ ភិក្ខវេ ទុតិយោ បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ

ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ទ្រង់ជាសារថីទូន្មាននូវបុរសដែលគួរទូន្មានបាន ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលទី ១ ដែលនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះធម៌ថា ព្រះបរិយត្តិធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ ព្រះនពលោកុត្តរធម៌ ជាធម៌ដែលព្រះអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិត ដោយបច្ចវេក្ខណ-ញ្ញាណ ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌ដែលព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលទី ២ ដែលនាំមកនូវសេចក្តីសុខ

សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ អរិយស្សាវកោ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវក-សង្ឃោ សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញ-ក្ខេត្តំ លោកស្សាតិ អយំ ភិក្ខវេ តតិយោ បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សា-ហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ

ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅ ដើម្បីកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះសង្ឃថា ព្រះសង្ឃ ជាសាវ័កនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃ ព្រះសង្ឃ ជាសាវ័កនៃព្រះដ៏មានព្រះភាគ ប្រតិ-បត្តិដោយត្រង់ ព្រះសង្ឃ ជាសាវ័កនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ព្រះសង្ឃ ជាសាវ័កនៃព្រះដ៏មានព្រះភាគប្រតិបត្តិសមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា ព្រះសង្ឃអង្គណា បើរាប់ជាគូនៃបុរសមាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ គួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលនាំមកបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលទី ៣ ដែលនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើត ក្នុងស្ថានសួគ៌

១៣៩



ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ ។

បុន ចបរំ ភិក្ខវេ អរិយសាវកោ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ ភុជិស្សេហិ វិញ្ញុបសត្ថេហិ អបរាមដ្ឋេហិ សមាធិសំវត្តនិកេហិ អយំ ភិក្ខវេ ចតុត្ថោ បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុញ្ញាភិសន្ទា កុសលាភិសន្ទា សុខស្សាហារា សោវគ្គិកា សុខវិបាកា សគ្គសំវត្តនិកា ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តន្តីតិ ។

ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក ជាអ្នកប្រកបដោយសីលទាំងឡាយ ជាទីត្រេកអរនៃព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះធ្លាយ មិនពពាល មិនពព្រុស ជាសីលរបស់អ្នកជា ជាសីលដែលវិញ្ញូជនតែងសរសើរ ជាសីលមិនប៉ះពាល់ដោយតណ្ហាទិដ្ឋិ ប្រព្រឹត្តទៅដើម្បីបាននូវសមាធិ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលទី ៤ ដែលនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ជាទីហូរមកនៃបុណ្យ ជាទីហូរមកនៃកុសលមាន ៤ យ៉ាងនេះឯង ជាទីនាំមកនូវសេចក្តីសុខ ឲ្យនូវផលដ៏ល្អវិសេស មានផលជាសុខ ប្រព្រឹត្តទៅ ដើម្បីកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។

យស្ស សទ្ធា តថាគតេ អចលា សុប្បតិដ្ឋិតា
សីលញ្ច យស្ស កល្យាណំ អរិយកន្តំ បសំសិតំ ។
សង្ឃេ បសាទោ យស្សត្ថិ ឧជុភូតញ្ច ទស្សនំ
អទលិទ្ទោតិ តំ អាហុ អមោឃំ តស្ស ជីវិតំ ។
តស្មា សទ្ធញ្ច សីលញ្ច បសាទំ ធម្មទស្សនំ
អនុយុញ្ជេថ មេធាវី សរំ ពុទ្ធានសាសនន្តិ ។

[៤៨] ឯកំ សមយំ ភគវា អន្តរា ច មធុរំ អន្តរា ច វេរញ្ជំ អទ្ធានមគ្គប្បដិបន្នោ ហោតិ ។ សម្ពហុលាបិ គហបតី ច គហបតានិយោ ច អន្តរា ច មធុរំ អន្តរា ច វេរញ្ជំ(១) អទ្ធានមគ្គប្បដិបន្នា ហោន្តិ ។ អថខោ ភគវា មគ្គា ឱក្កម្ម អញ្ញតរស្មឹ រុក្ខមូលេ(២) និសីទិ ។ អទ្ទសំសុ ខោ តេ គហបតី ច គហបតានិយោ ច ភគវន្តំ អញ្ញតរស្មឹ រុក្ខមូលេ និសិន្នំ

១ ឱ. វេរញ្ជឹ ។ ២ ឱ. ម. ឯត្ថន្តរេ បញ្ញត្តេ អាសនេតិ បាឋោ អត្ថិ ។

សេចក្តីជឿ ក្នុងព្រះតថាគតរបស់បុគ្គលណា មិនបាន ញាប់ញ័រ បានតម្កល់ហើយដោយប្រពៃ សីលរបស់ បុគ្គលណា ជាសីលល្អ ជាទីត្រេកអរនៃព្រះអរិយៈដែល ព្រះអរិយៈសរសើរហើយ ។ សេចក្តីជ្រះថ្លាក្នុងព្រះសង្ឃ និងការឃើញដោយត្រង់ពិត របស់បុគ្គលណា អ្នក ប្រាជ្ញទាំងឡាយ ពោលនូវបុគ្គលនោះថា ជាអ្នកមិន ទ័លក្រ ទាំងជីវិត របស់បុគ្គលនោះ មិនបានសូន្យ ឡើយ ។ ព្រោះហេតុនោះ អ្នកប្រាជ្ញ កាលរលឹកឃើញ ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គួរប្រកបទុក នូវសេចក្តីជឿផង នូវសីលផង នូវសេចក្តីជ្រះថ្លាផង នូវការឃើញធម៌ផង ។

[៥២] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះស្រុកមធុរានិងចន្លោះស្រុកវេរញ្ជា ។ មានពួក[១] គហបតី និងពួកគហបតានីជាច្រើននាក់ ដើរទៅកាន់ផ្លូវឆ្ងាយក្នុងចន្លោះស្រុកមធុរា និងចន្លោះស្រុកវេរញ្ជាដែរ ។ គ្រានោះព្រះដ៏មានព្រះភាគ ទ្រង់គេចចេញ ចាកផ្លូវហើយ ទ្រង់គង់ក្រោមម្លប់ឈើមួយ ។ ពួកគហបតីនិងគហបតានី ទាំងនោះ បានឃើញព្រះដ៏មានព្រះភាគ ស្តេចគង់ក្រោមម្លប់ឈើមួយ

១ ជនទាំងនោះ មានដំណើរទៅរៀបចំអាវាហវិវាហមង្គលឲ្យកូនចៅក្នុងស្រុកនោះ ព្រោះហេតុនោះបានជានាំគ្នាដើរ ទៅតាមផ្លូវនោះដែរ ។ អដ្ឋកថា ។

១៤១

ទុតិយបណ្ណាសកេ   បុញ្ញាភិសន្ទវគ្គោ

ទិស្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ តេ គហបតី ច គហបតានិយោ ច ភគវា ឯតទវោច ចត្តារោមេ គហបតយោ សំវាសា ។ កតមេ ចត្តារោ ។ ឆវោ ឆវាយ សទ្ធឹ សំវសតិ ឆវោ ទេវិយា សទ្ធឹ សំវសតិ ទេវោ ឆវាយ សទ្ធឹ សំវសតិ ទេវោ ទេវិយា សទ្ធឹ សំវសតិ ។ កថញ្ច គហបតយោ ឆវោ ឆវាយ សទ្ធឹ សំវសតិ ។ ឥធ គហបតយោ សាមិកោ ហោតិ បាណាតិបាតី អទិន្នាទាយី កាមេសុ មិច្ឆាចារី មុសាវាទី សុរាមេរយមជ្ជប្បមាទដ្ឋាយី ទុស្សីលោ បាបធម្មោ មច្ឆេរមលបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសតិ អក្កោសកបរិភាសកោ សមណព្រាហ្មណានំ ភរិយាបិស្ស ហោតិ បាណាតិបាតិនី អទិន្នាទាយិនី កាមេសុ មិច្ឆាចារិនី មុសាវាទិនី សុរាមេរយមជ្ជប្បមាទដ្ឋាយិនី

លុះឃើញហើយ ក៏នាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះពួកគហបតីនឹងគហបតានីទាំងនោះ អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលគហបតីនិងគហបតានីទាំងឡាយ សង្វាស (ការនៅរួមគ្នាជាមួយនឹងស្វាមីភរិយា) នេះមាន ៤ យ៉ាង ។ សង្វាស ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺខ្មោចប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ១ ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ១ ទេវតាប្រុសនៅរួមគ្នា ជាមួយនឹងខ្មោចស្រី ១ ទេវតាប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ១ ។ ម្នាលគហបតីទាំងឡាយ ចុះខ្មោចប្រុស នៅរួមគ្នាជាមួយនឹងខ្មោចស្រី តើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកធ្វើនូវបាណាតិបាត ធ្វើនូវអទិន្នាទាន ប្រព្រឹត្តនូវកាមេសុមិច្ឆាចារ ពោលពាក្យមុសា ក្រេបផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មានចិត្តត្រូវមន្ទិលគឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជាអ្នកជេរប្រទេចពួកសមណព្រាហ្មណ៍ ទាំងភរិយារបស់ស្វាមីនោះ ក៏ជាអ្នកប្រព្រឹត្តធ្វើនូវបាណាតិបាត ប្រព្រឹត្តធ្វើនូវអទិន្នាទាន ប្រព្រឹត្តធ្វើនូវកាមេសុមិច្ឆាចារ ពោលនូវពាក្យមុសា ក្រេបផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ

ទុស្សីលា បាបធម្មា មច្ឆេរមលបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសន្តិ អក្កោសិកបរិភាសិកា សមណព្រាហ្ម-ណានំ ។ ឯវំ ខោ គហបតយោ ឆវោ ឆវាយ សទ្ធឹ សំវសតិ ។ កថញ្ច គហបតយោ ឆវោ ទេវិយា សទ្ធឹ សំវសតិ ។ ឥធ គហបតយោ សាមិកោ ហោតិ បាណាតិបាតី ។ បេ ។ សុរាមេ-រយមជ្ជប្បមាទដ្ឋាយី ទុស្សីលោ បាបធម្មោ មច្ឆេរ-មលបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសតិ អក្កោសកបរិភាសកោ សមណព្រាហ្មណានំ ភរិយា ច ខ្វស្ស ហោតិ បាណាតិបាតា បដិវិរតា អទិន្នា-ទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតា សីលវតី កល្យាណធម្មា វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ អនក្កោសិកបរិភាសិកា សមណព្រាហ្មណានំ ។ ឯវំ ខោ គហបតយោ ឆវោ ទេវិយា សទ្ធឹ សំវសតិ ។ កថញ្ច គហប-តយោ ទេវោ ឆវាយ សទ្ធឹ សំវសតិ ។

ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មានចិត្តត្រូវមន្ទិលគឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជាអ្នកជេរប្រទេចពួកសមណព្រាហ្មណ៍ដែរ ។ ម្នាលគហបតីទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ។ ម្នាលគហបតីទាំងឡាយ ចុះខ្មោចប្រុស នៅរួមជាមួយនឹងទេវតាស្រី តើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកធ្វើនូវបាណាតិបាត ។ បេ ។ ក្រេបផឹកនូវសុរានិងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មានចិត្តត្រូវមន្ទិលគឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជាអ្នកជេរប្រទេចពួកសមណព្រាហ្មណ៍ ប៉ុន្តែភរិយារបស់ស្វាមីនោះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ ជាអ្នកវៀរចាកការក្រេបផឹកទឹកស្រវឹងគឺសុរានិងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកមានសីល មានធម៌ល្អ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ ជាអ្នកមិនជេរប្រទេចពួកសមណព្រាហ្មណ៍ ។ ម្នាលគហបតីទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ។ ម្នាលគហបតីទាំងឡាយ ចុះទេវតាប្រុស នៅរួមជាមួយគ្នានឹងខ្មោចស្រី តើដូចម្តេច ។

១៤៣



ឥធ គហបតយោ សាមិកោ ហោតិ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ កាមេសុ មិច្ឆាចារា បដិវិរតោ មុសាវាទា បដិវិរតោ សុរាមេរយ-មជ្ជប្បមាទដ្ឋានា បដិវិរតោ សីលវា កល្យាណធម្មោ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ អនក្កោសកបរិភាសកោ សមណព្រាហ្មណានំ ភរិយា ច ខ្វស្ស ហោតិ បាណាតិបាតិនី ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋាយិនី ទុស្សីលា បាបធម្មា មច្ឆេរមលបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសតិ អក្កោសិកបរិភាសិកា សមណព្រាហ្មណានំ ។ ឯវំ ខោ គហបតយោ ទេវោ ឆវាយ សទ្ធឹ សំវសតិ ។ កថញ្ច គហបតយោ ទេវោ ទេវិយា សទ្ធឹ សំវសតិ ។ ឥធ គហបតយោ សាមិកោ ហោតិ បាណាតិបាតា បដិវិរតោ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ សីលវា

ម្នាលគហបតីទាំងឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកការក្រេបផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ មានសីល មានធម៌ល្អ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ ជាអ្នកមិនជេរប្រទេចពួកសមណព្រាហ្មណ៍ ទើបឯភរិយារបស់ស្វាមីនោះ ជាអ្នកប្រព្រឹត្តធ្វើនូវបាណាតិបាត ។ បេ ។ ក្រេបផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មានចិត្តត្រូវមន្ទិលគឺសេចក្តីកំណាញ់របរឹត នៅគ្រប់គ្រងផ្ទះ ជាអ្នកជេរប្រទេច ពួកសមណព្រាហ្មណ៍ ។ ម្នាលគហបតីទាំង-ឡាយ យ៉ាងនេះឯងឈ្មោះថា ទេវតាប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ។ ម្នាលគហបតីទាំងឡាយ ចុះទេវតាប្រុស នៅរួមជាមួយគ្នានឹងទេវតាស្រី តើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត ។ បេ ។ វៀរចាកការក្រេបផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកមានសីល

កល្យាណធម្មោ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ អនក្កោសកបរិភាសកោ សមណ-ព្រាហ្មណានំ ភរិយាបិស្ស ហោតិ បាណាតិបាតា បដិវិរតា ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតា សីលវតី កល្យាណធម្មា វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ អនក្កោសិកបរិភាសិកា សមណព្រាហ្មណានំ ។ ឯវំ ខោ គហបតយោ ទេវោ ទេវិយា សទ្ធឹ សំវសតិ ។ ឥមេ ខោ គហបតយោ ចត្តារោ សំវាសាតិ ។

ឧភោ ច ហោន្តិ ទុស្សីលា កទរិយា បរិភាសកា
តេ ហោន្តិ ជានិបតយោ ឆវា សំវាសមាគតា ។
សាមិកោ ហោតិ ទុស្សីលោ កទរិយោ បរិភាសកោ
ភរិយា សីលវតី ហោតិ វទញ្ញូ វីតមច្ឆរា ។

មានធម៌ដ៏ល្អ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ ជាអ្នកមិនជេរប្រទេច ពួកសមណព្រាហ្មណ៍ ទាំងភរិយារបស់ស្វាមីនោះ ក៏ជាអ្នកវៀរចាកបាណាតិបាត ។ បេ ។ វៀរចាកការក្រេបផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកមានសីល មានធម៌ដ៏ល្អ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ ជាអ្នកមិនជេរប្រទេចពួកសមណព្រាហ្មណ៍ដែរ ។ ម្នាលគហបតីទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ទេវតាប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ។ ម្នាលគហបតីទាំងឡាយ សំវាស (ការនៅរួមគ្នា) មាន ៤ យ៉ាងនេះឯង ។

ជនទាំងពីរនាក់ ជាអ្នកទ្រុស្តសីល ជាអ្នកកំណាញ់
ស្អិតស្អាញ ជេរប្រទេច (នូវសមណព្រាហ្មណ៍)
ប្រពន្ធនិងប្តីទាំងពីរនាក់នោះ ឈ្មោះថា ខ្មោចមកនៅរួម
គ្នា ។ ស្វាមីជាអ្នកទ្រុស្តសីល មានសេចក្តីកំណាញ់
ស្អិតស្អាញ ជេរប្រទេច (នូវសមណព្រាហ្មណ៍)
ភរិយា ជាអ្នកមានសីល ដឹងនូវពាក្យពេចន៍នៃពួក
ស្មូម មានសេចក្តីកំណាញ់ ប្រាសចេញហើយ

## ទុតិយបណ្ណាសកេ បុញ្ញាភិសន្ទវគ្គោ

សាបិ ទេវី សំវសតិ ឆវេន បតិនា សហ ។
សាមិកោ សីលវា ហោតិ វទញ្ញូ វីតមច្ឆរោ
ភរិយា ហោតិ ទុស្សីលា កទរិយា បរិភាសិកា
សាបិ ឆវា សំវសតិ ទេវេន បតិនា សហ ។
ឧភោ សទ្ធា វទញ្ញូ ច សញ្ញតា ធម្មជីវិនោ
តេ ហោន្តិ ជានិបតយោ អញ្ញមញ្ញំ បិយំវទា
អត្ថា សម្បចុរា ហោន្តិ ផាសុកំ[១] ឧបជាយតិ
អមិត្តា ទុម្មនា ហោន្តិ ឧភិន្នំ សមសីលិនំ
ឥធ ធម្មំ ចរិត្វាន សមសីលព្វតា ឧភោ
នន្ទិនោ ទេវលោកស្មឹ មោទន្តិ កាមកាមិនោ ។

---

១ ឱ. វាសត្ថំ ។

ភរិយានោះឯងឈ្មោះថា ទេវតាស្រី នៅរួមគ្នាជាមួយនឹងប្ដីខ្មោច ។ ស្វាមី ជាអ្នកមានសីល ដឹងនូវពាក្យពេចន៍នៃពួកស្មូម ជាអ្នកមានសេចក្ដីកំណាញ់ប្រាសចេញហើយ ភរិយាជាអ្នកទ្រុស្ដសីល មានសេចក្ដីកំណាញ់ស្អិតស្អាញ ជេរប្រទេច (នូវសមណព្រាហ្មណ៍) ភរិយានោះឯង ឈ្មោះថា ស្រីខ្មោចនៅរួមគ្នាជាមួយនឹងប្ដីទេវតា ។ ជនទាំងពីរនាក់ ជាអ្នកមានសទ្ធា ដឹងនូវពាក្យពេចន៍នៃពួកស្មូម ជាអ្នកសង្រួម (ក្នុងសីល) ជាអ្នកចិញ្ចឹមជីវិតតាមគន្លងធម៌ ប្រពន្ធនិងប្ដីទាំងពីរនាក់នោះ ពោលពាក្យផ្អែមល្ហែមទៅរកគ្នានឹងគ្នា រមែងមានសេចក្ដីចម្រើនដ៏ច្រើន ទាំងមានការនៅជាសុខកើតឡើងដល់គ្នានឹងគ្នា ពួកសត្រូវ រមែងអាក់អន់ចិត្តចំពោះជនទាំងពីរនាក់ ដែលមានសីលស្មើគ្នា ជនទាំងពីរនាក់ មានសីលនិងវត្តស្មើគ្នា លុះប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ បើនៅមានចំណង់ក្នុងកាម ក៏រមែងជាអ្នកត្រេកអរ រីករាយ ក្នុងទេវលោកបាន ។

[៤៤] ចត្តារោមេ ភិក្ខវេ សំវាសា ។ កតមេ ចត្តារោ ។ ឆវោ ឆវាយ សទ្ធឹ សំវសតិ ឆវោ ទេវិយា សទ្ធឹ សំវសតិ ទេវោ ឆវាយ សទ្ធឹ សំវសតិ ទេវោ ទេវិយា សទ្ធឹ សំវសតិ ។ កថញ្ច ភិក្ខវេ ឆវោ ឆវាយ សទ្ធឹ សំវសតិ ។ ឥធ ភិក្ខវេ សាមិកោ ហោតិ បាណាតិបាតី អទិន្នាទាយី កាមេសុ មិច្ឆាចារី មុសាវាទី បិសុណាវាចោ ផរុសាវាចោ សម្ផប្បលាបី អភិជ្ឈាលុ ព្យាបន្នចិត្តោ មិច្ឆាទិដ្ឋិកោ ទុស្សីលោ បាបធម្មោ មច្ឆេរមលបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសតិ អក្កោសកបរិភាសកោ សមណ-ព្រាហ្មណានំ ភរិយាបិស្ស ហោតិ បាណាតិបាតិនី អទិន្នាទាយិនី កាមេសុ មិច្ឆាចារិនី មុសាវាទិនី បិសុណាវាចា ផរុសាវាចា សម្ផប្បលាបិនី អភិជ្ឈាលុនី ព្យាបន្នចិត្តា មិច្ឆាទិដ្ឋិកា ទុស្សីលា បាបធម្មា មច្ឆេរមលបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសតិ អក្កោសិកបរិភាសិកា សមណព្រាហ្មណានំ ។

[៥៥] ម្នាលភិក្ខុទាំងឡាយ សំវាស (ការនៅរួមគ្នាជាមួយនឹងស្វាមីភរិយា) នេះមាន ៤ យ៉ាង ។ សំវាស ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺខ្មោចប្រុស នៅរួមគ្នាជាមួយនឹងខ្មោចស្រី ១ ខ្មោចប្រុស នៅរួមគ្នាជាមួយនឹងទេវតាស្រី ១ ទេវតាប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ១ ទេវតាប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះខ្មោចប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកប្រព្រឹត្តធ្វើនូវបាណាតិបាត ធ្វើនូវអទិន្នាទាន ធ្វើនូវកាមេសុមិច្ឆាចារ ពោលពាក្យមុសា ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យរោយរាយ មានអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្តីឃើញខុស ទ្រុស្តសីលមានធម៌លាមកមានចិត្តត្រូវមន្ទិលគឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជេរប្រទេចពួកសមណព្រាហ្មណ៍ ទាំងភរិយារបស់បុរសនោះ ក៏ជាអ្នកប្រព្រឹត្តធ្វើនូវបាណាតិបាត ធ្វើនូវអទិន្នាទាន ធ្វើនូវកាមេសុមិច្ឆាចារ ពោលពាក្យមុសា ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យរោយរាយ មានអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្តីឃើញខុស ទ្រុស្តសីល មានធម៌លាមក មានចិត្តត្រូវមន្ទិលគឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជេរប្រទេចពួកសមណព្រាហ្មណ៍ដែរ ។

## ១៤៧



ឯវំ ខោ ភិក្ខវេ ឆវោ ឆវាយ សទ្ធឹ សំវសតិ ។ កថញ្ច ភិក្ខវេ ឆវោ ទេវិយា សទ្ធឹ សំវសតិ ។ ឥធ ភិក្ខវេ សាមិកោ ហោតិ បាណាតិបាតី អទិន្នាទាយី ។ បេ ។ មច្ឆេរមលបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសតិ អក្កោសកបរិភាសកោ សមណព្រាហ្មណានំ ភរិយា ច ខ្វស្ស ហោតិ បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា បិសុណាយ វាចាយ បដិវិរតា ផរុសាយ វាចាយ បដិវិរតា សម្ផប្បលាបា បដិវិរតា អនភិជ្ឈាលុនី អព្យាបន្នចិត្តា សម្មាទិដ្ឋិកា សីលវតី កល្យាណធម្មា វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ អនក្កោសិកបរិភាសិកា សមណព្រាហ្មណានំ ។ ឯវំ ខោ ភិក្ខវេ ឆវោ ទេវិយា សទ្ធឹ សំវសតិ ។ កថញ្ច ភិក្ខវេ ទេវោ ឆវាយ សទ្ធឹ សំវសតិ ។ ឥធ ភិក្ខវេ សាមិកោ ហោតិ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ កាមេសុ មិច្ឆាចារា បដិវិរតោ មុសាវាទា បដិវិរតោ

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា ខ្មោចប្រុស នៅរួមគ្នាជាមួយនឹងខ្មោចស្រី ។ ម្នាលភិក្ខុទាំងឡាយ ចុះខ្មោចប្រុស នៅរួមគ្នាជាមួយនឹងទេវតាស្រី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកប្រព្រឹត្ត ធ្វើនូវបាណាតិបាត ធ្វើនូវអទិន្នាទាន ។ បេ ។ មានចិត្តត្រូវមន្ទិលគឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជេរប្រទេចពួកសមណព្រាហ្មណ៍ ប៉ុន្តែភរិយារបស់បុរសនោះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្ប-លាបៈ មិនមានអភិជ្ឈា មានចិត្តមិនព្យាបាទ ឃើញត្រូវ មានសីលមានធម៌ល្អ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មិនជេរប្រទេចពួកសមណព្រាហ្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ។ ម្នាលភិក្ខុទាំងឡាយ ចុះទេវតាប្រុស នៅរួមគ្នាជាមួយនឹងខ្មោចស្រី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ

បិសុណាយ វាចាយ បដិវិរតោ ផរុសាយ វាចាយ បដិវិរតោ សម្ផប្បលាបា បដិវិរតោ អនភិជ្ឈាលុ អព្យាបន្នចិត្តោ សម្មាទិដ្ឋិកោ សីលវា កល្យាណធម្មោ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ អនក្កោសកបរិភាសកោ សមណព្រាហ្មណានំ ភរិយា ច ខ្វស្ស ហោតិ បាណាតិបាតិនី ។ បេ ។ មច្ឆេរមលបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសតិ អក្កោសិកបរិភាសិកា សមណព្រាហ្មណានំ ។ ឯវំ ខោ ភិក្ខវេ ទេវោ ឆវាយ សទ្ធឹ សំវសតិ ។ កថញ្ច ភិក្ខវេ ទេវោ ទេវិយា សទ្ធឹ សំវសតិ ។ ឥធ ភិក្ខវេ សាមិកោ ហោតិ បាណាតិបាតា បដិវិរតោ ។ បេ ។ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ អនក្កោសកបរិភាសកោ សមណព្រាហ្មណានំ ភរិយាបិស្ស ហោតិ បាណាតិបាតា បដិវិរតា ។ បេ ។ អនក្កោសិកបរិភាសិកា សមណព្រាហ្មណានំ ។ ឯវំ ខោ ភិក្ខវេ ទេវោ ទេវិយា សទ្ធឹ សំវសតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ សំវាសាតិ ។

វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មានចិត្តមិនព្យាបាទ មានសេចក្តីឃើញត្រូវ មានសីល មានធម៌ល្អ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មិនជេរប្រទេចពួកសមណព្រាហ្មណ៍ ទើបឯភរិយារបស់បុរសនោះ ជាអ្នកប្រព្រឹត្តធ្វើនូវបាណាតិបាត ។ បេ ។ មានចិត្តត្រូវមន្ទិលគឺសេចក្តីកំណាញ់រួបរឹតនៅគ្រប់គ្រងផ្ទះ ជេរប្រទេចពួកសមណព្រាហ្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា ទេវតាប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ។ ម្នាលភិក្ខុទាំងឡាយ ចុះទេវតាប្រុស នៅរួមគ្នាជាមួយនឹងទេវតាស្រី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត ។ បេ ។ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មិនជេរប្រទេចពួកសមណព្រាហ្មណ៍ ទាំងភរិយារបស់បុរសនោះ ក៏ជាអ្នកវៀរចាកបាណាតិបាត ។ បេ ។ មិនជេរប្រទេចពួកសមណព្រាហ្មណ៍ដែរ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងឈ្មោះថា ទេវតាប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ។ ម្នាលភិក្ខុទាំងឡាយ សង្វាសមាន ៤ យ៉ាងនេះឯង ។

១៤៩

ទុតិយបណ្ណាសកេ    បុញ្ញាភិសន្ទវគ្គោ

ឧភោ  ច  ហោន្តិ  ទុស្សីលា  កទរិយា បរិភាសកា

តេ  ហោន្តិ  ជានិបតយោ  ឆវា  សំវាសមាគតា  ។

សាមិកោ  ហោតិ ទុស្សីលោ  កទរិយោ  បរិភាសកោ

ភរិយា  សីលវតី  ហោតិ  វទញ្ញូ  វីតមច្ឆរា

សាបិ  ទេវី  សំវសតិ  ឆវេន  បតិនា  សហ  ។

សាមិកោ  សីលវា  ហោតិ  វទញ្ញូ  វីតមច្ឆរោ

ភរិយា  ហោតិ  ទុស្សីលា  កទរិយា  បរិភាសិកា

សាបិ  ឆវា  សំវសតិ  ទេវេន  បតិនា  សហ  ។

ជនទាំងពីរនាក់ ជាអ្នកទ្រុស្តសីល ជាអ្នកកំណាញ់ស្វិតស្វាញ ជេរប្រទេច (សមណព្រាហ្មណ៍) ប្រពន្ធនិងប្តីទាំងពីរនាក់នោះ ឈ្មោះថា ខ្មោចនៅរួមជាមួយគ្នា ។ ស្វាមី ជាអ្នកទ្រុស្តសីល មានសេចក្តីកំណាញ់ស្វិតស្វាញ ជេរប្រទេច (សមណព្រាហ្មណ៍) ភរិយាជាអ្នកមានសីល ជាអ្នកដឹងនូវពាក្យពេចន៍នៃពួកស្មូម មានសេចក្តីកំណាញ់ប្រាសចេញហើយ ភរិយានោះឯងឈ្មោះថា ទេវតាស្រីនៅរួមគ្នាជាមួយនឹងប្តីខ្មោច ។ ស្វាមីជាអ្នកមានសីល ជាអ្នកដឹងនូវពាក្យពេចន៍នៃពួកស្មូម មានសេចក្តីកំណាញ់ប្រាសចេញហើយ ភរិយាជាអ្នកទ្រុស្តសីល មានសេចក្តីកំណាញ់ស្វិតស្វាញ ជេរប្រទេច (សមណព្រាហ្មណ៍) ភរិយានោះឯងឈ្មោះថា ស្រីខ្មោច នៅរួមគ្នាជាមួយនឹងប្តីទេវតា ។

ឧភោ សទ្ធា វទញ្ញូ ច សញ្ញតា ធម្មជីវិនោ
តេ ហោន្តិ ជានិបតយោ អញ្ញមញ្ញំ បិយំវទា
អត្ថា សម្បចុរា ហោន្តិ ផាសុកំ ឧបជាយតិ ។
អមិត្តា ទុម្មនា ហោន្តិ ឧភិន្នំ សមសីលិនំ
ឥធ ធម្មំ ចរិត្វាន សមសីលព្វតា ឧភោ
នន្ទិនោ ទេវលោកស្មឹ មោទន្តិ កាមកាមិនោតិ ។

[៥៦] ឯកំ សមយំ ភគវា ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន នកុលបិតុនោ គហបតិស្ស និវេសនំ តេនុ-បសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។

ជនទាំងពីរនាក់ ជាអ្នកមានសទ្ធា អ្នកដឹងនូវពាក្យពេចន៍ នៃពួកស្មូម ជាអ្នកសង្រួម (ក្នុងសីល) អ្នកចិញ្ចឹមជីវិតតាមគន្លងធម៌ ប្រពន្ធនិងប្តីទាំងនោះ ពោលពាក្យផ្អែមល្ហែមទៅរកគ្នានិងគ្នា រមែងមានសេចក្តីចម្រើនដ៏ច្រើន ទាំងមានការនៅជាសុខកើតឡើងដល់គ្នានិងគ្នា ពួកសត្រូវ រមែងអាក់អន់ចិត្ត ចំពោះជនទាំងពីរដែលមានសីលស្មើគ្នា ជនទាំងពីរនាក់ មានសីលនិងវត្តស្មើគ្នា លុះប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ (បើ) មានបំណងក្នុងកាម ក៏រមែងជាអ្នកត្រេកអររីករាយក្នុងទេវលោកបាន ។

[៥៦] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងភេសកឡាវន ជាទីឲ្យអភ័យដល់សត្វម្រឹគ ទៀបក្រុងសុង្សុមារគិរៈ ក្នុងដែនភគ្គៈ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់និវេសន៍ របស់គហបតីឈ្មោះនកុលបិតា លុះចូលទៅដល់ហើយ ទ្រង់គង់ លើអាសនៈដែលគេក្រាលថ្វាយ ។

១៨១



អថខោ នកុលបិតា ច គហបតិ នកុលមាតា ច គហបតានី យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ នកុលបិតា គហបតិ ភគវន្តំ ឯតទវោច យតោ មេ ភន្តេ នកុលមាតា គហបតានី ទហរស្សេវ ទហរា អានីតា នាភិជានាមិ នកុលមាតរំ គហបតានឹ មនសាបិ អតិចរិតា កុតោ បន កាយេន ឥច្ឆេយ្យាម មយំ ភន្តេ ទិដ្ឋេ ចេវ ធម្មេ អញ្ញមញ្ញំ បស្សិតុំ អភិសម្បរាយញ្ច អញ្ញមញ្ញំ បស្សិតុន្តិ ។ នកុលមាតាបិ ខោ គហបតានី ភគវន្តំ ឯតទវោច យតោហំ ភន្តេ នកុលបិតុនោ គហបតិស្ស ទហរស្សេវ ទហរា អានីតា នាភិជានាមិ នកុលបិតរំ គហបតឹ មនសាបិ អតិចរិតា កុតោ បន កាយេន ឥច្ឆេយ្យាម មយំ ភន្តេ ទិដ្ឋេ ចេវ ធម្មេ អញ្ញមញ្ញំ បស្សិតុំ អភិសម្បរាយញ្ច អញ្ញមញ្ញំ បស្សិតុន្តិ

លំដាប់នោះ នកុលបិតាគហបតីនិងនកុលមាតាគហបតានី បាននាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ បានថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនកុលបិតាគហបតី អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមពីខ្ញុំព្រះអង្គ បានប្រសប់គ្នានឹងនកុលមាតាគហបតានី តាំងពីកំឡោះក្រមុំមក មិនដែលប្រព្រឹត្តកន្លងចិត្ត នៃនកុលមាតាគហបតានី សូម្បីដោយចិត្តម្តងទេ មិនបាច់ពោលដល់ទៅការធ្វើដោយកាយឡើយ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នាក្នុងបរលោកផង ។ ចំណែកនកុលមាតាគហបតានី ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះដែរថា បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមពីខ្ញុំម្ចាស់ បានប្រសប់គ្នានឹងនកុលបិតាគហបតី តាំងអំពីកំឡោះក្រមុំមក មិនដែលប្រព្រឹត្តកន្លងចិត្តនៃនកុលបិតាគហបតី សូម្បីដោយចិត្តម្តងទេ មិនបាច់ពោលដល់ទៅការធ្វើដោយកាយឡើយ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នាក្នុងបរលោកផង ។

អាកង្ខេយ្យុំ ចេ គហបតយោ ឧភោ ជានិបតយោ ទិដ្ឋេ ចេវ ធម្មេ អញ្ញមញ្ញំ បស្សិតុំ អភិសម្ប-រាយញ្ច អញ្ញមញ្ញំ បស្សិតុំ ឧភោ វ អស្សុ សមសទ្ធា សមសីលា សមចាគា សមបញ្ញា តេ ទិដ្ឋេ ចេវ ធម្មេ អញ្ញមញ្ញំ បស្សន្តិ អភិសម្បរាយញ្ច អញ្ញមញ្ញំ បស្សន្តីតិ ។

ឧភោ សទ្ធា វទញ្ញូ ច សញ្ញតា ធម្មជីវិនោ
តេ ហោន្តិ ជានិបតយោ អញ្ញមញ្ញំ បិយំ វទា
អត្ថា សម្បចុរា ហោន្តិ ផាសុកំ ឧបជាយតិ
អមិត្តា ទុម្មនា ហោន្តិ ឧភិន្នំ សមសីលិនំ
ឥធ ធម្មំ ចរិត្វាន សមសីលព្វតា ឧភោ
នន្ទិនោ ទេវលោកស្មឹ មោទន្តិ កាមកាមិនោ ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលគហបតីនិងគហបតានីទាំងឡាយ បើជនទាំងពីរនាក់ប្តីប្រពន្ធ ប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នាក្នុងបរលោកផង លុះតែជនទាំងពីរនាក់នោះ មានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានចាគៈស្មើគ្នា មានបញ្ញាស្មើគ្នា ទើបជួបគ្នា ក្នុងបច្ចុប្បន្ននេះផង ជួបគ្នាក្នុងបរលោកផង ។

ជនទាំងពីរនាក់ ជាអ្នកមានសទ្ធា ជាអ្នកដឹងនូវពាក្យ
ពេចន៍នៃស្មូម ជាអ្នកសង្រួម (ក្នុងសីល) អ្នកចិញ្ចឹម
ជីវិត តាមគន្លងធម៌ ប្រពន្ធនិងប្តីទាំងនោះពោលពាក្យ
ផ្អែមល្ហែមរកគ្នានិងគ្នា រមែងមានសេចក្តីចម្រើនដ៏ច្រើន
ទាំងមានការនៅជាសុខ កើតឡើងដល់គ្នានិងគ្នា ពួក
សត្រូវ រមែងអាក់អន់ចិត្តចំពោះជនទាំងពីរនាក់ ដែល
មានសីលស្មើគ្នា ជនទាំងពីរនាក់មានសីលនិងវត្តស្មើ
គ្នា លុះប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ បើមាន
បំណងក្នុងកាម ក៏រមែង ជាអ្នកត្រេកអររីករាយ
ក្នុងទេវលោកបាន ។

១៨៣

ទុតិយបណ្ណាសកេ   បុញ្ញាភិសន្ទវគ្គោ

[៨៧] អាកង្ខេយ្យុំ ចេ ភិក្ខវេ ឧភោ ជានិ-បតយោ ទិដ្ឋេ ចេវ ធម្មេ អញ្ញមញ្ញំ បស្សិតុំ អភិសម្បរាយញ្ច អញ្ញមញ្ញំ បស្សិតុំ ឧភោ វ អស្សុ សមសទ្ធា សមសីលា សមចាគា សមប្បញ្ញា តេ ទិដ្ឋេ ចេវ ធម្មេ អញ្ញមញ្ញំ បស្សន្តិ អភិសម្បរាយញ្ច អញ្ញមញ្ញំ បស្សន្តីតិ ។

ឧភោ សទ្ធា វទញ្ញូ ច   សញ្ញតា ធម្មជីវិនោ
តេ ហោន្តិ ជានិបតយោ   អញ្ញមញ្ញំ បិយំ វទា
អត្ថា សម្បចុរា ហោន្តិ   ផាសុកំ ឧបជាយតិ
អមិត្តា ទុម្មនា ហោន្តិ   ឧភិន្នំ សមសីលិនំ
ឥធ ធម្មំ ចរិត្វាន   សមសីលព្វតា ឧភោ
នន្ទិនោ ទេវលោកស្មឹ   មោទន្តិ កាមកាមិនោតិ ។

[៥៧] ម្នាលភិក្ខុទាំងឡាយ បើប្រពន្ធនិងប្តីទាំងពីរនាក់ ប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នាក្នុងបរលោកផង លុះតែជនទាំងពីរនាក់នោះ មានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានចាគៈស្មើគ្នា មានបញ្ញាស្មើគ្នា ទើបជនទាំងនោះជួបគ្នាក្នុងបច្ចុប្បន្ននេះផង ជួបគ្នាក្នុងបរលោកផង ។

ជនទាំងពីរនាក់ ជាអ្នកមានសទ្ធា ជាអ្នកដឹងនូវពាក្យ
ពេចន៍នៃស្មូម ជាអ្នកសង្រួម (ក្នុងសីល) ជាអ្នក
ចិញ្ចឹមជីវិត តាមគន្លងធម៌ ប្រពន្ធនិងប្តីទាំងនោះ ពោល
ពាក្យផ្អែមល្ហែមរកគ្នានិងគ្នា រមែងមានសេចក្តីចម្រើនដ៏
ច្រើន ទាំងមានការនៅជាសុខ កើតឡើងដល់គ្នានិងគ្នា
ពួកសត្រូវ រមែងអាក់អន់ចិត្ត ចំពោះជនទាំងពីរដែល
មានសីលស្មើគ្នា ជនទាំងពីរនាក់ មានសីលនិងវត្ត
ស្មើគ្នា លុះប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ (បើ)
មានបំណងក្នុងកាម រមែងជាអ្នកត្រេកអររីករាយ
ក្នុងទេវលោកបាន ។

[៥៨] ឯកំ សមយំ ភគវា កោលិយេសុ វិហរតិ បជ្ជនេលំ⁽¹⁾ នាម កោលិយានំ និគមោ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន សុប្បវាសាយ កោលិយធីតាយ និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ សុប្បវាសា កោលិយធីតា ភគវន្តំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ សុប្បវាសា កោលិយធីតា ភគវន្តំ ភុត្តាវី ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ សុប្បវាសំ កោលិយធីតរំ ភគវា ឯតទវោច ភោជនំ សុប្បវាសេ ទេន្តី អរិយសាវិកា បដិគ្គាហកានំ ចត្តារិ ឋានានិ ទេតិ ។ កតមានិ ចត្តារិ ។ អាយុំ ទេតិ វណ្ណំ ទេតិ សុខំ ទេតិ ពលំ ទេតិ ។

1 ឱ. សជ្ជនេលំ ។ ម. បជ្ជនិកំ ។

[៥៨] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគម ឈ្មោះបជ្ជនេលៈ របស់ពួកកោលិយៈរាជត្រកូល ក្នុងដែនកោលិយៈ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហ-សម័យ ស្តេចចូលទៅកាន់និវេសន៍របស់នាងសុប្បវាសា ជាធីតានៃស្តេចកោឡិយៈ លុះស្តេចចូលទៅដល់ ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ វេលានោះ នាងសុប្បវាសាជាធីតានៃស្តេចកោឡិយៈបានអង្គាសថ្វាយខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពីសាដោយដៃខ្លួនឯង ចំពោះព្រះដ៏មានព្រះភាគ ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់ព្រះអង្គប្រកែកលែងទទួលទៀត ។ លុះព្រះដ៏មានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ទើបនាងសុប្បវាសាអង្គុយក្នុងទីសមគួរ ។ លុះនាងសុប្បវាសា ជាកោឡិយធីតា អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសុប្បវាសា អរិយសាវិកា ឲ្យភោជនាហារឈ្មោះថាឲ្យនូវឋានៈ ៤ យ៉ាង ដល់បដិគ្គាហកៈទាំងឡាយ ។ ឋានៈ ៤ យ៉ាង តើដូចម្តេច ។ គឺឲ្យអាយុ ១ ឲ្យវណ្ណៈ ១ ឲ្យសុខៈ ១ ឲ្យពលៈ ១ ។

អាយុំ ខោ បន ទត្វា អាយុស្ស ភាគិនី ហោតិ ទិព្វស្ស វា មានុសស្ស វា វណ្ណំ ទត្វា វណ្ណស្ស ភាគិនី ហោតិ ទិព្វស្ស វា មានុសស្ស វា សុខំ ទត្វា សុខស្ស ភាគិនី ហោតិ ទិព្វស្ស វា មានុសស្ស វា ពលំ ទត្វា ពលស្ស ភាគិនី ហោតិ ទិព្វស្ស វា មានុសស្ស វា ។ ភោជនំ សុប្បវាសេ ទេន្តី អរិយស្សាវិកា បដិគ្គាហកានំ ឥមានិ ចត្តារិ ឋានានិ ទេតីតិ ។

សង្ខតំ[១] ភោជនំ យា ទេតិ
សុចឹ បណីតំ[២] រសសា ឧបេតំ
សា ទក្ខិណា ឧជ្ជុគតេសុ ទិន្នា
ចរណោបបន្នេសុ មហគ្គតេសុ
បុញ្ញេន បុញ្ញំ សំសន្ទមានា
មហប្ផលា លោកវិទូន វណ្ណិតា

១ ឱ. ម. សុសង្ខតំ ។ ២ ម. សុប្បណីតំ ។

លុះឲ្យអាយុហើយ រមែងជាអ្នកមានចំណែក គឺបានទទួលយកនូវអាយុ ដែលជារបស់ទិព្វ ឬជារបស់មនុស្ស លុះឲ្យវណ្ណៈហើយ រមែងជាអ្នកមានចំណែក គឺបានទទួលយកនូវវណ្ណៈដែលជារបស់ទិព្វ ឬជារបស់មនុស្ស លុះឲ្យសុខហើយ រមែងជាអ្នកមានចំណែកគឺបានទទួលយកនូវសុខ ដែលជារបស់ទិព្វ ឬជារបស់មនុស្ស លុះឲ្យពលៈហើយ រមែងជាអ្នកមានចំណែកគឺបានទទួលយកនូវពលៈដែលជារបស់ទិព្វ ឬជារបស់មនុស្ស ។ ម្នាលសុប្បវាសា អរិយសាវិកា ឲ្យភោជនាហារ ឈ្មោះថា ឲ្យឋានៈទាំង ៤ យ៉ាងនេះ ដល់បដិគ្គាហកៈទាំងឡាយ ។

បុគ្គលឲ្យភោជនដែលខ្ជួនតាក់តែងស្អាត ឆ្ងាញ់ពីសាបរិបូណ៌ដោយរស (ដល់បដិគ្គាហកៈ) ទក្ខិណាទាននោះ ដែលបុគ្គលឲ្យហើយ ដល់ព្រះខីណាស្រពទាំងឡាយ មានដំណើរត្រង់ ប្រកបដោយចរណៈ ដល់នូវភាពដ៏ប្រសើរ ជាទីរួបរួមមកនូវបុណ្យ ដោយបុណ្យ ព្រះលោកវិទូ ទ្រង់សរសើរ (នូវទក្ខិណាទាននោះ) ថា ជាទានមានផលច្រើន

ឯតាទិសំ យញ្ញមនុស្សរន្តា
យេ វេទជាតា វិចរន្តិ លោកេ
វិនេយ្យ មច្ឆេរមលំ សមូលំ
អនិន្ទិតា សគ្គមុបេន្តិ ឋានន្តិ ។

[៤៩] អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច ភោជនំ គហបតិ ទទមានោ អរិយសាវកោ បដិគ្គាហកានំ ចត្តារិ ឋានានិ ទេតិ ។ កតមានិ ចត្តារិ ។ អាយុំ ទេតិ វណ្ណំ ទេតិ សុខំ ទេតិ ពលំ ទេតិ ។ អាយុំ ខោ បន ទត្វា អាយុស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា វណ្ណំ ទត្វា... សុខំ ទត្វា... ពលំ ទត្វា ពលស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា ។ ភោជនំ គហបតិ ទទមានោ អរិយសាវកោ បដិគ្គាហកានំ ឥមានិ ចត្តារិ ឋានានិ ទេតីតិ ។

ជនទាំងឡាយណា រលឹកឃើញនូវយញ្ញៈ ដូច្នោះ កើតមានសេចក្តីត្រេកអរ កម្ចាត់បង់នូវមន្ទិលគឺសេចក្តីកំណាញ់ ព្រមទាំងឫសក្នុងលោក ជនទាំងនោះឥតមានគេនិន្ទា តែងចូលទៅកាន់ស្ថានសួគ៌បាន ។

[៥៩] គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលគហបតី អរិយសាវក កាលឲ្យនូវភោជនាហារ ឈ្មោះថា ឲ្យនូវឋានៈ ៤ យ៉ាង ដល់បដិគ្គាហកៈទាំងឡាយ ។ ឋានៈ៤យ៉ាងតើដូចម្តេចខ្លះ ។ គឺឲ្យអាយុ ១ ឲ្យវណ្ណៈ ១ ឲ្យសុខៈ ១ ឲ្យពលៈ ១ ។ លុះឲ្យអាយុហើយ រមែងជាអ្នកមានចំណែក គឺបានទទួលយកនូវអាយុជារបស់ទិព្វ ឬជារបស់មនុស្ស លុះឲ្យវណ្ណៈហើយ... លុះឲ្យសុខៈហើយ... លុះឲ្យពលៈហើយ រមែងជាអ្នកមានចំណែក គឺបានទទួលយកនូវពលៈជារបស់ទិព្វ ឬជារបស់មនុស្ស ។ ម្នាលគហបតី អរិយសាវក កាលឲ្យភោជនាហារឈ្មោះថា ឲ្យនូវឋានៈ ៤ យ៉ាងនេះ ដល់បដិគ្គាហកៈទាំងឡាយ ។

យោ សញ្ញតានំ បរទត្តភោជិនំ
កាលេន សក្កច្ច ទទាតិ ភោជនំ
ចត្តារិ ឋានានិ អនុប្បវេច្ឆតិ
អាយុញ្ច វណ្ណញ្ច សុខំ ពលញ្ច ។

អាយុទាយី ពលទាយី[១] សុខំ វណ្ណំ ទទោ នរោ ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតីតិ ។

[៦០] ភោជនំ ភិក្ខវេ ទទមានោ ទាយកោ បដិគ្គាហកានំ ចត្តារិ ឋានានិ ទេតិ ។ កតមានិ ចត្តារិ ។ អាយុំ ទេតិ វណ្ណំ ទេតិ សុខំ ទេតិ ពលំ ទេតិ ។ អាយុំ ខោ បន ទត្វា អាយុស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា វណ្ណំ ទត្វា... សុខំ ទត្វា... ពលំ ទត្វា ពលស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា ភោជនំ ភិក្ខវេ ទទមានោ ទាយកោ បដិគ្គាហកានំ ឥមានិ ចត្តារិ ឋានានិ ទេតីតិ ។

១ ឱ. ម. សោ អាយុទាយី វណ្ណទាយី ។

បុគ្គលណាឲ្យនូវភោជនាហារ ដល់ពួកភិក្ខុដែលសង្រួម (ក្នុងសីល) ជាអ្នកបរិភោគភោជនដែលបុគ្គលដទៃឲ្យ ដោយគោរព តាមកាល បុគ្គលនោះ រមែងបាន ទទួលនូវឋានៈទាំង ៤ យ៉ាងគឺអាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ ។ ជនអ្នកឲ្យអាយុ ឲ្យពលៈ ឲ្យសុខៈ ឲ្យវណ្ណៈ កើតក្នុងភពណា ៗ រមែងជាអ្នកមានអាយុវែង មានយសបរិវារ ក្នុងភពនោះ ៗ ។

[៦០] ម្នាលភិក្ខុទាំងឡាយ ទាយកកាលឲ្យនូវភោជនាហារ ឈ្មោះថា ឲ្យនូវឋានៈ ៤ យ៉ាង ដល់បដិគ្គាហកៈទាំងឡាយ ។ ឋានៈ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺឲ្យអាយុ ១ ឲ្យវណ្ណៈ ១ ឲ្យសុខៈ ១ ឲ្យពលៈ ១ ។ លុះឲ្យអាយុហើយ រមែងជាអ្នកមានចំណែកគឺបានទទួលនូវអាយុ ជារបស់ទិព្វ ឬជារបស់មនុស្ស លុះឲ្យវណ្ណៈហើយ... លុះឲ្យសុខហើយ... លុះឲ្យពលៈហើយ រមែងជាអ្នកមានចំណែកគឺបានទទួលនូវពលៈ ជារបស់ទិព្វ ឬជារបស់មនុស្ស ម្នាលភិក្ខុទាំងឡាយ ទាយកកាលឲ្យនូវភោជនាហារ ឈ្មោះថា ឲ្យនូវឋានៈ ៤ យ៉ាងនេះ ដល់បដិគ្គាហកៈទាំងឡាយ ។

យោ សញ្ញតានំ បរទត្តភោជិនំ
កាលេន សក្កច្ច ទទាតិ ភោជនំ
ចត្តារិ ឋានានិ អនុប្បវេច្ឆតិ
អាយុញ្ច វណ្ណញ្ច សុខំ ពលញ្ច ។

អាយុទាយី ពលទាយី សុខំ វណ្ណំ ទទោ នរោ ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតីតិ ។

[៦១] អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច ចតូហិ ខោ គហបតិ ធម្មេហិ សមន្នាគតោ អរិយសាវកោ គិហិសាមីចិប្បដិបទំ បដិបន្នោ ហោតិ យសប្បដិលាភិនឹ សគ្គសំវត្តនិកំ ។ កតមេហិ ចតូហិ ។

បុគ្គលណាឲ្យនូវភោជនាហារ ដល់ពួកភិក្ខុដែលជាអ្នក សង្រួម (ក្នុងសីល) ជាអ្នកបរិភោគនូវភោជន ដែលអ្នកដទៃឲ្យ ដោយគោរពតាមកាល បុគ្គលនោះ រមែងបានទទួលនូវឋានៈទាំង ៤ យ៉ាងគឺអាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ ។ ជនអ្នកឲ្យអាយុ ឲ្យពលៈ ឲ្យសុខៈ ឲ្យវណ្ណៈ កើតក្នុងភពណា ៗ រមែងជាអ្នកមានអាយុវែង មានយសបរិវារ ក្នុងភពនោះ ៗ ។

[៦១] គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលគហបតី អរិយសាវ័ក ប្រកបដោយធម៌ ៤ យ៉ាង ប្រតិបត្តិនូវបដិបទា ដ៏សមគួររបស់គ្រហស្ថ មានប្រក្រតីបាននូវយស ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ។ អរិយសាវ័កប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។

ឥធ គហបតិ អរិយសាវកោ ភិក្ខុសង្ឃំ បច្ចុបដ្ឋិតោ ហោតិ ចីវរេន ភិក្ខុសង្ឃំ បច្ចុបដ្ឋិតោ ហោតិ បិណ្ឌបាតេន ភិក្ខុសង្ឃំ បច្ចុបដ្ឋិតោ ហោតិ សេនាសនេន ភិក្ខុសង្ឃំ បច្ចុបដ្ឋិតោ ហោតិ គិលានប្បច្ចយភេសជ្ជបរិក្ខារេន ។ ឥមេហិ ខោ គហបតិ ចតូហិ ធម្មេហិ សមន្នាគតោ អរិយសាវកោ គិហិសាមីចិប្បដិបទំ បដិបន្នោ ហោតិ យសប្បដិលាភិនី សគ្គសំវត្តនិកាន្តិ ។

| | |
|---|---|
| គិហិសាមីចិប្បដិបទំ | បដិបជ្ជន្តិ បណ្ឌិតា |
| សមគ្គតេ សីលវន្តេ | ចីវរេន ឧបដ្ឋិតា |
| បិណ្ឌបាតសយនេន | គិលានប្បច្ចយេន ច |
| តេសំ ទិវា ច រត្តោ ច | សទា បុញ្ញំ បវឌ្ឍតិ |
| សគ្គញ្ច កមតិដ្ឋានំ[១] | កម្មំ កត្វាន ភទ្ទកន្តិ ។ |

បុញ្ញាភិសន្ទវគ្គោ បឋមោ ។

---

១ ម. សប្បតិដ្ឋានំ ។

ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ ទំនុកបំរុងភិក្ខុសង្ឃដោយចីវរ ១ ទំនុកបំរុងភិក្ខុសង្ឃដោយបិណ្ឌបាត ១ ទំនុកបំរុងភិក្ខុសង្ឃដោយសេនាសនៈ ១ ទំនុកបំរុងភិក្ខុសង្ឃដោយភេសជ្ជបរិក្ខារ ជាបច្ច័យដល់មនុស្សមានជំងឺ ១ ។ ម្នាលគហបតី អរិយសាវក ប្រកបដោយធម៌ទាំង ៤ យ៉ាងនេះឯង ឈ្មោះថា ប្រតិបត្តិនូវបដិបទាដ៏សមគួររបស់គ្រហស្ថមានប្រក្រតីបាននូវយសប្រព្រឹត្តទៅដើម្បីកើត ក្នុងស្ថានសួគ៌ ។

បណ្ឌិតទាំងឡាយ តែងប្រតិបត្តិនូវបដិបទាដ៏សមគួរ
របស់គ្រហស្ថគឺទំនុកបំរុងភិក្ខុ ដែលមានសីល ជា
អ្នកព្រមព្រៀងគ្នាដោយចីវរ ដោយបិណ្ឌបាត ដោយ
សេនាសនៈ និងគិលានប្បច្ច័យ បុណ្យតែងចម្រើនដល់
បណ្ឌិតទាំងឡាយនោះ សព្វ ៗ កាល ទាំងយប់ទាំង
ថ្ងៃ លុះធ្វើកម្មដ៏ចម្រើនហើយ រមែងទៅកាន់ស្ថានសួគ៌ ។

ចប់ បុញ្ញាភិសន្ទវគ្គ ទី ១ ។

# តស្សុទ្ទានំ

ទ្វេ បុញ្ញាភិសន្ទា ទ្វេ
សំវាសា ទ្វេ ច ហោន្តិ សមជីវិនោ
សុប្បវាសា សុទត្តោ ច
ភោជនំ គិហិសាមីចីតិ(១) ។

១ ឱ. សាមីចិនាតិ ។

# ឧទ្ទាននៃបុញ្ញាភិសន្ទវគ្គនោះគឺ

*និយាយពីអានិសង្សនៃបុណ្យ ២ លើក និយាយពីសង្វាស ២ លើក និយាយពីការចិញ្ចឹមជីវិត តាមគន្លងធម៌ ២ លើក និយាយពីរឿងនាងសុប្បវាសា ១ និយាយពីការឲ្យទានដោយប្រពៃ ១ និយាយពីការឲ្យភោជន ១ និយាយពីអរិយសាវក ប្រតិបត្តិដ៏សមគួររបស់គ្រហស្ថ ១ ។*

---

# បត្តកម្មវគ្គោ

[៦២] អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច ចត្តារោមេ គហបតិ ធម្មា ឥដ្ឋា កន្តា មនាបា ទុល្លភា លោកស្មឹ ។ កតមេ ចត្តារោ ។ ភោគា មេ ឧប្បជ្ជន្តុ សហធម្មេនាតិ អយំ បឋមោ ធម្មោ ឥដ្ឋោ កន្តោ មនាបោ ទុល្លភោ លោកស្មឹ ។ ភោគេ លទ្ធា សហធម្មេន យសោ មំ អព្ភុគ្គច្ឆតុ សហ ញាតីហិ សហ ឧបជ្ឈាយេហីតិ អយំ ទុតិយោ ធម្មោ ឥដ្ឋោ កន្តោ មនាបោ ទុល្លភោ លោកស្មឹ ។ ភោគេ លទ្ធា សហធម្មេន យសំ លទ្ធា សហ ញាតីហិ សហ ឧបជ្ឈាយេហិ ចិរំ ជីវាមិ ទីឃមាយុំ[១] បាលេមីតិ អយំ តតិយោ ធម្មោ

---

១ ឱ. ទីឃមទ្ធាយុំ ។

# បត្តកម្មវគ្គ

[៦២] គ្រានោះឯង អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ដូច្នេះថា ម្នាលគហបតី ធម៌ ៤ ប្រការនេះ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្តដែលបុគ្គលរកបានដោយក្រក្នុងលោក ។ ធម៌ ៤ ប្រការ ដូចម្តេចខ្លះ ។ បំណងថា ភោគៈទាំងឡាយ ចូរកើតដល់អាត្មាអញដែលប្រកបដោយធម៌ នេះជាធម៌ទី ១ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោក ។ បំណងថា កាលបើអាត្មាអញ បាននូវភោគៈដោយកម្មប្រកបដោយធម៌ហើយ សូមឲ្យយសរបស់អាត្មាអញល្បីខ្ចរខ្ចាយឡើងព្រមទាំងពួកញាតិ ព្រមទាំងពួកឧបជ្ឈាយ៍ គឺមិត្រសំឡាញ់ទាំងឡាយ នេះជាធម៌ទី ២ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោក ។ បំណងថា កាលបើអាត្មាអញ បានភោគៈដោយកម្មប្រកបដោយធម៌ហើយ បានយសហើយ ទើបអាត្មាអញព្រមទាំងពួកញាតិ ព្រមទាំងពួកឧបជ្ឈាយ៍ នឹងចិញ្ចឹមជីវិតអស់កាលយូរ រក្សាអាយុឲ្យបានវែង នេះជាធម៌ទី ៣ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោក ។

ឥដ្ឋោ កន្តោ មនាបោ ទុល្លភោ លោកស្មឹ ។ ភោគេ លទ្ធា សហ ធម្មេន យសំ លទ្ធា សហ ញាតីហិ សហ ឧបជ្ឈាយេហិ ចិរំ ជីវិត្វា ទីឃមាយុំ បាលេត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជាមីតិ អយំ ចតុត្ថោ ធម្មោ ឥដ្ឋោ កន្តោ មនាបោ ទុល្លភោ លោកស្មឹ ។ ឥមេ ខោ គហបតិ ចត្តារោ ធម្មា ឥដ្ឋា កន្តា មនាបា ទុល្លភា លោកស្មឹ ។ ឥមេសំ ខោ គហបតិ ចតុន្នំ ធម្មានំ ឥដ្ឋានំ កន្តានំ មនាបានំ ទុល្លភានំ លោកស្មឹ ចត្តារោ ធម្មា បដិលាភាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ សទ្ធាសម្បទា សីលសម្បទា ចាគសម្បទា បញ្ញាសម្បទា ។ កតមា ច គហបតិ សទ្ធាសម្បទា ។ ឥធ គហបតិ អរិយ-សាវកោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ-សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ

បំណងថា កាលបើអាត្មាអញ បាននូវភោគៈ ដោយកម្មប្រកបដោយធម៌ហើយ បានយសហើយ ទើបអាត្មាអញព្រមទាំងពួកញាតិ ព្រមទាំងឧបជ្ឈាយ៍ បានចិញ្ចឹមជីវិតអស់កាលយូរ រក្សាអាយុឲ្យបានវែងហើយ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ សូមឲ្យបានទៅកើតក្នុងសុគតិសួគ៌ទេវលោក នេះជាធម៌ ទី ៤ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោក ។ ម្នាលគហបតី ធម៌ ៤ ប្រការនេះ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោក ។ ម្នាលគហបតី ធម៌ ៤ ប្រការ ប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវធម៌ ៤ ប្រការ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោកនេះ ។ ធម៌ ៤ ប្រការដូចម្តេច ។ គឺសទ្ធាសម្បទា ១ សីលសម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលគហបតី ចុះសទ្ធាសម្បទា តើដូចម្តេច ។ ម្នាលគហបតី អរិយសាវ័ក ក្នុងសាសនានេះ មានសទ្ធាជឿសេចក្តីត្រាស់ដឹងព្រះតថាគតថា ព្រះដ៏មានព្រះភាគនោះ ព្រះអង្គ ជាអរហន្ត ជាសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ មានព្រះដំណើរល្អ ជ្រាបច្បាស់នូវលោក ឥតមានបុគ្គលដទៃស្មើ ទូន្មានបុរសដែលគួរទូន្មានបាន

សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ អយំ វុច្ចតិ គហបតិ សទ្ធាសម្បទា ។ កតមា ច គហបតិ សីលសម្បទា ។ ឥធ គហបតិ អរិយសាវកោ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ អយំ វុច្ចតិ គហបតិ សីល-សម្បទា ។ កតមា ច គហបតិ ចាគសម្បទា ។ ឥធ គហបតិ អរិយសាវកោ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តចាគោ បយតបាណិ វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ អយំ វុច្ចតិ គហបតិ ចាគសម្បទា ។ កតមា ច គហបតិ បញ្ញាសម្បទា ។ អភិជ្ឈាវិសមលោភាភិភូតេន គហបតិ ចេតសា វិហរន្តោ អកិច្ចំ ករោតិ កិច្ចំ អបរាធេតិ អកិច្ចំ ករោន្តោ កិច្ចំ អបរាធេន្តោ យសា ច សុខា ច ធំសតិ ព្យាបាទាភិភូតេន គហបតិ ចេតសា វិហរន្តោ អកិច្ចំ ករោតិ កិច្ចំ អបរាធេតិ អកិច្ចំ ករោន្តោ

ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវចតុរារិយសច្ច លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ម្នាលគហបតី នេះហៅថា សទ្ធាសម្បទា ។ ម្នាលគហបតី ចុះសីលសម្បទា តើដូចម្តេច ។ ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ វៀរចាកបាណាតិបាត ។ បេ ។ វៀរចាកទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ម្នាលគហបតី នេះហៅថា សីលសម្បទា ។ ម្នាលគហបតី ចុះចាគសម្បទា តើដូចម្តេច ។ ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ មានចិត្តប្រាសចាកសេចក្តីកំណាញ់ ជាមន្ទិល មានការបរិច្ចាគហើយ មានដៃលាងស្អាត ត្រេកអរក្នុងការលះបង់ គួរដល់ស្មូម ត្រេកអរក្នុងទាននិងការចែកចាយ នៅគ្រប់គ្រងផ្ទះ ម្នាលគហបតី នេះហៅថា ចាគសម្បទា ។ ម្នាលគហបតី ចុះបញ្ញាសម្បទា តើដូចម្តេច ។ ម្នាលគហបតី បុគ្គលកាលមានចិត្តត្រូវអភិជ្ឈាវិសមលោភៈគ្របសង្កត់ រមែងធ្វើការងារដែលមិនគួរ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ កាលធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ រមែងសាបសូន្យចាកយសនិងសេចក្តីសុខ ម្នាលគហបតី បុគ្គលកាល មានចិត្តត្រូវព្យាបាទគ្របសង្កត់ រមែងធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ កាលធ្វើការងារ ដែលមិនគួរធ្វើ

កិច្ចំ អបាជេន្តោ យសា ច សុខា ច ជំសតិ ថីនមិទ្ធាភិភូតេន គហបតិ ចេតសា វិហរន្តោ អកិច្ចំ ករោតិ កិច្ចំ អបាជេតិ អកិច្ចំ ករោន្តោ កិច្ចំ អបាជេន្តោ យសា ច សុខា ច ជំសតិ ឧទ្ធច្ច-កុក្កុច្ចាភិភូតេន គហបតិ ចេតសា វិហរន្តោ អកិច្ចំ ករោតិ កិច្ចំ អបាជេតិ អកិច្ចំ ករោន្តោ កិច្ចំ អបាជេន្តោ យសា ច សុខា ច ជំសតិ វិចិកិច្ឆា-ភិភូតេន គហបតិ ចេតសា វិហរន្តោ អកិច្ចំ ករោតិ កិច្ចំ អបាជេតិ អកិច្ចំ ករោន្តោ កិច្ចំ អបាជេន្តោ យសា ច សុខា ច ជំសតិ ។ ស ខោ សោ[១] គហបតិ អរិយសាវកោ អភិជ្ឈាវិសមលោភោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា អភិជ្ឈាវិសមលោភំ ចិត្តស្ស ឧបក្កិលេសំ បជហាតិ ព្យាបាទោ ចិត្តស្ស ឧបក្កិ-លេសោតិ ឥតិ វិទិត្វា ព្យាបាទំ ចិត្តស្ស ឧបក្កិលេសំ បជហាតិ ថីនមិទ្ធំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា

១ ម. អថខោ សោ ។

ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ រមែងសាបសូន្យចាកយសនិង សេចក្តីសុខ ម្នាលគហបតី បុគ្គលកាល មានចិត្តត្រូវថីនមិទ្ធៈ គ្រប សង្កត់ រមែងធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាស ទៅ កាលធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាស ទៅ រមែងសាបសូន្យចាកយសនិងសេចក្តីសុខ ម្នាលគហបតី បុគ្គល កាលមានចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ រមែងធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ កាលធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ រមែងសាបសូន្យចាកយសនឹង សេចក្តីសុខ ម្នាលគហបតី បុគ្គលកាល មានចិត្តត្រូវវិចិកិច្ឆាគ្របសង្កត់ រមែងធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើ ឲ្យវិនាសទៅ កាលធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើ ឲ្យវិនាសទៅ រមែងសាបសូន្យចាកយសនិងសេចក្តីសុខ ។ ម្នាលគហបតី អរិយ-សាវ័កនោះឯង ដឹងច្បាស់ថា អភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃ ចិត្តហើយ ក៏លះបង់អភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃចិត្តចេញ ដឹងច្បាស់ថា ព្យាបាទជាឧបក្កិលេសនៃចិត្តហើយ ក៏លះបង់ព្យាបាទជា ឧបក្កិលេសនៃចិត្តចេញ ដឹងច្បាស់ថាថីនមិទ្ធៈ ជាឧបក្កិលេសនៃចិត្តហើយ

ថីនមិទ្ធំ ចិត្តស្ស ឧបក្កិលេសំ បជហាតិ ឧទ្ធច្ចកុក្កុច្ចំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ឧទ្ធច្ចកុក្កុច្ចំ ចិត្តស្ស ឧបក្កិលេសំ បជហាតិ វិចិកិច្ឆា ចិត្តស្ស ឧប-ក្កិលេសោតិ ឥតិ វិទិត្វា វិចិកិច្ឆំ ចិត្តស្ស ឧបក្កិលេសំ បជហាតិ ។ យតោ ច ខោ គហបតិ អរិយស្សាវ-កស្ស[(១)] អភិជ្ឈាវិសមលោភោ ចិត្តស្ស ឧបក្កិលេ-សោតិ ឥតិ វិទិត្វា អភិជ្ឈាវិសមលោភោ ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ព្យាបាទោ ចិត្តស្ស ឧបក្កិលេសោ... ថីនមិទ្ធំ ចិត្តស្ស ឧបក្កិលេសោ... ឧទ្ធច្ចកុក្កុច្ចំ ចិត្តស្ស ឧបក្កិលេសោ... វិចិកិច្ឆា ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា វិចិកិច្ឆា ចិត្តស្ស ឧបក្កិ-លេសោ បហីនោ ហោតិ ។ អយំ វុច្ចតិ គហបតិ អរិយស្សាវកោ មហាបញ្ញោ បុថុបញ្ញោ អាបាថទសោ បញ្ញាសម្បន្នោ[(២)] ។ អយំ វុច្ចតិ គហបតិ បញ្ញា-សម្បទា ។ ឥមេសំ ខោ គហបតិ ចតុន្នំ ធម្មានំ ឥដ្ឋានំ កន្តានំ មនាបានំ ទុល្លភានំ លោកស្មឹ ឥមេ ចត្តារោ ធម្មា បដិលាភាយ សំវត្តន្តិ ។

១ ឱ. អរិយសាវកោ ។ ២ ម ហាសបញ្ញោ ។

ក៏លះបង់ថីនមិទ្ធៈជាឧបក្កិលេសនៃចិត្តចេញ ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈ ជាឧបក្កិលេសនៃចិត្តហើយ ក៏លះបង់ឧទ្ធច្ចកុក្កុច្ចៈ ជាឧបក្កិលេសនៃចិត្តចេញ ដឹងច្បាស់ថា វិចិកិច្ឆា ជាឧបក្កិលេសនៃចិត្តហើយ ក៏លះបង់វិចិកិច្ឆា ជាឧបក្កិលេសនៃចិត្តចេញ ។ ម្នាលគហបតី កាលណា អរិយសាវ័ក ដឹងច្បាស់ថា អភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃចិត្តហើយ ក៏បានលះបង់អភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃចិត្តចេញ ព្យាបាទ ជាឧបក្កិលេសនៃចិត្ត... ថីនមិទ្ធៈជាឧបក្កិលេសនៃចិត្ត... ឧទ្ធច្ចកុក្កុច្ចៈ ជាឧបក្កិលេសនៃចិត្តហើយ... ដឹងច្បាស់ថា វិចិកិច្ឆាជាឧបក្កិលេសនៃចិត្តហើយ ក៏បានលះបង់វិចិកិច្ឆាជាឧបក្កិលេសនៃចិត្តចេញ ។ ម្នាលគហបតី អរិយសាវ័កនេះហៅថាជាអ្នកមានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស់ ជាអ្នកយល់សេចក្តីតាមគន្លងនៃពាក្យ បរិបូណ៌ដោយប្រាជ្ញា ។ ម្នាលគហបតី នេះហៅថា បញ្ញាសម្បទា ។ ម្នាលគហបតី ធម៌ទាំង ៤ ប្រការនេះ ប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវធម៌ទាំង ៤ ប្រការនេះ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោក ។

ស ខោ សោ គហបតិ អរិយស្សាវកោ ឧដ្ឋាន-
វីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ
សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ ចត្តារិ
បត្តកម្មានិ កត្តា ហោតិ ។ កតមានិ
ចត្តារិ ។ ឥធ គហបតិ អរិយស្សាវកោ ឧដ្ឋានវីរិយា-
ធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិ-
ត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ អត្តានំ សុខេតិ
បីណេតិ សម្មា សុខំ បរិហរតិ មាតាបិតរោ សុខេតិ
បីណេតិ សម្មា សុខំ បរិហរតិ បុត្តទារទាសកម្មករ-
បោរិសេ សុខេតិ បីណេតិ សម្មា សុខំ បរិហរតិ
មិត្តាមច្ចេ សុខេតិ បីណេតិ សម្មា សុខំ បរិហរតិ ។
ឥទមស្ស បឋមំ ឋានំ គតំ ហោតិ បត្តគតំ
អាយតនសោ បរិភុត្តំ ។ បុន ចបរំ គហបតិ

ម្នាលគហបតី អរិយសាវ័កនោះ ជាអ្នកធ្វើកម្មដ៏សមគួរ ៤ ប្រការ ដោយភោគៈទាំងឡាយ ដែលអរិយសាវ័ក បានដោយសេចក្តីព្យាយាមពោល គឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមក ដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។ កម្មដ៏សមគួរ ៤ ប្រការដូចម្តេច ។ ម្នាលគហបតី អរិយសាវ័ក ក្នុងសាសនានេះ ញុំាងខ្លួនឲ្យសុខ ឲ្យឆ្អែត រក្សាសុខដោយប្រពៃ ញុំាងមាតាបិតាឲ្យសុខ ឲ្យឆ្អែត រក្សាសុខដោយប្រពៃ ញុំាងកូនប្រពន្ធនិងបុរស ជាទាសកម្មករ ឲ្យសុខ ឲ្យឆ្អែត រក្សាសុខដោយប្រពៃ ញុំាងមិត្ត អាមាត្យ ឲ្យសុខ ឲ្យឆ្អែត រក្សាសុខដោយប្រពៃដោយភោគៈទាំងឡាយ ដែលបានមកដោយសេចក្តីព្យាយាមពោលគឺសេចក្តីខ្នះខ្នែង សន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជារបស់ប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី ១ ដែលអរិយសាវ័កនោះបានដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។ ម្នាលគហបតី ប្រការមួយទៀត

ទុតិយបណ្ណាសកេ បត្តកម្មវគ្គោ

អរិយសាវកោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ យា តា ហោន្តិ អាបទា អគ្គិតោ វា ឧទកតោ វា រាជតោ វា ចោរតោ វា អប្បិយតោ វា ទាយាទតោ វា តថារូបាសុ អាបទាសុ ភោគេហិ បរិយោធាយ វត្តតិ សោត្ថឹ អត្តានំ ករោតិ ។ ឥទមស្ស ទុតិយំ ឋានំ គតំ ហោតិ បត្តគតំ អាយតនសោ បរិភុត្តំ ។ បុន ចបរំ គហបតិ អរិយសាវកោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ បញ្ច ពលី កត្តា ហោតិ ញាតិពលឹ អតិថិពលឹ បុព្វបេតពលឹ រាជពលឹ ទេវតាពលឹ ។ ឥទមស្ស តតិយំ ឋានំ គតំ ហោតិ បត្តគតំ អាយតនសោ បរិភុត្តំ ។

សេចក្តីអន្តរាយណា ដែលកើតអំពីភ្លើងក្តី អំពីទឹកក្តី អំពីស្តេចក្តី អំពីចោរក្តី អំពីបុគ្គលមិនជាទីស្រឡាញ់ក្តី អំពីអ្នកទទួលមត៌កក្តី អរិយសាវ័ក ក៏ការពារទប់ទល់ ចំពោះអន្តរាយ មានសភាពដូច្នោះបាន ដោយភោគៈទាំងឡាយ ធ្វើខ្លួនឲ្យដល់នូវសួស្តីបាន ក៏ដោយភោគៈទាំងឡាយ ដែលបានដោយព្យាយាមពោលគឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមក ដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី ២ ដែលអរិយសាវ័កនោះដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។ ម្នាលគហបតី ប្រការមួយទៀត អរិយ-សាវក ធ្វើពលីទាំង ៥ គឺញាតិពលិ ១ អតិថិពលិ ១ បុព្វបេតពលិ ១ រាជពលិ ១ ទេវតាពលិ ១ ដោយភោគៈទាំងឡាយ ដែលបានមកដោយព្យាយាម ពោលគឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមក ដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី ៣ ដែលអរិយសាវ័កនោះដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។

បុន ចបរំ គហបតិ អរិយសាវកោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ យេ តេ សមណព្រាហ្មណា មទប្បមាទា បដិវិរតា ខន្តិសោរច្ចេ និវិដ្ឋា ឯកមត្តានំ ទមេន្តិ ឯកមត្តានំ សមេន្តិ ឯកមត្តានំ បរិនិព្វាបេន្តិ តថារូបេសុ សមណព្រាហ្មណេសុ ឧទ្ធគ្គិកំ ទក្ខិណំ បតិដ្ឋាបេតិ សោវគ្គិកំ សុខវិបាកំ សគ្គសំវត្តនិកំ ។ ឥទមស្ស ចតុត្ថំ ឋានំ គតំ ហោតិ បត្តគតំ អាយតនសោ បរិភុត្តំ ។ ស ខោ សោ គហបតិ អរិយសាវកោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ ឥមានិ ចត្តារិ បត្តកម្មានិ កត្តា ហោតិ ។ យស្ស កស្សចិ គហបតិ អញ្ញត្រ ឥមេហិ ចតូហិ បត្តកម្មេហិ ភោគា បរិក្ខយំ គច្ឆន្តិ ឥមេ វុច្ចន្តិ គហបតិ ភោគា អដ្ឋានគតា

ម្នាលគហបតី ប្រការមួយទៀត ពួកសមណព្រាហ្មណ៍ណា វៀរចាកសេចក្តីវង្វេងនិងសេចក្តីប្រមាទ ឋិតនៅក្នុងខន្តិនិងសោរច្ចៈ ទូន្មានតែខ្លួនមួយ រម្ងាប់កិលេសចំពោះខ្លួនមួយ ញុំាងតែខ្លួនមួយឲ្យបរិនិព្វាន អរិយសាវ័ក រមែងញុំាងទក្ខិណាទាន មានផលដ៏ខ្ពស់ប្រសើរ នាំឲ្យទៅកើតក្នុងស្ថានសួគ៌ មានសុខជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ ឲ្យប្រតិ-ស្ឋាននៅក្នុងពួកសមណព្រាហ្មណ៍ មានសភាពដូច្នោះ បានដោយភោគៈទាំងឡាយ ដែលបានមកដោយព្យាយាម ពោលគឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមក ដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី ៤ ដែលអរិយសាវ័កនោះដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។ ម្នាលគហបតី អរិយសាវ័កនោះឯង ជាអ្នកធ្វើកម្មដ៏សមគួរទាំង ៤ ប្រការនេះ បានដោយភោគៈទាំងឡាយ ដែលបានមកដោយព្យាយាមពោលគឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមក ដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។ ម្នាលគហបតី ភោគៈទាំងឡាយរបស់បុគ្គលណាមួយ តែវៀរលែងចាកកម្មដ៏សមគួរទាំង ៤ ប្រការចេញហើយ រមែងដល់នូវការអស់ទៅ ម្នាលគហបតី ភោគៈទាំងឡាយនេះ ហៅថា មិនដល់នូវហេតុដ៏សមគួរ

អប្បត្តកតា អនាយតនសោ បរិភុត្តា ។ យស្ស កស្សចិ គហបតិ ឥមេហិ ចតូហិ បត្តកម្មេហិ ភោគា បរិក្ខយំ គច្ឆន្តិ ឥមេ វុច្ចន្តិ គហបតិ ភោគា ឋានគតា បត្តគតា អាយតនសោ បរិភុត្តាតិ ។

ភុត្តា ភោគា ភដា ភច្ចា[១] វិតិណ្ណា អាបទាសុ មេ
ឧទ្ធគ្គា ទក្ខិណា ទិន្នា អថោ បញ្ច ពលី កតា
ឧបដ្ឋិតា សីលវន្តោ សញ្ញតា ព្រហ្មចារិនោ
យទត្ថំ ភោគមិច្ឆេយ្យ បណ្ឌិតោ ឃរមាវសំ
សោ មេ អត្ថោ អនុប្បត្តោ កតំ អននុតាបិយំ

១ ម. គតា ភូតា ។

មិនបានសម្រេច មិនបានបរិភោគ ដោយទំនង៍ដ៏សមគួរ ។ ម្នាលគហបតី ភោគៈទាំង៍ឡាយ របស់បុគ្គលណាមួយ អស់ទៅដោយកម្មដ៏សមគួរ ទាំង៍ ៤ នេះ ម្នាលគហបតី ភោគៈទាំង៍ឡាយនេះ ហៅថា ដល់នូវហេតុដ៏សមគួរ បានសម្រេច បានបរិភោគដោយទំនង៍ដ៏សមគួរ ។

ភោគៈទាំង៍ឡាយ អាត្មាអញបរិភោគហើយ មិត្តអាមាត្យ អាត្មាអញចិញ្ចឹមហើយ អាត្មាអញឆ្លង៍អន្តរាយទាំង៍ឡាយបានហើយ ទក្ខិណាទាន មានផលដ៏ខ្ពស់ប្រសើរ អាត្មាអញបានឲ្យហើយ ឯពលីទាំង៍ ៥ អាត្មាអញបានធ្វើហើយ អ្នកមានសីល មានសេចក្តីសង្រួម មានព្រហ្មចរិយធម៌ អាត្មាអញបានទំនុកបម្រុង៍ហើយ បណ្ឌិតកាលនៅគ្រប់គ្រង៍ផ្ទះ គប្បីប្រាថ្នាភោគៈ ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ អាត្មាអញបានសម្រេចហើយ កម្មដែលមិននាំឲ្យកើតសេចក្តីក្តៅក្រហាយ អាត្មាអញបានធ្វើហើយ

ឯតំ[១] អនុស្សរំ មច្ចោ អរិយធម្មេ ឋិតោ នរោ
ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតីតិ ។

[៦៣] អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច ចត្តារីមានិ គហបតិ សុខានិ អធិគមនីយានិ គិហិនា កាមភោគិនា កាលេន កាលំ សមយេន សមយំ ឧបាទាយ ។ កតមានិ ចត្តារិ ។ អត្ថិសុខំ ភោគសុខំ អនណសុខំ[២] អនវជ្ជសុខំ ។ កតមញ្ច គហបតិ អត្ថិសុខំ ។ ឥធ គហបតិ កុលបុត្តស្ស ភោគា ហោន្តិ ឧដ្ឋានវីរិយាធិគតា ពាហាពលបរិចិតា សេទាវក្ខិត្តា

១ ម. ឯវំ ។ ២ ម. អនណ្យសុខំ ។

ជនអ្នកមានសេចក្តីស្ងាប់ជាធម្មតា កាលរលឹកឃើញនូវប្រយោជន៍នុ៎ះ រមែងឋិតនៅក្នុងអរិយធម៌ បណ្ឌិតទាំងឡាយ រមែងសរសើរជននោះ ក្នុងលោកនេះដោយពិត ជននោះ លុះលះលោកនេះទៅ រមែងត្រេកអរក្នុងឋានសួគ៌ ។

[៦៣] គ្រានោះឯង អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតី គិហិសុខ (សុខរបស់គ្រហស្ថ) នេះមាន ៤ យ៉ាង ដែលគ្រហស្ថអ្នកបរិភោគកាម អាស្រ័យនូវកាលតាមកាល នូវសម័យតាមសម័យ គប្បីបានសម្រេច ។ សេចក្តីសុខ ៤ ប្រការ ដូចម្តេចខ្លះ ។ គឺ អត្ថិសុខ (សុខព្រោះចេះតែមាន) ១ ភោគសុខ (សុខព្រោះចេះប្រើប្រាស់) ១ អនណសុខ (សុខព្រោះមិនជំពាក់បំណុលគេ) ១ អនវជ្ជសុខ (សុខព្រោះមិនមានទោស) ១ ។ ម្នាលគហបតី ចុះអត្ថិសុខតើដូចម្តេច ។ ម្នាលគហបតី កុលបុត្រក្នុងលោកនេះ មានភោគៈ ដែលបានមក ដោយព្យាយាមពោលគឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមក ដោយកម្លាំងដៃ មានញើសហូរចេញ

១៧១



ធម្មិកា ធម្មលទ្ធា សោ ភោគា មេ អត្ថិ ឧដ្ឋានវីរិយាធិគតា ពាហាពលបរិចិតា សេទាវក្ខិត្តា ធម្មិកា ធម្មលទ្ធាតិ អធិគច្ឆតិ សុខំ អធិគច្ឆតិ សោមនស្សំ ។ ឥទំ វុច្ចតិ គហបតិ អត្ថិសុខំ ។ កតមញ្ច គហបតិ ភោគសុខំ ។ ឥធ គហបតិ កុលបុត្តោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ ភោគេ ច ភុញ្ជតិ បុញ្ញានិ ច ករោតិ សោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ ភោគេ ច ភុញ្ជាមិ បុញ្ញានិ ច ករោមីតិ អធិគច្ឆតិ សុខំ អធិគច្ឆតិ សោមនស្សំ ។ ឥទំ វុច្ចតិ គហបតិ ភោគសុខំ ។ កតមញ្ច គហបតិ អនណសុខំ ។ ឥធ គហបតិ កុលបុត្តោ

ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ កុលបុត្រនោះ រមែងបាន សុខ រមែងបានសោមនស្សថា ភោគៈទាំងឡាយ ដែលបានមកដោយ ព្យាយាម ពោលគឺសេចក្ដីខ្នះខ្នែង ដែលសន្សំបានមក ដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ របស់ អាត្មាអញមាន ។ ម្នាលគហបតី នេះហៅថា អត្ថិសុខ ។ ម្នាលគហបតី ចុះភោគសុខតើដូចម្ដេច ។ ម្នាលគហបតី កុលបុត្រក្នុងលោកនេះប្រើប្រាស់ នូវភោគៈទាំងឡាយផង ធ្វើបុណ្យទាំងឡាយផង ដោយភោគៈទាំងឡាយ ដែលបានមកដោយព្យាយាម ពោលគឺសេចក្ដីខ្នះខ្នែង ដែលសន្សំបានមក ដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមក ដោយធម៌ កុលបុត្រនោះ រមែងបានសុខ បានសោមនស្សដូច្នេះថា អាត្មាអញប្រើប្រាស់ ភោគៈទាំងឡាយផង ធ្វើបុណ្យទាំងឡាយផង ដោយ ភោគៈទាំងឡាយ ដែលបានមកដោយព្យាយាម ពោលគឺសេចក្ដីខ្នះខ្នែង ដែលសន្សំបានមក ដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ ។ ម្នាលគហបតី នេះហៅថា ភោគសុខ ។ ម្នាល គហបតី ចុះអនណសុខតើដូចម្ដេច ។ ម្នាលគហបតី កុលបុត្រក្នុងលោកនេះ

ន កស្សចិ កិញ្ចិ ធារេតិ[១] អប្បំ វា ពហុំ វា សោ ន កស្សចិ កិញ្ចិ ធារេមិ[២] អប្បំ វា ពហុំ វាតិ អធិគច្ឆតិ សុខំ អធិគច្ឆតិ សោមនស្សំ ។ ឥទំ វុច្ចតិ គហបតិ អនណសុខំ ។ កតមញ្ច គហបតិ អនវជ្ជសុខំ ។ ឥធ គហបតិ អរិយសាវកោ អនវជ្ជេន កាយកម្មេន សមន្នាគតោ ហោតិ អនវជ្ជេន វចីកម្មេន សមន្នាគតោ ហោតិ អនវជ្ជេន មនោកម្មេន សមន្នាគតោ ហោតិ សោ អនវជ្ជេនម្ហិ កាយកម្មេន សមន្នាគតោ អនវជ្ជេន វចីកម្មេន សមន្នាគតោ អនវជ្ជេន មនោកម្មេន សមន្នាគតោតិ អធិគច្ឆតិ សុខំ អធិគច្ឆតិ សោមនស្សំ ។ ឥទំ វុច្ចតិ គហបតិ អនវជ្ជសុខំ ។ ឥមានិ ខោ គហបតិ ចត្តារិ សុខានិ អធិគមនីយានិ គិហិនា កាមភោគិនា កាលេន កាលំ សមយេន សមយំ ឧបាទាយាតិ ។

---

១ ម. វាទេតិ ។ ២ ម. វាទេមិ ។

មិនជំពាក់បំណុលអ្វីមួយ តិចក្តី ច្រើនក្តី របស់បុគ្គលណាមួយ កុលបុត្រនោះ រមែងបានសេចក្តីសុខ បានសោមនស្សដូច្នេះថា អាត្មាអញមិនជំពាក់បំណុលអ្វីមួយ តិចក្តី ច្រើនក្តី របស់បុគ្គលណាមួយទេ ។ ម្នាលគហបតី នេះហៅថា អនណសុខ ។ ម្នាលគហបតី ចុះអនវជ្ជសុខតើដូចម្តេច ។ ម្នាលគហបតី អរិយសាវ័ក ក្នុងសាសនានេះ អ្នកប្រកបដោយកាយកម្ម ឥតមានទោស ប្រកបដោយវចីកម្ម ឥតមានទោស ប្រកបដោយមនោកម្ម ឥតមានទោស អរិយសាវ័កនោះ រមែងបានសុខ បានសោមនស្សដូច្នេះថា អាត្មាអញប្រកបដោយកាយកម្ម ឥតមានទោសទេ ប្រកបដោយវចីកម្ម ឥតមានទោសទេ ប្រកបដោយមនោកម្ម ឥតមានទោសទេ ។ ម្នាលគហបតី នេះហៅថា អនវជ្ជសុខ ។ ម្នាលគហបតី សេចក្តីសុខ ៤ យ៉ាងនេះឯង ដែលគ្រហស្ថអ្នកបរិភោគកាម អាស្រ័យនូវកាលតាមកាល នូវសម័យតាមសម័យហើយគប្បីបានសម្រេចដោយប្រការដូច្នេះ ។

១៧៣



អនណំ សុខំ ញត្វាន(១) អថោ អត្ថិសុខំ សរ(២)
កុញ្ជំ ភោគំ សុខំ មច្ចោ អថោ(៣) បញ្ញា វិបស្សតិ
វិបស្សមានោ ជានាតិ ឧភោ ភាគេ សុមេធសោ
អនវជ្ជសុខស្សេតំ កលំ នាគ្ឃតិ សោឡសិន្តិ ។

[៦៤] សព្រហ្មកានិ ភិក្ខវេ តានិ កុលានិ យេសំ បុត្តានំ មាតាបិតរោ អជ្ឈាគារេ បូជិតា ហោន្តិ សបុព្វាចរិយកានិ ភិក្ខវេ តានិ កុលានិ យេសំ បុត្តានំ មាតាបិតរោ អជ្ឈាគារេ បូជិតា ហោន្តិ សបុព្វទេវានិ(៤) ភិក្ខវេ តានិ កុលានិ យេសំ បុត្តានំ មាតាបិតរោ អជ្ឈាគារេ បូជិតា ហោន្តិ សាហុនេយ្យកានិ ភិក្ខវេ តានិ កុលានិ យេសំ បុត្តានំ មាតាបិតរោ អជ្ឈាគារេ បូជិតា ហោន្តិ ។ ព្រហ្មាតិ ភិក្ខវេ មាតាបិតូនំ ឯតំ អធិវចនំ បុព្វាចរិយាតិ ភិក្ខវេ មាតាបិតូនំ ឯតំ អធិវចនំ បុព្វទេវាតិ ភិក្ខវេ មាតាបិតូនំ ឯតំ អធិវចនំ

១ ឱ. បត្វាន ។ ២ ម. បរេ ។ ៣ ម. តតោ ។ ៤ ម. សបុព្វទេវតានិ ។

បុគ្គលដឹងនូវសុខ ដែលមិនមានបំណុលក្តី រលឹកឃើញ
នូវសុខ ដែលមានភោគៈក្តី ពិចារណាឃើញនូវសុខ
ដែលកំពុងប្រើប្រាស់នូវភោគៈ ដោយប្រាជ្ញាក្តី កាល
ពិចារណាឃើញច្បាស់ រមែងដឹងនូវចំណែកទាំងពីរ
ដោយប្រាជ្ញាដ៏ប្រពៃថា សុខ (ទាំង ៣) នុ៎ះមិនដល់នូវ
ចំណែកមួយក្នុងចំណែកទី ១៦ របស់អនវជ្ជសុខឡើយ ។

[៦៤] ម្នាលភិក្ខុទាំងឡាយ មាតាបិតាទាំងឡាយ ដែលពួកបុត្រណា បូជាហើយក្នុងផ្ទះ ត្រកូលទាំងនោះឈ្មោះថា ប្រកបដោយឋានៈជាព្រហ្ម ម្នាលភិក្ខុទាំងឡាយ មាតាបិតាទាំងឡាយ ដែលពួកបុត្រណាបូជាហើយក្នុងផ្ទះ ត្រកូលទាំងនោះឈ្មោះថា ប្រកបដោយឋានៈជាបុព្វាចារ្យ ម្នាលភិក្ខុទាំងឡាយ មាតាបិតាទាំងឡាយ ដែលពួកបុត្រណាបូជាហើយក្នុងផ្ទះ ត្រកូលទាំងនោះឈ្មោះថា ប្រកបដោយឋានៈជាបុព្វទេព ម្នាលភិក្ខុទាំង-ឡាយ មាតាបិតាទាំងឡាយ ដែលពួកបុត្រណាបូជាហើយក្នុងផ្ទះ ត្រកូលទាំងនោះឈ្មោះថា ប្រកបដោយឋានៈជាអាហុនេយ្យបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រហ្មនុ៎ះ ជាឈ្មោះរបស់មាតាបិតាទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វាចារ្យនុ៎ះ ជាឈ្មោះរបស់មាតាបិតាទាំងឡាយ

អាហុនេយ្យាតិ ភិក្ខវេ មាតាបិតូនំ ឯតំ អធិវចនំ ។ តំ កិស្ស ហេតុ ។ ពហុបការា ភិក្ខវេ មាតាបិតរោ បុត្តានំ អាបាទកា បោសកា ឥមស្ស លោកស្ស ទស្សេតារោតិ ។

ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ
អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកា ។
តស្មា ហិ នេ នមស្សេយ្យ សក្ករេយ្យាថ[១] បណ្ឌិតោ
អន្នេន អថោ បានេន វត្ថេន សយនេន ច
ឧច្ឆាទនេន[២] នហាបនេន បាទានំ ធោវនេន ច
តាយ[៣] បារិចរិយាយ មាតាបិតូសុ បណ្ឌិតា
ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតីតិ ។

១ ម. សក្ករេយ្យ ច ។ ២ ម. ឧច្ឆាទេន ។ ៣ ម. តាយ នំ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វទេពនុ៎ះ ជាឈ្មោះរបស់មាតាបិតាទាំង-ឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អាហុនេយ្យបុគ្គលនុ៎ះ ជាឈ្មោះរបស់មាតាបិតាទាំងឡាយ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា មាតាបិតាទាំងឡាយ មានឧបការៈច្រើន ជាអ្នករក្សា ជាអ្នកចិញ្ចឹម ជាអ្នកបង្ហាញនូវលោកនេះដល់បុត្រទាំងឡាយ ។

មាតាបិតាទាំងឡាយ ជាអ្នកអនុគ្រោះដល់ពួកបុត្រហៅ
ថាជាព្រហ្មផង ហៅថាជាបុព្វាចារ្យផង ជាអាហុនេយ្យ-
បុគ្គលផង របស់បុត្រទាំងឡាយ ។ ព្រោះហេតុដូច្នោះ
បណ្ឌិតគប្បីនមស្ការ ធ្វើសក្ការៈ ចំពោះមាតាបិតាទាំង
នោះដោយបាយ ទឹក សំពត់ ទីដេក ការដុសជម្រះ
ការផ្ងូតទឹក ការលាងជើង និងការបម្រើ ចំពោះមាតាបិតា
ទាំងឡាយនោះ បណ្ឌិតទាំងឡាយ តែងសរសើរ
បុគ្គលនោះក្នុងលោកនេះដោយពិត លុះលះលោកនេះ
ទៅ រមែងរីករាយក្នុងឋានសួគ៌ ។

[៦៥] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បុគ្គលោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ចតូហិ ។ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ បុគ្គលោ យថាភតំ និក្ខិត្តោ ឯវំ និរយេតិ ។

បាណាតិបាតោ អទិន្នាទានំ មុសាវាទោ ច វុច្ចតិ
បរទារគមនញ្ចាបិ នប្បសំសន្តិ បណ្ឌិតាតិ ។

[៦៦] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជ-មានា លោកស្មឹ ។ កតមេ ចត្តារោ ។ រូបប្បមាណោ រូបប្បសន្នោ ឃោសប្បមាណោ ឃោសប្បសន្នោ លូខប្បមាណោ លូខប្បសន្នោ ធម្មប្បមាណោ ធម្មប្បសន្នោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[៦៥] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ធម៌ ៤ ប្រការដូចម្តេចខ្លះ ។ គឺបុគ្គលអ្នកសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ពោលពាក្យកុហក ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ រមែងធ្លាក់ប្រូងទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។

ការសម្លាប់សត្វ ១ ការកាន់យករបស់ដែលគេមិនបាន
ឲ្យ ១ ការពោលមុសា ១ ការប្រព្រឹត្តខុសក្នុងប្រពន្ធ
បុគ្គលដទៃ ១ បណ្ឌិតទាំងឡាយ រមែងមិនសរសើរទេ ។

[៦៦] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួកដូចម្តេចខ្លះ ។ គឺបុគ្គលជ្រះថ្លាក្នុងរូបឈ្មោះថារូបប្បមាណ ១ ជ្រះថ្លាក្នុងសំឡេង ឈ្មោះថាឃោសប្បមាណ ១ ជ្រះថ្លាក្នុងវត្ថុសៅហ្មង ឈ្មោះថាលូខប្បមាណ ១ ជ្រះថ្លាក្នុងធម៌ ឈ្មោះថាធម្មប្បមាណ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

យេ ច រូបេន បាមឹសុ[១] យេ ច ឃោសេន អន្វគូ
ឆន្ទរាគវសូបេតា នាភិជានន្តិ តេ ជនា[២]
អជ្ឈត្តញ្ច ន ជានាតិ ពហិទ្ធា ច ន បស្សតិ
សមន្តាវរណោ ពាលោ ស វេ ឃោសេន វុយ្ហតិ ។
អជ្ឈត្តញ្ច ន ជានាតិ ពហិទ្ធា ច វិបស្សតិ
ពហិទ្ធា ផលទស្សាវី សោបិ ឃោសេន វុយ្ហតិ
អជ្ឈត្តញ្ច បជានាតិ ពហិទ្ធា ច វិបស្សតិ
ឯវំ វិនីវរណទស្សាវី ន ស ឃោសេន វុយ្ហតីតិ ។

[៦៧] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជ-មានា លោកស្មឹ ។ កតមេ ចត្តារោ ។ សរាគោ

១ ម. យេ ច រូបេ បមាណឹសុ ។ ២ តេ ជានន្តិ តញ្ញនន្តិប្បត្តិ ។

ជនទាំងឡាយណារាប់អាន ដោយរូប និយមទៅតាមសំឡេង លុះក្នុងអំណាចនៃឆន្ទរាគ ជនទាំងនោះឈ្មោះថាមិនដឹង (តាមពិត) បុគ្គលពាលអ្នកមានធម៌ជាគ្រឿងរារាំងដោយជុំវិញ រមែងមិនដឹងនូវគុណខាងក្នុង ទាំងមិនឃើញសេចក្ដីប្រតិបត្តិខាងក្រៅ បុគ្គលពាលនោះរមែងអណ្ដែត (ចិត្ត) ទៅតាមសំឡេង ។ មួយទៀតបុគ្គលពាល មិនដឹងនូវគុណខាងក្នុង តែឃើញច្បាស់នូវសេចក្ដីប្រតិបត្តិខាងក្រៅ បុគ្គលពាលនោះ ឈ្មោះថាជាអ្នកឃើញផលខាងក្រៅជាប្រក្រតី រមែងអណ្ដែត (ចិត្ត) ទៅតាមសំឡេង ។ ឯជនដឹងច្បាស់នូវគុណខាងក្នុង ទាំងឃើញច្បាស់ នូវសេចក្ដីប្រតិបត្តិជាខាងក្រៅ ជននោះឈ្មោះថាជាអ្នកឃើញធម៌ ជាគ្រឿងប្រាសចាកនីវរណៈ ជាប្រក្រតី រមែងមិនអណ្ដែត (ចិត្ត) ទៅតាមសំឡេងឡើយ ។

[៦៧] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួកដូចម្ដេចខ្លះ ។ គឺបុគ្គលប្រកបដោយរាគៈ ១

១៧៧



សទោសោ សមោហោ សមានោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

សារត្តា រជនីយេសុ   បិយរូបាភិនន្ទិនោ
មោហេន អធម្មសត្តា(១)   ពទ្ធា វឌ្ឍន្តិ ពន្ធនំ ។
រាគជំ ទោសជញ្ចាបិ   មោហជំ វាបិ អវិទ្ទសុ
ករោន្តិ អកុសលំ កម្មំ(២) សវិឃាតំ   ទុក្ខុទ្រយំ
អវិជ្ជានិវុតា ចោសា   អន្ធភូតា អចក្ខុកា
យថា ធម្មា តថា សន្តា ន តស្សេវន្តិ មញ្ញរេតិ ។

[៦៨] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សាវត្ថិយំ អញ្ញតរោ ភិក្ខុ អហិនា ឌដ្ឋោ កាលកតោ ហោតិ ។ អថខោ សម្ពហុលា ភិក្ខូ

១ ម. អាវុតា សត្តា ។ ២ ម. ករោន្តា កុសលំ ធម្មំ ។

ប្រកបដោយទោសៈ ១ ប្រកបដោយមោហៈ ១ ប្រកបដោយមានះ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

ពួកសត្វ ឥតមានធម៌ ប្រកបដោយសេចក្តីត្រេកអរ ក្នុង
អារម្មណ៍គួរត្រេកត្រអាលរីករាយ ក្នុងរូបជាទីស្រឡាញ់
ជាប់ដោយមោហៈ ញ៉ាំងចំណង (នៃមារ) ឲ្យចម្រើន ។
ពួកសត្វអ្នកមិនដឹងនូវហេតុដែលកើតអំពីរាគៈ កើតអំពី
ទោសៈ កើតអំពីមោហៈ រមែងធ្វើអកុសលកម្ម ប្រកប
ដោយទុក្ខ មានទុក្ខជាកម្រៃ ពួកសត្វត្រូវអវិជ្ជារួបរឹត
ដូចជាខ្វាក់ឥតចក្ខុគឺបញ្ញា ទើបមិនសម្គាល់នូវអកុសល-
កម្មនោះថា យើងទាំងឡាយ នឹងមានសភាព ប្រព្រឹត្ត
ទៅតាមធម៌ទាំងឡាយយ៉ាងនេះ មិនខាន ។

[៦៨] សម័យមួយ ព្រះដ៏មានព្រះភាគស្តេចគង់នៅ ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ក្រុងសាវត្ថីមានភិក្ខុមួយរូប ត្រូវពស់ចឹកធ្វើមរណកាលទៅ ។ លំដាប់នោះ ភិក្ខុជាច្រើន

យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ សាវត្ថិយំ អញ្ញតរោ ភិក្ខុ អហិនា ទដ្ឋោ កាលកតោតិ ។ នហនូន[១] សោ ភិក្ខវេ ភិក្ខុ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរិ សចេ ហិ សោ ភិក្ខវេ ភិក្ខុ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរេយ្យ ន ហិ សោ ភិក្ខវេ ភិក្ខុ អហិនា ទដ្ឋោ កាលំ ករេយ្យ ។ កតមានិ ចត្តារិ[២] ។ វិរូបក្ខំ អហិរាជកុលំ ឯរាបថំ អហិរាជកុលំ ឆព្យាបុត្តំ អហិរាជកុលំ កណ្ហាគោតមកំ អហិរាជកុលំ ។ នហនូន សោ ភិក្ខវេ ភិក្ខុ ឥមានិ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរិ សចេ ហិ សោ ភិក្ខវេ ភិក្ខុ ឥមានិ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរេយ្យ ន ហិ សោ ភិក្ខវេ ភិក្ខុ អហិនា ទដ្ឋោ កាលំ ករេយ្យ ។ អនុជានាមិ ភិក្ខវេ ឥមានិ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរិតុំ អត្តគុត្តិយា អត្តរក្ខាយ អត្តបរិត្តាយាតិ ។

---

១ ម. នហិនូន ។ ២ ឱ. កតមានិ ចត្តារិ អហិរាជកុលានិ ។

ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងក្រុងសាវត្ថីនេះ មានភិក្ខុមួយរូបត្រូវពស់ចឹកធ្វើមរណកាលទៅ ។ ម្នាលភិក្ខុទាំងឡាយ ពិតដូច្នោះមែន ព្រោះថា ភិក្ខុនោះ មិនផ្សាយចិត្តមេត្តាចំពោះត្រកូលស្តេចពស់ទាំង ៤ ពួក ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុនោះ ផ្សាយចិត្តមេត្តាចំពោះ ត្រកូលស្តេចពស់ទាំង ៤ ពួក ម្នាលភិក្ខុទាំងឡាយ ពស់មិនគប្បីចឹកភិក្ខុនោះឲ្យស្លាប់ទៅទេ ។ ត្រកូលស្តេចពស់ ៤ ពួកដូចម្តេចខ្លះ ។ គឺត្រកូលស្តេចពស់ឈ្មោះវិរូបក្ខៈ ១ ត្រកូលស្តេចពស់ឈ្មោះឯរាបថៈ ១ ត្រកូលស្តេចពស់ឈ្មោះឆព្យាបុត្តៈ ១ ត្រកូលស្តេចពស់ឈ្មោះកណ្ហាគោតមកៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ពិតដូច្នោះមែន ព្រោះថា ភិក្ខុនោះមិនផ្សាយចិត្តមេត្តាចំពោះត្រកូលស្តេចពស់ទាំង ៤ ពួកនេះ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុនោះ ផ្សាយចិត្តមេត្តាចំពោះត្រកូលស្តេចពស់ទាំង ៤ ពួកនេះ ម្នាលភិក្ខុទាំងឡាយ ពស់មិនហ៊ានចឹកភិក្ខុនោះឲ្យស្លាប់ទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យផ្សាយចិត្តមេត្តាចំពោះត្រកូលស្តេចពស់ទាំង ៤ ពួកនេះ ដើម្បីគ្រប់គ្រងខ្លួន រក្សាខ្លួន ការពារខ្លួន ។

១៧៩



វិរូបក្ខេហិ មេ មេត្តំ មេត្តំ ឯរាបថេហិ មេ

ឆព្យាបុត្តេហិ មេ មេត្តំ មេត្តំ កណ្ហាគោតមកេហិ ច

អចាទកេហិ មេ មេត្តំ មេត្តំ ទិចាទកេហិ មេ

ចតុប្បទេហិ មេ មេត្តំ មេត្តំ ពហុប្បទេហិ មេ ។

មា មំ អចាទកោ ហឹសិ មា មំ ហឹសិ ទិចាទកោ

មា មំ ចតុប្បទោ ហឹសិ មា មំ ហឹសិ ពហុប្បទោ ។

ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមាន) ជាមួយនឹងត្រកូលស្តេចពស់ឈ្មោះវិរូបក្ខៈទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមាន) ជាមួយនឹងត្រកូលស្តេចពស់ឈ្មោះឯរាបថៈទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមាន) ជាមួយនឹងត្រកូលស្តេចពស់ឈ្មោះឆព្យាបុត្តៈទាំងឡាយផង ភាវៈជាមិត្ររបស់អញ (ចូរមាន) ជាមួយនឹងត្រកូលស្តេចពស់ ឈ្មោះកណ្ហាគោតមកៈទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមាន) ជាមួយនឹងសត្វឥតជើងទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមាន) ជាមួយនឹងសត្វមានជើងពីរទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមាន) ជាមួយនឹងសត្វជើង ៤ ទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមាន) ជាមួយនឹងសត្វមានជើងច្រើនទាំងឡាយផង ។ សត្វឥតជើងកុំបៀតបៀនអាត្មាអញ សត្វជើងពីរ កុំបៀតបៀនអាត្មាអញ សត្វជើង ៤ កុំបៀតបៀនអាត្មាអញ សត្វជើងច្រើន កុំបៀតបៀនអាត្មាអញឡើយ ។

សព្វេ សត្តា សព្វេ បាណា សព្វេ ភូតា ច កេវលា
សព្វេ ភទ្រានិ បស្សន្តុ មា កិញ្ចិ បាបមាគមា ។
អប្បមាណោ ពុទ្ធោ អប្បមាណោ ធម្មោ អប្បមាណោ សង្ឃោ បមាណវន្តានិ សិរឹសបានិ អហិ វិច្ឆិកា សតបទី ឧណ្ណានាភី សរពូ មូសិកា ។ កតា មេ រក្ខា កតា មេ បរិត្តា បដិក្កមន្តុ ភូតានិ សោហំ នមោ ភគវតោ នមោ សត្តន្នំ សម្មាសម្ពុទ្ធានន្តិ ។

[៦៩] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ អចិរបក្កន្តេ ទេវទត្តេ ។ តត្រ ខោ ភគវា ទេវទត្តំ អារព្ភ ភិក្ខូ អាមន្តេសិ អត្តវធាយ ភិក្ខវេ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ បរាភវាយ ភិក្ខវេ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ ។

សព្វសត្វ ទាំងឡាយផង សព្វប្រាណ ទាំងឡាយផង
សព្វភូត ទាំងឡាយផង ទាំងអស់គ្នា សត្វទាំង
អស់ (នោះ) ចូរប្រទះ នូវសេចក្តីចម្រើនទាំងឡាយ
សេចក្តីអាក្រក់ បន្តិចបន្តួច កុំមកឡើយ ។

ព្រះពុទ្ធមានគុណប្រមាណមិនបាន ព្រះធម៌មានគុណប្រមាណមិនបាន ព្រះសង្ឃមានគុណប្រមាណមិនបាន សត្វលូនឬសត្វវារទាំងឡាយគឺពស់ ខ្ជួយ ក្អែប ពីងពាង តុកកែ កណ្តុរ សុទ្ធតែមានប្រមាណ (រាប់បាន) គឺថា មិនច្រើនដូចគុណព្រះរត្នត្រ័យទេ ។ កិរិយារក្សា ខ្ញុំបានធ្វើហើយ កិរិយាការពារ ខ្ញុំបានធ្វើហើយ ពួកសត្វចូរចៀសទៅ ខ្ញុំសូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ សូមនមស្ការព្រះសម្មាសម្ពុទ្ធទាំង ៧ ព្រះអង្គ ។

[៦៩] សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ កាលទេវទត្តភិក្ខុ ចេញទៅមិនយូរប៉ុន្មាន ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគប្រារព្ធទេវទត្តភិក្ខុ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ។

សេយ្យថាបិ ភិក្ខវេ កទលី អត្តវធាយ ផលំ ទេតិ បរាភវាយ ផលំ ទេតិ ឯវមេវ ខោ ភិក្ខវេ អត្តវធាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ ។ សេយ្យថាបិ ភិក្ខវេ វេឡុ អត្តវធាយ ផលំ ទេតិ បរាភវាយ ផលំ ទេតិ ឯវមេវ ខោ ភិក្ខវេ អត្តវធាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ ។ សេយ្យថាបិ ភិក្ខវេ នឡោ អត្តវធាយ ផលំ ទេតិ បរាភវាយ ផលំ ទេតិ ឯវមេវ ខោ ភិក្ខវេ អត្តវធាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ ។ សេយ្យថាបិ ភិក្ខវេ អស្សតរី អត្តវធាយ គព្ភំ គណ្ហាតិ

ម្នាលភិក្ខុទាំងឡាយ ដូចជាដើមចេកតែបញ្ចេញផ្លែមក ដើម្បីសម្លាប់ដើម តែបញ្ចេញផ្លែមក ដើម្បីសេចក្តីវិនាសយ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ក៏ដូចគ្នាដែរ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឫស្សី បញ្ចេញផ្លែមក ដើម្បីសម្លាប់ដើម បញ្ចេញផ្លែមក ដើម្បីសេចក្តីវិនាសយ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ក៏ដូចគ្នាដែរ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាដើមបបុស បញ្ចេញផ្លែមក ដើម្បីសម្លាប់ដើម បញ្ចេញផ្លែមក ដើម្បីសេចក្តីវិនាសយ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសេចក្តីវិនាសក៏ដូចគ្នាដែរ ។ ម្នាលភិក្ខុទាំង-ឡាយ ដូចជាមេសេះអស្សតរ តែចាប់មានផ្ទៃឡើង ដើម្បីសម្លាប់ខ្លួន

បរាភវាយ គព្ភំ គណ្ហាតិ ឯវមេវ ខោ ភិក្ខវេ អត្តវធាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភសក្ការ-សិលោកោ ឧទបាទីតិ ។

ផលំ វេ កទលឹ ហន្តិ ផលំ វេឡុំ ផលំ នឡំ
សក្ការោ កាបុរិសំ ហន្តិ គព្ភោ អស្សតរឹ យថាតិ ។

[៧០] ចត្តារីមានិ ភិក្ខវេ បធានានិ ។ កតមានិ ចត្តារិ ។ សំវរប្បធានំ បហានប្បធានំ ភាវនាប្បធានំ អនុរក្ខនាប្បធានំ ។ កតមញ្ច ភិក្ខវេ សំវរប្បធានំ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥទំ វុច្ចតិ ភិក្ខវេ សំវរប្បធានំ ។ កតមញ្ច ភិក្ខវេ បហានប្បធានំ ។ ឥធ ភិក្ខវេ ភិក្ខុ

តែចាប់មានផ្លែឡើង ដើម្បីសេចក្តីវិនាសយ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ក៏ដូចគ្នាដែរ ។

ផ្លែចេក រមែងសម្លាប់ដើមចេក ផ្លែឫស្សី រមែងសម្លាប់ដើមឫស្សី ផ្លែបបុស រមែងសម្លាប់ដើមបបុស សក្ការៈ រមែងសម្លាប់ បុរសអាក្រក់ ដូចជាគភ៌ រមែងសម្លាប់មេសេះអស្សតរ ។

[៧០] ម្នាលភិក្ខុទាំងឡាយ បធាន (សេចក្តីព្យាយាម) នេះ មាន ៤ យ៉ាង ។ បធាន ៤ យ៉ាងដូចម្តេចខ្លះ ។ គឺ សំវរប្បធាន ១ បហានប្បធាន ១ ភាវនាបធាន ១ អនុរក្ខនាបធាន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសំវរប្បធាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បណ្តុះឆន្ទៈ ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីញុំាងអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សំវរប្បធាន ។ ម្នាលភិក្ខុទាំងឡាយ ចុះបហានប្បធាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥទំ វុច្ចតិ ភិក្ខវេ បហានប្បធានំ ។ កតមញ្ច ភិក្ខវេ ភាវនាបធានំ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ភាវនាបធានំ ។ កតមញ្ច ភិក្ខវេ អនុរក្ខនាបធានំ ។ ឥធ ភិក្ខវេ ភិក្ខុ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥទំ វុច្ចតិ ភិក្ខវេ អនុរក្ខនាបធានំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ បធានានីតិ ។

បណ្តុះឆន្ទៈ ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីលះបង់អកុសលធម៌ ដ៏លាមកទាំងឡាយ ដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បហានប្បធាន ។ ម្នាលភិក្ខុទាំងឡាយ ចុះភាវនាបធាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បណ្តុះឆន្ទៈ ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីញ៉ាំងកុសលធម៌ទាំងឡាយ ដែលមិនទាន់កើតឡើងឲ្យកើតឡើង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាវនាបធាន ។ ម្នាលភិក្ខុទាំងឡាយ អនុរក្ខនាបធាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បណ្តុះឆន្ទៈ ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីញ៉ាំងកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ ដើម្បីឲ្យឋិតនៅ មិនឲ្យភ្លេចភ្លាំងទៅ ឲ្យចម្រើនពេញលេញ ធំទូលាយ ក្រៃលែងឡើង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនុរក្ខនាបធាន ។ ម្នាលភិក្ខុទាំងឡាយ បធានមាន ៤ យ៉ាងនេះឯង ។

សំវរោ ច បហានញ្ច ភាវនា អនុរក្ខនា
ឯតេ បធានា ចត្តារោ ទេសិតាទិច្ចពន្ធុនា
យេហិ ភិក្ខុ ឥធាតាបី ខយំ ទុក្ខស្ស បាបុណេតិ ។

[៧១] យស្មឹ ភិក្ខវេ សមយេ រាជានោ អធម្មិកា ហោន្តិ រាជយុត្តាបិ[១] តស្មឹ សមយេ អធម្មិកា ហោន្តិ រាជយុត្តេសុ ភិក្ខវេ អធម្មិកេសុ ព្រាហ្មណ-គហបតិកាបិ តស្មឹ សមយេ អធម្មិកា ហោន្តិ ព្រាហ្មណគហបតិកេសុ អធម្មិកេសុ នេគមជានបទាបិ តស្មឹ សមយេ អធម្មិកា ហោន្តិ នេគមជានបទេសុ អធម្មិកេសុ វិសមំ ចន្ទិមសុរិយា បរិវត្តន្តិ វិសមំ ចន្ទិម-សុរិយេសុ បរិវត្តន្តេសុ វិសមំ នក្ខត្តានិ តារករូបានិ បរិវត្តន្តិ វិសមំ នក្ខត្តេសុ តារករូបេសុ បរិវត្តន្តេសុ វិសមំ រត្តិន្ទិវា បរិវត្តន្តិ វិសមំ រត្តិន្ទិវេសុ បរិវត្តន្តេសុ

១ ឱ. រាជបុត្តាបិ ។

សំវរប្បធាន ១ បហានប្បធាន ១ ភាវនាបធាន ១ អនុរក្ខនាបធាន ១ បធានទាំង ៤ នុ៎ះ ព្រះពុទ្ធជាផៅពង្សនៃព្រះអាទិត្យ ទ្រង់សម្តែងហើយ ជាហេតុឲ្យភិក្ខុក្នុងសាសនានេះ ជាអ្នកមានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស គប្បីដល់នូវការអស់ទៅនៃទុក្ខបាន ។

[៧១] ម្នាលភិក្ខុទាំងឡាយ សម័យណា ពួកព្រះរាជាមិនប្រកបដោយធម៌ សម័យនោះ ពួកខ្ញុំរាជការ ក៏មិនប្រកបដោយធម៌ដែរ ម្នាលភិក្ខុទាំងឡាយ កាលពួកអ្នករាជការ មិនប្រកបដោយធម៌ សម័យនោះ ពួកព្រាហ្មណ៍និងគហបតី ក៏មិនប្រកបដោយធម៌ដែរ កាលពួកព្រាហ្មណ៍និងគហបតី មិនប្រកបដោយធម៌ហើយ សម័យនោះ ពួកអ្នកនិគមនិងអ្នកជនបទ ក៏មិនប្រកបដោយធម៌ដែរ កាលអ្នកនិគមនឹងអ្នកជនបទ មិនប្រកបដោយធម៌ ព្រះចន្ទ្រនិងព្រះអាទិត្យ ក៏គោចរទៅមិនស្មើដែរ កាលព្រះចន្ទ្រនិងព្រះអាទិត្យ គោចរទៅមិនស្មើ ពួកផ្កាយនក្ខត្តឫក្សក៏គោចរទៅមិនស្មើដែរ កាលពួកផ្កាយនក្ខត្តឫក្ស គោចរទៅមិនស្មើ យប់និងថ្ងៃ ក៏ប្រព្រឹត្តទៅមិនស្មើដែរ កាលយប់និងថ្ងៃប្រព្រឹត្តទៅមិនស្មើ

វិសមំ មាសឌ្ឍមាសា បរិវត្តន្តិ វិសមំ មាសឌ្ឍមាសេសុ បរិវត្តន្តេសុ វិសមំ ឧតុសំវច្ឆរា បរិវត្តន្តិ វិសមំ ឧតុសំវច្ឆរេសុ បរិវត្តន្តេសុ វិសមំ វាតា វាយន្តិ វិសមំ វាតេសុ វាយន្តេសុ វិសមា អបញ្ជសា បរិវត្តន្តិ វិសមេសុ អបញ្ជសេសុ បរិវត្តន្តេសុ ទេវតា បរិកុបិតា ភវន្តិ ទេវ-តាសុ បរិកុបិតាសុ ទេវោ ន សម្មា ធារំ អនុប្បវេច្ឆតិ ទេវេ ន សម្មា ធារំ អនុប្បវេច្ឆន្តេ វិសមបាកីនិ សស្សានិ ភវន្តិ វិសមបាកីនិ ភិក្ខវេ សស្សានិ មនុស្សា បរិភុញ្ជន្តា អប្បាយុកា ច ហោន្តិ ទុព្វណ្ណា ច ទុព្វលា ច ពហ្វាពាធា ច ។ យស្មឹ ភិក្ខវេ សមយេ រាជានោ ធម្មិកា ហោន្តិ រាជយុត្តាបិ តស្មឹ សមយេ ធម្មិកា ហោន្តិ រាជយុត្តេសុ ធម្មិកេសុ ព្រាហ្មណគហបតិកាបិ តស្មឹ សមយេ ធម្មិកា ហោន្តិ ព្រាហ្មណគហបតិកេសុ ធម្មិកេសុ នេគមជានបទាបិ តស្មឹ សមយេ ធម្មិកា

ខែនឹងកន្លះខែ ក៏ប្រព្រឹត្តទៅមិនស្មើដែរ កាលខែនិងកន្លះខែប្រព្រឹត្តទៅមិនស្មើ រដូវនិងឆ្នាំក៏ប្រព្រឹត្តទៅមិនស្មើដែរ កាលរដូវនិងឆ្នាំប្រព្រឹត្តទៅមិនស្មើ ខ្យល់ក៏បក់មិនស្មើដែរ កាលខ្យល់បក់មិនស្មើ ខ្យល់បក់ខុសផ្លូវទាំងឡាយ ក៏ប្រព្រឹត្តទៅមិនស្មើដែរ កាលខ្យល់បក់ខុសផ្លូវទាំងឡាយប្រព្រឹត្តទៅមិនស្មើ ទេវតាទាំងឡាយខឹងសម្បា កាលទេវតាទាំងឡាយខឹងសម្បា ភ្លៀងក៏មិនបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ កាលភ្លៀងមិនបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ ស្រូវទាំងឡាយក៏ឲ្យផលមិនស្មើល្អ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្ស កាលបរិភោគស្រូវឲ្យផលមិនស្មើ រមែងមានអាយុខ្លី មានសម្បុរអាក្រក់ មានកម្លាំងតិច មានអាពាធច្រើន ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ពួកព្រះរាជាប្រកបដោយធម៌ សម័យនោះ ពួកខ្ញុំរាជការ ក៏ប្រកបដោយធម៌ដែរ កាលបើពួកខ្ញុំរាជការប្រកបដោយធម៌ ក្នុងសម័យនោះ ពួកព្រាហ្មណ៍និងគហបតីក៏ប្រកបដោយធម៌ដែរ កាលពួកព្រាហ្មណ៍និងគហបតី ប្រកបដោយធម៌ ក្នុងសម័យនោះ ពួកអ្នកនិគមនិងអ្នកជនបទ ក៏ប្រកបដោយធម៌ដែរ

ហោន្តិ នេគមជានបទេសុ ធម្មិកេសុ សមំ ចន្ទិមសុរិយា បរិវត្តន្តិ សមំ ចន្ទិមសុរិយេសុ បរិវត្តន្តេសុ សមំ នក្ខត្តានិ តារករូបានិ បរិវត្តន្តិ សមំ នក្ខត្តេសុ តារករូបេសុ បរិវត្តន្តេសុ សមំ រត្តិន្ទិវា បរិវត្តន្តិ សមំ រត្តិន្ទិវេសុ បរិវត្តន្តេសុ សមំ មាសឌ្ឍមាសា បរិវត្តន្តិ សមំ មាសឌ្ឍមាសេសុ បរិវត្តន្តេសុ សមំ ឧតុសំវច្ឆរា បរិវត្តន្តិ សមំ ឧតុសំវច្ឆរេសុ បរិវត្តន្តេសុ សមំ វាតា វាយន្តិ សមំ វាតេសុ វាយន្តេសុ សមា បញ្ចសា បរិវត្តន្តិ សមេសុ បញ្ចសេសុ បរិវត្តន្តេសុ ទេវតា អបរិកុបិតា ភវន្តិ ទេវតាសុ អបរិកុបិតាសុ ទេវោ សម្មា ធារំ អនុប្បវេច្ឆតិ ទេវេ សម្មា ធារំ អនុប្បវេច្ឆន្តេ សមបាកីនិ សស្សានិ ភវន្តិ សមបាកីនិ ភិក្ខវេ សស្សានិ មនុស្សា បរិភុញ្ជន្តា ទីឃាយុកា ច ហោន្តិ វណ្ណវន្តោ ច ពលវន្តោ ច អប្បាពាធា ចាតិ ។

កាលបើពួកអ្នកនិគមនិងអ្នកជនបទ ប្រកបដោយធម៌ ព្រះចន្ទ្រនិងព្រះអាទិត្យ ក៏គោចរទៅស្មើដែរ កាលព្រះចន្ទ្រនិងព្រះអាទិត្យគោចរទៅស្មើ ពួកផ្កាយនក្ខត្តឫក្សក៏គោចរទៅស្មើដែរ កាលពួកផ្កាយនក្ខត្តឫក្សគោចរទៅស្មើយប់និងថ្ងៃ ក៏ប្រព្រឹត្តទៅស្មើដែរ កាលយប់នឹងថ្ងៃប្រព្រឹត្តទៅស្មើ ខែនឹងកន្លះខែ ក៏ប្រព្រឹត្តទៅស្មើដែរ កាលខែនិងកន្លះខែប្រព្រឹត្តទៅស្មើ រដូវនិងឆ្នាំក៏ប្រព្រឹត្តទៅស្មើដែរ កាលរដូវនិងឆ្នាំប្រព្រឹត្តទៅស្មើ ខ្យល់ក៏បក់ស្មើដែរ កាលខ្យល់បក់ទៅស្មើ ផ្លូវខ្យល់ទាំងឡាយ ក៏ប្រព្រឹត្តទៅបានស្មើ កាលបើផ្លូវខ្យល់ទាំងឡាយស្មើ ពួកទេវតាក៏មិនខឹងសម្បា កាលពួកទេវតាមិនខឹងសម្បា ភ្លៀងក៏បង្អុរទឹកភ្លៀងចុះមកដោយប្រពៃ កាលភ្លៀងបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ ស្រូវក៏ឲ្យផលស្មើល្អ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងឡាយ កាលបរិភោគស្រូវ ដែលមានផលស្មើល្អ រមែងមានអាយុវែង មានសម្បុរល្អ មានកម្លាំង ព្រមទាំងមានអាពាធតិច ។

១៨៧

ទុតិយបណ្ណាសកេ   បត្តកម្មវគ្គោ

គុន្នញ្ចេ   តរមានានំ   ជិម្ហំ   គច្ឆតិ   បុង្គវោ
សព្វា   តា   ជិម្ហំ   គច្ឆន្តិ   នេត្តេ   ជិម្ហំ   គតេ   សតិ
ឯវមេវ   មនុស្សេសុ   យោ ហោតិ   សេដ្ឋសម្មតោ
សោ   ចេ   អធម្មំ   ចរតិ   បគេវ   ឥតរា   បជា
សព្វំ   រដ្ឋំ   ទុក្ខំ   សេតិ   រាជា ចេ ហោត្យធម្មិកោ[1] ។
គុន្នញ្ចេ   តរមានានំ   ឧជុំ   គច្ឆតិ   បុង្គវោ
សព្វា   តា   ឧជុំ   គច្ឆន្តិ   នេត្តេ   ឧជុំ   គតេ   សតិ
ឯវមេវ   មនុស្សេសុ   យោ ហោតិ សេដ្ឋសម្មតោ
សោ   ចេ   ធម្មំ   ចរតិ[2]   បគេវ   ឥតរា   បជា
សព្វំ   រដ្ឋំ   សុខំ   សេតិ   រាជា ចេ ហោតិ ធម្មិកោតិ ។

បត្តកម្មវគ្គោ   ទុតិយោ   ។

១ ឱ. ម. ហោតិ   អធម្មិកោ ។ ២ ឱ. សោ   ចេវ   ធម្មំ   ចរតិ ។ ម. សោ   សចេ   ធម្មំ   ចរតិ ។

បើគោទាំងឡាយ កំពុងឆ្លងទៅ គោមេហ្វូងនាំទៅកាន់ផ្លូវខុសកំពង់ កាលបើគោមេហ្វូង នាំទៅកាន់ផ្លូវខុសកំពង់ ពួកគោទាំងអស់នោះ ក៏នាំគ្នាទៅកាន់ផ្លូវខុសកំពង់ដែរ មានឧបមាយ៉ាងណា ក្នុងពួកមនុស្សក៏ដូច្នោះដែរ អ្នកណាដែលគេសន្មតថា ប្រសើរជាងគេ បើអ្នកនោះ ប្រព្រឹត្តមិនត្រូវតាមធម៌ នឹងបាច់និយាយទៅថ្វី ដល់ប្រជាជនដទៃឡើយ បើព្រះរាជាមិនប្រកបដោយធម៌ រាស្ត្រទាំងអស់ រមែងដេកកើតទុក្ខ ។ កាលបើគោទាំងឡាយ កំពុងឆ្លងទៅ គោមេហ្វូង នាំទៅកាន់ផ្លូវត្រង់ កាលបើគោមេហ្វូងនាំទៅកាន់ផ្លូវត្រង់ គោទាំងអស់នោះ រមែងទៅកាន់ផ្លូវត្រង់ដែរ មានឧបមាយ៉ាងណា ក្នុងពួកមនុស្សក៏ដូច្នោះដែរ អ្នកណាដែលគេសន្មតថា ប្រសើរជាងគេ បើអ្នកនោះ ប្រព្រឹត្តតាមធម៌ នឹងបាច់និយាយទៅថ្វី ដល់ប្រជាជនដទៃ បើព្រះរាជាប្រកបដោយធម៌ រាស្ត្រទាំងអស់ រមែងដេកនៅជាសុខ ។

ចប់ បត្តកម្មវគ្គ ទី ២ ។

# តស្សុទ្ទានំ

បត្តកម្មំ អនណោ[1]
សព្រហ្មនិរយា[2] រូបេន បញ្ចមំ
សរាគអហិណា[3] ទេវទត្តោ
បធានំ ធម្មិកេន[4] ចាតិ ។

១ ឱ. អន្នណកោ ។ ម. អនណ្យតោ ។ ២ ឱ. សព្រហ្មចារី ។ ម. សព្រហ្មចរិយា ។ ៣ ឱ. សរាគអហិន្ទ ។ ម. សរាគអហិរាជា ។ ៤ ឱ. ម. បធានំ អធម្មិកេន ចាតិ ។

# ឧទ្ទាននៃបត្តកម្មវគ្គនោះគឺ

*និយាយអំពីកម្មដ៏គួរ ១ អំពីសេចក្តីសុខមានការមិនជំពាក់បំណុលជាដើម ១ អំពីត្រកូលប្រកបដោយឋានៈជាព្រហ្មជាដើម ១ អំពីបុគ្គលធ្លាក់ទៅក្នុងនរក ១ អំពីរូបប្បមាណបុគ្គលជាដើមជាគម្រប់ប្រាំ ១ អំពីបុគ្គលប្រកបដោយរាគៈជាដើម ១ អំពីពស់ចឹកភិក្ខុ ១ អំពីទេវទត្ត ១ អំពីបធានបួន ១ អំពីអធម្មិករាជ ១ ។*

# អបណ្ណកវគ្គោ

[៧២] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អបណ្ណកប្បដិបទំ[១] បដិបន្នោ ហោតិ យោនិ ចស្ស អារទ្ធា ហោតិ អាសវានំ ខយាយ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ពហុស្សុតោ ហោតិ អារទ្ធវីរិយោ ហោតិ បញ្ញវា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អបណ្ណកប្បដិបទំ បដិបន្នោ ហោតិ យោនិ ចស្ស អារទ្ធា ហោតិ អាសវានំ ខយាយាតិ ។

[៧៣] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អបណ្ណកប្បដិបទំ បដិបន្នោ ហោតិ យោនិ ចស្ស អារទ្ធា ហោតិ អាសវានំ ខយាយ ។ កតមេហិ ចតូហិ ។ នេក្ខម្មវិតក្កេន អព្យាបាទ-វិតក្កេន អវិហឹសាវិតក្កេន សម្មាទិដ្ឋិយា ។

១ ឱ. អបណ្ណកតំ បដិបទំ ។

# អបណ្ណកវគ្គ

[៧២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការឈ្មោះថាជាអ្នកប្រតិបត្តិចំពោះអបណ្ណកប្បដិបទា គឺប្រតិបត្តិមិនខុសផង ភិក្ខុនោះឈ្មោះថាជាអ្នកប្រារព្ធហេតុ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។ ធម៌ ៤ ប្រការដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ១ ជាអ្នកចេះដឹងច្រើន ១ ជាអ្នកមានព្យាយាមប្រារព្ធ ១ ជាអ្នកមានប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការនេះ ឈ្មោះថា ប្រតិបត្តិអបណ្ណកប្បដិបទាផង ភិក្ខុនោះឈ្មោះថាជាអ្នកប្រារព្ធហេតុ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។

[៧៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថា ប្រតិបត្តិ នូវអបណ្ណកប្បដិបទាផង ភិក្ខុនោះឈ្មោះថាជាអ្នកប្រារព្ធហេតុ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។ ធម៌ ៤ ប្រការដូចម្តេចខ្លះ ។ គឺសេចក្តីត្រិះរិះ ក្នុងការចេញចាកកាម ១ សេចក្តីត្រិះរិះ ក្នុងការមិនព្យាបាទ ១ សេចក្តីត្រិះរិះ ក្នុងការមិនបៀតបៀន ១ សេចក្តីឃើញត្រូវ ១ ។

ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អបណ្ណកប្បដិបទំ បដិបន្នោ ហោតិ យោនិ ចស្ស អារទ្ធា ហោតិ អាសវានំ ខយាយាតិ ។

[៧៤] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អសប្បុរិសោតិ វេទិតព្វោ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ អសប្បុរិសោ យោ ហោតិ បរស្ស អវណ្ណោ តំ អបុដ្ឋោបិ ធាតុករោតិ ។ កោ បន វាទោ បុដ្ឋស្ស ។ បុដ្ឋោ ខោ បន បញ្ហាភិនីតោ អហាបេត្វា អលម្ពេត្វា បរិបូរំ វិត្ថារេន បរស្ស អវណ្ណំ ភាសិតា ហោតិ ។ វេទិតព្វមេតំ ភិក្ខវេ អសប្បុរិសោ អយំ ភវន្តិ ។ បុន ចបរំ ភិក្ខវេ អសប្បុរិសោ យោ ហោតិ បរស្ស វណ្ណោ តំ បុដ្ឋោបិ ន ធាតុករោតិ ។ កោ បន វាទោ អបុដ្ឋស្ស ។ បុដ្ឋោ ខោ បន បញ្ហាភិនីតោ ហាបេត្វា លម្ពេត្វា អបរិបូរំ អវិត្ថារេន បរស្ស វណ្ណំ ភាសិតា ហោតិ ។ វេទិតព្វមេតំ ភិក្ខវេ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការនេះ ឈ្មោះថាជាអ្នកប្រតិបត្តិនូវអបណ្ណកប្បដិបទាផង ភិក្ខុនោះឈ្មោះថា ជាអ្នកប្រារព្ធហេតុដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។

[៧៤] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ អ្នកប្រាជ្ញគប្បីដឹងថាជាអសប្បុរស ។ ធម៌ ៤ ប្រការដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ រឿងណាជាទោសរបស់បុគ្គលដទៃ អសប្បុរសក្នុងលោកនេះ ទុកជាគេមិនសួរក៏ប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វីដល់រឿងដែលគេសួរ ។ តែថា អសប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលទោសរបស់បុគ្គលដទៃ ដោយពិស្តារពេញទី មិនចេះអស់មិនចេះហើយទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹង ដំណើរនុ៎ះថា អ្នកនេះជាអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត រឿងណាជាគុណរបស់បុគ្គលដទៃ អសប្បុរសទុកជាមានគេសាកសួរ ក៏មិនប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វីដល់រឿងដែលគេមិនសួរ ។ តែថា អសប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលគុណរបស់បុគ្គលដទៃ ដោយសេចក្តីមិនពិស្តារ មិនពេញលេញឲ្យធាប់អស់ឲ្យធាប់ហើយទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងដំណើរនុ៎ះថា

១៩១



អសប្បុរិសោ អយំ ភវន្តិ ។ បុន ចបរំ ភិក្ខវេ អសប្បុរិសោ យោ ហោតិ អត្តនោ អវណ្ណោ តំ បុដ្ឋោបិ ន ចាតុករោតិ ។ កោ បន វាទោ អបុដ្ឋស្ស ។ បុដ្ឋោ ខោ បន បញ្ហាភិនីតោ ហាបេត្វា លម្ពេត្វា អបរិបូរំ អវិត្ថារេន អត្តនោ អវណ្ណំ ភាសិតា ហោតិ ។ វេទិតព្វមេតំ ភិក្ខវេ អសប្បុរិសោ អយំ ភវន្តិ ។ បុន ចបរំ ភិក្ខវេ អសប្បុរិសោ យោ ហោតិ អត្តនោ វណ្ណោ តំ អបុដ្ឋោបិ ចាតុករោតិ ។ កោ បន វាទោ បុដ្ឋស្ស ។ បុដ្ឋោ ខោ បន បញ្ហាភិនីតោ អហាបេត្វា អលម្ពេត្វា អបរិបូរំ វិត្ថារេន អត្តនោ វណ្ណំ ភាសិតា ហោតិ ។ វេទិតព្វមេតំ ភិក្ខវេ អសប្បុរិសោ អយំ ភវន្តិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ អសប្បុរិសោតិ វេទិតព្វោ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សប្បុរិសោតិ វេទិតព្វោ ។ កតមេហិ ចតូហិ ។

អ្នកនេះជាអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត រឿងណាជាទោសរបស់ខ្លួន អសប្បុរសទុកជាមានគេសួរ ក៏មិនប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វី ដល់រឿងដែលគេមិនសួរ ។ តែថា អសប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលទោសរបស់ខ្លួន មិនដោយសេចក្តីពិស្តារ មិនពេញលេញ ឲ្យដាច់អស់ឲ្យដាច់ហើយទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងដំណើរនុ៎ះថា អ្នកនេះជាអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត រឿងណាជាគុណរបស់ខ្លួន អសប្បុរសទុកជាមិនមានគេសួររឿងនោះ ក៏ប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វីដល់រឿងដែលគេសួរ ។ តែថា អសប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលគុណរបស់ខ្លួន ឲ្យពិស្តារ ឲ្យពេញលេញ មិនឲ្យអស់ មិនឲ្យហើយទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងដំណើរនុ៎ះថា អ្នកនេះជាអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ អ្នកប្រាជ្ញគប្បីដឹងថាជាអសប្បុរស ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ (ដោយឡែកទៀត) អ្នកប្រាជ្ញគប្បីដឹងថាជាសប្បុរស ។ ធម៌ ៤ ប្រការ ដូចម្តេចខ្លះ ។

ឥធ ភិក្ខវេ សប្បុរិសោ យោ ហោតិ បរស្ស អវណ្ណោ តំ បុដ្ឋោបិ ន ចាតុករោតិ ។ កោ បន វាទោ អបុដ្ឋស្ស ។ បុដ្ឋោ ខោ បន បញ្ហាភិនីតោ ហាបេត្វា លម្ពេត្វា អបរិបូរំ អវិត្ថារេន បរស្ស អវណ្ណំ ភាសិតា ហោតិ ។ វេទិតព្វមេតំ ភិក្ខវេ សប្បុរិសោ អយំ ភវន្តិ ។ បុន ចបរំ ភិក្ខវេ សប្បុរិសោ យោ ហោតិ បរស្ស វណ្ណោ តំ អបុដ្ឋោបិ ចាតុករោតិ ។ កោ បន វាទោ បុដ្ឋស្ស ។ បុដ្ឋោ ខោ បន បញ្ហាភិនីតោ អហាបេត្វា អលម្ពេត្វា បរិបូរំ វិត្ថារេន បរស្ស វណ្ណំ ភាសិតា ហោតិ ។ វេទិតព្វមេតំ ភិក្ខវេ សប្បុរិសោ អយំ ភវន្តិ ។ បុន ចបរំ ភិក្ខវេ សប្បុរិសោ យោ ហោតិ អត្តនោ អវណ្ណោ តំ អបុដ្ឋោបិ ចាតុករោតិ ។ កោ បន វាទោ

ម្នាលភិក្ខុទាំងឡាយ រឿងណាជាទោសរបស់បុគ្គលដទៃ សប្បុរសក្នុងលោកនេះ បើទុកជាមានគេសួរក៏មិនប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងពោលទៅថ្វី ដល់រឿងដែលគេមិនសួរ ។ ចំណែកខាង សប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលទោសរបស់បុគ្គលដទៃ ដោយមិនពិស្តារមិនពេញលេញ ឲ្យធាប់អស់ ឲ្យធាប់ហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងដំណើរនុ៎ះថា អ្នកនេះជាសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត រឿងណាដែលជាគុណ របស់បុគ្គលដទៃ សប្បុរសទុកជាគេមិនសួរ ក៏ប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វី ដល់រឿងដែលគេសួរ ។ ចំណែកខាង សប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលគុណរបស់បុគ្គលដទៃឲ្យពិស្តារឲ្យពេញលេញ មិនចេះអស់ មិនចេះហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងដំណើរនុ៎ះថា អ្នកនេះជាសប្បុរស ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត រឿងណាជាទោសរបស់ខ្លួន សប្បុរសទុកជាគេមិនសួរ ក៏ប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វី

១៩៣



បុដ្ឋស្ស ។ បុដ្ឋោ ខោ បន បញ្ហាភិនីតោ អហាបេត្វា អលម្ពេត្វា បរិបូរំ វិត្ថារេន អត្តនោ អវណ្ណំ ភាសិតា ហោតិ ។ វេទិតព្វមេតំ ភិក្ខវេ សប្បុរិសោ អយំ ភវន្តិ ។ បុន ចបរំ ភិក្ខវេ សប្បុរិសោ យោ ហោតិ អត្តនោ វណ្ណោ តំ បុដ្ឋោបិ ន បាតុករោតិ ។ កោ បន វាទោ អបុដ្ឋស្ស ។ បុដ្ឋោ ខោ បន បញ្ហាភិនីតោ ហាបេត្វា លម្ពេត្វា អបរិបូរំ អវិត្ថារេន អត្តនោ វណ្ណំ ភាសិតា ហោតិ ។ វេទិតព្វមេតំ ភិក្ខវេ សប្បុរិសោ អយំ ភវន្តិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ សប្បុរិសោតិ វេទិតព្វោ ។ សេយ្យថាបិ ភិក្ខវេ វធុកា យញ្ញេវ រត្តឹ វា ទិវសំ វា អានីតា ហោតិ តាវទេវស្សា តិព្វំ ហិរោត្តប្បំ បច្ចុបដ្ឋិតំ ហោតិ សស្សុយាបិ សស្សុរេបិ សាមិកេបិ អន្តមសោ ទាសកម្មករបោរិសេសុ សា អបរេន សមយេន សំវាសមន្វាយ[1] សស្សុំបិ សស្សុរំបិ សាមិកំបិ ឯវមាហ

១ ឱ. ម. ឯត្ថន្តរេ វិស្សាសមន្វាយាតិ អត្ថិ ។

ដល់រឿងដែលគេសួរ ។ មួយទៀត សប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលទោសរបស់ខ្លួនឲ្យពិស្តារ ឲ្យពេញលេញ មិនចេះអស់ មិនចេះហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងដំណើរនុ៎ះថា អ្នកនេះជាសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងឯរឿងណាជាគុណរបស់ខ្លួន សប្បុរសទុកជាគេសួរក៏មិនប្រាប់រឿងនោះឲ្យប្រាកដឡើង ។ នឹងបាច់ពោលទៅថ្វី ដល់រឿងដែលគេមិនសួរ ។ មួយវិញទៀត សប្បុរសដែលគេសួរ គេនាំមកដើម្បីចោទសួរ ក៏ពោលគុណរបស់ខ្លួនដោយសេចក្តីមិនពិស្តារ មិនឲ្យពេញលេញ ឲ្យឆាប់អស់ ឲ្យឆាប់ហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញគប្បីដឹងដំណើរនុ៎ះថា អ្នកនេះជាសប្បុរស ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ អ្នកប្រាជ្ញគប្បីដឹងថាជាសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ត្រីមានគូស្រករ ដែលគេនាំមកក្នុងវេលាយប់ណា ឬថ្ងៃណា វេលានោះស្ត្រីនោះក៏តាំងហិរិនិងឱត្តប្បៈដ៏មាំមួន ទៅរកម្តាយក្មេកផង ឪពុកក្មេកផង ប្តីផង ដោយហោចទៅសូម្បីចំពោះពួកបុរសជាទាសកម្មករ សម័យក្រោយមក ស្ត្រីនោះអាស្រ័យការនៅរួមសំវាសហើយ និយាយយ៉ាងនេះនឹងម្តាយក្មេក ឪពុកក្មេកនិងប្តីថា

អបេថ កឹំ បន តុម្ហេ ជានាថាតិ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ ភិក្ខុ យញ្ញទេវ រត្តឹ វា ទិវសំ វា អគារស្មា អនគារិយំ បព្វជិតោ ហោតិ តទេវស្ស តិព្វំ ហិរោត្តប្បំ បច្ចុបដ្ឋិតំ ហោតិ ភិក្ខូសុ ភិក្ខុនីសុ ឧបាសកេសុ ឧបាសិកាសុ អន្តមសោ អារាមិក-ស្សមណុទ្ទេសេសុ សោ អបរេន សមយេន សំវា-សមន្វាយ អាចរិយំបិ ឧបជ្ឈាយំបិ ឯវមាហ អបេថ កឹំ បន តុម្ហេ ជានាថាតិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ អជុនាគតវជុកសមេន ចេតសា វិហរិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[៧៨] ចត្តារីមានិ ភិក្ខវេ អគ្គានិ ។ កតមានិ ចត្តារិ ។ សីលគ្គំ សមាធគ្គំ បញ្ញគ្គំ វិមុត្តគ្គំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អគ្គានីតិ ។

សូមអ្នកទាំងឡាយចៀសចេញទៅ សូមអ្នកទាំងឡាយដឹងការងារអ្វី ៗ ចុះ មានឧបមាយ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ក៏មានឧបមេយ្យដូច្នោះដែរ គឺបានចេញចាកផ្ទះ ចូលកាន់ផ្នួសក្នុងពេលយប់ ឬថ្ងៃណាហើយ វេលានោះ ភិក្ខុនោះតាំងហិរិនិងឱត្តប្បៈដ៏មាំមួនទៅរកពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដោយហោចទៅ សូម្បីពួកអារាមិកជន គឺអ្នកធ្វើការក្នុងអារាម និងសមណុទ្ទេស (សាមណេរ) សម័យក្រោយមក ភិក្ខុនោះអាស្រ័យការនៅរួបរួមគ្នា ទើបនិយាយយ៉ាងនេះនឹងអាចារ្យខ្លះ ឧបជ្ឈាយ៍ខ្លះថា សូមលោកទាំងឡាយចៀសចេញទៅ សូមលោកទាំងឡាយដឹងការងារអ្វី ៗ ចុះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយ នឹងមានចិត្តស្មើដូចជាស្ត្រីមានគូស្រករ ដែលទើបមកដល់ថ្មី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

[៧៩] ម្នាលភិក្ខុទាំងឡាយ ការប្រសើរនេះមាន ៤ ប្រការ ។ ការប្រសើរមាន ៤ ប្រការដូចម្តេចខ្លះ ។ គឺសីលប្រសើរ ១ សមាធិប្រសើរ ១ បញ្ញាប្រសើរ ១ វិមុត្តិប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ ការប្រសើរមាន ៤ ប្រការនេះឯង ។

[៧៦] ចត្តារីមានិ ភិក្ខវេ អគ្គានិ ។ កតមានិ ចត្តារិ ។ រូបគ្គំ វេទនគ្គំ សញ្ញគ្គំ ភវគ្គំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អគ្គានីតិ ។

[៧៧] ឯកំ សមយំ ភគវា កុសិនារាយំ វិហរតិ ឧបវត្តនេ មល្លានំ សាលវនេ អន្តរេ[១] យមកសាលានំ បរិនិព្វានសមយេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សិយា ខោ បន ភិក្ខវេ ឯកភិក្ខុស្សាបិ កង្ខា វា វិមតិ វា ពុទ្ធេ វា ធម្មេ វា សង្ឃេ វា មគ្គេ វា បដិបទាយ វា បុច្ឆថ ភិក្ខវេ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ សម្មុខីភូតោ នោ សត្ថា អហោសិ ជាសក្ខិម្ហា ភគវន្តំ សម្មុខា បដិបុច្ឆិតុន្តិ ។ ឯវំ វុត្តេ តេ ភិក្ខូ តុណ្ហី អហេសុំ ។ ទុតិយម្បិ ខោ ភគវា ភិក្ខូ អាមន្តេសិ... តតិយម្បិ ខោ ភគវា ភិក្ខូ អាមន្តេសិ

១ ឱ. អន្តរេន ។

[៧៦] ម្នាលភិក្ខុទាំងឡាយ ការប្រសើរនេះមាន ៤ ប្រការ ។ ការប្រសើរមាន ៤ ប្រការដូចម្តេចខ្លះ ។ គឺរូបប្រសើរ ១ វេទនាប្រសើរ ១ សញ្ញាប្រសើរ ១ ភពប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ ការប្រសើរ ៤ យ៉ាងនេះឯង ។

[៧៧] សម័យមួយ ព្រះដ៏មានព្រះភាគ ស្តេចគង់នៅនាចន្លោះដើមសាលព្រឹក្សទាំងគូក្នុងសាលវននៃស្តេចមល្លៈទាំងឡាយ ជាទីបត់ចូលទៅក្នុងក្រុង ជិតនគរកុសិនារា ក្នុងសម័យជិតបរិនិព្វាន ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទូលព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ បានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើសេចក្តីសង្ស័យឬសេចក្តីវង្វៀងសចិត្ត ក្នុងព្រះពុទ្ធក្តី ព្រះធម៌ក្តី ព្រះសង្ឃក្តី មគ្គក្តី បដិបទាក្តី មានដល់ភិក្ខុមួយរូប ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសួរមកចុះ កុំឲ្យមានសេចក្តីក្តៅក្រហាយស្តាយក្រោយថា ព្រះសាស្តារបស់យើង គង់នៅក្នុងទីចំពោះមុខ ពួកយើងមិនបានទូលសួរព្រះដ៏មានព្រះភាគចំពោះព្រះភក្ត្រសោះ ។ កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ពួកភិក្ខុទាំងនោះក៏នៅស្ងៀម ។ ព្រះដ៏មានព្រះភាគត្រាស់នឹងពួកភិក្ខុជាគម្រប់ពីរដងទៀត..ព្រះដ៏មានព្រះភាគត្រាស់នឹងពួកភិក្ខុជាគម្រប់ ៣ ដងទៀតថា

សិយា ខោ បន ភិក្ខវេ ឯកភិក្ខុស្សបិ កង្ខា វា វិមតិ វា ពុទ្ធេ វា ធម្មេ វា សង្ឃេ វា មគ្គេ វា បដិបទាយ វា បុច្ឆថ ភិក្ខវេ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ សម្មុខីភូតោ នោ សត្ថា អហោសិ នាសក្ខិម្ហា ភគវន្តំ សម្មុខា បដិបុច្ឆិតុន្តិ ។ តតិយម្បិ ខោ តេ ភិក្ខូ តុណ្ហី អហេសុំ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ សិយា ខោ បន ភិក្ខវេ សត្ថុ គារវេនបិ ន បុច្ឆេយ្យាថ សហាយកោបិ ភិក្ខវេ សហាយកស្ស អារោចេតូតិ ។ ឯវំ វុត្តេ តេ ភិក្ខូ តុណ្ហី អហេសុំ ។ អថខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ ឯវំ បសន្នោ អហំ ភន្តេ ឥមស្មឹ ភិក្ខុសង្ឃេ ។ នត្ថិ ឥមស្មឹ ភិក្ខុសង្ឃេ ឯកភិក្ខុស្សបិ កង្ខា វា វិមតិ វា ពុទ្ធេ វា ធម្មេ វា សង្ឃេ វា មគ្គេ វា បដិបទាយ វាតិ ។

ម្នាលភិក្ខុទាំងឡាយ បើសេចក្តីសង្ស័យឬសេចក្តីរវៀសចិត្ត ក្នុងព្រះពុទ្ធក្តី ព្រះធម៌ក្តី ព្រះសង្ឃក្តី មគ្គក្តី បដិបទាក្តី មានដល់ភិក្ខុមួយរូប ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសួរមកចុះ កុំមានសេចក្តីក្តៅក្រហាយស្តាយក្រោយថា ព្រះសាស្តារបស់យើងគង់នៅក្នុងទីចំពោះមុខ ពួកយើងមិនបានទូលសួរព្រះដ៏មានព្រះភាគ ចំពោះព្រះភក្ត្រសោះ ។ ភិក្ខុទាំងនោះនៅស្ងៀមអស់វារៈជាគម្រប់ ៣ ដងទៀត ។ លំដាប់នោះព្រះដ៏មានព្រះភាគត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ មិនហ៊ានសួរ ព្រោះមានសេចក្តីគោរព ក្នុងព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុជាសំឡាញ់ ចូរប្រាប់ភិក្ខុជាសំឡាញ់ផងគ្នាចុះ ។ កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ពួកភិក្ខុទាំងនោះក៏នៅស្ងៀម ។ លំដាប់នោះព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា អស្ចារ្យណាស់ព្រះអង្គ ចម្លែកណាស់ព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីជ្រះថ្លាក្នុងពួកភិក្ខុនេះដោយប្រការយ៉ាងនេះ ។ សេចក្តីសង្ស័យឬសេចក្តីរវៀសចិត្ត ក្នុងព្រះពុទ្ធក្តី ព្រះធម៌ក្តី ព្រះសង្ឃក្តី មគ្គក្តី បដិបទាក្តី ក្នុងពួកភិក្ខុទាំងនេះ មិនមានដល់ភិក្ខុមួយរូបឡើយ ។

បសាទា ខោ ត្វំ អានន្ទ វទេសិ ញាណមេវេត្ថ អានន្ទ តថាគតស្ស នត្ថិ ឥមស្មឹ ភិក្ខុសង្ឃេ ឯកភិក្ខុស្សបិ កង្ខា វា វិមតិ វា ពុទ្ធេ វា ធម្មេ វា សង្ឃេ វា មគ្គេ វា បដិបទាយ វាតិ ។ ឥមេសំ ហិ អានន្ទ បញ្ចន្នំ ភិក្ខុសតានំ យោ បច្ឆិមកោ ភិក្ខុ សោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។

[៧៨] ចត្តារីមានិ ភិក្ខវេ អចិន្តេយ្យានិ ន ចិន្តេ-តព្វានិ យានិ ចិន្តេន្តោ ឧម្មាទស្ស វិឃាតស្ស ភាគី អស្ស ។ កតមានិ ចត្តារិ ។ ពុទ្ធានំ ភិក្ខវេ ពុទ្ធវិសយោ អចិន្តេយ្យោ ន ចិន្តេតព្វោ យំ ចិន្តេន្តោ ឧម្មាទស្ស វិឃាតស្ស ភាគី អស្ស

ម្នាលអានន្ទ អ្នកពោលតាមសេចក្តីជ្រះថ្លាពិត ម្នាលអានន្ទ តថាគតក៏មានសេចក្តីដឹងក្នុងដំណើរនោះដែរថា សេចក្តីសង្ស័យឬសេចក្តីងឿងឆ្ងល់ក្នុងព្រះពុទ្ធក្តី ព្រះធម៌ក្តី ព្រះសង្ឃក្តី មគ្គក្តី បដិបទាក្តី ក្នុងពួកភិក្ខុទាំងនេះ មិនមានដល់ភិក្ខុមួយរូបឡើយ ។ ម្នាលអានន្ទ ព្រោះថា បណ្តាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុណាដែលមានគុណជាន់ទាបជាងគេ ភិក្ខុនោះគង់ជាសោតាបន្នៈ មិនធ្លាក់ចុះទៅ ក្នុងអបាយទេ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

[៧៨] ម្នាលភិក្ខុទាំងឡាយ អចិន្រ្តេយ្យ (ហេតុដែលមិនគួរគិត) នេះមាន ៤ ប្រការ ដែលបុគ្គលមិនគួរគិតទេ តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្តីឆ្កួតនិងសេចក្តីលំបាក ។ អចិន្រ្តេយ្យ ៤ ប្រការដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវិស័យរបស់ព្រះពុទ្ធទាំង-ឡាយ ជាអចិន្រ្តេយ្យ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះ គប្បីបាននូវចំណែកនៃសេចក្តីឆ្កួត និងសេចក្តីលំបាកទទេ ១

ឈាយិស្ស ភិក្ខវេ ឈានវិសយោ អចិន្តេយ្យោ ន ចិន្តេតព្វោ យំ ចិន្តេន្តោ ឧម្មាទស្ស វិឃាតស្ស ភាគី អស្ស កម្មវិបាកោ ភិក្ខវេ អចិន្តេយ្យោ ន ចិន្តេតព្វោ យំ ចិន្តេន្តោ ឧម្មាទស្ស វិឃាតស្ស ភាគី អស្ស លោកចិន្តា ភិក្ខវេ អចិន្តេយ្យា ន ចិន្តេតព្វា យំ ចិន្តេន្តោ ឧម្មាទស្ស វិឃាតស្ស ភាគី អស្ស ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អចិន្តេយ្យានិ ន ចិន្តេតព្វានិ យានិ ចិន្តេន្តោ ឧម្មាទស្ស វិឃាតស្ស ភាគី អស្សាតិ ។

[៧៩] ចតស្សោ ឥមា ភិក្ខវេ ទក្ខិណាវិសុទ្ធិយោ ។ កតមា ចតស្សោ ។ អត្ថិ ភិក្ខវេ ទក្ខិណា ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ អត្ថិ ភិក្ខវេ ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ

ម្នាលភិក្ខុទាំងឡាយ ឈានវិស័យរបស់បុគ្គលអ្នកបានឈាន ជាអចិន្ត្រៃយ៍ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះបាននូវចំណែកនៃសេចក្តីឆ្កួតនឹងសេចក្តីលំបាកទទេ ១ ម្នាលភិក្ខុទាំងឡាយ វិបាករបស់កម្មជាអចិន្ត្រៃយ៍ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្តីឆ្កួតនិងសេចក្តីលំបាកទទេ ១ ម្នាលភិក្ខុទាំង-ឡាយ លោកចិន្តា[១] (ការគិតអំពីលោក) ជាអចិន្ត្រៃយ៍ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះ គប្បីបាននូវចំណែកនៃសេចក្តីឆ្កួតនិងសេចក្តីលំបាកទទេ ១ ។ ម្នាលភិក្ខុទាំងឡាយ អចិន្ត្រៃយ៍មាន ៤ ប្រការប៉ុណ្ណេះ ដែលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្តីឆ្កួតនិងសេចក្តីលំបាកទទេ ។ ។

[៧៩] ម្នាលភិក្ខុទាំងឡាយ ទក្ខិណាវិសុទ្ធិ (សេចក្តីបរិសុទ្ធនៃទក្ខិណាទាន) នេះមាន ៤ ប្រការ ។ ទក្ខិណាវិសុទ្ធិ ៤ ប្រការដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ទក្ខិណា បរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គា-ហកៈក៏មាន ១ ម្នាលភិក្ខុទាំងឡាយ ទក្ខិណា បរិសុទ្ធអំពីបដិគ្គាហកៈ

---

១ គិតថាព្រះចន្ទ្រ ព្រះអាទិត្យ ផែនដី មហាសមុទ្រ អ្នកណាសាង ពួកសត្វនិងភ្នំនិងព្រៃព្រឹក្សាមានដើមស្វាយ ដើមចេកនិងដើមដូងជាដើម អ្នកណាបង្កើតជាដំបូង គំនិតយ៉ាងនេះ ហៅថា លោកចិន្តា ។ អដ្ឋកថា ។

១៩៩



នោ ទាយកតោ អត្ថិ ភិក្ខវេ ទក្ខិណា នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ អត្ថិ ភិក្ខវេ ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច ។ កថញ្ច ភិក្ខវេ ទក្ខិណា ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ។ ឥធ ភិក្ខវេ ទាយកោ ហោតិ សីលវា កល្យាណធម្មោ បដិគ្គាហកោ ហោតិ ទុស្សីលោ បាបធម្មោ ។ ឯវំ ខោ ភិក្ខវេ ទក្ខិណា ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ។ កថញ្ច ភិក្ខវេ ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ ។ ឥធ ភិក្ខវេ ទាយកោ ហោតិ ទុស្សីលោ បាបធម្មោ បដិគ្គាហកោ ហោតិ សីលវា កល្យាណធម្មោ ។ ឯវំ ខោ ភិក្ខវេ ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ ។ កថញ្ច ភិក្ខវេ ទក្ខិណា នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ។ ឥធ ភិក្ខវេ ទាយកោ ហោតិ

មិនបរិសុទ្ធអំពីទាយកក៏មាន ១ ទក្ខិណា មិនបរិសុទ្ធអំពីទាយក ទាំងមិនបរិសុទ្ធអំពីបដិគ្គាហកៈក៏មាន ១ ម្នាលភិក្ខុទាំងឡាយ ទក្ខិណា បរិសុទ្ធអំពីទាយកផង បរិសុទ្ធអំពីបដិគ្គាហកៈផងក៏មាន ១ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះទក្ខិណា បរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទាយកក្នុងសាសនានេះ មានសីល មានកល្យាណធម៌ តែបដិគ្គាហកៈជាអ្នកទ្រុស្តសីល មានបាបធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា ទក្ខិណាបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណាបរិសុទ្ធអំពីបដិគ្គាហកៈ មិនបរិសុទ្ធអំពីទាយក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទាយកក្នុងសាសនានេះ ជាអ្នកទ្រុស្តសីល មានបាបធម៌ តែបដិគ្គាហកៈជាអ្នកមានសីល មានកល្យាណធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា ទក្ខិណា បរិសុទ្ធអំពីបដិគ្គាហកៈ មិនបរិសុទ្ធអំពីទាយក ។ ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណា មិនបរិសុទ្ធអំពីទាយក ទាំងមិនបរិសុទ្ធអំពីបដិគ្គាហកៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទាយកក្នុងសាសនានេះ

ទុស្សីលោ បាបធម្មោ បដិគ្គាហកោបិ ហោតិ ទុស្សីលោ បាបធម្មោ ។ ឯវំ ខោ ភិក្ខវេ ទក្ខិណា នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ។ កថញ្ច ភិក្ខវេ ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច ។ ឥធ ភិក្ខវេ ទាយកោ ហោតិ សីលវា កល្យាណធម្មោ បដិគ្គាហកោបិ ហោតិ សីលវា កល្យាណធម្មោ ។ ឯវំ ខោ ភិក្ខវេ ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច ។ ឥមា ខោ ភិក្ខវេ ចតស្សោ ទក្ខិណាវិសុទ្ធិយោតិ ។

[៨០] អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច

ជាអ្នកទ្រុស្តសីល មានបាបធម៌ ទាំងបដិគ្គាហកៈក៏ជាអ្នកទ្រុស្តសីល មានបាបធម៌ដែរ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា ទក្ខិណាមិនបរិសុទ្ធអំពីទាយក ទាំងមិនបរិសុទ្ធអំពីបដិគ្គាហកៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណា បរិសុទ្ធអំពីទាយកផង អំពីបដិគ្គាហកៈផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទាយកក្នុងសាសនានេះ ជាអ្នកមានសីល មានកល្យាណធម៌ បដិគ្គាហកៈក៏ជាអ្នកមានសីល មានកល្យាណធម៌ដូចគ្នា ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា ទក្ខិណាបរិសុទ្ធអំពីទាយកផង អំពីបដិគ្គាហកៈផង ។ ម្នាលភិក្ខុទាំងឡាយ ទក្ខិណាវិសុទ្ធិ មាន ៤ ប្រការប៉ុណ្ណេះឯង ។

[៨០] គ្រានោះ ព្រះសារីបុត្រដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្រដ៏មានអាយុ គង់នៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដោយពាក្យដូច្នេះថា

កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចស្ស តាទិសា វ វណិជ្ជា បយុត្តា ឆេទគាមិនី ហោតិ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចស្ស តាទិសា វ វណិជ្ជា បយុត្តា ន យថាធិប្បាយា ហោតិ កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចស្ស តាទិសា វ វណិជ្ជា បយុត្តា យថាធិប្បាយា ហោតិ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចស្ស តាទិសា វ វណិជ្ជា បយុត្តា បរាធិប្បាយា ហោតីតិ ។ ឥធ សារីបុត្ត ឯកច្ចោ សមណំ វា ព្រាហ្មណំ វា ឧបសង្កមិត្វា បវារេតិ វទ ភន្តេ បច្ចយេនាតិ សោ យេន បវារេតិ តំ ន ទេតិ សោ ចេ តតោ ចុតោ ឥត្ថត្តំ អាគច្ឆតិ សោ យញ្ញទេវ វណិជ្ជំ បយោ-ជេតិ សាស្ស[១] ហោតិ ឆេទគាមិនី ។

១ ម. ស្វាស្ស ។

បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យជំនួញបែបនោះរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មានតែខាតទុនជាប្រក្រតី បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មិនបានចំណេញដូចបំណង បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មានចំណេញដូចបំណង បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ បានចំណេញលើសបំណង ។ ម្នាលសារីបុត្រ បុគ្គលពួកខ្លះ ក្នុងលោកនេះ ចូលទៅរកសមណៈឬព្រាហ្មណ៍ ហើយបវារណាថា បពិត្រលោកដ៏ចម្រើន លោកចូរប្រាប់ (សុំ) ដោយបច្ច័យចុះ បុគ្គលនោះ បវារណាដោយបច្ច័យណាមែន តែមិនឲ្យបច្ច័យនោះទេ បុគ្គលនោះបើច្យុតអំពីលោកនោះទៅ មកកើតក្នុងលោកនេះ បុគ្គលនោះប្រកបការជំនួញណា ជំនួញរបស់បុគ្គលនោះ រមែងខាតទុនទៅជាប្រក្រតី ។

ឥធ បន សារីបុត្ត ឯកច្ចោ សមណំ វា ព្រាហ្មណំ វា ឧបសង្កមិត្វា បវារេតិ វទ ភន្តេ បច្ចយេនាតិ សោ យេន បវារេតិ តំ ន យថាធិប្បាយំ ទេតិ សោ ចេ តតោ ចុតោ ឥត្ថត្តំ អាគច្ឆតិ សោ យញ្ញទេវ វណិជ្ជំ បយោជេតិ សាស្ស ហោតិ ន យថា-ធិប្បាយា ។ ឥធ បន សារីបុត្ត ឯកច្ចោ សមណំ វា ព្រាហ្មណំ វា ឧបសង្កមិត្វា បវារេតិ វទ[១] ភន្តេ បច្ចយេនាតិ សោ យេន បវារេតិ តំ យថាធិប្បាយំ ទេតិ សោ ចេ តតោ ចុតោ ឥត្ថត្តំ អាគច្ឆតិ សោ យញ្ញទេវ វណិជ្ជំ បយោជេតិ សាស្ស ហោតិ យថាធិប្បាយា ។ ឥធ បន សារីបុត្ត ឯកច្ចោ សមណំ វា ព្រាហ្មណំ វា ឧបសង្កមិត្វា បវារេតិ វទ ភន្តេ បច្ចយេនាតិ សោ យេន បវារេតិ

១ ម. វទតុ ។

ម្នាលសារីបុត្រ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ចូលទៅរកសមណៈឬព្រាហ្មណ៍ ហើយបវារណាថា បពិត្រលោកដ៏ចម្រើន លោកចូរប្រាប់ដោយបច្ច័យចុះ បុគ្គលនោះ បវារណាដោយបច្ច័យណាមែន តែឲ្យបច្ច័យនោះមិនតាមបំណងទេ បុគ្គលនោះ បើច្យុតអំពីលោកនោះទៅមកកើតក្នុងលោកនេះ បុគ្គលនោះប្រកបការជំនួញណា ជំនួញរបស់បុគ្គលនោះ មិនមានចំណេញដូចបំណង ។ ម្នាលសារីបុត្រ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ចូលទៅរកសមណៈឬព្រាហ្មណ៍ ហើយបវារណាថា បពិត្រលោកដ៏ចម្រើន លោកចូរប្រាប់ដោយបច្ច័យចុះ បុគ្គលនោះ បវារណាដោយបច្ច័យណា ក៏ឲ្យបច្ច័យនោះតាមបំណងមែន បុគ្គលនោះ បើច្យុតអំពីលោកនោះទៅ បានមកកើតក្នុងលោកនេះ បុគ្គលនោះប្រកបជំនួញណា ជំនួញរបស់បុគ្គលនោះ រមែងមានចំណេញដូចបំណង ។ ម្នាលសារីបុត្រ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ចូលទៅរកសមណៈឬព្រាហ្មណ៍ ហើយបវារណាថា បពិត្រលោកដ៏ចម្រើន លោកចូរប្រាប់ដោយបច្ច័យចុះ បុគ្គលនោះ បវារណាដោយបច្ច័យណា

តំ បាដិប្បាយំ ទេតិ សោ ចេ តតោ ចុតោ ឥត្ថត្តំ អាគច្ឆតិ សោ យញ្ញទេវ វណិជ្ជំ បយោជេតិ សាស្ស ហោតិ បាដិប្បាយា ។ អយំ ខោ សារីបុត្ត ហេតុ អយំ បច្ចយោ យេន មិធេកច្ចស្ស តាទិសា វ វណិជ្ជា បយុត្តា ឆេទគាមិនី ហោតិ អយំ បន សារីបុត្ត ហេតុ អយំ បច្ចយោ យេន មិធេកច្ចស្ស តាទិសា វ វណិជ្ជា បយុត្តា ន យថាធិប្បាយា ហោតិ អយំ ខោ សារីបុត្ត ហេតុ អយំ បច្ចយោ យេន មិធេកច្ចស្ស តាទិសា វ វណិជ្ជា បយុត្តា យថា-ធិប្បាយា ហោតិ អយំ បន សារីបុត្ត ហេតុ អយំ បច្ចយោ យេន មិធេកច្ចស្ស តាទិសា វ វណិជ្ជា បយុត្តា បាដិប្បាយា ហោតីតិ ។

ក៏ឲ្យបច្ច័យនោះលើសបវារណា បុគ្គលនោះ បើច្យុតអំពីលោកនោះទៅ បានមកកើតក្នុងលោកនេះ បុគ្គលនោះប្រកបជំនួញណា ជំនួញរបស់បុគ្គលនោះ រមែងមានចំណេញលើសបំណង ។ ម្នាលសារីបុត្រ នេះជាហេតុ នេះជាបច្ច័យដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មានតែខាតទុនជាប្រក្រតី ១ ម្នាលសារីបុត្រ មួយទៀត នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មិនមានចំណេញដូចបំណង ១ ម្នាលសារីបុត្រ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ បានចំណេញដូចបំណង ១ ម្នាលសារីបុត្រ មួយទៀត នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មានចំណេញលើសបំណង ១ ។

[៨១] ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មាតុគ្គាមោ នេវ សភាយំ និសីទតិ ន កម្មន្តំ បយោជេតិ ន កម្ពោជំ គច្ឆតីតិ ។ កោធនោ អានន្ទ មាតុគ្គាមោ ឥស្សុកី អានន្ទ មាតុគ្គាមោ មច្ឆរី អានន្ទ មាតុគ្គាមោ ទុប្ប-ញ្ញោ អានន្ទ មាតុគ្គាមោ ។ អយំ ខោ អានន្ទ ហេតុ អយំ បច្ចយោ យេន មាតុគ្គាមោ នេវ សភាយំ និសីទតិ ន កម្មន្តំ បយោជេតិ ន កម្ពោជំ គច្ឆតីតិ ។

អបណ្ណកវគ្គោ តតិយោ ។

[៨១] សម័យមួយ ព្រះដ៏មានព្រះភាគ ស្តេចគង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុគង់នៅក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យមាតុគ្រាម មិនបានអង្គុយក្នុងសភា មិនបានប្រកបការងារ (ធំៗ) មិនសម្រេចនូវភោគសម្បត្តិ ដែលកើតអំពីការងារបាន ។ ម្នាលអានន្ទ មាតុគ្រាមហែក្រោធ ម្នាលអានន្ទ មាតុគ្រាមហែឫស្យា ម្នាលអានន្ទ មាតុគ្រាមហែកំណាញ់ ម្នាលអានន្ទ មាតុគ្រាមអប្បប្រាជ្ញា ។ ម្នាលអានន្ទ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាម មិនបានចូលទៅអង្គុយ ក្នុងសភា មិនបានប្រកបការងារ (ធំៗ) មិនសម្រេចនូវភោគសម្បត្តិ ដែលកើតអំពីការងារបាន ។

ចប់ អបណ្ណកវគ្គ ទី ៣ ។

ទុតិយបណ្ណាសកេ អបណ្ណកវគ្គោ

# តស្សុទ្ទានំ

បធានទិដ្ឋិសប្បុរិសវធុកា
ទ្វេ ច ហោន្តិ អគ្គានិ កុសិនារាយ
អចិន្តិតំ ទក្ខិណាយ
វណិជ្ជា កម្ពោជេន វគ្គោ[១]តិ ។

---

១ ឱ. បធានទិដ្ឋិសប្បុរិសវធុកញ្ចេវ ហោន្តិ អគ្គានិ កុសិនារ អចិន្តិតំ ទក្ខិណាយ វណិជ្ជា កម្មោជេន ច វគ្គោតិ ។

ទុតិយបណ្ណាសក អបណ្ណកវគ្គ

# ឧទ្ទាននៃអបណ្ណកវគ្គនោះគឺ

ពោលអំពីអបណ្ណកប្បដិបទា មានសេចក្តីព្យាយាម ជាដើម ១ អំពីអបណ្ណកប្បដិបទា មានសម្មាទិដ្ឋិជាដើម ១ អំពីអសប្បុរស ១ អំពីសប្បុរស ១ អំពីភិក្ខុមានហិរិឱត្តប្បៈ មានសេចក្តីប្រៀបដូចស្ត្រីមានគូស្រករ ១ អំពីការប្រសើរមានពីរលើក ១ អំពីព្រះដ៏មានព្រះភាគគង់ទៀបក្រុងកុសិនារា ១ អំពីអចិន្ត្រៃយ៍ ១ អំពីទក្ខិណាវិសុទ្ធិ ១ អំពីជំនួញ ១ អំពីមាតុគ្រាមមិនសម្រេចនូវភោគសម្បត្តិដែលកើតអំពីការងារជាដើម ១ ទើបហៅថា អបណ្ណកវគ្គ ។

# មចលវគ្គោ

[៨២] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ចតូហិ ។ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ចតូហិ ។ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

[៨៣] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ចតូហិ ។ មុសាវាទី ហោតិ បិសុណាវាចោ ហោតិ ផរុសវាចោ ហោតិ សម្ផប្បលាបី ហោតិ ។

# មចលវគ្គ

[៨២] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែង ធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកសម្លាប់សត្វមានជីវិត ១ កាន់យកទ្រព្យដែល គេមិនបានឲ្យ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ និយាយពាក្យ កុហក ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ តែង ធ្លាក់ប្រួងទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំ យកទៅដាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកវៀរ ចាកបាណាតិបាត ១ វៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយ ធម៌ ៤ យ៉ាងនេះ តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

[៨៣] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយ ធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកនិយាយពាក្យកុហក ១ និយាយ ពាក្យញុះញង់ ១ និយាយពាក្យអាក្រក់ ១ ពោលពាក្យឥតប្រយោជន៍ ១ ។

ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ចតូហិ ។ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

[៨៤] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ចតូហិ ។ អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា វណ្ណារហស្ស អវណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា អប្បសាទ-នីយេ ឋានេ បសាទំ ឧបទំសេតិ អននុវិច្ច អបរិយោ-គាហេត្វា បសាទនីយេ ឋានេ អប្បសាទំ ឧបទំសេតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ទាំង ៤ យ៉ាងនេះ តែងធ្លាក់ប្រុងទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកវៀរចាកមុសាវាទ ១ វៀរចាកបិសុណាវាចា ១ វៀរចាកផរុសវាចា ១ វៀរចាកសម្ផប្បលាបៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ទាំង ៤ យ៉ាងនេះ តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

[៨៤] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលមិនពិនិត្យមើល មិនស្ទង់មើល (ជាមុន) ហើយ ពោលសរសើរបុគ្គលដែលគួរតិះដៀល ១ មិនពិនិត្យមើល មិនស្ទង់មើល (ជាមុន) ហើយពោលតិះដៀល បុគ្គលដែលគួរសរសើរ ១ មិនពិនិត្យមើល មិនស្ទង់មើល(ជាមុន)ហើយ បណ្តុះសេចក្តីជ្រះថ្លា ក្នុងទីដែលមិនគួរជ្រះថ្លា ១ មិនពិនិត្យមើល មិនស្ទង់មើល ( ជាមុន ) ហើយបណ្តុះសេចក្តីមិនជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា ១ ។

ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថា-
ភតំ និក្ខិត្តោ ឯវំ និរយេ ។ ចតូហិ ភិក្ខវេ ធម្មេហិ
សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។
កតមេហិ ចតូហិ ។ អននុវិច្ច បរិយោគាហេត្វា អវណ្ណា-
រហស្ស អវណ្ណំ ភាសតិ[១] អនុវិច្ច បរិយោគាហេត្វា
វណ្ណារហស្ស វណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា
អប្បសាទនីយេ ឋានេ អប្បសាទំ ឧបទំសេតិ
អនុវិច្ច បរិយោគាហេត្វា បសាទនីយេ ឋានេ បសាទំ
ឧបទំសេតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ
សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

[៨៤] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ
និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ចតូហិ ។ កោធគរុ
ហោតិ ន សទ្ធម្មគរុ មក្ខគរុ ហោតិ ន សទ្ធម្មគរុ លាភគរុ
ហោតិ ន សទ្ធម្មគរុ សក្ការគរុ ហោតិ ន សទ្ធម្មគរុ ។

១ ម. ភាសិតា ហោតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ តែងធ្លាក់ប្រូងទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលបានពិនិត្យមើល បានស្ទង់មើលរួចហើយ ទើបពោលទោសចំពោះបុគ្គលដែលប្រកបដោយទោស ១ បានពិនិត្យមើល បានស្ទង់មើលរួចហើយ ទើបពោលគុណចំពោះបុគ្គលដែលប្រកបដោយគុណ ១ បានពិនិត្យមើល បានស្ទង់មើលរួចហើយទើបបណ្តុះសេចក្តីមិនជ្រះថ្លា ក្នុងទីដែលមិនគួរជ្រះថ្លា ១ បានពិនិត្យមើល បានស្ទង់មើលរួចហើយ ទើបបណ្តុះសេចក្តីជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ទាំង ៤ យ៉ាងនេះ តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

[៨៥] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលជាអ្នកធ្ងន់ក្នុងសេចក្តីក្រោធ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ជាអ្នកធ្ងន់ក្នុងសេចក្តីលុបគុណ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ជាអ្នកធ្ងន់ក្នុងលាភ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ជាអ្នកធ្ងន់ក្នុងសក្ការៈ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ។

ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ចតូហិ ។ សទ្ធម្មគរុ ហោតិ ន កោធគរុ សទ្ធម្មគរុ ហោតិ ន មក្ខគរុ សទ្ធម្មគរុ ហោតិ ន លាភគរុ សទ្ធម្មគរុ ហោតិ ន សក្ការគរុ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

[៨៦] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ តមោ តមបរាយនោ តមោ ជោតិបរាយនោ ជោតិ តមបរាយនោ ជោតិ ជោតិបរាយនោ ។ កថញ្ច ភិក្ខវេ បុគ្គលោ តមោ ហោតិ តមបរាយនោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ នីចកុលេ បច្ចាជាតោ[១] ហោតិ ចណ្ឌាលកុលេ វា វេណកុលេ វា

១ បច្ចាជាតោតិ បច្ឆាជាតោតិ ឥទដ្ឋកថា ។ បាឡិយំ អយមេវ បាឋោ វា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ តែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គល ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសេចក្តីក្រោធ ១ ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសេចក្តីលុបគុណ ១ ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងលាភ ១ ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសក្ការៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

[៨៦] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលងងឹត មានងងឹតទៅខាងមុខទៀត ១ បុគ្គលងងឹត មានពន្លឺទៅខាងមុខ ១ បុគ្គលភ្លឺ មានងងឹតទៅខាងមុខវិញ ១ បុគ្គលភ្លឺ មានពន្លឺទៅខាងមុខទៀត ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលងងឹត មានងងឹតទៅខាងមុខទៀត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលថោកទាប គឺត្រកូលចណ្ឌាល ត្រកូលអ្នកត្បាញផែង

នេសាទកុលេ វា រថការកុលេ វា បុក្កុសកុលេ វា ទលិទ្ទេ អប្បន្នបានភោជនេ កសិរវុត្តិកេ យត្ថ កសិរេន ឃាសច្ឆាទោ លព្ភតិ ។ សោ ច ហោតិ ទុព្វណ្ណោ ទុទ្ទសិកោ ឱកោដិមកោ ពហ្វាពាធោ កាណោ វា កុណី វា ខញ្ជោ វា បក្ខហតោ វា ន លាភី អន្នស្ស បានស្ស វត្ថស្ស យានស្ស មាលាគន្ធវិលេបនស្ស សេយ្យាវសថប្បទីបេយ្យស្ស ។ សោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ តមោ ហោតិ តមបរាយនោ ។ កថញ្ច ភិក្ខវេ បុគ្គលោ តមោ ហោតិ ជោតិបរាយនោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ នីចកុលេ បច្ចាជាតោ[១] ហោតិ ចណ្ឌាលកុលេ វា វេណកុលេ វា

១ ឥទដ្ឋកថាយំ បច្ចាជាតោតិ បច្ឆាជាតោតិ ។

ត្រកូលអ្នកនេសាទ ត្រកូលអ្នកធ្វើរថ ត្រកូលអ្នកចោលសម្រាម ឬត្រកូលកម្សត់ ដែលមានបាយទឹកនិងភោជនតិច ប្រព្រឹត្តចិញ្ចឹមជីវិតបានដោយលំបាក ដែលជាត្រកូល រកអាហារសម្រាប់បរិភោគ និងសំពត់សម្រាប់បិទបាំង បានដោយត្រដាបត្រដួស ។ បុគ្គលនោះ ជាអ្នកមានសម្បុរអាក្រក់ មានរូបឆោមអាក្រក់ ជាមនុស្សតឿ មានអាពាធច្រើន ខ្វាក់ ក្ញែង ខ្វិន ខ្វិន ជាអ្នកមិនសូវបានបាយទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ទីដេក ផ្ទះសំណាក់ និងគ្រឿងប្រទីប ។ បុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ តែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងងឹត មានងងឹតទៅខាងមុខទៀត យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលងងឹត តែមានពន្លឺទៅខាងមុខ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលថោកទាប គឺត្រកូលចណ្ឌាល ត្រកូលអ្នកត្បាញផែង

នេសាទកុលេ វា រថការកុលេ វា បុក្កុសកុលេ វា ទលិទ្ទេ អប្បន្នបានភោជនេ កសិរវុត្តិកេ យត្ថ កសិរេន ឃាសច្ឆាទោ លព្ភតិ ។ សោ ច ហោតិ ទុព្វណ្ណោ ទុទ្ទសិកោ ឱកោដិមកោ ពវ្ហាពាធោ កាណោ វា កុណី វា ខញ្ជោ វា បក្ខហតោ វា ន លាភី អន្នស្ស បានស្ស វត្ថស្ស យានស្ស មាលាគន្ធវិលេបនស្ស សេយ្យាវសថប្បទីបេយ្យស្ស ។ សោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ សោ កាយេន សុចរិតំ ចរិត្វា វាចាយ សុចរិតំ ចរិត្វា មនសា សុចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ តមោ ហោតិ ជោតិបរាយនោ ។ កថញ្ច ភិក្ខវេ បុគ្គលោ ជោតិ ហោតិ តមបរាយនោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧច្ចេ កុលេ បច្ចាជាតោ ហោតិ ខត្តិយមហាសាលកុលេ វា

ត្រកូលអ្នកនេសាទ ត្រកូលអ្នកធ្វើរថ ត្រកូលអ្នកចោលសម្រាម ឬត្រកូលកម្សត់ ដែលមានបាយទឹកនិងភោជនតិច ប្រព្រឹត្តចិញ្ចឹមជីវិតបានដោយលំបាក ជាត្រកូល រកអាហារសម្រាប់បរិភោគ និងសំពត់សម្រាប់បិទបាំង បានដោយត្រដាបត្រដួស ។ បុគ្គលនោះជាអ្នកមានសម្បុរអាក្រក់ មានរូបឆោមអាក្រក់ ជាមនុស្សតឿ មានអាពាធច្រើន ខ្វាក់ ក្ញែង ខ្ចក ឬខ្វិន ជាអ្នកមិនសូវបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ទីដេក ផ្ទះសំណាក់ និងគ្រឿងប្រទីប ។ ប៉ុន្តែបុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបែកធ្លាយរាងកាយ ស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងងឹត តែមានពន្លឺទៅខាងមុខយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលភ្លឺ តែមានងងឹតទៅខាងមុខ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាល

ព្រាហ្មណមហាសាលកុលេ វា គហបតិមហាសាល-
កុលេ វា អឌ្ឍេ មហទ្ធនេ មហាភោគេ បហូត-
ជាតរូបរជតេ បហូតវិត្តុបករណេ បហូតធនធញ្ញេ សោ
ច ហោតិ អភិរូបោ ទស្សនីយោ បាសាទិកោ
បរមាយ វណ្ណាបោក្ខរតាយ សមន្នាគតោ លាភី
អន្នស្ស បានស្ស វត្ថស្ស យានស្ស មាលាគន្ធ-
វិលេបនស្ស សេយ្យាវសថប្បទីបេយ្យស្ស ។ សោ
កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ
មនសា ទុច្ចរិតំ ចរតិ សោ កាយេន ទុច្ចរិតំ ចរិត្វា
វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា
កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ
វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឯវំ ខោ ភិក្ខវេ
បុគ្គលោ ជោតិ ហោតិ តមបរាយនោ ។ កថញ្ច
ភិក្ខវេ បុគ្គលោ ជោតិ ហោតិ ជោតិបរាយនោ ។
ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧច្ចេ កុលេ បច្ចាជាតោ
ហោតិ ខត្តិយមហាសាលកុលេ វា ព្រាហ្មណ-
មហាសាលកុលេ វា គហបតិមហាសាលកុលេ វា

ឬត្រកូលព្រាហ្មណមហាសាល និងត្រកូលគហបតិមហាសាល ដែលជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីត្រេកអរច្រើន មានស្រូវជាទ្រព្យច្រើន បុគ្គលនោះ រមែងមានរូបល្អ គួរពិតពិលរមិលមើល គួរជាទីជ្រះថ្លា ប្រកបដោយរូបឆោម ល្អក្រៃលែង ជាអ្នកបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ទីដេក ផ្ទះសំណាក់ និងគ្រឿងប្រទីប ជាប្រក្រតី ។ ប៉ុន្តែបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ តែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលភ្លឺ តែមានងងឹតទៅខាងមុខ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលភ្លឺ មានពន្លឺទៅខាងមុខទៀត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហា-សាល ឬត្រកូលព្រាហ្មណមហាសាល និងត្រកូលគហបតិមហាសាល

អឌ្ឍោ មហទ្ធនេ មហាភោគេ បហូតជាតរូបរជតេ បហូតវិត្តូបករណោ បហូតធនធញ្ញោ សោ ច ហោតិ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ លាភី អន្នស្ស បានស្ស វត្ថស្ស យានស្ស មាលាគន្ធវិលេបនស្ស សេយ្យាវស-ថប្បទីបេយ្យស្ស ។ សោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ សោ កាយេន សុចរិតំ ចរិត្វា វាចាយ សុចរិតំ ចរិត្វា មនសា សុចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ជោតិ ហោតិ ជោតិបរាយនោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[៨៧] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឱណតោណតោ ឱណតុណ្ណតោ ឧណ្ណតោណតោ ឧណ្ណតុណ្ណតោ ។ កថញ្ច ភិក្ខវេ បុគ្គលោ ឱណតោណតោ ហោតិ ។

ដែលជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ ជាទីត្រេកអរច្រើន មានស្រូវជាទ្រព្យច្រើន បុគ្គលនោះ ជាអ្នកមានរូបល្អ គួរពិតពិលរមិលមើល គួរជាទីជ្រះថ្លា ប្រកបដោយរូបឆោម ល្អក្រៃលែង ជាអ្នកបានបាយទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ទីដេក ផ្ទះសំណាក់ និងគ្រឿងប្រទីប ជាប្រក្រតី ។ បុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ តែងទៅកើត ក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលភ្លឺមានពន្លឺ ទៅខាងមុខទៀត យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។

[៨៧] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលទាបកាន់តែទាបទៅ ១ បុគ្គលទាបត្រឡប់ទៅជាខ្ពស់វិញ ១ បុគ្គលខ្ពស់ត្រឡប់មកជាទាបវិញ ១ បុគ្គលខ្ពស់កាន់តែខ្ពស់ឡើង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទាបកាន់តែទាបទៅ តើដូចម្តេច ។

ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ នីចកុលេ បច្ចាជាតោ ហោតិ ចណ្ឌាលកុលេ វា ។ បេ ។ សោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ឱណតោណតោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ ឱណតុណ្ណតោ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ នីចកុលេ បច្ចាជាតោ ហោតិ ចណ្ឌាលកុលេ វា ។ បេ ។ សោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ សោ កាយេន សុចរិតំ ចរិត្វា វាចាយ សុចរិតំ ចរិត្វា មនសា សុចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ឱណតុណ្ណតោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលទាប គឺត្រកូលចណ្ឌាល ។ បេ ។ បុគ្គលនោះ តែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងអបាយទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាបកាន់តែទាបទៅយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទាបត្រឡប់ទៅជាខ្ពស់វិញ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលទាប គឺត្រកូលចណ្ឌាល ។ បេ ។ បុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបុគ្គលនោះប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាបត្រឡប់ជាខ្ពស់វិញយ៉ាងនេះឯង ។

កថញ្ច ភិក្ខវេ បុគ្គលោ ឧណ្ណតោណតោ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧច្ចេ កុលេ បច្ចា-ជាតោ ហោតិ ខត្តិយមហាសាលកុលេ វា ។ បេ ។ សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ឧណ្ណតោណតោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ ឧណ្ណតុណ្ណតោ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧច្ចេ កុលេ បច្ចា-ជាតោ ហោតិ ខត្តិយមហាសាលកុលេ វា ។ បេ ។ សោ កាយេន សុចរិតំ ចរិត្វា វាចាយ សុចរិតំ ចរិត្វា មនសា សុចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ឧណ្ណតុណ្ណតោ ហោតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលខ្ពស់ត្រឡប់មកជាទាបវិញ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាល ។ បេ ។ ប៉ុន្តែបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្ពស់ត្រឡប់មកជាទាបវិញ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលខ្ពស់កាន់តែខ្ពស់ឡើង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្ពស់គឺត្រកូលខត្តិយមហាសាល ។ បេ ។ បុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្ពស់កាន់តែខ្ពស់ឡើងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[៨៨] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ សមណមចលោ សមណបុណ្ឌរីកោ សមណបទុមោ សមណេសុ សមណសុខុមាលោ ។ កថញ្ច ភិក្ខវេ បុគ្គលោ សមណមចលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សេក្ខោ ហោតិ បដិបទោ អនុត្តរំ យោគក្ខេមំ បត្ថយមានោ វិហរតិ ។ សេយ្យថាបិ ភិក្ខវេ រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស[១] ជេដ្ឋោ បុត្តោ អភិសេកោ អនភិសិត្តោ មចលប្បត្តោ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សេក្ខោ ហោតិ បដិបទោ អនុត្តរំ យោគក្ខេមំ បត្ថយមានោ វិហរតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណមចលោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ សមណបុណ្ឌរីកោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ

១ ឱ. មុទ្ធាវសិត្តស្សាតិ ទិស្សតិ ។

[៨៨] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ គឺសមណៈមិនរំភើប ១ សមណៈឈូកស ១ សមណៈឈូកក្រហម ១ សមណចម្រើនដោយសុខ ក្នុងពួកសមណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈមិនរំភើប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាសេក្ខៈ អ្នកប្រតិបត្តិប្រាថ្នានូវធម៌ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចព្រះរាជបុត្រច្បង របស់ខត្តិយរាជ ដែលបានមុទ្ធាភិសេកហើយ ជាព្រះរាជកុមារ គួរនឹងអភិសេក តែមិនទាន់អភិសេកនៅឡើយ តែងដល់នូវសេចក្តីមិនរំភើប (ចំពោះការអភិសេក) យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសេក្ខៈអ្នកប្រតិបត្តិ ប្រាថ្នានូវធម៌ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈមិនរំភើបយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន

នោ ច ខោ អដ្ឋ វិមោក្ខេ កាយេន ផុសិត្វា វិហរតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណបុណ្ឌរីកោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ សមណបទុមោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ អដ្ឋ ច វិមោក្ខេ កាយេន ផុសិត្វា វិហរតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណបទុមោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ សមណេសុ សមណសុខុមាលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យាចិតោ វ ពហុលំ ចីវរំ បរិភុញ្ជតិ អប្បំ អយាចិតោ យាចិតោ វ ពហុលំ បិណ្ឌបាតំ បរិភុញ្ជតិ អប្បំ អយាចិតោ យាចិតោ វ ពហុលំ សេនាសនំ បរិភុញ្ជតិ អប្បំ អយាចិតោ យាចិតោ វ ពហុលំ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បរិភុញ្ជតិ អប្បំ អយាចិតោ ។

តែមិនទាន់ពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាមកាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកក្រហម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញា-វិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ទាំងបានពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាមកាយទៀតផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកក្រហម យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈ ចម្រើនដោយសុខក្នុងពួកសមណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បើទាយកអង្វរ ទើបប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់តិច បើទាយកអង្វរ ទើបឆាន់បិណ្ឌបាតច្រើន បើគេមិនអង្វរទេ ក៏ឆាន់តិច បើទាយកអង្វរ ទើបប្រើប្រាស់សេនាសនៈច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់តិច បើទាយកអង្វរ ទើបឆាន់គិលានប្បច្ច័យភេសជ្ជបរិក្ខារច្រើន បើគេមិនអង្វរទេ ក៏ឆាន់តិច ។

យេហិ ខោ បន សព្រហ្មចារីហិ សទ្ធឹ វិហរតិ ត្យស្ស មនាបេនេវ ពហុលំ កាយកម្មេន សមុទាចរន្តិ អប្បំ អមនាបេន មនាបេនេវ ពហុលំ វចីកម្មេន សមុទាចរន្តិ អប្បំ អមនាបេន មនាបេនេវ ពហុលំ មនោកម្មេន សមុទាចរន្តិ អប្បំ អមនាបេន មនាបំយេវ ពហុលំ ឧបហារំ ឧបហរន្តិ អប្បំ អមនាបំ ។ យានិ ខោ បន តានិ វេទយិតានិ បិត្តសមុដ្ឋានានិ វា សេម្ហសមុដ្ឋានានិ វា វាតសមុដ្ឋានានិ វា សន្និបាតិកានិ វា ឧតុបរិណាមជានិ វា វិសមបរិហារជានិ វា ឱបក្កមិកានិ វា កម្មវិបាកជានិ វា តានស្ស[១] ន ពហុទេវ ឧប្បជ្ជន្តិ អប្បាពាធោ ហោតិ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។

១ ម. តានិ បនស្សាតិ ទិស្សតិ ។

បើភិក្ខុនោះ នៅជាមួយនឹងសព្រហ្មចារីបុគ្គលទាំងឡាយណា សព្រហ្មចារីបុគ្គលទាំងនោះ តែងប្រព្រឹត្តកិច្ចការច្រើនដោយកាយកម្ម ជាទីគាប់ចិត្តនៃភិក្ខុនោះ ដែលមិនជាទីគាប់ចិត្តតិច តែងប្រព្រឹត្តកិច្ចការច្រើន ដោយវចីកម្មជាទីគាប់ចិត្ត ដែលមិនជាទីគាប់ចិត្តតិច តែងប្រព្រឹត្តកិច្ចការច្រើន ដោយមនោកម្ម ជាទីគាប់ចិត្ត ដែលមិនជាទីគាប់ចិត្តតិច តែងប្រគេននូវគ្រឿងបូជាច្រើន ជាទីគាប់ចិត្ត ដែលមិនជាទីគាប់ចិត្តតិច ។ មួយទៀត វេទនាទាំងឡាយណា កើតអំពីប្រមាត់ក្តី កើតអំពីស្លេស្មក្តី កើតអំពីខ្យល់ក្តី កើតអំពីសន្និបាត គឺការកម្រើកប្រមាត់ ស្លេស្មនិងខ្យល់ប្រជុំគ្នាក្តី កើតអំពីរដូវប្រែប្រួលក្តី កើតអំពីការផ្លាស់ប្តូរឥរិយាបថមិនស្មើគ្នាក្តី កើតអំពីសេចក្តីព្យាយាម (របស់អ្នកឯទៀត មានការចាប់ចងវាយកាប់ជាដើម) ក្តី កើតអំពីវិបាកនៃកម្មក្តី វេទនាទាំងអស់នោះមិនកើតឡើង ច្រើនដល់ភិក្ខុនោះ ។ ជាអ្នកមានអាពាធតិច ជាអ្នកបានមិនបាច់ប្រាថ្នា បានមិនលំបាក បានមិនត្រដាបត្រដួស នូវឈានទាំង ៤ ដែលកើតអំពីអធិចិត្ត ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន តែងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់អាសវៈ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។

ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណេសុ សមណ-
សុខុមាលោ ហោតិ ។ យញ្ហិ តំ ភិក្ខវេ
សម្មា វទមានោ វទេយ្យ សមណេសុ សមណ-
សុខុមាលោតិ មមេវ តំ ភិក្ខវេ សម្មា វទមានោ
វទេយ្យ សមណេសុ សមណសុខុមាលោតិ ។
អហញ្ហិ ភិក្ខវេ យាចិតោ វ ពហុលំ ចីវរំ បរិភុញ្ជាមិ
អប្បំ អយាចិតោ យាចិតោ វ ពហុលំ បិណ្ឌបាតំ
បរិភុញ្ជាមិ អប្បំ អយាចិតោ យាចិតោ វ ពហុលំ
សេនាសនំ បរិភុញ្ជាមិ អប្បំ អយាចិតោ យាចិតោ
វ ពហុលំ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បរិភុញ្ជាមិ
អប្បំ អយាចិតោ ។ យេហិ ខោ បន ភិក្ខូហិ
សទ្ធឹ វិហរាមិ តេ មេ[1] មនាបេនេវ ពហុលំ
កាយកម្មេន សមុទាចរន្តិ អប្បំ អមនាបេន
មនាបេនេវ ពហុលំ វចីកម្មេន សមុទាចរន្តិ អប្បំ
អមនាបេន មនាបេនេវ ពហុលំ មនោកម្មេន
សមុទាចរន្តិ អប្បំ អមនាបេន មនាបំយេវ
ពហុលំ ឧបហារំ ឧបហរន្តិ អប្បំ អមនាបំ ។

---
១ ឱ. មម ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈ ចម្រើនដោយសុខក្នុងពួកសមណៈ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកផង ពោលសរសើរបុគ្គលណាថាជាសមណៈ ចម្រើនដោយសុខ ក្នុងពួកសមណៈ ម្នាលភិក្ខុទាំងឡាយ អ្នកផងដែលពោលសរសើរបុគ្គលនោះ ក៏ត្រូវត្រង់តថាគតហ្នឹងឯង ថាជាសមណៈចម្រើនដោយសុខក្នុងពួកសមណៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា តថាគត បើទាយកអង្វរ ទើបប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់តិច បើទាយកអង្វរ ទើបឆាន់បិណ្ឌបាតច្រើន បើគេមិនអង្វរទេ ក៏ឆាន់តិច បើទាយកអង្វរ ទើបប្រើប្រាស់សេនាសនៈច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់តិច បើទាយកអង្វរ ទើបឆាន់គិលានប្បច្ចយភេសជ្ជបរិក្ខារច្រើន បើគេមិនបានអង្វរទេ ក៏ឆាន់តិច ។ បើតថាគតនៅជាមួយនឹងភិក្ខុទាំងឡាយណា ភិក្ខុទាំងនោះ តែងប្រព្រឹត្តកិច្ចការច្រើន ដោយកាយកម្មជាទីគាប់ចិត្តនៃតថាគត ដែលមិនជាទីគាប់ចិត្តតិច តែងប្រព្រឹត្តកិច្ចការច្រើន ដោយវចីកម្មជាទីគាប់ចិត្ត ដែលមិនជាទីគាប់ចិត្តតិច តែងប្រព្រឹត្តកិច្ចការច្រើន ដោយមនោកម្មជាទីគាប់ចិត្ត ដែលមិនជាទីគាប់ចិត្តតិច តែងប្រគេននូវគ្រឿងបូជាច្រើន ជាទីគាប់ចិត្ត ដែលមិនជាទីគាប់ចិត្តតិច ។

យានិ ខោ បន តានិ វេទយិតានិ បិត្តសមុដ្ឋានានិ វា សេម្ហសមុដ្ឋានានិ វា វាតសមុដ្ឋានានិ វា សន្និបាតិកានិ វា ឧតុបរិណាមជានិ វា វិសមបរិហារជានិ វា ឱបក្កមិកានិ វា កម្មវិបាកជានិ វា តានិ មេ ន ពហុទេវ ឧប្បជ្ជន្តិ អប្បាពាធោហមស្មិ ចតុន្នំ ខោ បនស្មិ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមិ ។ យញ្ហិ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ សមណេសុ សមណសុខុមាលោតិ មមេវ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ សមណេសុ សមណសុខុមាលោតិ ។ ឥមា ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[៨៩] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ សមណមចលោ សមណបុណ្ឌរីកោ សមណបទុមោ សមណេសុ សមណសុខុមាលោ ។

មួយទៀត វេទនាទាំងឡាយណា កើតអំពីប្រមាត់ក្តី កើតអំពីស្លេស្មក្តី កើតអំពីខ្យល់ក្តី កើតអំពីសន្និបាតគឺការកម្រើកប្រមាត់ ស្លេស្មនឹងខ្យល់ប្រជុំគ្នាក្តី កើតអំពីរដូវប្រែប្រួលក្តី កើតអំពីការផ្លាស់ប្តូរឥរិយាបថមិនស្មើគ្នាក្តី កើតអំពីសេចក្តីព្យាយាម (របស់អ្នកឯទៀតមានការចាប់ចងវាយកាប់ជាដើម) ក្តី កើតអំពីវិបាកនៃកម្មក្តី វេទនាទាំងអស់នោះ មិនកើតឡើងច្រើនដល់តថាគតឡើយ តថាគតជាអ្នកមានអាពាធតិច ជាអ្នកបានមិនបាច់ប្រាថ្នា បានមិនលំបាក បានមិនត្រដាបត្រដួស នូវឈាន ៤ ដែលកើតអំពីអធិចិត្ត ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកផងពោលសរសើរបុគ្គលណាថាជាសមណៈចម្រើនដោយសុខ ក្នុងពួកសមណៈ ម្នាលភិក្ខុទាំងឡាយ អ្នកផងដែលគេពោលសរសើរបុគ្គលនោះ ក៏ត្រូវត្រង់តថាគតហ្នឹងឯង ជាសមណៈចម្រើនដោយសុខ ក្នុងពួកសមណៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមាននៅក្នុងលោក ។

[៨៩] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ គឺ សមណៈមិនរំកើប ១ សមណៈឈូកស ១ សមណៈឈូកក្រហម ១ សមណៈចម្រើនដោយសុខ ក្នុងពួកសមណៈ ១ ។

២២១



កថញ្ច ភិក្ខវេ បុគ្គលោ សមណមចលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណមចលោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ សមណបុណ្ឌរីកោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមី ហោតិ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករោតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណបុណ្ឌរីកោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ សមណបទុមោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ ។ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណបទុមោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ សមណេសុ សមណសុខុមាលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ

ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈ មិនរំភើប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាសោតាបន្នបុគ្គល មិនបានធ្លាក់ចុះ ក្នុងអបាយជាធម្មតា ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ព្រោះអស់សញ្ញោជនៈ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈ មិនរំភើប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈ ឈូកស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាសកទាគាមិបុគ្គល ព្រោះអស់សញ្ញោជនៈ ៣ ទាំងមានរាគៈ ទោសៈ មោហៈ ស្រាលស្តើង មកកាន់លោកនេះម្តងទៀត ទើបធ្វើនូវទីបំផុតនៃទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកក្រហម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាឱបបាតិកៈកំណើត រលត់កិលេសក្នុងទីនោះ មិនបានត្រឡប់ចាកលោកនោះមកវិញទេ ព្រោះអស់ឱរម្ភាគិយសញ្ញោជនៈទាំង ៥ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកក្រហមយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈ ចម្រើនដោយសុខក្នុងពួកសមណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណេសុ សមណសុខុមាលោ ហោតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[៩០] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ សមណមចលោ សមណបុណ្ឌរីកោ សមណបទុមោ សមណេសុ សមណសុខុមាលោ ។ កថញ្ច ភិក្ខវេ បុគ្គលោ សមណមចលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋិកោ ហោតិ សម្មាសង្កប្បោ ហោតិ សម្មាវាចោ ហោតិ សម្មាកម្មន្តោ ហោតិ សម្មា-អាជីវោ ហោតិ សម្មាវាយាមោ ហោតិ សម្មាសតិ ហោតិ សម្មាសមាធិ ហោតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណមចលោ ហោតិ ។

បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់អាសវៈ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈ ចម្រើនដោយសុខ ក្នុងពួកសមណៈ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[៩០] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ គឺសមណៈមិនរំភើប ១ សមណៈឈូកស ១ សមណៈឈូកក្រហម ១ សមណៈចម្រើនដោយសុខ ក្នុងពួកសមណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈមិនរំភើប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីយល់ឃើញត្រូវ មានសេចក្តីត្រិះរិះត្រូវ មានវាចាត្រូវ មានការងារត្រូវ មានការចិញ្ចឹមជីវិតត្រូវ មានព្យាយាមត្រូវ មានស្មារតីត្រូវ មានការតម្កល់ចិត្តត្រូវ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈមិនរំភើបយ៉ាងនេះឯង ។

កាថញ្ច ភិក្ខវេ បុគ្គលោ សមណបុណ្ឌរីកោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋិកោ ហោតិ សម្មាសង្កប្បោ ហោតិ សម្មាវាចោ ហោតិ សម្មាកម្មន្តោ ហោតិ សម្មាអាជីវោ ហោតិ សម្មាវាយាមោ ហោតិ សម្មាសតិ ហោតិ សម្មាសមាធិ ហោតិ សម្មាញាណី ហោតិ សម្មាវិមុត្តិ ហោតិ នោ ច ខោ អដ្ឋ វិមោក្ខេ កាយេន ផុសិត្វា វិហរតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណបុណ្ឌរីកោ ហោតិ ។ កាថញ្ច ភិក្ខវេ បុគ្គលោ សមណបទុមោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋិកោ ហោតិ ។ បេ ។ សម្មាញាណី ហោតិ សម្មាវិមុត្តិ ហោតិ អដ្ឋ ច វិមោក្ខេ កាយេន ផុសិត្វា វិហរតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណបទុមោ ហោតិ ។ កាថញ្ច ភិក្ខវេ បុគ្គលោ សមណេសុ សមណសុខុមាលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យាចិតោវ ពហុលំ ចីវរំ បរិភុញ្ជតិ អប្បំ អយាចិតោ ។ បេ ។

ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីយល់ត្រូវ មានសេចក្តីត្រិះរិះត្រូវ មានវាចាត្រូវ មានការងារត្រូវ មានការចិញ្ចឹមជីវិតត្រូវ មានព្យាយាមត្រូវ មានស្មារតីត្រូវ មានការតម្កល់ចិត្តត្រូវ មានការដឹងត្រូវ មានការរួចចាកកិលេសត្រូវ តែមិនទាន់បានពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាមកាយទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកក្រហម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីយល់ត្រូវ ។ បេ ។ មានការដឹងត្រូវ មានការរួចចាកកិលេសត្រូវ ទាំងបានពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាម-កាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកក្រហម យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈចម្រើនដោយសុខ ក្នុងពួកសមណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះបើគេអង្វរ ទើបប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់តិច ។ បេ ។

យញ្ហិ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ សមណេសុ សមណសុខុមាលោតិ មមេវ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ សមណេសុ សមណសុខុមាលោតិ ។ អហញ្ហិ ភិក្ខវេ យាចិតោ វ ពហុលំ ចីវរំ បរិភុញ្ជាមិ អប្បំ អយាចិតោ ។ បេ ។[១] ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[៩១] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ សមណមចលោ សមណបុណ្ឌរីកោ សមណបទុមោ សមណេសុ សមណសុខុមាលោ ។ កថញ្ច ភិក្ខវេ បុគ្គលោ សមណមចលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សេក្ខោ ហោតិ អប្បត្តមានសោ អនុត្តរំ យោគក្ខេមំ បត្ថយមានោ វិហរតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណមចលោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ សមណបុណ្ឌរីកោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ

១ ឱ. ម. អហញ្ហិ ភិក្ខវេ យាចិតោវ ពហុលំ ចីវរំ បរិភុញ្ជាមិ អប្បំ អយាចិតោ ។ បេ ។ ឥតិ ន ទិស្សន្តិ ។

ម្នាលភិក្ខុទាំងឡាយ អ្នកផងកាលបើពោលសរសើរ បុគ្គលណាថាជាសមណៈចម្រើនដោយសុខ ក្នុងពួកសមណៈ ម្នាលភិក្ខុទាំងឡាយ អ្នកផងដែលពោលសរសើរបុគ្គលនោះ ក៏ត្រូវត្រង់តថាគតហ្នឹងឯងថាជាសមណៈចម្រើនដោយសុខក្នុងពួកសមណៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា តថាគត បើគេអង្វរ ទើបប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់តិច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមាននៅក្នុងលោក ។

[៩១] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ គឺសមណៈមិនរំភើប ១ សមណៈឈូកស ១ សមណៈឈូកក្រហម ១ សមណៈចម្រើនដោយសុខ ក្នុងពួកសមណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈមិនរំភើប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាសេក្ខបុគ្គលជាអ្នកមានសេចក្តីប្រាថ្នាក្នុងចិត្ត មិនទាន់បានសម្រេច រមែងប្រាថ្នានូវធម៌ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ គឺព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈ មិនរំភើប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

២២៥



បញ្ចសុ ឧបាទានក្ខន្ធេសុ ឧទយព្វយានុបស្សី វិហរតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា... ឥតិ សញ្ញា... ឥតិ សង្ខារា.. ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ នោ ច ខោ អដ្ឋ វិមោក្ខេ កាយេន ផុសិត្វា វិហរតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណបុណ្ឌរីកោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ សមណបទុមោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ បញ្ចសុ ឧបាទានក្ខន្ធេសុ ឧទយព្វយានុបស្សី វិហរតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា... ឥតិ សញ្ញា... ឥតិ សង្ខារា... ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ អដ្ឋ ច វិមោក្ខេ កាយេន ផុសិត្វា វិហរតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ សមណបទុមោ ហោតិ ។

រមែងពិចារណាឃើញនូវការកើតឡើង និងការវិនាសទៅវិញ ក្នុងឧបាទានក្ខន្ធ ៥ ថា រូប ដូច្នេះ ហេតុជាទីកើតនៃរូប ដូច្នេះ ការវិនាសទៅនៃរូប ដូច្នេះ វេទនា ដូច្នេះ... សញ្ញា ដូច្នេះ... សង្ខារ ដូច្នេះ... វិញ្ញាណ ដូច្នេះ ហេតុជាទីកើតនៃវិញ្ញាណ ដូច្នេះ ការវិនាសទៅនៃវិញ្ញាណ ដូច្នេះ តែមិនបានពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាមកាយទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈឈូកក្រហម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងពិចារណានូវការកើតនិងការវិនាសទៅ ក្នុងឧបាទានក្ខន្ធ ៥ ថា រូប ដូច្នេះ ហេតុជាទីកើតនៃរូបដូច្នេះ ការរលត់ទៅនៃរូប ដូច្នេះ វេទនា ដូច្នេះ... សញ្ញា ដូច្នេះ... សង្ខារ ដូច្នេះ... វិញ្ញាណ ដូច្នេះ ហេតុជាទីកើតនៃវិញ្ញាណ ដូច្នេះ ការរលត់នៃវិញ្ញាណ ដូច្នេះ ទាំងបានពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាមកាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសមណៈឈូកក្រហម យ៉ាងនេះឯង ។

កាថញ្ច ភិក្ខវេ បុគ្គលោ សមណេសុ សមណសុខុ-
មាលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យាចិតោ វ ពហុលំ
ចីវរំ បរិភុញ្ជតិ អប្បំ អយាចិតោ ។ បេ ។ យញ្ហិ តំ
ភិក្ខវេ សម្មា វទមានោ វទេយ្យ សមណេសុ សមណ-
សុខុមាលោតិ មមេវ តំ ភិក្ខវេ សម្មា វទមានោ
វទេយ្យ សមណេសុ សមណសុខុមាលោតិ ។ អហញ្ហិ
ភិក្ខវេ យាចិតោ វ ពហុលំ ចីវរំ បរិភុញ្ជាមិ អប្បំ
អយាចិតោ ។ បេ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ
បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

មចលវគ្គោ ចតុត្ថោ ។

# តស្សុទ្ទានំ

ចាណាតិចាតោ ច មុសា
វណ្ណកោធតមោណតា
បុត្តោ សញ្ញោជនញ្ចេវ
ទិដ្ឋិ ខន្ធេន តេ ទសាតិ ។

*ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសមណៈ ចម្រើនដោយសុខ ក្នុងពួកសមណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បើគេអង្វរ ទើបប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់តិច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកផងពោលសរសើរ បុគ្គលណាថាជាសមណៈចម្រើនដោយសុខក្នុងពួកសមណៈ ម្នាលភិក្ខុទាំងឡាយ អ្នកផងដែលពោលសរសើរបុគ្គលនោះ ក៏ត្រូវត្រង់តថាគតហ្នឹងឯង ថាជាសមណៈចម្រើនដោយសុខក្នុងពួកសមណៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា តថាគត បើគេអង្វរ ទើបប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់ចីវរតិច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមាននៅក្នុងលោក ។*

ចប់ មចលវគ្គ ទី ៤ ។

# ឧទ្ទាននៃមចលវគ្គនោះគឺ

*និយាយអំពីបាណាតិបាតជាដើម ១ អំពីមុសាវាទជាដើម ១ អំពីបុគ្គលពោលសរសើរគុណ ១ អំពីបុគ្គលធ្ងន់ក្នុងសេចក្តីក្រោធ ១ អំពីបុគ្គលងងឹត ១ អំពីបុគ្គលទាប ១ អំពីសេក្ខភិក្ខុ ប្រៀបដោយព្រះរាជបុត្រ ១ អំពីសញ្ញោជនៈ ១ អំពីភិក្ខុជាអ្នកយល់ត្រូវជាដើម ១ អំពីភិក្ខុជាអ្នកពិចារណាក្នុងឧបាទានក្ខន្ធ ១ រួមទាំងអស់នោះត្រូវជា ១០ ។*

# អសុរវគ្គោ

[៩២] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ អសុរោ អសុរបរិវារោ អសុរោ ទេវបរិវារោ ទេវោ អសុរបរិវារោ ទេវោ ទេវបរិវារោ ។ កថញ្ច ភិក្ខវេ បុគ្គលោ អសុរោ ហោតិ អសុរបរិវារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ទុស្សីលោ ហោតិ បាបធម្មោ បរិសាបិស្ស ហោតិ ទុស្សីលា បាបធម្មា ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ អសុរោ ហោតិ អសុរបរិវារោ ។ កថញ្ច ភិក្ខវេ បុគ្គលោ អសុរោ ហោតិ ទេវបរិវារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ទុស្សីលោ ហោតិ បាបធម្មោ បរិសា ច ខ្វស្ស ហោតិ សីលវតី កល្យាណធម្មា ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ អសុរោ ហោតិ ទេវបរិវារោ ។ កថញ្ច ភិក្ខវេ បុគ្គលោ ទេវោ ហោតិ អសុរបរិវារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សីលវា ហោតិ កល្យាណធម្មោ

# អសុរវគ្គ

[៩២] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្ដេចខ្លះ ។ គឺអសុរ មានអសុរ ជាបរិវារ ១ អសុរ មានទេវតាជាបរិវារ ១ ទេវតា មានអសុរ ជាបរិវារ ១ ទេវតា មានទេវតា ជាបរិវារ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គល ជាអសុរ មានអសុរជាបរិវារ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ទាំងបរិសទ្យនៃបុគ្គលនោះ ក៏ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអសុរ មានអសុរ ជាបរិវារ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអសុរ មានទេវតាជាបរិវារ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ប៉ុន្តែឯបរិសទ្យនៃបុគ្គលនោះ ជាអ្នកមានសីល មានធម៌ល្អ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអសុរ មានទេវតា ជាបរិវារ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គល ជាទេវតា មានអសុរ ជាបរិវារ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ

បរិសា ច ខ្វស្ស ហោតិ ទុស្សីលា ធាបធម្មា ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ធេវោ ហោតិ អសុរបរិវារោ ។ កថញ្ច ភិក្ខវេ បុគ្គលោ ធេវោ ហោតិ ធេវបរិវារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សីលវា ហោតិ កល្យាណធម្មោ បរិសាបិស្ស ហោតិ សីលវតី កល្យាណធម្មា ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ធេវោ ហោតិ ធេវបរិវារោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[៩៣] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជ-មានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ លាភី ហោតិ អជ្ឈត្តំ ចេតោ-សមថស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ លាភី ហោតិ អធិប្បញ្ញាធម្មវិបស្សនាយ ន លាភី អជ្ឈត្តំ ចេតោ-សមថស្ស ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ នេវ លាភី ហោតិ អជ្ឈត្តំ ចេតោសមថស្ស

ប៉ុន្តែបរិសទ្យនៃបុគ្គលនោះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាទេវតា មានអសុរ ជាបរិវារ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គល ជាទេវតា មានទេវតា ជាបរិវារ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ ទាំងបរិសទ្យនៃបុគ្គលនោះ ក៏ជាអ្នកមានសីល មានធម៌ល្អដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាទេវតា មានទេវតា ជាបរិវារ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[៩៣] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបាននូវចេតោសមថៈ[១] ខាងក្នុងសន្តាន មិនបាននូវអធិប្បញ្ញាធម្មវិបស្សនា[២] ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បាននូវអធិប្បញ្ញាធម្មវិបស្សនា តែមិនបាននូវចេតោសមថៈ ខាងក្នុងសន្តាន ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបាននូវចេតោសមថៈ ខាងក្នុងសន្តានផង

១ អប្បនាសមាធិ ។ ២ វិបស្សនាញាណ សម្រាប់កំណត់នូវសង្ខារ ។ អដ្ឋកថា ។

ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ លាភី ចេវ ហោតិ អជ្ឈត្តំ ចេតោ-សមថស្ស លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[៩៤] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជ-មានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ លាភី ហោតិ អជ្ឈត្តំ ចេតោសម-ថស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ លាភី ហោតិ អធិប្បញ្ញា-ធម្មវិបស្សនាយ ន លាភី អជ្ឈត្តំ ចេតោសមថស្ស ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ នេវ លាភី ហោតិ អជ្ឈត្តំ ចេតោសមថស្ស ន លាភី អធិប្បញ្ញាធម្ម-វិបស្សនាយ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ លាភី ចេវ ហោតិ អជ្ឈត្តំ ចេតោសមថស្ស លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ លាភី ហោតិ អជ្ឈត្តំ ចេតោសមថស្ស

មិនបាននូវអធិប្បញ្ញាធម្មវិបស្សនាផង ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបាននូវចេតោសមថៈ ខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[៩៤] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបាននូវចេតោសមថៈ ខាងក្នុងសន្តាន តែមិនបាននូវអធិប្បញ្ញាធម្មវិបស្សនា ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបាននូវអធិប្បញ្ញាធម្មវិបស្សនា តែមិនបាននូវចេតោសមថៈខាងក្នុងសន្តាន ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបាននូវចេតោសមថៈ ខាងក្នុងសន្តានផង មិនបាននូវអធិប្បញ្ញាធម្មវិបស្សនាផង ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបាននូវចេតោសមថៈ ខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាដែលបាននូវចេតោសមថៈ ខាងក្នុងសន្តាន

ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ តេន ភិក្ខវេ បុគ្គលេន អជ្ឈត្តំ ចេតោសមថេ បតិដ្ឋាយ អធិប្បញ្ញាធម្មវិបស្សនាយ យោគោ ករណីយោ សោ អបរេន សមយេន លាភី ចេវ ហោតិ អជ្ឈត្តំ ចេតោសមថស្ស លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ លាភី អធិប្បញ្ញាធម្មវិបស្សនាយ ន លាភី អជ្ឈត្តំ ចេតោសមថស្ស តេន ភិក្ខវេ បុគ្គលេន អធិប្បញ្ញាធម្មវិបស្សនាយ បតិដ្ឋាយ អជ្ឈត្តំ ចេតោសមថេ យោគោ ករណីយោ សោ អបរេន សមយេន លាភី ចេវ ហោតិ អធិប្បញ្ញាធម្មវិបស្សនាយ លាភី ច អជ្ឈត្តំ ចេតោសមថស្ស ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ នេវ លាភី អជ្ឈត្តំ ចេតោសមថស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ តេន ភិក្ខវេ បុគ្គលេន តេសំយេវ កុសលានំ ធម្មានំ បដិលាភាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវាណី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។

តែមិនបាននូវអធិប្បញ្ញាធម្មវិបស្សនាទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះ គប្បីតាំងនៅក្នុងចេតោសមថៈ ខាងក្នុងសន្តាន ហើយធ្វើសេចក្តីព្យាយាម ក្នុងអធិប្បញ្ញាធម្មវិបស្សនា លុះសម័យខាងក្រោយមក បុគ្គលនោះ រមែង បាននូវចេតោសមថៈ ខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនា ផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា បាននូវអធិប្បញ្ញាធម្មវិបស្សនា តែមិនបាននូវចេតោសមថៈ ខាងក្នុង សន្តានទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះ គប្បីតាំងនៅក្នុងអធិប្បញ្ញា-ធម្មវិបស្សនា ហើយធ្វើសេចក្តីព្យាយាមក្នុងចេតោសមថៈ ខាងក្នុងសន្តាន លុះសម័យខាងក្រោយមក បុគ្គលនោះ រមែងបាននូវអធិប្បញ្ញាធម្ម-វិបស្សនាផង បាននូវចេតោសមថៈ ខាងក្នុងសន្តានផង ។ ម្នាល ភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា មិនបាន នូវចេតោសមថៈ ខាងក្នុងសន្តានផង មិនបាននូវអធិប្បញ្ញាធម្មវិបស្សនា ផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះ គប្បីធ្វើសេចក្តីប៉ុនប៉ង សេចក្តី ព្យាយាម សេចក្តីខ្មីឃ្មាត សេចក្តីប្រឹងប្រែង សេចក្តីមិនរួញរា សតិនិង សម្បជញ្ញៈដ៏ក្រៃលែង ដើម្បីឲ្យបានសម្រេចនូវកុសលធម៌ទាំងនោះ ។

សេយ្យថាបិ ភិក្ខវេ អាទិត្តចេលោ វា អាទិត្តសីសោ វា តស្ស[១] តស្សេវ ចេលស្ស វា សីសស្ស វា និព្វាបនាយ អធិមត្តំ ឆន្ទញ្ច វាយាមញ្ច ឧស្សាហញ្ច ឧស្សោឡ្ហិញ្ច អប្បដិវាណិញ្ច សតិញ្ច សម្បជញ្ញញ្ច ករេយ្យ ឯវមេវ ខោ ភិក្ខវេ តេន បុគ្គលេន តេសំយេវ កុសលានំ ធម្មានំ បដិលាភាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវាណី ច សតិ ច សម្បជញ្ញញ្ច ករណីយំ សោ អបរេន សមយេន លាភី ចេវ ហោតិ អជ្ឈត្តំ ចេតោសមថស្ស លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ លាភី ចេវ អជ្ឈត្តំ ចេតោសមថស្ស លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ តេន ភិក្ខវេ បុគ្គលេន តេសុយេវ កុសលេសុ ធម្មេសុ បតិដ្ឋាយ ឧត្តរឹ អាសវានំ ខយាយ យោគោ ករណីយោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

១ ម. តស្សាតិ នត្ថិ ។

ម្នាលភិក្ខុទាំងឡាយ ប្រៀបដូច បុគ្គលមានភ្លើងឆេះសំពត់ឬមានភ្លើងឆេះក្បាល គប្បីធ្វើសេចក្ដីប៉ុនប៉ង សេចក្ដីព្យាយាម សេចក្ដីខ្មីឃ្មាត សេចក្ដីប្រឹងប្រែង សេចក្ដីមិនរួញរា សតិនិងសម្បជញ្ញៈដ៏ក្រៃលែង ដើម្បីលត់នូវសំពត់ឬក្បាលនោះ ៗ ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះគប្បីធ្វើសេចក្ដីប៉ុនប៉ង សេចក្ដីព្យាយាម សេចក្ដីខ្មីឃ្មាត សេចក្ដីប្រឹងប្រែង សេចក្ដីមិនរួញរា សតិនិងសម្បជញ្ញៈដ៏ក្រៃលែង ដើម្បីឲ្យបានសម្រេចនូវកុសលធម៌ទាំងនោះ ក៏ដូច្នោះដែរ លុះសម័យខាងក្រោយមក បុគ្គលនោះរមែងបាននូវចេតោសមថៈ ខាងក្នុងសន្ដានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបុគ្គល ៤ ពួកនោះ បុគ្គលណាបាននូវចេតោសមថៈខាងក្នុងសន្ដានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះ គប្បីតាំងនៅស៊ប់ ក្នុងកុសលធម៌ទាំងនោះ ហើយធ្វើសេចក្ដីព្យាយាម ដើម្បីឲ្យអស់ទៅនៃអាសវៈ តទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[៩៨] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ លាភី ហោតិ អជ្ឈត្តំ ចេតោសមថស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ លាភី ហោតិ អធិប្បញ្ញាធម្មវិបស្សនាយ ន លាភី អជ្ឈត្តំ ចេតោសមថស្ស ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ នេវ លាភី ហោតិ អជ្ឈត្តំ ចេតោសមថស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ លាភី ចេវ ហោតិ អជ្ឈត្តំ ចេតោសមថស្ស លាភី អធិប្បញ្ញាធម្មវិបស្សនាយ ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ លាភី អជ្ឈត្តំ ចេតោសមថស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ តេន ភិក្ខវេ បុគ្គលេន យ្វាយំ បុគ្គលោ លាភី អធិប្បញ្ញាធម្មវិបស្សនាយ សោ ឧបសង្កមិត្វា ឯវមស្ស វចនីយោ កថន្នុ ខោ អាវុសោ សង្ខារា ទដ្ឋព្វា កថំ សង្ខារា សមសិតព្វា កថំ សង្ខារា វិបស្សិតព្វាតិ[១] ។

១ ម. បស្សិតព្វាតិ ។

[៩៤] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បាននូវចេតោសមថៈ ខាងក្នុងសន្តាន តែមិនបាននូវអធិប្បញ្ញាធម្មវិបស្សនា ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បាននូវអធិប្បញ្ញាធម្មវិបស្សនា តែមិនបាននូវចេតោសមថៈ ខាងក្នុងសន្តាន ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបាននូវចេតោសមថៈ ខាងក្នុងសន្តាន ទាំងមិនបាននូវអធិប្បញ្ញាធម្មវិបស្សនា ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបាននូវចេតោសមថៈ ខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាបាននូវចេតោសមថៈ ខាងក្នុងសន្តាន តែមិនបាននូវអធិប្បញ្ញាធម្មវិបស្សនា ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះគប្បីចូលទៅរកបុគ្គលដែលបាននូវអធិប្បញ្ញាធម្មវិបស្សនា ហើយសួរយ៉ាងនេះថា ម្នាលអាវុសោ សង្ខារទាំងឡាយ គេត្រូវឃើញដូចម្តេច សង្ខារទាំងឡាយ គេត្រូវពិចារណាយ៉ាងណា សង្ខារទាំងឡាយ គេត្រូវឃើញច្បាស់ដោយហេតុដូចម្តេច ។

តស្ស សោ យថាទិដ្ឋំ យថាវិទិតំ ព្យាករោតិ ឯវំ ខោ អាវុសោ សង្ខារា ទដ្ឋព្វា ឯវំ សង្ខារា សម្មសិតព្វា ឯវំ សង្ខារា វិបស្សិតព្វាតិ សោ អបរេន សមយេន លាភី ចេវ ហោតិ អជ្ឈត្តំ ចេតោសមថស្ស លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ លាភី អធិប្បញ្ញាធម្មវិបស្សនាយ ន លាភី អជ្ឈត្តំ ចេតោសមថស្ស តេន ភិក្ខវេ បុគ្គលេន យ្វាយំ បុគ្គលោ លាភី អជ្ឈត្តំ ចេតោសមថស្ស សោ ឧបសង្កមិត្វា ឯវមស្ស វចនីយោ កថន្នុ ខោ អាវុសោ ចិត្តំ សណ្ឋាបេតព្វំ កថំ ចិត្តំ សន្និយាទេតព្វំ[១] កថំ ចិត្តំ ឯកោទិកាតព្វំ កថំ ចិត្តំ សមាទហាតព្វន្តិ ។ តស្ស សោ យថាទិដ្ឋំ យថាវិទិតំ ព្យាករោតិ ឯវំ ខោ អាវុសោ ចិត្តំ សណ្ឋាបេតព្វំ ឯវំ ចិត្តំ សន្និយាទេតព្វំ ឯវំ ចិត្តំ ឯកោទិកាតព្វំ ឯវំ ចិត្តំ សមាទហាតព្វន្តិ សោ អបរេន សមយេន លាភី ចេវ ហោតិ អធិប្បញ្ញាធម្មវិបស្សនាយ

១ ម. សន្និសាទេតព្វន្តិ ទិស្សតិ ។

ភិក្ខុនោះក៏ដោះស្រាយ តាមដែលខ្លួនធ្លាប់យល់ តាមដែលខ្លួនធ្លាប់ដឹងមក ចំពោះភិក្ខុនោះថា ម្នាលអាវុសោ សង្ខារទាំងឡាយ គេត្រូវឃើញយ៉ាងនេះ សង្ខារទាំងឡាយ គេត្រូវពិចារណាយ៉ាងនេះ សង្ខារទាំងឡាយ គេត្រូវឃើញច្បាស់យ៉ាងនេះ ឯភិក្ខុនោះ លុះសម័យខាងក្រោយមក រមែងបាននូវចេតោសមថៈ ខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាបាននូវអធិប្បញ្ញាធម្មវិបស្សនា តែមិនបាននូវចេតោសមថៈ ខាងក្នុងសន្តាន ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះគប្បីចូលទៅរកបុគ្គលដែលបាននូវចេតោសមថៈ ខាងក្នុងសន្តាន ហើយសួរយ៉ាងនេះថា ម្នាលអាវុសោ ចិត្តគេត្រូវតម្កល់ដូចម្តេច ចិត្តគេត្រូវពត់ដូចម្តេច ចិត្តគេត្រូវធ្វើឲ្យមានអារម្មណ៍ខ្ពស់ឯកដូចម្តេច ចិត្តគេត្រូវតាំងឲ្យនឹងធឹងដូចម្តេច ។ ភិក្ខុនោះ ក៏ដោះស្រាយតាមដែលខ្លួនធ្លាប់យល់ តាមដែលខ្លួនធ្លាប់ដឹងមក ចំពោះភិក្ខុនោះថា ម្នាលអាវុសោ ចិត្តគេត្រូវតម្កល់យ៉ាងនេះ ចិត្តគេត្រូវពត់យ៉ាងនេះ ចិត្តគេត្រូវធ្វើឲ្យមានអារម្មណ៍ខ្ពស់ឯកយ៉ាងនេះ ចិត្តគេត្រូវតាំងឲ្យនឹងធឹងយ៉ាងនេះ ឯភិក្ខុនោះ លុះសម័យខាងក្រោយមក រមែងបាននូវអធិប្បញ្ញាធម្មវិបស្សនាផង

លាភី ច អជ្ឈត្តំ ចេតោសមថស្ស ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ នេវ លាភី[១] អជ្ឈត្តំ ចេតោសមថស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ តេន ភិក្ខវេ បុគ្គលេន យ្វាយំ បុគ្គលោ លាភី ចេវ អជ្ឈត្តំ ចេតោសមថស្ស លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ សោ ឧបសង្កមិត្វា ឯវមស្ស វចនីយោ កថន្នុ ខោ អាវុសោ ចិត្តំ សណ្ឋាបេតព្វំ កថំ ចិត្តំ សន្និយាទេតព្វំ កថំ ចិត្តំ ឯកោទិកាតព្វំ កថំ ចិត្តំ សមាទហាតព្វំ កថំ សង្ខារា ទដ្ឋព្វា កថំ សង្ខារា សមសិតព្វា កថំ សង្ខារា វិបស្សិតព្វាតិ ។ តស្ស សោ យថាទិដ្ឋំ យថាវិទិតំ ព្យាករោតិ ឯវំ ខោ អាវុសោ ចិត្តំ សណ្ឋាបេតព្វំ ឯវំ ចិត្តំ សន្និយាទេតព្វំ ឯវំ ចិត្តំ ឯកោទិកាតព្វំ ឯវំ ចិត្តំ សមាទហាតព្វំ ឯវំ សង្ខារា ទដ្ឋព្វា ឯវំ សង្ខារា សមសិតព្វា ឯវំ សង្ខារា វិបស្សិតព្វាតិ សោ អបរេន សមយេន លាភី ចេវ ហោតិ អជ្ឈត្តំ ចេតោសមថស្ស

១ ម. ន ចេវ លាភី ។

បាននូវចេតោសមថៈ ខាងក្នុងសន្តានផង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា មិនបាននូវចេតោសមថៈ ខាងក្នុងសន្តានផង ទាំងមិនបាននូវអធិប្បញ្ញាធម្មវិបស្សនាផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះ គប្បីចូលទៅរកបុគ្គលដែលបាននូវចេតោសមថៈខាងក្នុងសន្តាន ទាំងបាននូវអធិប្បញ្ញាធម្មវិបស្សនា ហើយសួរយ៉ាងនេះថា ម្នាលអាវុសោ ចិត្តគេត្រូវតម្កល់ដូចម្ដេច ចិត្តគេត្រូវពត់ដូចម្ដេច ចិត្តគេត្រូវធ្វើឲ្យមានអារម្មណ៍ខ្ពស់ឯកដូចម្ដេច ចិត្តគេត្រូវតាំងឲ្យនឹងធឹងដូចម្ដេច សង្ខារទាំងឡាយ គេត្រូវឃើញដូចម្ដេច សង្ខារទាំង-ឡាយ គេត្រូវពិចារណាដូចម្ដេច សង្ខារទាំងឡាយ គេត្រូវឃើញច្បាស់ដូចម្ដេច ។ ភិក្ខុនោះក៏ដោះស្រាយ តាមដែលខ្លួនធ្លាប់យល់តាមដែលខ្លួនធ្លាប់ដឹងមក ចំពោះភិក្ខុនោះថា ម្នាលអាវុសោ ចិត្តគេត្រូវតម្កល់យ៉ាងនេះ ចិត្តគេត្រូវពត់យ៉ាងនេះ ចិត្តគេត្រូវធ្វើឲ្យមានអារម្មណ៍ខ្ពស់ឯកយ៉ាងនេះ ចិត្តគេត្រូវតាំងឲ្យនឹងធឹងយ៉ាងនេះ សង្ខារទាំងឡាយគេត្រូវឃើញយ៉ាងនេះ សង្ខារទាំងឡាយ គេត្រូវពិចារណាយ៉ាងនេះសង្ខារទាំងឡាយ គេត្រូវឃើញច្បាស់យ៉ាងនេះ ភិក្ខុនោះ លុះសម័យខាងក្រោយមក រមែងបាននូវចេតោសមថៈ ខាងក្នុងសន្តានផង

លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ លាភី ចេវ អជ្ឈត្តំ ចេតោសមថស្ស លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ តេន ភិក្ខវេ បុគ្គលេន តេសុយេវ កុសលេសុ ធម្មេសុ បតិដ្ឋាយ ឧត្តរឹ អាសវានំ ខយាយ យោគោ ករណីយោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[៩៦] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ នេវ អត្តហិតាយ បដិបន្នោ នោ បរហិតាយ បរហិតាយ បដិបន្នោ នោ អត្តហិតាយ អត្តហិតាយ បដិបន្នោ នោ បរហិ-តាយ អត្តហិតាយ ច បដិបន្នោ បរហិតាយ ច ។ សេយ្យថាបិ ភិក្ខវេ ឆវាលាតំ ឧភតោ បទិត្តំ មជ្ឈេ គូថគតំ នេវ គាមេ កដ្ឋត្ថំ ផរតិ ន អរញ្ញេ កដ្ឋត្ថំ ផរតិ

បានទូវអធិប្បញ្ញាធម្មវិបស្សនាផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គល ទាំង ៤ ពួកនោះ បុគ្គលណា បានទូវចេតោសមថៈ ខាងក្នុងសន្តានផង បានទូវអធិប្បញ្ញាធម្មវិបស្សនាផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះ គប្បីតាំងនៅ ក្នុងធម៌ជាកុសលទាំងនោះ ហើយធ្វើសេចក្តីព្យាយាម ដើម្បីឲ្យអស់អាសវៈ តទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[៩៦] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលប្រតិបត្តិ ដើម្បី ប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ១ បុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គល ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ ។ ម្នាល ភិក្ខុទាំងឡាយ ប្រៀបដូចអង្កត់ឧសដុតខ្មោច ដែលភ្លើងឆេះរន្ទាលទាំង សងខាង មានលាមកប្រឡាក់ត្រង់កណ្តាល រមែងមិនសម្រេចជាឧសក្នុង ស្រុកបាន ទាំងមិនសម្រេចជាឧសក្នុងព្រៃបាន មានឧបមាយ៉ាងណាមិញ

តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ យ្វាយំ បុគ្គលោ នេវ អត្តហិតាយ បដិបន្នោ នោ បរហិតាយ ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ បរហិតាយ បដិបន្នោ នោ អត្តហិតាយ អយំ ឥមេសំ ទ្វិន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ អត្តហិតាយ បដិបន្នោ នោ បរហិតាយ អយំ ឥមេសំ តិណ្ណំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ អត្តហិតាយ ច បដិបន្នោ បរហិតាយ ច អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អគ្គោ ច សេដ្ឋោ ច បាមោក្ខោ ច ឧត្តមោ ច បវរោ ច សេយ្យថាបិ ភិក្ខវេ គវា ខីរំ ខីរម្ហា ទធិ ទធិម្ហា នវនីតំ នវនីតម្ហា សប្បិ សប្បិម្ហា សប្បិមណ្ឌោ សប្បិមណ្ឌោ[១] តត្ថ អគ្គមក្ខាយតិ

១ ឱ. ម. អយំ បាហោ នត្ថិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ជាអ្នកមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា ប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន បណ្ដាបុគ្គលទាំងពីរនេះ បុគ្គលនេះចាត់ថា ល្អជាង ប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា ជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ បណ្ដាបុគ្គលទាំងបីនេះ បុគ្គលនេះចាត់ថាល្អជាង ប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង បណ្ដាបុគ្គលទាំង ៤ នេះ បុគ្គលនេះចាត់ថា ជាអ្នកលើសលុប ជាចំបង ជាប្រធាន ឧត្តម ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចទឹកដោះស្រស់ ចេញមកអំពីមេគោ ទឹកដោះជូរក្លាយមកអំពីទឹកដោះស្រស់ ទឹកដោះខាប់ក្លាយមកអំពីទឹកដោះជូរ ទឹកដោះថ្លា ក្លាយមកអំពីទឹកដោះខាប់ ដុំនៃទឹកដោះថ្លា ក្លាយមកអំពីទឹកដោះថ្លា បណ្ដាទឹកដោះទាំងនោះ ដុំនៃទឹកដោះថ្លា ប្រាកដថា ប្រសើរជាង យ៉ាងណាមិញ

ឯវមេវ ខោ ភិក្ខវេ យ្វាយំ អត្តហិតាយ ច បដិបន្នោ បរហិតាយ ច អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អគ្គោ ច សេដ្ឋោ ច បាមោក្ខោ ច ឧត្តមោ ច បវរោ ច ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[៩៧] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ អត្តហិតាយ បដិបន្នោ នោ បរហិតាយ បរហិតាយ បដិបន្នោ នោ អត្តហិតាយ នេវ អត្តហិតាយ បដិបន្នោ នោ បរហិតាយ អត្តហិតាយ ច បដិបន្នោ បរហិតាយ ច ។ កថញ្ច ភិក្ខវេ បុគ្គលោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អត្តនា រាគវិនយាយ បដិបន្នោ ហោតិ នោ បរំ រាគវិនយាយ សមាទបេតិ អត្តនា ទោសវិនយាយ បដិបន្នោ ហោតិ នោ បរំ ទោសវិនយាយ សមាទបេតិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង បណ្តាបុគ្គលទាំង ៤ នេះ បុគ្គលនេះ ចាត់ថាជាអ្នកលើសលុប ជាចំបង ជាប្រធាន ឧត្តម ប្រសើរ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[៩៧] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ១ បុគ្គលមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រតិបត្តិ ដើម្បីកម្ចាត់បង់រាគៈចំពោះខ្លួន តែមិនបបួលបុគ្គលដទៃ (ឲ្យប្រតិបត្តិ) ដើម្បីកម្ចាត់បង់រាគៈ ជាអ្នកប្រតិបត្តិ ដើម្បីកម្ចាត់បង់ទោសៈ ចំពោះខ្លួន តែមិនបបួលបុគ្គលដទៃ (ឲ្យប្រតិបត្តិ) ដើម្បីកម្ចាត់បង់ទោសៈ

អត្តនា មោហវិនយាយ បដិបន្នោ ហោតិ នោ បរំ មោហវិនយាយ សមាទបេតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ កថញ្ច ភិក្ខវេ បុគ្គលោ បរហិតាយ បដិបន្នោ ហោតិ នោ អត្តហិតាយ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អត្តនា ន រាគវិនយាយ បដិបន្នោ ហោតិ បរំ រាគវិនយាយ សមាទបេតិ អត្តនា ន ទោសវិនយាយ បដិបន្នោ ហោតិ បរំ ទោសវិនយាយ សមាទបេតិ អត្តនា ន មោហវិនយាយ បដិបន្នោ ហោតិ បរំ មោហវិនយាយ សមាទបេតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ បរហិតាយ បដិបន្នោ ហោតិ នោ អត្តហិតាយ ។ កថញ្ច ភិក្ខវេ បុគ្គលោ នេវ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អត្តនា ន រាគវិនយាយ បដិបន្នោ ហោតិ នោ បរំ រាគវិនយាយ សមាទបេតិ អត្តនា ន ទោសវិនយាយ បដិបន្នោ ហោតិ

ជាអ្នកប្រតិបត្តិ ដើម្បីកម្ចាត់បង់មោហៈចំពោះខ្លួន មិនបបួលបុគ្គលដទៃ (ឲ្យប្រតិបត្តិ) ដើម្បីកម្ចាត់បង់មោហៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនប្រតិបត្តិ ដើម្បីកម្ចាត់រាគៈចំពោះខ្លួន តែបបួលបុគ្គលដទៃ (ឲ្យប្រតិបត្តិ) ដើម្បីកម្ចាត់បង់រាគៈ មិនប្រតិបត្តិ ដើម្បីកម្ចាត់បង់ទោសៈចំពោះខ្លួន តែបបួលបុគ្គលដទៃ (ឲ្យប្រតិបត្តិ) ដើម្បីកំ-ចាត់បង់ទោសៈ មិនប្រតិបត្តិ ដើម្បីកម្ចាត់បង់មោហៈ ចំពោះខ្លួន តែបបួលបុគ្គលដទៃ (ឲ្យប្រតិបត្តិ) ដើម្បីកម្ចាត់បង់មោហៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនប្រតិបត្តិ ដើម្បីកម្ចាត់បង់រាគៈចំពោះខ្លួន ទាំងមិនបបួលបុគ្គលដទៃ (ឲ្យប្រតិបត្តិ) ដើម្បីកម្ចាត់បង់រាគៈ មិនប្រតិបត្តិ ដើម្បីកម្ចាត់បង់ទោសៈចំពោះខ្លួន

## ២៣៩



នោ បរំ ទោសវិនយាយ សមាទបេតិ អត្តនា ច មោហវិនយាយ បដិបន្នោ ហោតិ នោ បរំ មោហវិនយាយ សមាទបេតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ នេវ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ កថញ្ច ភិក្ខវេ បុគ្គលោ អត្តហិតាយ ច បដិបន្នោ ហោតិ បរហិតាយ ច ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អត្តនា ច រាគវិនយាយ បដិបន្នោ ហោតិ បរញ្ច រាគវិនយាយ សមាទបេតិ អត្តនា ច ទោសវិនយាយ បដិបន្នោ ហោតិ បរញ្ច ទោសវិនយាយ សមាទបេតិ អត្តនា ច មោហវិនយាយ បដិបន្នោ ហោតិ បរញ្ច មោហវិនយាយ សមាទបេតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ អត្តហិតាយ ច បដិបន្នោ ហោតិ បរហិតាយ ច ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

ទាំងមិនបបួលបុគ្គលដទៃ (ឲ្យប្រតិបត្តិ) ដើម្បីកម្ចាត់បង់ទោសៈ ជាអ្នកមិនប្រតិបត្តិ ដើម្បីកម្ចាត់បង់មោហៈចំពោះខ្លួន ទាំងមិនបបួលបុគ្គលដទៃ (ឲ្យប្រតិបត្តិ) ដើម្បីកម្ចាត់បង់មោហៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រតិបត្តិ ដើម្បីកម្ចាត់បង់រាគៈចំពោះខ្លួនផង បបួលអ្នកដទៃ (ឲ្យប្រតិបត្តិ) ដើម្បីកំចាត់បង់រាគៈផង ជាអ្នកប្រតិបត្តិ ដើម្បីកម្ចាត់បង់ទោសៈចំពោះខ្លួនផង បបួលអ្នកដទៃ (ឲ្យប្រតិបត្តិ) ដើម្បីកម្ចាត់បង់ទោសៈផង ជាអ្នកប្រតិ-បត្តិ ដើម្បីកម្ចាត់បង់មោហៈចំពោះខ្លួនផង បបួលបុគ្គលដទៃ (ឲ្យប្រតិបត្តិ) ដើម្បីកម្ចាត់បង់មោហៈផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[៩៨] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ អត្តហិតាយ បដិបន្នោ នោ បរហិតាយ បរហិតាយ បដិបន្នោ នោ អត្តហិតាយ នេវ អត្តហិតាយ បដិបន្នោ នោ បរហិតាយ អត្តហិតាយ ច បដិបន្នោ បរហិតាយ ច ។ កថញ្ច ភិក្ខវេ បុគ្គលោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារកជាតិកោ ហោតិ ធតានញ្ច ធម្មានំ អត្ថុបបរិក្ខី ហោតិ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ នោ ច កល្យាណវាចោ ហោតិ កល្យាណវាក្ករណោ ចោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា នោ ច សព្រហ្មចារីនំ ។ សន្ទស្សកោ ហោតិ សមាទបកោ សមុត្តេជកោ សម្បហំសកោ

[៩៨] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួកតើដូចម្តេចខ្លះ ។ គឺបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ១ បុគ្គលមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ អាចដឹងឆាប់ក្នុងកុសលធម៌ទាំងឡាយ ជាអ្នកចងចាំនូវធម៌ ដែលខ្លួនបានស្តាប់មកផង ជាអ្នកត្រិះរិះនូវសេចក្តីនៃធម៌ ដែលខ្លួនចងចាំមកផង ជាអ្នកដឹងនូវអដ្ឋកថា ដឹងនូវបាលី ហើយប្រតិបត្តិ នូវធម៌ដ៏សមគួរដល់ធម៌ផង តែជាអ្នកមានពាក្យមិនពីរោះ មិនបញ្ចេញនូវពាក្យដែលពីរោះ មិនប្រកបដោយពាក្យអ្នកក្រុង មិនពន្យល់ មិនបបួល មិនធ្វើឲ្យក្លាហាន មិនធ្វើឲ្យរីករាយដល់សព្រហ្មចារីបុគ្គលទាំងឡាយ ដោយពាក្យដែលប្រាសចាកសេចក្តីរង្កៀស ជាពាក្យឥតទោស ជាពាក្យពន្យល់នូវសេចក្តី ។

២៤១



ឯវំ ខោ ភិក្ខវេ បុគ្គលោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ កថញ្ច ភិក្ខវេ បុគ្គលោ បរហិតាយ បដិបន្នោ ហោតិ នោ អត្តហិតាយ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ន ហេវ ខោ ខិប្បនិសន្តិ ហោតិ កុសលេសុ ធម្មេសុ នោ ច សុតានំ ធម្មានំ ធារកជាតិកោ ហោតិ នោ ច ធាតានំ ធម្មានំ អត្ថុបបរិក្ខី ហោតិ នោ ច អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ កល្យាណវាចោ ច ហោតិ កល្យាណវាក្ករណោ បោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា សន្ទស្សកោ ច ហោតិ សមាទបកោ សមុត្តេជកោ សម្បហំសកោ សព្រហ្មចារីនំ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ បរហិតាយ បដិបន្នោ ហោតិ នោ អត្តហិតាយ ។ កថញ្ច ភិក្ខវេ បុគ្គលោ នេវ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនអាចដឹងឆាប់ ក្នុងកុសលធម៌ទាំងឡាយផង ជាអ្នកមិនចងចាំនូវធម៌ដែលខ្លួនបានស្តាប់មកផង ជាអ្នកមិនត្រិះរិះសេចក្តីនៃធម៌ដែលខ្លួនចងចាំមកផង ជាអ្នកមិនដឹងនូវអដ្ឋកថា មិនដឹងនូវបាលី ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ផង តែជាអ្នកមានពាក្យពីរោះ បញ្ចេញនូវពាក្យពីរោះ ប្រកបដោយពាក្យអ្នកក្រុង ជាអ្នកពន្យល់ បបួល ធ្វើឲ្យក្លាហានធ្វើឲ្យរីករាយ ដល់សព្រហ្មចារីបុគ្គលទាំងឡាយ ដោយពាក្យដែលប្រាសចាកសេចក្តីរង្អៀស ជាពាក្យឥតទោស ជាពាក្យពន្យល់នូវសេចក្តី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ

នហេវ ខោ ខិប្បនិសន្តី ហោតិ កុសលេសុ ធម្មេសុ នោ ច សុតានំ ធម្មានំ ធារកជាតិកោ ហោតិ នោ ច ធតានំ ធម្មានំ អត្ថុបបរិក្ខី ហោតិ នោ ច អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ នោ ច កល្យាណវាចោ ហោតិ កល្យាណវាក្ករណោ បោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា នោ ច សន្ទស្សកោ ហោតិ សមាទបកោ សមុត្តេជកោ សម្បហំសកោ សព្រហ្មចារីនំ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ នេវ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ កតមោ ច ភិក្ខវេ បុគ្គលោ អត្តហិតាយ ច បដិបន្នោ ហោតិ បរហិតាយ ច ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ខិប្បនិសន្តី ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារកជាតិកោ ហោតិ ធតានញ្ច ធម្មានំ អត្ថុបបរិក្ខី ហោតិ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ

ជាអ្នកមិនអាចដឹងឆាប់ ក្នុងកុសលធម៌ផង ជាអ្នកមិនអាចចងចាំនូវធម៌ ដែលខ្លួនបានស្តាប់មកផង ជាអ្នកមិនត្រិះរិះនូវសេចក្តីនៃធម៌ ដែលខ្លួនចងចាំមកផង ជាអ្នកមិនដឹងនូវអដ្ឋកថា មិនដឹងនូវបាលី ហើយមិនប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ផង ទាំងជាអ្នកមិនមានពាក្យពីរោះ មិនបញ្ចេញនូវពាក្យពីរោះ មិនប្រកបដោយពាក្យរបស់អ្នកក្រុង មិនពន្យល់ មិនបបួល មិនធ្វើឲ្យក្លាហាន មិនធ្វើឲ្យរីករាយ ដល់សព្រហ្មចារីបុគ្គលទាំងឡាយ ដោយពាក្យប្រាសចាកសេចក្តីរង្គៀស ជាពាក្យឥតទោស ជាពាក្យពន្យល់នូវសេចក្តី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកអាចដឹងឆាប់ក្នុងកុសលធម៌ផង ជាអ្នកចងចាំនូវធម៌ ដែលខ្លួនបានស្តាប់មកផង ជាអ្នកត្រិះរិះនូវសេចក្តីនៃធម៌ ដែលខ្លួនចងចាំមកផង ជាអ្នកដឹងនូវអដ្ឋកថា ដឹងនូវបាលី ហើយប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ផង

កល្យាណវាចោ ហោតិ កល្យាណវាក្ករណោ ចោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា សន្ទ-ស្សកោ ច ហោតិ សមាទបកោ សមុត្តេជកោ សម្បហំសកោ សព្រហ្មចារីនំ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ អត្តហិតាយ ច បដិបន្នោ ហោតិ បរហិ-តាយ ច ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[៩៩] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ អត្តហិតាយ បដិបន្នោ នោ បរហិតាយ បរហិតាយ បដិបន្នោ នោ អត្តហិតាយ នេវ អត្តហិតាយ បដិបន្នោ នោ បរហិតាយ អត្តហិតាយ ច បដិបន្នោ បរហិតាយ ច ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

ជាអ្នកមានពាក្យពីរោះ បញ្ចេញនូវពាក្យពីរោះ ប្រកបដោយពាក្យរបស់អ្នកក្រុង ជាអ្នកពន្យល់ បបួល ធ្វើឲ្យក្លាហាន ធ្វើឲ្យរីករាយដល់សព្រហ្មចារីបុគ្គលទាំងឡាយ ដោយពាក្យប្រាសចាកសេចក្តីរង្កៀស ជាពាក្យឥតទោស ជាពាក្យពន្យល់នូវសេចក្តី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[៩៩] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ១ បុគ្គលអ្នកមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនទាំងមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[១០០] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ អត្តហិតាយ បដិបន្នោ នោ បរហិតាយ បរហិតាយ បដិបន្នោ នោ អត្តហិតាយ នេវ អត្តហិតាយ បដិបន្នោ នោ បរហិតាយ អត្តហិតាយ ច បដិបន្នោ បរហិតាយ ច ។ កថញ្ច ភិក្ខវេ បុគ្គលោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អត្តនា បាណាតិបាតា បដិវិរតោ ហោតិ នោ បរំ បាណាតិបាតា វេរមណិយា សមាទបេតិ អត្តនា អទិន្នាទានា បដិវិរតោ ហោតិ នោ បរំ អទិន្នាទានា វេរមណិយា សមាទបេតិ អត្តនា កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ នោ បរំ កាមេសុ មិច្ឆាចារា វេរមណិយា សមាទបេតិ អត្តនា មុសាវាទា បដិវិរតោ ហោតិ នោ បរំ មុសាវាទា វេរមណិយា សមាទបេតិ អត្តនា សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ នោ បរំ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណិយា សមាទបេតិ ។

[១០០] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ១ បុគ្គលអ្នកមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាតចំពោះខ្លួន តែមិនបបួលអ្នកដទៃ ឲ្យវៀរចាកបាណាតិបាត ជាអ្នកវៀរចាកអទិន្នាទានចំពោះខ្លួន តែមិនបបួលអ្នកដទៃ ឲ្យវៀរចាកអទិន្នាទាន ជាអ្នកវៀរចាកកាមេសុមិច្ឆាចារចំពោះខ្លួន តែមិនបបួលអ្នកដទៃ ឲ្យវៀរចាកកាមេសុមិច្ឆាចារ ជាអ្នកវៀរចាកមុសាវាទចំពោះខ្លួន តែមិនបបួលអ្នកដទៃ ឲ្យវៀរចាកមុសាវាទ ជាអ្នកវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យចំពោះខ្លួន តែមិនបបួលអ្នកដទៃ ឲ្យវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

ឯវំ ខោ ភិក្ខវេ បុគ្គលោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ កថញ្ច ភិក្ខវេ បុគ្គលោ បរហិតាយ បដិបន្នោ ហោតិ នោ អត្តហិតាយ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អត្តនា បាណាតិបាតា អប្បដិវិរតោ ហោតិ បរំ បាណាតិបាតា វេរមណិយា សមាទបេតិ ។ បេ ។ អត្តនា សុរាមេរយមជ្ជប្បមា-ទដ្ឋានា អប្បដិវិរតោ ហោតិ បរំ សុរាមេរយមជ្ជប្បមា-ទដ្ឋានា វេរមណិយា សមាទបេតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ បរហិតាយ បដិបន្នោ ហោតិ នោ អត្តហិ-តាយ ។ កថញ្ច ភិក្ខវេ បុគ្គលោ នេវ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អត្តនា បាណាតិបាតា អប្បដិវិរតោ ហោតិ នោ បរំ បាណាតិបាតា វេរមណិយា សមា-ទបេតិ ។ បេ ។ អត្តនា សុរាមេរយមជ្ជប្បមាទដ្ឋានា អប្បដិវិរតោ ហោតិ នោ បរំ សុរាមេរយ-មជ្ជប្បមាទដ្ឋានា វេរមណិយា សមាទបេតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនវៀរចាកបាណាតិបាតចំពោះខ្លួន តែបបួលអ្នកដទៃ ឲ្យវៀរចាកបាណាតិបាត ។ បេ ។ ជាអ្នកមិនវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ចំពោះខ្លួន តែបបួលអ្នកដទៃ ឲ្យវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនវៀរចាកបាណាតិបាតចំពោះខ្លួន ទាំងមិនបបួលអ្នកដទៃ ឲ្យវៀរចាកបាណាតិបាត ។ បេ ។ ជាអ្នកមិនវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ចំពោះខ្លួន ទាំងមិនបបួលអ្នកដទៃ ឲ្យវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

ឯវំ ខោ ភិក្ខវេ បុគ្គលោ នេវ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ កតមញ្ច ភិក្ខវេ បុគ្គលោ អត្តហិតាយ ច បដិបន្នោ ហោតិ បរហិតាយ ច ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អត្តនា ច បាណាតិបាតា បដិវិរតោ ហោតិ បរញ្ច បាណាតិបាតា វេរមណិយា សមាទបេតិ អត្តនា ច អទិន្នាទានា បដិវិរតោ ហោតិ បរញ្ច អទិន្នាទានា វេរមណិយា សមាទបេតិ អត្តនា ច កាមេសុ មិច្ឆា-ចារា បដិវិរតោ ហោតិ បរញ្ច កាមេសុ មិច្ឆាចារា វេរមណិយា សមាទបេតិ អត្តនា ច មុសាវាទា បដិ-វិរតោ ហោតិ បរញ្ច មុសាវាទា វេរមណិយា សមា-ទបេតិ អត្តនា ច សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ បរញ្ច សុរាមេរយមជ្ជប្បមាទដ្ឋានា វេរម-ណិយា សមាទបេតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ អត្តហិតាយ ច បដិបន្នោ ហោតិ បរហិតាយ ច ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជ-មានា លោកស្មិន្តិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាតចំពោះខ្លួនផង បបួលអ្នកដទៃ ឲ្យវៀរចាកបាណាតិបាតផង វៀរចាកអទិន្នាទានចំពោះខ្លួនផង បបួលអ្នកដទៃ ឲ្យវៀរចាកអទិន្នាទានផង វៀរចាកកាមេសុមិច្ឆាចារ ចំពោះខ្លួនផង បបួលបុគ្គលដទៃ ឲ្យវៀរចាកកាមេសុមិច្ឆាចារផង វៀរចាកមុសាវាទចំពោះខ្លួនផង បបួលបុគ្គលដទៃ ឲ្យវៀរចាកមុសាវាទផង វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ចំពោះខ្លួនផង បបួលអ្នកដទៃ ឲ្យវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[១០១] អថខោ ចោតលិយោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ចោតលិយំ បរិព្វាជកំ ភគវា ឯតទវោច ចត្តារោមេ ចោតលិយ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ចោតលិយ ឯកច្ចោ បុគ្គលោ អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន នោ ច ខោ វណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន ឥធ បន ចោតលិយ ឯកច្ចោ បុគ្គលោ វណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន នោ ច ខោ អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន ឥធ បន ចោតលិយ ឯកច្ចោ បុគ្គលោ នេវ អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន

ទុតិយបណ្ណាសក អសុរវគ្គ

[១០១] គ្រានោះឯង បោតលិយបរិព្វាជក បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ កាលបោតលិយបរិព្វាជកអង្គុយក្នុងទីសមគួរស៊ប់ហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលបោតលិយៈ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួកនេះ តើដូចម្តេចខ្លះ ។ ម្នាលបោតលិយៈ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលនូវពាក្យតិះដៀលចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរ តែមិនពោលនូវពាក្យសរសើរចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរ ១ ម្នាលបោតលិយៈ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរ តែមិនពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរ ១ ម្នាលបោតលិយៈ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរផង

នោបិ វណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន ឥធ បន បោតលិយ ឯកច្ចោ បុគ្គលោ អវណ្ណារហស្ស ច អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន វណ្ណារហស្ស ច វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន ។ ឥមេ ខោ បោតលិយ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឥមេសំ ខោ បោតលិយ ចតុន្នំ បុគ្គលានំ កតមោ តេ បុគ្គលោ ខមតិ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ ចត្តារោ ភោ គោតម បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភោ គោតម ឯកច្ចោ បុគ្គលោ អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន នោ ច ខោ វណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន ឥធ បន ភោ គោតម ឯកច្ចោ បុគ្គលោ វណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន នោ ច ខោ អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន

មិនពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរផង ១ ម្នាលបោតលិយៈ បុគ្គលពួកខ្លះ ក្នុងលោកនេះជាអ្នកពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរផង ពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរផង ១ ។ ម្នាលបោតលិយៈ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ ម្នាលបោតលិយៈ បណ្តាបុគ្គលទាំង ៤ ពួកនេះ តើបុគ្គលដូចម្តេច ដែលល្អជាងផង ប្រសើរជាងផង រមែងគាប់ចិត្តដល់អ្នក ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលនូវពាក្យតិះដៀលចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរ តែមិនពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរ ១ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរ តែមិនពោលពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរ ១

ឥធ បន ភោ គោតម ឯកច្ចោ បុគ្គលោ នេវ អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន នោបិ វណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន ឥធ បន ភោ គោតម ឯកច្ចោ បុគ្គលោ អវណ្ណារហស្ស ច អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន វណ្ណារហស្ស ច វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន ។ ឥមេ ខោ ភោ គោតម ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឥមេសំ ខោ ភោ គោតម ចតុន្នំ បុគ្គលានំ យ្វាយំ បុគ្គលោ នេវ អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន នោបិ វណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន អយំ មេ បុគ្គលោ ខមតិ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីត-តរោ ច ។ តំ កិស្ស ហេតុ ។ អភិក្កន្តា[១] ហេសា ភោ គោតម យទិទំ ឧបេក្ខាតិ ។ ចត្តារោមេ ចោតលិយ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។

១ ម. អភិក្កន្តតរា ។

បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនពោលនូវពាក្យតិះដៀលចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរផង មិនពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរផង ១ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរផង ពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរផង ១ ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលទាំង ៤ ពួកនេះឯង រមែងមាននៅក្នុងលោក ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលណា មិនពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរផង មិនពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរផង បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះល្អជាងផង ប្រសើរជាងផង រមែងគាប់ចិត្តដល់ខ្ញុំព្រះអង្គ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រោះឧបេក្ខានោះ ជាគុណជាតិដ៏ល្អ ។ ម្នាលបោតលិយៈ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

កតមេ ចត្តារោ ។ បេ ។ ឥមេ ខោ ចោតលិយ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឥមេសំ ខោ ចោតលិយ ចតុន្នំ បុគ្គលានំ យ្វាយំ បុគ្គលោ អវណ្ណារហស្ស ច អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន វណ្ណារហស្ស ច វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច ។ តំ កិស្ស ហេតុ ។ អភិក្កន្តា ហេសា ចោតលិយ យទិទំ តត្រ តត្រ កាលញ្ញុតាតិ ។ ចត្តារោមេ ភោ គោតម បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភោ គោតម ឯកច្ចោ បុគ្គលោ អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន នោ ច ខោ វណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន ឥធ បន ភោ គោតម ឯកច្ចោ បុគ្គលោ

បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ បេ ។ ម្នាលបោតលិយៈ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ ម្នាលបោតលិយៈ បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលណា ពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរផង ពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរផង បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះល្អជាងផង ប្រសើរជាងផង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលបោតលិយៈ ព្រោះថា ការដឹងនូវកាលដ៏សមគួរក្នុងហេតុនោះ ៗ នោះចាត់ថាជាការល្អ ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គលទាំង ៤ ពួក តើដូចម្តេចខ្លះ ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរ តែមិនពោលពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរ ១ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ

២៤១



វណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន នោ ច ខោ អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន ឥធ បន ភោ គោតម ឯកច្ចោ បុគ្គលោ នេវ អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន នោបិ វណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន ឥធ បន ភោ គោតម ឯកច្ចោ បុគ្គលោ អវណ្ណារហស្ស ច អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន វណ្ណារហស្ស ច វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន ។ ឥមេ ខោ ភោ គោតម ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឥមេសំ ខោ ភោ គោតម ចតុន្នំ បុគ្គលានំ យ្វាយំ បុគ្គលោ អវណ្ណារហស្ស ច អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន

ជាអ្នកពោលសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែន ដោយកាលគួរ តែមិនពោលតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរ ១ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិតពាក្យមែនដោយកាលគួរផង មិនពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរផង ១ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរផង ពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរផង ១ ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលណា ពោលនូវពាក្យតិះដៀល ចំពោះបុគ្គលដែលគួរតិះដៀល ជាពាក្យពិត ពាក្យមែនដោយកាលគួរផង

វណ្ណារហស្ស ច វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន អយំ មេ បុគ្គលោ ខមតិ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច ។ តំ កិស្ស ហេតុ ។ អភិក្កន្តា ហេសា ភោ គោតម យទិទំ តត្រ តត្រ កាលញ្ញុតា ។ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ។ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

អសុរវគ្គោ បញ្ចមោ ។

ពោលនូវពាក្យសរសើរ ចំពោះបុគ្គលដែលគួរសរសើរ ជាពាក្យពិត ពាក្យមែនដោយកាលគួរផង បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះ ចាត់ថាល្អជាងផង ប្រសើរជាងផង រមែងគាប់ចិត្តដល់ខ្ញុំព្រះអង្គ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថា ការដឹងកាលដ៏សមគួរក្នុងហេតុនុ៎ះ ៗ នោះចាត់ថាជាការល្អ ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន សម្តែងដោយអនេកបរិយាយយ៉ាងនេះ ភ្លឺច្បាស់ណាស់ ឧបមាដូចបុគ្គលផ្ងារនូវរបស់ដែលគេផ្កាប់ ឬបើកនូវរបស់ដែលកំបាំង ឬបង្ហាញផ្លូវដល់បុគ្គលអ្នកវង្វេងទិស ពុំនោះសោតដូចគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹតដោយបំណងថា អ្នកមានភ្នែកភ្លឺ រមែងមើលឃើញនូវរូបទាំងឡាយបាន ។ ខ្ញុំព្រះអង្គ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកអ្នកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើម តាំងអំពីថ្ងៃនេះជាដើមទៅ ។

ចប់ អសុរវគ្គទី ៥ ។

២៤៣

ទុតិយបណ្ណាសកេ អសុរវគ្គោ

# គស្សុទ្ធានំ

អសុរោ តយោ សមាធី[១]

ឆវាលាតេន បញ្ចមំ

រាគានំ សន្តិ អត្តហិតាយ

សិក្ខា[២] ចោតលិយេន ចាតិ[៣] ។

ទុតិយោ បណ្ណាសកោ និដ្ឋិតោ ។

---

១ ម. សមាធិ ច ។ ២ ឱ. សន្តិ អត្តហិតា សិក្ខា ។ ៣ ឱ. ម. តេទសាតិ ។

# ឧទ្ទាននៃអសុរវគ្គនោះគឺ

*បុគ្គលជាអសុរ មានអសុរ ជាបរិវារជាដើម ១ បុគ្គលបាននូវចេតោសមថៈ ជាដើមមាន ៣ លើក បុគ្គល ៤ ពួក មានសេចក្តីប្រៀបដោយអង្កត់ឧស ជាគម្រប់ប្រាំ ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីកម្ចាត់រាគៈ ជាដើម ១ បុគ្គលអាចដឹងឆាប់ ក្នុងកុសលធម៌ជាដើម ១ អ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនជាដើម ១ បុគ្គលអ្នកប្រតិបត្តិ តាមសិក្ខាបទ ៥ ជាដើម ១ បោតលិយបរិញ្ញាជក ១ ។*

ចប់ បណ្ណាសក ទី ២ ។

# តតិយបណ្ណាសកោ

## វលាហកវគ្គោ

[១០២] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ចត្តារោមេ ភិក្ខវេ វលាហកា ។ កតមេ ចត្តារោ ។ គជ្ជិតា នោ វស្សិតា វស្សិតា នោ គជ្ជិតា នេវ គជ្ជិតា នោ វស្សិតា គជ្ជិតា ច វស្សិតា ច ។ ឥមេ ខោ ភិក្ខវេ ចត្តារោ វលាហកា ។ ឯវមេវ ខោ ភិក្ខវេ ចត្តារោមេ[១] វលាហកូបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ គជ្ជិតា នោ វស្សិតា វស្សិតា នោ គជ្ជិតា នេវ គជ្ជិតា នោ វស្សិតា គជ្ជិតា ច វស្សិតា ច ។ កថញ្ច ភិក្ខវេ បុគ្គលោ គជ្ជិតា ហោតិ នោ វស្សិតា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ភាសិតា ហោតិ នោ កត្តា

១ ម. មេសទ្វោ ន ហោតិ ។

# តតិយបណ្ណាសក

## វលាហកវគ្គ

[១០២] សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មេឃនេះមាន ៤ យ៉ាង ។ មេឃ ៤ យ៉ាងដូចម្តេចខ្លះ ។ គឺមេឃគ្រហឹម ឥតភ្លៀង ១ មេឃបង្អុរភ្លៀង ឥតគ្រហឹម ១ មេឃទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង ១ មេឃគ្រហឹមផង បង្អុរភ្លៀងផង ១ ។ ម្នាលភិក្ខុទាំងឡាយ មេឃមាន ៤ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលឧបមាដោយមេឃនេះមាន ៤ ពួក រមែងមាននៅក្នុងលោកដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលជាអ្នកគ្រហឹម ឥតបង្អុរភ្លៀង ១ បង្អុរភ្លៀង ឥតគ្រហឹម ១ ទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង ១ គ្រហឹមផង បង្អុរភ្លៀងផង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកគ្រហឹម ឥតបង្អុរភ្លៀង តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបានតែនិយាយ តែមិនធ្វើ

ឯវំ ខោ ភិក្ខវេ បុគ្គលោ គជ្ជិតា ហោតិ នោ វស្សិតា ។ សេយ្យថាបិ សោ ភិក្ខវេ វលាហកោ គជ្ជិតា នោ វស្សិតា តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ វស្សិតា ហោតិ នោ គជ្ជិតា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ កត្តា ហោតិ នោ ភាសិតា ឯវំ ខោ ភិក្ខវេ បុគ្គលោ វស្សិតា ហោតិ នោ គជ្ជិតា ។ សេយ្យថាបិ សោ ភិក្ខវេ វលាហកោ វស្សិតា នោ គជ្ជិតា តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ នេវ គជ្ជិតា ហោតិ នោ វស្សិតា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ នេវ ភាសិតា ហោតិ នោ កត្តា ឯវំ ខោ ភិក្ខវេ បុគ្គលោ នេវ គជ្ជិតា ហោតិ នោ វស្សិតា ។ សេយ្យថាបិ សោ ភិក្ខវេ វលាហកោ នេវ គជ្ជិតា នោ វស្សិតា តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ គជ្ជិតា ច ហោតិ វស្សិតា ច ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកគ្រហឹម ឥតបង្អុរភ្លៀង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះគ្រហឹម ឥតបង្អុរភ្លៀង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកបង្អុរភ្លៀង ឥតគ្រហឹម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកធ្វើ តែមិននិយាយ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកបង្អុរភ្លៀង ឥតគ្រហឹម យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះបង្អុរភ្លៀង ឥតគ្រហឹម មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកទាំងមិននិយាយ ទាំងមិនធ្វើ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុគ្គលជាអ្នកគ្រហឹមផង បង្អុរភ្លៀងផង តើដូចម្តេច ។

ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ភាសិតា ច ហោតិ កត្តា ច ឯវំ ខោ ភិក្ខវេ បុគ្គលោ គជ្ជិតា ច ហោតិ វស្សិតា ច ។ សេយ្យថាបិ សោ ភិក្ខវេ វលាហកោ គជ្ជិតា ច[១] វស្សិតា ច តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ វលាហកូបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១០៣] ចត្តារោមេ ភិក្ខវេ វលាហកា ។ កតមេ ចត្តារោ ។ គជ្ជិតា នោ វស្សិតា វស្សិតា នោ គជ្ជិតា នេវ គជ្ជិតា នោ វស្សិតា គជ្ជិតា ច វស្សិតា ច ។ ឥមេ ខោ ភិក្ខវេ ចត្តារោ វលាហកា ។ ឯវមេវ ខោ ភិក្ខវេ ចត្តារោមេ វលាហកូបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ គជ្ជិតា នោ វស្សិតា វស្សិតា នោ គជ្ជិតា នេវ គជ្ជិតា នោ វស្សិតា គជ្ជិតា ច វស្សិតា ច ។

១ ឱ. ម. ឯត្ថន្តរេ ហោតីតិ ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកនិយាយផង ជាអ្នកធ្វើផង ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកគ្រហឹមផង បង្អុរភ្លៀងផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះគ្រហឹមផង បង្អុរភ្លៀងផង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលឧបមាដោយមេឃ ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[១០៣] ម្នាលភិក្ខុទាំងឡាយ មេឃនេះ មាន ៤ យ៉ាង ។ មេឃ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺគ្រហឹមឥតបង្អុរភ្លៀង ១ បង្អុរភ្លៀងឥតគ្រហឹម ១ ទាំងមិនគ្រហឹមទាំងមិនបង្អុរភ្លៀង ១ គ្រហឹមផង បង្អុរភ្លៀងផង ១ ។ ម្នាលភិក្ខុទាំងឡាយ មេឃមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ ឧបមាដោយមេឃ រមែងមាននៅក្នុងលោកក៏ដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលជាអ្នកគ្រហឹម ឥតបង្អុរភ្លៀង ១ បង្អុរភ្លៀងឥតគ្រហឹម ១ ទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង ១ គ្រហឹមផង បង្អុរភ្លៀងផង ១ ។

២៤៧



កថញ្ច ភិក្ខវេ បុគ្គលោ គជ្ជិតា ហោតិ នោ វស្សិតា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ សោ ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ នប្បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ គជ្ជិតា ហោតិ នោ វស្សិតា ។ សេយ្យថាបិ សោ ភិក្ខវេ វលាហកោ គជ្ជិតា នោ វស្សិតា តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ វស្សិតា ហោតិ នោ គជ្ជិតា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ នេវ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ

ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកគ្រហឹម ឥតបង្អុរភ្លៀង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រៀនសូត្រនូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះ មិនដឹងច្បាស់ តាមសេចក្ដីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់ តាមសេចក្ដីពិតថា នេះជាទុក្ខសមុទយៈ ដូច្នេះ មិនដឹងច្បាស់ តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធៈ ដូច្នេះ មិនដឹងច្បាស់ តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកគ្រហឹម ឥតបង្អុរភ្លៀង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះគ្រហឹម ឥតបង្អុរភ្លៀងមានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកបង្អុរភ្លៀង ឥតគ្រហឹម តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបាន រៀនសូត្រនូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះ រមែងដឹងច្បាស់ តាមសេចក្ដីពិតថា នេះជាទុក្ខដូច្នេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ

អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ វស្សិតា ហោតិ នោ គជ្ជិតា ។ សេយ្យថាបិ សោ ភិក្ខវេ វលាហកោ វស្សិតា នោ គជ្ជិតា តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ នេវ គជ្ជិតា ហោតិ នោ វស្សិតា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ធម្មំ ន បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ សោ ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ នប្បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ នេវ គជ្ជិតា ហោតិ នោ វស្សិតា ។ សេយ្យថាបិ សោ ភិក្ខវេ វលាហកោ នេវ គជ្ជិតា នោ វស្សិតា តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។

ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកបង្អុរភ្លៀង ឥតគ្រហឹម យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះ បង្អុរភ្លៀងឥតគ្រហឹម មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនរៀនសូត្រនូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ដូច្នេះ មិនដឹងច្បាស់ តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់ តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់ តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះ ទាំងមិនគ្រហឹម ទាំងមិនបង្អុរភ្លៀង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។

កាថញ្ច ភិក្ខវេ បុគ្គលោ គជ្ជិតា ច ហោតិ វស្សិតា ច ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ គជ្ជិតា ច ហោតិ វស្សិតា ច ។ សេយ្យថាបិ សោ ភិក្ខវេ វលាហកោ គជ្ជិតា ច វស្សិតា ច តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ វលាហកូបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១០៤] ចត្តារោមេ ភិក្ខវេ កុម្ភា ។ កតមេ ចត្តារោ ។ តុច្ឆោ បិហិតោ បូរោ វិវដោ តុច្ឆោ វិវដោ បូរោ បិហិតោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ កុម្ភា ។

ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលគ្រហឹមផង បង្អុរភ្លៀងផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រៀនសូត្រនូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធៈ ដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកគ្រហឹមផង បង្អុរភ្លៀងផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មេឃនោះគ្រហឹមផង បង្អុរភ្លៀងផង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល មានឧបមាដោយមេឃ ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[១០៤] ម្នាលភិក្ខុទាំងឡាយ ក្អមនេះ មាន ៤ យ៉ាង ។ ក្អម ៤ យ៉ាង ដូចម្តេចខ្លះ ។ គឺក្អមទទេគ្របមាត់ ១ ក្អមពេញ (ដោយទឹក) តែបើកចំហមាត់ ១ ក្អមទទេបើកចំហមាត់ ១ ក្អមពេញ (ដោយទឹក) គ្របមាត់ ១ ។ ម្នាលភិក្ខុទាំងឡាយ ក្អមមាន ៤ យ៉ាងនេះឯង ។

ឯវមេវ ខោ ភិក្ខវេ ចត្តារោមេ កុម្ភូបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ តុច្ឆោ បិហិតោ បូរោ វិវដោ តុច្ឆោ វិវដោ បូរោ បិហិតោ ។ កថញ្ច ភិក្ខវេ បុគ្គលោ តុច្ឆោ ហោតិ បិហិតោ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស បាសាទិកំ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ សោ ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ នប្បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ តុច្ឆោ ហោតិ បិហិតោ ។ សេយ្យថាបិ សោ ភិក្ខវេ កុម្ភោ តុច្ឆោ បិហិតោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ បូរោ ហោតិ វិវដោ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយក្អម ៤ ពួកនេះ រមែងមាននៅក្នុងលោកដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្តេច ។ គឺបុគ្គលទទេគ្របមាត់ ១ បុគ្គលពេញដោយទឹក តែបើកចំហមាត់ ១ បុគ្គលទទេបើកចំហមាត់ ១ បុគ្គលពេញដោយទឹក ទាំងគ្របមាត់ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទទេគ្របមាត់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ គួរជាទីជ្រះថ្លា បុគ្គលនោះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធ ដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលទទេគ្របមាត់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្អមនោះជាក្អមទទេគ្របមាត់ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុគ្គលពេញដោយទឹក បើកចំហមាត់ តើដូចម្តេច ។

ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស ន បាសាទិកំ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ បូរោ ហោតិ វិវដោ ។ សេយ្យថាបិ សោ ភិក្ខវេ កុម្ភោ បូរោ វិវដោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ តុច្ឆោ ហោតិ វិវដោ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស ន បាសាទិកំ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ សោ ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានាតិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវៈយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ មិនជាទីជ្រះថ្លា បុគ្គលនោះ រមែងដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខ ដូច្នេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធៈ ដូច្នេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលពេញដោយទឹក បើកចំហមាត់យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្អមនោះជាក្អមពេញដោយទឹក បើកចំហមាត់ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទទេ ទាំងបើកចំហមាត់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ មិនជាទីជ្រះថ្លា បុគ្គលនោះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខដូច្នេះ

អយំ ទុក្ខសមុទយោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ នប្បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ តុច្ឆោ ហោតិ វិវដោ ។ សេយ្យថាបិ សោ ភិក្ខវេ កុម្ភោ តុច្ឆោ វិវដោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ បូរោ ហោតិ បិហិតោ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស បាសាទិកំ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ បូរោ ហោតិ បិហិតោ ។ សេយ្យថាបិ សោ ភិក្ខវេ កុម្ភោ បូរោ បិហិតោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។

មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលទទេ បើកចំហមាត់យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្អមនោះជាក្អមទទេ បើកចំហមាត់ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលពេញដោយទឹកគ្របមាត់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឈានដើរទៅមុខ ឈានដើរថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ គួរជាទីជ្រះថ្លា បុគ្គលនោះរមែងដឹងច្បាស់ តាមសេចក្ដីពិតថា នេះជាទុក្ខ ដូច្នេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធដូច្នេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធ-គាមិនីបដិបទា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលពេញ ដោយទឹកទាំងបិទមាត់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្អមនោះជាក្អមពេញដោយទឹកគ្របមាត់ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យ ដូច្នោះដែរ ។

ឥមេ ខោ ភិក្ខវេ ចត្តារោ កុម្ភូបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១០៨] ចត្តារោមេ ភិក្ខវេ ឧទករហទា ។ កតមេ ចត្តារោ ។ ឧត្តានោ គម្ភីរោភាសោ គម្ភីរោ ឧត្តានោភាសោ ឧត្តានោ ឧត្តានោភាសោ គម្ភីរោ គម្ភីរោភាសោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ឧទករហទា ។ ឯវមេវ ខោ ភិក្ខវេ ចត្តារោមេ ឧទករហទុបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឧត្តានោ គម្ភីរោភាសោ គម្ភីរោ ឧត្តានោភាសោ ឧត្តានោ ឧត្តានោភាសោ គម្ភីរោ គម្ភីរោភាសោ ។ កថញ្ច ភិក្ខវេ បុគ្គលោ ឧត្តានោ ហោតិ គម្ភីរោភាសោ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស បាសាទិកំ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ

ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយក្អម ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[១០៩] ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកនេះមាន ៤ យ៉ាង ។ អន្លង់ទឹក ៤ យ៉ាង តើដូចម្តេច ។ គឺអន្លង់ទឹករាក់មានឱភាស (ធ្លុះស្រមោលទៅជ្រៅ) ១ អន្លង់ទឹកជ្រៅមានឱភាសរាក់ ១ អន្លង់ទឹករាក់ មានឱភាសរាក់ ១ អន្លង់ទឹកជ្រៅមានឱភាសជ្រៅ ១ ។ ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកមាន ៤ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឧបមាដោយអន្លង់ទឹក ៤ ពួកនេះ រមែងមាននៅក្នុងលោកដូច្នោះដែរ ។ បុគ្គល ៤ ពួកតើដូចម្តេច ។ គឺបុគ្គលរាក់មានឱភាសជ្រៅ ១ បុគ្គលជ្រៅមានឱភាសរាក់ ១ បុគ្គលរាក់ មានឱភាសរាក់ ១ បុគ្គលជ្រៅមានឱភាសជ្រៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលរាក់ មានឱភាសជ្រៅតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូលលាតអវយវៈចេញ ទ្រទ្រង់សង្ឃាដី បាត្រនិងចីវរគួរជាទី

សោ ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ នប្បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ ឧត្តានោ ហោតិ គម្ភីរោភាសោ ។ សេយ្យថាបិ សោ ភិក្ខវេ ឧទករហទោ ឧត្តានោ គម្ភីរោភាសោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ គម្ភីរោ ហោតិ ឧត្តានោភាសោ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស ន បាសាទិកំ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ ម្ភីរោ ហោតិ ឧត្តានោភាសោ ។

ជ្រះថ្លាតែបុគ្គលនោះមិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមពិតថា នេះជាទុក្ខ-និរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលរាក់ មានឱភាសជ្រៅយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកនោះរាក់ មានឱភាសជ្រៅ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជ្រៅមានឱភាសរាក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ មិនជាទីជ្រះថ្លា បុគ្គលនោះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ-និរោធដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលជ្រៅមានឱភាសរាក់យ៉ាងនេះឯង ។

សេយ្យថាបិ សោ ភិក្ខវេ ឧទករហទោ គម្ភីរោ ឧត្តានោ-
ភាសោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច
ភិក្ខវេ បុគ្គលោ ឧត្តានោ ហោតិ ឧត្តានោភាសោ ។
ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស ន ចាសាទិកំ
ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ
សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ សោ
ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានាតិ អយំ
ទុក្ខសមុទយោតិ យថាភូតំ នប្បជានាតិ អយំ
ទុក្ខនិរោធោតិ យថាភូតំ នប្បជានាតិ អយំ
ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ នប្បជានាតិ
ឯវំ ខោ ភិក្ខវេ បុគ្គលោ ឧត្តានោ ហោតិ
ឧត្តានោភាសោ ។ សេយ្យថាបិ សោ ភិក្ខវេ
ឧទករហទោ ឧត្តានោ ឧត្តានោភាសោ តថូបមាហំ
ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ
បុគ្គលោ គម្ភីរោ ហោតិ គម្ភីរោភាសោ ។

ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកនោះជ្រៅ មានឱភាសរាក់ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលរាក់ មានឱភាសរាក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅខាងមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ មិនជាទីជ្រះថ្លា បុគ្គលនោះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈ ដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធ ដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលរាក់មានឱភាសរាក់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ អន្លង់ទឹកនោះរាក់ មានឱភាសរាក់មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជ្រៅ មានឱភាសជ្រៅ តើដូចម្តេច ។

ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស ចាសាទិកំ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ គម្ភីរោ ហោតិ គម្ភីរភាសោ ។ សេយ្យថាបិ សោ ភិក្ខវេ ឧទករហទោ គម្ភីរោ គម្ភីរោភាសោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ឧទករហទុបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១០៦] ចត្តារីមានិ ភិក្ខវេ អម្ពានិ ។ កាតមានិ ចត្តារិ ។ អាមំ បក្កវណ្ណិ បក្កំ អាមវណ្ណិ អាមំ អាមវណ្ណិ បក្កំ បក្កវណ្ណិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អម្ពានិ ។ ឯវមេវ ខោ ភិក្ខវេ ចត្តារោមេ អម្ពុបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ គួរជាទីជ្រះថ្លា បុគ្គលនោះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលជ្រៅ មានឱភាសជ្រៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកនោះជ្រៅ មានឱភាសជ្រៅ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឧបមាដោយអន្លង់ទឹក ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[១០៦] ម្នាលភិក្ខុទាំងឡាយ ផ្លែស្វាយនេះមាន ៤ យ៉ាង ។ ផ្លែស្វាយ ៤ យ៉ាងតើដូចម្តេចខ្លះ ។ គឺផ្លែស្វាយខ្ចីមានសម្បុរទុំ ១ ផ្លែស្វាយទុំមានសម្បុរខ្ចី ១ ផ្លែស្វាយខ្ចីមានសម្បុរខ្ចី ១ ផ្លែស្វាយទុំមានសម្បុរទុំ ១ ។ ម្នាលភិក្ខុទាំងឡាយ ផ្លែស្វាយមាន ៤ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ មានឧបមាដោយផ្លែស្វាយ ៤ ពួកនេះ រមែងមាននៅក្នុងលោកដូច្នោះដែរ ។

២៦៧



កតមេ ចត្តារោ ។ អាមោ បក្កវណ្ណី បក្កោ អាមវណ្ណី អាមោ អាមវណ្ណី បក្កោ បក្កវណ្ណី ។ កថញ្ច ភិក្ខវេ បុគ្គលោ អាមោ ហោតិ បក្កវណ្ណី ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស បាសាទិកំ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ សោ ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ នប្បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ អាមោ ហោតិ បក្កវណ្ណី ។ សេយ្យថាបិ តំ ភិក្ខវេ អម្ពំ អាមំ បក្កវណ្ណី តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ បក្កោ ហោតិ អាមវណ្ណី ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស ន បាសាទិកំ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ

បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលខ្ចីមានសម្បុរទុំ ១ បុគ្គលទុំមានសម្បុរខ្ចី ១ បុគ្គលខ្ចីមានសម្បុរខ្ចី ១ បុគ្គលទុំមានសម្បុរទុំ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលខ្ចីមានសម្បុរទុំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ គួរជាទីជ្រះថ្លា បុគ្គលនោះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្ចីមានសម្បុរទុំយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ផ្លែស្វាយនោះខ្ចីមានសម្បុរទុំមានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនោះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទុំមានសម្បុរខ្ចី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ

សង្ឃាដិបត្តចីវរធារណំ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ បក្កោ ហោតិ អាមវណ្ណី ។ សេយ្យថាបិ តំ ភិក្ខវេ អម្ពំ បក្កំ អាមវណ្ណី តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ អាមោ ហោតិ អាមវណ្ណី ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស ន បាសាទិកំ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ សោ ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ នប្បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ អាមោ ហោតិ អាមវណ្ណី ។

ទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ មិនជាទីជ្រះថ្លា តែបុគ្គលនោះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធ ដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលទុំមានសម្បុរខ្ចីយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ផ្លែស្វាយនោះទុំមានសម្បុរខ្ចី មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំង-ឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលខ្ចីមានសម្បុរខ្ចី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ មិនជាទីជ្រះថ្លា បុគ្គលនោះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធ ដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្ចី មានសម្បុរខ្ចី យ៉ាងនេះឯង ។

២៦៩



សេយ្យថាបិ តំ ភិក្ខវេ អម្ពំ អាមំ អាមវណ្ណី តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ បក្កោ ហោតិ បក្កវណ្ណី ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស បាសាទិកំ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ បក្កោ ហោតិ បក្កវណ្ណី ។ សេយ្យថាបិ តំ ភិក្ខវេ អម្ពំ បក្កំ បក្កវណ្ណី តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អម្ពុបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

ម្នាលភិក្ខុទាំងឡាយ ផ្លែស្វាយនោះខ្ចី មានសម្បុរខ្ចី មានឧបមាយ៉ាង ណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧប-មេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទុំ មានសម្បុរទុំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាតអវយវៈចេញ ទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ គួរជាទីជ្រះថ្លា បុគ្គលនោះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលទុំមានសម្បុរទុំយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ផ្លែស្វាយនោះទុំ មានសម្បុរទុំ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយផ្លែស្វាយ ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[១០៧] ចតស្សោ ឥមា ភិក្ខវេ មូសិកា ។ កតមា ចតស្សោ ។ គាធំ កត្តា នោ វសិតា វសិតា នោ គាធំ កត្តា នេវ គាធំ កត្តា នោ វសិតា គាធំ កត្តា ច វសិតា ច ។ ឥមា ខោ ភិក្ខវេ ចតស្សោ មូសិកា ។ ឯវមេវ ខោ ភិក្ខវេ ចត្តារោមេ មូសិកុបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ គាធំ កត្តា នោ វសិតា វសិតា នោ គាធំ កត្តា នេវ គាធំ កត្តា នោ វសិតា គាធំ កត្តា ច វសិតា ច ។ កថញ្ច ភិក្ខវេ បុគ្គលោ គាធំ កត្តា ហោតិ នោ វសិតា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ សោ ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ នប្បជានាតិ

[១០៧] ម្នាលភិក្ខុទាំងឡាយ កណ្ដុរនេះមាន ៤ ពួក ។ កណ្ដុរ ៤ ពួក តើដូចម្ដេចខ្លះ ។ គឺកណ្ដុរកកាយរន្ធ តែមិននៅ ១ នៅតែមិនកកាយរន្ធ ១ ទាំងមិនកកាយរន្ធទាំងមិននៅ ១ កកាយរន្ធផង នៅផង ១ ។ ម្នាលភិក្ខុទាំងឡាយ កណ្ដុរមាន ៤ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឧបមាដោយកណ្ដុរ ៤ ពួកនេះ រមែងមាននៅក្នុងលោកក៏ដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្ដេចខ្លះ ។ គឺបុគ្គលកកាយរន្ធ តែមិននៅ ១ នៅតែមិនកកាយរន្ធ ១ ទាំងមិនកកាយរន្ធទាំងមិននៅ ១ កកាយរន្ធផង នៅផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកកកាយរន្ធ តែមិននៅ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រៀនសូត្រនូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខ ដូច្នេះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខសមុទយៈ ដូច្នេះ មិនដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធ ដូច្នេះ

២៧១



អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ នប្បជា-
នាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ គាធំ កត្តា ហោតិ
នោ វសិតា ។ សេយ្យថាបិ សា ភិក្ខវេ មូសិកា
គាធំ កត្តា នោ វសិតា តថូបមាហំ ភិក្ខវេ ឥមំ
បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ វសិតា
ហោតិ នោ គាធំ កត្តា ។ ឥធ ភិក្ខវេ ឯកច្ចោ
បុគ្គលោ ធម្មំ ន បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យា-
ករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ
វេទល្លំ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ
ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខ-
និរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី
បដិបទាតិ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ
វសិតា ហោតិ នោ គាធំ កត្តា ។ សេយ្យថាបិ
សា ភិក្ខវេ មូសិកា វសិតា នោ គាធំ កត្តា
តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច
ភិក្ខវេ បុគ្គលោ នេវ គាធំ កត្តា ហោតិ នោ វសិតា ។

មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកកកាយរន្ធ តែមិននៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កណ្តុរនោះ កកាយរន្ធ តែមិននៅមានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកនៅ តែមិនកកាយរន្ធ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនរៀនសូត្រនូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈ ដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធ ដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលជាអ្នកនៅ តែមិនកកាយរន្ធ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កណ្តុរនោះនៅ តែមិនកកាយរន្ធមានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទាំងមិនកកាយរន្ធទាំងមិននៅ តើដូចម្តេច ។

ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ធម្មំ ន បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ សោ ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ នប្បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ នប្បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ នេវ គាធំ កត្តា ហោតិ នោ វសិតា ។ សេយ្យថាបិ សា ភិក្ខវេ មូសិកា នេវ គាធំ កត្តា នោ វសិតា តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ គាធំ កត្តា ច ហោតិ វសិតា ច ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនរៀនសូត្រនូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធដូច្នេះ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងមិនកកាយរន្ធ ទាំងមិននៅយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កណ្តុរនោះទាំងមិនកកាយរន្ធ ទាំងមិននៅ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថាបុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកកកាយរន្ធផង នៅផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រៀនសូត្រនូវធម៌គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ដូច្នេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទយៈដូច្នេះ

អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខ-និរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ គាជំ កត្តា ច ហោតិ វសិតា ច ។ សេយ្យថាបិ សា ភិក្ខវេ មូសិកា គាជំ កត្តា ច វសិតា ច តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ មូសិកុបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១០៨] ចត្តារោមេ ភិក្ខវេ ពលិវទ្ទា ។ កតមេ ចត្តារោ ។ សគវចណ្ឌោ[១] នោ បរគវចណ្ឌោ បរគវចណ្ឌោ នោ សគវចណ្ឌោ សគវចណ្ឌោ ច បរគវចណ្ឌោ ច នេវ សគវចណ្ឌោ នោ បរគវចណ្ឌោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ពលិវទ្ទា ។ ឯវមេវ ខោ ភិក្ខវេ ចត្តារោមេ ពលិវទ្ទុបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ សគវចណ្ឌោ នោ បរគវចណ្ឌោ បរគវចណ្ឌោ

១ ឱ. សកគវចណ្ឌោ ។

ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធៈ ដូច្នេះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នក កកាយរន្ធផង នៅផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ កណ្តុរនោះ កកាយរន្ធផង នៅផង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ មានឧបមាដោយកណ្តុរ រមែងមាននៅក្នុងលោក ។

[១០៨] ម្នាលភិក្ខុទាំងឡាយ គោបម្រើនេះ មាន ៤ ពួក ។ គោបម្រើ ៤ ពួក តើដូចម្តេចខ្លះ ។ គឺជាសត្វកាចក្នុងហ្វូងគោរបស់ខ្លួន មិនកាចក្នុងហ្វូងគោដទៃ ១ ជាសត្វកាចក្នុងហ្វូងគោដទៃ មិនកាចក្នុងហ្វូងគោរបស់ខ្លួន ១ ជាសត្វកាចក្នុងហ្វូងគោរបស់ខ្លួនផង កាចក្នុងហ្វូងគោដទៃផង ១ ជាសត្វមិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ ១ ។ ម្នាលភិក្ខុទាំងឡាយ គោបម្រើមាន ៤ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយគោបម្រើ ៤ ពួកនេះ រមែងមាននៅក្នុងលោក ដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួន តែមិនកាចក្នុងហ្វូងគោដទៃ ១ កាចក្នុងហ្វូងគោដទៃ

នោ សតរចណ្ហោ សតរចណ្ហោ ច បរតរចណ្ហោ ច នេវ សតរចណ្ហោ នោ បរតរចណ្ហោ ។ កថញ្ច ភិក្ខវេ បុគ្គលោ សតរចណ្ហោ ហោតិ នោ បរតរចណ្ហោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សកាបរិសំ ឧព្វេជេតា ហោតិ នោ បរបរិសំ ឯវំ ខោ ភិក្ខវេ បុគ្គលោ សតរចណ្ហោ ហោតិ នោ បរតរចណ្ហោ ។ សេយ្យថាបិ សោ ភិក្ខវេ ពលិវទ្ទោ សតរចណ្ហោ នោ បរតរចណ្ហោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ បរតរចណ្ហោ ហោតិ នោ សតរ-ចណ្ហោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ បរបរិសំ ឧព្វេជេតា ហោតិ នោ សកាបរិសំ ឯវំ ខោ ភិក្ខវេ បុគ្គលោ បរតរចណ្ហោ ហោតិ នោ សតរចណ្ហោ ។ សេយ្យថាបិ សោ ភិក្ខវេ ពលិវទ្ទោ បរតរចណ្ហោ នោ សតរចណ្ហោ

តែមិនកាចក្នុងហ្វូងគោរបស់ខ្លួន ១ កាចក្នុងហ្វូងគោរបស់ខ្លួនផង កាចក្នុងហ្វូងគោដទៃផង ១ មិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួន តែមិនកាចក្នុងហ្វូងគោដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកគំរាមបរិសទ្យរបស់ខ្លួន តែមិនគំរាមបរិសទ្យដទៃ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួន តែមិនកាចក្នុងហ្វូងគោដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ គោបម្រើនោះជាសត្វកាចក្នុងហ្វូងគោរបស់ខ្លួន តែមិនកាចក្នុងហ្វូងគោដទៃ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យ ដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដូចគោកាចក្នុងហ្វូងគោដទៃ តែមិនកាចក្នុងហ្វូងគោ របស់ខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកគំរាមបរិសទ្យរបស់អ្នកដទៃ តែមិនគំរាមបរិសទ្យរបស់ខ្លួន ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចគោកាចក្នុងហ្វូងគោរបស់អ្នកដទៃ តែមិនកាចក្នុងហ្វូងគោរបស់ខ្លួន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ គោបម្រើនោះ ជាសត្វកាចក្នុងហ្វូងគោដទៃ តែមិនកាចក្នុងហ្វូងគោរបស់ខ្លួន

តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ សតវចណ្ឌោ ច ហោតិ បរតវចណ្ឌោ ច ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សកបរិសញ្ច ឧព្វេជេតា ហោតិ បរបរិសញ្ច ឯវំ ខោ ភិក្ខវេ បុគ្គលោ សតវចណ្ឌោ ច ហោតិ បរតវចណ្ឌោ ច ។ សេយ្យថាបិ សោ ភិក្ខវេ ពលិវទ្ទោ សតវចណ្ឌោ ច បរតវចណ្ឌោ ច តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ នេវ សតវចណ្ឌោ ហោតិ នោ បរតវចណ្ឌោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ នេវ សកបរិសំ ឧព្វេជេតា ហោតិ នោ បរបរិសំ ឯវំ ខោ ភិក្ខវេ បុគ្គលោ នេវ សតវចណ្ឌោ ហោតិ នោ បរតវចណ្ឌោ ។ សេយ្យថាបិ សោ ភិក្ខវេ ពលិវទ្ទោ នេវ សតវចណ្ឌោ

មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួនផង កាចក្នុងហ្វូងគោដទៃផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកគំរាមបរិសទ្យរបស់ខ្លួនផង គំរាមបរិសទ្យរបស់អ្នកដទៃផង ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួនផង កាចក្នុងហ្វូងគោដទៃផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ គោបម្រើនោះ កាចក្នុងហ្វូងគោរបស់ខ្លួនផង កាចក្នុងហ្វូងគោដទៃផង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យ ដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គល ដូចគោមិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនគំរាមបរិសទ្យរបស់ខ្លួន ទាំងមិនគំរាមបរិសទ្យរបស់អ្នកដទៃ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចគោមិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ គោបម្រើនោះ ជាសត្វមិនកាចក្នុងហ្វូងគោរបស់ខ្លួន

ជោ បរគវចណ្ណោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ពលិវទ្ទូបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១០៩] ចត្តារោមេ ភិក្ខវេ រុក្ខា ។ កតមេ ចត្តារោ ។ ផេគ្គុ ផេគ្គុបរិវារោ ផេគ្គុ សារបរិវារោ សារោ ផេគ្គុបរិវារោ សារោ សារបរិវារោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ រុក្ខា ។ ឯវមេវ ខោ ភិក្ខវេ ចត្តារោមេ រុក្ខូបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ផេគ្គុ ផេគ្គុបរិវារោ ផេគ្គុ សារបរិវារោ សារោ ផេគ្គុបរិវារោ សារោ សារ-បរិវារោ ។ កថញ្ច ភិក្ខវេ បុគ្គលោ ផេគ្គុ ហោតិ ផេគ្គុ-បរិវារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ទុស្សីលោ ហោតិ បាបធម្មោ បរិសាបិស្ស ហោតិ ទុស្សីលា

ទាំងមិនកាចក្នុងហ្វូងគោដទៃ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឧបមាដោយគោបម្រើ ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[១០៩] ម្នាលភិក្ខុទាំងឡាយ ដើមឈើនេះ មាន ៤ ពួក ។ ដើមឈើ ៤ ពួក តើដូចម្តេចខ្លះ ។ គឺដើមឈើស្រាយ មានដើមឈើស្រាយជាបរិវារ ១ ដើមឈើស្រាយ មានដើមឈើខ្លឹមជាបរិវារ ១ ដើមឈើខ្លឹម មានដើមឈើស្រាយជាបរិវារ ១ ដើមឈើខ្លឹម មានដើមឈើខ្លឹមជាបរិវារ ១ ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើមាន ៤ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយដើមឈើ ៤ ពួកនេះ រមែងមាននៅក្នុងលោកដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលស្រាយ មានស្រាយជាបរិវារ ១ បុគ្គលស្រាយមានខ្លឹមជាបរិវារ ១ បុគ្គលខ្លឹម មានស្រាយជាបរិវារ ១ បុគ្គលខ្លឹម មានខ្លឹមជាបរិវារ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលស្រាយ មានស្រាយជាបរិវារ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ទាំងបរិសទ្យរបស់បុគ្គលនោះ ក៏ជាអ្នកទ្រុស្តសីល

ចាបជម្មា ឯវំ ខោ ភិក្ខវេ បុគ្គលោ ផេគ្គុ ហោតិ ផេគ្គុបរិវារោ ។ សេយ្យថាបិ សោ ភិក្ខវេ រុក្ខោ ផេគ្គុ ផេគ្គុបរិវារោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កាថញ្ច ភិក្ខវេ បុគ្គលោ ផេគ្គុ ហោតិ សារបរិវារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ទុស្សីលោ ហោតិ ចាបជម្មោ បរិសា ច ខ្វស្ស ហោតិ សីលវតី កល្យាណជម្មា ឯវំ ខោ ភិក្ខវេ បុគ្គលោ ផេគ្គុ ហោតិ សារបរិវារោ ។ សេយ្យថាបិ សោ ភិក្ខវេ រុក្ខោ ផេគ្គុ សារបរិវារោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កាថញ្ច ភិក្ខវេ បុគ្គលោ សារោ ហោតិ ផេគ្គុបរិវារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សីលវា ហោតិ កល្យាណជម្មោ បរិសា ច ខ្វស្ស ហោតិ ទុស្សីលា ចាប-ជម្មា ឯវំ ខោ ភិក្ខវេ បុគ្គលោ សារោ ហោតិ ផេគ្គុបរិវារោ ។

មានធម៌ដ៏លាមកដែរ ម្នាលភិក្ខុទាំងឡាយ បុគ្គលស្រាយ មានស្រាយជាបរិវារយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើនោះ ជាឈើស្រាយ មានដើមឈើស្រាយជាបរិវារ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលស្រាយ មានខ្លឹមជាបរិវារ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកទ្រុស្តសីលមានធម៌ដ៏លាមក ប៉ុន្តែបរិសទ្យរបស់បុគ្គលនោះ ជាអ្នកមានសីល មានធម៌ល្អ ម្នាលភិក្ខុទាំងឡាយ បុគ្គលស្រាយ មានខ្លឹមជាបរិវារ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើនោះជាដើមឈើស្រាយ មានដើមឈើខ្លឹមជាបរិវារ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លឹមមានស្រាយជាបរិវារ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ ប៉ុន្តែបរិសទ្យរបស់បុគ្គលនោះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា បុគ្គលខ្លឹម មានស្រាយជាបរិវារ យ៉ាងនេះឯង ។

សេយ្យថាបិ សោ ភិក្ខវេ រុក្ខោ សារោ ផេគ្គុបរិវារោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ សារោ ហោតិ សារបរិវារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សីលវា ហោតិ កល្យាណធម្មោ បរិសាបិស្ស ហោតិ សីលវតី កល្យាណធម្មា ឯវំ ខោ ភិក្ខវេ បុគ្គលោ សារោ ហោតិ សារបរិវារោ ។ សេយ្យថាបិ សោ ភិក្ខវេ រុក្ខោ សារោ សារបរិវារោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ រុក្ខុបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១១០] ចត្តារោ មេ ភិក្ខវេ អាសីវិសា ។ កតមេ ចត្តារោ ។ អាគតវិសោ ន ឃោរវិសោ ឃោរវិសោ ន អាគតវិសោ អាគតវិសោ ច ឃោរវិសោ ច

ម្នាលភិក្ខុទាំងឡាយ ដើមឈើនោះ ជាដើមឈើខ្ទឹម មានដើមឈើស្រាយជាបរិវារ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលខ្ទឹម មានខ្ទឹមជាបរិវារ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ ទាំងបរិសទ្យរបស់បុគ្គលនោះ ក៏ជាអ្នកមានសីល មានធម៌ល្អដែរ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលខ្ទឹម មានខ្ទឹមជាបរិវារ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើនោះ ជាដើមឈើមានខ្ទឹម មានដើមឈើខ្ទឹម ជាបរិវារ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយដើមឈើ ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[១១០] ម្នាលភិក្ខុទាំងឡាយ អាសិរពិសនេះមាន ៤ ពួក ។ អាសិរ-ពិស ៤ ពួក តើដូចម្តេចខ្លះ ។ គឺអាសិរពិស មានពិសជ្រួតជ្រាបឆាប់ តែមិនមានពិសដ៏ពន្លឹក ១ មានពិសដ៏ពន្លឹក តែមិនមានពិសជ្រួត-ជ្រាបឆាប់ ១ មានពិសជ្រួតជ្រាបឆាប់ផង មានពិសដ៏ពន្លឹកផង ១

២៧៩



នេវ អាគតវិសោ ន ឃោរវិសោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អាសីវិសា ។ ឯវមេវ ខោ ភិក្ខវេ ចត្តារោមេ អាសីវិសុបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ អាគតវិសោ ន ឃោរវិសោ ឃោរវិសោ ន អាគតវិសោ អាគតវិសោ ច ឃោរវិសោ ច នេវ អាគតវិសោ ន ឃោរវិសោ ។ កថញ្ច ភិក្ខវេ បុគ្គលោ អាគតវិសោ ហោតិ ន ឃោរវិសោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អភិណ្ហំ កុជ្ឈតិ សោ ច ខ្វស្ស កោធោ[១] ន ទីឃរត្តំ អនុសេតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ អាគតវិសោ ហោតិ ន ឃោរវិសោ ។ សេយ្យថាបិ សោ ភិក្ខវេ អាសីវិសោ អាគតវិសោ ន ឃោរវិសោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ ឃោរវិសោ ហោតិ ន អាគតវិសោ ។

១ ម. កោបោ ។

មិនមានពិសជ្រួតជ្រាបឆាប់ ទាំងមិនមានពិសដ៏ពន្លឹក ១ ។ ម្នាលភិក្ខុទាំង-ឡាយ អាសិរពិសមាន ៤ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយអាសិរពិស ៤ ពួកនេះ រមែងមាននៅក្នុងលោក ដូច្នោះដែរ ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលមានពិសជ្រួតជ្រាបឆាប់ តែមិនមានពិសដ៏ពន្លឹក ១ មានពិសដ៏ពន្លឹក តែមិនមានពិសជ្រួតជ្រាបឆាប់ ១ មានពិសជ្រួតជ្រាបឆាប់ផង មានពិសដ៏ពន្លឹកផង ១ មិនមានពិសជ្រួតជ្រាបឆាប់ ទាំងមិនមានពិសដ៏ពន្លឹក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានពិសជ្រួតជ្រាបឆាប់ តែមិនមានពិសដ៏ពន្លឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងក្រោធរឿយ ៗ តែសេចក្តីក្រោធរបស់បុគ្គលនោះ មិនងំនៅអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានពិសជ្រួតជ្រាបឆាប់ តែមិនមានពិសដ៏ពន្លឹកយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អាសិរពិសនោះ មានពិសជ្រួតជ្រាបឆាប់ តែមិនមានពិសដ៏ពន្លឹក មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានពិសដ៏ពន្លឹក តែមិនមានពិសជ្រួតជ្រាបឆាប់ តើដូចម្តេច ។

ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ន ហេវ ខោ អភិណ្ហំ កុជ្ឈតិ សោ ច ខ្វស្ស កោធោ ទីឃរត្តំ អនុសេតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ ឃោរវិសោ ហោតិ ន អាគតវិសោ ។ សេយ្យថាបិ សោ ភិក្ខវេ អាសីវិសោ ឃោរវិសោ ន អាគតវិសោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ អាគត-វិសោ ច ហោតិ ឃោរវិសោ ច ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អភិណ្ហំ កុជ្ឈតិ សោ ច ខ្វស្ស កោធោ ទីឃរត្តំ អនុសេតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ អាគតវិសោ ច ហោតិ ឃោរវិសោ ច ។ សេយ្យថាបិ សោ ភិក្ខវេ អាសីវិសោ អាគតវិសោ ច ឃោរវិសោ ច តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ កថញ្ច ភិក្ខវេ បុគ្គលោ នេវ អាគតវិសោ ហោតិ ន ឃោរវិសោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងមិនក្រោធរឿយ ៗ ទេ តែសេចក្តីក្រោធរបស់បុគ្គលនោះ រមែងជាប់នៅអស់កាលយូរ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលមានពិសដ៏ពន្លឺក តែមិនមានពិសជ្រួតជ្រាបឆាប់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អាសិរពិសនោះ មានពិសដ៏ពន្លឺក តែមិនមានពិសជ្រួតជ្រាបឆាប់ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានពិសជ្រួតជ្រាបឆាប់ផង មានពិសដ៏ពន្លឺកផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងក្រោធរឿយ ៗ ផង សេចក្តីក្រោធរបស់បុគ្គលនោះ រមែងជាប់នៅអស់កាលយូរផង ម្នាលភិក្ខុទាំងឡាយ បុគ្គលមានពិសជ្រួតជ្រាបឆាប់ផង មានពិសដ៏ពន្លឺកផងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អាសិរពិសនោះ មានពិសជ្រួតជ្រាបឆាប់ផង មានពិសដ៏ពន្លឺកផង មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំង-ឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមិនមានពិសជ្រួតជ្រាបឆាប់ ទាំងមិនមានពិសដ៏ពន្លឺក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ

២៨១



នហេវ ខោ អភិណ្ហំ កុជ្ឈតិ សោ ច ខ្វស្ស កោធោ[១] ន ទីឃរត្តំ អនុសេតិ ឯវំ ខោ ភិក្ខវេ បុគ្គលោ នេវ អាគតវិសោ ហោតិ ន ឃោរវិសោ ។ សេយ្យថាបិ សោ ភិក្ខវេ អាសីវិសោ នេវ អាគតវិសោ ន ឃោរវិសោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អាសីវិសុបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

វលាហកវគ្គោ បឋមោ ។

## តស្សុទ្ទានំ

ទ្វេ វលាហកកុម្ភា
ឧទករហទា ទ្វេ ហោន្តិ
អម្ពានិ មូសិកា ពលិពទ្ទា
រុក្ខា អាសីវិសេន តេ ទសាតិ ។

១ ម. នាបិ ។

មិនក្រោធរឿយ ៗ ទាំងសេចក្ដីក្រោធរបស់បុគ្គលនោះ ក៏មិនជំនៅអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានពិសជ្រួតជ្រាបឆាប់ ទាំងមិនមានពិសដ៏ពន្លឹកយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អាសិរពិសនោះ មិនមានពិសជ្រួតជ្រាបឆាប់ ទាំងមិនមានពិសដ៏ពន្លឹក មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដោយអាសិរពិស ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

ចប់ វលាហកវគ្គ ទី ១ ។

# ឧទ្ទាននៃវលាហកវគ្គនោះគឺ

និយាយអំពីមេឃមានពីរលើក អំពីក្អម ១ អំពីអន្លង់ទឹក មានពីរលើក អំពីផ្លែស្វាយ ១ អំពីសត្វកណ្ដុរ ១ អំពីគោបម្រើ ១ អំពីដើមឈើ ១ អំពីអាសិរពិស ១ រួមត្រូវជា ១០ ។

# កេសីវគ្គោ

[១១១] អថខោ កេសី អស្សទម្មសារថិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ កេសឹ អស្សទម្មសារថឹ ភគវា ឯតទវោច ត្វញ្ច ខ្វាសិ កេសិ សញ្ញាតោ អស្សទម្មសារថិ(១) កថញ្ច បន ត្វំ កេសិ អស្សទម្មំ វិនេសីតិ ។ អហំ ខោ ភន្តេ អស្សទម្មំ សណ្ហេនបិ វិនេមិ ផរុសេនបិ វិនេមិ សណ្ហផរុសេនបិ វិនេមីតិ ។ សចេ តេ(២) កេសិ អស្សទម្មោ សណ្ហេន វិនយំ ន ឧបេតិ ផរុសេន វិនយំ ន ឧបេតិ សណ្ហ-ផរុសេន វិនយំ ន ឧបេតិ កិន្តិ តំ ករោសីតិ ។ សចេ មេ ភន្តេ អស្សទម្មោ សណ្ហេន វិនយំ ន ឧបេតិ ផរុសេន វិនយំ ន ឧបេតិ សណ្ហផរុសេន វិនយំ ន ឧបេតិ ហនាមិ នំ ភន្តេ ។ តំ កិស្ស ហេតុ ។

---

១ ម. បញ្ញាតោ អស្សទម្មសារថីតិ ។ ២ ម. តេ ឥតិ នត្ថិ ។

# កេសីវគ្គ

[១១១] គ្រានោះ កេសីជាសារថី អ្នកបង្ហាត់សេះដែលគួរបង្ហាត់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះកេសីជាសារថី អ្នកបង្ហាត់សេះដែលគួរបង្ហាត់ អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលកេសី ខ្លួនអ្នកគេតែងដឹងច្បាស់ថាជាសារថី អ្នកបង្ហាត់សេះដែលគួរបង្ហាត់ ម្នាលកេសី ចុះអ្នកបង្ហាត់សេះដែលគួរបង្ហាត់ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបង្ហាត់សេះ ដែលគួរបង្ហាត់ដោយល្អខ្លះ ដោយអាក្រក់ខ្លះ ដោយល្អនិងអាក្រក់ខ្លះ ។ ម្នាលកេសី ប្រសិនបើសេះដែលគួរបង្ហាត់របស់អ្នក ប្រើវិធីបង្ហាត់ដោយល្អក៏មិនបាន ប្រើវិធីបង្ហាត់ដោយអាក្រក់ក៏មិនបាន ប្រើវិធីបង្ហាត់ដោយល្អនិងអាក្រក់ក៏មិនបាន ចុះអ្នកធ្វើសេះនោះដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើសេះដែលគួរបង្ហាត់របស់ខ្ញុំព្រះអង្គ ប្រើវិធីបង្ហាត់ដោយល្អក៏មិនបាន ប្រើវិធីបង្ហាត់ដោយអាក្រក់ក៏មិនបាន ប្រើវិធីបង្ហាត់ដោយល្អនិងអាក្រក់ក៏មិនបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គក៏សម្លាប់សេះនោះចោល ។ ដំណើរនោះ ព្រោះហេតុអ្វី ។

មា មេ អាចរិយកុលស្ស អវណ្ណោ អហោសីតិ ។ ភគវា បន ភន្តេ អនុត្តរោ បុរិសទម្មសារថិ កថំ បន ភន្តេ ភគវា បុរិសទម្មំ វិនេតីតិ ។ អហំ ខោ កេសិ បុរិសទម្មំ សណ្ហេនបិ វិនេមិ ផរុសេនបិ វិនេមិ សណ្ហផរុសេនបិ វិនេមិ ។ តត្រិទំ កេសិ សណ្ហស្មឹ ឥតិ កាយសុចរិតំ ឥតិ កាយសុចរិតស្ស វិបាកោ ឥតិ វចីសុចរិតំ ឥតិ វចីសុចរិតស្ស វិបាកោ ឥតិ មនោសុចរិតំ ឥតិ មនោសុចរិតស្ស វិបាកោ ឥតិ ទេវា ឥតិ មនុស្សា ។ តត្រិទំ កេសិ ផរុសស្មឹ ឥតិ កាយទុច្ចរិតំ ឥតិ កាយទុច្ចរិតស្ស វិបាកោ ឥតិ វចីទុច្ចរិតំ ឥតិ វចីទុច្ចរិតស្ស វិបាកោ ឥតិ មនោទុច្ចរិតំ ឥតិ មនោទុច្ចរិតស្ស វិបាកោ ឥតិ និរយោ ឥតិ តិរច្ឆានយោនិ ឥតិ បិត្តិវិសយោ ។ តត្រិទំ កេសិ សណ្ហផរុសស្មឹ ឥតិ កាយសុចរិតំ ឥតិ កាយសុចរិតស្ស វិបាកោ ឥតិ កាយទុច្ចរិតំ

ព្រោះថា កុំឲ្យមានពាក្យដំនៀលដល់ត្រកូល នៃអាចារ្យរបស់ខ្ញុំព្រះអង្គឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសារថីទូន្មាននូវបុរសដែលគួរទូន្មាន រកបុគ្គលណាមួយស្មើគ្មាន បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះដ៏មានព្រះភាគ ទ្រង់ណែនាំបុរសដែលគួរទូន្មានតើដូចម្តេច ។ ម្នាលកេសី តថាគត រមែងណែនាំបុរសដែលគួរទូន្មានដោយល្អខ្លះ ដោយអាក្រក់ខ្លះ ដោយល្អនិងអាក្រក់ខ្លះ ។ ម្នាលកេសី បណ្តាអំពើទាំងនោះ អំពើល្អ ដូច្នេះ គឺកាយសុចរិត ដូច្នេះ ផលរបស់កាយសុចរិត ដូច្នេះ វចីសុចរិត ដូច្នេះ ផលរបស់វចីសុចរិត ដូច្នេះ មនោសុចរិត ដូច្នេះ ផលរបស់មនោសុចរិត ដូច្នេះ ទេវតា ដូច្នេះ មនុស្ស ដូច្នេះ ។ ម្នាលកេសី បណ្តាអំពើទាំងអស់នោះ អំពើអាក្រក់ ដូច្នេះ គឺកាយទុច្ចរិត ដូច្នេះ ផលរបស់កាយទុច្ចរិត ដូច្នេះ វចីទុច្ចរិត ដូច្នេះ ផលរបស់វចីទុច្ចរិត ដូច្នេះ មនោទុច្ចរិត ដូច្នេះ ផលរបស់មនោទុច្ចរិត ដូច្នេះ នរក ដូច្នេះ កំណើតតិរច្ឆាន ដូច្នេះ បិត្តិវិស័យ ដូច្នេះ ។ ម្នាលកេសី បណ្តាអំពើទាំងនោះ អំពើល្អនិងអំពើអាក្រក់ ដូច្នេះគឺកាយសុចរិត ដូច្នេះ ផលរបស់កាយសុចរិត ដូច្នេះ កាយទុច្ចរិត ដូច្នេះ

ឥតិ កាយទុច្ចរិតស្ស វិបាកោ ឥតិ វចីសុចរិតំ ឥតិ វចីសុចរិតស្ស វិបាកោ ឥតិ វចីទុច្ចរិតំ ឥតិ វចីទុច្ចរិតស្ស វិបាកោ ឥតិ មនោសុចរិតំ ឥតិ មនោសុចរិតស្ស វិបាកោ ឥតិ មនោទុច្ចរិតំ ឥតិ មនោទុច្ចរិតស្ស វិបាកោ ឥតិ ទេវា ឥតិ មនុស្សា ឥតិ និរយោ ឥតិ តិរច្ឆានយោនិ ឥតិ បិត្តិវិសយោតិ ។ សចេ តេ ភន្តេ បុរិសទម្មា សណ្ហេន វិនយំ ន ឧបេតិ ផរុសេន វិនយំ ន ឧបេតិ សណ្ហផរុសេន វិនយំ ន ឧបេតិ កិន្តិ តំ ភគវា ករោតីតិ ។ សចេ មេ កេសិ បុរិសទម្មា សណ្ហេន វិនយំ ន ឧបេតិ ផរុសេន វិនយំ ន ឧបេតិ សណ្ហផរុសេន វិនយំ ន ឧបេតិ ហនាមិ នំ កេសីតិ ។ ន ខោ នោ ភន្តេ ភគវតោ បាណាតិបាតោ កប្បតិ អថ ច បន ភគវា ឯវមាហ ហនាមិ នំ កេសីតិ ។ សច្ចំ កេសិ ន តថាគតស្ស បាណាតិបាតោ កប្បតិ អបិច

ផលរបស់កាយទុច្ចរិត ដូច្នេះ វចីសុចរិត ដូច្នេះ ផលរបស់វចីសុចរិត ដូច្នេះ វចីទុច្ចរិត ដូច្នេះ ផលរបស់វចីទុច្ចរិត ដូច្នេះ មនោសុចរិត ដូច្នេះ ផលរបស់មនោសុចរិតដូច្នេះ មនោទុច្ចរិត ដូច្នេះ ផលរបស់មនោទុច្ចរិត ដូច្នេះ ទេវតា ដូច្នេះ មនុស្ស ដូច្នេះ នរក ដូច្នេះ កំណើតតិរច្ឆាន ដូច្នេះ បិត្តិវិស័យ ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើបុរសដែលគួរទូន្មានរបស់ព្រះអង្គ ប្រើវិធីបង្ហាត់ដោយល្អក៏មិនបាន ប្រើវិធីបង្ហាត់ដោយអាក្រក់ក៏មិនបាន ប្រើវិធីបង្ហាត់ដោយល្អនិងអាក្រក់ក៏មិនបាន ចុះព្រះដ៏មានព្រះភាគទ្រង់ធ្វើបុរសនោះដូចម្តេចទៅវិញ ។ ម្នាលកេសី ប្រសិនបើបុរសដែលគួរទូន្មានរបស់តថាគត ប្រើវិធីបង្ហាត់ដោយល្អក៏មិនបាន ប្រើវិធីបង្ហាត់ដោយអាក្រក់ក៏មិនបាន ប្រើវិធីបង្ហាត់ដោយល្អនិងអាក្រក់ក៏មិនបាន ម្នាលកេសី តថាគតក៏សម្លាប់បុរសនោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន បាណាតិបាត មិនគួរដល់ព្រះដ៏មានព្រះភាគរបស់យើងទេ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលកេសី តថាគតក៏សម្លាប់បុរសនោះដែរ ។ ម្នាលកេសី បាណាតិបាត មិនគួរដល់តថាគតក៏ពិតមែន តែថា

២៨៤

យោ[១] បុរិសទម្មោ សណ្ហេន វិនយំ ន ឧបេតិ ផរុសេន វិនយំ ន ឧបេតិ សណ្ហផរុសេន វិនយំ ន ឧបេតិ ន តំ តថាគតោ វត្តព្វំ អនុសាសិតព្វំ មញ្ញតិ នបិ វិញ្ញូ សព្រហ្មចារី វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ សុវធោ ហេសោ កេសិ អរិយស្ស វិនយេ យំ ន តថាគតោ វត្តព្វំ អនុសាសិតព្វំ មញ្ញតិ នបិ វិញ្ញូ សព្រហ្មចារី វត្តព្វំ អនុសាសិតព្វំ មញ្ញន្តីតិ ។ សោ ហិ នូន ភន្តេ សុវធោ[២] ហោតិ យំ ន តថាគតោ វត្តព្វំ អនុសាសិតព្វំ មញ្ញតិ នបិ វិញ្ញូ សព្រហ្មចារី វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ

១ ឱ. សោ សទ្ធោ អត្ថិ ។ ២ ម. សុហតោ ។ ឱ. សុគតហតោ ។

បុរសដែលគួរទូន្មានណា ប្រើវិធីបង្ហាត់ដោយល្អក៏មិនបាន ប្រើវិធីបង្ហាត់ដោយអាក្រក់ក៏មិនបាន ប្រើវិធីបង្ហាត់ដោយល្អនិងអាក្រក់ក៏មិនបាន តថាគត រមែងមិនសម្គាល់នូវបុរសនោះថា គួរពោល គួរប្រៀនប្រដៅទេ សូម្បីវិញ្ញូជនជាសព្រហ្មចារីក៏មិនសម្គាល់ (បុរសនោះ) ថា គួរពោល គួរប្រៀនប្រដៅដែរ មួយទៀត តថាគតមិនសម្គាល់បុរសណាថា គួរពោល គួរប្រៀនប្រដៅ សូម្បីពួកវិញ្ញូជនជាសព្រហ្មចារី ក៏មិនសម្គាល់នូវបុរសណាថា គួរពោល គួរប្រៀនប្រដៅដែរ ម្នាលកេសី បុរសនោះឈ្មោះថា ត្រូវសម្លាប់ដោយល្អក្នុងអរិយវិន័យ ។ ព្រះតថាគតមិនសម្គាល់បុរសណាថា គួរពោល គួរប្រៀនប្រដៅ សូម្បីពួកវិញ្ញូជនជាសព្រហ្មចារី ក៏មិនសម្គាល់បុរសណាថា គួរពោល គួរប្រៀនប្រដៅដែរ បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះឈ្មោះថា ត្រូវសម្លាប់ដោយល្អដោយពិត បពិត្រព្រះអង្គដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបដូចបុរសផ្ងារនូវរបស់ដែលគេផ្កាប់ ឬបើកបង្ហាញនូវរបស់ដែលកំបាំង ពុំនោះសោត ដូចជាបុគ្គលប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬទ្រោលប្រទីប ក្នុងទីងងឹតដោយគិតថា បុគ្គលមានចក្ខុរមែងមើលឃើញនូវរូបទាំងឡាយបាន យ៉ាងណាមិញ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ប្រកាសហើយ ដោយអនេកបរិយាយ ក៏យ៉ាងនោះដែរ

ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភន្តេ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

[១១២] ចតូហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ កតមេហិ ចតូហិ ។ អាជ្ជវេន ជវេន ខន្តិយា សោរច្ចេន ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុ-នេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ ចតូហិ ។ អាជ្ជវេន ជវេន ខន្តិយា សោរច្ចេន ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។

[១១២] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យ ប្រកបដោយអង្គ ៤ ជាសេះចម្រើនរបស់ស្តេច គួរដល់ស្តេច ទុកជាព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គរបស់ស្តេច ។ ប្រកបដោយអង្គ ៤ ដូចម្តេចខ្លះ ។ គឺប្រកបដោយសេចក្តីស្មោះត្រង់ ១ ដោយសន្ទុះ ១ ដោយអំណត់ ១ ដោយការស្ងប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យ ប្រកបដោយអង្គ ៤ នេះ ជាសេះចម្រើនរបស់ស្តេច គួរដល់ស្តេច ទុកជាព្រះរាជទ្រព្យ ដល់នូវការរាប់ថា ជាអង្គរបស់ស្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ក៏ដូច្នោះដែរ គឺជាអ្នកគួរគេបូជា គួរទទួលនូវអាគន្តុកទាន ជាអ្នកគួរទទួលនូវទក្ខិណាទាន ជាអ្នកគួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្ត ដ៏ប្រសើរនៃសត្វលោក ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺប្រកបដោយសេចក្តីស្មោះត្រង់ ១ ដោយសន្ទុះ ១ ដោយអំណត់ ១ ដោយការស្ងប់ស្ងៀម ១ ។

ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[១១៣] ចត្តារោមេ ភិក្ខវេ ភទ្រា អស្សាជានីយា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចោ ភទ្រោ អស្សាជានីយោ បតោទច្ឆាយំ ទិស្វា សំវិជតិ សំវេគំ អាបជ្ជតិ ។ កិន្នុ ខោ មំ អជ្ជ អស្សទម្មសារថិ ការណំ ការេស្សតិ កិមស្សាហំ បដិករោមីតិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ ភទ្រោ អស្សាជានីយោ ហោតិ អយំ ភិក្ខវេ បឋមោ ភទ្រោ អស្សាជានីយោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ ភទ្រោ អស្សាជានីយោ ន ហេវ ខោ បតោទច្ឆាយំ ទិស្វា សំវិជតិ សំវេគំ អាបជ្ជតិ អបិច ខោ លោមវេធវិទ្ធោ សំវិជតិ សំវេគំ អាបជ្ជតិ កិន្នុ ខោ មំ អជ្ជ អស្សទម្មសារថិ ការណំ ការេស្សតិ កិមស្សាហំ[១] បដិករោមីតិ ។

១ ម. កតមស្សាហំ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះ ឈ្មោះថាជាអ្នកគួរទទួលនូវទាន ដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្ត ដ៏ប្រសើរនៃសត្វលោក ។

[១១៣] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើន មាន ៤ ពួក រមែងមាននៅក្នុងលោក ។ ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ សេះអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ បានឃើញនូវស្រមោលនៃជន្លួញហើយ ក៏រំភើបដល់នូវសេចក្តីតក់ស្លុតថា សារថីជាអ្នកទូន្មាននូវសេះ ដែលគួរទូន្មាន នឹងធ្វើហេតុអ្វីដល់អញក្នុងថ្ងៃនេះ អញនឹងធ្វើតបទៅសារថីនោះដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ មានសភាពដូច្នោះដែរ ម្នាលភិក្ខុទាំងឡាយនេះជាសេះអាជានេយ្យដ៏ចម្រើនទី ១ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះអាជានេយ្យដ៏ចម្រើន ពួកខ្លះ ក្នុងលោកនេះ បានឃើញស្រមោលនៃជន្លួញ ហើយនៅតែមិនរំភើបដល់នូវសេចក្តីតក់ស្លុតទេ លុះតែគេចាក់ត្រង់រោម ដោយជន្លួញ ទើបរំភើបដល់នូវសេចក្តីតក់ស្លុតថា សារថីជាអ្នកទូន្មាននូវសេះ ដែលគួរទូន្មាន នឹងធ្វើហេតុអ្វីដល់អញក្នុងថ្ងៃនេះ  អញនឹងធ្វើតបទៅសារថីនោះដូចម្តេច ។

ឯវរូបោបិ ភិក្ខវេ ឯកច្ចោ ភទ្រោ អស្សាជានីយោ ហោតិ អយំ ភិក្ខវេ ទុតិយោ ភទ្រោ អស្សាជានីយោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឯកច្ចោ ភទ្រោ អស្សាជានីយោ ន ហេវ ខោ បតោទច្ឆាយំ ទិស្វា សំវិជតិ សំវេគំ អាបជ្ជតិ នបិ លោមវេធវិទ្ធោ សំវិជតិ សំវេគំ អាបជ្ជតិ អបិច ខោ ចម្មវេធវិទ្ធោ[១] សំវិជតិ សំវេគំ អាបជ្ជតិ កិន្នុខោ មំ អជ្ជ អស្សទម្មសារថិ ការណំ ការេស្សតិ កិមស្សាហំ បដិករោមីតិ ។ ឯវរូបោបិ ភិក្ខវេ ឯកច្ចោ ភទ្រោ អស្សាជានីយោ ហោតិ អយំ ភិក្ខវេ តតិយោ ភទ្រោ អស្សាជានីយោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឯកច្ចោ ភទ្រោ អស្សាជានីយោ ន ហេវ ខោ បតោទច្ឆាយំ ទិស្វា សំវិជតិ សំវេគំ អាបជ្ជតិ នបិ លោមវេធវិទ្ធោ សំវិជតិ សំវេគំ អាបជ្ជតិ នបិ ចម្មវេធវិទ្ធោ សំវិជតិ សំវេគំ អាបជ្ជតិ អបិច ខោ អដ្ឋិវេធវិទ្ធោ

១ ឱ. មំសវេធវិទ្ធោ ។

ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើន ពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ នេះជាសេះអាជានេយ្យដ៏ចម្រើនទី ២ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះអាជានេយ្យដ៏ចម្រើន ពួកខ្លះ ក្នុងលោកនេះ ឃើញនូវស្រមោលនៃជន្ទួញ ហើយនៅតែមិនរំភើបដល់នូវសេចក្តីតក់ស្លុត ទុកជាចាក់ត្រង់រោម (ដោយជន្ទួញ) ក៏នៅតែមិនរំភើបដល់នូវសេចក្តីតក់ស្លុតដែរ លុះតែចាក់ត្រង់ស្បែក ដោយជន្ទួញ ទើបរំភើបដល់នូវសេចក្តីតក់ស្លុតថា សារថីជាអ្នកទូន្មាននូវសេះ ដែលគួរទូន្មាន នឹងធ្វើនូវហេតុអ្វីដល់អញ អញនឹងធ្វើតបទៅសារថីនោះ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើន ពួកខ្លះ ក្នុងលោកនេះ មានសភាពដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះជាសេះអាជានេយ្យដ៏ចម្រើនទី ៣ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះអាជានេយ្យដ៏ចម្រើន ពួកខ្លះ ក្នុងលោកនេះ បានឃើញស្រមោលនៃជន្ទួញហើយ នៅតែមិនរំភើបដល់នូវសេចក្តីតក់ស្លុត ទុកជាគេចាក់ត្រង់រោម ដោយជន្ទួញ ក៏នៅតែមិនរំភើបដល់នូវសេចក្តីតក់ស្លុតដែរ ទុកជាគេចាក់ត្រង់ស្បែកដោយជន្ទួញ ក៏នៅតែមិនរំភើបដល់នូវសេចក្តីតក់ស្លុតដែរ លុះតែគេចាក់ដល់ឆ្អឹងដោយជន្ទួញ

សំវិជតិ សំវេគំ អាបជ្ជតិ កិន្នុ ខោ មំ អជ្ជ អស្ស-
ទម្មសារថិ ការណំ ការេស្សតិ កិមស្សាហំ បដិ-
ករោមីតិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ ភទ្រោ
អស្សាជានីយោ ហោតិ អយំ ភិក្ខវេ ចតុត្ថោ ភទ្រោ
អស្សាជានីយោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ ឥមេ
ខោ ភិក្ខវេ ចត្តារោ ភទ្រា អស្សាជានីយា សន្តោ
សំវិជ្ជមានា លោកស្មឹ ។ ឯវមេវ ខោ ភិក្ខវេ
ចត្តារោមេ ភទ្រា បុរិសាជានីយា សន្តោ សំវិជ្ជ-
មានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ
ភិក្ខវេ ឯកច្ចោ ភទ្រោ បុរិសាជានីយោ សុណាតិ
អមុកស្មឹ ជាម គាមេ វា និគមេ វា ឥត្ថី វា បុរិសោ
វា ទុក្ខិតោ វា កាលកតោ វាតិ សោ តេន
សំវិជតិ សំវេគំ អាបជ្ជតិ សំវិគ្គោ យោនិសោ
បទហាតិ បហិតត្តោ កាយេន ចេវ បរមសច្ចំ
សច្ឆិករោតិ បញ្ញាយ ច អតិវិជ្ឈ បស្សតិ
សេយ្យថាបិ សោ ភិក្ខវេ ភទ្រោ អស្សាជានីយោ
បតោទច្ឆាយំ ទិស្វា សំវិជតិ សំវេគំ អាបជ្ជតិ

ទើបរំភើប ដល់នូវសេចក្តីតក់ស្លុតថា សារថីជាអ្នកទូន្មាននូវសេះ ដែលគួរទូន្មាន នឹងធ្វើហេតុអ្វីដល់អញក្នុងថ្ងៃនេះ អញនឹងត្រូវធ្វើតបទៅនាយសារថីនោះដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើន ពួកខ្លះក្នុងលោកនេះ ក៏មានសភាពយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ នេះជាសេះអាជានេយ្យដ៏ចម្រើនទី ២ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើន ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ចម្រើននេះមាន ៤ ពួក រមែងមាននៅក្នុងលោកក៏ដូច្នោះដែរ ។ ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ ឮថាស្ត្រីឬបុរសក្នុងស្រុកឬនិគមឯណោះ ដល់នូវសេចក្តីទុក្ខក្តី ធ្វើមរណកាលទៅក្តី បុរសអាជានេយ្យនោះ ក៏រំភើបដល់នូវសេចក្តីតក់ស្លុតដោយហេតុនោះ (បុរសអាជានេយ្យនោះ) ជាអ្នកតក់ស្លុត តម្កល់ព្យាយាម ដោយឧបាយនៃប្រាជ្ញា មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបធ្វើឲ្យជាក់ច្បាស់ នូវបរមសច្ចៈដោយនាមកាយផង ចាក់ធ្លុះ ឃើញច្បាស់ ដោយបញ្ញាផង ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើននោះ គ្រាន់តែឃើញនូវស្រមោលជន្លួញហើយ ក៏រំភើបដល់នូវសេចក្តីតក់ស្លុត មានឧបមាយ៉ាងណា

តថូបមាហំ ភិក្ខវេ ឥមំ ភទ្រំ បុរិសាជានីយំ វទាមិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ ភទ្រោ បុរិសាជានីយោ ហោតិ អយំ ភិក្ខវេ បឋមោ ភទ្រោ បុរិសាជានីយោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ ភទ្រោ បុរិសាជានីយោ ន ហេវ ខោ សុណាតិ អមុកស្មឹ គាមេ វា និគមេ វា ឥត្ថី វា បុរិសោ វា ទុក្ខិតោ វា កាលកតោ វាតិ អបិច ខោ សាមំ បស្សតិ ឥត្ថឹ វា បុរិសំ វា ទុក្ខិតំ វា កាលកតំ វា សោ តេន សំវិជតិ សំវេគំ អាបជ្ជតិ សំវិគ្គោ យោនិសោ បទហតិ បហិតត្តោ កាយេន ចេវ បរមសច្ចំ សច្ឆិករោតិ បញ្ញាយ ច អតិវិជ្ឈ បស្សតិ សេយ្យថាបិ សោ ភិក្ខវេ ភទ្រោ អស្សាជានីយោ លោមវេធវិទ្ធោ សំវិជតិ សំវេគំ អាបជ្ជតិ តថូបមាហំ ភិក្ខវេ ឥមំ ភទ្រំ បុរិសាជានីយំ វទាមិ ។

ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុរសអាជានេយ្យដ៏ចម្រើននេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ មានសភាពដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះ បុរសអាជានេយ្យដ៏ចម្រើនទី ១ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុរសអាជានេយ្យដ៏ចម្រើន ពួកខ្លះ ក្នុងលោកនេះ មិនបានឮថា ស្ត្រីឬបុរសក្នុងស្រុក ឬនិគមឯណោះ ដល់នូវសេចក្តីទុក្ខ ឬធ្វើមរណកាល ស្រាប់តែឃើញដោយខ្លួនឯង នូវស្ត្រីឬបុរសដល់នូវសេចក្តីទុក្ខ ឬធ្វើមរណកាល បុរសអាជានេយ្យនោះក៏រំភើបដល់នូវសេចក្តីតក់ស្លុត ដោយហេតុនោះ (បុរសអាជានេយ្យនោះ) ជាអ្នកតក់ស្លុត តម្កល់នូវសេចក្តីព្យាយាមដោយឧបាយនៃប្រាជ្ញា មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបធ្វើឲ្យជាក់ច្បាស់នូវបរមសច្ចៈ ដោយនាម-កាយផង ចាក់ធ្លុះ ឃើញច្បាស់ដោយបញ្ញាផង ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើននោះ គ្រាន់តែត្រូវគេចាក់ដោយជន្លួញត្រង់រោម ក៏រំភើបដល់នូវសេចក្តីតក់ស្លុត មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុរសអាជានេយ្យដ៏ចម្រើននេះ មានឧបមេយ្យដូច្នោះដែរ ។

ឯវរូបោបិ ភិក្ខវេ ឯកច្ចោ ភទ្រោ បុរិសាជានីយោ ហោតិ អយំ ភិក្ខវេ ទុតិយោ ភទ្រោ បុរិសាជានីយោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឯកច្ចោ ភទ្រោ បុរិសាជានីយោ ន ហេវ ខោ សុណាតិ អមុកស្មឹ នាម គាមេ វា និគមេ វា ឥត្ថី វា បុរិសោ វា ទុក្ខិតោ វា កាលកតោ វាតិ នបិ សាមំ បស្សតិ ឥត្ថឹ វា បុរិសំ វា ទុក្ខិតំ វា កាលកតំ វា អបិច ខ្វស្ស ញាតិ វា សាលោហិតោ វា ទុក្ខិតោ វា ហោតិ កាលកតោ វា សោ តេន សំវិជតិ សំវេគំ អាបជ្ជតិ សំវិគ្គោ យោនិសោ បទហតិ បហិ-តត្តោ កាយេន ចេវ បរមសច្ចំ សច្ឆិករោតិ បញ្ញាយ ច អតិវិជ្ឈ បស្សតិ សេយ្យថាបិ សោ ភិក្ខវេ ភទ្រោ អស្សាជានីយោ ចម្មវេធវិទ្ធោ សំវិជតិ សំវេគំ អាបជ្ជតិ តថូបមាហំ ភិក្ខវេ ឥមំ ភទ្រំ បុរិសាជានីយំ វទាមិ ។ ឯវរូបោបិ ភិក្ខវេ ឯកច្ចោ ភទ្រោ បុរិសាជានីយោ

ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ចម្រើន ពួកខ្លះ ក្នុងលោកនេះ មានសភាពដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះជាបុរសអាជានេយ្យដ៏ចម្រើនទី ២ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុរសអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ មិនបានឮថា ស្ត្រីឬបុរសក្នុងស្រុក ឬក្នុងនិគមឯណោះ ដល់នូវសេចក្តីទុក្ខ ឬធ្វើមរណកាល ទាំងមិនបានឃើញដោយខ្លួនឯង នូវស្ត្រីឬបុរស ដល់នូវសេចក្តីទុក្ខ ឬធ្វើមរណកាលឡើយ មួយទៀត លុះតែញាតិឬសាលោហិត របស់បុរសអាជានេយ្យនោះ ដល់នូវសេចក្តីទុក្ខឬធ្វើមរណកាលទៅ បុរសអាជានេយ្យនោះទើបរំភើបដល់នូវសេចក្តីតក់ស្លុត ដោយហេតុនោះ (បុរសអាជានេយ្យនោះ) ជាអ្នកតក់ស្លុត តម្កល់នូវសេចក្តីព្យាយាម ដោយឧបាយនៃប្រាជ្ញា មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបធ្វើឲ្យជាក់ច្បាស់នូវបរមសច្ចៈ ដោយនាមកាយផង ចាក់ធ្លុះ ឃើញច្បាស់ ដោយបញ្ញាផង ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើននោះ ត្រូវគេចាក់ដោយជន្លួញត្រង់ស្បែក ទើបរំភើបដល់នូវសេចក្តីតក់ស្លុត មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុរសអាជានេយ្យដ៏ចម្រើននេះ មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ចម្រើន ពួកខ្លះ ក្នុងលោកនេះ មានសភាពដូច្នេះ

ហោតិ អយំ ភិក្ខវេ តតិយោ ភទ្រោ បុរិសាជានីយោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ ភទ្រោ បុរិសាជានីយោ ន ហេវ ខោ សុណាតិ អមុកស្មឹ គាមេ វា និគមេ វា ឥត្ថី វា បុរិសោ វា ទុក្ខិតោ វា កាលកតោ វាតិ នបិ សាមំ បស្សតិ ឥត្ថឹ វា បុរិសំ វា ទុក្ខិតំ វា កាលកតំ វា នបិស្សុ ញាតិ វា សាលោហិតោ វា ទុក្ខិតោ វា ហោតិ កាលកតោ វា អបិច ខោ សាមញ្ញេវ ផុដ្ឋោ ហោតិ សារីរិកាហិ វេទនាហិ ទុក្ខាហិ តិព្វាហិ ខរាហិ កដុកាហិ អសាតាហិ អមនាបាហិ បាណហរាហិ សោ តេន សំវិជតិ សំវេគំ អាបជ្ជតិ សំវិគ្គោ យោនិសោ បទហតិ បហិតត្តោ កាយេន ចេវ បរមសច្ចំ សច្ឆិករោតិ បញ្ញាយ ច អតិវិជ្ឈ បស្សតិ សេយ្យថាបិ សោ ភិក្ខវេ ភទ្រោ អស្សាជានីយោ អដ្ឋិវេធវិទ្ធោ សំវិជតិ សំវេគំ អាបជ្ជតិ តថូបមាហំ ភិក្ខវេ ឥមំ ភទ្រំ បុរិសាជានីយំ វទាមិ ។

ម្នាលភិក្ខុទាំងឡាយ នេះជាបុរសអាជានេយ្យដ៏ចម្រើនទី ៣ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុរសអាជានេយ្យដ៏ចម្រើនពួកខ្លះ ក្នុងលោកនេះ មិនឮថា ស្រ្តី ឬបុរសក្នុងស្រុក ឬនិគមឯណោះដល់នូវសេចក្តីទុក្ខ ឬធ្វើមរណកាល ទាំងមិនឃើញដោយខ្លួនឯង នូវស្រ្តីឬបុរសដល់នូវសេចក្តីទុក្ខឬធ្វើមរណកាលទៅ ទោះបីញាតិឬសាលោហិតរបស់បុរសអាជានេយ្យនោះក៏មិនដល់នូវសេចក្តីទុក្ខ ឬធ្វើមរណកាលទៅ ស្រាប់តែខ្លួនឯង ពាល់ត្រូវដោយទុក្ខវេទនា ជាទីប្រជុំចុះក្នុងកាយដ៏ក្លាខ្លាំងរឹងរូសក្តៅផ្សា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ជាទីនាំបង់នូវជីវិត បុរសអាជានេយ្យនោះ ក៏រំភើបដល់នូវសេចក្តីតក់ស្លុតដោយហេតុនោះ (បុរសអាជានេយ្យនោះ) ជាអ្នកតក់ស្លុត ទើបតម្កល់សេចក្តីព្យាយាមដោយឧបាយនៃប្រាជ្ញា មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបធ្វើឲ្យជាក់ច្បាស់នូវបរមសច្ចៈដោយនាមកាយផង ចាក់ធ្លុះឃើញច្បាស់ដោយបញ្ញាផង ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើននោះ ត្រូវគេចាក់ដោយជន្លួញត្រង់ឆ្អឹងក៏រំភើបដល់នូវសេចក្តីតក់ស្លុត មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុរសអាជានេយ្យដ៏ចម្រើននេះ មានឧបមេយ្យដូច្នោះដែរ ។

ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ ភទ្រោ បុរិសាជានីយោ ហោតិ អយំ ភិក្ខវេ ចតុត្ថោ ភទ្រោ បុរិសាជានីយោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ភទ្រា បុរិសាជានីយា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១១៤] ចតូហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ នាគោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេ្វវ សង្ខំ គច្ឆតិ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ សោតា ច ហោតិ ហន្តា ច ខន្តា ច គន្តា ច ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ សោតា ហោតិ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ យមេនំ ហត្ថិទម្មសារថិ ការណំ ការេតិ យទិ វា កតបុព្វំ យទិ វា អកតបុព្វំ តំ អដ្ឋិកត្វា មនសិកត្វា សព្វំ ចេតសោ សមន្នាហរិត្វា ឱហិតសោ្សតោ សុណាតិ ។ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ សោតា ហោតិ ។

ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ចម្រើន ពួកខ្លះ ក្នុងលោកនេះ មានសភាពដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះជាបុរសអាជានេយ្យដ៏ចម្រើន ទី ៤ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យ ដ៏ចម្រើន ៤ ពួកនេះ រមែងមាននៅក្នុងលោក ។

[១១៤] ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេចប្រកបដោយអង្គ ៤ ជាដំរីគួរដល់ស្តេច ទុកជាព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គរបស់ស្តេច ។ ប្រកបដោយអង្គ ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេចក្នុងលោកនេះ ជាសត្វមានត្រចៀក (រៃ) ១ ជាសត្វបៀតបៀន ១ ជាសត្វអត់ធ្មត់ ១ ជាសត្វដើរ (លឿន) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច ជាសត្វមានត្រចៀក (រៃ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ សារថី អ្នកបង្ហាត់នូវដំរីដែលគួរបង្ហាត់ ឲ្យធ្វើនូវហេតុណា ទោះបីខ្លួនធ្លាប់ធ្វើក្តី ទោះបីខ្លួនមិនធ្លាប់ធ្វើក្តី ក៏ធ្វើនូវហេតុនោះឲ្យមានប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវហេតុទាំងអស់ដោយចិត្ត មានត្រចៀកផ្ទៀងស្តាប់ ។

កថញ្ច ភិក្ខវេ រញ្ញោ នាគោ ហន្តា ហោតិ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ សង្គាមគតោ ហត្ថិម្បិ ហនតិ ហត្ថារូហម្បិ ហនតិ អស្សម្បិ ហនតិ អស្សារូហម្បិ ហនតិ រថម្បិ ហនតិ រថិកម្បិ ហនតិ បត្តិកម្បិ ហនតិ ។ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ ហន្តា ហោតិ ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ ខន្តា ហោតិ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ សង្គាមគតោ ខមោ ហោតិ សត្តិប្បហារានំ ឥសិប្បហារានំ[១] ឧសុប្បហារានំ[២] ភេរិបណវសង្ខ-តិណវនិន្នាទសទ្ទានំ ។ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ ខន្តា ហោតិ ។ កថញ្ច ភិក្ខវេ រញ្ញោ នាគោ គន្តា ហោតិ ។ ឥធ ភិក្ខវេ រញ្ញោ នាគោ

១ ឱ. អសិប្បហារានំ ។ ២ ឱ. ម. ផរុសុប្បហារានំ ។

ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេចជាសត្វមានត្រចៀក (រៃ) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច ជាសត្វបៀតបៀន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេចក្នុងលោកនេះ កាលចូលសង្គ្រាម ក៏បៀតបៀននូវដំរីផងគ្នាផង បៀតបៀននូវទ្រម័កដំរីផង បៀតបៀននូវសេះផង បៀតបៀននូវអ្នកជិះសេះផង បៀតបៀននូវរថផង បៀតបៀននូវបុរសអ្នកជិះរថផង បៀតបៀននូវសេនាថ្មើរជើងផង ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេចជាសត្វបៀតបៀនយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច ជាសត្វអត់ធ្មត់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ កាលចូលសង្គ្រាម ជាសត្វអត់ធ្មត់នឹងការប្រហារដោយលំពែង ប្រហារដោយដាវ ប្រហារដោយព្រួញ (ជាសត្វអត់ធ្មត់) នឹងសំឡេងស្គរជ័យ ខ្ចៅ ស័ង្ខ ស្គរធំ និងសូរសំឡេងគឹកកងទាំងឡាយបាន ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វអត់ធ្មត់យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច ជាសត្វដើរ (លឿន) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ

យមេនំ ហត្ថិទម្មសារថិ ទិសំ បេសេតិ យទិ វា គតបុព្វំ យទិ វា អគតបុព្វំ តំ ខិប្បញ្ញេវ គន្តា ហោតិ ។ ឯវំ ខោ ភិក្ខវេ រញ្ញោ នាគោ គន្តា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ អង្គេហិ សមន្នាគតោ រញ្ញោ នាគោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្ត្វេវ សង្ខ្យំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ ភិក្ខុ សោតា ច ហោតិ ហន្តា ច ខន្តា ច គន្តា ច ។ កថញ្ច ភិក្ខវេ ភិក្ខុ សោតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ តថាគតប្បវេទិតេ ធម្មវិនយេ ទេសិយមានេ អដ្ឋិកត្វា មនសិកត្វា សព្វំ ចេតសោ សមន្នាហរិត្វា ឱហិតស្សោតោ ធម្មំ សុណាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សោតា ហោតិ ។

សារថីអ្នកបង្ហាត់នូវដំរីដែលគួរបង្ហាត់ បញ្ជូនទៅកាន់ទិសណា ទោះបីធ្លាប់ទៅក្តី មិនធ្លាប់ទៅក្តី ក៏ជាសត្វដើរ (លឿន) ទៅកាន់ទិសនោះដោយឆាប់ ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វដើរ (លឿន) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៤ នេះ ជាដំរីគួរដល់ស្តេច ទុកជាព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គរបស់ស្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងក៏ដូច្នោះដែរ គឺជាអ្នកគួរទទួលនូវទាន ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសោតប្រសាទផង ជាអ្នកបៀតបៀនផង ជាអ្នកអត់ធ្មត់ផង ជាអ្នកដើរ (លឿន) ផង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកមានសោតប្រសាទ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលគេកំពុងសម្តែងធម្មវិន័យដែលតថាគតប្រកាសហើយ ក៏ធ្វើឲ្យមានប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវធម្មវិន័យទាំងអស់ដោយចិត្ត មានសោតប្រសាទ ផ្ទៀងចុះចាំស្តាប់នូវធម៌ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសោតប្រសាទយ៉ាងនេះឯង ។

កថញ្ច ភិក្ខវេ ភិក្ខុ ហន្តា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ឧប្បន្នំ ព្យាបាទវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ឧប្បន្នំ វិហឹសាវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ហន្តា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ខន្តា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ខមោ ហោតិ សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ ឌំស-មកសវាតាតបសិរឹសបសម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អធិវាសកជាតិកោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបៀតបៀន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទទួលរ៉ាប់រង លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមាន តទៅទៀតនូវកាមវិតក្កៈដែលកើតឡើងហើយ មិនទទួលរ៉ាប់រង លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើត តទៅទៀត នូវព្យាបាទវិតក្កៈដែលកើតឡើងហើយ មិនទទួលរ៉ាប់រង លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើត តទៅទៀត នូវវិហឹសាវិតក្កៈដែលកើតឡើងហើយ មិនទទួលរ៉ាប់រង លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមាន តទៅទៀត នូវអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយ ៗ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបៀតបៀនយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកអត់ធ្មត់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកអត់ធ្មត់នូវត្រជាក់ ក្តៅ សេចក្តីឃ្លាន សេចក្តីស្រេក សម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃនិងពស់តូច ពស់ធំទាំងឡាយ និងពាក្យដែលគេនិយាយអាក្រក់ និងគន្លងនៃពាក្យដែលកើតឡើង និងទុក្ខវេទនា ជាទីប្រជុំចុះក្នុងសរីរៈ ដ៏ក្លាខ្លាំង រឹងរូស ក្តៅផ្សា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ជាទីនាំបង់នូវជីវិត ជាអ្នកប្រកបដោយអធិវាសនក្ខន្តិ ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ ខន្តា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ គន្តា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យា ទិសា[1] អគតបុព្វា ឥមិនា ទីឃេន អទ្ធុនា យទិទំ សព្វសង្ខារសមថោ សព្វុបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ តំ ខិប្បញ្ញេវ គន្តា ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ គន្តា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[១១៨] ចត្តារីមានិ ភិក្ខវេ ឋានានិ ។ កតមានិ ចត្តារិ ។ អត្ថិ ភិក្ខវេ ឋានំ អមនាបំ កាតុំ តញ្ច ករិយមានំ អនត្ថាយ សំវត្តតិ អត្ថិ ភិក្ខវេ ឋានំ អមនាបំ កាតុំ តញ្ច ករិយមានំ អត្ថាយ សំវត្តតិ

១ ម. យាយ ទិសា ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកអត់ធ្មត់យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកដើរ (លឿន) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទិសណាដែលគេមិនធ្លាប់ទៅ ដោយកាលយូរអង្វែងនេះ សភាវៈណា ដែលជាទីរម្ងាប់បង់នូវសង្ខារទាំងពួង ជាទីលះបង់នូវឧបធិទាំងពួង ជាទីអស់ទៅនៃតណ្ហា ជាទីប្រាសចាករាគៈ ជាទីរលត់ គឺព្រះនិព្វាន ភិក្ខុក្នុងសាសនានេះ ជាអ្នកដើរទៅកាន់ទិសនិងសភាវៈនោះដោយឆាប់រួសរាន់បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដើរ (លឿន) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះ ជាអ្នកគួរទទួលនូវទាន ដែលគេនាំមកបូជា ជាអ្នកគួរទទួលនូវអាគន្តុកទាន ជាអ្នកគួរទទួលនូវទក្ខិណាទាន ជាអ្នកគួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្ត ដ៏ប្រសើររបស់សត្វលោក ។

[១១៥] ម្នាលភិក្ខុទាំងឡាយ ហេតុនេះមាន ៤ យ៉ាង ។ ហេតុ ៤ យ៉ាងដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើនូវហេតុមិនជាទីគាប់ចិត្ត ហេតុដែលគួរធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនជាប្រយោជន៍ក៏មាន ម្នាលភិក្ខុទាំងឡាយ ការធ្វើនូវហេតុមិនជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ក៏មាន

អត្ថិ ភិក្ខវេ ឋានំ មនាបំ កាតុំ តញ្ច កយិ-
រមានំ អនត្ថាយ សំវត្តតិ អត្ថិ ភិក្ខវេ ឋានំ
មនាបំ កាតុំ តញ្ច កយិរមានំ អត្ថាយ សំវត្តតិ ។
តត្រ ភិក្ខវេ យមិទំ ឋានំ អមនាបំ កាតុំ តញ្ច
កយិរមានំ អនត្ថាយ សំវត្តតិ ឥទំ ភិក្ខវេ ឋានំ
ឧភយេនេវ ន កត្តព្វំ មញ្ញតិ យម្បិទំ ឋានំ
អមនាបំ កាតុំ ឥមិនាបិ ន កត្តព្វំ[១] មញ្ញតិ
យម្បិទំ ឋានំ កយិរមានំ អនត្ថាយ សំវត្តតិ
ឥមិនាបិ ន កត្តព្វំ មញ្ញតិ ឥទំ ភិក្ខវេ ឋានំ
ឧភយេនេវ ន កត្តព្វំ មញ្ញតិ ។ តត្រ ភិក្ខវេ
យមិទំ ឋានំ អមនាបំ កាតុំ តញ្ច កយិរមានំ
អត្ថាយ សំវត្តតិ ឥមស្មឹ ភិក្ខវេ ឋានេ ពាលោ ច
បណ្ឌិតោ ច វេទិតព្វោ បុរិសត្ថាមេ បុរិសវីរិយេ

១ ឱ. ឥមិនាបិ តំ ន កត្តព្វំ ។ ម. ឥមិនាបិ ន កត្តព្វំ ។

ម្នាលភិក្ខុទាំងឡាយ ការធ្វើនូវហេតុជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ក៏មាន ម្នាលភិក្ខុទាំងឡាយ ការធ្វើនូវហេតុមិនជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ បណ្តាហេតុទាំង ៤ យ៉ាងនោះ ការធ្វើនូវហេតុណា មិនជាទីគាប់ចិត្ត ហេតុដែលធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ បុគ្គល រមែងសម្គាល់នូវហេតុនេះ ថាជាហេតុដែលខ្លួនមិនត្រូវធ្វើ ដោយហេតុ ២ ប្រការ គឺការធ្វើនូវហេតុណា មិនជាទីគាប់ចិត្ត ក៏សម្គាល់នូវហេតុនេះ ថាជាហេតុដែលខ្លួនមិនត្រូវធ្វើ ១ ហេតុណាដែលបុគ្គលធ្វើ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ក៏សម្គាល់នូវហេតុនេះ ថាជាហេតុដែលខ្លួនមិនត្រូវធ្វើ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គល រមែងសម្គាល់នូវហេតុនេះថាជាហេតុដែលខ្លួនមិនត្រូវធ្វើដោយហេតុ ២ ប្រការ ។ ម្នាលភិក្ខុទាំង-ឡាយ បណ្តាហេតុទាំង ៤ យ៉ាងនោះ ការធ្វើនូវហេតុណា មិនជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ ជនជាពាលក្តី ជាបណ្ឌិតក្តី គេត្រូវដឹងច្បាស់ក្នុងហេតុនេះ គឺក្នុងកម្លាំងរបស់បុរស ក្នុងសេចក្តីព្យាយាមរបស់បុរស

បុរិសបរក្កមេ ន ភិក្ខវេ ពាលោ ឥតិ បដិសញ្ចិក្ខតិ កិញ្ចាបិ ខោ ឥទំ ឋានំ អមនាបំ កាតុំ អថចរហីទំ ឋានំ ករិយមានំ អត្ថាយ សំវត្តតីតិ សោ តំ ឋានំ ន ករោតិ តស្ស តំ ឋានំ អករិយមានំ អនត្ថាយ សំវត្តតិ ។ បណ្ឌិតោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ កិញ្ចាបិ ខោ ឥទំ ឋានំ អមនាបំ កាតុំ អថចរហីទំ ឋានំ ករិយមានំ អត្ថាយ សំវត្តតីតិ សោ តំ ឋានំ ករោតិ តស្ស តំ ឋានំ ករិយមានំ អត្ថាយ សំវត្តតិ ។ តត្រ ភិក្ខវេ យទិទំ ឋានំ មនាបំ កាតុំ តញ្ច ករិយមានំ អនត្ថាយ សំវត្តតិ ឥមស្មឹបិ ភិក្ខវេ ឋានេ ពាលោ ច បណ្ឌិតោ ច វេទិតព្វោ បុរិសត្ថាមេ បុរិសវីរិយេ បុរិសបរក្កមេ ន ភិក្ខវេ ពាលោ ឥតិ បដិសញ្ចិក្ខតិ កិញ្ចាបិ ខោ ឥទំ ឋានំ មនាបំ កាតុំ អថចរហីទំ ឋានំ ករិយមានំ អនត្ថាយ សំវត្តតីតិ សោ តំ ឋានំ ករោតិ តស្ស តំ ឋានំ ករិយមានំ អនត្ថាយ សំវត្តតិ ។

ក្នុងសេចក្តីប្រឹងប្រែងរបស់បុរស ម្នាលភិក្ខុទាំងឡាយ ជនពាលមិនពិចារ-ណាដូច្នេះថា ការធ្វើនូវហេតុមិនជាទីគាប់ចិត្តនេះ ក៏ពិតមែនហើយ តែហេតុដែលធ្វើនេះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ជនពាលនោះទើបមិនធ្វើនូវហេតុនោះ ហេតុដែលជនពាលមិនធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកឯបណ្ឌិត រមែងពិចារណា ដូច្នេះថា ការធ្វើនូវហេតុមិនជាទីគាប់ចិត្តនេះ ក៏ពិតមែនហើយ តែហេតុដែលបណ្ឌិតធ្វើនេះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ បណ្ឌិតនោះ ទើបធ្វើនូវហេតុនោះ ហេតុដែលបណ្ឌិតធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាហេតុទាំង ៤ យ៉ាងនោះ ការធ្វើនូវហេតុណា ជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ ជនជាពាលក្តី ជាបណ្ឌិតក្តី គេត្រូវដឹងច្បាស់ក្នុងហេតុនេះ គឺក្នុងកម្លាំងរបស់បុរស ក្នុងសេចក្តីព្យាយាមរបស់បុរស ក្នុងសេចក្តីប្រឹងប្រែងរបស់បុរស ម្នាលភិក្ខុទាំងឡាយ ជនពាលមិនពិចារណា ដូច្នេះថា ការធ្វើនូវហេតុជាទីគាប់ចិត្តនេះ ក៏ពិតមែនហើយ តែហេតុដែលធ្វើនេះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ជនពាលនោះ ទើបធ្វើនូវហេតុនោះ ហេតុដែលជនពាលធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ។

បណ្ឌិតោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ កិញ្ចាបិ ខោ ឥទំ ឋានំ មនាបំ កាតុំ អថចរហីទំ ឋានំ កយិរមានំ អនត្ថាយ សំវត្តតីតិ សោ តំ ឋានំ ន ករោតិ តស្ស តំ ឋានំ អកយិរមានំ អត្ថាយ សំវត្តតិ ។ តត្រ ភិក្ខវេ យទិទំ ឋានំ មនាបំ កាតុំ តញ្ច កយិរមានំ អត្ថាយ សំវត្តតិ ឥទំ ភិក្ខវេ ឋានំ ឧភយេនេវ កត្តព្វំ មញ្ញតិ យម្បិទំ ឋានំ មនាបំ កាតុំ ឥមិនាបិ កត្តព្វំ មញ្ញតិ យម្បិទំ ឋានំ កយិរមានំ អត្ថាយ សំវត្តតិ ឥមិនាបិ កត្តព្វំ មញ្ញតិ ឥទំ ភិក្ខវេ ឋានំ ឧភយេនេវ កត្តព្វំ មញ្ញតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ឋានានីតិ ។

ម្នាលភិក្ខុទាំងឡាយ ចំណែកឯបណ្ឌិត រមែងពិចារណា ដូច្នេះថា ការធ្វើនូវហេតុជាទីគាប់ចិត្តនេះ ក៏មែនពិតហើយ តែថា ហេតុដែលធ្វើនេះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ទើបបណ្ឌិតនោះមិនធ្វើនូវហេតុនោះ ហេតុដែលបណ្ឌិត មិនធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាហេតុទាំង ៤ យ៉ាងនោះ ការធ្វើនូវហេតុណា ជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ បុគ្គល រមែងសម្គាល់នូវហេតុនេះ ថាជាហេតុដែលខ្លួនត្រូវធ្វើ ដោយហេតុ ២ ប្រការ គឺការធ្វើនូវហេតុណា ជាទីគាប់ចិត្ត ក៏សម្គាល់នូវហេតុនេះ ថាជាហេតុដែលខ្លួនត្រូវធ្វើ ១ ហេតុណាដែលខ្លួនធ្វើ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ក៏សម្គាល់នូវហេតុនេះ ថាជាហេតុដែលខ្លួនត្រូវធ្វើ ១ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតសម្គាល់នូវហេតុនេះ ថាជាហេតុដែលខ្លួនត្រូវធ្វើដោយហេតុ ២ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ ហេតុមាន ៤ យ៉ាងនេះឯង ។

[១១៦] ចតូហិ ភិក្ខវេ ឋានេហិ អប្បមាទោ ករណីយោ ។ កតមេហិ ចតូហិ ។ កាយ-ទុច្ចរិតំ ភិក្ខវេ បជហថ កាយសុចរិតំ ភាវេថ តត្ថ ច មា បមាទត្ថ ។ វចីទុច្ចរិតំ ភិក្ខវេ បជហថ វចីសុចរិតំ ភាវេថ តត្ថ ច មា បមាទត្ថ ។ មនោទុច្ចរិតំ ភិក្ខវេ បជហថ មនោសុចរិតំ ភាវេថ តត្ថ ច មា បមាទត្ថ ។ មិច្ឆាទិដ្ឋឹ ភិក្ខវេ បជហថ សម្មាទិដ្ឋឹ ភាវេថ តត្ថ ច មា បមាទត្ថ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ កាយទុច្ចរិតំ បហីនំ ហោតិ កាយសុចរិតំ ភាវិតំ វចីទុច្ចរិតំ បហីនំ ហោតិ វចីសុចរិតំ ភាវិតំ មនោទុច្ចរិតំ បហីនំ ហោតិ មនោសុចរិតំ ភាវិតំ មិច្ឆាទិដ្ឋិ បហីនា ហោតិ សម្មាទិដ្ឋិ ភាវិតា សោ ន ភាយតិ សម្បរាយិកស្ស មរណស្សាតិ[១] ។

១ ម. អន្តកស្សាតិ ។

[១១៦] ម្នាលភិក្ខុទាំងឡាយ បុគ្គលគប្បីធ្វើសេចក្ដីមិនប្រមាទ ដោយហេតុ ៤ យ៉ាង ។ ដោយហេតុ ៤ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់នូវកាយទុច្ចរិត ចូរចម្រើននូវកាយសុចរិតវិញ ទាំងកុំបីប្រមាទ ក្នុងកាយសុចរិតនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់នូវវចីទុច្ចរិត ចូរចម្រើននូវវចីសុចរិតវិញ ទាំងកុំបីធ្វេសប្រហែស ក្នុងវចីសុចរិតនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់នូវមនោទុច្ចរិត ចូរចម្រើននូវមនោសុចរិតវិញ ទាំងកុំបីធ្វេសប្រហែស ក្នុងមនោសុចរិតនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់នូវមិច្ឆាទិដ្ឋិ ចូរចម្រើននូវសម្មាទិដ្ឋិ ទាំងកុំបីធ្វេសប្រហែស ក្នុងសម្មាទិដ្ឋិនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុលះបង់នូវកាយទុច្ចរិត ចម្រើនកាយសុចរិត លះបង់វចីទុច្ចរិត ចម្រើនវចីសុចរិត លះបង់មនោទុច្ចរិត ចម្រើនមនោសុចរិត លះបង់មិច្ឆាទិដ្ឋិ ចម្រើនសម្មាទិដ្ឋិហើយ ភិក្ខុនោះតែងមិនខ្លាចសេចក្ដីស្លាប់ ដែលប្រព្រឹត្តទៅក្នុងខាងមុខ ។

[១១៧] ចតូសុ ភិក្ខវេ ឋានេសុ អត្តរូបេន អប្បមាទោ សតិចេតសោ អារក្ខោ ករណីយោ ។ កតមេសុ ចតូសុ ។ មា មេ រជនីយេសុ ធម្មេសុ ចិត្តំ រជ្ជីតិ អត្តរូបេន អប្បមាទោ សតិចេតសោ អារក្ខោ ករណីយោ មា មេ ទោសនីយេសុ ធម្មេសុ ចិត្តំ ទុស្សីតិ អត្តរូបេន អប្បមាទោ សតិចេតសោ អារក្ខោ ករណីយោ មា មេ មោហ-នីយេសុ ធម្មេសុ ចិត្តំ មុយ្ហីតិ អត្តរូបេន អប្បមាទោ សតិចេតសោ អារក្ខោ ករណីយោ មា មេ មទនីយេសុ ធម្មេសុ ចិត្តំ មជ្ជីតិ អត្តរូបេន អប្បមាទោ សតិចេតសោ អារក្ខោ ករណីយោ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ រជនីយេសុ ធម្មេសុ ចិត្តំ ន រជ្ជតិ វីតរាគត្តា ទោសនីយេសុ ធម្មេសុ ចិត្តំ ន ទុស្សតិ វីតទោសត្តា មោហនីយេសុ ធម្មេសុ ចិត្តំ ន មុយ្ហតិ វីតមោហត្តា

[១១៧] ម្នាលភិក្ខុទាំងឡាយ សេចក្ដីមិនប្រមាទគឺការថែរក្សាចិត្តដោយសតិ បុគ្គលគួរធ្វើតាមសមគួរដល់ខ្លួន ក្នុងហេតុ ៤ យ៉ាង ។ ហេតុ ៤ យ៉ាងដូចម្ដេចខ្លះ ។ គឺសេចក្ដីមិនប្រមាទ បានដល់ការថែរក្សាចិត្តដោយសតិ បុគ្គលគួរធ្វើ តាមសមគួរដល់ខ្លួនថា ចិត្តរបស់អាត្មាអញ កុំត្រេកត្រអាលទៅក្នុងធម៌ទាំងឡាយ ដែលគួរត្រេកត្រអាលឡើយ ១ សេចក្ដីមិនប្រមាទ បានដល់ការថែរក្សាចិត្តដោយសតិ ដែលបុគ្គលគួរធ្វើតាមសមគួរដល់ខ្លួនថា ចិត្តរបស់អាត្មាអញ កុំប្រទុស្ត ក្នុងធម៌ទាំងឡាយ ដែលគួរប្រទុស្តឡើយ ១ សេចក្ដីមិនប្រមាទ បានដល់ការថែរក្សានូវចិត្តដោយសតិ បុគ្គលគួរធ្វើតាមសមគួរដល់ខ្លួនថា ចិត្តរបស់អាត្មាអញ កុំភាន់ច្រឡំ ក្នុងធម៌ទាំងឡាយ ដែលគួរភាន់ច្រឡំ ១ សេចក្ដីមិនប្រមាទ បានដល់ការថែរក្សាចិត្តដោយសតិ បុគ្គលគួរធ្វើតាមសមគួរដល់ខ្លួនថា អាត្មាអញ កុំស្រវឹង ក្នុងធម៌ទាំងឡាយដែលគួរស្រវឹងឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុមានចិត្ត មិនត្រេកអរ ក្នុងធម៌ដែលគួរត្រេកអរ ព្រោះប្រាសចាករាគៈ មានចិត្ត មិនប្រទុស្ត ក្នុងធម៌ដែលគួរប្រទុស្ត ព្រោះប្រាសចាកទោសៈ មានចិត្ត មិនវង្វេង ក្នុងធម៌ដែលគួរវង្វេង ព្រោះប្រាសចាកមោហៈ

មទនីយេសុ ធម្មេសុ ចិត្តំ ន មជ្ជតិ វីតមទត្តា សោ នច្ឆម្ភតិ ន កម្បតិ ន វេធតិ ន សន្តាសំ អាបជ្ជតិ ន ច បន សមណវចនហេតុបិ គច្ឆតីតិ ។

[១១៨] ចត្តារីមានិ ភិក្ខវេ សទ្ធស្ស កុលបុត្តស្ស ទស្សនីយានិ សំវេជនីយានិ ឋានានិ ។ កតមានិ ចត្តារិ ។ ឥធ តថាគតោ ជាតោតិ ភិក្ខវេ សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ សំវេជនីយំ ឋានំ ឥធ តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ភិក្ខវេ សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ សំវេជនីយំ ឋានំ ឥធ តថាគតោ អនុត្តរំ ធម្មចក្កំ បវត្តេសីតិ ភិក្ខវេ សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ សំវេជនីយំ ឋានំ ឥធ តថាគតោ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វុតោតិ ភិក្ខវេ សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ សំវេជនីយំ ឋានំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ សទ្ធស្ស កុលបុត្តស្ស ទស្សនីយានិ សំវេជនីយានិ ឋានានីតិ ។

មានចិត្ត មិនស្រវឹង ក្នុងធម៌ដែលគួរស្រវឹង ព្រោះប្រាសចាកសេចក្តីស្រវឹង ភិក្ខុនោះមិនញាប់ញ័រ មិនកម្រើក មិនរន្ធត់ មិនដល់នូវសេចក្តីតក់ស្លុត ទាំងមិនប្រព្រឹត្តទៅ ព្រោះហេតុតែពាក្យរបស់សមណៈ ។

[១១៨] ម្នាលភិក្ខុទាំងឡាយ ហេតុដែលកុលបុត្រមានសទ្ធាគួរឃើញ គួរសំវេគនោះមាន ៤ យ៉ាង ។ ហេតុ ៤ យ៉ាងដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលកុលបុត្រមានសទ្ធាគួរឃើញ គួរសំវេគថា ព្រះតថាគតកើត ក្នុងលោកនេះហើយដូច្នេះ ១ ម្នាលភិក្ខុទាំងឡាយ ហេតុដែលកុលបុត្រមានសទ្ធា គួរឃើញ គួរសំវេគថា ព្រះតថាគតត្រាស់ដឹង ចំពោះនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោកនេះហើយដូច្នេះ ១ ម្នាលភិក្ខុទាំងឡាយ ហេតុដែលកុលបុត្រមានសទ្ធាគួរឃើញ គួរសំវេគថា ព្រះតថាគតញ៉ាំងធម្មចក្រដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅ ក្នុងលោកនេះហើយ ដូច្នេះ ១ ម្នាលភិក្ខុទាំងឡាយ ហេតុដែលកុលបុត្រមានសទ្ធា គួរឃើញ គួរសំវេគថា ព្រះតថាគតទ្រង់បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងលោកនេះហើយ ដូច្នេះ ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលកុលបុត្រមានសទ្ធា គួរឃើញ គួរសំវេគមាន ៤ យ៉ាងនេះ ។

[១១៩] ចត្តារីមានិ ភិក្ខវេ ភយានិ ។ កតមានិ ចត្តារិ ។ ជាតិភយំ ជរាភយំ ព្យាធិភយំ មរណភយំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ភយានីតិ ។

[១២០] ចត្តារីមានិ ភិក្ខវេ ភយានិ ។ កតមានិ ចត្តារិ ។ អគ្គិភយំ ឧទកភយំ រាជភយំ ចោរភយំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ភយានីតិ ។

កេសីវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

កេសី ជវោ បតោទោ ច
នាគឋានេន បញ្ចមំ
អប្បមាទោ ច អារក្ខោ
វេជនីយញ្ច ទ្វេ ភយាតិ ។

[១១៩] ម្នាលភិក្ខុទាំងឡាយ ភ័យនេះ មាន ៤ យ៉ាង ។ ភ័យ ៤ យ៉ាងដូចម្តេចខ្លះ ។ គឺជាតិភ័យ ១ ជរាភ័យ ១ ព្យាធិភ័យ ១ មរណភ័យ ១ ។ ម្នាលភិក្ខុទាំងឡាយ ភ័យមាន ៤ យ៉ាងនេះឯង ។

[១២០] ម្នាលភិក្ខុទាំងឡាយ ភ័យនេះមាន ៤ យ៉ាង ។ ភ័យ ៤ យ៉ាងដូចម្តេចខ្លះ ។ គឺអគ្គិភ័យ ១ ឧទកភ័យ ១ រាជភ័យ ១ ចោរភ័យ ១ ។ ម្នាលភិក្ខុទាំងឡាយ ភ័យមាន ៤ យ៉ាងនេះឯង ។

ចប់ កេសីវគ្គ ទី ២ ។

## ឧទ្ទាននៃកេសីវគ្គនោះគឺ

និយាយអំពីសារថីអ្នកបង្ហាត់សេះឈ្មោះកេសី ១ អំពីសន្ទុះ ១ អំពីជន្ទញ ១ អំពីដំរីដ៏ប្រសើរ ១ អំពីហេតុជាគម្រប់ប្រាំ ១ អំពីសេចក្តីមិនប្រមាទ គឺការថែរក្សាចិត្តដោយសតិ ១ អំពីហេតុដែលគួរសំវេគ ១ អំពីភ័យមានពីរលើក ។

# ភយវគ្គោ

[១២១] ចត្តារីមានិ ភិក្ខវេ ភយានិ ។ កតមានិ ចត្តារិ ។ អត្តានុវាទភយំ បរានុវាទភយំ ទណ្ឌភយំ ទុគ្គតិភយំ ។ កតមញ្ច ភិក្ខវេ អត្តានុវាទភយំ ។ ឥធ ភិក្ខវេ ឯកច្ចោ ឥតិ បដិសញ្ចិក្ខតិ អហញ្ចេវ ខោ បន កាយេន ទុច្ចរិតំ ចរេយ្យំ វាចាយ ទុច្ចរិតំ ចរេយ្យំ មនសា ទុច្ចរិតំ ចរេយ្យំ កិញ្ច មំ[១] អត្តា សីលតោ ន ឧបវទេយ្យាតិ សោ អត្តានុវាទភយស្ស ភីតោ កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេតិ វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេតិ មនោទុច្ចរិតំ បហាយ មនោសុចរិតំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។ ឥទំ វុច្ចតិ ភិក្ខវេ អត្តានុវាទភយំ ។ កតមញ្ច ភិក្ខវេ បរានុវាទភយំ ។ ឥធ ភិក្ខវេ ឯកច្ចោ ឥតិ បដិសញ្ចិក្ខតិ អហញ្ចេវ ខោ បន កាយេន ទុច្ចរិតំ ចរេយ្យំ

១ ឱ. ម. កញ្ច តំ កម្មំ ។

# ភយវគ្គ

[១២១] ម្នាលភិក្ខុទាំងឡាយ ភ័យនេះមាន ៤ យ៉ាង ។ ភ័យ ៤ យ៉ាងដូចម្តេចខ្លះ ។ គឺ អត្តានុវាទភ័យ (ភ័យអំពីការតិះដៀលខ្លួនឯង) ១ បរានុវាទភ័យ (ភ័យអំពីការតិះដៀលរបស់បុគ្គលដទៃ) ១ ទណ្ឌភ័យ (ភ័យអំពីទណ្ឌកម្ម) ១ ទុគ្គតិភ័យ (ភ័យអំពីទុគ្គតិគឺអបាយទាំងបួន) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះអត្តានុវាទភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ពិចារណាដូច្នេះថា ប្រសិនបើខ្លួនអញ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តើខ្លួនអញនឹងមិនតិះដៀលខ្លួនឯង ព្រោះសីលទេឬ បុគ្គលនោះក៏ខ្លាចចំពោះភ័យដែលកើតឡើង អំពីការតិះដៀលខ្លួនឯង ហើយលះបង់កាយទុច្ចរិត ចម្រើនកាយសុចរិត លះបង់វចីទុច្ចរិត ចម្រើនវចីសុចរិត លះបង់មនោទុច្ចរិត ចម្រើនមនោសុចរិត គ្រប់គ្រងរក្សាខ្លួនឲ្យស្អាតវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អត្តានុវាទភ័យ ។ ម្នាលភិក្ខុទាំងឡាយ ចុះបរានុវាទភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាដូច្នេះថា ប្រសិនបើ អញប្រព្រឹត្តទុច្ចរិតដោយកាយ

វាចាយ ទុច្ចរិតំ ចរេយ្យំ មនសា ទុច្ចរិតំ ចរេយ្យំ កិញ្ច មំ បរេ សីលតោ ន ឧបវទេយ្យុន្តិ សោ បរានុវាទភយស្ស ភីតោ កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេតិ វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេតិ មនោទុច្ចរិតំ បហាយ មនោសុចរិតំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។ ឥទំ វុច្ចតិ ភិក្ខវេ បរានុវាទភយំ ។ កតមញ្ច ភិក្ខវេ ទណ្ឌភយំ ។ ឥធ ភិក្ខវេ ឯកច្ចោ បស្សតិ ចោរំ អាគុចារឹ រាជានោ គហេត្វា វិវិធា កម្មការណា ការេន្តេ[១] កសាហិបិ តាឡេន្តេ វេត្តេហិបិ តាឡេន្តេ អឌ្ឍទណ្ឌកេហិបិ តាឡេន្តេ ហត្ថម្បិ ឆិន្ទន្តេ បាទម្បិ ឆិន្ទន្តេ ហត្ថបាទម្បិ ឆិន្ទន្តេ កណ្ណម្បិ ឆិន្ទន្តេ នាសម្បិ ឆិន្ទន្តេ កណ្ណនាសម្បិ ឆិន្ទន្តេ ពិលង្គថាលិកម្បិ ករោន្តេ សង្ខមុណ្ឌិកម្បិ ករោន្តេ រាហុមុខម្បិ ករោន្តេ ជោតិមាលិកម្បិ ករោន្តេ

១ ម. វិវិធានិ កម្មករណានិ ការេន្តេ ។

ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តើបុគ្គលដទៃនឹងមិនតិះ-ដៀលខ្លួនអញ ព្រោះសីលទេឬ បុគ្គលនោះក៏ខ្លាចចំពោះភ័យ ដែលកើតឡើង អំពីការតិះដៀលរបស់បុគ្គលដទៃ ហើយលះបង់កាយទុច្ចរិត ចម្រើនកាយសុចរិត លះបង់វចីទុច្ចរិត ចម្រើនវចីសុចរិត លះបង់មនោទុច្ចរិត ចម្រើនមនោសុចរិត ត្រឡប់រក្សាខ្លួនឲ្យស្អាតវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បរានុវាទភ័យ ។ ម្នាលភិក្ខុទាំងឡាយ ចុះទណ្ឌភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ឃើញព្រះរាជាទាំងឡាយកំពុងចាប់ចោរ ប្រព្រឹត្តអាក្រក់ ហើយត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ មានប្រការផ្សេង ៗ គឺវាយដោយរំពាត់ខ្លះ វាយដោយផ្តៅខ្លះ វាយដោយដំបងខ្លីខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ទាំងដៃទាំងជើងខ្លះ កាត់ស្លឹកត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ធ្វើនូវពិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ[១] ធ្វើនូវសង្ខមុណ្ឌិកកម្ម គឺអំពើដែលគេធ្វើក្បាល ឲ្យរលីងដូចជាសម្បកស័ង្ខខ្លះ ធ្វើនូវរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ឲ្យដូចជាមាត់រាហូខ្លះ ធ្វើនូវជោតិមាលិកកម្ម គឺអំពើដែលគេធ្វើខ្លួនមនុស្ស ឲ្យដូចជាផ្កាភ្លើងខ្លះ

---

១ ពីត្រឹមពិលង្គថាលិកកម្មទៅដល់បលាលបីឋកកម្ម មានយោងលេខពន្យល់យ៉ាងពិស្តារក្នុងសុត្តន្តបិដកមជ្ឈិមនិកាយមូលបណ្ណាសកភាគ ២០ ត្រង់ទំព័រ ៣២១ និង ៣២២ រួចហើយ ។

ហត្ថប្បជ្ជោតិកម្បិ ករោន្តេ ឯរកវត្តិកម្បិ ករោន្តេ ចិរកវាសិកម្បិ ករោន្តេ ឯណេយ្យកម្បិ ករោន្តេ ពលិសមំសិកម្បិ ករោន្តេ កហាបណកម្បិ ករោន្តេ ខារាបជិច្ឆកម្បិ ករោន្តេ បលិឃបរិវត្តកម្បិ ករោន្តេ បលាលបីឋកម្បិ ករោន្តេ តត្តេនបិ តេលេន ឱសិញ្ចន្តេ សុនខេហិបិ ខាទាបេន្តេ ជីវន្តម្បិ សូលេ ឧត្តាសេន្តេ អសិនាបិ សីសំ ឆិន្ទន្តេ តស្ស ឯវំ ហោតិ យថារូបានំ ខោ បាបកានំ កម្មានំ ហេតុ ចោរំ អាគុ-ចារឹ រាជានោ គហេត្វា វិវិធា កម្មការណា ការេន្តិ កសាហិបិ តាឡេន្តិ ។ បេ ។ អសិនាបិ សីសំ ឆិន្ទន្តិ អហញ្ចេវ ខោ បន ឯវរូបំ បាបកម្មំ ករេយ្យំ មម្បិ រាជានោ គហេត្វា ឯវរូបា វិវិធា កម្មការណា ការេយ្យុំ កសាហិបិ តាឡេយ្យុំ ។ បេ ។

ធ្វើនូវហត្ថប្បជ្ជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ ធ្វើនូវឯរកវដ្តិកកម្ម គឺអំពើដែលគេធ្វើដូចជាពន្ទាត់ស្បែកពពែខ្លះ ធ្វើនូវចិរវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាស្បៀកសំពត់សម្បកឈើខ្លះ ធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាជើងសត្វទ្រាយខ្លះ ធ្វើនូវពលិសមំសិកកម្ម គឺអំពើដែលគេថ្ពក់មាត់ដោយកាង ឬសន្ទូចខ្លះ ធ្វើនូវកហាបណកកម្ម គឺអំពើ ដែលគេធ្វើឲ្យខូចសរីរៈ ប្រមាណប៉ុនកហាបណៈមួយ ៗ ខ្លះ ធ្វើនូវខារាបដិច្ឆកកម្ម គឺអំពើដែលគេយកទឹកផ្សាស្រោចខ្លះ ធ្វើនូវបលិឃបរិវត្តកកម្ម គឺអំពើដែលគេធ្វើដូចជាបង្វិលជើងគុល ឬសសរគោលខ្លះ ធ្វើនូវបលាលបីឋកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាកណ្តាប់ចំបើងខ្លះ ស្រោចដោយប្រេងកំពុងក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ បុគ្គលនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះរាជាទាំងឡាយ កំពុងចាប់ចោរ ដែលប្រព្រឹត្តអាក្រក់ហើយត្រាស់បង្គាប់ ឲ្យធ្វើកម្មករណ៍មានប្រការផ្សេង ៗ គឺវាយដោយរំពាត់ខ្លះ ។ បេ ។ កាត់ក្បាលដោយដាវខ្លះ ព្រោះហេតុនៃកម្មដ៏លាមកមានសភាពយ៉ាងណា ប្រសិនបើអញ ធ្វើនូវកម្មដ៏លាមកមានសភាពយ៉ាងនោះដែរ មុខជាព្រះរាជាទាំងឡាយ ចាប់ខ្លួនអញហើយធ្វើកម្មករណ៍មានប្រការផ្សេង ៗ យ៉ាងនោះមិនខាន គឺវាយដោយរំពាត់ខ្លះ ។ បេ ។

អសិនាបិ សីសំ ឆិន្ទេយ្យុន្តិ សោ ទណ្ឌភយស្ស ភីតោ ន បរេសំ បាភដំ បលុម្បន្តោ ចរតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ទណ្ឌភយំ ។ កាតមញ្ច ភិក្ខវេ ទុគ្គតិភយំ ។ ឥធ ភិក្ខវេ ឯកច្ចោ ឥតិ បដិសញ្ចិក្ខតិ កាយ-ទុច្ចរិតស្ស ខោ បាបកោ វិបាកោ អភិសម្បរាយំ វចីទុច្ចរិតស្ស បាបកោ វិបាកោ អភិសម្បរាយំ មនោទុច្ចរិតស្ស បាបកោ វិបាកោ អភិសម្បរាយំ អហញ្ចេវ ខោ បន កាយេន ទុច្ចរិតំ ចរេយ្យំ វាចាយ ទុច្ចរិតំ ចរេយ្យំ មនសា ទុច្ចរិតំ ចរេយ្យំ កិញ្ច តំ យេនាហំ កាយស្ស[១] ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យន្តិ សោ ទុគ្គតិភយស្ស ភីតោ កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេតិ វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេតិ មនោទុច្ចរិតំ បហាយ មនោសុចរិតំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។

---

១ ឱ. ម. យាហំ ន កាយស្ស ។

កាត់ក្បាលដោយដាវខ្លះ បុគ្គលនោះ ក៏ខ្លាចចំពោះភ័យដែលកើតឡើង អំពីទណ្ឌកម្ម ហើយក៏លែងប្រព្រឹត្តប្លន់ដណ្តើមយកទ្រព្យជាដើមទុន របស់បុគ្គលដទៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទណ្ឌភ័យ ។ ម្នាលភិក្ខុទាំងឡាយ ចុះទុគ្គតិភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាដូច្នេះថា កាយទុច្ចរិត មានផល អាក្រក់ក្នុងលោកខាងមុខ វចីទុច្ចរិត មានផលអាក្រក់ក្នុងលោកខាងមុខ មនោទុច្ចរិត មានផលអាក្រក់ក្នុងលោកខាងមុខ ប្រសិនបើអញ ប្រព្រឹត្ត ទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះអាត្មាអញបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះអំពើនោះពុំខានឡើយ បុគ្គលនោះក៏ខ្លាច ចំពោះភ័យ ដែលកើតឡើងអំពីទុគ្គតិហើយ ក៏លះបង់កាយទុច្ចរិត ចម្រើនកាយសុចរិត លះបង់វចីទុច្ចរិត ចម្រើនវចីសុចរិត លះបង់ មនោទុច្ចរិត ចម្រើនមនោសុចរិត ត្រឡប់រក្សាខ្លួនឲ្យស្អាតវិញ ។

ឥទំ វុច្ចតិ ភិក្ខវេ ទុគ្គតិភយំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ភយានីតិ ។

[១២២] ចត្តារីមានិ ភិក្ខវេ ភយានិ ឧទកោរោហន្តស្ស បាដិកង្ខិតព្វានិ ។ កតមានិ ចត្តារិ ។ ឩមិភយំ កុម្ភីលភយំ អាវដ្ដភយំ សុសុកាភយំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ភយានិ ឧទកោរោហន្តស្ស បាដិកង្ខិតព្វានិ ។ ឯវមេវ ខោ ភិក្ខវេ ចត្តារីមានិ ភយានិ ឥធេកច្ចស្ស កុលបុត្តស្ស[១] ឥមស្មឹ ធម្មវិនយេ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ[២] បាដិកង្ខិតព្វានិ ។ កតមានិ ចត្តារិ ។ ឩមិភយំ កុម្ភីលភយំ អាវដ្ដភយំ សុសុកាភយំ ។ កតមញ្ច ភិក្ខវេ ឩមិភយំ ។ ឥធ ភិក្ខវេ ឯកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ

---

១ ឱ. ឥធេកច្ចេ កុលបុត្តេ ។ ២ បព្វជិតស្សាតិ បាឋោ យុត្តតរោ ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុគ្គតិភ័យ[១] ។ ម្នាលភិក្ខុទាំងឡាយ ភ័យ ៤ យ៉ាងនេះឯង ។

[១២២] ម្នាលភិក្ខុទាំងឡាយ ភ័យនេះមាន ៤ យ៉ាង រមែងមានប្រាកដដល់បុគ្គលកាលចុះទឹក ។ ភ័យ ៤ យ៉ាងដូចម្ដេចខ្លះ ។ គឺឩមិភ័យ (ភ័យអំពីរលកទឹក) ១ កុម្ភីលភ័យ (ភ័យអំពីក្រពើ) ១ អាវដ្ដភ័យ (ភ័យអំពីទឹកក្ដួចវិលវល់) ១ សុសុកាភ័យ (ភ័យអំពីត្រីកាច) ១ ។ ម្នាលភិក្ខុទាំងឡាយ ភ័យ ៤ យ៉ាងនេះឯង រមែងមានប្រាកដដល់បុគ្គលកាលចុះទឹក ។ ម្នាលភិក្ខុទាំងឡាយ ភ័យនេះមាន ៤ យ៉ាង រមែងមានប្រាកដដល់កុលបុត្តខ្លះ ក្នុងលោកនេះ ដែលមានសទ្ធា ក្នុងធម្មវិន័យនេះ ចេញចាកផ្ទះចូលកាន់ផ្នួស ក៏យ៉ាងនោះដែរ ។ ភ័យ ៤ យ៉ាង ដូចម្ដេចខ្លះ ។ គឺឩមិភ័យ ១ កុម្ភីលភ័យ ១ អាវដ្ដភ័យ ១ សុសុកាភ័យ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះឩមិភ័យ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តខ្លះ ក្នុងលោកនេះ មានសទ្ធាចេញចាកផ្ទះចូលកាន់ផ្នួសដោយគិតថា

---

១ កាលបើបុគ្គលពិចារណានូវអត្តានុវាទភ័យ និងទុគ្គតិភ័យ ហិរិរមែងតាំងឡើងក្នុងសន្តាន ចំណែកបុគ្គលដែលពិចារណានូវបរានុវាទភ័យ និងទណ្ឌភ័យ ឱត្តប្បៈខាងក្រៅ រមែងកើតឡើង។ ហិរិឱត្តប្បៈនោះ ក៏ញ៉ាំងសំវរៈក្នុងទ្វារទាំង ៣ ឲ្យកើតឡើង សំវរៈនោះជាបច្ច័យឲ្យកើត ចតុប្បា-រិសុទ្ធិសីល លុះបុគ្គលនោះ តាំងនៅក្នុងសីលនោះ ហើយបានចម្រើនវិបស្សនា រមែងតម្កល់នៅក្នុងផលដ៏ប្រសើរ ។ អដ្ឋកថា ។

ឱតិណ្ណាម្ហិ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណា ទុក្ខបរេតា អប្បេវនាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ តមេនំ តថាបព្វជិតំ សមានំ សព្រហ្មចារី[១] ឱវទន្តិ អនុសាសន្តិ ឯវន្តេ អភិក្កមិតព្វំ ឯវន្តេ បដិក្កមិតព្វំ ឯវន្តេ អាលោកេតព្វំ ឯវន្តេ វិលោកេតព្វំ ឯវន្តេ សម្មិញ្ជិតព្វំ ឯវន្តេ បសារេតព្វំ ឯវន្តេ សង្ឃាដិបត្តចីវរំ ធារេតព្វន្តិ ។ តស្ស ឯវំ ហោតិ មយំ ខោ បុព្វេ អគារិយភូតា សមានា អញ្ញេ ឱវទាមបិ អនុសាសាមបិ ឥមេ បន អម្ហាកំ បុត្តមត្តា មញ្ញេ នត្តមត្តា មញ្ញេ ឱវទិតព្វំ អនុសាសិតព្វំ មញ្ញន្តីតិ ។ សោ កុបិតោ អនត្តមនោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ឩមិភយស្ស ភីតោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តោ ។ ឩមិភយន្តិ ខោ ភិក្ខវេ កោធុបាយាសស្សេតំ អធិវចនំ ។

១ ម. សព្រហ្មចារិនោ ។

អញតែងត្រូវជាតិ ជរា ព្យាធិ មរណៈ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្សនិងសេចក្តីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ ត្រូវទុក្ខគ្របសង្កត់ ត្រូវទុក្ខបៀតបៀន ដូចម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ ពួកសព្រហ្មចារីក៏ទូន្មាន ប្រៀនប្រដៅនូវកុលបុត្ត ដែលបួសដោយប្រការដូច្នោះនោះថា អ្នកត្រូវឈានដើរទៅមុខយ៉ាងនេះ អ្នកត្រូវថយក្រោយយ៉ាងនេះ អ្នកត្រូវងាកមើលទិសផ្សេង ៗ យ៉ាងនេះ អ្នកត្រូវបត់អវយវៈយ៉ាងនេះ អ្នកត្រូវលាអវយវៈយ៉ាងនេះ អ្នកត្រូវប្រើប្រាស់ សង្ឃាដី បាត្រនិងចីវរយ៉ាងនេះ ។ កុលបុត្តនោះ ក៏មានសេចក្តីត្រិះរិះ យ៉ាងនេះថា យើងហ្នឹងឯង ក្នុងកាលពីដើមជាគ្រហស្ថ ក៏ធ្លាប់ទូន្មាន ប្រៀនប្រដៅបុគ្គលដទៃដែរ គួរបើដែរ លោកទាំងនេះ (មានជំនាន់) ប្រហែលត្រឹមតែកូន ត្រឹមតែចៅ របស់យើងប៉ុណ្ណោះ មកសម្គាល់នូវយើង ថាជាបុគ្គលគួរទូន្មានគួរប្រៀនប្រដៅវិញ ។ កុលបុត្តនោះ ក៏ខឹងអាក់អន់ ចិត្ត លាសិក្ខាត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុខ្លាចចំពោះភ័យអំពីរលក ហើយលាសិក្ខាត្រឡប់ទៅ កាន់ភេទដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពីរលក នេះឯង ជាឈ្មោះនៃសេចក្តីក្រោធ និងសេចក្តីចង្អៀតចង្អល់ចិត្ត ។

៣១១



ឥទំ វុច្ចតិ ភិក្ខវេ ឩមិភយំ ។ កតមញ្ច ភិក្ខវេ កុម្ភីលភយំ ។ ឥធ ភិក្ខវេ ឯកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវនាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ តមេនំ តថាបព្វជិតំ សមានំ សព្រហ្មចារី ឱវទន្តិ អនុសាសន្តិ ឥទន្តេ ខាទិតព្វំ ឥទន្តេ ន ខាទិតព្វំ ឥទន្តេ ភុញ្ជិតព្វំ ឥទន្តេ ន ភុញ្ជិតព្វំ ឥទន្តេ សាយិតព្វំ ឥទន្តេ ន សាយិតព្វំ ឥទន្តេ បាតព្វំ ឥទន្តេ ន បាតព្វំ កប្បិយន្តេ ខាទិតព្វំ អកប្បិយន្តេ ន ខាទិតព្វំ កប្បិយន្តេ ភុញ្ជិតព្វំ អកប្បិយន្តេ ន ភុញ្ជិតព្វំ កប្បិយន្តេ សាយិតព្វំ អកប្បិយន្តេ ន សាយិតព្វំ កប្បិយន្តេ បាតព្វំ អកប្បិយន្តេ ន បាតព្វំ កាលេ តេ ខាទិតព្វំ វិកាលេ តេ ន ខាទិតព្វំ កាលេ តេ ភុញ្ជិតព្វំ

ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឱមិភ័យ ។ ម្នាលភិក្ខុទាំងឡាយ ចុះកុម្ភីលភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តខ្លះ ក្នុងលោកនេះ មានសទ្ធាចេញចាកផ្ទះ ចូលកាន់ផ្នួស ដោយគិតថា អញតែងត្រូវជាតិ ជរា មរណៈ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ ត្រូវទុក្ខគ្របសង្កត់ ត្រូវទុក្ខបៀតបៀន ដូចម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ ពួកសព្រហ្មចារី ក៏ទូន្មានប្រៀនប្រដៅកុលបុត្តដែលបួសដោយប្រការដូច្នោះនោះថា របស់នេះអ្នកគួរទំពាស៊ី របស់នេះអ្នកមិនគួរទំពាស៊ី របស់នេះអ្នកគួរបរិភោគ របស់នេះអ្នកមិនគួរបរិភោគ របស់នេះអ្នកគួរជញ្ជាបជញ្ជក់ របស់នេះអ្នកមិនគួរជញ្ជាបជញ្ជក់ របស់នេះអ្នកគួរផឹក របស់នេះអ្នកមិនគួរផឹក របស់ដែលគួរ អ្នកគប្បីទំពាស៊ី របស់ដែលមិនគួរ អ្នកមិនគប្បីទំពាស៊ី របស់ដែលគួរ អ្នកគប្បីបរិភោគ របស់ដែលមិនគួរ អ្នកមិនគប្បីបរិភោគ របស់ដែលគួរ អ្នកគប្បីជញ្ជាបជញ្ជក់ របស់ដែលមិនគួរ អ្នកមិនគប្បីជញ្ជាបជញ្ជក់ របស់ដែលគួរ អ្នកគប្បីផឹក របស់ដែលមិនគួរ អ្នកមិនគប្បីផឹក អ្នកគួរទំពាស៊ី តែក្នុងកាលគួរ អ្នកមិនគួរទំពាស៊ីក្នុងកាលមិនគួរ អ្នកគួរបរិភោគ តែក្នុងកាលគួរ

វិកាលេ តេ ន កុញ្ចិតព្វំ កាលេ តេ សាយិតព្វំ វិកាលេ តេ ន សាយិតព្វំ កាលេ តេ ចាតព្វំ វិកាលេ តេ ន ចាតព្វន្តិ ។ តស្ស ឯវំ ហោតិ មយំ ខោ បុព្វេ អគារិយភូតា សមានា យំ ឥច្ឆាម តំ ខាទាម យំ ន ឥច្ឆាម ន តំ ខាទាម យំ ឥច្ឆាម តំ កុញ្ជាម យំ ន ឥច្ឆាម ន តំ កុញ្ជាម យំ ឥច្ឆាម តំ សាយាម យំ ន ឥច្ឆាម ន តំ សាយាម យំ ឥច្ឆាម តំ បិវាម យំ ន ឥច្ឆាម ន តំ បិវាម កប្បិយំបិ ខាទាម អកប្បិ-យំបិ ខាទាម កប្បិយំបិ កុញ្ជាម អកប្បិយំបិ កុញ្ជាម កប្បិយំបិ សាយាម អកប្បិយំបិ សាយាម កប្បិយំបិ បិវាម អកប្បិយំបិ បិវាម កាលេបិ ខាទាម វិកាលេបិ ខាទាម កាលេបិ កុញ្ជាម វិកាលេបិ កុញ្ជាម កាលេបិ សាយាម វិកាលេបិ សាយាម កាលេបិ បិវាម វិកាលេបិ បិវាម យំបិ នោ សទ្ធា គហបតិកា ទិវា វិកាលេ បណីតំ ខាទនីយំ វា ភោជនីយំ វា ទេន្តិ

អ្នកមិនគួរបរិភោគ ក្នុងកាលមិនគួរ អ្នកគួរជញ្ជាបជញ្ជក់ តែក្នុងកាលគួរ អ្នកមិនគួរជញ្ជាបជញ្ជក់ ក្នុងកាលមិនគួរ អ្នកគួរផឹកតែក្នុងកាលគួរ អ្នកមិនគួរផឹក ក្នុងកាលមិនគួរទេ ។ កុលបុត្រនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា យើងហ្នឹងឯង ក្នុងកាលពីដើមជាគ្រហស្ថ (បើ) ចង់របស់ណា ក៏ទំពាស៊ី របស់នោះ មិនចង់របស់ណា មិនទំពាស៊ី របស់នោះទេ ចង់របស់ណា ក៏បរិភោគរបស់នោះ មិនចង់របស់ណា ក៏មិនបរិភោគរបស់នោះទេ ចង់របស់ណា ក៏ជញ្ជាបជញ្ជក់របស់នោះ មិនចង់របស់ណា ក៏មិនជញ្ជាបជញ្ជក់របស់នោះ ចង់ទឹកណា ក៏ផឹកទឹកនោះ មិនចង់ទឹកណា ក៏មិនផឹកទឹកនោះ តែងទំពាស៊ីរបស់ដែលគួរក៏បាន ទំពាស៊ីរបស់ដែលមិនគួរក៏បាន បរិភោគភោជនដែលគួរក៏បាន បរិភោគភោជនដែលមិនគួរក៏បាន ជញ្ជាបជញ្ជក់របស់ដែលគួរក៏បាន ជញ្ជាបជញ្ជក់របស់ដែលមិនគួរក៏បាន ផឹកទឹកដែលគួរក៏បាន ផឹកទឹកដែលមិនគួរក៏បាន ទំពាស៊ីក្នុងកាលគួរក៏បាន ទំពាស៊ីក្នុងកាលមិនគួរក៏បាន បរិភោគក្នុងកាលគួរក៏បាន បរិភោគក្នុងកាលមិនគួរក៏បាន ជញ្ជាបជញ្ជក់ក្នុងកាលគួរក៏បាន ជញ្ជាបជញ្ជក់ក្នុងកាលមិនគួរក៏បាន ផឹកក្នុងកាលគួរក៏បាន ផឹកក្នុងកាលមិនគួរក៏បាន ពួកគហបតីដែលមានសទ្ធា ធ្លាប់ឲ្យខាទនីយ-ភោជនីយាហារដ៏ឧត្តមណា ដល់យើងក្នុងវេលាថ្ងៃ ជាកាលមិនគួរ

៣១៣



តត្រាបីមេ មុខាវរណំ មញ្ញេ ករោន្តីតិ ។ សោ កុបិតោ អនត្តមនោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ កុម្ភីលភយស្ស ភីតោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តោ ។ កុម្ភីលភយន្តិ ខោ ភិក្ខវេ ឱទរិកត្តស្សេតំ អធិវចនំ ។ ឥទំ វុច្ចតិ ភិក្ខវេ កុម្ភីលភយំ ។ កតមញ្ច ភិក្ខវេ អាវដភយំ ។ ឥធ ភិក្ខវេ ឯកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវនាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ គាមំ វា និគមំ វា បិណ្ឌាយ បាវិសិ អរក្ខិតេនេវ កាយេន អរក្ខិតាយ វាចាយ អរក្ខិតេន ចិត្តេន អនុបដ្ឋិតាយ សតិយា អសំវុតេហិ ឥន្ទ្រិយេហិ

ឥឡូវនេះលោកទាំងនេះ ធ្វើទំនងដូចជាបិទមាត់ (អញ) ចំពោះខាទនីយ-ភោជនីយាហារ (របស់គហបតី) ទាំងនោះ ។ កុលបុត្តនោះ ក៏ខឹងអាក់អន់ចិត្តហើយ លាសិក្ខាត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុខ្លាចចំពោះភ័យអំពីក្រពើ ហើយលាសិក្ខាត្រឡប់ទៅកាន់ភេទដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពីក្រពើនេះឯង ជាឈ្មោះនៃសេចក្តីប្រាថ្នាអាហារចម្អែតពោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កុម្ភីលភ័យ ។ ម្នាលភិក្ខុទាំងឡាយ ចុះអាវដភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តខ្លះ ក្នុងលោកនេះ មានសទ្ធាចេញចាកផ្ទះ ចូលកាន់ផ្នួស ដោយគិតថា អញត្រូវជាតិ ជរា មរណៈ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ ត្រូវទុក្ខគ្របសង្កត់ ត្រូវទុក្ខបៀតបៀន ដូចម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ កាលបុគ្គលនោះ បួសយ៉ាងនេះ ក៏ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាបុព្វណ្ហសម័យ ចូលទៅកាន់ស្រុក ឬនិគមដើម្បីបិណ្ឌបាត ដោយមិនសង្រួមកាយ មិនសង្រួមវាចា មិនសង្រួមចិត្ត មិនផ្ចង់ស្មារតី មិនសង្រួមឥន្ទ្រិយ

សោ តត្ថ បស្សតិ គហបតឹ វា គហបតិបុត្តំ វា បញ្ចហិ កាមគុណេហិ សមប្បិតំ សមង្គីភូតំ បរិចារយមានំ តស្ស ឯវំ ហោតិ មយំ ខោ បុព្វេ អគារិយភូតា សមានា បញ្ចហិ កាមគុណេហិ សមប្បិតា សមង្គីភូតា បរិចារយិម្ហា សំវិជ្ជន្តេ ខោ បន មេ កុលេ ភោគា សក្កា ភោគេ ច ភុញ្ជិតុំ បុញ្ញានិ ច កាតុំ យន្នូនាហំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិត្វា ភោគេ ច ភុញ្ជេយ្យំ បុញ្ញានិ ចករេយ្យន្តិ ។ សោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អាវដ្ដភយស្ស ភីតោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តោ ។ អាវដ្ដភយន្តិ ខោ ភិក្ខវេ បញ្ចន្នំ[១] កាមគុណានំ អធិវចនំ ។ ឥទំ វុច្ចតិ ភិក្ខវេ អាវដ្ដភយំ ។ កតមញ្ច ភិក្ខវេ សុសុកាភយំ ។ ឥធ ភិក្ខវេ ឯកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ

១ ឱ. ម. បញ្ចន្នេតំ ។

កុលបុត្តនោះ ឃើញគហបតីក្តី កូនគហបតីក្តី ដែលឆ្អែតស្កប់ស្កល់ព្រមព្រៀង មូលមិត្តដោយកាមគុណទាំង ៥ ក្នុងស្រុក ឬនិគមនោះ កុលបុត្តនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា យើងហ្នឹងឯង ក្នុងកាលពីដើមជាគ្រហស្ថ ជាអ្នកធ្លាប់ឆ្អែតស្កប់ស្កល់ព្រមព្រៀងមូលមិត្តដោយកាមគុណទាំង ៥ ដែរ ទាំងភោគសម្បត្តិក្នុងត្រកូលរបស់អញក៏មានគ្រប់គ្រាន់ អញអាចនឹងប្រើប្រាស់ភោគសម្បត្តិបានផង នឹងធ្វើនូវបុណ្យក៏បានផង បើដូច្នោះ គួរតែអញលាសិក្ខាត្រឡប់ទៅកាន់ភេទជាគហទាបវិញ ហើយប្រើប្រាស់ភោគសម្បត្តិផង ធ្វើបុណ្យផង ។ កុលបុត្តនោះ ក៏លាសិក្ខាត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុខ្លាចចំពោះភ័យអំពីទឹកក្ួចវិល ហើយលាសិក្ខាត្រឡប់ទៅកាន់ភេទដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពីទឹកក្ួចវិលនេះឯង ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាវដភ័យ ។ ម្នាលភិក្ខុទាំងឡាយ ចុះសុសុកាភ័យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តខ្លះ ក្នុងលោកនេះ មានសទ្ធា ចេញចាកផ្ទះ ចូលកាន់ផ្នួសដោយគិតថា អញត្រូវជាតិ ជរា មរណៈ សេចក្តីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្សនិងសេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ ត្រូវទុក្ខគ្របសង្កត់

ទុក្ខបរេតោ អប្បេវនាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ គាមំ វា និគមំ វា បិណ្ឌាយ បាវិសិ អរក្ខិតេនេវ កាយេន អរក្ខិតាយ វាចាយ អរក្ខិតេន ចិត្តេន អនុបដ្ឋិតាយ សតិយា អសំវុតេហិ ឥន្ទ្រិយេហិ សោ តត្ថ បស្សតិ មាតុគ្គាមំ ទុន្និវត្ថំ វា ទុប្បារុតំ វា តស្ស មាតុគ្គាមំ ទិស្វា ទុន្និវត្ថំ វា ទុប្បារុតំ វា រាគោ ចិត្តំ អនុទ្ធំសេតិ សោ រាគានុទ្ធំសេន[១] ចិត្តេន សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សុសុកាភយស្ស ភីតោ សិក្ខំ បច្ចក្ខាយ ហីនា-យាវត្តោ ។ សុសុកាភយន្តិ ខោ ភិក្ខវេ មាតុគ្គាមស្សេតំ អធិវចនំ ។ ឥទំ វុច្ចតិ ភិក្ខវេ សុសុកាភយំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ភយានិ ឥធេកច្ចស្ស កុលបុត្តស្ស ឥមស្មឹ ធម្មវិនយេ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ បាដិកង្ខិតព្វានីតិ ។

---

១ ឱ. រាគានុទ្ធស្តេន ។ អយំ បាឋោ យុត្តតរោ ។

ត្រូវទុក្ខបៀតបៀន ដូចម្ដេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។ កាលកុលបុត្តនោះ បួសយ៉ាងនេះ ក៏ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាបុព្វណ្ហសម័យ ចូលទៅកាន់ស្រុកឬនិគមដើម្បីបិណ្ឌបាត ដោយមិនរក្សាកាយ មិនរក្សាវាចា មិនរក្សាចិត្ត មិនផ្ចង់ស្មារតី មិនសង្រួមឥន្ទ្រិយ កុលបុត្តនោះ ឃើញមាតុគ្រាមដែលស្លៀកមិនស្រួល ឬដណ្ដប់មិនស្រួល លុះកុលបុត្រនោះ ឃើញមាតុគ្រាមដែលស្លៀកមិនស្រួល ដណ្ដប់មិនស្រួលហើយ ក៏មានចិត្តត្រូវរាគៈកំសួលឡើង កាលកុលបុត្តនោះ មានចិត្តត្រូវរាគៈកំសួលឡើងហើយ ក៏លាសិក្ខាត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាភិក្ខុខ្លាចចំពោះភ័យអំពីត្រីកាច ហើយលាសិក្ខាត្រឡប់ទៅកាន់ភេទដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពីត្រីកាចនេះ ជាឈ្មោះនៃមាតុគ្រាម ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សុសុកាភ័យ ។ ម្នាលភិក្ខុទាំងឡាយ ភ័យ ៤ យ៉ាងនេះឯង រមែងមានប្រាកដដល់កុលបុត្តខ្លះ ក្នុងលោកនេះ ដែលមានសទ្ធាក្នុងធម្មវិន័យនេះ ចេញចាកផ្ទះចូលកាន់ផ្នួស ។

[១២៣] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តឹ អាបជ្ជតិ តត្ថ ឋិតោ តទធិមុត្តោ តព្ពហុលវិហារី អបរិហីនោ កាលំ កុរុមានោ ព្រហ្មកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ ព្រហ្មកាយិកានំ ភិក្ខវេ ទេវានំ កប្បោ អាយុប្បមាណំ តត្ថ បុថុជ្ជនោ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា

[១២៣] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ ក៏បានដល់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់សម្រាន្តនៅ ។ កុលបុត្តនោះ ក៏ត្រេកអរនឹងបឋមជ្ឈាននោះ ស្រឡាញ់បឋមជ្ឈាននោះ ដល់នូវសេចក្តីត្រេកអរដោយបឋមជ្ឈាននោះ ឋិតនៅក្នុងបឋមជ្ឈាននោះ មានចិត្តចុះស៊ប់ក្នុងបឋមជ្ឈាននោះ ជាអ្នកនៅច្រើនដោយបឋមជ្ឈាននោះ មិនបានសាបសូន្យចាកឈាន លុះធ្វើមរណកាលទៅ រមែងទៅកើតជាមួយនឹងពួកព្រហ្មកាយិកទេវតា ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកព្រហ្មកាយិកទេវតាប្រមាណ ១ កប្ប[១] ព្រហ្មបុថុជ្ជនឋិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជននោះ ញ៉ាំងអាយុទាំងអស់នោះឲ្យអស់ហើយ

១ បឋមជ្ឈាន (មាន ៣ ចំណែក) គឺបឋមជ្ឈានដ៏ថោកទាប ១ បឋមជ្ឈានយ៉ាងកណ្តាល ១ បឋមជ្ឈានយ៉ាងឧត្តម ១ ។ កប្ប ១ ចែកជា ៣ ចំណែក ៗ ទី ៣ ទុកជាប្រមាណនៃអាយុរបស់សត្វដែលកើតដោយបឋមជ្ឈានដ៏ថោកទាប កន្លះកប្ប ជាប្រមាណនៃអាយុរបស់សត្វដែលកើតដោយបឋមជ្ឈានយ៉ាងកណ្តាល ១ កប្ប ជាប្រមាណនៃអាយុរបស់សត្វដែលកើតដោយបឋមជ្ឈានយ៉ាងឧត្តម ។ អដ្ឋកថា ។

និរយំបិ គច្ឆតិ តិរច្ឆានយោនឹបិ គច្ឆតិ បិត្តិវិសយំបិ គច្ឆតិ ភគវតោ បន សាវកោ តត្ថ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា តស្មឹយេវ ភវេ បរិនិព្វាយតិ ។ អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយសោ[១] ឥទំ នានាករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេន យទិទំ គតិយា ឧបបត្តិយា សតិ[២] ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តឹ អាបជ្ជតិ តត្ថ ឋិតោ តទធិមុត្តោ តព្ពហុលវិហារី អបរិហីនោ កាលំ កុរុមានោ អាភស្សរានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។

---

១ ឱ. ម. អធិប្បាយាសោ ។ ២ ម. ចុតិយា ឧបបត្តិយា ចាតិ ។

រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវ័ករបស់ព្រះដ៏មានព្រះភាគ ឋិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា ក៏ញុំាងអាយុទាំងអស់នោះ ឲ្យអស់ហើយ រមែងបរិនិព្វានក្នុងភពនោះតែម្តង ។ ម្នាលភិក្ខុទាំងឡាយ នេះសេចក្តីប្លែកគ្នា នេះសេចក្តីអធិប្បាយ នេះដំណើរផ្សេងគ្នារបស់អរិយសាវ័ក ដែលមានសេចក្តីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្តីចេះដឹង ដោយគតិនិងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ បានដល់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តានចិត្ត ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិ និងសុខដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ព្រោះរម្ងាប់វិតក្កៈនិងវិចារៈសម្រាន្តនៅ ។ បុគ្គលនោះ ក៏ត្រេកអរ នឹងទុតិយជ្ឈាននោះ ស្រឡាញ់ទុតិយជ្ឈាននោះ ដល់នូវសេចក្តីត្រេកអរដោយទុតិយជ្ឈាននោះ ឋិតនៅក្នុងទុតិយជ្ឈាននោះ មានចិត្តចុះស៊ប់ក្នុងទុតិយជ្ឈាននោះ ជាអ្នកនៅដោយច្រើនក្នុងទុតិយជ្ឈាននោះ មិនបានសាបសូន្យចាកឈាន លុះធ្វើមរណកាលទៅ រមែងទៅកើតជាមួយនឹងពួកទេវតាជាន់អាភស្សរៈ ។

អាភស្សរានំ ភិក្ខវេ ទេវានំ ទ្វេ កប្បា អាយុប្បមាណំ តត្ថ បុថុជ្ជនោ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា និរយំបិ គច្ឆតិ តិរច្ឆានយោនឹបិ គច្ឆតិ បិត្តិវិសយំបិ គច្ឆតិ ភគវតោ បន សាវកោ តត្ថ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា តស្មឹយេវ ភវេ បរិនិព្វាយតិ ។ អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយសោ ឥទំ នានាករណំ សុតវតោ អរិយ-ស្សាវកស្ស អស្សុតវតា បុថុជ្ជនេន យទិទំ គតិយា ឧបបត្តិយា សតិ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ

ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកទេវតាជាន់អាភស្សរៈ ប្រមាណ ២ កប្ប[១] ព្រហ្មបុថុជ្ជនឋិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជន ញុាំងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវ័ករបស់ព្រះដ៏មានព្រះភាគ ក៏ឋិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញុាំងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងបរិនិព្វានក្នុងភពនោះតែម្តង ។ ម្នាលភិក្ខុទាំងឡាយ នេះសេចក្តីប្លែកគ្នា នេះសេចក្តីអធិប្បាយ នេះដំណើរផ្សេងគ្នា របស់អរិយសាវ័កដែលមានសេចក្តីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្តីចេះដឹង ដោយគតិនិងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ព្រោះនឿយណាយចាកបីតិផង ជាបុគ្គលព្រងើយកន្តើយផង មានស្មារតីដឹងខ្លួនផង បាននូវសុខដោយនាមកាយផង

១ ទុតិយជ្ឈាន ក៏ចែកជា ៣ ចំណែកដូចបឋមជ្ឈានដែរ គឺសត្វដែលកើតក្នុងអាភស្សរព្រហ្ម ដោយទុតិយជ្ឈានដ៏ឧត្តម មានអាយុប្រមាណ ៨ កប្ប ដោយទុតិយជ្ឈានយ៉ាងកណ្តាលអាយុ ៤ កប្ប ដោយទុតិយជ្ឈានយ៉ាងថោកទាប អាយុ ២ កប្ប ។ អដ្ឋកថា ។

យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តឹ អាបជ្ជតិ តត្ថ ឋិតោ តទធិមុត្តោ តព្ពហុលវិហារី អបរិហីនោ កាលំ កុរុមានោ សុភកិណ្ហានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ សុភកិណ្ហានំ ភិក្ខវេ ទេវានំ ចត្តារោ កប្បា អាយុប្បមាណំ តត្ថ បុថុជ្ជនោ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា និរយំបិ គច្ឆតិ តិរច្ឆានយោនឹបិ គច្ឆតិ បិត្តិវិសយំបិ គច្ឆតិ ភគវតោ បន សាវកោ តត្ថ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា តស្មឹយេវ ភវេ បរិនិព្វាយតិ ។

រមែងបានដល់នូវតតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយ តែងសរសើរថា បុគ្គលដែលបានតតិយជ្ឈាន ជាអ្នកព្រងើយកន្តើយ មានស្មារតីនៅជាសុខ ។ បុគ្គលនោះ ក៏ត្រេកអរនឹងតតិយជ្ឈាននោះ ស្រឡាញ់តតិយជ្ឈាននោះ ដល់នូវសេចក្តីត្រេកអរដោយតតិយជ្ឈាននោះ ឋិតនៅក្នុងតតិយជ្ឈាននោះ មានចិត្តចុះស៊ប់ក្នុងតតិយជ្ឈាននោះ ជាអ្នកនៅដោយច្រើនក្នុងតតិយជ្ឈាននោះ មិនសាបសូន្យចាកឈាន លុះធ្វើមរណកាលទៅ ក៏ទៅកើតជាមួយនឹងពួកទេវតាជាន់សុភកិណ្ហៈ ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកទេវតាជាន់សុភកិណ្ហៈ ប្រមាណ ៤ កប្ប[១] ព្រហ្មបុថុជ្ជនឋិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ពួកទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជនញ៉ាំងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវ័ករបស់ព្រះដ៏មានព្រះភាគ ឋិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ពួកទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញ៉ាំងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងបរិនិព្វានក្នុងភពនោះតែម្តង ។

---

១ តតិយជ្ឈានចែកជា ៣ ចំណែកដូចទុតិយជ្ឈានដែរ គឺតតិយជ្ឈានដ៏ថោកទាបអាយុ ១៦ កប្ប យ៉ាងកណ្តាលអាយុ ៣២ កប្ប យ៉ាងឧត្តម អាយុ ៦៤ កប្ប ។ អដ្ឋកថា ។

អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយសោ ឥទំ នានាករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេន យទិទំ គតិយា ឧបបត្តិយា សតិ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិចារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តឹ អាបជ្ជតិ តត្ថ ឋិតោ តទធិមុត្តោ តព្ពហុលវិហារី អបរិហីនោ កាលំ កុរុមានោ វេហប្ផលានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ វេហប្ផលានំ ភិក្ខវេ ទេវានំ បញ្ច កប្បសតានិ អាយុប្បមាណំ តត្ថ បុថុជ្ជនោ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា និរយំបិ គច្ឆតិ តិរច្ឆានយោនឹបិ គច្ឆតិ បិត្តិវិសយំបិ គច្ឆតិ

ម្នាលភិក្ខុទាំងឡាយ នេះសេចក្តីប្លែកគ្នា នេះសេចក្តីអធិប្បាយ នេះដំណើរផ្សេងគ្នារបស់អរិយសាវក ដែលមានសេចក្តីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្តីចេះដឹង ដោយគតិនិងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលខ្លះ ក្នុងលោកនេះ ព្រោះលះបង់សុខផង លះបង់ទុក្ខផង ព្រោះវិនាសទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុនផង ក៏បានដល់នូវចតុត្ថជ្ឈាន ដែលមិនមានសុខមិនមានទុក្ខ មានតែសតិដ៏បរិសុទ្ធកើតអំពីឧបេក្ខា សម្រាន្តនៅ ។ បុគ្គលនោះ ក៏ត្រេកអរនឹងចតុត្ថជ្ឈាននោះ ស្រឡាញ់ចតុត្ថជ្ឈាននោះ ដល់នូវសេចក្តីត្រេកអរដោយចតុត្ថជ្ឈាននោះ ឋិតនៅក្នុងចតុត្ថជ្ឈាននោះ មានចិត្តចុះស៊ប់ក្នុងចតុត្ថជ្ឈាននោះ ជាអ្នកនៅដោយច្រើនក្នុងចតុត្ថជ្ឈាននោះ មិនបានសាបសូន្យចាកឈាន លុះធ្វើមរណកាលទៅ រមែងទៅកើតជាមួយនឹងពួកទេវតាជាន់វេហប្ផលៈ ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកទេវតាជាន់វេហប្ផលៈ ប្រមាណ ៥០០ កប្ប[១] ព្រហ្មបុថុជ្ជនឋិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជន ញុំាំងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ

១ សំដៅយកឧបបត្តិជ្ឈានដ៏ឧត្តមតែម្យ៉ាង ឯប្រមាណនៃអាយុក្នុងស្ថានវេហប្ផលព្រហ្មតែប៉ុណ្ណោះឯង ព្រោះព្រហ្មនេះមិនមានចែកជា ៣ ៗ ដូចជាព្រហ្មក្នុងបឋមជ្ឈានភូមិជាដើមទេ ។ អដ្ឋកថា ។

ភគវតោ បន សាវកោ តត្ថ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា តស្មឹយេវ ភវេ បរិនិព្វាយតិ ។ អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយសោ ឥទំ នានាករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេន យទិទំ គតិយា ឧបបត្តិយា សតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១២៤] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ

ចំណែកសាវ័ករបស់ព្រះដ៏មានព្រះភាគ ឋិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញុំាងអាយុទាំងអស់នោះឲ្យអស់ហើយ ក៏រមែងបរិនិព្វានក្នុងភពនោះតែម្តង ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីប្លែកគ្នា នេះជាសេចក្តីអធិប្បាយ នេះជាដំណើរផ្សេងគ្នា របស់អរិយសាវ័ក ដែលមានសេចក្តីចេះដឹង នឹងបុថុជ្ជន ដែលមិនមានសេចក្តីចេះដឹងដោយគតិនិងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

[១២៤] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ បានដល់បឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខៈកើតអំពីសេចក្តីស្ងប់ស្ងាត់សម្រាន្តនៅ ។ ធម៌គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា មានក្នុងលោកនេះ បុគ្គលនោះ

តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ ។ សោ កាយស្ស ភេទា បរម្មរណា សុទ្ធាវាសានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខវេ ឧបបត្តិ អសាធារណា បុថុជ្ជនេហិ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ វិវិច្ចេវ កាមេហិ ។បេ។ ទុតិយំ ឈានំ ។បេ។ តតិយំ ឈានំ ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ ។ សោ កាយស្ស ភេទា បរម្មរណា សុទ្ធាវាសានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។

ក៏ពិចារណាឃើញនូវធម៌ទាំងនោះ ដោយសភាពថា មិនទៀង ថាជាទុក្ខ ថាជារោគ ថាជាបូស ថាជាព្រួញ ថាជាសេចក្តីតានតឹង ថាជាអាពាធ ថាជារបស់អ្នកដទៃ ថាជារបស់ទ្រុឌទ្រោម ថាជារបស់សោះសូន្យ ថាជារបស់មិនមែនរបស់ខ្លួន បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់សុទ្ធាវាស ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាឧបបត្តិ (ការកើត) មិនបានទូទៅ ដល់បុថុជ្ជនទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ បានដល់ទុតិយជ្ឈាន ។ បេ ។ តតិយជ្ឈាន ។ បេ ។ បានដល់ចតុត្ថជ្ឈាន សម្រាន្តនៅ ។ ធម៌គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា មាននៅក្នុងលោកនោះ បុគ្គលនោះ ក៏ពិចារណាឃើញនូវធម៌ទាំងនោះ ដោយសភាពថា មិនទៀង ថាជាទុក្ខ ថាជារោគ ថាជាបូស ថាជាព្រួញ ថាជាសេចក្តីតានតឹង ថាជាអាពាធ ថាជារបស់អ្នកដទៃ ថាជារបស់ទ្រុឌទ្រោម ថាជារបស់សោះសូន្យ ថាជារបស់មិនមែនជារបស់ខ្លួន ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់សុទ្ធាវាស ។

អយំ ខោ ភិក្ខវេ ឧបបត្តិ អសាធារណា បុថុជ្ជនេហិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១២៥] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ សោ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តឹ អាបជ្ជតិ តត្ថ ឋិតោ តទធិមុត្តោ តព្វហុលវិហារី អបរិហីនោ កាលំ កុរុមានោ ព្រហ្មកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ ព្រហ្មកាយិកានំ ភិក្ខវេ ទេវានំ កប្បោ អាយុប្បមាណំ

ម្នាលភិក្ខុទាំងឡាយ នេះឯងជាឧបបត្តិ មិនបានទូទៅ ដល់បុថុជ្ជនទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

[១២៥] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ មានចិត្តប្រកដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូច ។ គ្នា មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹងគឺទិសតូច ។ ដោយការយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួងក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ។ បុគ្គលនោះ ក៏ត្រេកអរនឹងមេត្តានោះ ស្រឡាញ់មេត្តានោះ ដល់នូវសេចក្ដីត្រេកអរ ដោយមេត្តានោះ ឋិតនៅក្នុងមេត្តានោះ មានចិត្តចុះស៊ប់ក្នុងមេត្តានោះ ជាអ្នកនៅដោយច្រើនដោយមេត្តានោះ មិនបានសាបសូន្យចាកមេត្តា លុះធ្វើមរណកាលទៅ រមែងចូលទៅកាន់សហភាពនៃពួកព្រហ្មកាយិកទេវតា ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកព្រហ្មកាយិកទេវតា មានប្រមាណ ១ កប្ប

តត្ថ បុថុជ្ជនោ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា និរយំបិ គច្ឆតិ តិរច្ឆានយោនឹបិ គច្ឆតិ បិត្តិ-វិសយំបិ គច្ឆតិ ភគវតោ បន សាវកោ តត្ថ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា តស្មឹយេវ ភវេ បរិនិព្វាយតិ ។ អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយោ ឥទំ នានាករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេន យទិទំ គតិយា ឧបបត្តិយា សតិ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ករុណាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ករុណាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។

ព្រហ្មបុថុជ្ជនឋិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជនញ៉ាំងអាយុទាំងអស់នោះ ឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវ័ករបស់ព្រះដ៏មានព្រះភាគ ក៏ឋិតនៅក្នុងទីនោះ ដរាបអស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញ៉ាំងអាយុទាំងអស់នោះ ឲ្យអស់ហើយ រមែងបរិនិព្វានក្នុងភពនោះតែម្តង ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីប្លែកគ្នា នេះជាសេចក្តីអធិប្បាយ នេះជាដំណើរផ្សេងគ្នា របស់អរិយសាវ័ក ដែលមានសេចក្តីចេះដឹងនិងបុថុជ្ជនដែលមិនមានសេចក្តីចេះដឹង ដោយគតិនិងឧបបត្តិ ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ មានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូច ។ គ្នា មានចិត្តប្រកបដោយករុណាដ៏ធំទូលាយ ប្រមាណមិនបានមិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹងគឺទិសតូច ។ ដោយការយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទិសទាំងពួង សម្រេចសម្រាន្តនៅ ។

៣២៤



សោ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តឹ អាបជ្ជតិ តត្ថ ឋិតោ តទធិមុត្តោ តព្ពហុលវិហារី អបរិហីនោ កាលំ កុរុមានោ អាភស្សរានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ អាភស្សរានំ ភិក្ខវេ ទេវានំ ទ្វេ កប្បា អាយុប្បមាណំ តត្ថ បុថុជ្ជនោ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា និរយំបិ គច្ឆតិ តិរច្ឆានយោនឹបិ គច្ឆតិ បិត្តិវិសយំបិ គច្ឆតិ ភគវតោ បន សាវកោ តត្ថ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្ប-មាណំ តំ សព្វំ ខេបេត្វា តស្មឹយេវ ភវេ បរិនិព្វាយតិ ។ អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយសោ ឥទំ នានាករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេន យទិទំ គតិយា ឧប-បត្តិយា សតិ ។ បុន ចបរំ ភិក្ខវេ ឥធេ-កច្ចោ បុគ្គលោ មុទិតាសហគតេន ចេតសា

បុគ្គលនោះ ក៏ត្រេកអរនឹងករុណានោះ ស្រឡាញ់ករុណានោះ ដល់នូវសេចក្ដីត្រេកអរ ដោយករុណានោះ ឋិតនៅក្នុងករុណានោះ មានចិត្តចុះស៊ប់ក្នុងករុណានោះ ជាអ្នកនៅដោយច្រើនដោយករុណានោះ មិនបានសាបសូន្យចាកករុណា លុះធ្វើមរណកាលទៅ រមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់អាកស្សរៈ ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកទេវតាជាន់អាកស្សរៈមានប្រមាណ ២ កប្ប ព្រហ្មបុថុជ្ជនឋិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជនញុំាងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវ័ករបស់ព្រះដ៏មានព្រះភាគឋិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញុំាងអាយុទាំងអស់នោះ ឲ្យអស់ហើយ រមែងបរិនិព្វានក្នុងភពនោះតែម្ដង ។ ម្នាលភិក្ខុទាំង-ឡាយ នេះជាសេចក្ដីប្លែកគ្នា នេះជាសេចក្ដីអធិប្បាយ នេះជាដំណើរផ្សេងគ្នា របស់អរិយសាវ័ក ដែលមានសេចក្ដីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្ដីចេះដឹង ដោយគតិនិងឧបបត្តិ ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ មានចិត្តប្រកបដោយមុទិតា

៣២៦

ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មុទិតាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ សោ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តឹ អាបជ្ជតិ តត្ថ ឋិតោ តទធិមុត្តោ តព្វហុលវិហារី អបរិហីនោ កាលំ កុរុមានោ សុភកិណ្ហានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ សុភកិណ្ហានំ ភិក្ខវេ ទេវានំ ចត្តារោ កប្បា អាយុប្បមាណំ តត្ថ បុថុជ្ជនោ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា និរយំបិ គច្ឆតិ តិរច្ឆានយោនឹបិ គច្ឆតិ បិត្តិវិសយំបិ គច្ឆតិ ភគវតោ បន សាវកោ តត្ថ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា

ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូច ៗ គ្នា មានចិត្តប្រកបដោយមុទិតា ដ៏ធំទូលាយប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូច ៗ ដោយការយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ។ បុគ្គលនោះក៏ត្រេកអរនឹងមុទិតានោះ ស្រឡាញ់មុទិតានោះ ដល់នូវសេចក្តីត្រេកអរដោយមុទិតានោះ ឋិតនៅក្នុងមុទិតានោះ មានចិត្តចុះស៊ប់ក្នុងមុទិតានោះ ជាអ្នកនៅច្រើនដោយមុទិតានោះ មិនបានសាបសូន្យចាកមុទិតា លុះធ្វើមរណកាលទៅ រមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់សុភកិណ្ហៈ ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកទេវតា ជាន់សុភកិណ្ហៈ មានប្រមាណ ៤ កប្ប បុថុជ្ជនឋិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជន ញ៉ាំងអាយុទាំងអស់នោះ ឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវ័ករបស់ព្រះដ៏មានព្រះភាគ ឋិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញ៉ាំងអាយុទាំងនោះ ឲ្យអស់ហើយ

តស្មិំយេវ ភវេ បរិនិព្វាយតិ ។ អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយសោ ឥទំ នានាករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេន យទិទំ គតិយា ឧបបត្តិយា សតិ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហ-គតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ សោ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តឹ អាបជ្ជតិ តត្ថ ឋិតោ តទធិ-មុត្តោ តព្វហុលវិហារី អបរិហីនោ កាលំ កុរុមានោ វេហប្ផលានំ ទេវានំ សហាព្យតំ ឧបបជ្ជតិ ។ វេហប្ផលានំ ភិក្ខវេ ទេវានំ បញ្ច កប្បសតានិ អាយុប្បមាណំ

រមែងបរិនិព្វានក្នុងភពនោះតែម្តង ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីប្លែកគ្នា នេះជាសេចក្តីអធិប្បាយ នេះជាដំណើរផ្សេងគ្នា របស់អរិយសាវ័កដែលមានសេចក្តីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្តីចេះដឹង ដោយគតិនិងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលខ្លះ ក្នុងលោកនេះ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូច ។ គ្នា មានចិត្តប្រកបដោយឧបេក្ខា ដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូច ។ ដោយការយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួងក្នុងទីទាំងពួងសម្រេចសម្រាន្តនៅ ។ បុគ្គលនោះក៏ត្រេកអរនឹងឧបេក្ខានោះស្រឡាញ់ឧបេក្ខានោះ ដល់នូវសេចក្តីត្រេកអរ ដោយឧបេក្ខានោះឋិតនៅក្នុងឧបេក្ខានោះ មានចិត្តចុះស៊ប់ក្នុងឧបេក្ខានោះ ជាអ្នកនៅច្រើនដោយឧបេក្ខានោះ មិនបានសាបសូន្យចាកឧបេក្ខា លុះធ្វើមរណកាលទៅរមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់វេហប្ផលៈ ។ ម្នាលភិក្ខុទាំងឡាយ អាយុនៃពួកទេវតាជាន់វេហប្ផលៈ មានប្រមាណ ៥០០ កប្ប

តត្ថ បុថុជ្ជនោ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា និរយំបិ គច្ឆតិ តិរច្ឆានយោនឹបិ គច្ឆតិ បិត្តិវិសយំបិ គច្ឆតិ ភគវតោ បន សាវកោ តត្ថ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា តស្មឹយេវ ភវេ បរិនិព្វាយតិ ។ អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយសោ ឥទំ នានាករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេន យទិទំ គតិយា ឧបបត្តិយា សតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១២៦] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ

ព្រហ្មបុថុជ្ជនឋិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះព្រហ្មបុថុជ្ជន ញ៉ាំងអាយុទាំងអស់នោះ ឲ្យអស់ហើយ រមែងទៅកាន់នរកខ្លះ ទៅកាន់តិរច្ឆានកំណើតខ្លះ ទៅកាន់បិត្តិវិស័យខ្លះ ចំណែកសាវ័ករបស់ព្រះដ៏មានព្រះភាគ ឋិតនៅក្នុងទីនោះ ដរាបដល់អស់កំណត់អាយុ ប្រមាណនៃអាយុរបស់ទេវតាទាំងនោះ មានកំណត់ត្រឹមណា លុះញ៉ាំងអាយុទាំងអស់នោះឲ្យអស់ហើយ រមែងបរិនិព្វានក្នុងភពនោះតែម្តង ។ ម្នាលភិក្ខុទាំង-ឡាយ នេះជាសេចក្តីប្លែកគ្នា នេះជាសេចក្តីអធិប្បាយ នេះជាដំណើរផ្សេងគ្នា របស់អរិយសាវ័ក ដែលមានសេចក្តីចេះដឹង និងបុថុជ្ជនដែលមិនមានសេចក្តីចេះដឹង ដោយគតិនិងឧបបត្តិ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

[១២៦] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលខ្លះ ក្នុងលោកនេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូច ។ គ្នា

## ៣២៩



ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ សោ យទេវ តត្ថ ហោតិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ ។ សោ កាយស្ស ភេទា បរម្មរណា សុទ្ធាវាសានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខវេ ឧបបត្តិ អសាធារណា បុថុជ្ជនេហិ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ករុណាសហគតេន ចេតសា... ។ មុទិតាសហគតេន ចេតសា... ។ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ

មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹងគឺ ទិសតូច ៗ ដោយការយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទិសទាំងពួងសម្រេចសម្រាន្តនៅ ។ ធម៌គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា មានក្នុងលោកនេះ បុគ្គលនោះ តែងពិចារណាឃើញនូវធម៌ទាំងនោះ ដោយសភាពថា មិនទៀង ថាជាទុក្ខ ថាជារោគ ថាជាបូស ថាជាព្រួញ ថាជាសេចក្តីតានតឹង ថាជាអាពាធ ថាជារបស់អ្នកដទៃ ថាជារបស់ទ្រុឌទ្រោម ថាជារបស់សោះសូន្យ ថាជារបស់មិនមែនរបស់ខ្លួន ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់សុទ្ធាវាស ។ ម្នាលភិក្ខុទាំង-ឡាយនេះឯងជាឧបបត្តិ មិនបានទូទៅដល់បុថុជ្ជនទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ មានចិត្តប្រកបដោយករុណា... ។ មានចិត្តប្រកបដោយមុទិតា... ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូច ៗ គ្នា

ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ សោ យទេវ តត្ថ ហោតិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ ។ សោ កាយស្ស ភេទា បរម្មរណា សុទ្ធាវាសានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ ភិក្ខវេ ឧបបត្តិ អសាធារណា បុថុជ្ជនេហិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១២៧] តថាគតស្ស ភិក្ខវេ អរហតោ សម្មា-សម្ពុទ្ធស្ស ចាតុភាវា ចត្តារោ អច្ឆរិយា អព្ភុតធម្មា បាតុភវន្តិ ។ កតមេ ចត្តារោ ។ យទា ភិក្ខវេ ពោធិសត្តោ តុសិតា កាយា ចវិត្វា សតោ

មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹងគឺទិសតូច ៗ ដោយការយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ។ ធម៌គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា មានក្នុងលោកនោះ បុគ្គលនោះតែងពិចារណាឃើញនូវធម៌ទាំងនោះ ដោយសភាពថា មិនទៀង ថាជាទុក្ខ ថាជារោគ ថាជាបូស ថាជាព្រួញ ថាជាសេចក្ដីតានតឹង ថាជាអាពាធ ថាជារបស់អ្នកដទៃ ថាជារបស់ទ្រុឌទ្រោម ថាជារបស់សោះសូន្យ ថាជារបស់មិនមែនជារបស់ខ្លួន ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកាន់សហភាពនៃពួកទេវតាជាន់សុទ្ធាវាស ។ ម្នាលភិក្ខុទាំង-ឡាយ នេះឯងជាឧបបត្តិ មិនបានទូទៅដល់បុថុជ្ជនទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

[១២៧] ម្នាលភិក្ខុទាំងឡាយ ហេតុដែលអស្ចារ្យចម្លែក ៤ យ៉ាង រមែងកើតប្រាកដ ព្រោះការកើតនៃតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ហេតុដែលអស្ចារ្យចម្លែក ៤ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពោធិសត្វច្យុតចាកពួកទេវតាជាន់តុសិត មានស្មារតី

តតិយបណ្ណាសកេ ភយវគ្គោ

សម្បជានោ មាតុកុច្ឆឹ ឱក្កមតិ អថ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អប្បមាណោ ឧឡារោ ឱភាសោ ចាតុភវតិ អតិក្កម្មេវ ទេវានំ ទេវានុភាវំ យាបិ តា[១] លោកន្តរិកា អឃា អសំវុតា អន្ធការា អន្ធការតិមិសា យត្ថិមេសំ ចន្ទិមសុរិយានំ ឯវំ-មហិទ្ធិកានំ ឯវំមហានុភាវានំ អាភា នានុភោន្តិ

១ ម. យាវតា ។

*ដឹងខ្លួនចុះកាន់ផ្ទៃនៃព្រះមាតា ក្នុងកាលណា កាលនោះពន្លឺដ៏លើសលុប ប្រមាណមិនបាន កន្លងបង់នូវអានុភាពដ៏ប្រសើររបស់ទេវតាទាំងឡាយ ក៏កើតប្រាកដក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ចំណែកលោកន្តរិកនរក[១] ទាំងប៉ុន្មាន ដែលជាទីចំហមិនមានអ្វីទ្រខាងក្រោម ជាទីងងឹត មានតែអ័ព្ទងងឹតសូន្យសុង ពន្លឺព្រះចន្ទ្រនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ[២] រមែងផ្សាយទៅមិនដល់[៣] លោកន្តរិកនរកណា*

---

១ នរកដែលតាំងនៅក្នុងចន្លោះនៃចក្រវាឡ ៣ ៗ ហៅថាលោកន្តរៈ ១ ដូចជាឱកាសត្រង់កណ្តាលនៃប្រជុំកង់រទេះបី ៗ ឬបាត្របីដែលគេដាក់ទល់គ្នានឹងគ្នា នរកនោះឯងមានទំហំ ៨ ពាន់យោជន៍ សត្វដែលកើតក្នុងនរកនោះព្រោះធ្វើនូវកំហុសដ៏មានទម្ងន់ចំពោះមាតាបិតា និងសមណព្រាហ្មណ៍ដែលប្រកបដោយធម៌ ឬព្រោះអំពើដទៃ ដ៏ឆុតឆាប់ មានសម្លាប់សត្វរាល់ ៗ ថ្ងៃជាដើម សត្វនរកទាំងនោះមានខ្លួន ៣ គាវុត មានក្រចកវែង ៗ ព្យួរតែងតោងនឹងជើងភ្នំចក្រវាឡដោយក្រចកដូចសត្វប្រចៀវតោងដើមឈើ ។ អដ្ឋកថា ។

២ មានឫទ្ធិច្រើនដោយហេតុរះឡើងម្តង បំភ្លឺបានក្នុងទ្វីប ៣ មានអានុភាពច្រើន ដោយហេតុកម្ចាត់បង់នូវងងឹតបញ្ចេញពន្លឺចម្ងាយ ៩ សែនយោជន៍ទៅក្នុងទិសមួយ ៗ ។

៣ ព្រះចន្ទ្រនិងព្រះអាទិត្យទាំងនោះ ដើរចំកណ្តាលភ្នំចក្រវាឡ ឯលោកន្តរិកនរកកន្លងហួសភ្នំចក្រវាឡទៅទៀត ព្រោះហេតុនោះ បានជាពន្លឺនៃព្រះអាទិត្យព្រះចន្ទ្រផ្សាយទៅមិនដល់ក្នុងនរកនោះ ។ អដ្ឋកថា ។

តត្ថបិ អប្បមាណោ ឧឡារោ ឱភាសោ បាតុភវតិ អតិក្កម្មេវ ទេវានំ ទេវានុភាវំ យេបិ តត្ថ សត្តា ឧបបន្នា តេបិ តេនោភាសេន អញ្ញមញ្ញំ សញ្ជានន្តិ អញ្ញេបិ កិរ ភោ សន្តិ សត្តា ឥធូបបន្នាតិ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បាតុភាវា អយំ បឋមោ អច្ឆរិយោ អព្ភុតធម្មោ បាតុភវតិ ។ បុន ចបរំ ភិក្ខវេ យទា ពោធិសត្តោ សតោ សម្បជានោ មាតុកុច្ឆិស្មា និក្ខមតិ ។ បេ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បាតុភាវា អយំ ទុតិយោ អច្ឆរិយោ អព្ភុតធម្មោ បាតុភវតិ ។ បុន ចបរំ ភិក្ខវេ យទា តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈតិ ។ បេ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បាតុភាវា អយំ តតិយោ អច្ឆរិយោ អព្ភុតធម្មោ បាតុភវតិ ។ បុន ចបរំ ភិក្ខវេ យទា តថាគតោ អនុត្តរំ ធម្មចក្កំ បវត្តេតិ អថ

ពន្លឺដ៏លើសលុបប្រមាណមិនបាន កន្លងបង់នូវអានុភាពដ៏ប្រសើររបស់ទេវតាទាំងឡាយ ក៏កើតមានប្រាកដ ក្នុងលោកន្តរិកនរកនោះឯង ពួកសត្វណា ដែលកើតក្នុងលោកន្តរិកនរកនោះ សត្វទាំងនោះ ក៏ស្គាល់គ្នានឹងគ្នាដោយសារពន្លឺនោះថា ឱហ្ន៎ ពួកសត្វដទៃមកកើតក្នុងទីនេះដែរតើ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ១ កើតប្រាកដឡើង ព្រោះការកើតឡើងនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពោធិសត្វ មានស្មារតីដឹងខ្លួន ប្រសូតចេញចាកផ្ទៃនៃព្រះមាតា ក្នុងកាលណា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុដែលអស្ចារ្យចម្លែកទី ២ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគត បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងកាលណា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ៣ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ព្រះតថាគត ញុំាងធម្មចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅក្នុងកាលណា កាលនោះ

៣៣៣



សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណ-ព្រាហ្មណិយា បជាយ សទេវមនុស្សាយ អប្បមាណោ ឧឡារោ ឱភាសោ បាតុភវតិ អតិក្កម្មេវ ទេវានំ ទេវានុភាវំ យាបិ តា លោកន្តរិកា អឃា អសំវុតា អន្ធការា អន្ធការតិមិសា យត្ថិមេសំ ចន្ទិមសុរិយានំ ឯវំមហិ-ទ្ធិកានំ ឯវំមហានុភាវានំ អាភា នានុភោន្តិ តត្ថបិ អប្បមាណោ ឧឡារោ ឱភាសោ បាតុភវតិ អតិក្ក-ម្មេវ ទេវានំ ទេវានុភាវំ យេបិ តត្ថ សត្តា ឧបបន្នា តេបិ តេនោភាសេន អញ្ញមញ្ញំ សញ្ជានន្តិ អញ្ញេបិ កិរ ភោ សន្តិ សត្តា ឥធូបបន្នាតិ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បាតុភាវា អយំ ចតុត្ថោ អច្ឆរិយោ អព្ភុតធម្មោ បាតុភវតិ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បាតុភាវា ឥមេ ចត្តារោ អច្ឆរិយា អព្ភុតធម្មា បាតុភវន្តីតិ ។

ពន្លឺដ៏លើសលុប ប្រមាណមិនបាន កន្លងបង់នូវអានុភាពដ៏ប្រសើររបស់ទេវតាទាំងឡាយ ក៏កើតមានប្រាកដ ក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសចំណែកលោកន្តរិកនរកទាំងប៉ុន្មាន ដែលជាទីចំហ មិនមានអ្វីទ្រខាងក្រោម ជាទីងងឹត មានតែអ័ព្ទងងឹតសូន្យសុង ពន្លឺនៃព្រះចន្ទ្រនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើន យ៉ាងនេះ មានអានុភាពច្រើន យ៉ាងនេះ ក៏រមែងផ្សាយទៅមិនដល់ ក្នុងលោកន្តរិកនរកណា ពន្លឺដ៏លើសលុប ប្រមាណមិនបាន កន្លងបង់នូវអានុភាពដ៏ប្រសើររបស់ទេវតាទាំងឡាយ ក៏កើតមានប្រាកដ ក្នុងលោកន្តរិកនរកនោះឯង ពួកសត្វណា កើតក្នុងលោកន្តរិកនរកនោះ សត្វទាំងនោះឯង ក៏ស្គាល់គ្នានឹងគ្នាដោយសារពន្លឺនោះថា ឱហ្ន៎ មានពួកសត្វដទៃមកកើតក្នុងទីនេះដែរតើ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ៤ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែក ៤ យ៉ាងនេះឯង រមែងកើតប្រាកដព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។

[១២៨] តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស ចាតុភាវា ចត្តារោ អច្ឆរិយា អព្ភុតធម្មា ចាតុភវន្តិ ។ កតមេ ចត្តារោ ។ អាលយារាមា ភិក្ខវេ បជា អាលយរតា អាលយសម្មុទិតា សា តថាគតេន អនាលយេ ធម្មេ ទេសិយមានេ សុស្សុតិ[១] សោតំ ឱទហតិ អញ្ញាចិត្តំ ឧបដ្ឋបេតិ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស ចាតុភាវា អយំ បឋមោ អច្ឆរិយោ អព្ភុតធម្មោ ចាតុភវតិ ។ មានារាមា ភិក្ខវេ បជា មានរតា មានសម្មុទិតា សា តថាគតេន មានវិនយេ ធម្មេ ទេសិយមានេ សុស្សុតិ សោតំ ឱទហតិ អញ្ញាចិត្តំ ឧបដ្ឋបេតិ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស ចាតុភាវា អយំ ទុតិយោ អច្ឆរិយោ អព្ភុតធម្មោ ចាតុភវតិ ។ អនុបសមារាមា ភិក្ខវេ បជា អនុបសមរតា អនុបសមសម្មុទិតា សា តថាគតេន ឱបសមិកេ ធម្មេ ទេសិយមានេ សុស្សុតិ សោតំ ឱទហតិ អញ្ញាចិត្តំ ឧបដ្ឋបេតិ ។

១ ឱ. សុស្សូយតិ ។ ម. សុស្សុសតិ ។

[១២៨] ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែក ៤ យ៉ាង រមែងកើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ហេតុអស្ចារ្យ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពពួកសត្វមានអាល័យ[១] ជាទីត្រេកអរ ត្រេកអរក្នុងអាល័យ រីករាយក្នុងអាល័យ ពពួកសត្វនោះឯង កាលបើតថាគតសម្តែងធម៌ជាទំនាស់ដល់អាល័យក៏ចង់ស្តាប់ ផ្ទង់ត្រចៀកតម្កល់ចិត្តខ្ជាប់ដើម្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ១ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ពពួកសត្វមានមានះជាទីត្រេកអរ ត្រេកអរក្នុងមានះ រីករាយក្នុងមានះ ពពួកសត្វនោះ កាលបើព្រះតថាគត សម្តែងនូវធម៌ជាគ្រឿងកម្ចាត់បង់នូវមានះ ក៏ចង់ស្តាប់ ផ្ទង់ត្រចៀក តម្កល់ចិត្តខ្ជាប់ដើម្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ២ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្ត-សម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ពពួកសត្វមានសេចក្តីមិនស្ងប់រម្ងាប់ជាទីត្រេកអរ ត្រេកអរក្នុងសេចក្តីមិនស្ងប់រម្ងាប់ រីករាយក្នុងសេចក្តីមិនស្ងប់រម្ងាប់ ពពួកសត្វនោះ កាលបើព្រះតថាគត សម្តែងនូវធម៌ជាគ្រឿងស្ងប់រម្ងាប់ ក៏ចង់ស្តាប់ ផ្ទង់ត្រចៀក តម្កល់ចិត្តខ្ជាប់ដើម្បីដឹង ។

---

១ កាមគុណ ៥ ឬវដ្តៈទាំងអស់នេះហៅថា អាល័យ ក្នុងទីនេះបានសេចក្តីថា ជាប់នៅដោយ តណ្ហានិងទិដ្ឋិ ។ អដ្ឋកថា ។

តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស ចាតុ-ភាវា អយំ តតិយោ អច្ឆរិយោ អព្ភុតធម្មោ ចាតុភវតិ ។ អវិជ្ជាគតា ភិក្ខវេ បជា អណ្ឌភូតា បរិយោនទ្ធា សា តថាគតេន អវិជ្ជាវិនយេ ធម្មេ ទេសិយមានេ សុស្សូតិ សោតំ ឱទហាតិ អញ្ញាចិត្តំ ឧបដ្ឋបេតិ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស ចាតុភាវា អយំ ចតុត្ថោ អច្ឆរិយោ អព្ភុតធម្មោ ចាតុភវតិ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស ចាតុភាវា ឥមេ ចត្តារោ អច្ឆរិយា អព្ភុតធម្មា ចាតុភវន្តីតិ ។

[១២៩] ចត្តារោមេ ភិក្ខវេ អច្ឆរិយា អព្ភុតធម្មា អានន្ទេ ។ កតមេ ចត្តារោ ។ សចេ ភិក្ខវេ ភិក្ខុ-បរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ ទស្សនេនបិ សា អត្តមនា ហោតិ តត្ថ ចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ ភិក្ខុបរិសា ហោតិ អថ អានន្ទោ តុណ្ហី ភវតិ ។ សចេ ភិក្ខវេ ភិក្ខុនីបរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ

ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ៣ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំង-ឡាយ ពពួកសត្វប្រកបដោយអវិជ្ជា ដូចខ្វាក់ ត្រូវអវិជ្ជារួបរឹត ពពួកសត្វនោះ កាលបើព្រះតថាគត សម្តែងធម៌ជាគ្រឿងកម្ចាត់បង់អវិជ្ជា ក៏ចង់ស្តាប់ ផ្ចង់ត្រចៀក តម្កល់ចិត្តខ្ជាប់ដើម្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ៤ កើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្ត-សម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែកទាំង ៤ នេះឯង រមែងកើតប្រាកដ ព្រោះការកើតនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។

[១២៩] ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែកក្នុងអានន្ទ នេះមាន ៤ យ៉ាង ។ ហេតុអស្ចារ្យចម្លែក ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុបរិសទ្យចូលទៅដើម្បីជួបនឹង[១] អានន្ទ ភិក្ខុបរិសទ្យនោះតែងមានចិត្តរីករាយដោយការឃើញផង បើអានន្ទនិយាយធម៌ក្នុងទីនោះ ភិក្ខុបរិសទ្យនោះ ក៏មានចិត្តរីករាយដោយភាសិតផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិសទ្យមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនីបរិសទ្យចូលទៅ ដើម្បីជួបនឹងអានន្ទ

---

១. សំដៅយកពួកភិក្ខុដែលមានប្រាថ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ តែងចូលទៅរកព្រះអានន្ទសិន ឬពួកភិក្ខុដែលមក ព្រោះឮកិត្តិគុណរបស់ព្រះអានន្ទត្ថេរថា ព្រះអានន្ទដ៏មានអាយុមានរូបល្អ គួរឲ្យរមិលមើល ជាពហុស្សូត ជាធម្មកថិក ជាអ្នកមានលម្អក្នុងសង្ឃ ។ បរិសទ្យ ៣ ខាងចុងក៏មានន័យដូចនេះដែរ ។

៣៣៦



ទស្សនេនបិ សា អត្តមនា ហោតិ តត្ថ ចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ ភិក្ខុនីបរិសា ហោតិ អថ អានន្ទោ តុណ្ហី ភវតិ ។ សចេ ភិក្ខវេ ឧបាសក-បរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ ទស្សនេនបិ សា អត្តមនា ហោតិ តត្ថ ចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ ឧបាសកបរិសា ហោតិ អថ អានន្ទោ តុណ្ហី ភវតិ ។ សចេ ភិក្ខវេ ឧបាសិកាបរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ ទស្សនេនបិ សា អត្តមនា ហោតិ តត្ថ ចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ ឧបាសិកាបរិសា ហោតិ អថ អានន្ទោ តុណ្ហី ភវតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អច្ឆរិយា អព្ភុតធម្មា អានន្ទេតិ ។

ភិក្ខុនីបរិសទ្យនោះ តែងមានចិត្តរីករាយដោយការឃើញផង បើអានន្ទនិយាយធម៌ក្នុងទីនោះ[១] ភិក្ខុនីបរិសទ្យនោះ ក៏មានចិត្តរីករាយដោយភាសិតផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីបរិសទ្យមិនទាន់ឆ្អែតនៅឡើយ ស្រាប់តែអានន្ទឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ បើឧបាសកបរិសទ្យចូលទៅដើម្បីជួបនឹងអានន្ទ ឧបាសកបរិសទ្យ តែងមានចិត្តរីករាយដោយការឃើញផង បើអានន្ទនិយាយធម៌ក្នុងទីនោះ ឧបាសកបរិសទ្យ[២] នោះ តែងមានចិត្តរីករាយដោយភាសិតផង ម្នាលភិក្ខុទាំងឡាយ ឧបាសកបរិសទ្យមិនទាន់ឆ្អែតនៅឡើយ ស្រាប់តែអានន្ទឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ បើឧបាសិកាបរិសទ្យចូលទៅ ដើម្បីជួបនឹងអានន្ទ ឧបាសិកាបរិសទ្យនោះ តែងមានចិត្តរីករាយដោយការឃើញផង បើអានន្ទនិយាយធម៌ក្នុងទីនោះ ឧបាសិកាបរិសទ្យ ក៏មានចិត្តរីករាយដោយភាសិតផង ម្នាលភិក្ខុទាំងឡាយ ឧបាសិកាបរិសទ្យមិនទាន់ឆ្អែតនៅឡើយ ស្រាប់តែអានន្ទឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែកក្នុងអានន្ទ ៤ យ៉ាងនេះឯង ។

---

១. គឺនិយាយនូវបដិសន្ថារធម៌យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ចុះអ្នកល្មមអត់ទ្រាំបានដែរឬ ល្មមប្រព្រឹត្តទៅបានស្រួលដែរឬ អ្នកទាំងឡាយធ្វើនូវអំពើក្នុងការយកចិត្តទុកដាក់ដោយឧបាយប្រាជ្ញាបានបំពេញអាចរិយវត្តនិងឧបជ្ឈាយវត្តដែរឬ ។ ២. និយាយទូន្មានថា នែឧបាសក អ្នកទាំងឡាយ រក្សានូវសរណគមន៍ ៣ នឹងសីល៥ដូចម្តេចខ្លះ ធ្វើឧបោសថ៨ក្នុងខែ ១ ដូចម្តេចខ្លះ បំពេញនូវឧបដ្ឋានវត្តដល់មាតាបិតាដូចម្តេចខ្លះ ផ្គត់ផ្គង់សមណៈនិងព្រាហ្មណ៍ដែលប្រកបដោយធម៌ដូចម្តេចខ្លះ ។ ក្នុងឧបាសិកាបរិសទ្យក៏ដូចគ្នា ។ អដ្ឋកថា ។

[១៣០] ចត្តារោមេ ភិក្ខវេ អច្ឆរិយា អព្ភុតធម្មា អានន្ទេ ។ កតមេ ចត្តារោ ។ សចេ ភិក្ខវេ ខត្តិយបរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ ទស្សនេនបិ សា អត្តមនា ហោតិ តត្ថ ចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តាវ ភិក្ខវេ ខត្តិយបរិសា ហោតិ អថ អានន្ទោ តុណ្ហី ភវតិ ។ សចេ ភិក្ខវេ ព្រាហ្មណបរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ ទស្សនេនបិ សា អត្តមនា ហោតិ តត្ថ ចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តាវ ភិក្ខវេ ព្រាហ្មណបរិសា ហោតិ អថ អានន្ទោ តុណ្ហី ភវតិ ។ សចេ ភិក្ខវេ គហបតិបរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ ទស្សនេនបិ សា អត្តមនា ហោតិ តត្ថ ចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តាវ ភិក្ខវេ គហបតិបរិសា ហោតិ អថ អានន្ទោ តុណ្ហី ភវតិ ។

តតិយបណ្ណាសក ភយវគ្គ

[១៣០] ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែក ក្នុងស្តេចចក្រ-ពត្តិនេះ មាន ៤ យ៉ាង ។ ហេតុអស្ចារ្យចម្លែក ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើខត្តិយបរិសទ្យចូលទៅ ដើម្បីគាល់ស្តេចចក្រពត្តិ ខត្តិយបរិសទ្យនោះតែងមានចិត្តរីករាយដោយការឃើញផង បើស្តេចចក្រ-ពត្តិមានព្រះរាជឱង្ការ (ដោយបដិសន្ថារធម៌) ក្នុងទីនោះ ខត្តិយបរិសទ្យនោះ ក៏មានចិត្តរីករាយ ដោយព្រះរាជឱង្ការផង ម្នាលភិក្ខុទាំងឡាយ ខត្តិយ-បរិសទ្យ មិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែស្តេចចក្រពត្តិឈប់ស្ងៀម ។ ម្នាលភិក្ខុទាំងឡាយ បើព្រាហ្មណបរិសទ្យនោះចូលទៅ ដើម្បីគាល់ស្តេចចក្រពត្តិ ព្រាហ្មណបរិសទ្យនោះ តែងមានចិត្តរីករាយដោយការឃើញផង បើស្តេចចក្រពត្តិមានព្រះឱង្ការក្នុងទីនោះ ព្រាហ្មណបរិសទ្យនោះ ក៏មានចិត្តរីករាយដោយព្រះរាជឱង្ការផង ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណបរិ-សទ្យ មិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែស្តេចចក្រពត្តិឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ បើគហបតីបរិសទ្យចូលទៅ ដើម្បីគាល់ស្តេចចក្រពត្តិ គហបតីបរិសទ្យនោះ តែងមានចិត្តរីករាយដោយការឃើញផង បើស្តេចចក្រពត្តិមានព្រះឱង្ការក្នុងទីនោះ គហបតីបរិសទ្យនោះ ក៏មានចិត្តរីករាយដោយព្រះរាជឱង្ការផង ម្នាលភិក្ខុទាំងឡាយ គហបតីបរិសទ្យ មិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែស្តេចចក្រពត្តិឈប់ស្ងៀម ១ ។

សចេ ភិក្ខវេ សមណបរិសា រាជានំ ចក្កវត្តឹ ទស្សនាយ ឧបសង្កមតិ ទស្សនេនបិ សា អត្តមនា ហោតិ តត្ថ ចេ រាជា ចក្កវត្តី ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ សមណបរិសា ហោតិ អថ រាជា ចក្កវត្តី តុណ្ហី ភវតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អច្ឆរិយា អព្ភុតធម្មា រញ្ញេ ចក្កវត្តិម្ហិ ។ ឯវមេវ ខោ ភិក្ខវេ ចត្តារោ អច្ឆរិយា អព្ភុតធម្មា អានន្ទេ ។ កតមេ ចត្តារោ ។ សចេ ភិក្ខវេ ភិក្ខុបរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ ទស្សនេនបិ សា អត្តមនា ហោតិ តត្ថ ចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ ភិក្ខុបរិសា ហោតិ អថ អានន្ទោ តុណ្ហី ភវតិ ។ សចេ ភិក្ខវេ ភិក្ខុនីបរិសា… ។ សចេ ភិក្ខវេ ឧបាសកបរិសា… ។ សចេ ភិក្ខវេ ឧបាសិកាបរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ

ម្នាលភិក្ខុទាំងឡាយ បើសមណបរិសទ្យចូលទៅ ដើម្បីចួបស្តេចចក្រពត្តិ សមណបរិសទ្យនោះ តែងមានចិត្តរីករាយដោយការឃើញផង បើស្តេចចក្រពត្តិមានព្រះឱង្ការក្នុងទីនោះ សមណបរិសទ្យនោះ ក៏មានចិត្តរីករាយដោយព្រះឱង្ការផង ម្នាលភិក្ខុទាំងឡាយ សមណបរិសទ្យ មិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែស្តេចចក្រពត្តិឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែក ក្នុងស្តេចចក្រពត្តិ ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ហេតុអស្ចារ្យចម្លែក ក្នុងអានន្ទ ក៏មាន ៤ យ៉ាងដូច្នោះដែរ ។ ហេតុអស្ចារ្យចម្លែក ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុបរិសទ្យចូលទៅ ដើម្បីចួបនឹងអានន្ទ ភិក្ខុបរិសទ្យនោះ តែងមានចិត្តរីករាយដោយការឃើញផង បើអានន្ទនិយាយធម៌ក្នុងទីនោះ ភិក្ខុបរិសទ្យនោះ ក៏មានចិត្តរីករាយដោយភាសិតផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិសទ្យមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនីបរិសទ្យ... ។ ម្នាលភិក្ខុទាំងឡាយ បើឧបាសកបរិសទ្យ... ។ ម្នាលភិក្ខុទាំងឡាយ បើឧបាសិកាបរិសទ្យចូលទៅ ដើម្បីចួបនឹងអានន្ទ

ឧស្សនេនបិ សា អត្តមនា ហោតិ តត្ថ ចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ ឧបាសិកាបរិសា ហោតិ អថ អានន្ទោ តុណ្ហី ភវតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អច្ឆរិយា អព្ភុតធម្មា អានន្ទេតិ ។

ភយវគ្គោ តតិយោ ។

## តស្សុទ្ទានំ[១]

អត្តានុវាទឩមិ ច
ទ្វេ ច នានា ទ្វេ ច ហោន្តិ
មេត្តា ទ្វេ ច អច្ឆរិយា
អព្ភុតធម្មា បរា ទ្វេតិ ។

---

១ មរម្មបោត្ថកេយេវ អត្ថិ ។

ឧបាសិកាបរិសទ្យនោះ តែងមានចិត្តរីករាយដោយការឃើញផង បើអានន្ទនិយាយធម៌ក្នុងទីនោះ ឧបាសិកាបរិសទ្យនោះ ក៏មានចិត្តរីករាយដោយភាសិតផង ម្នាលភិក្ខុទាំងឡាយ ឧបាសិកាបរិសទ្យមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទឈប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែក ក្នុងអានន្ទ ៤ យ៉ាងនេះឯង ។

ចប់ ភយវគ្គ ទី ៣ ។

## ឧទ្ទាននៃភយវគ្គនោះគឺ[១]

និយាយអំពីអត្តានុវាទភ័យ ១ អំពីឧមិភ័យ ១ អំពីដំណើរផ្សេង ៗ គ្នានៃអរិយសាវ័ក និងបុថុជ្ជនមានពីរ ២ ដង អំពីមេត្តា ១ អំពីហេតុអស្ចារ្យចម្លែក ២ លើក និង ២ លើកដទៃទៀត ។

១ ឧទ្ទាននេះមានតែក្នុងអក្សរភូមា ។

# បុគ្គលវគ្គោ

[១៣១] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស ឱរម្ភាគិយានិ សញ្ញោជនានិ អប្បហីនានិ ហោន្តិ ឧប្បត្តិប្បដិលាភិកានិ[(១)] សញ្ញោជនានិ អប្បហីនានិ ហោន្តិ ភវប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ហោន្តិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស ឱរម្ភាគិយានិ សញ្ញោជនានិ បហីនានិ ហោន្តិ ឧប្បត្តិប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ហោន្តិ ភវប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ហោន្តិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស ឱរម្ភាគិយានិ សញ្ញោជនានិ បហីនានិ ហោន្តិ ឧប្បត្តិប្បដិលាភិកានិ សញ្ញោជនានិ បហីនានិ ហោន្តិ ភវប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ហោន្តិ ។

១ ម. ឧបបត្តិបដិលាភិយានិ ។

# បុគ្គលវគ្គ

[១៣១] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាន ប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ មិនទាន់បានលះបង់ឱរម្ភាគិយសញ្ញោជនៈ មិន ទាន់លះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ (សំយោជនៈជាបច្ច័យដើម្បី បានទូវឧបបត្តិភព) មិនទាន់បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ (សំយោជនៈជាបច្ច័យ ដើម្បីបានទូវភព) ។ ម្នាលភិក្ខុទាំងឡាយ មួយ ទៀត បុគ្គលខ្លះ ក្នុងលោកនេះ បានលះបង់ឱរម្ភាគិយសញ្ញោជនៈ តែមិន ទាន់បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ មិនទាន់បានលះបង់ភវប្ប-ដិលាភិកសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុង លោកនេះ បានលះបង់ឱរម្ភាគិយសញ្ញោជនៈ បានលះបង់ឧប្បត្តិប្បដិលា-ភិកសញ្ញោជនៈ តែមិនទាន់បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។

ឥធ បន ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស ឱរម្ភាគិយានិ សញ្ញោជនានិ បហីនានិ ហោន្តិ ឧប្បត្តិប្បដិលាភិកានិ សញ្ញោជនានិ បហីនានិ ហោន្តិ ភវប្បដិលាភិកានិ សញ្ញោជនានិ បហីនានិ ហោន្តិ ។ កតមស្ស ភិក្ខវេ បុគ្គលស្ស ឱរម្ភាគិយានិ សញ្ញោជនានិ អប្បហីនានិ ឧប្បត្តិប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ភវប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ។ សកទាគាមិស្ស ។ ឥមស្ស ខោ ភិក្ខវេ បុគ្គលស្ស ឱរម្ភាគិយានិ សញ្ញោជនានិ អប្បហីនានិ ឧប្បត្តិប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ភវប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ។ កតមស្ស ភិក្ខវេ បុគ្គលស្ស ឱរម្ភាគិយានិ សញ្ញោជនានិ បហីនានិ ឧប្បត្តិប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ភវប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ។ ឧទ្ធំសោតស្ស អកនិដ្ឋគាមិនោ ។ ឥមស្ស ខោ ភិក្ខវេ បុគ្គលស្ស ឱរម្ភាគិយានិ សញ្ញោជនានិ បហីនានិ

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលខ្លះ ក្នុងលោកនេះ បានលះបង់ឱរម្ភាគិយសញ្ញោជនៈ បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេច ដែលមិនទាន់បានលះបង់ឱរម្ភាគិយសញ្ញោជនៈ មិនទាន់បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ មិនទាន់បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ បានដល់សកទាគាមី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឯង ដែលមិនទាន់បានលះបង់ឱរម្ភាគិយសញ្ញោជនៈ មិនបានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ មិនទាន់បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេច ដែលបានលះបង់ឱរម្ភាគិយសញ្ញោជនៈ តែមិនទាន់បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ មិនទាន់បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ បានដល់ឧទ្ធំសោតអកនិដ្ឋគាមី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឯង ដែលបានលះបង់ឱរម្ភាគិយសញ្ញោជនៈ

ឧប្បត្តិប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ភវប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ។ កតមស្ស ភិក្ខវេ បុគ្គលស្ស ឱរម្ភាគិយានិ សញ្ញោជនានិ បហីនានិ ឧប្បត្តិប្បដិលាភិកានិ សញ្ញោជនានិ បហីនានិ ភវប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ។ អន្តរាបរិនិព្វាយិស្ស ។ ឥមស្ស ខោ ភិក្ខវេ បុគ្គលស្ស ឱរម្ភាគិយានិ សញ្ញោជនានិ បហីនានិ ឧប្បត្តិប្បដិលាភិកានិ សញ្ញោជនានិ បហីនានិ ភវប្បដិលាភិកានិ សញ្ញោជនានិ អប្បហីនានិ ។ កតមស្ស ភិក្ខវេ បុគ្គលស្ស ឱរម្ភាគិយានិ សញ្ញោជនានិ បហីនានិ ឧប្បត្តិប្បដិលាភិកានិ សញ្ញោជនានិ បហីនានិ ភវប្បដិលាភិកានិ សញ្ញោជនានិ បហីនានិ ។ អរហតោ ខីណាសវស្ស ។ ឥមស្ស ខោ ភិក្ខវេ បុគ្គលស្ស ឱរម្ភាគិយានិ សញ្ញោជនានិ បហីនានិ ឧប្បត្តិប្បដិលាភិកានិ សញ្ញោជនានិ បហីនានិ ភវប្បដិលាភិកានិ សញ្ញោជនានិ បហីនានិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

តែមិនទាន់បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ មិនទាន់បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេច ដែលបានលះបង់ឱរម្ភាគិយសញ្ញោជនៈ បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ តែមិនទាន់បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ បានដល់អន្តរាបរិនិព្វាយី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឯងដែលបានលះបង់ឱរម្ភាគិយសញ្ញោជនៈ បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ តែមិនទាន់បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេច ដែលបានលះបង់ឱរម្ភាគិយសញ្ញោជនៈ បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ បានដល់អរហន្តខីណាស្រព ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឯងដែលបានលះបង់ឱរម្ភាគិយសញ្ញោជនៈ បានលះបង់ឧប្បត្តិប្បដិលាភិកសញ្ញោជនៈ បានលះបង់ភវប្បដិលាភិកសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

តតិយបណ្ណាសកេ បុគ្គលវគ្គោ

[១៣៦] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ យុត្តប្បដិភាណោ ន មុត្តប្បដិភាណោ មុត្តប្បដិភាណោ ន យុត្តប្បដិភាណោ យុត្តប្បដិភាណោ ច មុត្តប្បដិ-ភាណោ ច នេវ យុត្តប្បដិភាណោ ន មុត្តប្បដិ-ភាណោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១៣៧] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឧគ្ឃដិតញ្ញូ វិបច្ចិតញ្ញូ នេយ្យោ បទបរមោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

តតិយបណ្ណាសក បុគ្គលវគ្គ

[១៣២] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលមានប្រាជ្ញាគួរ តែមិនមានប្រាជ្ញារហ័ស[១] ១ មានប្រាជ្ញារហ័ស តែមិនមានប្រាជ្ញាគួរ ១ មានប្រាជ្ញាគួរផង មានប្រាជ្ញារហ័សផង ១ មានប្រាជ្ញាមិនគួរ មានប្រាជ្ញាមិនរហ័ស ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

[១៣៣] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺឧគ្ឃដិតញ្ញូបុគ្គល ១ វិបច្ចិតញ្ញូបុគ្គល ១ នេយ្យបុគ្គល ១ បទបរមបុគ្គល[២] ១ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

---

១. បានដល់បុគ្គលកាលដោះស្រាយប្រស្នា ក៏ដោះស្រាយត្រឹមត្រូវ តែដោះស្រាយមិនរហ័ស គឺនិយាយសន្សឹម ៗ ។ ២ បុគ្គលដែលត្រាស់ដឹងធម៌ឆាប់រហ័សក្នុងវេលាដែលធម្មកថិកបង្ហើបសម្តែងឡើង ហៅថា ឧគ្ឃដិតញ្ញូបុគ្គល ។ បុគ្គលដែលត្រាស់ដឹងធម៌ក្នុងកាលធម្មកថិកបំបែកសេចក្តីឲ្យពិស្តារហៅថា វិបច្ចិតញ្ញូបុគ្គល ។ បុគ្គលលុះតែរៀនសាកសួរធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញាចូលទៅសេពគប់អង្គុយជិតកល្យាណមិត្រ ទើបត្រាស់ដឹងធម៌ដោយលំដាប់ហៅថានេយ្យ-បុគ្គល ។ បុគ្គលដែលស្តាប់ច្រើនក្តីសូត្ររៀនច្រើនក្តី ចងចាំច្រើនក្តី បង្ហាញច្រើនក្តី ក៏មិនត្រាស់ដឹងធម៌ក្នុងជាតិនោះឡើយ ហៅថា បទបរមបុគ្គល ។ អដ្ឋកថា ។

[១៣៤] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឧគ្ឃដិតញ្ញូ វិបចិតញ្ញូ នេយ្យោ បទបរមោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១៣៥] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឧដ្ឋានផលូបជីវី ន កម្មផលូបជីវី កម្មផលូបជីវី ន ឧដ្ឋានផលូបជីវី ឧដ្ឋានផលូបជីវី ចេវ កម្មផលូបជីវី ច នេវ ឧដ្ឋានផលូបជីវី ន កម្មផលូបជីវី ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១៣៦] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ សាវជ្ជោ វជ្ជពហុលោ អប្បវជ្ជោ អនវជ្ជោ ។ កថញ្ច ភិក្ខវេ បុគ្គលោ សាវជ្ជោ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សាវជ្ជេន កាយកម្មេន សមន្នាគតោ ហោតិ សាវជ្ជេន វចីកម្មេន សមន្នាគតោ ហោតិ សាវជ្ជេន មនោកម្មេន សមន្នាគតោ ហោតិ ។

[១៣៤] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្ដេច ។ គឺបុគ្គលចិញ្ចឹមជីវិត ដោយផលនៃការប្រឹងប្រែង មិនចិញ្ចឹមជីវិត ដោយផលនៃបុញ្ញកម្ម[១] ១ ចិញ្ចឹមជីវិតដោយផលនៃបុញ្ញកម្ម មិនចិញ្ចឹមជីវិតដោយផលនៃការប្រឹងប្រែង[២] ១ ចិញ្ចឹមជីវិតដោយផលនៃការប្រឹងប្រែងផង ចិញ្ចឹមជីវិតដោយផលនៃបុញ្ញកម្ម[៣]ផង ១ មិនចិញ្ចឹមជីវិតដោយផលនៃការប្រឹងប្រែង មិនចិញ្ចឹមជីវិតដោយផលនៃបុញ្ញកម្ម[៤] ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

[១៣៥] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្ដេច ។ គឺបុគ្គលប្រកបដោយទោស ១ ច្រើនដោយទោស ១ មានទោសតិច ១ មិនមានទោស ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលប្រកបដោយទោស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយកាយកម្មមានទោស ប្រកបដោយវចីកម្មមានទោស ប្រកបដោយមនោកម្មមានទោស ។

---

១ បានដល់បុគ្គលដែលប្រឹងប្រែងព្យាយាម ទើបបានអ្វីមួយមកចិញ្ចឹមជីវិត ។ ២ បានដល់ពួកទេវតាទាំងអស់ ។ ៣ បានដល់ស្ដេចនិងអាមាត្យធំនៃស្ដេចជាដើម ។ ៤ បានដល់ពួកសត្វនរក ។

៣៤៨

ឯវំ ខោ ភិក្ខវេ បុគ្គលោ សាវជ្ជោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ វជ្ជពហុលោ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សាវជ្ជេន ពហុលំ កាយកម្មេន សមន្នាគតោ ហោតិ អប្បំ អនវជ្ជេន សាវជ្ជេន ពហុលំ វចីកម្មេន សមន្នាគតោ ហោតិ អប្បំ អនវជ្ជេន សាវជ្ជេន ពហុលំ មនោកម្មេន សមន្នា-គតោ ហោតិ អប្បំ អនវជ្ជេន ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ វជ្ជពហុលោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ អប្បវជ្ជោ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អនវជ្ជេន ពហុលំ កាយកម្មេន សមន្នា-គតោ ហោតិ អប្បំ សាវជ្ជេន អនវជ្ជេន ពហុលំ វចីកម្មេន សមន្នាគតោ ហោតិ អប្បំ សាវជ្ជេន អនវជ្ជេន ពហុលំ មនោកម្មេន សមន្នាគតោ ហោតិ អប្បំ សាវជ្ជេន ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ អប្បវជ្ជោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ អនវជ្ជោ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អនវជ្ជេន កាយកម្មេន សមន្នាគតោ ហោតិ អនវជ្ជេន វចីកម្មេន សមន្នាគតោ ហោតិ អនវជ្ជេន មនោកម្មេន សមន្នាគតោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយទោស ២ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលច្រើនដោយទោស តើដូចម្ដេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយកាយកម្មមានទោសច្រើន មិនមានទោសតិច ប្រកបដោយវចីកម្មមានទោសច្រើន មិនមានទោសតិច ប្រកបដោយមនោកម្មមានទោសច្រើន មិនមានទោសតិច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលច្រើនដោយទោសយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុគ្គលមានទោសតិច តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយកាយកម្ម មិនមានទោសច្រើន មានទោសតិច ប្រកបដោយវចីកម្ម មិនមានទោសច្រើន មានទោសតិច ប្រកបដោយមនោកម្មមិនមានទោសច្រើន មានទោសតិច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានទោសតិច យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមិនមានទោស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយកាយកម្ម មិនមានទោស ប្រកបដោយវចីកម្ម មិនមានទោស ប្រកបដោយមនោកម្ម មិនមានទោស ។

ឯវំ ខោ ភិក្ខវេ បុគ្គលោ អនវជ្ជោ ហោតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១៣៦] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សីលេសុ ន បរិបូរការី ហោតិ សមាធិស្មឹ ន បរិបូរការី បញ្ញាយ ន បរិបូរ-ការី ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ សីលេសុ បរិបូរការី ហោតិ សមាធិស្មឹ ន បរិបូរការី បញ្ញាយ ន បរិបូរការី ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ សីលេសុ បរិបូរការី ហោតិ សមាធិស្មឹ បរិបូរការី បញ្ញាយ ន បរិបូរការី ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ សីលេសុ បរិបូរការី ហោតិ សមាធិស្មឹ បរិបូរការី បញ្ញាយ បរិបូរការី ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានទោស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។

[១៣៦] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមិនបំពេញក្នុងសីល មិនបំពេញក្នុងសមាធិ មិនបំពេញក្នុងបញ្ញា ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកបំពេញតែក្នុងសីល មិនបំពេញក្នុងសមាធិ មិនបំពេញក្នុងបញ្ញា ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកបំពេញក្នុងសីល បំពេញក្នុងសមាធិ តែមិនបំពេញក្នុងបញ្ញា ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ បំពេញក្នុងសីល បំពេញក្នុងសមាធិ បំពេញក្នុងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

[១៣៧] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ ន សីលគរុ ហោតិ ន សីលាធិបតេយ្យោ ន សមាធិគរុ ហោតិ ន សមា-ធាធិបតេយ្យោ ន បញ្ញាគរុ ហោតិ ន បញ្ញាធិបតេយ្យោ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ សីលគរុ ហោតិ សីលាធិបតេយ្យោ ន សមាធិគរុ ហោតិ ន សមាធាធិ-បតេយ្យោ ន បញ្ញាគរុ ហោតិ ន បញ្ញាធិបតេយ្យោ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ សីលគរុ ហោតិ សីលាធិបតេយ្យោ សមាធិគរុ ហោតិ សមាធាធិ-បតេយ្យោ ន បញ្ញាគរុ ហោតិ ន បញ្ញាធិបតេយ្យោ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ សីលគរុ ហោតិ សីលាធិបតេយ្យោ សមាធិគរុ ហោតិ សមាធាធិ-បតេយ្យោ បញ្ញាគរុ ហោតិ បញ្ញាធិបតេយ្យោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

តតិយបណ្ណាសក បុគ្គលវគ្គ

[១៣៧] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ មិនគោរពក្នុងសីល មិនយកសីលជាធំ មិនគោរពក្នុងសមាធិ មិនយកសមាធិជាធំ មិនគោរពក្នុងបញ្ញា មិនយកបញ្ញាជាធំ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ គោរពក្នុងសីល យកសីលជាធំ តែមិនគោរពក្នុងសមាធិ មិនយកសមាធិជាធំ មិនគោរពក្នុងបញ្ញា មិនយកបញ្ញាជាធំ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ គោរពក្នុងសីល យកសីលជាធំ គោរពក្នុងសមាធិ យកសមាធិជាធំ តែមិនគោរពក្នុងបញ្ញា មិនយកបញ្ញាជាធំ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ គោរពក្នុងសីល យកសីលជាធំ គោរពក្នុងសមាធិ យកសមាធិជាធំ គោរពក្នុងបញ្ញា យកបញ្ញាជាធំ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

[១៣៨] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ និក្កដ្ឋកាយោ អនិក្កដ្ឋចិត្តោ អនិក្កដ្ឋកាយោ និក្កដ្ឋចិត្តោ អនិក្កដ្ឋកាយោ ច អនិក្កដ្ឋចិត្តោ ច និក្កដ្ឋកាយោ ច និក្កដ្ឋចិត្តោ ច ។ កថញ្ច ភិក្ខវេ បុគ្គលោ និក្កដ្ឋកាយោ ហោតិ អនិក្កដ្ឋចិត្តោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ សោ តត្ថ កាម-វិតក្កំបិ វិតក្កេតិ ព្យាបាទវិតក្កំបិ វិតក្កេតិ វិហឹសា-វិតក្កំបិ វិតក្កេតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ និក្កដ្ឋកាយោ ហោតិ អនិក្កដ្ឋចិត្តោ ។ កថញ្ច ភិក្ខវេ បុគ្គលោ អនិក្កដ្ឋកាយោ ហោតិ និក្កដ្ឋ-ចិត្តោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ន ហេវ ខោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ សោ តត្ថ នេក្ខម្មវិតក្កំបិ វិតក្កេតិ អព្យាបាទ-វិតក្កំបិ វិតក្កេតិ អវិហឹសាវិតក្កំបិ វិតក្កេតិ ។

[១៣៨] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួកតើដូចម្តេច ។ គឺបុគ្គលមានកាយចេញទៅ មានចិត្តមិនចេញទៅ ១ មានកាយមិនចេញទៅ មានចិត្តចេញទៅ ១ មានកាយមិនចេញទៅផង មានចិត្តក៏មិនចេញទៅផង ១ មានកាយចេញទៅផង មានចិត្តចេញទៅផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានកាយចេញទៅ មានចិត្តមិនចេញទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ នៅអាស្រ័យព្រៃតូចឬព្រៃធំ ជាសេនាសនៈដ៏ស្ងាត់ តែបុគ្គលនោះ តែងត្រិះរិះនូវកាមវិតក្កៈក្តី ត្រិះ-រិះនូវព្យាបាទវិតក្កៈក្តី ត្រិះរិះនូវវិហឹសាវិតក្កៈក្តី ក្នុងទីនោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានកាយចេញទៅ តែមានចិត្តមិនចេញទៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានកាយមិនចេញទៅ មានចិត្តចេញទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ មិននៅអាស្រ័យព្រៃតូច ឬព្រៃធំជាសេនាសនៈដ៏ស្ងាត់ទេ តែបុគ្គលនោះ តែងត្រិះរិះនូវនេក្ខម្មវិតក្កៈក្តី ត្រិះរិះនូវអព្យាបាទវិតក្កៈក្តី ត្រិះរិះនូវអវិហឹសាវិតក្កៈក្តី ក្នុងទីនោះ ។

៣៤៩



ឯវំ ខោ ភិក្ខវេ បុគ្គលោ អនិក្ខន្តកាយោ ហោតិ និក្ខន្តចិត្តោ ។ កថញ្ច ភិក្ខវេ បុគ្គលោ អនិក្ខន្តកាយោ ច ហោតិ អនិក្ខន្តចិត្តោ ច ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ន ហេវ ខោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ សោ តត្ថ កាមវិតក្កំបិ វិតក្កេតិ ព្យាបាទវិតក្កំបិ វិតក្កេតិ វិហឹសាវិតក្កំបិ វិតក្កេតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ អនិក្ខន្តកាយោ ច ហោតិ អនិក្ខន្តចិត្តោ ច ។ កថញ្ច ភិក្ខវេ បុគ្គលោ និក្ខន្តកាយោ ច ហោតិ និក្ខន្តចិត្តោ ច ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ សោ តត្ថ នេក្ខម្មវិតក្កំបិ វិតក្កេតិ អព្យាបាទវិតក្កំបិ វិតក្កេតិ អវិហឹសាវិតក្កំបិ វិតក្កេតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ និក្ខន្តកាយោ ច ហោតិ និក្ខន្តចិត្តោ ច ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលមានកាយមិនចេញ តែមានចិត្តចេញទៅយ៉ាង នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានកាយមិនចេញទៅផង មានចិត្តក៏មិនចេញទៅផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ មិននៅអាស្រ័យព្រៃតូចឬព្រៃធំជាសេនាសនៈ ដ៏ស្ងាត់ទេ បុគ្គលនោះ ថែមទាំងត្រិះរិះនូវកាមវិតក្កៈក្តី ត្រិះរិះនូវព្យាបាទវិតក្កៈក្តី ត្រិះរិះនូវវិហឹសាវិតក្កៈក្តី ក្នុងទីនោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានកាយមិនចេញទៅផង មានចិត្តក៏មិនចេញទៅផង យ៉ាងនេះ ឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គល មានកាយចេញទៅផង មានចិត្តក៏ចេញទៅផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ នៅអាស្រ័យព្រៃតូច ឬព្រៃធំ ជាសេនាសនៈដ៏ស្ងាត់ បុគ្គលនោះ ថែមទាំងត្រិះរិះនូវនេក្ខម្មវិតក្កៈក្តី ត្រិះរិះនូវអព្យាបាទវិតក្កៈក្តី ត្រិះរិះនូវអវិហឹសាវិតក្កៈក្តី ក្នុងទីនោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល មានកាយចេញទៅផង មានចិត្តក៏ចេញទៅផង យ៉ាងនេះឯង ។ ម្នាល ភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

[១៣៩] ចត្តារោមេ ភិក្ខវេ ធម្មកថិកា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចោ ធម្មកថិកោ អប្បញ្ច ភាសតិ អសហិតញ្ច បរិសា ច ន កុសលា ហោតិ សហិតាសហិតស្ស ។ ឯវរូបោ ភិក្ខវេ ធម្មកថិកោ ឯវរូបាយ បរិសាយ ធម្មកថិកោត្វេវ សង្ខំ គច្ឆតិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ ធម្មកថិកោ អប្បញ្ច ភាសតិ សហិតញ្ច បរិសា ច កុសលា ហោតិ សហិតាសហិតស្ស ។ ឯវរូបោ ភិក្ខវេ ធម្មកថិកោ ឯវរូបាយ បរិសាយ ធម្មកថិកោត្វេវ សង្ខំ គច្ឆតិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ ធម្មកថិកោ ពហុញ្ច ភាសតិ អសហិតញ្ច បរិសា ច ន កុសលា ហោតិ សហិតាសហិតស្ស ។

[១៣៩] ម្នាលភិក្ខុទាំងឡាយ ធម្មកថិក (អ្នកសម្ដែងធម៌) នេះ មាន ៤ ពួក ។ ធម្មកថិកទាំង ៤ ពួក តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិកខ្លះ ក្នុងសាសនានេះ សម្ដែងធម៌តិចផង មិនប្រកបដោយប្រយោជន៍ផង ទាំងបរិសទ្យ ក៏ជាអ្នក មិនឈ្លាសវៃ ចំពោះធម៌ដែលប្រកបដោយប្រយោជន៍ និងធម៌ដែលមិនប្រកបដោយប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិក មានសភាពយ៉ាងនេះ រមែងដល់នូវការរាប់ថាជាធម្មកថិក របស់បរិសទ្យ មានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ធម្មកថិកខ្លះ ក្នុងសាសនានេះ សម្ដែងធម៌តិចផង ប្រកបដោយប្រយោជន៍ផង ទាំងបរិសទ្យក៏ជាអ្នកឈ្លាសវៃ ចំពោះធម៌ដែលប្រកបដោយប្រយោជន៍ និងធម៌ដែលមិនប្រកបដោយប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិកមានសភាពយ៉ាងនេះ រមែងដល់នូវការរាប់ថាជាធម្មកថិក របស់បរិសទ្យមានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ធម្មកថិកខ្លះ ក្នុងសាសនានេះ សម្ដែងធម៌ច្រើនផង មិនប្រកបដោយប្រយោជន៍ផង ទាំងបរិសទ្យក៏ជាអ្នកមិនឈ្លាសវៃ ចំពោះធម៌ដែលប្រកបដោយប្រយោជន៍ និងធម៌ដែលមិនប្រកបដោយប្រយោជន៍ ។

ឯវរូបោ ភិក្ខវេ ធម្មកថិកោ ឯវរូបាយ បរិសាយ ធម្មកថិកោត្វេវ សង្ខំ គច្ឆតិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ ធម្មកថិកោ ពហុញ្ច ភាសតិ សហិតញ្ច បរិសា ច កុសលា ហោតិ សហិ-តាសហិតស្ស ។ ឯវរូបោ ភិក្ខវេ ធម្មកថិកោ ឯវរូបាយ បរិសាយ ធម្មកថិកោត្វេវ សង្ខំ គច្ឆតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ធម្មកថិកាតិ ។

[១៤០] ចត្តារោមេ ភិក្ខវេ វាទី ។ កតមេ ចត្តារោ ។ អត្ថិ ភិក្ខវេ វាទី អត្ថតោ បរិយាទានំ គច្ឆតិ នោ ព្យញ្ជនតោ អត្ថិ ភិក្ខវេ វាទី ព្យញ្ជនតោ បរិយាទានំ គច្ឆតិ នោ អត្ថតោ អត្ថិ ភិក្ខវេ វាទី អត្ថតោ ច ព្យញ្ជនតោ ច បរិយាទានំ គច្ឆតិ អត្ថិ ភិក្ខវេ វាទី នេវ អត្ថតោ នោ ព្យញ្ជនតោ បរិយា-ទានំ គច្ឆតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ វាទី ។

ម្នាលភិក្ខុទាំងឡាយ ធម្មកថិកមានសភាពយ៉ាងនេះ រមែងដល់នូវការរាប់ថាជាធម្មកថិក របស់បរិសទ្យមានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ធម្មកថិកខ្លះ ក្នុងសាសនានេះ សម្តែងធម៌ច្រើនផង ប្រកបដោយប្រយោជន៍ផង ទាំងបរិសទ្យក៏ជាអ្នកឈ្លាសវៃ ចំពោះធម៌ដែលប្រកបដោយប្រយោជន៍ និងធម៌ដែលមិនប្រកបដោយប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិកមានសភាពយ៉ាងនេះ រមែងដល់នូវការរាប់ថាជាធម្មកថិក របស់បរិសទ្យមានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំង-ឡាយ ធម្មកថិក ៤ ពួកនេះឯង ។

[១៤០] ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលនេះមាន ៤ ពួក ។ បុគ្គលអ្នកពោល ៤ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលតែងដល់នូវការអស់ទៅដោយអត្ថ គឺអដ្ឋកថា មិនអស់ទៅដោយព្យញ្ជនៈ គឺបាឡីក៏មាន ១[១] ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលតែងដល់នូវការអស់ទៅដោយព្យញ្ជនៈ មិនអស់ទៅដោយអត្ថក៏មាន ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលតែងដល់នូវការអស់ទៅដោយអត្ថផងដោយព្យញ្ជនៈផងក៏មាន ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលមិនដល់នូវការអស់ទៅដោយអត្ថ ទាំងមិនដល់នូវការអស់ទៅដោយព្យញ្ជនៈក៏មាន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលមាន ៤ ពួកនេះឯង ។

---

១ បានសេចក្តីថា កាលបើគេសួរអដ្ឋកថា ក៏សម្តែងមិនរួច តែបើគេសួរតាមព្យញ្ជនៈ អាចសម្តែងបាន ។ អដ្ឋកថា ។

អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ចតូហិ បដិសម្ភិទាហិ សមន្នាគតោ ភិក្ខុ អត្ថតោ វា ព្យញ្ជនតោ វា បរិយាទានំ គច្ឆេយ្យាតិ ។

បុគ្គលវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ[១]

សំយោជនំ បដិភាណោ
ឧគ្ឃដិតញ្ញូ ឧដ្ឋាន-
សាវជ្ជោ ទ្វេ ច សីលានិ
និក្ខន្តធម្មារាមា ចាតិ ។

១ មរម្មបោត្ថកេ យេវ អត្ថិ ។

ម្នាលភិក្ខុទាំងឡាយ ការណ៍នុ៎ះ គ្មានហេតុ គ្មានបច្ច័យដែលនាំឲ្យភិក្ខុប្រកបដោយបដិសម្ភិទាទាំង ៤ ដល់នូវការអស់ទៅដោយអត្ថ ដោយព្យញ្ជនៈ ឡើយ ។

ចប់ បុគ្គលវគ្គ ទី ៥ ។

## ឧទ្ទាននៃបុគ្គលវគ្គនោះគឺ[១]

និយាយអំពីសំយោជនៈ ១ អំពីបុគ្គលមានប្រាជ្ញា ១ អំពីឧគ្ឃដិតញ្ញូបុគ្គល ១ អំពីបុគ្គលចិញ្ចឹមជីវិតដោយផលនៃព្យាយាម ១ អំពីបុគ្គលប្រកបដោយទោស ១ អំពីសីលមាន ២ លើក ១ អំពីបុគ្គលមានកាយចេញទៅមានចិត្តមិនចេញទៅ ១ អំពីធម្មកថិក ១ អំពីបុគ្គលអ្នកពោល ១ ។

១ ឧទ្ទាននេះមានតែក្នុងគម្ពីរអក្សរភូមា ។

# អាភាវគ្គោ

[១៤១] ចតស្សោ ឥមា ភិក្ខវេ អាភា ។ កតមា ចតស្សោ ។ ចន្ទាភា សុរិយាភា អគ្គាភា បញ្ញាភា ។ ឥមា ខោ ភិក្ខវេ ចតស្សោ អាភា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ចតស្សន្នំ អាភានំ យទិទំ បញ្ញាភាតិ ។

[១៤២] ចតស្សោ ឥមា ភិក្ខវេ បភា ។ កតមា ចតស្សោ ។ ចន្ទប្បភា សុរិយប្បភា អគ្គិប្បភា បញ្ញាបភា ។ ឥមា ខោ ភិក្ខវេ ចតស្សោ បភា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ចតស្សន្នំ បភានំ យទិទំ បញ្ញាបភាតិ ។

[១៤៣] ចត្តារោមេ ភិក្ខវេ អាលោកា ។ កតមេ ចត្តារោ ។ ចន្ទាលោកោ សុរិយាលោកោ អគ្គាលោកោ បញ្ញាលោកោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អាលោកា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ចតុន្នំ អាលោកានំ យទិទំ បញ្ញាលោកោតិ ។

# អាភាវគ្គ

[១៨១] ម្នាលភិក្ខុទាំងឡាយ ពន្លឺនេះមាន ៤ យ៉ាង ។ ពន្លឺ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺពន្លឺព្រះចន្ទ្រ ១ ពន្លឺព្រះអាទិត្យ ១ ពន្លឺភ្លើង ១ ពន្លឺប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺ ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ បណ្តាពន្លឺទាំង ៤ នេះ ពន្លឺដែលប្រសើរន៉ុះ គឺពន្លឺប្រាជ្ញា ។

[១៨២] ម្នាលភិក្ខុទាំងឡាយ រស្មីនេះមាន ៤ យ៉ាង ។ រស្មី ៤ យ៉ាងតើដូចម្តេចខ្លះ ។ គឺរស្មីព្រះចន្ទ្រ ១ រស្មីព្រះអាទិត្យ ១ រស្មីភ្លើង ១ រស្មីប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្តារស្មីទាំង ៤ នេះ រស្មីដែលប្រសើរន៉ុះ គឺរស្មីប្រាជ្ញា ។

[១៨៣] ម្នាលភិក្ខុទាំងឡាយ សេចក្តីរុងរឿងនេះមាន ៤ យ៉ាង ។ សេចក្តីរុងរឿង ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺសេចក្តីរុងរឿងនៃព្រះចន្ទ្រ ១ សេចក្តីរុងរឿងនៃព្រះអាទិត្យ ១ សេចក្តីរុងរឿងនៃភ្លើង ១ សេចក្តីរុងរឿងនៃប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរុងរឿង ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីរុងរឿងទាំង ៤ នេះ សេចក្តីរុងរឿងដែលប្រសើរន៉ុះ គឺសេចក្តីរុងរឿងនៃប្រាជ្ញា ។

[១៤៤] ចត្តារោមេ ភិក្ខវេ ឱភាសា ។ កតមេ ចត្តារោ ។ ចន្ទាភាសោ សុរិយោភាសោ អគ្គោភាសោ បញ្ញោភាសោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ឱភាសា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ចតុន្នំ ឱភាសានំ យទិទំ បញ្ញោភាសោតិ ។

[១៤៥] ចត្តារោមេ ភិក្ខវេ បជ្ជោតា ។ កតមេ ចត្តារោ ។ ចន្ទប្បជ្ជោតោ សុរិយប្បជ្ជោតោ អគ្គិប្បជ្ជោតោ បញ្ញាបជ្ជោតោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បជ្ជោតា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ចតុន្នំ បជ្ជោតានំ យទិទំ បញ្ញាបជ្ជោតោតិ ។

[១៤៦] ចត្តារោមេ ភិក្ខវេ កាលា ។ កតមេ ចត្តារោ ។ កាលេន ធម្មស្សវនំ[១] កាលេន ធម្មសាកច្ឆា កាលេន សមថោ កាលេន វិបស្សនា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ កាលាតិ ។

---

១ ម. ធម្មសវនា ។

[១៤៤] ម្នាលភិក្ខុទាំងឡាយ រស្មីរុងរឿងនេះ មាន ៤ យ៉ាង ។ រស្មីរុងរឿង ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺរស្មីរុងរឿងនៃព្រះចន្ទ្រ ១ រស្មីរុងរឿងនៃព្រះអាទិត្យ ១ រស្មីរុងរឿងនៃភ្លើង ១ រស្មីរុងរឿងនៃប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ រស្មីរុងរឿង ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ បណ្តារស្មីរុងរឿងទាំង ៤ នេះ រស្មីរុងរឿងដែលប្រសើរទុំះ គឺរស្មីរុងរឿងនៃប្រាជ្ញា ។

[១៤៥] ម្នាលភិក្ខុទាំងឡាយ ពន្លឺរស្មីនេះ មាន ៤ យ៉ាង ។ ពន្លឺរស្មី ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺពន្លឺរស្មីព្រះចន្ទ្រ ១ ពន្លឺរស្មីព្រះអាទិត្យ ១ ពន្លឺរស្មីភ្លើង ១ ពន្លឺរស្មីប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺរស្មី ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាពន្លឺរស្មីទាំង ៤ យ៉ាងនេះ ពន្លឺរស្មីដែលប្រសើរទុំះ គឺពន្លឺរស្មីប្រាជ្ញា ។

[១៤៦] ម្នាលភិក្ខុទាំងឡាយ កាល (នៃកុសលធម៌) នេះមាន ៤ យ៉ាង ។ កាល ៤ យ៉ាង តើដូចម្តេច ។ គឺការស្តាប់ធម៌តាមកាល ១ សាកច្ឆាធម៌តាមកាល ១ ការចម្រើនសមថៈតាមកាល ១ ការចម្រើនវិបស្សនាតាមកាល ១ ។ ម្នាលភិក្ខុទាំងឡាយ កាល (នៃកុសលធម៌) ៤ យ៉ាងនេះឯង ។

[១៤៧] ចត្តារោមេ ភិក្ខវេ កាលា សម្មាភាវិយមានា សម្មាអនុបរិវត្តិយមានា អនុបុព្វេន អាសវានំ ខយំ បាបេន្តិ ។ កតមេ ចត្តារោ ។ កាលេន ធម្មស្សវនំ កាលេន ធម្មសាកច្ឆា កាលេន សមថោ កាលេន វិបស្សនា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ កាលា សម្មាភាវិយមានា សម្មាអនុបរិវត្តិយមានា អនុបុព្វេន អាសវានំ ខយំ បាបេន្តិ សេយ្យថាបិ ភិក្ខវេ ឧបរិបព្វតេ ថុល្លផុសិតកេ ទេវេ វស្សន្តេ(១) ឧទកំ យថានិន្នំ បវត្តមានំ បព្វតកន្ទរបទរសាខា បរិបូរេតិ បព្វតកន្ទរបទរសាខា បរិបូរា កុសោព្ភេ បរិបូរេន្តិ កុសោព្ភា បរិបូរា មហាសោព្ភេ បរិបូរេន្តិ មហាសោព្ភា បរិបូរា កុន្នទិយោ បរិបូរេន្តិ កុន្នទិយោ បរិបូរា មហានទិយោ បរិបូរេន្តិ មហានទិយោ បរិបូរា សមុទ្ទសាគរំ បរិបូរេន្តិ ឯវមេវ ខោ ភិក្ខវេ ឥមេ ចត្តារោ កាលា សម្មាភាវិយមានា សម្មាអនុបរិវត្តិយមានា អនុបុព្វេន អាសវានំ ខយំ បាបេន្តីតិ ។

១ ឱ. ម. ឯត្តន្តរេ តំសទ្ទោ ទិស្សតិ ។

[១៤៧] ម្នាលភិក្ខុទាំងឡាយ កាល (នៃកុសលធម៌) ៤ យ៉ាងនេះ កាលបើបុគ្គលចម្រើនដោយប្រពៃ ឲ្យប្រព្រឹត្តទៅដោយប្រពៃ រមែងឲ្យដល់នូវការអស់ទៅនៃអាសវៈ ដោយលំដាប់ ។ កាល ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺការស្តាប់ធម៌តាមកាល ១ សាកច្ឆាធម៌តាមកាល ១ ការចម្រើនសមថៈតាមកាល ១ ការចម្រើនវិបស្សនាតាមកាល ១ ។ ម្នាលភិក្ខុទាំងឡាយ កាល ៤ យ៉ាងនេះឯង កាលបើបុគ្គលចម្រើនដោយប្រពៃ ឲ្យប្រព្រឹត្តទៅដោយប្រពៃ រមែងឲ្យដល់នូវការអស់ទៅនៃអាសវៈ ដោយលំដាប់ ម្នាលភិក្ខុទាំងឡាយ ភ្លៀងមានតំណក់ដ៏ថ្លោសធ្លាក់ចុះលើកំពូលភ្នំ ទឹកកាលហូរទៅកាន់ទំនាប រមែងញ៉ាំងជ្រោះ អូរនិងប្រឡាយភ្នំឲ្យពេញ លុះជ្រោះអូរនិងប្រឡាយភ្នំពេញហើយ រមែងញ៉ាំងបាពយណ៍[១]តូចឲ្យពេញ លុះបាពយណ៍តូចពេញហើយ រមែងញ៉ាំងបាពយណ៍ធំឲ្យពេញ លុះបាពយណ៍ធំពេញហើយ រមែងញ៉ាំងស្ទឹងតូចឲ្យពេញ លុះស្ទឹងតូចពេញហើយ រមែងញ៉ាំងស្ទឹងធំឲ្យពេញ លុះស្ទឹងធំពេញហើយ រមែងញ៉ាំងសមុទ្រសាគរឲ្យពេញ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ កាលទាំង ៤ យ៉ាងនេះ បើបុគ្គលចម្រើនដោយប្រពៃ ឲ្យប្រព្រឹត្តទៅដោយប្រពៃ រមែងឲ្យដល់នូវការអស់ទៅនៃអាសវៈ ដោយលំដាប់ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

១ បឹងតូច ។

[១៤៨] ចត្តារីមានិ ភិក្ខវេ វចីទុច្ចរិតានិ ។ កតមានិ ចត្តារិ ។ មុសាវាទោ បិសុណា វាចា ផរុសា វាចា សម្ផប្បលាបោ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ វចីទុច្ចរិតានីតិ ។

[១៤៩] ចត្តារីមានិ ភិក្ខវេ វចីសុចរិតានិ ។ កតមានិ ចត្តារិ ។ សច្ចវាចា អបិសុណាវាចា សណ្ហាវាចា មន្តាភាសា ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ វចីសុចរិតានីតិ ។

[១៥០] ចត្តារោមេ ភិក្ខវេ សារា ។ កតមេ ចត្តារោ ។ សីលសារោ សមាធិសារោ បញ្ញាសារោ វិមុត្តិសារោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ សារាតិ ។

អាភាវគ្គោ បញ្ចមោ ។

តតិយោ បណ្ណាសកោ និដ្ឋិតោ ។

[១៤៨] ម្នាលភិក្ខុទាំងឡាយ វចីទុច្ចរិតនេះមាន ៤ យ៉ាង ។ វចីទុច្ចរិត ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺការនិយាយកុហក ១ ការនិយាយញុះញង់ ១ ការនិយាយពាក្យទ្រគោះ ១ ការនិយាយពាក្យរោយរាយ ១ ។ ម្នាលភិក្ខុទាំងឡាយ វចីទុច្ចរិត ៤ យ៉ាងនេះឯង ។

[១៤៩] ម្នាលភិក្ខុទាំងឡាយ វចីសុចរិតនេះ មាន ៤ យ៉ាង ។ វចីសុចរិត ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺនិយាយពាក្យសត្យ ១ មិននិយាយពាក្យញុះញង់ ១ និយាយពាក្យពីរោះពិសា ១ និយាយតែពាក្យដែលប្រកបដោយប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ វចីសុចរិត ៤ យ៉ាងនេះឯង ។

[១៥០] ម្នាលភិក្ខុទាំងឡាយ សារៈ (ខ្លឹម) នេះមាន ៤ យ៉ាង ។ សារៈ ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺសីលសារៈ ១ សមាធិសារៈ ១ បញ្ញាសារៈ ១ វិមុត្តិសារៈ ១ ។ ម្នាលភិក្ខុទាំងឡាយ សារៈ ៤ យ៉ាងនេះឯង ។

ចប់ អាភាវគ្គ ទី ៥ ។

ចប់ បណ្ណាសក ទី ៣ ។

៣៤៧

តតិយបណ្ណាសកេ អាភាវគ្គោ

# តស្សុទ្ទានំ[១]

អាភា បភា ច អាលោកា
ឱភា បជ្ជោតា ទ្វេ កាលា
ទ្វេ ចរិតា ច សីលាតា
ហោន្តិ តេ ទស វគ្គេ ចាតិ ។

---

១ មរម្មបោត្ថកេយេវ អត្ថិ ។

តតិយបណ្ណាសក អាភាវគ្គ

## ឧទ្ទាននៃអាភាវគ្គនោះគឺ[១]

និយាយអំពីពន្លឺ ១ អំពីរស្មី ១ អំពីសេចក្ដីរុងរឿង ១ អំពីរស្មីរុងរឿង ១ អំពីពន្លឺរស្មី ១ អំពីកាលមាន ២ លើក អំពីចរិតមាន ២ លើក អំពីសីលសារៈ ១ ត្រូវជា ១០ ក្នុងវគ្គនេះ ។

---

១ ឧទ្ទាននេះ មានក្នុងគម្ពីរអក្សរភូមាតែម្យ៉ាង ។

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស ចតុក្កនិបាតោ

# តតិយោ ភាគោ

មាតិកា　　　　　　　　　　　　　　　　អង្កេ

## បឋមបណ្ណាសកោ


| | | | |
|---|---|---|---|
| បឋមបណ្ណាសកេ | ភណ្ឌគ្គាមវគ្គោ | បឋមោ............................ | ១ |
| | ចរវគ្គោ | ទុតិយោ ........................... | ៣១ |
| | ឧរុវេលវគ្គោ | តតិយោ ........................... | ៤៩ |
| | ចក្កវគ្គោ | ចតុត្ថោ............................. | ៧៩ |
| | រោហិតស្សវគ្គោ | បញ្ចមោ ........................... | ១០៧ |


## ទុតិយបណ្ណាសកោ


| | | | |
|---|---|---|---|
| ទុតិយបណ្ណាសកេ | បុញ្ញាភិសន្ទវគ្គោ | បឋមោ............................. | ១៣៣ |
| | បត្តកម្មវគ្គោ | ទុតិយោ ........................... | ១៦១ |
| | អបណ្ណកវគ្គោ | តតិយោ ........................... | ១៨៩ |
| | មចលវគ្គោ | ចតុត្ថោ............................. | ២០៦ |

# សុត្តន្តបិដក

# អង្គុត្តរនិកាយ ចតុក្កនិបាត

# តតិយភាគ

## មាតិកា លេខទំព័រ

## បឋមបណ្ណាសក


| | | | |
|---|---|---|---|
| *បឋមបណ្ណាសក* | *ភណ្ឌគ្គាមវគ្គ* | *ទី ១* ................................ | *១* |
| | *ចរវគ្គ* | *ទី ២* ................................ | *៣១* |
| | *ឧរុវេលវគ្គ* | *ទី ៣* ................................ | *៤៩* |
| | *ចក្កវគ្គ* | *ទី ៤* ................................ | *៧៩* |
| | *រោហិតស្សវគ្គ* | *ទី ៥* ................................ | *១០៧* |


## ទុតិយបណ្ណាសក


| | | | |
|---|---|---|---|
| *ទុតិយបណ្ណាសក* | *បុញ្ញាភិសន្ទវគ្គ* | *ទី ១* ................................ | *១៣៣* |
| | *បត្តកម្មវគ្គ* | *ទី ២* ................................ | *១៦១* |
| | *អបណ្ណកវគ្គ* | *ទី ៣* ................................ | *១៨៩* |
| | *មចលវគ្គ* | *ទី ៤* ................................ | *២០៦* |

# មាតិកាបត្តានិ

## មាតិកា អង្កេ

*ទុតិយបណ្ណាសកេ អសុរវគ្គោ បញ្ចមោ ............................ ២២៧*

## តតិយបណ្ណាសកោ

*តតិយបណ្ណាសកេ វលាហកវគ្គោ បឋមោ .............................. ២៥៤*

*កេសីវគ្គោ ទុតិយោ ............................ ២៨២*

*ភយវគ្គោ តតិយោ ............................ ៣០៥*

*បុគ្គលវគ្គោ ចតុត្ថោ .............................. ៣៤០*

*អាភាវគ្គោ បញ្ចមោ ............................ ៣៥៣*

# សន្លឹកចង្អុលប្រាប់មាតិកា

## មាតិកា លេខទំព័រ

*ទុតិយបណ្ណាសក អសុរវគ្គ ទី ៥ ................................ ២២៧*

## តតិយបណ្ណាសក

*តតិយបណ្ណាសក វលាហកវគ្គ ទី ១ ................................ ២៥៤*

*កេសីវគ្គ ទី ២ ................................ ២៨២*

*ភយវគ្គ ទី ៣ ................................ ៣០៥*

*បុគ្គលវគ្គ ទី ៤ ................................ ៣៤០*

*អាភាវគ្គ ទី ៥ ................................ ៣៥៣*

# រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

# គណៈកម្មការពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាជំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅព្រះត្រៃបិដកបាលី និងសេចក្តីប្រែជាភាសាខ្មែរ ដែលជាស្នាដៃ របស់លោកអ្នកប្រាជ្ញជំនាន់មុន គឺអាស្រ័យដោយការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ដោយកុសលផលបុណ្យទាំងអម្បាលមាណ ដែលកើតអំពីធម្មទាននេះ
សូមឲ្យព្រះពុទ្ធសាសនាផ្សាយទៅគ្រប់ទិសទីទូទាំងសកលលោក
សូមឲ្យសព្វសត្វទាំងឡាយទាំងពួងបាននូវសេចក្តីសុខសួស្តី
សូមឲ្យមនុស្សគ្រប់ជាតិសាសន៍មានភាតរភាពនឹងគ្នា
សូមឲ្យពិភពលោកទាំងមូលមានសុខសន្តិភាព ។

MAHA PANNA VIHARA FOUNDATION ORGANIZATION

大般若寺基金會

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ
វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៩២៩, (៨៥៥) ៩៧ ៥១១ ៦៧៨៨
អ៊ីមែល: maha.panna@gmail.com
គេហទំព័រ: http://www.mahapanna.org